# សេចក្តីពន្យល់ អំពី ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ភាគ ១ នីតិវិធីចេញសាលក្រម

## (គន្ថីទី ១ ដល់ គន្ថីទី ៥, គន្ថីទី ៨ និង ទី ៩)


**គន្ថីទី ១ នីតិវិធីរដ្ឋប្បវេណី** . . . . . ១

**ជំពូកទី ១ អត្ថន័យនៃនីតិវិធីរដ្ឋប្បវេណី** . . . . . ១

កថាភាគទី ១ របបរឿងក្តីរដ្ឋប្បវេណី . . . . . ១

១. ជីវភាពរស់នៅក្នុងសង្គម និង ស្វ័យភាពរបស់ឯកជន . . . . . ១

២. វិវាទក្នុងជីវភាពរស់នៅក្នុងសង្គម និង ការដោះស្រាយវិវាទនោះដោយខ្លួនឯង . . . . . ២

៣. ការដោះស្រាយវិវាទដោយបង្ខំ --- ប្រពន្ធ័នីតិវិធីរដ្ឋប្បវេណី . . . . . ៣

កថាភាគទី ២ គោលបំណងនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី . . . . . ៤

កថាភាគទី ៣ គោលការណ៍មូលដ្ឋានសំខាន់ៗនៅក្នុងនីតិវិធីរដ្ឋប្បវេណី . . . . . ៥

១. គោលការណ៍មូលដ្ឋាននៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ . . . . . ៥

២. ការធានានូវសិទ្ធិទាមទារសវនាការ . . . . . ៦

៣. គោលការណ៍ចំពោះមុខ . . . . . ៧

៤. ការទទួលខុសត្រូវរបស់តុលាការ និង ភាគី . . . . . ៧

៥. ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ . . . . . ៧

៦. ការចូលរួមរបស់តំណាងអយ្យការ . . . . . ៨

៧. គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្តី . . . . . ៨

**ជំពូកទី ២ កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី** . . . . . ៩

កថាភាគទី ១ កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យជាទម្រង់ និង កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី ក្នុងន័យជាសារធាតុ . . . . . ៩

កថាភាគទី ២ នីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី . . . . . ១០

១. គោលការណ៍នៃការជម្រះក្តីដោយផ្អែកតាមច្បាប់នីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី . . . . . ១០

២. មុខងារនៃនីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងនីតិវិធីរដ្ឋប្បវេណី . . . . . ១០

កថាភាគទី ៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា . . . . . ១១

**គន្ថីទី ២ ប្រធាននៃបណ្តឹង** . . . . . ១៣

**ជំពូកទី ១ តុលាការ** . . . . . ១៣

កថាភាគទី ១ សិទ្ធិជម្រះក្តី និង សមត្ថកិច្ច . . . . . ១៣

១. សិទ្ធិជម្រះក្តី . . . . . ១៣

២. សមត្ថកិច្ចសាលាជំនុំជម្រះ . . . . . ១៣

កថាភាគទី ២ ប្រភេទនៃសមត្ថកិច្ចរបស់តុលាការ . . . . . ១៣

១. សមត្ថកិច្ចតាមភារកិច្ច . . . . . ១៤

២. សមត្ថកិច្ចតាមដែនដី . . . . . ១៤

៣. សមត្ថកិច្ចដែលត្រូវបានកំណត់ដោយតុលាការថ្នាក់លើ ១៦
៤. សមត្ថកិច្ចផ្តាច់មុខ និង សមត្ថកិច្ចមិនផ្តាច់មុខ ១៧
៥. សមត្ថកិច្ចតាមការព្រមព្រៀង និង សមត្ថកិច្ចដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ ១៧
៦. ការស្រាវជ្រាវអំពីសមត្ថកិច្ច និង អានុភាពនៃការខុសសមត្ថកិច្ច ១៨
កថាភាគទី ៣ ការចាត់តាំងតុលាការ ១៩
១. តុលាការក្នុងនាមជាស្ថាប័នរដ្ឋ និង តុលាការក្នុងនាមជាអង្គភាពជម្រះក្តី ១៩
២. ការជម្រះក្តីដោយចៅក្រមម្នាក់ និង ការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ១៩
កថាភាគទី ៤ ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជិត ចិត្តចៅក្រម ជាអាទិ៍ ២០
១. ការបែងចែករឿងក្តី ២០
២. ការដកហូតសមត្ថកិច្ចជំនុំជម្រះ ការប្តឹងជិតចិត្ត ការដកខ្លួនរបស់ចៅក្រម ២១
**ជំពូកទី ២ ភាគី និង អ្នកតំណាង** ២២
កថាភាគទី ១ ភាគី ២២
១. អត្ថន័យនៃភាគី ២២
២. សមត្ថភាពភាគី ២៣
៣. សមត្ថភាពក្នុងការធ្វើបណ្តឹង ២៤
កថាភាគទី ២ អ្នកតំណាងតាមផ្លូវបណ្តឹង ២៨
១. អត្ថន័យនៃអ្នកតំណាងតាមផ្លូវបណ្តឹង ២៨
២. អ្នកតំណាងដែលច្បាប់បានកំណត់ ៣០
៣. អ្នកតំណាងដោយអាណត្តិ ៣១
៤. អ្នកជំនួយ ៣៤
**គន្ថីទី ៣ នីតិវិធីបណ្តឹងនៃការជំនុំជម្រះលើកទីមួយ** ៣៥
**ជំពូកទី ១ ការចាប់ផ្តើមបណ្តឹង** ៣៥
**ផ្នែកទី ១ ការដាក់ពាក្យបណ្តឹង** ៣៥
កថាភាគទី ១ របៀបដាក់ពាក្យបណ្តឹង ៣៥
កថាភាគទី ២ ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ៣៥
១. ចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់ ( មាត្រា ៧៥ កថាខណ្ឌទី ២) ៣៥
២. ចំណុចដែលត្រូវសរសេរ ក្រៅពីនេះ ( មាត្រា ៧៥ កថាខណ្ឌទី ៣ និង ទី ៤) ៤០
**ផ្នែកទី ២ បណ្តឹង និង ការទាមទារតាមផ្លូវបណ្តឹង** ៤១
កថាភាគទី ១ អត្ថន័យនៃបណ្តឹង ៤១
កថាភាគទី ២ ការទាមទារតាមផ្លូវបណ្តឹង និង កម្មវត្ថុនៃបណ្តឹង ៤២
១. អត្ថន័យនៃការទាមទារតាមផ្លូវបណ្តឹង ៤៣
២. ភាពតែមួយនៃការទាមទារតាមផ្លូវបណ្តឹង ៤៣
៣. គំនិតផ្ទុយគ្នា ស្តីពីភាពតែមួយនៃការទាមទារតាមផ្លូវបណ្តឹង ៤៤
**ផ្នែកទី ៣ ប្រភេទនៃបណ្តឹង** ៤៥
កថាភាគទី ១ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ៤៥

១. អត្ថន័យនៃបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក . . . . . . . . . . . . . . . . ៤៥
២. បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាបច្ចុប្បន្ន និង បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកនាពេលអនាគត . . ៤៦
៣. សាលក្រមនៃបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក . . . . . . . . . . . . . . . ៤៦
កថាភាគទី ២ បណ្ដឹងទាមទារឱ្យបញ្ជាក់ . . . . . . . . . . . . . . . . . . ៤៧
១. អត្ថន័យនៃបណ្ដឹងទាមទារឱ្យបញ្ជាក់ . . . . . . . . . . . . . . . . . . ៤៧
២. កម្មវត្ថុនៃបណ្ដឹងទាមទារឱ្យបញ្ជាក់ . . . . . . . . . . . . . . . . . . ៤៧
៣. សាលក្រមនៃបណ្ដឹងទាមទារឱ្យបញ្ជាក់ . . . . . . . . . . . . . . . . . . ៤៩
កថាភាគទី ៣ បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត . . . . . . . . ៥០
១. អត្ថន័យនៃបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត . . . . . . . . ៥០
២. កម្មវត្ថុនៃបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត (ការទាមទារតាមផ្លូវបណ្ដឹង) . ៥២
៣. សាលក្រមនៃបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត . . . . . . . ៥២
**ផ្នែកទី ៤ ការកំណត់នូវការទាមទារតាមផ្លូវបណ្ដឹង** . . . . . . . . . . . . ៥៣
កថាភាគទី ១ ភាពចាំបាច់នូវការកំណត់នូវការទាមទារ . . . . . . . . . . . . . ៥៣
កថាភាគទី ២ វិធីបញ្ជាក់នូវការទាមទារ . . . . . . . . . . . . . . . . . ៥៤
១. ការកំណត់ភាគី . . . . . . . . . . . . . . . . . . . . . . . . . ៥៤
២. ការកំណត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានអះអាង . . . . . . . . . . . ៥៤
៣. ការទាមទារមួយភាគ . . . . . . . . . . . . . . . . . . . . . . . ៥៧
៤. បែបផែនខុសគ្នានៃការទាមទារ . . . . . . . . . . . . . . . . . . . . ៥៩
**ផ្នែកទី ៥ ការទទួលពាក្យបណ្ដឹង និង អានុភាពនៃការដាក់ពាក្យបណ្ដឹង** . . . . . . . ៥៩
កថាភាគទី ១ ការចាត់ចែងពាក្យបណ្ដឹង . . . . . . . . . . . . . . . . . . ៥៩
១. ការទទួលពាក្យបណ្ដឹង . . . . . . . . . . . . . . . . . . . . . . . ៥៩
២. ការពិនិត្យពាក្យបណ្ដឹង . . . . . . . . . . . . . . . . . . . . . . . ៦០
៣. ការបញ្ជូនពាក្យបណ្ដឹង . . . . . . . . . . . . . . . . . . . . . . . ៦០
៤. ការកំណត់កាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការកោះហៅភាគី ៦១
កថាភាគទី ២ អានុភាពនៃការដាក់បណ្ដឹង . . . . . . . . . . . . . . . . . ៦២
១. ការចាត់ការបណ្ដឹងនឹងមានដំណើរការ . . . . . . . . . . . . . . . . . . ៦២
២. ការហាមធ្វើបណ្ដឹងជាន់គ្នា . . . . . . . . . . . . . . . . . . . . . ៦២
៣. អានុភាពតាមផ្លូវច្បាប់សារធាតុ . . . . . . . . . . . . . . . . . . . . ៦៣
**ជំពូកទី ២ ការជំនុំជម្រះលើបណ្ដឹង** . . . . . . . . . . . . . . . . . . ៦៤
**ផ្នែកទី ១ តួនាទីរបស់តុលាការ និង ភាគី នៅក្នុងការជំនុំជម្រះលើបណ្ដឹង** . . . . . . ៦៤
កថាភាគទី ១ ការដឹកនាំនីតិវិធី និង ការចាត់ចែងនិងរៀបចំការជំនុំជម្រះ . . . . . . . . ៦៤
១. សិទ្ធិអំណាចរបស់តុលាការ ក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង . . . . . . . . . . . ៦៤
២. សិទ្ធិតវ៉ារបស់ភាគី ចំពោះសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង . . . . . . . . ៦៥
កថាភាគទី ២ ការសម្រេច អំពីចំណុចដែលជាកម្មវត្ថុនៃការជំនុំជម្រះ និង ការសម្រេច សេចក្ដី -- សិទ្ធិចាត់ចែងរបស់ភាគី . . . . . . . . . . . . . . . . . . . . . . . . ៦៥

១. ការសម្រេចអំពីកម្មវត្ថុ និង ទំហំនៃការជំនុំជម្រះនិងការសម្រេចសេចក្ដី ដោយភាគី ៦៥
២. ការបញ្ចប់បណ្ដឹងដោយផ្អែកលើឆន្ទៈរបស់ភាគី ៦៦
៣. គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និង មូលដ្ឋាននៃសិទ្ធិនេះ ៦៦
កថាភាគទី ៣ ការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ ៦៦
១. ភាពចាំបាច់នៃការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ ៦៦
២. សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគី ក្នុងការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ -- គោលការណ៍នៃការទាញហេតុផល ៦៧
៣. កិច្ចសហការរបស់តុលាការ -- សិទ្ធិឱ្យបំភ្លឺ ៦៩

**ផ្នែកទី ២ នីតិវិធីនៃការជម្រះក្ដី** ៧១

កថាភាគទី ១ ការទាញហេតុផលដោយផ្ទាល់មាត់ និង ការរៀបចំ ៧១
១. គោលការណ៍នៃការជម្រះក្ដីដោយផ្ទាល់មាត់ ៧១
២. ភាពចាំបាច់ និង ភាពមិនចាំបាច់ នៃការទាញហេតុផលដោយផ្ទាល់មាត់ ៧២
៣. ភាពចាំបាច់នៃការត្រៀមរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ -- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ឯកសារត្រៀម ៧៣
កថាភាគទី ២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៧៤
១. អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៧៤
២. កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៧៦
៣. ការសាកល្បងផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៧៧
៤. ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផល -- ការរៀបចំនូវការអះអាង និង ភស្តុតាង និង ការកំណត់នូវចំណុចវិវាទ ៧៨
៥. សកម្មភាពបណ្ដឹងដែលអាចធ្វើបាន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៨៥
៦. ការបំបែក និង ការរួមបញ្ចូលរឿងក្ដី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៨៦
៧. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៨៦
៨. អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ៨៧
កថាភាគទី ៣ ការទាញហេតុផលដោយផ្ទាល់មាត់ ៨៧
១. អត្ថន័យនៃការទាញហេតុផលដោយផ្ទាល់មាត់ ៨៨
២. ការជម្រះក្ដី នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ៨៨
៣. ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៩០
កថាភាគទី ៤ សំណុំរឿងនៃបណ្ដឹង ៩១
១. អត្ថន័យនៃសំណុំរឿងនៃបណ្ដឹង ៩១
២. ឯកសារដែលត្រូវចងក្រងជាសំណុំរឿងនៃបណ្ដឹង ៩២
៣. ការរក្សាទុកនូវសំណុំរឿងនៃបណ្ដឹង ៩២
៤. ការមើលសំណុំរឿងនៃបណ្ដឹង ៩៣

**ផ្នែកទី ៣ ភស្តុតាង** ៩៣

កថាភាគទី ១ ការបញ្ជាក់ និង ភស្តុតាង ៩៣

១. ឯកសារ វត្ថុតាង ជាអាទិ៍ ដើម្បីបញ្ជាក់ (គោលការណ៍នៃការសម្រេចសេចក្តីដោយភស្តុតាង) . . ៩៣
២. ពាក្យបច្ចេកទេសអំពីភស្តុតាង និង ការបញ្ជាក់ . . . . . . . . . . . . . . . . . . ៩៤
៣. ប្រភេទនៃភស្តុតាង . . . . . . . . . . . . . . . . . . . . . . . ៩៤
កថាភាគទី ២ កម្មវត្ថុនៃការបញ្ជាក់ . . . . . . . . . . . . . . . . . . . . ៩៦
១. អង្គហេតុ . . . . . . . . . . . . . . . . . . . . . . . . . . ៩៦
២. វិធានតាមបទពិសោធន៍ . . . . . . . . . . . . . . . . . . . . . . ៩៦
៣. បញ្ញត្តិច្បាប់ . . . . . . . . . . . . . . . . . . . . . . . . . ៩៧
កថាភាគទី ៣ អង្គហេតុដែលមិនចាំបាច់ធ្វើការបញ្ជាក់ . . . . . . . . . . . . . . . ៩៧
១. ការសារភាពតាមផ្លូវតុលាការ . . . . . . . . . . . . . . . . . . . . ៩៧
២. ការចាត់ទុកថាបានសារភាព . . . . . . . . . . . . . . . . . . . . ៩៩
៣. អង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង . . . . . . . . . . . ១០០
កថាភាគទី ៤ គោលការណ៍នៃជំនឿទុកចិត្តដោយសេរី . . . . . . . . . . . . . . ១០០
១. អត្ថន័យនៃគោលការណ៍នៃជំនឿទុកចិត្តដោយសេរី . . . . . . . . . . . . . ១០១
២. ការវាយតម្លៃដោយសេរី . . . . . . . . . . . . . . . . . . . . . ១០១
៣. ការកម្រិតចំពោះគោលការណ៍នៃជំនឿទុកចិត្តដោយសេរី . . . . . . . . . . . ១០២
កថាភាគទី ៥ ការទទួលខុសត្រូវក្នុងការបញ្ជាក់ . . . . . . . . . . . . . . . . ១០២
១. អត្ថន័យនៃការទទួលខុសត្រូវក្នុងការបញ្ជាក់ . . . . . . . . . . . . . . ១០២
២. ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ . . . . . . . . . . . . . . ១០៤
៣. ការសន្មតតាមផ្លូវច្បាប់ និង ការប្តូរនូវការទទួលខុសត្រូវក្នុងការបញ្ជាក់ . . . . . ១០៦
កថាភាគទី ៦ ការពន្យល់ត្រួសៗអំពីនីតិវិធីនៃការពិនិត្យភស្តុតាង . . . . . . . . . . ១០៨
១. បទប្បញ្ញត្តិទូទៅស្តីពីការពិនិត្យភស្តុតាង . . . . . . . . . . . . . . . ១០៨
២. ការសាកសួរសាក្សី . . . . . . . . . . . . . . . . . . . . . . ១០៩
៣. ការសាកសួរភាគី . . . . . . . . . . . . . . . . . . . . . . . ១០៩
៤. កោសលវិច័យ . . . . . . . . . . . . . . . . . . . . . . . . ១១០
៥. ភស្តុតាងជាឯកសារ . . . . . . . . . . . . . . . . . . . . . . ១១១
៦. ការត្រួតពិនិត្យ . . . . . . . . . . . . . . . . . . . . . . . ១១៣
កថាភាគទី ៧ នីតិវិធីថែរក្សាការពារភស្តុតាង . . . . . . . . . . . . . . . . ១១៣
១. ភាពចាំបាច់នៃការថែរក្សាការពារភស្តុតាង . . . . . . . . . . . . . . . ១១៣
២. ការចាប់ផ្តើមនីតិវិធី . . . . . . . . . . . . . . . . . . . . . . ១១៤
៣. ការធ្វើការពិនិត្យភស្តុតាង . . . . . . . . . . . . . . . . . . . . ១១៥
៤. ការប្រើលទ្ធផលនៃការពិនិត្យភស្តុតាង . . . . . . . . . . . . . . . . ១១៥
**ផ្នែកទី ៤ កាលបរិច្ឆេទ អំឡុងពេល ការបញ្ជូន** . . . . . . . . . . . . . . . ១១៥
កថាភាគទី ១ កាលបរិច្ឆេទ . . . . . . . . . . . . . . . . . . . . . . ១១៥
១. អត្ថន័យនៃកាលបរិច្ឆេទ . . . . . . . . . . . . . . . . . . . . . ១១៥
២. ការកំណត់កាលបរិច្ឆេទ . . . . . . . . . . . . . . . . . . . . . ១១៦

៣. ការប្តូរកាលបរិច្ឆេទ ១១៦
កថាភាគទី ២ អំឡុងពេល ១១៧
១. អត្ថន័យនៃអំឡុងពេល ១១៧
២. ការគណនានៃអំឡុងពេល ១១៧
៣. ការពន្យារអំឡុងពេល ១១៧
៤. ការបំពេញសកម្មភាពបណ្តឹងនៅពេលក្រោយ ១១៨
កថាភាគទី ៣ ការបញ្ជូន ១១៨
១. អត្ថន័យនៃការបញ្ជូន ១១៨
២. ស្ថាប័នដែលធ្វើការបញ្ជូន ១១៨
៣. ការបញ្ជូនដោយការប្រគល់ ១១៩
៤. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ១២០
**ជំពូកទី ៣ ល័ក្ខខ័ណ្ឌបណ្តឹង** ១២១
**ផ្នែកទី ១ អត្ថន័យនៃល័ក្ខខ័ណ្ឌបណ្តឹង** ១២១
កថាភាគទី ១ ល័ក្ខខ័ណ្ឌបណ្តឹងដែលជាល័ក្ខខ័ណ្ឌមូលដ្ឋាននៃសាលក្រមនៃបណ្តឹងអង្គសេចក្តី ១២១
កថាភាគទី ២ ការចាត់ចែងក្នុងករណីដែលមានកង្វះល័ក្ខខ័ណ្ឌបណ្តឹង ១២១
**ផ្នែកទី ២ ប្រភេទនៃល័ក្ខខ័ណ្ឌបណ្តឹង** ១២១
កថាភាគទី ១ ល័ក្ខខ័ណ្ឌសកម្ម និង ល័ក្ខខ័ណ្ឌអកម្ម ១២១
កថាភាគទី ២ ល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចតវ៉ា ១២២
កថាភាគទី ៣ ល័ក្ខខ័ណ្ឌបណ្តឹងសំខាន់ៗ ១២២
**ផ្នែកទី ៣ ផលប្រយោជន៍ក្នុងការធ្វើបណ្តឹង** ១២៣
កថាភាគទី ១ ផលប្រយោជន៍ស្តីពីកម្មវត្ថុនៃបណ្តឹង និង ផលប្រយោជន៍ស្តីពីប្រធាន ១២៣
កថាភាគទី ២ ផលប្រយោជន៍ត្រឹមត្រូវស្តីពីកម្មវត្ថុនៃបណ្តឹង (ផលប្រយោជន៍នៃការធ្វើ បណ្តឹង ក្នុងន័យចង្អៀត) ១២៣
១. ផលប្រយោជន៍ស្តីពីកម្មវត្ថុរួមនៃបណ្តឹងទាំងមូល ១២៤
២. ផលប្រយោជន៍ស្តីពីកម្មវត្ថុពិសេស តាមប្រភេទនីមួយៗនៃបណ្តឹង ១២៤
កថាភាគទី ៣ ផលប្រយោជន៍ត្រឹមត្រូវស្តីពីប្រធាននៃបណ្តឹង (លក្ខណៈជាភាគី) ១២៦
១. អត្ថន័យនៃលក្ខណៈជាភាគី ១២៦
២. ជនដែលជាភាគីត្រឹមត្រូវ ១២៦
**ជំពូកទី ៤ ការបញ្ចប់បណ្តឹង** ១២៩
**ផ្នែកទី ១ សាលក្រមចុងក្រោយ** ១២៩
កថាភាគទី ១ ការបញ្ចប់បណ្តឹងដោយសាលក្រមចុងក្រោយ ១២៩
១. អត្ថន័យ និង ប្រភេទនៃសាលក្រមចុងក្រោយ ១២៩
២. សាលក្រមរបៀប ១៣០
កថាភាគទី ២ ការបង្កើតសាលក្រម ១៣២

១. ការបង្កើតនូវខ្លឹមសារនៃសាលក្រម . . . . . . . . . . . . . . . . ១៣២
២. ការបង្កើតលិខិតសាលក្រម . . . . . . . . . . . . . . . . . . . ១៣២
៣. ការបង្កើតសាលក្រម . . . . . . . . . . . . . . . . . . . . . ១៣៤
កថាភាគទី ៣ អានុភាពនៃសាលក្រមចុងក្រោយ . . . . . . . . . . . . . . ១៣៤
១. អត្តពន្ធភាព . . . . . . . . . . . . . . . . . . . . . . . ១៣៤
២. អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ . . . . . . . . . . . . . . . . . ១៣៥
៣. អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ . . . . . . . . . . . . . . . . ១៣៧
៤. អានុភាពអនុវត្ត . . . . . . . . . . . . . . . . . . . . . . ១៤៥
៥. អានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត . . . . . . . . ១៤៥
កថាភាគទី ៤ សាលក្រមកំបាំងមុខ . . . . . . . . . . . . . . . . . ១៤៦
១. អវត្តមាននៃភាគី និង ដំណើរការនៃនីតិវិធី . . . . . . . . . . . . . ១៤៦
២. នីតិវិធីរហូតដល់ការចេញសាលក្រមកំបាំងមុខ . . . . . . . . . . . . . ១៤៨
៣. បណ្តឹងឧបាស្រ័យចំពោះសាលក្រមកំបាំងមុខ . . . . . . . . . . . . . ១៥០
កថាភាគទី ៥ ការសម្រេចសេចក្តីបន្ទាប់បន្សំដែលភ្ជាប់ជាមួយនឹងសាលក្រមចុងក្រោយ . . . . ១៥២
១. ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន . . . . . . . . . . . . . . . ១៥២
២. ការសម្រេចសេចក្តីអំពីប្រាក់ប្រដាប់ក្តី . . . . . . . . . . . . . . . ១៥៤
៣. ការសង្គ្រោះលើបណ្តឹង . . . . . . . . . . . . . . . . . . . . ១៥៥
កថាភាគទី ៦ ដីកាសម្រេច . . . . . . . . . . . . . . . . . . . . ១៥៦
១. អត្ថន័យនៃដីកាសម្រេច . . . . . . . . . . . . . . . . . . . . ១៥៦
២. ចំណុចខុសគ្នានឹងសាលក្រម . . . . . . . . . . . . . . . . . . . ១៥៦
**ផ្នែកទី ២ មូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងដោយមិនធ្វើទៅតាមសាលក្រម** . . . ១៥៧
កថាភាគទី ១ មូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងនីមួយៗ . . . . . . . . . . ១៥៧
កថាភាគទី ២ ការបញ្ចប់នីតិវិធីបណ្តឹងដោយស្វ័យប្រវត្តិ . . . . . . . . . . . ១៥៨
កថាភាគទី ៣ ការដកពាក្យបណ្តឹង . . . . . . . . . . . . . . . . . ១៥៩
១. អត្ថន័យនៃការដកពាក្យបណ្តឹង . . . . . . . . . . . . . . . . . ១៥៩
២. ល័ក្ខខ័ណ្ឌ និង វិធីដកបណ្តឹង . . . . . . . . . . . . . . . . . ១៥៩
៣. អានុភាពនៃការដកពាក្យបណ្តឹង . . . . . . . . . . . . . . . . . ១៦១
កថាភាគទី ៤ ការលះបង់ និង ការទទួលស្គាល់នូវការទាមទារ . . . . . . . . . ១៦២
១. អត្ថន័យនៃការលះបង់ និង ការទទួលស្គាល់នូវការទាមទារ . . . . . . . . . ១៦២
២. ល័ក្ខខ័ណ្ឌ និង វិធីធ្វើការលះបង់ និង ការទទួលស្គាល់នូវការទាមទារ . . . . . ១៦៣
៣. អានុភាពនៃការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ . . . . . . . . . ១៦៤
កថាភាគទី ៥ ការសះជាតាមផ្លូវបណ្តឹង . . . . . . . . . . . . . . . . ១៦៥
១. អត្ថន័យនៃការសះជាតាមផ្លូវបណ្តឹង . . . . . . . . . . . . . . . . ១៦៥
២. ល័ក្ខខ័ណ្ឌ និង វិធីនៃការសះជាតាមផ្លូវបណ្តឹង . . . . . . . . . . . . ១៦៥
៣. អានុភាពនៃការសះជាតាមផ្លូវបណ្តឹង . . . . . . . . . . . . . . . . ១៦៧

**ជំពូកទី ៥ ភាពមានកម្មវត្ថុច្រើន ឬ ភាពមានប្រធានច្រើននាក់ក្នុងបណ្តឹង** . . . . ១៧០
**ផ្នែកទី ១ ភាពមានកម្មវត្ថុច្រើនក្នុងបណ្តឹង** . . . . ១៧០
កថាភាគទី ១ ការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង . . . . ១៧០
១. អត្ថន័យនៃការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង . . . . ១៧០
២. ល័ក្ខខ័ណ្ឌនៃការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង . . . . ១៧០
៣. បែបយ៉ាងនៃការរួមបញ្ចូលនូវការទាមទារ . . . . ១៧១
៤. ការវិនិច្ឆ័យ និង សាលក្រម . . . . ១៧៣
កថាភាគទី ២ ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង . . . . ១៧៤
១. អត្ថន័យនៃការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង . . . . ១៧៤
២. ល័ក្ខខ័ណ្ឌនៃការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង . . . . ១៧៥
៣. វិធីធ្វើការផ្លាស់ប្តូរបណ្តឹង . . . . ១៧៦
៤. ការចាត់ចែងអំពីការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង . . . . ១៧៦
កថាភាគទី ៣ បណ្តឹងតប . . . . ១៧៦
១. អត្ថន័យនៃបណ្តឹងតប . . . . ១៧៦
២. ល័ក្ខខ័ណ្ឌនៃបណ្តឹងតប . . . . ១៧៧
៣. វិធីដាក់ពាក្យបណ្តឹងតប និង ការចាត់ចែងបណ្តឹងតប . . . . ១៧៨
កថាភាគទី ៤ បណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី . . . . ១៧៨
១. អត្ថន័យនៃបណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី . . . . ១៧៨
២. ល័ក្ខខ័ណ្ឌនៃបណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី . . . . ១៧៩
៣. វិធីដាក់ពាក្យបណ្តឹង និង នីតិវិធីបណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី . . . . ១៧៩
**ផ្នែកទី ២ ភាពមានប្រធានច្រើននាក់ក្នុងបណ្តឹង** . . . . ១៧៩
កថាភាគទី ១ សហបណ្តឹង . . . . ១៧៩
១. អត្ថន័យនៃសហបណ្តឹង . . . . ១៧៩
២. ប្រភេទនៃសហបណ្តឹង . . . . ១៨០
៣. ករណីដែលមានសហបណ្តឹង . . . . ១៨៣
កថាភាគទី ២ ការជ្រើសរើសភាគី . . . . ១៨៥
១. អត្ថន័យនៃការជ្រើសរើសភាគី . . . . ១៨៥
២. ល័ក្ខខ័ណ្ឌនៃការជ្រើសរើស . . . . ១៨៦
៣. សកម្មភាពជ្រើសរើស . . . . ១៨៦
កថាភាគទី ៣ ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង . . . . ១៨៧
១. អត្ថន័យ និង ប្រភេទនៃការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង . . . . ១៨៧
២. ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង . . . . ១៨៧
៣. ការចូលរួមជួយអន្តរាគមន៍ . . . . ១៨៨
កថាភាគទី ៤ ការទទួលបន្តនូវបណ្តឹង . . . . ១៩៤
១. អត្ថន័យនៃការទទួលបន្តនូវបណ្តឹង . . . . ១៩៤

២. ករណីដែលការទទួលបន្តនូវបណ្តឹងកើតឡើង ១៩៤
៣. ការទទួលបន្តនូវបណ្តឹង និង ការផ្អាកនីតិវិធីនៃបណ្តឹង ១៩៥
៤. ការអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ និង ការទទួលបន្តនូវបណ្តឹង ( មាត្រា ៨៨) ១៩៥
**ជំពូកទី ៦ បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច** ១៩៨
កថាភាគទី ១ គោលគំនិត និង កម្មវត្ថុនៃនីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច ១៩៨
កថាភាគទី ២ បញ្ញត្តិពិសេសស្តីពីនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច ១៩៨
១. បញ្ញត្តិពិសេសស្តីពីការដាក់ពាក្យធ្វើបណ្តឹង ១៩៨
២. បញ្ញត្តិពិសេសស្តីពីការវិនិច្ឆ័យ ១៩៩
៣. បញ្ញត្តិពិសេសស្តីពីសាលក្រម ២០០
កថាភាគទី ៣ ទំនាក់ទំនងរវាងនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច និង នីតិវិធីធម្មតា ២០១
១. នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច និង ការជ្រើសរើសដោយភាគី ២០១
២. ការផ្ទេរបណ្តឹងទៅនីតិវិធីធម្មតា ដោយដីកាសម្រេចរបស់តុលាការ ២០២
**គន្ថីទី ៤ នីតិវិធីនៃការជំនុំជម្រះនៅតុលាការជាន់ខ្ពស់** ២០៣
**ជំពូកទី ១ អត្ថន័យនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់** ២០៣
១. ទស្សនៈនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ២០៣
២. គោលបំណងនៃរបបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ២០៣
៣. ប្រភេទនៃបណ្តឹងឧបាស្រ័យ ២០៤
**ជំពូកទី ២ បណ្តឹងឧទ្ធរណ៍** ២០៥
កថាភាគទី ១ ការធ្វើបណ្តឹងឧទ្ធរណ៍ ២០៥
១. សេចក្តីសម្រេចដែលអាចប្តឹងឧទ្ធរណ៍បាន ២០៥
២. សិទ្ធិប្តឹងឧទ្ធរណ៍ ២០៥
៣. អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ ២០៦
៤. របៀបធ្វើបណ្តឹងឧទ្ធរណ៍ ២០៧
៥. អានុភាពនៃការដាក់ពាក្យបណ្តឹង ២០៨
៦. ការដកពាក្យបណ្តឹងឧទ្ធរណ៍ ២០៩
កថាភាគទី ២ ការប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ២១០
កថាភាគទី ៣ ការវិនិច្ឆ័យ និង ចេញសាលក្រមនៃតុលាការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ២១២
១. ការជំនុំជម្រះនៃតុលាការនៃបណ្តឹងឧទ្ធរណ៍ ២១២
២. សាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ២១៣
**ជំពូកទី ៣ បណ្តឹងសាទុក្ខ** ២១៨
កថាភាគទី ១ អត្ថន័យនៃបណ្តឹងសាទុក្ខ ២១៨
១. ទស្សនៈនៃបណ្តឹងសាទុក្ខ ២១៨
២. គោលបំណងនៃការប្តឹងសាទុក្ខ ២១៨
៣. មូលហេតុនៃការប្តឹងសាទុក្ខ ២១៩
៤. បណ្តឹងសាទុក្ខ និង នីតិវិធីបណ្តឹងក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ ២២០

កថាភាគទី ២ ការធ្វើបណ្តឹងសាទុក្ខ ២២០
កថាភាគទី ៣ ការជំនុំជម្រះបណ្តឹងសាទុក្ខ និង ការចេញសាលដីកា ២២១
១. ការជំនុំជម្រះនៃតុលាការនៃបណ្តឹងសាទុក្ខ ២២១
**ជំពូកទី ៤ ការប្តឹងជំទាស់** ២២៦
កថាភាគទី ១ អត្ថន័យនៃការប្តឹងជំទាស់ ២២៦
កថាភាគទី ២ ដីកាសម្រេចដែលអាចប្តឹងជំទាស់បាន ២២៦
កថាភាគទី ៣ បណ្តឹងជំទាស់ និង ការវិនិច្ឆ័យបណ្តឹងជំទាស់ ២២៧
១. ការធ្វើបណ្តឹងជំទាស់ ២២៧
២. នីតិវិធីនៃការជំនុំជម្រះទៅលើបណ្តឹងជំទាស់ ២២៨
កថាភាគទី ៤ វិសាលភាពនៃការអនុញ្ញាតឱ្យប្តឹងជំទាស់ ២៣០
១. ការប្តឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍ ២៣០
២. បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់ សិទ្ធិ ២៣១
**គន្ថីទី ៥ នីតិវិធីនៃការជំនុំជម្រះសាជាថ្មី** ២៣២
**ជំពូកទី ១ អត្ថន័យនៃការជំនុំជម្រះសាជាថ្មី** ២៣២
**ជំពូកទី ២ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ២៣៣
១. មូលហេតុនៃការជំនុំជម្រះសាជាថ្មី ២៣៣
២. ល័ក្ខខ័ណ្ឌនៃបណ្តឹងសុំឱ្យជំនុំជម្រះសាជាថ្មី ២៣៤
៣. តុលាការដែលមានសមត្ថកិច្ចទៅលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ២៣៧
៤. ការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ២៣៧
**ជំពូកទី ៣ ការវិនិច្ឆ័យ និង សម្រេចសេចក្តីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ២៣៩
១. ពីរដំណាក់កាល នៃការវិនិច្ឆ័យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ២៣៩
២. ការវិនិច្ឆ័យ និង ការសម្រេចសេចក្តីអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការសុំឱ្យជំនុំជម្រះសាជាថ្មី ២៣៩
៣. ការវិនិច្ឆ័យ និង ចេញសាលក្រម ឬ សាលដីកាអំពីអង្គសេចក្តី ២៤០
**គន្ថីទី ៦ នីតិវិធីដាស់តឿន** ២៤២
**ជំពូកទី ១ អត្ថន័យនៃនីតិវិធីដាស់តឿន** ២៤២
**ជំពូកទី ២ ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន** ២៤៣
១. តុលាការដែលមានសមត្ថកិច្ច ២៤៣
២. ល័ក្ខខ័ណ្ឌនៃពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ២៤៣
៣. ការវិនិច្ឆ័យ និង សម្រេចសេចក្តីអំពីពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ២៤៤
**ជំពូកទី ៣ ការតវ៉ាចំពោះដីកាសម្រេចដាស់តឿន** ២៤៦
១. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ២៤៦
២. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ២៤៧
**គន្ថីទី ៧ អន្តរប្បញ្ញត្តិ និង អវសានប្បញ្ញត្តិ** ២៤៩
**ជំពូកទី ១ អត្ថន័យនៃអន្តរប្បញ្ញត្តិ និងភាពចាំបាច់នៃប្បញ្ញត្តិនេះ** ២៤៩

១. អត្ថន័យនៃអន្តរប្បញ្ញត្តិ ២៤៩
២. គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី និង គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ២៤៩
៣. ផលប្រយោជន៍ និង ផលវិបត្តិនៃគោលការណ៍អនុវត្តតាមច្បាប់ថ្មី និង គោលការណ៍នៃការអនុវត្តតាម ច្បាប់ចាស់ ព្រមទាំងគោលជំហរជាមូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ២៥០
**ជំពូកទី ២ គោលការណ៍នៃវិធានការអន្តរកាល** ២៥១
១. ការជ្រើសរើសយកគោលការណ៍ការអនុវត្តតាមច្បាប់ថ្មី ២៥១
២. ការរក្សាទុកនូវអានុភាពដែលកើតមានឡើងក្នុងនីតិវិធីនៃច្បាប់ចាស់ ២៥១
**ជំពូកទី ៣ វិធានការអន្តរកាលនីមួយៗ** ២៥២
១. វិធានការអន្តរកាលស្តីពីសមត្ថកិច្ច ២៥២
២. វិធានការអន្តរកាលស្តីពីការបែងចែករឿងក្តី ២៥២
៣. វិធានការអន្តរកាលស្តីពីការសម្រេចសេចក្តីអំពីពាក្យសុំដកហូត និង បណ្តឹងជំទាស់ ២៥៣
៤. វិធានការអន្តរកាលស្តីពីនីតិវិធីអង្កេតស៊ើបសួរ និងនីតិវិធីក្រោយពីនេះ ២៥៤
៥. វិធានការអន្តរកាលស្តីពីប្រាក់ប្រដាប់ក្តី ២៥៧
៦. វិធានការអន្តរកាលស្តីពីកាលបរិច្ឆេទនៃការជំនុំជម្រះរឿងក្តី ២៥៨
៧. វិធានការអន្តរកាលស្តីពីទណ្ឌកម្មនៅក្នុងការពិនិត្យភស្តុតាង ២៥៨
៨. វិធានការអន្តរកាលស្តីពីសាលក្រមកំបាំងមុខ ២៥៩
៩. វិធានការអន្តរកាលស្តីពីការអាច ឬ មិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះ ២៥៩
១០. វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ២៦៣
១១. វិធានការអន្តរកាលស្តីពីចំណាងនៃសាលដីការបស់តុលាការកំពូលដែលទុកជាមោឃៈនូវសាលដីកាដើម ២៦៦
១២. វិធានការអន្តរកាលស្តីពីការជំនុំជម្រះសាជាថ្មី ២៦៦
**ជំពូកទី ៤ អវសានប្បញ្ញត្តិ** ២៦៨
១. កាលបរិច្ឆេទនៃការអនុវត្ត ២៦៨
២. ការធ្វើនិរាករណ៍នូវច្បាប់ដទៃទៀត ជាអាទិ៍ ២៦៩

**សមាសភាពនៃក្រុមអ្នកនិពន្ធ ៖**

| | |
|---|---|
| លោក Takeshita Morio | ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ. សកលវិទ្យាល័យ Surugadai (ប្រធាន) |
| លោកស្រី Homma Yoshiko | មេធាវី. ការិយាល័យមេធាវី Homma Yoshiko |
| លោក Ikeda Tatsuo | សាស្ត្រាចារ្យ. សកលវិទ្យាល័យ Osaka. មេធាវី |
| លោក Matsushita Jun'ichi | សាស្ត្រាចារ្យ. សកលវិទ្យាល័យ Tokyo |
| លោក Miki Koichi | សាស្ត្រាចារ្យ. សកលវិទ្យាល័យ Keio |
| លោក Omura Hasahiko | សាស្ត្រាចារ្យ. សកលវិទ្យាល័យ Chuo |
| លោក Takada Masahiro | សាស្ត្រាចារ្យ. សកលវិទ្យាល័យទីក្រុង Osaka |
| លោក Uehara Toshio | សាស្ត្រាចារ្យ. សកលវិទ្យាល័យ Hitotsubashi |
| លោក Yamamoto Kazuhiko | សាស្ត្រាចារ្យ. សកលវិទ្យាល័យ Hitotsubashi |
| លោក Yanagida Kozo | ចៅក្រម. សាលាឧទ្ធរណ៍នៃតំបន់ Tokyo |

**សមាសភាពនៃក្រុមអ្នកបកប្រែ ៖**

| | |
|---|---|
| លោក **សាភាណុ អ៊ុំសេស** | ជំនាញការ . កម្មវិធីសាហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ. អង្គការ JICA ប្រចាំក្រសួងយុត្តិធម |
| លោក **ស្វាយ ឡេង** | SL Corporation |
| លោក **សរ សិនិរ** | ជំនួយការជាន់ខ្ពស់. កម្មវិធីសាហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ. អង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ |
| លោកស្រី **គគ បូរ៉េន** | អតីតជំនួយការជាន់ខ្ពស់. កម្មវិធីសាហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ. អង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ |

# គន្ថីទី ១ នីតិវិធីរដ្ឋប្បវេណី

## ជំពូកទី ១ អត្ថន័យនៃនីតិវិធីរដ្ឋប្បវេណី

### កថាភាគទី ១ របបរឿងក្តីរដ្ឋប្បវេណី

១. ជីវភាពរស់នៅក្នុងសង្គម និង ស្វ័យភាពរបស់ឯកជន

នៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលឯកជនម្នាក់ៗដែលជាសមាជិកសង្គមនោះ ចូលរួមក្នុងជីវភាពសេដ្ឋកិច្ច តាមរយៈការដោះដូរទំនិញ និង សេវា ដោយប្រើរូបិយវត្ថុជាចម្បង ។ ជាធម្មតា ការដោះដូរទំនិញ និង សេវា ត្រូវបានធ្វើឡើងតាមរយៈកិច្ចសន្យា ឬ ការសន្យារវាងបុគ្គលម្នាក់ និង បុគ្គលម្នាក់ទៀត ។ នៅក្នុងករណីជាច្រើន បុគ្គលនានា ប្រតិបត្តិតាមកិច្ចសន្យា គោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយអនុវត្តករណីយកិច្ចរបស់ខ្លួនដោយសេចក្តីសុចរិត ។ វាជាការធម្មតា ដែលប្រជាពលរដ្ឋរស់នៅក្នុងប្រទេសនីតិរដ្ឋ ត្រូវតែគោរពច្បាប់ ។ ក៏ដូចគ្នាផងដែរ បុគ្គលនានា តាំងចិត្តគោរពការសន្យារបស់ខ្លួន ដោយបុព្វហេតុនៃទំនុកចិត្តលើសង្គម ឬ ដោយបុព្វហេតុសាសនា ។

ឧទាហរណ៍ នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ A បានឱ្យ B ខ្ចីប្រាក់ ចំនួន ១០ លានរៀល ។ ក្នុងករណីនេះ នៅពេលដល់កាលបរិច្ឆេទកំណត់ដែលត្រូវសងហើយ A អាចទាមទារឱ្យ B សងប្រាក់ ១០ លានរៀលនោះមកវិញបាន ហើយជាធម្មតា B ក៏ត្រូវសងប្រាក់នេះទៅឱ្យ A វិញដែរ ។ ជាទូទៅ B នឹងសងប្រាក់កំចីនេះទៅឱ្យ A វិញ នៅកាលបរិច្ឆេទកំណត់ដែលត្រូវសង ហើយជាលទ្ធផល គឺពុំមានវិវាទអំពីប្រាក់កំចីរវាង A និង B ឡើយ ។ អាស្រ័យហេតុនេះ អ្នកទាំងពីរនឹងបន្តជីវភាពសេដ្ឋកិច្ចទៅមុខទៀត ដោយភាពរលូន ។

ជាគោលការណ៍ ច្បាប់គោរពនូវឆន្ទៈរបស់បុគ្គល ហើយអនុញ្ញាតឱ្យបុគ្គលអាចកំណត់នូវវិធានផ្ទាល់ខ្លួនដោយផ្អែកលើឆន្ទៈសេរីរបស់ពួកគេ ចំពោះបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងជីវភាពសេដ្ឋកិច្ច ដែលរួមមានការដោះដូរទំនិញ និង សេវា (លក់ ជួល ជាដើម) ។ បុគ្គលឯកជនអាចធ្វើការសម្រេចចិត្ត ដោយផ្អែកតាមឆន្ទៈរបស់ខ្លួន ដូចជាការសម្រេចថា ទំនិញ ឬ សេវាបែបណាដែលត្រូវទិញ វត្ថុផ្សំបែបណាដែលត្រូវរកផលិតផលបែបណាដែលត្រូវផលិត និង លក់ ជាដើម ។ លើសពីនេះទៅទៀត បុគ្គលឯកជនត្រូវបានចងតែដោយសេចក្តីសម្រេចរបស់ខ្លួនតែប៉ុណ្ណោះ ហើយរដ្ឋមិនអាចជ្រៀតជ្រែក ឬ ដាក់កំហិតទៅលើសេចក្តីសម្រេចរបស់បុគ្គលនោះបានឡើយ ។ យន្តការច្បាប់បែបនេះ គឺឈរលើមនោគមវិជ្ជាសេរីនិយម និង បុគ្គលនិយម ដែលថា ការមិនជ្រៀតជ្រែកក្នុងសកម្មភាពសេដ្ឋកិច្ច អាចជាចំណែកនៃអភិវឌ្ឍន៍សង្គម ។ យន្តការដែលតាមរយៈនេះ បុគ្គលឯកជនអាចធ្វើការសម្រេចចិត្តដោយសេរី នៅក្នុងជីវភាពសេដ្ឋកិច្ចរបស់ខ្លួន គេហៅថា "គោលការណ៍ស្វ័យភាពរបស់ឯកជន" ។ នៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ ជីវភាពសេដ្ឋកិច្ច និង សកម្មភាពសេដ្ឋកិច្ចរវាងបុគ្គលឯកជន ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃគោលការណ៍ស្វ័យភាពរបស់ឯកជន ។

## ២. វិវាទក្នុងជីវភាពរស់នៅក្នុងសង្គម និង ការដោះស្រាយវិវាទនោះដោយខ្លួនឯង

ផ្ទុយទៅវិញ នៅក្នុងករណីជាក់ស្តែង វិវាទអាចនឹងកើតមានឡើងរវាងភាគី A និង B ។ ឧទាហរណ៍ នៅក្នុងករណីខាងលើ B អាចនឹងមានចេតនាមិនព្រមសងប្រាក់ដែលបានខ្ចី ទោះបីជាដល់ពេលកំណត់ត្រូវសង ហើយក៏ដោយ ដោយអះអាងថា "ខ្ញុំបានទទួលប្រាក់នោះមែន ក៏ប៉ុន្តែ វាគឺជាអំណោយពី A ទេតើ" ឬក៏ "ខ្ញុំបាន ខ្ចីប្រាក់មែន ក៏ប៉ុន្តែ ខ្ញុំបានសងរួចទៅហើយ" ។ ករណីម៉្យាងទៀត B អាចនឹងមិនសងប្រាក់កំចី ដោយយកលេស ថា ខ្លួនមានការខ្វះខាតថវិកានៅពេលបច្ចុប្បន្ន បើទោះបីជាគាត់មិនប្រកែកទៅនឹងអង្គហេតុនៃការខ្ចីប្រាក់ ក៏ដោយ ។ មានដំណោះស្រាយផ្សេងៗជាច្រើន ចំពោះវិវាទបែបនេះ ។

ទីមួយ វិវាទនេះអាចនឹងត្រូវបានដោះស្រាយតាមរយៈកិច្ចសន្យាសះជា ដែលតាមរយៈនេះភាគីនៃវិវាទ គឺ A និង B ព្រមព្រៀងបញ្ចប់វិវាទ តាមរយៈការពិភាក្សា និង ការធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក (សូម មើលក្រមរដ្ឋប្បវេណី មាត្រា ៧២១) ។ ឧទាហរណ៍ A និង B អាចនឹងធ្វើការផ្សះផ្សាបញ្ចប់វិវាទរវាង ពួកគេទាំងពីរ ក្រោមល័ក្ខខ័ណ្ឌដូចតទៅ : (១) B សុខចិត្តទទួលកាតព្វកិច្ចសងប្រាក់ចំនួន ៥ លានរៀល ស្មើ នឹងពាក់កណ្តាលនៃទឹកប្រាក់អះអាងដោយ A ហើយ (២) នៅពេលបានទទួលប្រាក់ចំនួន ៥ លានរៀលនេះ ហើយ A មិនត្រូវទាមទារឱ្យមានការសងប្រាក់បន្ថែមលើសពីនេះទៀតទេ ។ ករណីម៉្យាងទៀត A និង B អាចនឹងព្រមព្រៀងគ្នាថា B ទទួលកាតព្វកិច្ចសងប្រាក់ចំនួន ១០ លានរៀល តែសន្យាថា សងបណ្តាក់រាល់ ចុងខែ ក្នុងមួយខែ ៤០ ម៉ឺនរៀល បូកសរុបចំនួន ២៥ ដង ជាដើម ។

ទីពីរ មានវិធីដោះស្រាយវិវាទមួយបែបទៀត ដែលគេហៅថាមជ្ឈត្តកម្ម ។ នៅក្នុងករណីនេះ តតិយជន ម្នាក់ ត្រូវដើរតួនាទីជាមជ្ឈត្តករ ហើយភាគីនៃទំនាស់ ត្រូវធ្វើការព្រមព្រៀងជាមុនថា នឹងសុខចិត្តគោរពតាម ការវិនិច្ឆ័យរបស់មជ្ឈត្តករ (ការព្រមព្រៀងនេះ គេហៅថា កិច្ចសន្យាមជ្ឈត្តកម្ម) ។ ដូច្នេះហើយ វិវាទនឹង ត្រូវបានដោះស្រាយដោយសេចក្តីសម្រេចដែលនឹងចេញដោយតតិយជននោះ (សេចក្តីសម្រេចនេះ គេហៅថា សេចក្តីសម្រេចមជ្ឈត្តករ) ។ ឧទាហរណ៍ ប្រសិនបើមជ្ឈត្តករសម្រេចថា ការអះអាងរបស់ A មានភាពត្រឹម ត្រូវ ហើយ B ត្រូវសងប្រាក់ចំនួន ១០ លានរៀលទៅ A នោះ B ត្រូវតែសងប្រាក់នោះ ដោយអនុវត្តតាម សេចក្តីសម្រេចមជ្ឈត្តករ ហើយវិវាទនេះក៏ត្រូវបានដោះស្រាយ ។ មជ្ឈត្តកម្មតែងត្រូវបានប្រើជាញឹកញាប់ នៅក្នុងប្រតិបត្តិការជំនួញ ជាពិសេស ក្នុងកិច្ចការជំនួញអន្តរជាតិ ។

ទីបី ប្រទេសជឿនលឿនជាច្រើនបានបង្កើតប្រព័ន្ធនៃការដោះស្រាយវិវាទមួយដែលគេហៅថា សន្ធានកម្ម ។ សន្ធានកម្ម គឺជាប្រព័ន្ធមួយដែលនៅក្នុងនោះ គណៈកម្មាធិការសន្ធានកម្មមួយដែលមានសមាជិកជាសន្ធានករ ដែលត្រូវបានជ្រើសរើសចេញពីសាធារណៈជនទូទៅ ជំរុញឱ្យភាគីនៃវិវាទ ឈានទៅរកការព្រមព្រៀងមួយ ក្នុងគោលគំនិតស្វែងរកការដោះស្រាយដ៏សមហេតុផល សមស្របទៅនឹងស្ថានភាពជាក់ស្តែងនៃវិវាទ ។ ហេតុ នេះហើយ ពេលដែលមានការស្នើសុំពីភាគីណាម្ខាង គណៈកម្មាធិការសន្ធានកម្ម ត្រូវកោះហៅភាគីទាំងសង

ខាង ត្រូវស្តាប់អំណះអំណាងរបស់ពួកគេ ហើយត្រូវជំរុញពួកគេឱ្យឈានទៅរកការព្រមព្រៀងមួយ សំដៅដោះស្រាយវិវាទតាមរយៈការធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក ឬ ត្រូវបង្ហាញដល់ពួកគេ នូវសំណើសម្រាប់ការដោះស្រាយវិវាទមួយ ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យពួកគេអាចឈានទៅរកការព្រមព្រៀង ដោយផ្អែកលើសំណើនោះ ។ ឧទាហរណ៍ គណៈកម្មាធិការសន្ធានកម្ម អាចនឹងលើកសំណើដូចតទៅ ហើយជំរុញឱ្យ A និង B ទទួលយកសំណើនេះ :

១. B ទទួលស្គាល់កាតព្វកិច្ចត្រូវសងប្រាក់ទាំងអស់ចំនួន ១០ លានរៀលទៅឱ្យ A ហើយខ្លួននឹងបង់ប្រាក់ចំនួន ១ លានរៀល នៅរៀងរាល់ចុងខែ ទៅឱ្យ A ។

២. ប្រសិនបើ B បានបង់ប្រាក់ចំនួន ១ លានរៀលរៀងរាល់ខែ ទៅឱ្យ A បានប្រាំពីរខែតាមការសន្យាហើយ A ត្រូវលើកលែងបំណុលចំនួន ៣ លានរៀលទៀត ពី B ។

៣. ប្រសិនបើ B មិនបានបង់ប្រាក់ ទោះមួយដងក៏ដោយ B ត្រូវបង់ប្រាក់ដែលនៅសល់ទាំងអស់តែម្តងជាអាទិ៍ ។

ប្រសិនបើភាគីទាំងសងខាងទទួលយកសំណើនេះ ការព្រមព្រៀងមួយនឹងត្រូវបានបង្កើតឡើង ហើយវិវាទនឹងត្រូវបានដោះស្រាយ ។ តាមន័យច្បាប់ ការព្រមព្រៀងនេះ គឺជាកិច្ចសន្យាសះជា ។ នៅប្រទេសជប៉ុន មានប្រព័ន្ធសន្ធានកម្មដឹកនាំដោយតុលាការ ដែលជារបៀបដោះស្រាយវិវាទមួយតាមបែបសន្សំសំចៃប្រាក់កាស សាមញ្ញ និង ឆាប់រហ័ស ។ នៅក្នុងប្រព័ន្ធសន្ធានកម្មរបស់ប្រទេសជប៉ុន គណៈកម្មាធិការសន្ធានកម្ម មានសមាជិកម្នាក់ជាចៅក្រមវិជ្ជាជីវៈ និង ពីរនាក់ទៀតជាសន្ធានករដែលត្រូវបានជ្រើសរើសចេញពីប្រជាពលរដ្ឋធម្មតា ។ គេអាចនឹងសន្មតថា នៅព្រះរាជាណាចក្រកម្ពុជានាពេលអនាគត នឹងមានប្រព័ន្ធសន្ធានកម្មដែលមានលក្ខណៈបែបនេះ ពោលគឺវិធីដោះស្រាយវិវាទដែលងាយស្រួលនឹងទទួលបាន ។

អាស្រ័យហេតុនេះ ការសះជា មជ្ឈត្តកម្ម និង សន្ធានកម្ម អាចហៅបានថាជាវិធីដោះស្រាយវិវាទដោយស្ម័គ្រចិត្ត និង ដោយឆន្ទានុសិទ្ធិរបស់ភាគី ព្រោះថា ដំណោះស្រាយទាំងនោះត្រូវបានធ្វើឡើងដោយផ្អែកលើការព្រមព្រៀងរវាងភាគី ។

### ៣. ការដោះស្រាយវិវាទដោយបង្ខំ --- ប្រពន្ធ័នីតិវិធីរដ្ឋប្បវេណី

ក៏ប៉ុន្តែ នៅក្នុងករណីមួយចំនួន វិវាទរវាងបុគ្គលឯកជន មិនអាចដោះស្រាយបាន តាមរយៈការប្រឹងប្រែងដោយស្ម័គ្រចិត្ត និង ដោយឆន្ទានុសិទ្ធិរបស់ភាគីឡើយ ។ នៅក្នុងឧទាហរណ៍ខាងលើនេះ អាចនឹងមានករណីដែលពុំអាចឈានទៅដល់ការផ្សះផ្សា ឬ ការព្រមព្រៀងគ្នាថានឹងគោរពតាមសេចក្តីសម្រេចរបស់តតិយជន (កិច្ចសន្យាមជ្ឈត្តកម្ម) ដោយហេតុថា ទាំងភាគី A និង ភាគី B ពុំបានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមកឡើយ ។ នៅក្នុងករណីបែបនេះ ទោះបីជាការអះអាងរបស់ A មានភាពត្រឹមត្រូវ ហើយ A មានសិទ្ធិទាមទារឱ្យ B សងប្រាក់ចំនួន ១០ លានរៀល មកខ្លួនក៏ដោយ ប្រសិនបើ A ត្រូវបានអនុញ្ញាតឱ្យធ្វើការប្រមូលប្រាក់ពី B

ដោយខ្លួនឯងនោះ នឹងធ្វើឱ្យប៉ះពាល់ដល់សេចក្តីសុខសាន្តក្នុងសង្គម ។ នៅក្នុងករណីដោយឡែកទៅវិញ បើទោះបីជាការអះអាងរបស់ B មានភាពត្រឹមត្រូវក៏ដោយ ក៏អាចមានករណីដែល A ប្រើប្រាស់កម្លាំង ដើម្បីប្រមូលប្រាក់ ១០ លានរៀលនោះពី B ដោយយកលេសថាជាការអនុវត្តសិទ្ធិរបស់ខ្លួនដែរ ។ ហេតុដូច្នេះហើយ នៅក្នុងប្រទេសទំនើប ជាគោលការណ៍ ការសង្គ្រោះដោយខ្លួនឯង ដោយប្រើកម្លាំងបែបនេះ ត្រូវបានហាមឃាត់ (ការហាមឃាត់ការសង្គ្រោះដោយខ្លួនឯង) ។ រដ្ឋត្រូវបង្កើតតុលាការ ហើយប្រសិនបើមានពាក្យបណ្តឹងពីភាគីណាម្ខាងនៃវិវាទ តុលាការត្រូវកោះហៅគូភាគីទាំងសងខាងដោយមិនគិតពីឆន្ទៈនៃភាគីម្ខាងទៀត ត្រូវឱ្យភាគីធ្វើការអះអាង ត្រូវវិនិច្ឆ័យ (សម្រេចសេចក្តី) ទៅលើចំណុចថាតើអំណះអំណាងរបស់ភាគីមួយណាដែលមានភាពត្រឹមត្រូវ និង ត្រូវបង្ខំឱ្យភាគីទាំងសងខាងអនុវត្តតាមសេចក្តីសម្រេចនោះ ។ ធ្វើបែបនេះគឺតុលាការតាំងចិត្តធ្វើការដោះស្រាយវិវាទរវាងភាគីទាំងពីរដោយបង្ខំ ។ នៅក្នុងឧទាហរណ៍ខាងលើ ប្រសិនបើ A ដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ B សងប្រាក់ ១០ លានរៀល មកខ្លួន ដោយអះអាងថា ខ្លួនមានសិទ្ធិទាមទារឱ្យ B បង់ប្រាក់នោះ តុលាការត្រូវស្តាប់ការអះអាងរបស់ភាគីទាំងសងខាងដោយមិនគិតពីឆន្ទៈរបស់ B ទេ ហើយចេញសាលក្រម ។ ប្រសិនបើតុលាការសម្រេចថា ការអះអាងរបស់ A មានភាពត្រឹមត្រូវ ហើយសម្រេចថា B ត្រូវសងប្រាក់ ១០ លានរៀលទៅ A នោះ B ត្រូវតែអនុវត្តតាមសេចក្តីសម្រេចនេះ ។ ប្រព័ន្ធបែបនេះ គេហៅថា ប្រព័ន្ធរឿងក្តីរដ្ឋប្បវេណី ឬ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ។

លើសពីនេះទៅទៀត រដ្ឋបានបង្កើតស្ថាប័នអនុវត្ត ដូចជាអាជ្ញាសាលា ដែលទទួលបន្ទុកក្នុងការសម្រេចសិទ្ធិដោយបង្ខំ ក្នុងគោលដៅការពារសិទ្ធិរបស់បុគ្គលឯកជន ។ ឧទាហរណ៍ នៅក្នុងករណីនៃសិទ្ធិទាមទារប្រាក់ ១០ លានរៀល ដែល A មានចំពោះ B ស្ថាប័នអនុវត្តនឹងធ្វើឱ្យសម្រេចនូវសិទ្ធិនេះ ឱ្យដូចជាក្នុងស្ថានភាពដែល B ស្ម័គ្រចិត្តសងប្រាក់ដែលបានខ្ចីដែរ តាមរយៈការរឹបអូសចលនវត្ថុ អចលនវត្ថុ ឬ សិទ្ធិលើបំណុល ជាអាទិ៍ ដែល B មាន ហើយប្តូរទ្រព្យសម្បត្តិទាំងនោះទៅជាប្រាក់ តាមវិធីផ្សេងៗដូចជាដាក់ដេញថ្លៃ ឬលក់ឡាយឡុង ឬ ទាមទារប្រមូលសិទ្ធិលើបំណុល ជាដើម ហើយបន្ទាប់មក ស្ថាប័នអនុវត្តនឹងដកប្រាក់ចំនួន ១០ លានរៀល ចេញពីប្រាក់ដែលប្រមូលបាននោះ ទៅប្រគល់ឱ្យ A ។ ប្រព័ន្ធបែបនេះ គេហៅថា "ប្រព័ន្ធនៃការអនុវត្តដោយបង្ខំ" ។ នៅក្នុងន័យទូលាយ ប្រព័ន្ធនៃការអនុវត្តដោយបង្ខំនេះ គឺជាផ្នែកមួយនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ។

## កថាភាគទី ២ គោលបំណងនៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី

ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី មានគោលបំណងការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ ។ ក្នុងគោលបំណងនេះ មាត្រា ២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី (ចាប់ពីត្រង់នេះទៅ មាត្រាទាំងឡាយដែលត្រូវបានលើកឡើងដោយមិនបញ្ជាក់ពីឈ្មោះច្បាប់ គឺសំដៅទៅលើមាត្រានៃក្រមនីតិវិធីរដ្ឋប្បវេណី) ចែងថា បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី

ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។ បណ្តឹងរដ្ឋប្បវេណី ដោះស្រាយវិវាទរវាងភាគីដោយបង្ខំ ភាគីដោយផ្ទាល់ ឱ្យគោរពតាមសេចក្តីសម្រេចរបស់តុលាការ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ រដ្ឋបង្កើតប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីនេះឡើង មិនមែនក្នុងគោលបំណងធ្វើការដោះស្រាយវិវាទនោះឯងទេ តែគឺដើម្បីធ្វើការទទួលស្គាល់ តាមរយៈតុលាការ ថា បុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ និង ដើម្បីការពារសិទ្ធិរបស់បុគ្គលនោះ ដោយបញ្ចប់នូវវិវាទ ។ ហេតុដូច្នេះហើយ វាមិនមែនមានន័យថា ការដោះស្រាយវិវាទអាចនាំឱ្យកើតជាលទ្ធផលអ្វី ដល់ភាគីនោះទេ ។ ម្យ៉ាងទៀត នីតិវិធីរដ្ឋប្បវេណីអាចសម្រេចគោលដៅបានលុះត្រាតែមានការដោះស្រាយមួយដ៏ត្រឹមត្រូវ ហើយសិទ្ធិរបស់បុគ្គលដែលជាម្ចាស់សិទ្ធិនោះ ត្រូវបានទទួលស្គាល់ដោយផ្អែកទៅលើច្បាប់ ។

ការការពារសិទ្ធិតាមរយៈនីតិវិធីរដ្ឋប្បវេណីបែបនេះ មិនមែនជាការដាក់ទានពីរដ្ឋទៅឱ្យប្រជាពលរដ្ឋនោះទេ ។ ផ្ទុយទៅវិញ គេត្រូវយល់ថា បុគ្គលឯកជនគ្រប់រូប រួមទាំងប្រជាជនកម្ពុជាផង មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីស្វែងរកការការពារសិទ្ធិរបស់ខ្លួន ល្គឹកណាដែលសិទ្ធិនោះត្រូវបានគេបំពាន នៅក្នុងវិវាទរដ្ឋប្បវេណី ។ ចំណុចនេះ មានចែងនៅក្នុងមាត្រា ២ កថាខណ្ឌទី ២ ។ បើទោះបីជាសិទ្ធិមូលដ្ឋាន និង សិទ្ធិផ្សេងៗទៀត ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និង ច្បាប់ក៏ដោយ តែបើគេពុំអាចស្វែងរកការការពារ និងការសង្គ្រោះនានា តាមរយៈការដាក់ពាក្យបណ្តឹងទៅតុលាការ នៅពេលណាដែលសិទ្ធិនោះត្រូវបានគេបំពានទេនោះ ការទទួលស្គាល់សិទ្ធិនោះនឹងពុំមានអត្ថន័យអ្វីឡើយ ។ អាស្រ័យហេតុនេះហើយ គេអាចនិយាយបានថា សិទ្ធិពឹងពាក់តុលាការ គឺជា "សិទ្ធិមូលដ្ឋាន ដើម្បីធានានូវសិទ្ធិមូលដ្ឋាន និង សិទ្ធិផ្សេងៗទៀត" ។

## កថាភាគទី ៣ គោលការណ៍មូលដ្ឋានសំខាន់ៗនៅក្នុងនីតិវិធីរដ្ឋប្បវេណី

### ១. គោលការណ៍មូលដ្ឋាននៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ

#### (១) ឯករាជ្យភាពនៃអំណាចតុលាការ និង ការធានាក្នុងមុខងាររបស់ចៅក្រម

មាត្រា ១២៨ ថ្មី កថាខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣) (ចាប់ពីត្រង់នេះតទៅ ហៅថារដ្ឋធម្មនុញ្ញ) ចែងថា អំណាចតុលាការ គឺជាអំណាចឯករាជ្យ ហើយមាត្រា ១៣២ ថ្មី ចែងថា ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ដោយសារថា ការដោះស្រាយបណ្តឹងរដ្ឋប្បវេណីគឺជាមុខងារមួយរបស់អង្គការតុលាការ (មាត្រា ១២៨ ថ្មី កថាខណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញ) ចៅក្រមដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងតុលាការ ត្រូវអនុវត្តនូវសិទ្ធិអំណាចរបស់ខ្លួនដោយឯករាជ្យពីការអន្តរាគមន៍នានាពីសំណាក់អាជ្ញាធររដ្ឋ ។ លើសពីនេះទៅទៀត ចៅក្រមត្រូវទទួលការធានានៅក្នុងមុខងាររបស់ខ្លួន គឺមិនអាចត្រូវគេដកពីមុខងារបានទេ លើកលែងតែក្នុងករណីដែលបានប្រព្រឹត្តបទព្រហ្មទណ្ឌ ហើយឧត្តមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យ (មាត្រា ១៣៣ ថ្មី នៃរដ្ឋធម្មនុញ្ញ) ។

ឯករាជ្យភាពនៃអង្គការតុលាការ និង ការធានានៅក្នុងមុខងាររបស់ចៅក្រមនេះ គឺជាផ្នែកមួយនៃគោលការណ៍មូលដ្ឋាននានានៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។

(២) គោលការណ៍នៃការជម្រះក្តីតាមច្បាប់

មាត្រា ១២៩ ថ្មី កថាខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ចែងថា ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និង ច្បាប់ជាធរមាន ។ នេះមានន័យថា ការជម្រះក្តីត្រូវធ្វើឡើង តាមច្បាប់ដែលអនុម័តដោយរដ្ឋសភា ដែលជាតំណាងរបស់ប្រជាពលរដ្ឋកម្ពុជា ដែលជាម្ចាស់នៃប្រទេសកម្ពុជា ហើយការជម្រះក្តី មិនត្រូវធ្វើតាមទំនើងចិត្តរបស់ចៅក្រមឡើយ ។ ហេតុនេះហើយ អាចបកស្រាយបានថា នីតិវិធីនៃការជម្រះក្តី ក៏ត្រូវធ្វើតាមច្បាប់ដែរ ។ ដោយសារថា គោលការណ៍នៃការជម្រះក្តីតាមច្បាប់ ត្រូវយកទៅអនុវត្តនៅក្នុងនីតិវិធីរដ្ឋប្បវេណី គោលការណ៍នេះ ក៏ត្រូវបានចាត់ទុកថាជាគោលការណ៍មូលដ្ឋានមួយនៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញដែរ ។ ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុម័តឡើង ទៅតាមការតម្រូវរបស់រដ្ឋធម្មនុញ្ញ ។

២. ការធានានូវសិទ្ធិទាមទារសវនាការ

ដោយសារថា ភាគីនៃបណ្តឹងរដ្ឋប្បវេណី ត្រូវអនុវត្តទៅតាមសេចក្តីសម្រេចរបស់តុលាការ ហេតុនេះហើយ ប្រសិនបើសេចក្តីសម្រេចនោះមិនមានភាពត្រឹមត្រូវទេ វាអាចនឹងបំពានលើសិទ្ធិរបស់បុគ្គលឯកជន ដោយមិនសមហេតុផល ។ ហេតុដូច្នេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណី ផ្តល់ការធានាដល់សិទ្ធិនីតិវិធីយ៉ាងច្រើនរបស់ភាគីនៃបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុងដំណើរការរឿងក្តី និង អាចការពារផលប្រយោជន៍របស់ខ្លួនបាន ។ សិទ្ធិដែលមានសារៈសំខាន់ជាមូលដ្ឋាន នៅក្នុងចំណោមសិទ្ធិនីតិវិធីនានាទាំងនោះ អាចហៅជាសរុបបានថា "សិទ្ធិមូលដ្ឋាននៃនីតិវិធី" ។

ក្នុងចំណោមសិទ្ធិមូលដ្ឋាននៃនីតិវិធី ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សិទ្ធិនីតិវិធីដែលសំខាន់ជាងគេបំផុត គឺសិទ្ធិទាមទារឱ្យសាកសួរ ។ សិទ្ធិទាមទារឱ្យសាកសួរ គឺជាសិទ្ធិទាមទារឱ្យមានការធានានូវឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលត្រូវសម្រេចសេចក្តីដោយតុលាការនៅក្នុងបណ្តឹងរដ្ឋប្បវេណី និង ក្នុងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀត ។ រដ្ឋ ត្រូវបង្កើតឱ្យមាននូវនីតិវិធីរដ្ឋប្បវេណី ដែលធានានូវឱកាសបែបនេះចំពោះភាគី ។ ជាគោលការណ៍ ឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន និង ឱកាសក្នុងការឆ្លើយតបទៅនឹងមតិយោបល់របស់ភាគីម្ខាងទៀត ត្រូវតែផ្តល់ឱ្យភាគីនៅមុនការសម្រេចសេចក្តី (មាត្រា ៣ កថាខណ្ឌទី ១) ។ ប៉ុន្តែ ក្នុងករណីពិសេសបន្ទាន់ ការសម្រេចសេចក្តីអាចត្រូវបានធ្វើឡើងជាមុន ហើយក្រោយមកទើបអនុញ្ញាតឱ្យស្តាប់មតិយោបល់របស់ភាគី ដែលបានទទួលរងនូវការខូចប្រយោជន៍ដោយសារការសម្រេចសេចក្តីបែបនេះបាន (មាត្រា ៣២៣ កថាខណ្ឌទី ១ និង មាត្រា ៥៤៨ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២ ជាដើម) ។

៣. គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរ ឱ្យមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់ ។ ប្រសិនបើអនុញ្ញាតឱ្យតុលាការអាចកោះហៅភាគីតែម្ខាង ហើយស្តាប់ការអះអាងរបស់ភាគីនោះ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងប៉ះពាល់ទៅដល់ទំនុកចិត្តរបស់ភាគី ទៅលើយុត្តិធម៌នៃការវិនិច្ឆ័យ ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍ តុលាការត្រូវវិនិច្ឆ័យ ដោយគោរពតាមគោលការណ៍ចំពោះមុខ ពោលគឺត្រូវកោះហៅភាគីទាំងសងខាង ឱ្យភាគីទាំងសងខាងថ្លែងពីអំណះអំណាងរបស់ខ្លួន និងជជែកតតាំងគ្នាទៅវិញទៅមក ( មាត្រា ៣ កថាខណ្ឌទី ២) ។ ចំពោះគោលការណ៍ចំពោះមុខនេះ ក៏មានករណីលើកលែងមួយចំនួនដែរ ( មាត្រា ២០០, មាត្រា ២០១, មាត្រា ៣២៣ កថាខណ្ឌទី ១ ជាដើម ។ ម្យ៉ាងទៀត សូមមើលមាត្រា ៥៤៨ កថាខណ្ឌទី ៤) ។

៤. ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

ក្នុងនាមជាអ្នកគ្រប់គ្រងនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវប្រឹងប្រែងធានាឱ្យបានថា រឿងក្តីរដ្ឋប្បវេណីត្រូវបានប្រព្រឹត្តឡើងដោយមានភាពយុត្តិធម៌ និង ឆាប់រហ័ស ។ នេះគឺជាកាតព្វកិច្ចជាមូលដ្ឋានដ៏ចម្បងបំផុតរបស់តុលាការ ។ ដោយឡែក ចំពោះភាគីវិញ ក្នុងខណៈដែលពួកគេត្រូវបានអនុញ្ញាតឱ្យអនុវត្តបណ្តឹងតាមឆន្ទៈរបស់ខ្លួន ដើម្បីឈ្នះក្តី តែពួកគេត្រូវបានហាមឃាត់មិនឱ្យអនុវត្តបណ្តឹងដោយមិនស្មោះត្រង់ និង ដោយទុច្ចរិត ចំពោះភាគីម្ខាងទៀតឡើយ ( មាត្រា ៤) ។ សកម្មភាពបណ្តឹងដែលត្រូវបានចាត់ទុកថាមិនមានភាពស្មោះត្រង់ ត្រូវកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗ ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានចែងនូវបញ្ញត្តិពាក់ព័ន្ធទៅនឹងអានុភាពមិនអំណោយផលមួយចំនួន ដែលកើតចេញពីការមិនគោរពកាតព្វកិច្ចអនុវត្តសកម្មភាពបណ្តឹងដោយស្មោះត្រង់ និង សុចរិត ( មាត្រា ៩៤, មាត្រា ១៤០ កថាខណ្ឌទី ២, មាត្រា ១៥៣ ជាអាទិ៍) ។

៥. ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ដែលជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ហើយភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំអ្នកបកប្រែដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់បាន ។ លើសពីនេះទៅទៀត នៅក្នុងករណីដែលភាគីមិនមានលទ្ធភាពជួលអ្នកបកប្រែដែលមានលក្ខណសម្បត្តិទេ ដោយមូលហេតុថាគាត់ពុំស្គាល់អ្នកបកប្រែដែលមានលក្ខណៈសម្បត្តិ ជាអាទិ៍ តុលាការត្រូវផ្តល់អ្នកបកប្រែដែលមានលក្ខណសម្បត្តិ ឱ្យភាគីនោះ ( មាត្រា ៥) ។ នៅពេលដែលភាគីណាមួយមិនអាចយល់ភាសាខ្មែរបាន ភាគីនោះពុំអាចថ្លែងពីអំណះអំណាងរបស់ខ្លួន និង ពុំអាចតតាំងចំពោះការអះអាងរបស់ភាគីម្ខាងទៀតបានឡើយ ។ ក្នុងន័យនេះ បញ្ញត្តិដែលចែងថា ភាគីនោះអាចជួលអ្នកបកប្រែដោយខ្លួនឯង

ឬ បើពុំអាចទៅរួចទេ តុលាការត្រូវផ្តល់អ្នកបកប្រែឱ្យភាគីនោះ អាចចាត់ទុកជាផ្នែកមួយនៃសិទ្ធិរបស់ភាគីក្នុងការទាមទារឱ្យសាកសួរ ។

៦. ការចូលរួមរបស់តំណាងអយ្យការ

តំណាងអយ្យការ គឺជាអ្នកតំណាងឱ្យផលប្រយោជន៍សាធារណៈ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ក្នុងករណីដែលយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការ អំពីការបានទទួលពាក្យបណ្តឹងរដ្ឋប្បវេណី (មាត្រា ៦ កថាខណ្ឌទី ១) ។ លើសពីនេះទៅទៀត ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ទោះបីជាគ្មានការជូនដំណឹងពីតុលាការក៏ដោយ ក៏តំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី និង បញ្ចេញយោបល់បានដែរ (មាត្រា ៦ កថាខណ្ឌទី ២) ។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់តំណាងអយ្យការ ត្រូវបានកម្រិតត្រឹមតែរឿងក្តីណាដែលមានភាពចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ ។ គួរកត់សំគាល់ថា នៅក្នុងករណីដែលភាគីជាអនីតិជន គឺអ្នកតំណាងដែលច្បាប់បានកំណត់ ដូចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលជាអាទិ៍ ដែលត្រូវដើរតួនាទីជាអ្នកការពារសិទ្ធិក្នុងនីតិវិធីរបស់ភាគី មិនមែនតំណាងអយ្យការឡើយ ។

៧. គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្តី

បន្ថែមពីលើគោលការណ៍នានាដែលបានរៀបរាប់ខាងលើ មានគោលការណ៍ផ្សេងៗទៀតជាច្រើន ពាក់ព័ន្ធទៅនឹងការជម្រះក្តី ដូចជា គោលការណ៍នៃការទាញហេតុផល គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និង គោលការណ៍នៃការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាង ជាអាទិ៍ ។ គោលការណ៍ទាំងនេះ នឹងមានពន្យល់នៅក្នុងផ្នែកនីមួយៗដែលពាក់ព័ន្ធ ។

## ជំពូកទី ២ កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី

### កថាភាគទី ១ កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យជាទម្រង់ និង កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី ក្នុងន័យជាសារធាតុ

ជាទូទៅ កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី សំដៅទៅលើច្បាប់មួយដែលគេដាក់ចំណងជើងថា "ក្រមនីតិវិធីរដ្ឋប្បវេណី" ។ កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី ក្នុងន័យនៃ "ក្រមនីតិវិធីរដ្ឋប្បវេណី" នេះ គេហៅថា "កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យជាទម្រង់" ដែលត្រូវបានបែងចែកដាច់ដោយឡែក ពីកម្រងច្បាប់នីតិវិធីក្នុងន័យជាសារធាតុ ដូចមានពន្យល់នៅខាងក្រោមនេះ ។

ពាក្យថា "កម្រងច្បាប់នីតិវិធីរដ្ឋប្បវេណី" នេះ ក៏ត្រូវបានគេប្រើក្នុងន័យទូលាយជាងនេះទៅទៀតដែរ ដោយសំដៅទៅលើការរៀបចំ និង ការចាត់ចែងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ឬ សំដៅទៅលើបទប្បញ្ញត្តិច្បាប់ទាំងអស់ដែលគ្រប់គ្រងទៅលើរចនាសម្ព័ន្ធ និង មុខងាររបស់នីតិវិធីរដ្ឋប្បវេណី ។ ដោយសារថាកម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យនេះ សំដៅទៅលើច្បាប់ទាំងមូលដែលគ្រប់គ្រងជាសារធាតុទៅលើប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី បើទោះណាជាបទប្បញ្ញត្តិទាំងនោះស្ថិតនៅក្នុងទម្រង់ច្បាប់បែបណាក៏ដោយ ក៏គេអាចហៅវាថាជាកម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យជាសារធាតុ បានដែរ ។ នៅពេលណាដែលកម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីត្រូវបានបកស្រាយតាមន័យជាសារធាតុបែបនេះ វានឹងរួមបញ្ចូលនូវ (១) ច្បាប់ស្ដីពីការរៀបចំតុលាការ ដែលបញ្ញត្តអំពីការរៀបចំស្ថាប័នតុលាការដែលមានសមត្ថកិច្ចក្នុងរឿងក្ដីរដ្ឋប្បវេណី (២) ច្បាប់ស្ដីពីបណ្ដឹងទាក់ទងទៅនឹងឋានៈបុគ្គល ដែលបញ្ញត្តអំពីនីតិវិធីនៃបណ្ដឹងទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ និង សុំកូន ជាអាទិ៍ (៣) ច្បាប់ស្ដីពីតុលាការពាណិជ្ជកម្ម ដែលបញ្ញត្តអំពីវិវាទពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម (៤) ច្បាប់ស្ដីពីក្ស័យធន ដែលបញ្ញត្តអំពីនីតិវិធីនៃការអនុវត្តដែលមានលក្ខណៈទូលំទូលាយ និង ឯកភាព ចំពោះទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលដែលក្ស័យធន ដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុលទាំងអស់ ព្រមទាំងច្បាប់ដទៃផ្សេងទៀត ។ លើសពីនេះទៅទៀត បទប្បញ្ញត្តិស្ដីអំពីភាគីនៃវិវាទ និង សមត្ថកិច្ចរបស់តុលាការ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ក៏ត្រូវបានរាប់បញ្ចូលទៅក្នុងកម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យជាសារធាតុដែរ ។ ផ្ទុយទៅវិញ ចំពោះកម្រងច្បាប់នីតិវិធីរដ្ឋប្បវេណីក្នុងន័យជាទម្រង់វិញ គេអាចនិយាយបានថា វាជាច្បាប់ដែលបញ្ញត្តអំពីនីតិវិធីបីបែបដូចតទៅ ដោយផ្អែកទៅលើខ្លឹមសាររបស់វា : (១) នីតិវិធីនៃបណ្ដឹងដែលមាននីតិវិធីនៃការចេញសាលក្រម ជានីតិវិធីចម្បង ដើម្បីកំណត់ជាស្ថាពរ អំពីអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិនិងកាតព្វកិច្ចរវាងបុគ្គលឯកជន (២) នីតិវិធីនៃការអនុវត្តដោយបង្ខំ ដើម្បីធ្វើឱ្យសម្រេចដោយបង្ខំ នូវសិទ្ធិដែលត្រូវបានកំណត់ជាស្ថាពរ និង (៣) នីតិវិធីនៃការចាត់ចែងរក្សាការពារ ដើម្បីធានានូវការធ្វើឱ្យសម្រេចសិទ្ធិនាពេលអនាគត ។

## កថាភាគទី ២ នីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី

### ១. គោលការណ៍នៃការជម្រះក្ដីដោយផ្អែកតាមច្បាប់នីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី

នីតិឯកជន គឺជាច្បាប់ដែលបញ្ញត្តអំពីទំនាក់ទំនងនៅក្នុងជីវភាពឯកជនរវាងបុគ្គល ។ ច្បាប់ដែលមានលក្ខណៈទូទៅ និងជាមូលដ្ឋានបំផុត នៃនីតិឯកជន គឺក្រមរដ្ឋប្បវេណី ។ ជាបឋម នីតិឯកជន កំណត់អំពីមាត្រដ្ឋានសម្រាប់ឱ្យតុលាការប្រើ ក្នុងការចេញសាលក្រម សាលដីកា ។ ហេតុដូច្នេះ គេអាចនិយាយបានថា នីតិឯកជន បញ្ញត្តអំពីខ្លឹមសារនៃសាលក្រម សាលដីកា ។ ក្នុងន័យនេះ នីតិឯកជន គឺជាបទដ្ឋាននៃការជំនុំជម្រះ ។ នៅក្នុងករណីដែលមានវិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ បានកើតឡើងរវាងបុគ្គលឯកជន ប្រសិនបើតុលាការចេញសេចក្ដីសម្រេចដោយផ្អែកលើនីតិឯកជន នោះបុគ្គលឯកជននឹងដឹងថា ជាការប្រសើរ ពួកគេគួរតែធ្វើសកម្មភាព ដោយគោរពតាមបទបញ្ញត្តិនៃនីតិឯកជន ។ ហេតុដូច្នេះហើយ ជាបន្ទាប់ គេអាចនិយាយបានថា នីតិឯកជនគឺជាក្រមសីលធម៌ដែលកំណត់អំពីមាត្រដ្ឋានសម្រាប់ការធ្វើសកម្មភាពរបស់បុគ្គលឯកជន នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។

អាស្រ័យហេតុនេះហើយ នីតិវិធីរដ្ឋប្បវេណី ត្រូវប្រព្រឹត្តទៅដោយផ្អែកលើនីតិឯកជន ដែលជាមាត្រដ្ឋាននៃការសម្រេចសេចក្ដី ។ ដើម្បីធ្វើឱ្យសម្រេច នូវគោលការណ៍នៃការជម្រះសេចក្ដីដោយផ្អែកលើច្បាប់ ដែលជាគោលការណ៍ទាមទារដោយប្រទេសប្រជាធិបតេយ្យជឿនលឿន ការដែលគ្រាន់តែបង្កើតឱ្យមានក្រមរដ្ឋប្បវេណី និងច្បាប់ឯកជនផ្សេងៗទៀត ដែលជាមាត្រដ្ឋានសម្រាប់ឱ្យតុលាការធ្វើការសម្រេចសេចក្ដី និង ចេញសាលក្រម សាលដីកានោះ ពុំទាន់គ្រប់គ្រាន់នៅឡើយទេ ។ មានតែពេលដែលក្រមនីតិវិធីរដ្ឋប្បវេណី ដែលបញ្ញត្តអំពីរចនាសម្ព័ន្ធ និង មុខងារនៅក្នុងដំណើរការរឿងក្ដីរដ្ឋប្បវេណី ត្រូវបានអនុម័តឡើង ហើយតុលាការចាត់ចែងរឿងក្ដីដោយផ្អែកទៅលើក្រមនេះ តែប៉ុណ្ណោះ ដែលគេអាចធ្វើឱ្យសម្រេច នូវគោលការណ៍នៃការជម្រះសេចក្ដីដោយផ្អែកលើច្បាប់ ដោយលុបបំបាត់ចោលនូវការចាត់ចែងតាមទំនើងចិត្តរបស់ចៅក្រម ។

### ២. មុខងារនៃនីតិឯកជន និង ក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងនីតិវិធីរដ្ឋប្បវេណី

ដូចបានរៀបរាប់ខាងលើ នីតិឯកជន ក៏ដូចជាក្រមនីតិវិធីរដ្ឋប្បវេណី គឺសុទ្ធតែជាបទដ្ឋានដែលបញ្ញត្តអំពីការជម្រះសេចក្ដីក្នុងរឿងរដ្ឋប្បវេណី ហើយច្បាប់ទាំងពីរនេះ ត្រូវរួមគ្នាធ្វើឱ្យសម្រេច និង ធានានូវគោលការណ៍នៃការជម្រះសេចក្ដីដោយផ្អែកលើច្បាប់ ។ ក្នុងខណៈដែលនីតិឯកជន ដូចជាច្បាប់រដ្ឋប្បវេណី ត្រូវបានតុលាការយកទៅអនុវត្តជាមាត្រដ្ឋានក្នុងការសម្រេចអំពីខ្លឹមសារនៃសារធាតុរបស់រឿងក្ដីដែលត្រូវជំនុំជម្រះ ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានចាត់ទុកជាមាត្រដ្ឋាននៃទម្រង់ការ និង នីតិវិធី ដែលតុលាការត្រូវអនុវត្តតាម នៅក្នុងការចេញសេចក្ដីសម្រេច ។ ដោយផ្អែកទៅលើមុខងាររបស់វានៅក្នុងនីតិវិធីរដ្ឋប្បវេណី គេហៅនីតិឯកជន ដែលរួមមានក្រមរដ្ឋប្បវេណី ថាជាច្បាប់សារធាតុ ចំណែកឯក្រមនីតិវិធីរដ្ឋប្បវេណីវិញ គេហៅថាច្បាប់ទម្រង់ការ ឬ ច្បាប់នីតិវិធី ។

ច្បាប់សារធាតុ និង ច្បាប់នីតិវិធី គឺដូចជាកង់រថយន្ត ដែលត្រូវរួមគ្នាធ្វើឱ្យសម្រេចនូវគោលដៅនៃប្រព័ន្ធរឿងក្តីរដ្ឋប្បវេណី ក្នុងការដោះស្រាយវិវាទ និងការការពារសិទ្ធិរបស់បុគ្គលឯកជន ។

## កថាភាគទី ៣ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ដោយផ្អែកទៅលើកិច្ចព្រមព្រៀងស្តីពីជំនួយរវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលជប៉ុន ដែលបានចុះហត្ថលេខាកាលពីខែមីនា ឆ្នាំ ១៩៩៩ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានរៀបចំតាក់តែងឡើង ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងក្រុមការងារដែលត្រូវបានបង្កើតឡើងនៅក្នុងក្រសួងយុត្តិធម៌កម្ពុជា និង ក្រុមការងារមួយទៀតនៅប្រទេសជប៉ុន ដែលទទួលបន្ទុកតាក់តែងសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា និង ដែលត្រូវបានបង្កើតឡើង តាមការចាត់ចែងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។ ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុម័តនៅឆ្នាំ ២០០៦ ដោយផ្អែកលើខ្លឹមសារនៃសេចក្តីព្រាងចុងក្រោយនៃក្រមនេះ ដែលបានបញ្ចប់កាលពីឆ្នាំ ២០០៣ ។ ជាមួយនឹងចក្ខុវិស័យរយៈពេលវែង ដែលមានតាំងពីការចាប់ផ្តើមដំបូងនៃដំណើរការនៃការតាក់តែងដោយក្រុមការងារទាំងពីរ ក្រសួងយុត្តិធម៌កម្ពុជា មានគោលបំណងអនុម័តក្រមនីតិវិធីរដ្ឋប្បវេណីមួយដែលមានស្តង់ដារខ្ពស់ និងមានលក្ខណៈប្រកួតប្រជែង ដែលអាចទទួលបាននូវការវាយតម្លៃជាអន្តរជាតិ នៅក្នុងរយៈពេលពីរ បី ទសវត្សរ៍ខាងមុខនេះ ។

នៅពេលចាប់ផ្តើមដំណើរការនៃការតាក់តែងសេចក្តីព្រាងក្រមនេះ ក្រុមការងារទាំងពីរ បានពិភាក្សាគ្នាអំពីវិធានទូទៅក្នុងការកសាងប្រព័ន្ធរឿងក្តីរដ្ឋប្បវេណី ហើយបានព្រមព្រៀងគ្នាទៅលើសមាសភាពតាមគន្លឹនីមួយៗនៃក្រម ។ ចំពោះការតាក់តែងបញ្ញត្តិនីមួយៗ ជាដំបូង ក្រុមការងារជប៉ុនបានរៀបចំសេចក្តីព្រាងដើមម្តងម្តៃសាមសិបមាត្រា ហើយបន្ទាប់មក ក្រុមការងារទាំងពីរបានធ្វើការពិនិត្យរួមគ្នាទៅលើសេចក្តីព្រាងនោះ ម្តងមួយៗ តាមរយៈសិក្ខាសាលានៃក្រុមការងារទាំងពីរ ។ ហេតុដូច្នេះហើយ សេចក្តីព្រាងចុងក្រោយនៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ បានទទួលឥទ្ធិពលយ៉ាងខ្លាំង ពីក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន (អនុម័តនៅឆ្នាំ ១៩៩៦) ច្បាប់ស្តីពីការអនុវត្តផ្នែករដ្ឋប្បវេណីជប៉ុន (អនុម័តនៅឆ្នាំ ១៩៧៩) និង ច្បាប់ស្តីពីការចាត់ចែងរក្សាការពាររដ្ឋប្បវេណីជប៉ុន (អនុម័តនៅឆ្នាំ ១៩៨៩) ។ ប៉ុន្តែ ទន្ទឹមគ្នានេះ សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីនេះក៏ឆ្លុះបញ្ចាំងអំពីកម្រិតយល់ដឹងផ្នែកច្បាប់របស់ប្រជាជនកម្ពុជា ក៏ដូចជាប្រពៃណី និង ស្ថានភាពនៃប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជាផងដែរ ។ តាមរយៈការពិនិត្យឡើងវិញដោយក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និង តាមរយៈការពិភាក្សាសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី សេចក្តីព្រាងក្រមនេះ ត្រូវបានបញ្ជូនទៅរដ្ឋសភា ហើយរដ្ឋសភាបានអនុម័ត ដោយពុំមានកែប្រែអ្វីក្រៅពីពាក្យ និង ប្រយោគមួយចំនួនតែប៉ុណ្ណោះ ។ តាមរយៈដំណើរការបែបនេះ ក្រមនីតិវិធីរដ្ឋប្បវេណីទំនើបមួយ ដែលស្របតាមមាត្រដ្ឋានអន្តរជាតិ ត្រូវបាន

បង្កើតឡើងតាមការស្នើសុំរបស់ក្រសួងយុត្តិធម៌កម្ពុជា ។

# គន្ថីទី ២ ប្រធាននៃបណ្តឹង

## ជំពូកទី ១ តុលាការ

### កថាភាគទី ១ សិទ្ធិជម្រះក្តី និង សមត្ថកិច្ច

១. សិទ្ធិជម្រះក្តី

បណ្តឹងរដ្ឋប្បវេណី ត្រូវដឹកនាំដោយសកម្មភាពនៃអំណាចតុលាការរបស់រដ្ឋមួយ ដែលត្រូវបានប្រគល់ទៅឱ្យតុលាការ តាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ (រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២៨ ថ្មី) ។ ក្នុងចំណោមអំណាចតុលាការ មុខងារធ្វើការវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី និង ការសម្រេចសេចក្តី គេអាចហៅថា សិទ្ធិជម្រះក្តីរដ្ឋប្បវេណី ។ សាលក្រម ឬ សាលដីកាដែលធ្វើឡើងដោយតុលាការ ត្រូវចងភាគីទាំងសងខាង នេះគឺដោយផ្អែកទៅលើការទទួលស្គាល់នូវសិទ្ធិជម្រះក្តីរបស់តុលាការ ហើយតុលាការអាចកោះហៅតតិយជនមកសាកសួរជាសាក្សី ឬ ជាអ្នកធ្វើកោសលវិច័យ ក៏ដោយសារតែសិទ្ធិជម្រះក្តីនេះដែរ ។ ជាគោលការណ៍ សិទ្ធិជម្រះក្តី គ្របដណ្តប់ទៅលើបុគ្គលគ្រប់រូប និង ទៅលើវត្ថុទាំងអស់ដែលនៅលើដែនដីកម្ពុជា ។ ក៏ប៉ុន្តែ សិទ្ធិជម្រះក្តីរបស់ព្រះរាជាណាចក្រកម្ពុជា ពុំមានអានុភាពទៅលើជនដែលត្រូវបានទទួលស្គាល់នូវអភ័យឯកសិទ្ធិ តាមច្បាប់អន្តរជាតិ ដូចជាគណៈប្រតិភូការបរទេស ព្រមទាំងសមាជិក និង ក្រុមគ្រួសារដែលអមតាមនោះទេ លើកលែងតែក្នុងករណីដែលប្រទេសដែលបានបញ្ជូនគណៈប្រតិភូនោះ បានបោះបង់ចោលនូវអភ័យឯកសិទ្ធិរបស់គេ ។

២. សមត្ថកិច្ចសាលាជំនុំជម្រះ

សិទ្ធិជម្រះក្តី គឺជាសិទ្ធិអំណាចដែលត្រូវបានប្រគល់ទាំងស្រុងទៅឱ្យតុលាការទាំងមូល ហើយតុលាការដែលជាអង្គភាពរដ្ឋដែលអនុវត្តសិទ្ធិជម្រះក្តីនេះ ត្រូវបានបែងចែកជា តុលាការកំពូល (មានតែមួយសម្រាប់ទូទាំងប្រទេស) សាលាឧទ្ធរណ៍ និង សាលាដំបូង (សូមមើលសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងតុលាការ មាត្រា ១) ហើយតុលាការប្រភេទដូចគ្នាមានច្រើនកន្លែង ។ ការកំណត់ស្តីពីការបែងចែកបន្ទុកក្នុងការអនុវត្តសិទ្ធិជម្រះក្តីនៃតុលាការប្រភេទខុសគ្នា ឬ តុលាការដែលមានប្រភេទដូចគ្នា តែច្រើនកន្លែងនោះ មានន័យថា ការកំណត់នូវការបែងចែកបន្ទុកនៃសិទ្ធិជម្រះក្តីរដ្ឋប្បវេណី គេហៅថា សមត្ថកិច្ចជំនុំជម្រះរបស់តុលាការ ។ បើមើលពីតុលាការ ទំហំនៃសិទ្ធិអំណាចដែលអាចអនុវត្តសិទ្ធិជម្រះក្តី គេហៅថា សមត្ថកិច្ច ហើយបើមើលពីករណីពិសេសណាមួយវិញ តុលាការដែលអាចចាត់ចែងរឿងក្តីនោះ គេហៅថា "តុលាការដែលមានសមត្ថកិច្ច" (មាត្រា ៧) ។

### កថាភាគទី ២ ប្រភេទនៃសមត្ថកិច្ចរបស់តុលាការ

សមត្ថកិច្ច អាចបែងចែកតាមទស្សនៈផ្សេងៗបាន ។ មានន័យថា (១) បើមើលពីទស្សនៈថា តើសមត្ថកិច្ច

ត្រូវបានកំណត់ដោយបទដ្ឋានអ្វីខ្លះនោះវិញ គឺគេបែងចែកជា សមត្ថកិច្ចតាមភារកិច្ច និង សមត្ថកិច្ចតាមដែនដី ម្យ៉ាងទៀត (២) មានការបែងចែកទៅតាមមូលហេតុដែលកំណត់សមត្ថកិច្ច ឬ មូលហេតុដែលបង្កើតសមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចដែលច្បាប់បានកំណត់ សមត្ថកិច្ចដែលត្រូវបានកំណត់ដោយតុលាការថ្នាក់លើ សមត្ថកិច្ចតាមការព្រមព្រៀង និង សមត្ថកិច្ចជម្រះក្តីដែលបានកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ ។ លើសពីនេះ សមត្ថកិច្ចដែលច្បាប់បានកំណត់ អាចបែងចែកជាពីរប្រភេទទៀត ដោយយោងតាមការអាចអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យប្តូរសមត្ថកិច្ចដោយឆន្ទៈរបស់ភាគី គឺ សមត្ថកិច្ចមិនផ្តាច់មុខ និង សមត្ថកិច្ចផ្តាច់មុខ ។

១. សមត្ថកិច្ចតាមភារកិច្ច

សមត្ថកិច្ចតាមភារកិច្ច គឺជាការកំណត់នូវការទទួលបន្ទុកតាមមុខងារនៃសិទ្ធិជម្រះក្តីនៃតុលាការប្រភេទនីមួយៗ ទៅតាមភាពខុសគ្នានៃមុខងារនៃសិទ្ធិជម្រះក្តី ។ ប្រសិនបើមើលពីទស្សនៈ នៃនីតិវិធីដែលជាការអនុវត្តសិទ្ធិជម្រះក្តីវិញ នេះគឺជាការបែងចែកនូវសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធី ដែលមានខ្លឹមសារថា តើឱ្យតុលាការណាដឹកនាំនីតិវិធីប្រភេទណា ។

ឧទាហរណ៍ សិទ្ធិជម្រះក្តីរដ្ឋប្បវេណីរបស់រដ្ឋ អាចបែងចែកជាបឋមទៅតាមបន្ទុក គឺ ស្ថាប័នជម្រះក្តីដែលទទួលបន្ទុកនូវនីតិវិធីចេញសាលក្រម ឬ សាលដីកា (តុលាការដែលទទួលបណ្តឹង) និង ស្ថាប័នជម្រះក្តីដែលទទួលបន្ទុកនូវនីតិវិធីអនុវត្តដោយបង្ខំ (តុលាការអនុវត្ត, មាត្រា ៣៣៦) ។ នេះគឺជាសមត្ថកិច្ចតាមភារកិច្ចមូលដ្ឋានមួយ ។

បន្ទាប់មក នៅតុលាការទទួលបណ្តឹងដែលទទួលបន្ទុកអំពីនីតិវិធីចេញសាលក្រម ក៏មានការបែងចែកនូវសិទ្ធិជម្រះក្តីទៅតាមមុខងារដែរ ។ យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មានចែងអំពីរបបប្តឹងបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយប្រព័ន្ធវិនិច្ឆ័យបីថ្នាក់ ដូច្នេះមានការអនុញ្ញាតឱ្យប្តឹងឧបាស្រ័យចំពោះសាលក្រម ឬ សាលដីកាបាន ។ ដូច្នេះ ត្រូវកំណត់ថា តើតុលាការណាទទួលខុសត្រូវនីតិវិធីបណ្តឹងនៃការជម្រះក្តីលើកទីមួយ តើតុលាការណាទទួលខុសត្រូវនីតិវិធីនៃបណ្តឹងនៃការជម្រះក្តីលើកទីពីរ ឬ លើកទីបី ។ ការកំណត់នេះគេហៅថា សមត្ថកិច្ចតាមថ្នាក់នៃការជំនុំជម្រះ ។ សមត្ថកិច្ចតាមថ្នាក់នៃការជំនុំជម្រះ ក៏ជាសមត្ថកិច្ចតាមភារកិច្ចមួយដែរ ។

២. សមត្ថកិច្ចតាមដែនដី

(១) អត្ថន័យនៃសមត្ថកិច្ចតាមដែនដី

សមត្ថកិច្ចតាមដែនដី គឺជាការកំណត់ដូចជា ក្នុងចំណោមតុលាការច្រើនដែលមានប្រភេទដូចគ្នា តែទីតាំងខុសគ្នា តើតុលាការណាមួយត្រូវទទួលបន្ទុកនូវសិទ្ធិជម្រះក្តីប្រភេទដូចគ្នា ។ សមត្ថកិច្ចតាមដែនដី ត្រូវបានកំណត់ ដោយផ្អែកលើបទដ្ឋានដើម្បីវិនិច្ឆ័យថា តើរឿងក្តីមួយមានទំនាក់ទំនងជិតស្និទ្ធនឹងទីកន្លែងណាមួយនៃតំបន់ដែលនៅក្រោមសមត្ថកិច្ចរបស់តុលាការណាមួយ ដោយបែងចែកដែនដីនៃប្រទេសទាំងមូលជាតំបន់ៗ

ជាមុន ឱ្យមានចំនួនស្មើនឹងចំនួនតុលាការប្រភេទដូចគ្នា ហើយតុលាការនីមួយៗត្រូវទទួលបន្ទុកតំបន់មួយនោះ ។ មានន័យថា តុលាការដែលមានតំបន់សមត្ថកិច្ចដែលនៅក្នុងនោះមានទីកន្លែងនោះ នឹងមានសមត្ថកិច្ចតាមដែនដីស្តីពីរឿងក្តីនោះ ។

(២) ប្រភេទនៃសមត្ថកិច្ចតាមដែនដី

(ក) សមត្ថកិច្ចទូទៅដែលបានកំណត់ទៅតាមលំនៅឋាន ជាអាទិ៍ (មាត្រា ៨)

បណ្តឹងអាចត្រូវបានដាក់ទៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីកន្លែង ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៨ ចំណុច ក ដូចជាលំនៅឋានរបស់ចុងចម្លើយ ជាអាទិ៍ ប្រសិនបើចុងចម្លើយជារូបវន្តបុគ្គល ឬ អាចត្រូវបានដាក់ទៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីកន្លែង ដែលបានកំណត់នៅក្នុងមាត្រា ៨ ចំណុច ខ ដូចជាទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ជាអាទិ៍ ប្រសិនបើចុងចម្លើយជានីតិបុគ្គលកម្ពុជា ឬ អាចត្រូវបានដាក់ទៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីកន្លែង ដែលបានកំណត់នៅក្នុងមាត្រា ៨ ចំណុច គ ដូចជាទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បងក្នុងប្រទេសកម្ពុជា ប្រសិនបើចុងចម្លើយជានីតិបុគ្គលបរទេស ដោយពុំចាំបាច់គិតអំពីខ្លឹមសារ ឬ លក្ខណៈនៃរឿងក្តីនោះឡើយ ។

នេះគឺដើម្បីការពារផលប្រយោជន៍ក្នុងការឆ្លើយតប និង ការការពារខ្លួនរបស់ចុងចម្លើយដែលជាប់ខ្លួនក្នុងបណ្តឹង ដោយគិតដល់ផលប្រយោជន៍នៃការឆ្លើយតបរបស់ចុងចម្លើយ ។

(ខ) សមត្ថកិច្ចពិសេសដែលបានកំណត់ទៅតាមទីកន្លែងត្រូវអនុវត្តកាតព្វកិច្ច ឬ ទីកន្លែងនៃទ្រព្យសម្បត្តិ ជាអាទិ៍ (មាត្រា ៩)

គឺជាសមត្ថកិច្ចដែលគេទទួលស្គាល់ ដោយប្រជែងនឹងសមត្ថកិច្ចដែលមានពន្យល់ក្នុង (ក) ខាងលើនេះ ដោយគិតដល់ខ្លឹមសារនៃរឿងក្តី ជាដើម ។ ក្នុងករណីដែលមានតុលាការច្រើនដែលមានសមត្ថកិច្ចស្តីពីរឿងក្តីនោះ ដូចជាសមត្ថកិច្ចដែលត្រូវបានទទួលស្គាល់ដោយយោងតាមមាត្រា ៨ ឬ សមត្ថកិច្ចដែលត្រូវបានទទួលស្គាល់ដោយយោងតាមចំណុចនីមួយៗ នៃមាត្រា ៩ ជនដែលមានគោលបំណងចង់ដាក់បណ្តឹង អាចជ្រើសរើសតុលាការណាមួយពីក្នុងចំណោមតុលាការទាំងនោះដោយសេរីបាន ។ សមត្ថកិច្ចដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃមាត្រា ៩ ត្រូវបានកំណត់ ដោយគិតដល់ទំនាក់ទំនងរវាងទីកន្លែង និង សកម្មភាពជំនួញ ឬ អំពើអនីត្យានុកូលរបស់ចុងចម្លើយ ដើម្បផ្តល់នូវផលប្រយោជន៍ក្នុងការឆ្លើយតបរបស់ចុងចម្លើយ ឬ សម្រួលក្នុងការវិនិច្ឆ័យបណ្តឹង តាមរយៈចំណងទៅនឹងទីកន្លែងនៃភស្តុតាង ។

(គ) សមត្ថកិច្ចលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (មាត្រា ១០)

ក្នុងចំណោមបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បណ្តឹងសុំលែងលះគ្នា និង បណ្តឹងសុំបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុត្តភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខ របស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅឋាននាពេលដែលភាគីនោះទទួល

មរណភាពនោះ ។ មូលហេតុដែលមានមាត្រា ១០ នេះគឺមានដូចតទៅ : មានន័យថា ពេលក្រមនីតិវិធីរដ្ឋប្បវេណីចូលជាធរមាន គន្លឹស្តីពីញាតិ និង សន្តតិកម្មនៃក្រមរដ្ឋប្បវេណី មិនទាន់ចូលជាធរមានទេ ហេតុនេះហើយបានជាបានចែងនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដោយបំបែកពីក្រមនីតិវិធីរដ្ឋប្បវេណី ទៅដាក់បញ្ចូលទៅក្នុង "ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល" ដែលមានគម្រោងនឹងអនុម័ត ពេលក្រោយដើម្បីតម្រូវទៅនឹងដំណើរនៃសកម្មភាពតាក់តែងក្រមរដ្ឋប្បវេណី ។ ក៏ប៉ុន្តែ ក្នុងចំណោមបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បណ្តឹងដែលនឹងមានច្រើនជាងគេគឺបណ្តឹងលែងលះគ្នា និង បណ្តឹងបញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃបុត្តភាព ហេតុនេះហើយបានជាបានកំណត់អំពីតុលាការដែលមានសមត្ថកិច្ចនៃបណ្តឹងទាំងនេះ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាមុន ។ ដូច្នេះហើយបានជា នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលនឹងតាក់តែងក្រោយពីនោះ មានបញ្ញត្តិចែងអំពីសមត្ថកិច្ចស្តីពីរឿងក្តីទាក់ទងនឹងឋានៈបុគ្គលទូទៅ (សូមមើលសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៤) ។

សមត្ថកិច្ចលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល គឺជាសមត្ថកិច្ចផ្តាច់មុខ (នឹងពន្យល់ស្តីពីសមត្ថកិច្ចផ្តាច់មុខ ខាងក្រោយ) ដូច្នេះហើយ មិនអាចដាក់ពាក្យបណ្តឹងទៅតុលាការ ក្រៅពីតុលាការដែលបានកំណត់ក្នុងនេះឡើយ ។

(ឃ) សមត្ថកិច្ចលើរឿងក្តីដែលពាក់ព័ន្ធ (មាត្រា ១១, មាត្រា ៥១ កថាខណ្ឌទី ១)

សមត្ថកិច្ចលើរឿងក្តីដែលពាក់ព័ន្ធ គឺជាសមត្ថកិច្ចដែលត្រូវបានទទួលស្គាល់ចំពោះតុលាការដែលមានទំនាក់ទំនងនឹងរឿងក្តីនេះ ដោយផ្អែកទៅលើការមានទំនាក់ទំនងនឹងរឿងក្តីផ្សេង ។ ឧទាហរណ៍ដូចជា ពាក់ព័ន្ធនឹងការទាមទារនៃរឿងក្តីមួយដែលបានធ្វើឡើងដោយការរួមបញ្ចូលនឹងការទាមទារនៃរឿងក្តីផ្សេង ករណីដែលមានការទទួលស្គាល់នូវសមត្ថកិច្ចស្តីពីការទាមទារមួយទៀត ចំពោះតុលាការដែលមានតែសមត្ថកិច្ចនៃការទាមទារផ្សេងពីនេះ (មាត្រា ១១) ឬ ករណីដែលទទួលស្គាល់នូវសមត្ថកិច្ចលើបណ្តឹងដែលយកដើមចោទ និងចុងចម្លើយក្នុងរឿងក្តីផ្សេង មកធ្វើជាសហចុងចម្លើយ (មាត្រា ៥១ កថាខណ្ឌទី ១) ជាអាទិ៍ ។

(៣) តុលាការដែលមានសមត្ថកិច្ចតាមដែនដីលើបណ្តឹងនៅក្នុងករណីឧទាហរណ៍

នៅក្នុងករណីឧទាហរណ៍ដើមនេះ ឧទាហរណ៍ ប្រសិនបើលំនៅឋានរបស់ចុងចម្លើយ B គឺក្រុង X រីឯទីកន្លែងអនុវត្តកាតព្វកិច្ចគឺនៅក្រុង Y ដែលមានលំនៅឋានរបស់ដើមចោទ A (សូមមើលក្រមរដ្ឋប្បវេណី មាត្រា ៤៤៥ វាក្យខណ្ឌទី ១) ស្តីពីបណ្តឹងរបស់ A នេះ សាលាដំបូងដែលមានសមត្ថកិច្ចនៅក្រុង X ព្រមទាំងសាលាដំបូងដែលមានសមត្ថកិច្ចនៅក្រុង Y ទាំងពីរ មានសមត្ថកិច្ច (សមត្ថកិច្ចតាមដែនដី) ក្នុងរឿងក្តីនេះ ។ ហេតុដូច្នេះ A មានសេរីភាពក្នុងការជ្រើសរើសតុលាការដែលត្រូវដាក់បណ្តឹងនេះ ។

៣. សមត្ថកិច្ចដែលត្រូវបានកំណត់ដោយតុលាការថ្នាក់លើ

ដូចដែលបានពន្យល់ខាងលើនេះ សមត្ថកិច្ចត្រូវបានកំណត់ដោយច្បាប់ ក៏ប៉ុន្តែ ក្នុងករណីដែលមិនច្បាស់លាស់ស្តីពីសមត្ថកិច្ចនៃរឿងក្តីជាក់ស្តែងណាមួយ ឬ ក្នុងករណីដែល ទោះជាតុលាការដែលមានសមត្ថកិច្ច ត្រូវ

បានកំណត់ក៏ដោយ ក៏ប៉ុន្តែជួនជាតុលាការពុំអាចអនុវត្តសិទ្ធិជម្រះក្តីរបស់ខ្លួន ដោយសារតែមានឧបសគ្គដោយសារច្បាប់ ឬ ដោយសារហេតុការណ៍ពិតនោះ តុលាការមានសមត្ថកិច្ចត្រូវកំណត់ដោយតុលាការកំពូលដោយដីកាសម្រេច (មាត្រា ១២) ។ នេះគេហៅថា ការកំណត់សមត្ថកិច្ច ហើយសមត្ថកិច្ចដែលកើតឡើងដោយការកំណត់នេះ គេហៅថា សមត្ថកិច្ចកំណត់ដោយតុលាការថ្នាក់លើ (មាត្រា ១២) ។

៤. សមត្ថកិច្ចផ្តាច់មុខ និង សមត្ថកិច្ចមិនផ្តាច់មុខ

ជាទូទៅ សមត្ថកិច្ចត្រូវបានកំណត់ដោយបញ្ញត្តិច្បាប់ ក៏ប៉ុន្តែ ក្នុងចំណោមសមត្ថកិច្ចដែលកំណត់ដោយបញ្ញត្តិច្បាប់ (សមត្ថកិច្ចដែលច្បាប់បានកំណត់) ជាពិសេស ដោយសារមូលហេតុនៃផលប្រយោជន៍សាធារណៈដូចជាភាពចាំបាច់ដោះស្រាយរឿងក្តីនោះឱ្យបានទាន់ពេលវេលា និង ឱ្យបានត្រឹមត្រូវ ជាអាទិ៍ មានករណីខ្លះដែលមានតែតុលាការណាមួយមានសមត្ថកិច្ច ដោយមិនទទួលស្គាល់សមត្ថកិច្ចរបស់តុលាការផ្សេងទៀត ហើយដែលមិនអនុញ្ញាតឱ្យភាគីផ្តល់សមត្ថកិច្ចទៅតុលាការណាមួយដោយឆន្ទៈរបស់ខ្លួន (សូមមើលមាត្រា ១៥) ។ សមត្ថកិច្ចនៃករណីប្រភេទនេះ គេហៅថា សមត្ថកិច្ចផ្តាច់មុខ ។ ក្រៅពីនេះ សមត្ថកិច្ចនៃករណីដែលអនុញ្ញាតឱ្យផ្តល់សមត្ថកិច្ចដល់តុលាការផ្សេង ដោយកំណត់ជាពិសេសទៅតាមទស្សនៈនៃសមភាព និង សម្រាប់បម្រើផលប្រយោជន៍ដល់ភាគី ហើយដែលអនុញ្ញាតឱ្យភាគីផ្តល់សមត្ថកិច្ចទៅតុលាការផ្សេង ដោយប្តូរផ្សេងពីការកំណត់នៃច្បាប់ តាមការព្រមព្រៀង ជាអាទិ៍គេហៅថា សមត្ថកិច្ចមិនផ្តាច់មុខ ។ តាមលក្ខណៈនៃរឿងក្តីរដ្ឋប្បវេណី ជាគោលការណ៍ សមត្ថកិច្ចស្តីពីរឿងក្តីនេះ គឺជាសមត្ថកិច្ចមិនផ្តាច់មុខ រីឯសមត្ថកិច្ចផ្តាច់មុខមានតែសម្រាប់ករណីដែលបានពន្យល់ក្នុង ១. ខាងលើនេះ ដែលជាសមត្ថកិច្ចតាមភារកិច្ច (ការកំណត់ស្តីពីការបែងចែកបន្ទុកដោយផ្អែកលើសកម្មភាពនៃការជម្រះក្តី) និង សម្រាប់ករណីដែលមានការកំណត់អំពីសមត្ថកិច្ចផ្តាច់មុខពិសេស នៅក្នុងច្បាប់ ។ ឧទាហរណ៍ដែលមានការកំណត់នូវសមត្ថកិច្ចផ្តាច់មុខ មានដូចជា បណ្តឹងលែងលះគ្នា និង បណ្តឹងបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃបុត្តភាព (មាត្រា ១០ កថាខណ្ឌទី ១) បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ៣០៩ កថាខណ្ឌទី ១) នីតិវិធីដាស់តឿន (មាត្រា ៣២០ កថាខណ្ឌទី ៣) សមត្ថកិច្ចនៃតុលាការពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំ (មាត្រា ៣៤៦) និង សមត្ថកិច្ចនៃតុលាការពាក់ព័ន្ធនឹងការរក្សាការពារ (មាត្រា ៥៣៣) ជាអាទិ៍ ។

៥. សមត្ថកិច្ចតាមការព្រមព្រៀង និង សមត្ថកិច្ចដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ

(១) សមត្ថកិច្ចតាមការព្រមព្រៀង

ការកំណត់សមត្ថកិច្ចខុសពីសមត្ថកិច្ចមិនផ្តាច់មុខ ដោយការព្រមព្រៀងរបស់ភាគី គេហៅថា ការព្រមព្រៀងអំពីសមត្ថកិច្ច ហើយសមត្ថកិច្ចដែលកើតមានឡើងដោយសារការព្រមព្រៀងនេះ គេហៅថា សមត្ថកិច្ចតាមការព្រមព្រៀង ។ ដើម្បីឱ្យមានការទទួលស្គាល់អំពីការព្រមព្រៀងស្តីពីសមត្ថកិច្ចនេះ ចាំបាច់ត្រូវ (១) មានការព្រមព្រៀងស្តីពីសមត្ថកិច្ចនៃតុលាការជម្រះក្តីលើកទី ១ (២) ជាអំពើដែលធ្វើឡើងរវាងពាណិជ្ជករ ឬ

រវាងនីតិបុគ្គល ឬ រវាងពាណិជ្ជករ និង នីតិបុគ្គល (៣) ជាបណ្តឹងដែលត្រូវបានធ្វើឡើងដោយផ្អែកលើទំនាក់ទំនងគតិយុត្តកំណត់មួយ (៤) ជាការព្រមព្រៀងដែលបានធ្វើជាលាយលក្ខណ៍អក្សរ (ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា មានការព្រមព្រៀង និង ឱ្យដឹងខ្លឹមសារច្បាស់លាស់) ព្រមទាំង (៥) ពុំមានបញ្ញត្តិអំពីសមត្ថកិច្ចផ្តាច់មុខស្តីពីរឿងក្តីនោះ (មាត្រា ១៣ កថាខណ្ឌទី ១ និង ទី ២, មាត្រា ១៥) ។

ការព្រមព្រៀងនេះត្រូវបានទទួលស្គាល់តែចំពោះសមត្ថកិច្ចតាមដែនដីប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការព្រមព្រៀងស្តីពីសមត្ថកិច្ច ជាការព្រមព្រៀងតាមផ្លូវច្បាប់នីតិវិធី ។ ដូច្នេះ ទោះជាករណីដែលការព្រមព្រៀងអំពីសមត្ថកិច្ចនេះត្រូវបានធ្វើឡើងព្រមគ្នានឹងកិច្ចសន្យាតាមផ្លូវនីតិឯកជនក៏ដោយ ក៏ការបង្កើត និង អានុភាពនៃការព្រមព្រៀងស្តីពីសមត្ថកិច្ចនេះ ក៏ត្រូវវិនិច្ឆ័យតាមទស្សនៈនៃច្បាប់នីតិវិធី ដោយឯករាជ្យ គឺមិនត្រូវឱ្យមានឥទ្ធិពលភ្លាមពីអត្ថិភាព ឬ នត្ថិភាពនៃការបង្កើត ឬ ពីអានុភាពនៃកិច្ចសន្យាតាមផ្លូវនីតិឯកជនឡើយ ។

(២) សមត្ថកិច្ចសាលាជម្រះក្តីដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ

សមត្ថកិច្ចសាលាជម្រះក្តីដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ គឺជាសមត្ថកិច្ចដែលកើតឡើងដោយសកម្មភាពឆ្លើយតបចំពោះបណ្តឹងរបស់ចុងចម្លើយ ។ ចំពោះបណ្តឹងដែលខុសសមត្ថកិច្ចជម្រះក្តី ប្រសិនបើចុងចម្លើយបង្ហាញឆន្ទៈឆ្លើយតបនឹងបណ្តឹង ដោយពុំបានតវ៉ាអំពីសមត្ថកិច្ចនេះ សមត្ថកិច្ចនៃតុលាការនោះ នឹងកើតមានឡើង ។ នេះគេហៅថា សមត្ថកិច្ចសាលាជម្រះក្តីដែលកើតមានឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ ហើយត្រូវបានទទួលស្គាល់តចំពោះសមត្ថកិច្ចមិនផ្តាច់មុខប៉ុណ្ណោះ (មាត្រា ១៤, មាត្រា ១៥) ។ ម្យ៉ាងទៀត សមត្ថកិច្ចសាលាជម្រះក្តីដែលកើតមានឡើងដោយគ្មានការតវ៉ាពីចុងចម្លើយនេះ ត្រូវបានទទួលស្គាល់ចំពោះសមត្ថកិច្ចតាមដែនដី ។

## ៦. ការស្រាវជ្រាវអំពីសមត្ថកិច្ច និង អានុភាពនៃការខុសសមត្ថកិច្ច

ករណីដែលតុលាការមានសមត្ថកិច្ចលើរឿងក្តី គឺជាល័ក្ខខ័ណ្ឌមួយនៃបណ្តឹង (ស្តីពីល័ក្ខខ័ណ្ឌបណ្តឹង សូមមើលការពន្យល់ក្នុងជំពូកទី ៧) ។ ល័ក្ខខ័ណ្ឌបណ្តឹង គឺជាបុរេល័ក្ខខ័ណ្ឌចាំបាច់មួយដើម្បីឱ្យតុលាការចេញសាលក្រមអំពីអង្គសេចក្តី (សាលក្រមដែលបង្ហាញការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ដើមចោទ) ហើយល័ក្ខខ័ណ្ឌនេះមានដូចជា តុលាការត្រូវមានសិទ្ធិជម្រះក្តី និង សមត្ថកិច្ចលើរឿងក្តីនេះ ឬ ការដាក់ពាក្យបណ្តឹងមានសុពលភាព ជាអាទិ៍ ។ ស្តីពីបញ្ហាថា តើមានល័ក្ខខ័ណ្ឌបណ្តឹងនេះដែរឬទេនោះ ជាគោលការណ៍ តុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ។ ស្តីពីការមាន ឬ មិនមានសមត្ថកិច្ច ក៏ដូចគ្នាដែរ តុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ។ ប្រសិនបើមានការចាំបាច់ក្នុងការស្រាវជ្រាវនេះ តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន (មាត្រា ១៦) ។ បញ្ហាមាន ឬ មិនមានសមត្ថកិច្ច ត្រូវកំណត់ដោយយកពេលដាក់ពាក្យបណ្តឹងជាពេលវេលាមូលដ្ឋាន ឧទាហរណ៍ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃលំនៅឋានរបស់ចុងចម្លើយនាពេលដាក់ពាក្យបណ្តឹង (មាត្រា ៨ កថាខណ្ឌទី ១) ទោះជាក្រោយមក

ទៀត មានការផ្លាស់ប្តូរលំនៅឋានរបស់ចុងចម្លើយក៏ដោយ ក៏តុលាការនោះមិនបាត់បង់សមត្ថកិច្ចរបស់ខ្លួនទេ (មាត្រា ១៧) ។

តាមលទ្ធផលនៃការស្រាវជ្រាវនេះ ប្រសិនបើទទួលស្គាល់ថា តុលាការមានសមត្ថកិច្ច តុលាការនោះត្រូវបន្តនីតិវិធីជម្រះក្តីនោះទៅទៀត ។ ប្រសិនបើមានពាក្យសុំផ្ទេរបណ្តឹង ដោយយកមូលហេតុនៃការខុសសមត្ថកិច្ចពីភាគី (មាត្រា ១៨ កថាខណ្ឌទី ១) តុលាការត្រូវលើកចោលពាក្យសុំនោះ ។ ចំពោះដីកាសម្រេចលើកចោលនេះ ភាគីដែលមានការមិនពេញចិត្ត អាចប្តឹងជំទាស់បាន (មាត្រា ២១) ។ ប្រសិនបើភាគីមិនប្តឹងជំទាស់ក្នុងឱកាសនេះទេ ក្រោយពីនោះ ភាគីមិនអាចយកអសមត្ថកិច្ចរបស់សាលាជម្រះក្តីលើកទីមួយមកធ្វើជាមូលហេតុនៃបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមចុងក្រោយបានឡើយ (មាត្រា ២៧៥. លើកលែងតែករណីនៃការខុសនឹងសមត្ថកិច្ចផ្តាច់មុខ) ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការទទួលស្គាល់ថា បណ្តឹងត្រូវបានដាក់ខុសសមត្ថកិច្ច តុលាការត្រូវផ្ទេរបណ្តឹងនោះទៅតុលាការដែលមានសមត្ថកិច្ច (មាត្រា ១៨ កថាខណ្ឌទី ១) ។ ការផ្ទេរបណ្តឹងនេះ តុលាការត្រូវធ្វើដោយដីកាសម្រេច ។ ចំពោះដីកាសម្រេចផ្ទេរនេះ ភាគីដែលមានការមិនពេញចិត្តអាចប្តឹងជំទាស់បាន (មាត្រា ២១) ។

ម្យ៉ាងទៀត ក្រៅពីករណីដែលផ្ទេរបណ្តឹងដោយផ្អែកលើអសមត្ថកិច្ច ដែលបានកំណត់នៅក្នុងមាត្រា ១៨ កថាខណ្ឌទី ១ ការផ្ទេរបណ្តឹងអាចធ្វើទៅបានក្នុងករណីដែលតុលាការយល់ឃើញថា ចាំបាច់ដើម្បីជៀសវាងនូវការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងភាគី (មាត្រា ១៩) ។

## កថាភាគទី ៣ ការចាត់តាំងតុលាការ

### ១. តុលាការក្នុងនាមជាស្ថាប័នរដ្ឋ និង តុលាការក្នុងនាមជាអង្គភាពជម្រះក្តី

ក្នុងការប្រើពាក្យរៀងរាល់ថ្ងៃ ពេលដែលយើងប្រើពាក្យតុលាការ គឺយើងចង់និយាយអំពីស្ថាប័នរដ្ឋ ដែលមានចៅក្រម ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល ជាអាទិ៍ ។ តាមផ្លូវក្រមនីតិវិធីរដ្ឋប្បវេណី តុលាការក្នុងករណីសមត្ថកិច្ចរបស់តុលាការ គេចង់និយាយអំពីតុលាការក្នុងនាមជាស្ថាប័នរដ្ឋនោះតែម្តង ។ ក៏ប៉ុន្តែ តាមផ្លូវក្រមនីតិវិធីរដ្ឋប្បវេណី គេច្រើននិយាយអំពីតុលាការក្នុងនាមជាអង្គភាពជម្រះក្តី ដែលទទួលបន្ទុកក្នុងការជម្រះក្តី និង ការចេញសាលក្រម ឬ សាលដីកានៃរឿងក្តីនីមួយៗ ផ្សេងពីន័យតុលាការដែលបានពន្យល់មុននេះ (មាត្រា ៣ កថាខណ្ឌទី ២, មាត្រា ៤, មាត្រា ៥, មាត្រា ៦ កថាខណ្ឌទី ១, មាត្រា ៣៥ កថាខណ្ឌទី ១ ជាដើម) ។ នេះគេហៅថា តុលាការក្នុងនាមជាអង្គភាពជម្រះក្តី ឬ តុលាការក្នុងន័យចង្អៀត ឬ តុលាការដែលទទួលបណ្តឹង ។

### ២. ការជម្រះក្តីដោយចៅក្រមម្នាក់ និង ការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

ចំពោះរបៀបចាត់តាំងតុលាការក្នុងនាមជាអង្គភាពជម្រះក្តី មានការជម្រះក្តីដោយចៅក្រមម្នាក់ និង ការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។ ការជម្រះក្តីដោយចៅក្រមម្នាក់ គឺជាវិធីចាត់តាំងចៅក្រម

ម្នាក់ជាតុលាការក្នុងនាមជាអង្គភាពជម្រះក្តី រីឯការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម គឺជាវិធីចាត់តាំងចៅក្រមច្រើននាក់ជាតុលាការ ។ ការជម្រះក្តីដោយចៅក្រមម្នាក់ គឺជារបបមួយសមស្របចំពោះការវិនិច្ឆ័យ និង សម្រេចសេចក្តីឱ្យបានឆាប់រហ័ស ស្តីពីរឿងក្តីដែលស្រួលៗ រីឯការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមវិញ គឺជារបបមួយសមស្របចំពោះការវិនិច្ឆ័យ និង សម្រេចសេចក្តីយ៉ាងប្រយ័ត្នដោយចៅក្រមច្រើននាក់ សម្រាប់ករណីសំខាន់ៗ ។

នៅព្រះរាជាណាចក្រកម្ពុជា ការចាត់តាំងអង្គភាពជម្រះក្តីនៅតុលាការកំពូល និង នៅសាលាឧទ្ធរណ៍ នឹងត្រូវបានកំណត់ដោយច្បាប់ស្តីពីការចាត់តាំងតុលាការ ដូច្នេះហើយ ក្រមនីតិវិធីនេះបានកំណត់តែការចាត់តាំងតុលាការនៃរឿងក្តីរដ្ឋប្បវេណី នៅសាលាដំបូងប៉ុណ្ណោះ ។ យោងតាមក្រមនីតិវិធីនេះ ជាគោលការណ៍ នៅសាលាដំបូង ការជម្រះក្តីត្រូវធ្វើឡើងដោយចៅក្រមម្នាក់ ហើយរឿងក្តីដែលត្រូវធ្វើការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម មានតែ (១) រឿងក្តីដែលសិទ្ធិ ឬ ករណីយកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង មានតម្លៃមិនតិចជាង ៥ លានរៀល ហើយតុលាការសម្រេចដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយដីកាសម្រេចថា ត្រូវវិនិច្ឆ័យ និង ជម្រះដោយ ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីស្ថានភាពដូចជា មានភាគីច្រើន ហើយរឿងក្តីនោះមានភាពស្មុគស្មាញ ជាអាទិ៍ និង (២) រឿងក្តីដែលច្បាប់កំណត់ជាពិសេស (មាត្រា ៣០ ជាអាទិ៍) ថា ត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមប៉ុណ្ណោះ (មាត្រា ២៣ កថាខណ្ឌទី ១ និង ទី ២) ។ ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមសម្រាប់ករណីណាក៏ដោយ ក៏មានចំនួនបីនាក់ដែរ ហើយក្នុងនោះ មានម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ (មាត្រា ២៣ កថាខណ្ឌទី ៣) ។

## កថាភាគទី ៤ ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជំទាស់ចិត្តចៅក្រម ជាអាទិ៍

### ១. ការបែងចែករឿងក្តី

ក្នុងករណីដែលបានដាក់ពាក្យបណ្តឹងទៅតុលាការមួយ (តុលាការក្នុងនាមជាស្ថាប័នរដ្ឋ) ការកំណត់ឱ្យក្រុមប្រឹក្សាជំនុំជម្រះណា ឬ ចៅក្រមណា ទទួលបន្ទុកបណ្តឹងនោះ គេហៅថា ការបែងចែករឿងក្តី ។ ការបែងចែករឿងក្តី ត្រូវធ្វើដោយស្វ័យប្រវត្តិ ទៅតាមលំដាប់ដែលប្រធានតុលាការបានកំណត់ជាមុនរៀងរាល់ឆ្នាំ ។ ស្តីពីលំដាប់របស់ចៅក្រមដែលត្រូវជំនួស ក្នុងករណីដែលមានឧបសគ្គ ដូចជា ចៅក្រមដែលបានទទួលបន្ទុករឿងក្តីតាមលំដាប់នោះមានជម្ងឺបន្ទាន់ ជាអាទិ៍ ក៏ដូចគ្នាដែរ (មាត្រា ២៦ កថាខណ្ឌទី ១ និង ទី ២) ។ ការបែងចែករឿងក្តី មិនមែនគ្រាន់តែជានីតិវិធីរដ្ឋបាលប៉ុណ្ណោះទេ គឺជាការកំណត់ឱ្យភាគីទទួលនូវការវិនិច្ឆ័យពីចៅក្រមណាម្នាក់ ដូច្នេះមិនត្រូវធ្វើឡើងដោយទំនើងចិត្តបានឡើយ ។ ការកំណត់ឱ្យភាគីទទួលនូវការវិនិច្ឆ័យពីចៅក្រមណា គឺត្រូវឱ្យមានយុត្តិធម៌ និង សមភាព ហេតុនេះហើយ ការបែងចែករឿងក្តីត្រូវធ្វើឡើង ដោយ

ផ្នែកទៅតាមលំដាប់ដែលប្រធានតុលាការបានកំណត់ជាមុន ។

លំដាប់បែងចែករឿងក្តី និង លំដាប់សម្រាប់ចៅក្រមជំនួស ក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ មិនត្រូវកែឡើយ ក្នុងឆ្នាំសារពើពន្ធនោះ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២៦ កថាខណ្ឌទី ៣ ដូចជាករណីដែលចៅក្រមណាម្នាក់មានការទទួលបន្ទុកកិច្ចការច្រើនជ្រុល ជាដើម ។ ទោះជាប្រធានតុលាការ ក៏ដោយ ក៏មិនអាចកែលំដាប់នោះបានឡើយ ។

២. ការដកហូតសមត្ថកិច្ចជំនុំជម្រះ ការប្តឹងជំទាស់ ការដកខ្លួនរបស់ចៅក្រម

ដើម្បីធានានូវសមភាពនៃការជំនុំជម្រះ ប្រសិនបើចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាក់ក្នុងស្ថានភាពដែល អាចរារាំងសមភាព ចាំបាច់ត្រូវដកចៅក្រមនោះពីការបំពេញមុខងាររបស់ខ្លួន ។

(១) ការដកហូតសមត្ថកិច្ចជំនុំជម្រះ គឺជារបបមួយដែលដកចៅក្រមពីការបំពេញមុខងារ ដោយស្វ័យប្រវត្តិ តាមផ្លូវច្បាប់ ក្នុងករណីដែលមានហេតុដែលប៉ះពាល់ដល់សមភាពដោយធ្ងន់ធ្ងរ ។ ក្នុងករណីដែលមានមូលហេតុ ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៧ កថាខណ្ឌទី ១ ត្រូវដកសមត្ថកិច្ចជំនុំជម្រះ ពីចៅក្រមនោះ ។ ប្រសិនបើមានមូលហេតុទាំងនេះ តែគេមិនបានដឹង ហើយបានចេញសាលក្រម ឬ សាលដីកា ភាគីអាចទាមទារឱ្យលុបចោលនូវសាលក្រម ឬ សាលដីកានោះ ដោយបណ្តឹងសាទុក្ខ ឬ បណ្តឹងសុំឱ្យជំនុំជម្រះ សាជាថ្មីបាន ( មាត្រា ២៨៥ កថាខណ្ឌទី ១ ចំណុចទី ២, មាត្រា ៣០៧ កថាខណ្ឌ ទី ១ ចំណុចទី ២) ។

(២) ការប្តឹងជំទាស់ គឺជារបបដកចៅក្រមណាម្នាក់ពីការបំពេញមុខងាររបស់ខ្លួន ក្នុងករណីដែលចៅក្រម ទទួលបន្ទុករឿងក្តីនោះ ពុំមានបញ្ហាធ្ងន់ធ្ងររហូតដល់អាចជាមូលហេតុដែលត្រូវដកហូតសមត្ថកិច្ចជំនុំជម្រះទេ ក៏ប៉ុន្តែ មានបញ្ហាដែលអាចរារាំងសមភាពក្នុងការជំនុំជម្រះ ហើយប្រសិនបើភាគីបានដាក់ពាក្យសុំដោយលើក យកមូលហេតុនោះឡើង ( មាត្រា ២៨) ។

(៣) ការដកខ្លួនរបស់ចៅក្រម គឺជារបបមួយដែលចៅក្រមលាលែងពីការបំពេញមុខងាររបស់ខ្លួន ដោយ ទទួលនូវការអនុញ្ញាតពីប្រធានតុលាការ ក្នុងករណីដែលបានដឹងខ្លួនដោយខ្លួនឯងថា មានមូលហេតុនៃការដក ហូតសមត្ថកិច្ចជំនុំជម្រះ ឬ ការប្តឹងជំទាស់ ( មាត្រា ២៩) ។

បញ្ញត្តិច្បាប់ស្តីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ ការប្តឹងជំទាស់ ការដកខ្លួនរបស់ចៅក្រម ក៏ត្រូវអនុវត្តដូច គ្នាផងដែរ ចំពោះក្រឡាបញ្ជី ( មាត្រា ៣១) ។

# ជំពូកទី ២ ភាគី និង អ្នកតំណាង

## កថាភាគទី ១ ភាគី

### ១. អត្ថន័យនៃភាគី

(១) ភាគីគឺជាជនដែលទាមទារនូវសាលក្រម ឬ សាលដីកាក្នុងនាមរបស់ខ្លួន ដើម្បីដោះស្រាយវិវាទ ព្រមទាំងជនដែលត្រូវបានទាមទារឱ្យចង្អុលឈ្មោះនៅក្នុងសាលក្រម ឬ សាលដីកានោះ ក្នុងនាមជាភាគីម្ខាងទៀត ។ ភាគី គេហៅថា ដើមចោទ និង ចុងចម្លើយ ក្នុងការជម្រះក្ដីលើកទី ១ ហើយដើមបណ្ដឹងឧទ្ធរណ៍ និង ចុងបណ្ដឹងឧទ្ធរណ៍ ក្នុងការជម្រះក្ដីនៃបណ្ដឹងឧទ្ធរណ៍ ហើយដើមបណ្ដឹងសាទុក្ខ និង ចុងបណ្ដឹងសាទុក្ខ ក្នុងការជម្រះក្ដីនៃបណ្ដឹងសាទុក្ខ ។

ភាគីគឺជាប្រធាននៃនីតិវិធីបណ្ដឹងរដ្ឋប្បវេណី មិនមែនគ្រាន់តែជាកម្មវត្ថុ (កម្មវត្ថុនៃការពិនិត្យ) ទេ ។ រឿងក្ដីរដ្ឋប្បវេណី ត្រូវបានធ្វើឡើងក្នុងគោលបំណងកំណត់ជាស្ថាពរនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ នៃទំនាក់ទំនងគតិយុត្តកំណត់ណាមួយរវាងភាគីទាំងសងខាង ហើយការពារសិទ្ធិរបស់អ្នកដែលមានសិទ្ធិនោះ ហេតុនេះហើយ តុលាការត្រូវឱ្យភាគីទាំងសងខាងដែលប្រឆាំងគ្នានោះ ចូលរួមក្នុងនីតិវិធីនោះ ក្នុងនាមជាប្រធាននៃបណ្ដឹង ហើយស្ដាប់នូវការអះអាងទាំងនោះ និង ធ្វើការពិនិត្យភស្ដុតាងដែលគេបានដាក់ រួចចេញសាលក្រម ។ ដូច្នេះ ភាគីត្រូវបានទទួលស្គាល់នូវសិទ្ធិមូលដ្ឋាននៃនីតិវិធី ដែលមានដូចជា សិទ្ធិទាមទារឱ្យសាកសួរ ជាដើម (សូមមើលការពន្យល់ខាងលើនេះ) ។

ការប្រឈមមុខគ្នានៃភាគីដូចនេះ គឺជាទម្រង់មូលដ្ឋាននៃរឿងក្ដី (គោលការណ៍នៃការប្រឈមមុខគ្នានៃភាគីទាំងពីរ) ។ ហើយលទ្ធផលគឺ ក្នុងករណីដែលឋានៈរបស់ដើមចោទ និង ចុងចម្លើយបានក្លាយទៅជាមួយដោយសារសន្តតិកម្ម ឬ ដោយសារការរួមបញ្ចូលនៃនីតិបុគ្គល ជាដើម រឿងក្ដីនោះក៏នឹងត្រូវរលាយដោយស្វ័យប្រវត្តិ ទោះជាបណ្ដឹងនោះកំពុងត្រូវចាត់ការក៏ដោយ (មាត្រា ១៧៤) ។

(២) ភាគីគឺជាចំណុចដែលត្រូវសរសេរបញ្ជាក់ក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុចទី ១) ហើយនៅក្នុងពាក្យបណ្ដឹងនោះ ដើមចោទ និង ចុងចម្លើយ អាចកំណត់ជាក់លាក់បានដោយការបង្ហាញឈ្មោះបុគ្គលនោះ (ឬ នាមករណ៍) ព្រមទាំងអាសយដ្ឋាន ។ តាមធម្មតា បញ្ហាថាតើអ្នកណាជាដើមចោទ ឬ ចុងចម្លើយនៃដំណើងមួយនោះ គឺមានសរសេរច្បាស់លាស់ក្នុងពាក្យបណ្ដឹង ហើយពុំមានបញ្ហាអ្វីកើតមានឡើងទេ ។ ក៏ប៉ុន្តែ ឧទាហរណ៍ ក្នុងរឿងក្ដីនៃករណីឧទាហរណ៍ ដែលមាននៅភាគដើមនៃសៀវភៅ តាមពិតភាគីដែលមានវិវាទ គឺ A និង B ទេ តែ C បានប្រើឈ្មោះរបស់ A ទៅប្ដឹង B ជាភាគីម្ខាងទៀត ។ ករណីនេះមានតិចទេ តែអាចមាន (នេះគេហៅថា បណ្ដឹងប្រើឈ្មោះដោយបំពាន) ។ ប្រសិនបើ C បានប្រាប់គេថា ខ្លួនឈ្មោះ A ហើយបានបង្ហាញខ្លួនក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្ដឹង

ហើយទទួលនូវការសាកសួរលើភាគី (មាត្រា ១៤០) ហើយតុលាការក៏មានការកាន់ច្រឡំ រួចចេញសាលក្រម ពេលនោះ តើដើមចោទនៃរឿងក្ដីនេះ ជា A ឬ ជា C គឺជាបញ្ហា ។ ម្យ៉ាងទៀត អាចមានករណីដែល A បានដាក់ពាក្យបណ្ដឹង ក៏ប៉ុន្តែ B បានទទួលមរណភាពមុនពេលនោះ ហើយមតិករបស់អ្នកនោះ ត្រូវបាន D ទទួលដោយសន្តតិកម្ម តែ A មិនបានដឹងអំពីព័ត៌មាននោះ ហើយបានដាក់ពាក្យបណ្ដឹងដោយមានឈ្មោះ B ជាចុងចម្លើយ រីឯតុលាការវិញ ក៏បានចេញសាលក្រមដែលចាត់ទុក B ជាចុងចម្លើយដែរ ។ ក្នុងករណីនេះ តើចុងចម្លើយ ជា B ឬ ជា D គឺជាបញ្ហា ។ ក្នុងករណីទាំងនេះ ស្ដីពីការកំណត់ថា តើអ្នកណាជាភាគី ហើយតើយកបទដ្ឋានអ្វីមកធ្វើការកំណត់នោះ គឺមានមតិផ្សេងៗគ្នាច្រើន ។ ក៏ប៉ុន្តែ បញ្ហាថា តើអ្នកណាជាភាគី ត្រូវបានកំណត់ឡើង ដោយមានមូលដ្ឋានច្បាស់លាស់ ដោយហេតុថា ការកំណត់ភាគី គឺជាបុរេល័ក្ខខ័ណ្ឌ ដើម្បីសម្រេចថាតើឱ្យអ្នកណាចូលរួមក្នុងនីតិវិធីក្នុងបណ្ដឹងនោះ នៅពេលបណ្ដឹងត្រូវបានចាត់ការ (តើត្រូវកោះហៅអ្នកណា នៅកាលបរិច្ឆេទ ឬ ឱ្យអ្នកណាធ្វើការអះអាង និង បញ្ជាក់) និង ដើម្បីសម្រេចថា តើអ្នកណាជាអ្នកទទួលអានុភាពនៃសាលក្រម (មាត្រា ១៩៨ ចំណុចទី ១) ក្រោយការបញ្ចប់នៃបណ្ដឹងនោះ ។ ដូច្នេះហើយ ក្នុងករណីខាងលើណាមួយក៏ដោយ ការកំណត់ដើមចោទ និង ចុងចម្លើយដោយផ្អែកលើការបង្ហាញ (ការសរសេរ) ក្នុងពាក្យបណ្ដឹង គឺជាការសមរម្យ ។ យោងតាមគំនិតនេះ ក្នុងករណីឧទាហរណ៍នៃបណ្ដឹង ដែលបានប្រើឈ្មោះដោយបំពាននេះ A ជាដើមចោទ ហើយ ក្នុងករណីឧទាហរណ៍ទី ២ B ដែលបានទទួលមរណភាព គឺជាចុងចម្លើយ ។ ទោះជាគិតដូចនេះក៏ដោយ ក្នុងករណីដែលបានចេញសាលក្រមឱ្យ A ចាញ់ ក្នុងបណ្ដឹងដែលប្រើឈ្មោះដោយបំពាននេះ A អាចទាមទារឱ្យលុបចោលនូវសាលក្រមស្ថាពរបាន ដោយបណ្ដឹងសុំឱ្យជំនុំជម្រះសាជាថ្មី (ករណីនេះមានន័យដូចគ្នានឹងករណីដែល A មិនត្រូវបានតំណាងដោយអ្នកតំណាងដែលមានសិទ្ធិតំណាងត្រឹមត្រូវតាមច្បាប់ ដូច្នេះហើយ គេអាចដាក់ពាក្យបណ្ដឹងសុំឱ្យជំនុំជម្រះសាជាថ្មី តាមការបកស្រាយដោយសទិសនៃមាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុច គ) ម្យ៉ាងទៀត ក្នុងករណីនៃបណ្ដឹងដែលមានចុងចម្លើយជាអ្នកដែលបានទទួលមរណភាព ប្រសិនបើបានចាប់ភ្លឹកដឹងនាពេលកណ្ដាលបណ្ដឹង តុលាការ អាចលើកបណ្ដឹងនោះចោលបាន ហើយទោះជាមិនបានចាប់ភ្លឹក ហើយបានចេញសាលក្រមក៏ដោយ ក៏ D ដែលមិនមែនជាចុងចម្លើយនោះ មិនទទួលនូវអានុភាពនៃសាលក្រមនោះឡើយ ដូច្នេះមិនមែនជាលទ្ធផលមិនសមហេតុផលនោះទេ ។

## ២. សមត្ថភាពភាគី

### (១) អត្ថន័យនៃសមត្ថភាពភាគី

សមត្ថភាពភាគី គឺជាលក្ខណសម្បត្តិទូទៅដែលអាចក្លាយជាភាគីនៃរឿងក្ដីរដ្ឋប្បវេណី ។ ដើម្បីអាចក្លាយជាភាគីនៃរឿងក្ដីរដ្ឋប្បវេណី ចាំបាច់ត្រូវមានលក្ខណសម្បត្តិទូទៅនេះ ។

រឿងក្ដីរដ្ឋប្បវេណី គឺជារបបមួយដើម្បីដោះស្រាយវិវាទរវាងបុគ្គលឯកជន តាមរយៈការកំណត់ជាស្ថាពរ

នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវនីតិឯកជន ហេតុនេះហើយ ការកំណត់ឱ្យជនដែលអាចជាប្រធានដែលមានសិទ្ធិនីតិឯកជន ជាប្រធាននៃនីតិវិធីរឿងក្តី គឺជាការសមរម្យ ។ ដូច្នេះ ក្រមនីតិវិធីរដ្ឋប្បវេណីមានចែងថា ជាគោលការណ៍ បុគ្គលដែលមានសមត្ថភាពក្នុងការទទួលសិទ្ធិតាមក្រមរដ្ឋប្បវេណី ជាបុគ្គលដែលមានសមត្ថភាពភាគីតាមផ្លូវបណ្តឹង (អ្នកមានសមត្ថភាពភាគី) (មាត្រា ៣២ កថាខណ្ឌទី ១) ។

ហេតុនេះហើយ រូបវន្តបុគ្គល និង នីតិបុគ្គល មានសមត្ថភាពភាគីទាំងអស់ (ក្រមរដ្ឋប្បវេណី មាត្រា ៦, មាត្រា ៤៦) ។ ហើយទារកក្នុងគភ៌ ក៏មានសមត្ថភាពទទួលសិទ្ធិស្តីពីបណ្តឹងទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ឬ ស្តីពីបណ្តឹងពាក់ព័ន្ធនឹងសន្តតិកម្ម និង អច្ច័យទានដែរ (ក្រមរដ្ឋប្បវេណី មាត្រា ៩, មាត្រា ១១៤៩ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត នីតិបុគ្គលមានសមត្ថភាពទទួលសិទ្ធិ ក្នុងវិសាលភាពនៃគោលបំណងនៃការជម្រះបញ្ជី ទោះជាបានរំលាយហើយក៏ដោយ (ក្រមរដ្ឋប្បវេណី មាត្រា ៦៦) ដូច្នេះ ក្នុងទំហំនេះ នីតិបុគ្គលមានសមត្ថភាពភាគីដែរ ។

(២) អានុភាពតាមផ្លូវច្បាប់នីតិវិធីនៃសមត្ថភាពភាគី

ការដែលភាគីនៃបណ្តឹងមានសមត្ថភាពភាគី គឺជាល័ក្ខខ័ណ្ឌនៃបណ្តឹងមួយ ហើយតុលាការត្រូវស្រាវជ្រាវនូវចំណុចនេះដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។ ប្រសិនបើភាគីម្ខាង ឬ ទាំងសងខាងមានកង្វះសមត្ថភាពភាគី តុលាការត្រូវចេញសាលក្រមលើកចោលបណ្តឹងនោះ ដោយសារតែមិនស្របច្បាប់ ។ ក្នុងករណីដែល ទោះបីជាភាគីពុំមានសមត្ថភាពភាគីក៏ដោយ តែបើតុលាការមិនបានដឹង ហើយចេញសាលក្រម ឬ សាលដីកា ភាគីណាម្ខាងក៏អាចប្តឹងទាមទារឱ្យលុបចោលសាលក្រម ឬ សាលដីកានោះ តាមបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន (បណ្តឹងឧទ្ធរណ៍, បណ្តឹងសាទុក្ខ) នៅពេលដែលសាលក្រម ឬ សាលដីកានោះមិនទាន់ចូលជាស្ថាពរ ។ ក៏ប៉ុន្តែ ក្រោយពេលចូលជាស្ថាពរ មិនអាចទាមទារឱ្យលុបចោលដោយបណ្តឹងសុំជំនុំជម្រះសាជាថ្មីបានទេ (មិនចាំបាច់សុំលុបចោល ក៏ពុំមានអានុភាពដែរ) ។

ម្យ៉ាងទៀត ប្រសិនបើភាគីបាត់បង់សមត្ថភាពភាគី ដូចជាករណីដែលភាគីបានទទួលមរណភាព ជាអាទិ៍ នៅពេលដែលបណ្តឹងកំពុងត្រូវបានចាត់ការ (មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច ក និង ខ) បណ្តឹងនោះ មិនត្រូវបានលើកចោលទេ តែឋានៈរបស់ភាគីនោះនឹងត្រូវបន្តទៅឱ្យសន្តតិជន ជាដើម ហើយនីតិវិធីបណ្តឹងត្រូវធ្វើបន្តទៅទៀត ។ ក៏ប៉ុន្តែ នីតិវិធីបណ្តឹងនោះនឹងត្រូវបានផ្អាក រហូតដល់ពេលដែលអ្នកទទួលបន្តអាចបន្តនីតិវិធីនោះជាក់ស្តែងបាន (សូមមើលមាត្រា ១៧៣ កថាខណ្ឌទី ១ និង ទី ២) ។

៣. សមត្ថភាពក្នុងការធ្វើបណ្តឹង

(១) អត្ថន័យនៃសមត្ថភាពក្នុងការធ្វើបណ្តឹង

សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាលក្ខណសម្បត្តិដែលភាគី ឬ បុគ្គលផ្សេងដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង

អាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបានឱ្យមានអានុភាព ឬ អាចទទួលនូវសកម្មភាពបណ្ដឹងរបស់តុលាការ និង ភាគីម្ខាងទៀតបាន ។

ទោះជាភាគីមានសមត្ថភាពភាគីក៏ដោយ តែប្រសិនបើសាមីខ្លួនពុំមានសមត្ថភាពអាចយល់បាននូវគោលគំនិត ឬ អានុភាពនៃសកម្មភាពនៅពេលដែលធ្វើ ឬ ទទួលសកម្មភាពបណ្ដឹងជាក់ស្ដែងបានទេ បុគ្គលនោះមិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមបណ្ដឹងបានទេ ហើយអាចបាត់បង់នូវផលប្រយោជន៍ច្រើនបាន ។ ឧទាហរណ៍ អាចមានករណីដែលភាគីពុំមានសមត្ថភាពគ្រប់គ្រាន់អាចឆ្លើយតបភ្លាម១ចំពោះការអះអាងរបស់ភាគីម្ខាងទៀត ឬ ដាក់ភស្តុតាងដើម្បីបញ្ជាក់ការអះអាងរបស់ខ្លួនបានទេ ហើយដែលភាគីនោះនឹងចាញ់បណ្ដឹងដែលតាមការពិតសាមីខ្លួនអាចឈ្នះបាន ។ ដូច្នេះ ដើម្បីការពារជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអះអាង និង ការពារផលប្រយោជន៍របស់ខ្លួនតាមបណ្ដឹងបាន ច្បាប់បង្កើតនូវរបបនៃសមត្ថភាពក្នុងការធ្វើបណ្ដឹង ដោយចាត់ទុកថា ជនទាំងនោះពុំមានលក្ខណសម្បត្តិធ្វើសកម្មភាពក្នុងការធ្វើបណ្ដឹង ហើយឱ្យអ្នកតំណាងដែល ច្បាប់បានកំណត់ ធ្វើសកម្មភាពបណ្ដឹងជំនួសជននោះ ។ របបនេះមានគោលគំនិតដូចគ្នានឹងរបបនៃសកម្មភាព ក្នុងការធ្វើសកម្មភាព ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីដែរ ( មាត្រា ៣២ កថាខណ្ឌទី ២ និង ទី ៣) ។

(២) បទដ្ឋាននៃសមត្ថភាពក្នុងការធ្វើបណ្ដឹង

(ក) គោលការណ៍

បណ្ដឹង គឺជានីតិវិធីកំណត់ជាស្ថាពរនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច ឬ ទំនាក់ទំនងគតិយុត្តតាមក្រមរដ្ឋប្បវេណី ឬ ច្បាប់សារធាតុផ្សេងទៀត ហើយលទ្ធផលនៃបណ្ដឹង គឺដូចជាការចាត់ចែងសិទ្ធិនិងកាតព្វកិច្ច ឬ ទំនាក់ទំនងគតិយុត្តដែរ ហេតុនេះហើយ ជាគោលការណ៍ វិសាលភាពនៃជនដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ត្រូវបានសម្រេចដោយយកវិសាលភាពនៃជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពតាមច្បាប់សារធាតុ មកធ្វើជាបទដ្ឋាន ។ ដូច្នេះ បុគ្គលទាំងឡាយដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព យោងតាមបញ្ញត្តិនៃច្បាប់សារធាតុ ដូចជាក្រមរដ្ឋប្បវេណី ជាអាទិ៍ នឹងមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ( មាត្រា ៣២ កថាខណ្ឌទី ២) ។

(ខ) អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ

ក្នុងចំណោមជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព (ក្រមរដ្ឋប្បវេណី មាត្រា ១៦) អនីតិជន និង ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ជាគោលការណ៍ ពុំមានសមត្ថភាពក្នុងការធ្វើបណ្ដឹងទេ ហើយអាចធ្វើសកម្មភាពបណ្ដឹងសុពលបានលុះត្រាតែត្រូវបានធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់ ( មាត្រា ៣២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១) ។ សកម្មភាពបណ្ដឹងដែលអនីតិជន និង ជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើ មិនត្រឹមតែអាចលុបចោលទេ (សូមមើលក្រមរដ្ឋប្បវេណី មាត្រា ១៨)

គឺសកម្មភាពនោះមោឃៈជាដាច់ខាត ។ ទោះជាមានការយល់ព្រមពីជនដែលមានសិទ្ធិអំណាចមេបា ឬពីអ្នកអាណាព្យាបាលក៏ដោយ ក៏មោឃៈដែរ ។ ក៏ប៉ុន្តែ ទោះជាអនីតិជនក៏ដោយ តែក្នុងករណីដែលជននោះត្រូវបានចាត់ទុកថា ដល់នីតិភាព ដោយសារអាពាហ៍ពិពាហ៍ (ក្រមរដ្ឋប្បវេណី មាត្រា ៩៦៨) ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹងជាទូទៅ ម្យ៉ាងទៀត ក្នុងករណីដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យចាត់ចែងចំពោះទ្រព្យសម្បត្តិជាក់លាក់ពិសេស ឬ ត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ហើយមានសមត្ថភាពក្នុងការធ្វើសកម្មភាពត្រឹមទំហំនោះ (ក្រមរដ្ឋប្បវេណី មាត្រា ១៩ និង មាត្រា ២០) ជននោះមានសមត្ថភាពក្នុងការធ្វើបណ្តឹង ចំពោះបណ្តឹងដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ ឬ អាជីវកម្មនោះ (មាត្រា ៣២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

(គ) អ្នកនៅក្រោមហិតូបត្ថម្ភ

ដើម្បីធ្វើសកម្មភាពបណ្តឹង អ្នកនៅក្រោមហិតូបត្ថម្ភត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ (ក្រមរដ្ឋប្បវេណី មាត្រា ៣០ ចំណុច ឃ) ។ ដូច្នេះ ដើម្បីដាក់បណ្តឹង ឬ ធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អ្នកនៅក្រោមហិតូបត្ថម្ភត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ (ការយល់ព្រមនេះ ត្រូវធ្វើការបញ្ជាក់ដោយលិខិតជាលាយលក្ខណ៍អក្សរ, មាត្រា ៣៥ កថាខណ្ឌទី ៣) ។ ក៏ប៉ុន្តែ ដើម្បីធ្វើសកម្មភាពតប ចំពោះបណ្តឹង ឬ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានឡើងដោយភាគីម្ខាងទៀត មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ (មាត្រា ៣៣ កថាខណ្ឌទី ១) ។ ប្រសិនបើចាំបាច់ឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈទៅ ប្រសិនជាពុំបានទទួលការយល់ព្រមនោះទៅ ភាគីម្ខាងទៀតពុំអាចដាក់ពាក្យបណ្តឹង ឬ ធ្វើការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ (ហិតូបត្ថម្ភកៈពុំមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ ដូច្នេះហើយ មិនអាចឱ្យហិតូបត្ថម្ភកៈតំណាងបានទេ) ។ ក៏ប៉ុន្តែ ចំពោះសកម្មភាពដកពាក្យបណ្តឹង ឬ ដកបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ជាដើម ដែលជាសកម្មភាពបញ្ចប់បណ្តឹងដោយមិនឆ្លងកាត់តាមសាលក្រម ឬ សាលដីកា ជននៅក្រោមហិតូបត្ថម្ភចាំបាច់ត្រូវមានការយល់ព្រមពិសេសជានិច្ច (មាត្រា ៣៣ កថាខណ្ឌទី ២) ។

(ឃ) ជនបរទេស

ក្នុងករណីដែលជនបរទេសណាម្នាក់ មានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយយោងតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះជាជននោះពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយយោងតាមច្បាប់នៃប្រទេសរបស់ជននោះក៏ដោយ ក៏ត្រូវចាត់ទុកថា មានសមត្ថភាពក្នុងការធ្វើបណ្តឹងនៅកម្ពុជាដែរ (មាត្រា ៣៤) ។

(ង) សមត្ថភាពក្នុងការធ្វើបណ្តឹង នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល សកម្មភាពទាក់ទងនឹងឋានៈបុគ្គល មិនមែនត្រូវធ្វើឡើងដោយអ្នកតំណាងទេ គឺត្រូវធ្វើឡើងដោយផ្អែកលើឆន្ទៈសាមីខ្លួន ហេតុនេះហើយ អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ មានសមត្ថភាពក្នុងការធ្វើបណ្តឹង (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹង

ឋានៈបុគ្គល មាត្រា ៧ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ តាមការពិត ការធ្វើសកម្មភាពបណ្តឹងដោយអនីតិជន ឬ ដោយជននៅក្រោមអាណាព្យាបាលទូទៅ ខ្លួនឯង អាចនឹងធ្វើឱ្យខូចផលប្រយោជន៍របស់ខ្លួនបាន ហេតុនេះហើយ ប្រសិនបើមានពាក្យសុំពីអ្នកទាំងនោះ តុលាការអាចជ្រើសតាំងមេធាវីធ្វើជាអ្នកតំណាងឱ្យភាគីទាំងនោះបាន (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៧ កថាខណ្ឌទី ២) ។ ទោះជាពុំមានពាក្យសុំក៏ដោយ ក៏តុលាការ អាចបង្គាប់ឱ្យភាគីធ្វើការជ្រើសតាំងមេធាវីជាអ្នកតំណាង ឬ អាចជ្រើសតាំងមេធាវីធ្វើជាអ្នកតំណាង ដោយឆន្ទានុសិទ្ធិបាន (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៧ កថាខណ្ឌទី ៣) ។

(៣) អានុភាពតាមផ្លូវច្បាប់នីតិវិធីនៃសមត្ថភាពក្នុងការធ្វើបណ្តឹង

សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាល័ក្ខខ័ណ្ឌសុពលភាពនៃសកម្មភាពបណ្តឹងនីមួយៗ ហើយសកម្មភាពរបស់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាសកម្មភាពមោឃៈ ។ ករណីនេះខុសគ្នានឹងករណីដែលមានកង្វះសមត្ថភាពក្នុងការធ្វើសកម្មភាពតាមក្រមរដ្ឋប្បវេណី (ក្រមរដ្ឋប្បវេណី មាត្រា ១៨ មាត្រា ២៦ មាត្រា ៣៥៨ កថាខណ្ឌទី ១) ដែលចែងថា សកម្មភាពមានសុពលភាព រហូតដល់ពេលដែលមានការលុបចោល ។ នេះគឺដោយសារតែដើម្បីឱ្យមានស្ថិរភាពក្នុងនីតិវិធីបណ្តឹង ។ តុលាការត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃសមត្ថភាពក្នុងការធ្វើបណ្តឹង ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ពេលណាក៏ដោយ ។

(ក) ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង

ក-ការផ្តល់សច្ចានុមតិ

ទោះជាសកម្មភាពណ្តឹងរបស់ជនដែលមានកង្វះសកម្មភាពក្នុងការធ្វើបណ្តឹងក៏ដោយ មិនមែនមានន័យថាជននោះបាត់បង់នូវផលប្រយោជន៍រាល់ពេលទេ ហេតុនេះហើយ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងវិញ បានផ្តល់សច្ចានុមតិ សកម្មភាពនោះនឹងមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះត្រូវបានធ្វើឡើង (មាត្រា ៣៥ កថាខណ្ឌទី ២) ។

ខ-ដីកាបង្គាប់ឱ្យធ្វើការកែតម្រូវ

តាមលទ្ធផលនៃការស្រាវជ្រាវ ទោះជាតុលាការរកឃើញថា ភាគីពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងក៏ដោយ ក៏អាចមានការផ្តល់នូវសច្ចានុមតិ ដូច្នេះហើយ មិនត្រូវបដិសេធសកម្មភាពនោះភ្លាមៗទេ ត្រូវបង្គាប់ឱ្យធ្វើការកែតម្រូវ ដោយកំណត់អំឡុងពេលមួយ (មាត្រា ៣៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក្នុងករណីដែលបានបង្គាប់ឱ្យធ្វើការកែតម្រូវ ត្រូវបង្អាក់នូវនីតិវិធីរហូតដល់អំឡុងពេលសម្រាប់ធ្វើការកែតម្រូវនោះបានកន្លងផុតទៅ ។ ក៏ប៉ុន្តែ ក្នុងករណីដែលអាចមានការខូចផលប្រយោជន៍ដោយសារការយឺតយ៉ាវក្នុងអំឡុងពេលបង្អាក់ បើមិនធ្វើសកម្មភាពបណ្តឹងណាមួយ តុលាការអាចឱ្យធ្វើសកម្មភាពបណ្តឹងនោះជាបណ្តោះអាសន្នបាន (កថាខណ្ឌដដែល វាក្យខណ្ឌទី ២) ។

(ខ) ឥទ្ធិពលនៃកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទៅលើបណ្តឹង

ក្នុងករណីដែល ដើមចោទពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង នៅពេលដាក់ពាក្យបណ្តឹង ឬ ចុងចម្លើយពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង នៅពេលដែលបានទទួលនូវការបញ្ជូនពាក្យបណ្តឹងនោះ តុលាការត្រូវលើកចោលបណ្តឹងនោះ ដោយសារមូលហេតុមិនស្របច្បាប់ ប្រសិនបើពុំមានការកែតម្រូវនូវកង្វះលក្ខណៈនោះទេ ។

ម្យ៉ាងទៀត ក្នុងករណីដែលកង្វះនូវសមត្ថភាពក្នុងការធ្វើបណ្តឹងកើតមានឡើង ក្រោយពេលបានចាត់ការបណ្តឹងនោះ ត្រូវផ្អាកនីតិវិធីបណ្តឹងនោះ ហើយអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវទទួលបន្ត (មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច គ) ។ ក្នុងករណីដែលតុលាការបានចេញសាលក្រមនៃការជម្រះក្តីលើកទី ១ ដោយមិនបានដឹងអំពីអសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី ភាគីខាងណាក៏អាចទាមទារឱ្យលុបចោលសាលក្រម ឬ សាលដីកានោះ តាមរយៈបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (បណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ) បាន (ស្តីពីបណ្តឹងសាទុក្ខ សូមមើលមាត្រា ២៨៥ កថាខណ្ឌទី ១ ចំណុច ឃ) ។ ម្យ៉ាងទៀត ទោះជាសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរក៏ដោយ ក៏អាចទាមទារឱ្យលុបចោលសាលក្រម ឬ សាលដីកានោះ តាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដែរ (មាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុច គ) ។

## កថាភាគទី ២ អ្នកតំណាងតាមផ្លូវបណ្តឹង

### ១. អត្ថន័យនៃអ្នកតំណាងតាមផ្លូវបណ្តឹង

អ្នកតំណាងតាមផ្លូវបណ្តឹងគឺជាអ្នកធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬ ភាគីម្ខាងទៀត ដោយផ្អែកលើឆន្ទៈរបស់ខ្លួន ក្នុងនាមជាភាគី ហើយជំនួសភាគី ហើយអានុភាពនៃការធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងនោះនឹងមានទៅលើភាគី ។ អានុភាពនៃសកម្មភាពរបស់អ្នកតំណាង មានទៅលើសាមីខ្លួន ដោយសារតែអ្នកតំណាងនោះមានសិទ្ធិតំណាង ។ ចំពោះអ្នកតំណាងតាមផ្លូវបណ្តឹង មានអ្នកតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដោយអាណត្តិ ។

អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិនោះដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬ តាមរយៈសេចក្តីសម្រេចរបស់តុលាការ ជាអាទិ៍ មិនមែនបានទទួលសិទ្ធិនោះដោយផ្អែកលើឆន្ទៈរបស់សាមីភាគីទេ ។ អ្នកតំណាងដែលច្បាប់បានកំណត់ ជាទូទៅ នឹងធ្វើសកម្មភាពបណ្តឹង ជំនួសភាគីដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង ដើម្បីផលប្រយោជន៍ភាគីនោះ ។ ក៏ប៉ុន្តែ ក្នុងករណីដែលពុំមានអ្នកតំណាងដែលច្បាប់បានកំណត់នេះ ហើយដោយសារតែភាគីម្ខាងទៀតចាំបាច់ធ្វើបណ្តឹងជាបន្ទាន់នោះ ដូច្នេះហើយ តុលាការត្រូវធ្វើការជ្រើសតាំងអ្នកតំណាងពិសេស សម្រាប់តែករណីពិសេសនេះ ដើម្បីការពារផលប្រយោជន៍ភាគីម្ខាងទៀតទៅវិញ (មាត្រា ៣៦) ហើយនេះក៏ជាតំណាងដែលច្បាប់បានកំណត់មួយប្រភេទដែរ ។

អ្នកតំណាងដោយអាណត្តិ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិតំណាងនោះ ដោយផ្អែកលើឆន្ទៈរបស់សាមី

ភាគី ។ ទោះជាភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងក៏ដោយ តាមធម្មតា ច្រើនតែពុំមានចំណេះដឹងស្តីពីច្បាប់ដែលចាំបាច់ដើម្បីធ្វើសកម្មភាពបណ្តឹងឱ្យមានប្រសិទ្ធិភាព និង ឱ្យបានសមស្របទេ ដូច្នេះហើយ អ្នកតំណាងដោយអាណត្តិ គឺជាអ្នកទទួលនូវសិទ្ធិដោយការអាណត្តិពីភាគី ចំពោះរឿងក្តីនីមួយៗ ហើយធ្វើសកម្មភាពបណ្តឹងនោះ ។ ក្រៅពីនេះ ក្នុងករណីដែលស្ថាប័នរដ្ឋដូចជារដ្ឋ ឬ ក្រសួង ជាដើម ជាភាគីវិញ គេចាត់តាំងឱ្យមន្ត្រីស្ថាប័ននោះធ្វើសកម្មភាពបណ្តឹង ហើយនេះក៏ជាអ្នកតំណាងដោយអាណត្តិដែរ ( មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុចទី ២) ។

(តារាង) ប្រភេទនៃអ្នកតំណាងតាមផ្លូវបណ្តឹង

<table>
<tr>
<td rowspan="2">អ្នកតំណាងតាមផ្លូវបណ្តឹង</td>
<td>អ្នកតំណាងដែលច្បាប់បានកំណត់ : ករណីដែលបានជ្រើសតាំងដោយមិនផ្អែកលើឆន្ទៈរបស់សាមីភាគី<br>(១) អ្នកតំណាងតាមផ្លូវច្បាប់សារធាតុ (មាត្រា ៣២ កថាខណ្ឌទី ៣)<br>ឧទាហរណ៍ : ជនដែលមានសិទ្ធិអំណាចមេបា, អ្នកអាណាព្យាបាលទូទៅ<br>(២) អ្នកតំណាងពិសេស (មាត្រា ៣៦ កថាខណ្ឌទី ១, មាត្រា ១៦៦)</td>
</tr>
<tr>
<td>អ្នកតំណាងដោយអាណត្តិ : ករណីដែលបានជ្រើសតាំងដោយផ្អែកលើឆន្ទៈរបស់សាមីភាគី<br>(១) មេធាវី (មាត្រា ៥៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១)<br>(២) គតិយុត្តជន ក្រៅពីមេធាវី ដែលត្រូវបានទទួលស្គាល់ឱ្យធ្វើសកម្មភាពបណ្តឹងជំនួសភាគី ដោយយោងតាម ក្រមនីតិវិធីរដ្ឋប្បវេណី ឬ តាមច្បាប់ដទៃទៀត (កថាខណ្ឌដដែល ចំណុច ក)<br>(៣) ក្នុងករណីដែលភាគីជារដ្ឋ ឬ ស្ថាប័នរដ្ឋ ជាអាទិ៍ ហើយស្ថាប័នរដ្ឋនោះ ជាអាទិ៍ បានចាត់តាំងមន្ត្រីរបស់ខ្លួន ជាអ្នកតំណាង (កថាខណ្ឌដដែល ចំណុច ខ)<br>(៤) ករណីដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយគតិយុត្តជនដែលមិនមែនជាមេធាវី ក្នុងរឿងក្តីដែល តម្លៃកម្មវត្ថុនៃបណ្តឹងតិចជាង ១.០០០.០០០ (មួយលាន) រៀល (កថាខណ្ឌដដែល ចំណុច គ)</td>
</tr>
</table>

២. អ្នកតំណាងដែលច្បាប់បានកំណត់

(១) ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ មានការពាក់ព័ន្ធនឹងបណ្តឹង

ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់មានការពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង ជាបឋម ភាគីជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅ ហេតុនេះហើយ ជនដែលត្រូវបានផ្តល់នូវសិទ្ធិតំណាងដែលច្បាប់បានកំណត់ តាមផ្លូវច្បាប់សារធាតុ (អ្នកតំណាងតាមផ្លូវច្បាប់សារធាតុ) ដូចជាអ្នកមានសិទ្ធិអំណាចមេបាលើអនីតិជននោះ ឬ អ្នកអាណាព្យាបាលទូទៅ ជាដើម ក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់តាមផ្លូវនីតិវិធីបណ្តឹង សម្រាប់អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលនោះផងដែរ ។ ម្យ៉ាងទៀត ប្រសិនបើគ្មានមានអ្នកតំណាងដែលច្បាប់កំណត់តាមផ្លូវច្បាប់សារធាតុ ឬ ប្រសិនបើអ្នកតំណាងដែលច្បាប់បានកំណត់ពុំអាចអនុវត្តសិទ្ធិតំណាងរបស់ខ្លួនបាន តុលាការអាចជ្រើសតាំងអ្នកតំណាងពិសេស (មាត្រា ៣៦ កថាខណ្ឌទី ១, ម្យ៉ាងទៀត សូមមើលមាត្រា ១៦៦) សម្រាប់ជនដែលមានបំណងធ្វើសកម្មភាពបណ្តឹងចំពោះបុគ្គលដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង ដោយផ្អែកលើពាក្យសុំរបស់បុគ្គលនោះ ។ អ្នកតំណាងដែលត្រូវបានតុលាការជ្រើសតាំងសម្រាប់ភាគីដែលជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅ ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក៏ជាអ្នកតំណាងដែលច្បាប់បានកំណត់ដែរ ។

(២) ឋានៈរបស់អ្នកតំណាងដែលច្បាប់បានកំណត់

អ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាង មិនមែនសាមីភាគីទេ ដូច្នេះ មិនអាចក្លាយជាអ្នកដែលមានឈ្មោះនៅក្នុងសាលក្រម ឬ សាលដីកាបានឡើយ (មាត្រា ១៩៨ ចំណុច ក) ។ ក៏ប៉ុន្តែ អ្នកតំណាង

ដែលច្បាប់បានកំណត់ ធ្វើសកម្មភាពបណ្តឹង ជំនួសសាមីភាគី ក្នុងករណីដែលសាមីភាគីនោះពុំមានសមត្ថភាព ក្នុងការធ្វើបណ្តឹង ហេតុនេះហើយ មានករណីជាច្រើនដែលត្រូវចាត់ទុកអ្នកតំណាងដែលច្បាប់បានកំណត់ ដូច សាមីភាគីដែរ ( មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក, មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច គ, មាត្រា ២៤៨, មាត្រា ១៤២, មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច គ ជាអាទិ៍) ។

(៣) ទំហំនៃសិទ្ធិតំណាងដែលច្បាប់បានកំណត់

ទំហំនៃសិទ្ធិតំណាងដែលច្បាប់បានកំណត់ ត្រូវកំណត់តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ដទៃទៀត ប្រសិនបើគ្មានចែងពិសេសទេ ( មាត្រា ៣២ កថាខណ្ឌទី ៤) ។ ក៏ប៉ុន្តែ ដើម្បីការពារសាមីខ្លួន ឬ ភាគីម្ខាង ទៀត និង ដើម្បីឱ្យមានស្ថិរភាពក្នុងនីតិវិធីបណ្តឹង មានបញ្ញត្តិកម្រិត និង កែតម្រូវខ្លះៗ ( មាត្រា ៣៣, មាត្រា ៣៧ ជាអាទិ៍) ។

ម្យ៉ាងទៀត ចំពោះអ្នកតំណាងនីតិបុគ្គលវិញ ក៏ត្រូវអនុលោមតាមបញ្ញត្តិស្តីពីការតំណាងដែលច្បាប់បាន កំណត់ខាងលើនេះដែរ ( មាត្រា ៣៨) ។ នេះគឺមានន័យថា តាមផ្លូវបណ្តឹង អ្នកតំណាងនីតិបុគ្គល ត្រូវបានចាត់ចែង ដូចអ្នកតំណាងដែលច្បាប់បានកំណត់ដែរ ។

៣. អ្នកតំណាងដោយអាណត្តិ

(១) លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ

(ក) គោលការណ៍

ជាគោលការណ៍ ជនដែលអាចក្លាយទៅជាអ្នកតំណាងដោយអាណត្តិ មានតែមេធាវីទេ ( គោលការណ៍នៃ ការតំណាងដោយមេធាវី, មាត្រា ៥៣ កថាខណ្ឌទី ១) ។ នេះគឺដើម្បីការពារផលប្រយោជន៍សាមីភាគីដែលជា អ្នកពឹងពាក់ ។ ហេតុនេះហើយ ក្នុងករណីដែលជនក្រៅពីមេធាវី បានធ្វើសកម្មភាពបណ្តឹង ក្នុងនាមជា អ្នក តំណាងដោយអាណត្តិ ជាគោលការណ៍ គឺជាអំពើខុសនឹងច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ ព័ន្ធរបស់អ្នកនោះ ក្នុងបណ្តឹង ។ សកម្មភាពដែលអ្នកនោះបានធ្វើ ពុំមានសុពលភាពទេ ក៏ប៉ុន្តែ ប្រសិនបើភាគី បានផ្តល់សច្ចានុមតិ សកម្មភាពនោះនឹងមានសុពលភាព ។

(ខ) ករណីពិសេស

ស្តីពីករណីដែលអាចជ្រើសតាំងជនក្រៅពីមេធាវីធ្វើអ្នកតំណាងដោយអាណត្តិ ក្រមនីតិវិធីរដ្ឋប្បវេណីបាន ទទួលស្គាល់ករណីដូចជា (១) ករណីដែលទទួលស្គាល់ឱ្យតតិយជនក្រៅពីមេធាវី ធ្វើសកម្មភាពបណ្តឹង ជំនួស ភាគី ដោយយោងតាមច្បាប់ ( មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ក) (២) ករណីដែលរដ្ឋ ឬ ស្ថាប័នរដ្ឋ ជាអាទិ៍ ជាភាគី ហើយមានការកំណត់ឱ្យមន្ត្រីស្ថាប័ននោះធ្វើជាអ្នកតំណាងស្ថាប័ននោះ ជាអាទិ៍ ( មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច ខ) និង (៣) ករណីដែលអនុញ្ញាតឱ្យតតិយជនពិសេសក្រៅពីមេធាវី ធ្វើជាអ្នកតំណាង ក្នុងរឿងក្តីដែលទឹកប្រាក់នៃកម្មវត្ថុនៃបណ្តឹងនោះតិចជាង ១ លានរៀល ( មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច គ

ម្យ៉ាងទៀត សូមមើលមាត្រា៥ដែល កថាខណ្ឌទី ៣) ។ ករណី (៣) គឺជាករណីដែលទឹកប្រាក់សេដ្ឋកិច្ចនៃសិទ្ធិ និង កាតព្វកិច្ចដែលត្រូវកំណត់ដោយបណ្តឹងនេះ មានតិចតួច ដូច្នេះហើយ ទោះជាមិនមែនជាមេធាវីក៏ដោយ ក៏ទទួលស្គាល់ឱ្យជនដែលភាគីមានការទុកចិត្ត ហើយដែលតុលាការយល់ឃើញថាអត់មានបញ្ហាដែរ ធ្វើជាអ្នកតំណាងដោយអាណត្តិ ។

(២) ការប្រគល់សិទ្ធិតំណាងដោយអាណត្តិ

សិទ្ធិតំណាងដោយអាណត្តិ ត្រូវបានផ្តល់ដោយការបង្ហាញឆន្ទៈដោយភាគីថា បានផ្តល់នូវសិទ្ធិតំណាងដោយអាណត្តិក្នុងរឿងក្តីពិសេសណាមួយ ចំពោះជនដែលត្រូវធ្វើតំណាង ។ ដើម្បីធ្វើសកម្មភាពតាមផ្លូវនីតិវិធីបណ្តឹង អ្នកតំណាងដោយអាណត្តិ ត្រូវធ្វើការបញ្ជាក់ដោយលាយលក្ខណ៍អក្សរថា ខ្លួនមានសិទ្ធិតំណាងដោយអាណត្តិនោះ (មាត្រា ៣៥ កថាខណ្ឌទី ៣) ។

(៣) ឋានៈរបស់អ្នកតំណាងដោយអាណត្តិ

សកម្មភាពបណ្តឹងដែលធ្វើដោយអ្នកតំណាងដោយអាណត្តិ នឹងបង្កើតនូវអានុភាពដូចគ្នានឹងសកម្មភាពដែលធ្វើដោយភាគី (មាត្រា ៥២ កថាខណ្ឌទី ៣) ។ ក៏ប៉ុន្តែ អ្នកតំណាងដោយអាណត្តិមិនមែនជាភាគីទេ ដូច្នេះមិនទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាឡើយ ។ ម្យ៉ាងទៀត ខុសពីអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងដោយអាណត្តិអាចធ្វើជាសាក្សី ឬ អ្នកធ្វើកោសលវិច័យបាន ។

ទោះបីជាបានធ្វើការជ្រើសតាំងអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនោះអាចចូលតុលាការតែឯង ឬ ជាមួយអ្នកតំណាងដោយអាណត្តិ ដើម្បីទាញហេតុផលដោយផ្ទាល់មាត់ដោយខ្លួនឯងបាន (មាត្រា ៥២ កថាខណ្ឌទី ២) ។ ក្នុងករណីដែលសាមីភាគីបានចូលតុលាការជាមួយអ្នកតំណាងដោយអាណត្តិ ហើយបានលុបចោល ឬ កែតម្រូវភ្លាមៗនូវការសារភាព និង សេចក្តីថ្លែងការណ៍ផ្សេងទៀតស្តីពីអង្គហេតុដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ សកម្មភាពរបស់អ្នកតំណាងដោយអាណត្តិនោះនឹងពុំមានសុពលភាពឡើយ (មាត្រា ៥២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

(៤) សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ---ទំហំនៃសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិ

អ្នកតំណាងដោយអាណត្តិ អាចធ្វើរាល់សកម្មភាពបណ្តឹង ដែលចាំបាច់ក្នុងការបន្តនីតិវិធី ដូចជា ការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសារចំពោះបណ្តឹង ការប្តឹងតប ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាដើម ចំពោះរឿងក្តីដែលខ្លួនបានទទួលអាណត្តិ (មាត្រា ៥៤ កថាខណ្ឌទី ១) ។ លើសពីនេះទៀត ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ភាគីមិនអាចកម្រិតនូវសិទ្ធិតំណាងនោះបានទេ លើកលែងតែករណីកំណត់មួយចំនួន (មាត្រា ៥៤ កថាខណ្ឌទី ៣) ។ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាជនដែលមិនមែនជាមេធាវី ភាគីអាចកម្រិតនូវទំហំនៃសិទ្ធិតំណាងនោះបាន ហើយអាចឱ្យអ្នកតំណាងដោយអាណត្តិនោះធ្វើតំណាងតែចំពោះសកម្មភាពបណ្តឹងមួយចំនួនដែលកំណត់ដោយឡែកបាន (មាត្រា ៥៤ កថាខណ្ឌទី ៤) ។

ទោះបីជាអ្នកតំណាងដោយអាណត្តិជាមេធាវីក៏ដោយ ចំពោះសកម្មភាពបណ្តឹងដែលមិនចាំបាច់ដើម្បីឈ្នះក្តីក្នុងរឿងក្តីដែលភាគីបានពឹងពាក់ ហើយ ដែលអាចមានអានុភាពធ្វើឱ្យខូចផលប្រយោជន៍របស់ខ្លួន ភាគីអាចកម្រិតសិទ្ធិអំណាចតំណាងបានដែរ ( មាត្រា ៥៤ កថាខណ្ឌទី ៣) ។ សកម្មភាពបណ្តឹងទាំងនោះគឺមានដូចជា ការប្តឹងតប ( មាត្រា ៨៦) ការដកពាក្យបណ្តឹង ( មាត្រា ២១៧) ការផ្សះផ្សា ( មាត្រា ២២០) ការលះបង់ និងការទទួលស្គាល់នូវការទាមទារ ( មាត្រា ២២១) ការដកខ្លួនពីបណ្តឹង ការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ( មាត្រា ២៦០) ការដកពាក្យបណ្តឹងឧបាស្រ័យពីតុលាការជាន់ខ្ពស់ ( មាត្រា ២៦៩, មាត្រា ២៨៦) ការជ្រើសតាំងអនុតំណាង ( មាត្រា ៥៤ កថាខណ្ឌទី ២) ។

( ៥) មូលហេតុនៃការរលត់សិទ្ធិនូវតំណាងដោយអាណត្តិ

សិទ្ធិតំណាងដោយអាណត្តិ នឹងត្រូវរលត់ដោយមូលហេតុដូចជា មរណភាពរបស់អ្នកតំណាងដោយអាណត្តិ ការបាត់បង់នូវលក្ខណសម្បត្តិរបស់អ្នកតំណាង ឬ ការបញ្ចប់កិច្ចការអាណត្តិ ជាអាទិ៍ ( មាត្រា ៥៦ កថាខណ្ឌទី ១) ម្យ៉ាងទៀត ភាគីអាចដកសិទ្ធិតំណាងដោយអាណត្តិនៅពេលណាក៏បានដែរ រីឯអ្នកតំណាងដោយអាណត្តិវិញ អាចលាឈប់ពីការធ្វើតំណាង នៅពេលណាក៏បានដែរ ( មាត្រា ៥៦ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ តាមទស្សនៈនៃស្ថិរភាពនៃនីតិវិធីបណ្តឹង ការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ ពុំមានអានុភាពឡើយ ប្រសិនបើមិនបានជូនដំណឹងអំពីការរលត់សិទ្ធិនោះ ពីសាមីភាគី ឬ ពីអ្នកតំណាង ទៅភាគីម្ខាងទៀត ( មាត្រា ៥៦ កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ទោះបីជាមានករណីដែលភាគីបានទទួលមរណភាព ឬ បាត់បង់សមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវបានប្តូរ ជាអាទិ៍ ក៏ដោយ ក៏សិទ្ធិតំណាងមិនរលត់ទេ ហើយអ្នកតំណាងដោយអាណត្តិនឹងក្លាយទៅជា អ្នកតំណាងដោយអាណត្តិរបស់សន្តតិជន ឬ អ្នកអាណាព្យាបាលថ្មីទៅ ជាអាទិ៍ ( មាត្រា ៥៥) ។

( ៦) ការចាត់ចែងក្នុងករណីមានកង្វះនូវសិទ្ធិតំណាងដោយអាណត្តិ

( ក) ករណីមានកង្វះនូវសិទ្ធិតំណាងដោយអាណត្តិ

ការមានសិទ្ធិតំណាងដោយអាណត្តិ គឺជាល័ក្ខខ័ណ្ឌនៃអានុភាពនៃសកម្មភាពបណ្តឹងដែលធ្វើដោយអ្នកតំណាង ហេតុនេះហើយ ប្រសិនបើមានការសង្ស័យនូវការខ្វះសិទ្ធិតំណាងដោយអាណត្តិ តុលាការត្រូវស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិតំណាង ដោយឆន្ទានុសិទ្ធិ ( មាត្រា ៥៧ កថាខណ្ឌទី ១) ។ ហើយលទ្ធផលគឺក្នុងករណីដែលបានដឹងថា ពុំមានសិទ្ធិតំណាងដោយអាណត្តិទេ តុលាការត្រូវណែនាំឱ្យកែតម្រូវនូវចំណុចកង្វះនោះ ( ការផ្តល់សច្ចានុមតិ) ដោយកំណត់នូវអំឡុងពេលមួយ ( មាត្រា ៥៧ កថាខណ្ឌទី ២) ។ ប្រសិនបើភាគីបានផ្តល់សច្ចានុមតិ សកម្មភាពតំណាងដោយគ្មានសិទ្ធិ នឹងមានអានុភាពប្រតិសកម្ម តាំងពីពេលដែលសកម្មភាពនោះត្រូវបានធ្វើឡើង ( មាត្រា ៥៧ កថាខណ្ឌទី ៣) ។

( ខ) ឥទ្ធិពលនៃកង្វះសិទ្ធិតំណាង ទៅលើបណ្តឹង

ក្នុងករណីដែលបណ្តឹងត្រូវបានធ្វើឡើងដោយអ្នកតំណាង ប្រសិនបើពុំមានសិទ្ធិតំណាងទេ សកម្មភាពដាក់បណ្តឹងនោះ នឹងក្លាយទៅជាមោឃៈ ដូច្នេះហើយ ប្រសិនបើពុំមានសច្ចានុមតិទេ តុលាការត្រូវលើកចោលបណ្តឹងនោះ ដោយលើកយកមូលហេតុថា ជាបណ្តឹងមិនស្របច្បាប់ ។ ប៉ុន្តែ ទោះជាបានចេញសាលក្រម ឬ សាលដីកា ដោយមិនបានដឹងអំពីកង្វះសិទ្ធិតំណាងក៏ដោយ សាលក្រម ឬ សាលដីកានោះមិនមែនមោឃៈដោយស្វ័យប្រវត្តិទេ គឺ ភាគីអាចទាមទារឱ្យលុបចោលដោយបណ្តឹងឧទ្ធរណ៍ ឬ ដោយបណ្តឹងសាទុក្ខបាន (មាត្រា ២៨៥ កថាខណ្ឌទី ១ ចំណុច ឃ) ហើយ ក្រោយសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរក៏ដោយ ក៏អាចទាមទារឱ្យលុបចោលបាន ដោយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញបាន (មាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុច គ) ។

៤. អ្នកជំនួយ

អ្នកជំនួយគឺជាអ្នកចូលសាលសវនាការជាមួយនឹងភាគី ឬ អ្នកតំណាងដោយអាណត្តិ ហើយជួយក្នុងការទាញហេតុផល នៅពេលដែលមានការអនុញ្ញាតពីតុលាការ ។ អ្នកជំនួយ គឺខុសពីអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ពីអ្នកតំណាងដោយអាណត្តិ ដែលធ្វើសកម្មភាពបណ្តឹងជំនួសភាគី ។ ក៏ប៉ុន្តែ សេចក្តីថ្លែងការណ៍ដែលអ្នកជំនួយបានធ្វើ ប្រសិនបើភាគី ឬ អ្នកតំណាងដោយអាណត្តិមិនបានលុបចោល ឬ កែតម្រូវភ្លាម១ទេ អានុភាពនៃសេចក្តីថ្លែងការណ៍នោះ នឹងធ្លាក់ទៅលើសាមីភាគី (មាត្រា ៥៨ កថាខណ្ឌទី ៣) ដូចសេចក្តីថ្លែងការណ៍របស់សាមីភាគី ឬ អ្នកតំណាងដោយអាណត្តិដែរ ។

របបអ្នកជំនួយត្រូវបានប្រើសម្រាប់បណ្តឹងទាក់ទងនឹងកម្មសិទ្ធិបញ្ញា ជាអាទិ៍ ដែលចាំបាច់ត្រូវមានចំណេះដឹងជំនាញ ហើយភាគី និង អ្នកតំណាងដោយអាណត្តិ ជាអាទិ៍ ពុំមានចំណេះដឹងនោះ ។

# គន្ថីទី ៣ នីតិវិធីបណ្ដឹងនៃការជំនុំជម្រះលើកទីមួយ

## ជំពូកទី ១ ការចាប់ផ្ដើមបណ្ដឹង

### ផ្នែកទី ១ ការដាក់ពាក្យបណ្ដឹង

#### កថាភាគទី ១ របៀបដាក់ពាក្យបណ្ដឹង

ចំពោះករណីគំរូនៅក្នុងគន្ថីទី ១ ក្នុងករណីដែល A និង B មានវិវាទជាមួយគ្នា ហើយមិនអាចដោះស្រាយវិវាទនោះដោយខ្លួនឯង និង ដោយស្ម័គ្រចិត្តបានទេ A ប្រហែលជានឹងគ្មានជម្រើសណាផ្សេងក្រៅពីការប្រើប្រាស់ប្រព័ន្ធតុលាការរដ្ឋប្បវេណីដើម្បីទទួលបាននូវដំណោះស្រាយដោយបង្ខំមួយនោះឡើយ ។ ដើម្បីទាមទារប្រាក់នោះមកវិញ A អាចដាក់ពាក្យបណ្ដឹងទៅតុលាការមួយកំណត់ ដើម្បីឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ B សងប្រាក់កំចី ១០ លានរៀលនោះមកវិញ ។ ផ្អែកលើសាលក្រមនោះ ការអនុវត្តដោយបង្ខំមួយអាចត្រូវធ្វើឡើង ។ ដូច្នេះនីតិវិធីនៃបណ្ដឹងត្រូវចាប់ផ្ដើមពីពេលដែល A ដាក់ពាក្យបណ្ដឹង ។

វាមាននូវបញ្ញត្តិច្បាប់ដែលចែងថា ការដាក់បណ្ដឹងត្រូវធ្វើដោយដាក់ពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរទៅតុលាការ (មាត្រា ៧៥ កថាខណ្ឌទី ១) ។ មានន័យថា ការប្ដឹង គឺជាសកម្មភាពមួយដែលទាមទារឱ្យមានការបំពេញនូវល័ក្ខខ័ណ្ឌជាក់លាក់មួយជាកំណត់ គឺ ការប្រគល់នូវពាក្យបណ្ដឹង (ដែលជា "សកម្មភាពដែលតម្រូវឱ្យមានល័ក្ខខ័ណ្ឌទម្រង់") ដើម្បីបង្គាប់ឱ្យបានច្បាស់លាស់នូវអង្គហេតុនៃការធ្វើបណ្ដឹងតាមនីតិវិធី ។

#### កថាភាគទី ២ ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង

១. ចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់ (មាត្រា ៧៥ កថាខណ្ឌទី ២)

ចំណុចដែលត្រូវសរសេរ ដើម្បីឱ្យពាក្យបណ្ដឹងមានសុពលភាព គេហៅថា ចំណុចចំបាច់ដែលត្រូវសរសេរបញ្ជាក់នៃពាក្យបណ្ដឹង ។ ពេលដែលមានកង្វះនូវចំណុចនេះ ពាក្យបណ្ដឹងគ្មានសុពលភាពឡើយ ។ មានន័យថា ពេលមានកង្វះនូវចំណុចនេះ តុលាការត្រូវបង្គាប់ឱ្យកែតម្រូវនូវកង្វះនេះ ហើយប្រសិនបើមិនបានធ្វើការកែតម្រូវទេ តុលាការត្រូវលើកបណ្ដឹងនោះចោល (មាត្រា ៧៨) (ស្ដីពីការពិនិត្យពាក្យបណ្ដឹង សូមមើលផ្នែកទី ៥ កថាភាគទី ១ ២. នៃជំពូកនេះ) ។

(១) ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក.)

(ក) ភាគី គឺជាឈ្មោះទូទៅនៃដើមចោទដែលបានធ្វើបណ្ដឹងទាមទារឱ្យចេញសាលក្រម និង ចុងចម្លើយដែលជាភាគីម្ខាងទៀតនៃបណ្ដឹងនោះ ។

ពេលដែលបានដាក់ពាក្យបណ្ដឹងហើយ តុលាការត្រូវមានករណីយកិច្ចធ្វើការវិនិច្ឆ័យស្ដីពីវិវាទរវាងដើមចោទ

និង ចុងចម្លើយនោះ ហើយជាគោលការណ៍ អានុភាពនៃសាលក្រមដែលចេញដោយតុលាការ នឹងមានឥទ្ធិពលទៅលើភាគី ហើយត្រូវចងភាគីនោះ (មាត្រា ១៩៨ កថាខណ្ឌទី ១) ។ ដូច្នេះ ក្នុងពាក្យបណ្ដឹង តើអ្នកណាជាដើមចោទ តើអ្នកណាជាចុងចម្លើយនោះ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ មានន័យថា តើអ្នកណាប្ដឹងអ្នកណា ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ។ ដូច្នេះ ដើម្បីកុំឱ្យមានការច្រឡំនឹងអ្នកផ្សេង ប្រសិនបើរូបវន្តបុគ្គល ត្រូវសរសេរអំពីអាសយដ្ឋាន និង ឈ្មោះអ្នកនោះ ប្រសិនបើនីតិបុគ្គលវិញ ត្រូវសរសេរនាមករណ៍ ឬ ឈ្មោះ និង ទីតាំងនៃទីស្នាក់ការរបស់នីតិបុគ្គលនោះ (បើជាក្រុមហ៊ុន គឺទីស្នាក់ការនាយក) ហើយបង្ហាញឱ្យបានច្បាស់លាស់អំពីដើមចោទ និង ចុងចម្លើយ (ប្រសិនបើអាចធ្វើទៅបាន គួរតែបញ្ជាក់អំពីអាសយដ្ឋានដើមតាមច្បាប់ អាយុ ភេទ ជាអាទិ៍ផងដែរ) ។ តាមរយៈចំណុចដែលបានសរសេរក្នុងពាក្យបណ្ដឹងនេះ យើងអាចដឹងច្បាស់លាស់ថា តើអ្នកណាជាភាគី ហើយការនេះ គេហៅថា ការបញ្ជាក់ ឬ ការកំណត់ភាគី ។ ក្នុងករណីជាក់ស្ដែង តាមធម្មតា តើអ្នកណាជាភាគី គឺត្រូវបានបញ្ជាក់ច្បាស់លាស់ ក៏ប៉ុន្តែ ឧទាហរណ៍ A បានប្រើឈ្មោះរបស់ B ដោយពុំមានការអនុញ្ញាតពីសាមីខ្លួន ហើយទៅធ្វើពាក្យបណ្ដឹងទៅតុលាការក្នុងនាម B ហើយបានបង្ហាញខ្លួននៅតុលាការ ក្លែងបន្លំធ្វើសកម្មភាពក្នុងនាមរបស់ B រីឯ B វិញ មិនបានដឹងខ្លួនទេ តែនីតិវិធីបណ្ដឹងនោះមានដំណើរការ ហើយចូលដល់ដំណាក់កាលមួយដែលតុលាការរៀបចេញសាលក្រម ក្នុងករណីនេះ បញ្ហាដែលមានគឺ តើដើមចោទនៃបណ្ដឹងនេះ ជា B ដែលត្រូវគេប្រើឈ្មោះដោយមិនដឹងខ្លួននោះ ឬ A ដែលបានធ្វើសកម្មភាពជាភាគីពិតប្រាកដនោះ (ស្ដីពីបទដ្ឋានធ្វើការកំណត់ភាគី សូមមើលការពន្យល់ក្នុងគន្ថីទី ២ ជំពូកទី ២ កថាភាគទី ១ ១.(២) ) ។

(ខ) បន្ទាប់មក ក្នុងករណីដែល ដោយសារតែភាគីពុំមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ដូចជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អ្នកតំណាងដែលច្បាប់បានកំណត់ត្រូវធ្វើសកម្មភាពបណ្ដឹងជំនួសភាគីនោះ (សកម្មភាពដែលបង្កើតអានុភាពតាមផ្លូវច្បាប់នីតិវិធី មានន័យថា ការដាក់ពាក្យបណ្ដឹង ការអះអាងស្ដីពីអង្គហេតុ ការស្នើសុំឱ្យពិនិត្យភស្តុតាង ជាដើម) ឬ ទទួលនូវសកម្មភាពបណ្ដឹងរបស់ភាគីម្ខាងទៀត ឬ របស់តុលាការ (ឧទាហរណ៍ ការទទួលនូវការបញ្ជូនពាក្យបណ្ដឹង) នៅក្នុងពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់អំពីឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក) ។ ក្នុងករណីដែលភាគីជានីតិបុគ្គល បញ្ញត្តិស្ដីពីការតំណាងដែលច្បាប់បានកំណត់ និង អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងនៃនីតិបុគ្គល (មាត្រា ៣៨) ហេតុនេះហើយ ត្រូវសរសេរ ឈ្មោះ និង អាសយដ្ឋានរបស់អភិបាល នាយកប្រតិបត្តិសហគ្រាស ជាអាទិ៍) ។

ផ្ទុយទៅវិញ ក្នុងពាក្យបណ្ដឹង ការសរសេរបញ្ជាក់អំពីអ្នកតំណាងដោយអាណត្តិ មិនមែនជាចំណុចដែលចាំបាច់សរសេរបញ្ជាក់ក្នុងពាក្យបណ្ដឹងទេ ។ ដូច្នេះហើយ ទោះបីជាមានកង្វះអំពីការសរសេរបញ្ជាក់ស្ដីពីអ្នកតំណាងដោយអាណត្តិក្នុងពាក្យបណ្ដឹងក៏ដោយ ក៏មិនមែនជាកម្មវត្ថុនៃការបង្គាប់ឱ្យកែតម្រូវពាក្យបណ្ដឹងទេ

(មាត្រា ៧៨ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ក្នុងករណីដែលបានជ្រើសតាំងអ្នកតំណាងដោយអាណត្តិ គួរតែសរសេរបញ្ជាក់អំពីឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងនោះ ជាការល្អ ។ នេះគឺដើម្បីបង្ហាញឱ្យគេដឹងថា តើអ្នកណាជាអ្នកធ្វើការតាមដានបណ្តឹងនោះពិតប្រាកដ ព្រមទាំងមានការងាយស្រួលក្នុងការបញ្ជូនឯកសារបណ្តឹង ។

**(២) ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ)**

(ក) ក្នុងពាក្យបណ្តឹង ដើមចោទត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដែលខ្លួនទាមទារ ។ ឧទាហរណ៍ ប្រសិនបើបានថ្លែងបញ្ជាក់ដូចជា "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ចុងចម្លើយត្រូវបង់ប្រាក់ ១០ លានរៀល ទៅឱ្យដើមចោទ" (ករណីនៃបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក) "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ដើមចោទពិតជាមានកម្មសិទ្ធិលើដីធ្លីដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីអចលនវត្ថុដែលមានភ្ជាប់ជាមួយ" (ករណីនៃបណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត) "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ដើមចោទ និង ចុងចម្លើយត្រូវលែងលះគ្នា" (ករណីនៃបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត) ជាដើម តើសាមីភាគីចង់ទាមទារឱ្យតុលាការចេញសាលក្រមដែលមានសេចក្តីសម្រេចបញ្ចប់យ៉ាងណានោះ នឹងត្រូវបានបញ្ជាក់ច្បាស់លាស់ ។ ការសរសេរបញ្ជាក់អំពីសាលក្រមដែលចង់ឱ្យតុលាការចេញនោះ គឺជាចំណុចមួយដែលចាំបាច់ត្រូវសរសេរបញ្ជាក់ក្នុងពាក្យបណ្តឹង ។ ការសរសេរបញ្ជាក់អំពីសាលក្រមដែលទាមទារនេះ គឺដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការអះអាងសិទ្ធិរបស់ដើមចោទ (មានន័យថា ការទាមទារតាមផ្លូវបណ្តឹង) រួមទាំងការសរសេរអំពីអង្គហេតុដែលនឹងពន្យល់ក្នុង (៣) ។ មានន័យថា ការសរសេរអំពីសាលក្រមដែលទាមទារឱ្យតុលាការចេញនោះ គឺមានតួនាទីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការទាមទារតាមផ្លូវបណ្តឹង ដែលជាកម្មវត្ថុនៃការជំនុំជម្រះក្នុងបណ្តឹងរដ្ឋប្បវេណីនោះ ព្រមទាំងកម្រិតនូវវិសាលភាពនៃការជំនុំជម្រះរបស់តុលាការ (ស្តីពីការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការទាមទារ សូមមើលការពន្យល់ក្នុងផ្នែកទី ៤) ។

(ខ) តាមគោលគំនិតដែលបានពន្យល់ខាងលើនេះ ជាដំបូង ការសរសេរអំពីសាលក្រមដែលទាមទារឱ្យតុលាការចេញនេះ ត្រូវធ្វើឱ្យបានលំអិត និង ឱ្យបានច្បាស់លាស់ ។ ក្នុងករណីទាមទារឱ្យបង់ជាប្រាក់ ជាអាទិ៍ ចាំបាច់ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីចំនួនទឹកប្រាក់ដែលទាមទារនោះ ជាអាទិ៍ ។ ឧទាហរណ៍ ក្នុងបណ្តឹងទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ការសរសេរបញ្ជាក់អំពីសាលក្រមដែលទាមទារឱ្យតុលាការចេញនោះ ត្រឹមតែថា ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា បង្គាប់ឱ្យចុងចម្លើយបង់សំណងនៃការខូចខាត ដែលស្មើនឹងចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ដោយមិនបញ្ជាក់អំពីទឹកប្រាក់នោះ មិនមានភាពគ្រប់គ្រាន់ទេ គឺចាំបាច់បញ្ជាក់អំពីចំនួនទឹកប្រាក់នោះផងដែរ ។ បញ្ហានេះក៏ដូចគ្នាដែរចំពោះករណីទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃកាតព្វកិច្ចជាប្រាក់ ។

ម្យ៉ាងទៀត ទីពីរគឺ ចំណុចដែលទាមទារឱ្យតុលាការចេញសាលក្រមនេះ ត្រូវឱ្យអាចកំណត់បានច្បាស់លាស់ មិនត្រូវភ្ជាប់នូវល័ក្ខខ័ណ្ឌ ឬ នូវកំណត់ពេលទេ ។ ឧទាហរណ៍ ការសរសេរក្នុងពាក្យបណ្តឹងថា "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ប្រសិនបើដើមចោទចាញ់បណ្តឹងដែលដាក់ដោយតតិយជន ដែលទាមទារឱ្យប្រគល់អាគារ ចុងចម្លើយត្រូវប្រគល់ផ្ទះដែលខ្លួនរស់នៅសព្វថ្ងៃនេះទៅឱ្យដើមចោទ" គឺមិនស្របច្បាប់ទេ ។ ទោះជាតុលាការបានដឹកនាំនីតិវិធីបណ្តឹង តាមការទាមទាររបស់ដើមចោទបែបនេះក៏ដោយ តែប្រសិនបើតុលាការផ្សេងដែលបានទទួលពាក្យបណ្តឹងរវាងដើមចោទនោះ និង តតិយជន បានវិនិច្ឆ័យឱ្យដើមចោទឈ្នះ ក្នុងករណីនេះ ដើមចោទមិនទាមទារនូវសាលក្រមនោះទៅវិញ ហេតុនេះហើយ នីតិវិធីចាប់ផ្តើមបណ្តឹង ក៏ក្លាយទៅជាគ្មានបានការទៅវិញ ដែលអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពនៃនីតិវិធីបណ្តឹងបាន (បើមើលពីទស្សនៈផ្សេងទៀត នេះគឺជាការផ្តល់ចំពោះតុលាការ និង ចុងចម្លើយ នូវឋានៈមួយដែលពុំមានស្ថិរភាពទៅវិញ) ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបំពេញ ឬ មិនបំពេញល័ក្ខខ័ណ្ឌ អាចត្រូវបានបញ្ជាក់ច្បាស់លាស់ក្នុងដំណើរការនៃការជំនុំជម្រះបណ្តឹងនោះ គឺពុំមានការធ្វើឱ្យខូចដល់ស្ថិរភាពក្នុងនីតិវិធីបណ្តឹងទេ ហេតុនេះហើយ ក្នុងករណីនេះ អាចអនុញ្ញាតឱ្យធ្វើការទាមទារដោយភ្ជាប់នូវល័ក្ខខ័ណ្ឌបាន (ពាក្យសុំសម្រាប់ត្រៀម ឬ ពាក្យសុំតាមជម្រើស) ។ មានន័យថា ក្នុងករណីដែលមានការសរសេរការទាមទារដែលមានលក្ខណៈត្រៀម និង ការទាមទារដែលមានលក្ខណៈមានឋានៈចម្បង ចំពោះចុងចម្លើយតែម្នាក់ ប្រសិនបើមិនមានការទទួលស្គាល់នូវការទាមទារក្នុងនាមជាឋានៈចម្បងទេ (មានន័យថា ទាមទារដោយមានល័ក្ខខ័ណ្ឌថា មិនទទួលស្គាល់នូវការទាមទារក្នុងនាមជាឋានៈចម្បង) គេអាចទទួលស្គាល់ការទាមទារនូវសាលក្រមដែលមានការទាមទារដែលមានលក្ខណៈត្រៀម ។ ឧទាហរណ៍ A បានអះអាងចំពោះ B ថា ភាគីទាំងសងខាងបានបង្កើតកិច្ចសន្យាលក់ទិញរថយន្តក្នុងតម្លៃ ១០ លានរៀលហើយ ដូច្នេះ B ត្រូវប្រគល់រថយន្តនោះមកឱ្យខ្លួន ហើយសរសេរក្នុងពាក្យបណ្តឹងថា "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ចុងចម្លើយត្រូវប្រគល់រថយន្តដែលមានបញ្ជាក់ក្នុងបញ្ជីសារពើភ័ណ្ឌដែលមានភ្ជាប់ជាមួយទៅឱ្យដើមចោទ" ហើយព្រមជាមួយគ្នានេះ អាចទាមទារត្រៀមចំពោះករណីដែលតុលាការមិនទទួលស្គាល់នូវសុពលភាពនៃកិច្ចសន្យានោះ ហើយច្រានចោលនូវការទាមទារនេះ ដោយធ្វើការអះអាងទាមទារឱ្យប្រគល់ប្រាក់ដែលបានបង់រួចហើយក្នុងពាក្យបណ្តឹងនោះដោយមានខ្លឹមសារថា "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ចុងចម្លើយត្រូវសងប្រាក់ ១០ លានរៀលទៅឱ្យដើមចោទវិញ" ។ ម្យ៉ាងទៀត ក៏អាចអនុញ្ញាតឱ្យធ្វើពាក្យបណ្តឹងដែលមានការទាមទារច្រើនដោយមានល័ក្ខខ័ណ្ឌរំលាយថា ការទទួលស្គាល់នូវការទាមទារណាមួយក្នុងចំណោមនៃការទាមទារច្រើនដោយតុលាការ (នេះគេហៅថា ការរួមបញ្ចូលនូវការទាមទារដោយជម្រើស) ។ ឧទាហរណ៍ អាចអនុញ្ញាតឱ្យធ្វើបណ្តឹងដែលមានខ្លឹមសារថា ប្រសិនបើតុលាការមិនទទួលស្គាល់នូវការទាមទារណាមួយ ក្នុងចំណោមនៃការទាមទារនូវសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល និង ការទាមទារនូវសំណងនៃការខូចខាត

ដោយមានមូលហេតុថា មិនបានអនុវត្តពេញលេញនូវកិច្ចសន្យាព្យាបាលជម្ងឺ ក្នុងរឿងក្តីស្តីពីកំហុសនៃការព្យាបាលតែមួយ ពេលនោះនឹងមិនទាមទារឱ្យចេញសាលក្រមដែលមានខ្លឹមសារនៃការទាមទារមួយទៀតទេ ។

(៣) អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ( មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ)

ពាក្យថា "អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ" ក្នុងនេះ មានន័យថា ជាអង្គហេតុចាំបាច់សម្រាប់បញ្ជាក់ (បង្ហាញ) អំពីការអះអាងអំពីសិទ្ធិ = ការទាមទារតាមផ្លូវបណ្តឹង ដែលដើមចោទទាមទារឱ្យតុលាការធ្វើការជំនុំជម្រះ និង ចេញសាលក្រមនៃបណ្តឹងនេះ ដើម្បីកុំឱ្យមានការភាន់ច្រឡំ និង ការមិនអាចបែងចែកបានទៅនឹងការទាមទារផ្សេងទៀត រួមជាមួយនឹងការសរសេរអំពីសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។

ដូចដែលនឹងពន្យល់ខាងក្រោម (សូមមើលផ្នែកទី ២ កថាភាគីទី ២) ក្នុងការទាមទារតាមផ្លូវបណ្តឹង (អាចហៅកាត់ថា ការទាមទារ) គឺ ត្រូវអះអាងអំពីសិទ្ធិកំណត់មួយរបស់ដើមចោទ មានន័យថា អះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជន ។ ក៏ប៉ុន្តែ ក្នុងចំណោមប្រភេទនៃបណ្តឹងដែលនឹងពន្យល់ខាងក្រោមនេះ ក្នុងករណីនៃការទាមទារឱ្យបញ្ជាក់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមរយៈសាលក្រមដែលទាមទារឱ្យតុលាការចេញ គេអាចបង្ហាញច្បាស់លាស់អំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាព (ឧទាហរណ៍ដូចជា កម្មសិទ្ធិរបស់ដើមចោទលើដីធ្លីណាមួយ) ហេតុនេះហើយ តាមរយៈការសរសេរនូវចំណុចនេះ តើដើមចោទបានអះអាងអំពីសិទ្ធិអ្វីខ្លះនោះ នឹងត្រូវបានបញ្ជាក់ច្បាស់លាស់ ។ ផ្ទុយទៅវិញ ក្នុងករណីនៃបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ឬ បណ្តឹងទាមទារឱ្យបង្កើតប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត តាមរយៈការសរសេរក្នុងសាលក្រមដែលទាមទារនោះ មានករណីខ្លះដែលគេមិនអាចដឹងឱ្យបានច្បាស់លាស់អំពីសិទ្ធិដែលដើមចោទបានអះអាងទេ ។ ឧទាហរណ៍ ទោះបីជាមានសរសេរក្នុងពាក្យបណ្តឹង នូវខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញថា "ទាមទារឱ្យចេញសាលក្រមដែលបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ ១០ លានរៀលទៅដើមចោទ" ក៏ដោយ ក៏អាចជាករណីដែលប្រាក់កំចីចំនួន ១០ លានរៀលរវាងភាគីនោះ មានច្រើនដង ឬ អាចជាករណីនៃប្រតិបត្តិការជំនួញ ដូចជាការលក់ទិញដែលមានទឹកប្រាក់ ១០ លានរៀល ជាអាទិ៍ ដែរ ហើយលើសពីនេះ អាចមានករណីដែលសិទ្ធិទាមទារឱ្យសងនូវសេចក្តីចំរើនឥតហេតុនោះ កើតមានឡើងដោយសារតែការអត់សុពលភាពនៃកិច្ចសន្យាឱ្យខ្ចីបរិភោគ ឬ កិច្ចសន្យាលក់ទិញ ជាអាទិ៍ ដូច្នេះ ការទាមទារឱ្យបង់ប្រាក់ ១០ លានរៀលនោះ ដែលអះអាងដោយដើមចោទក្នុងបណ្តឹងនោះ មិនដឹងថា ជាសិទ្ធិមួយណាទេ ។ ដូច្នេះ ដើម្បីឱ្យបានដឹងច្បាស់លាស់ថា ជាការអះអាងនូវសិទ្ធិមួយណានោះ ហើយកុំឱ្យមានការភាន់ច្រឡំ ឬ មានការមិនអាចបែងចែកឱ្យដាច់នឹងការអះអាងស្តីពីសិទ្ធិដទៃទៀតនោះ ចាំបាច់ត្រូវសរសេរអំពីអង្គហេតុបញ្ជាក់នូវការអះអាងសិទ្ធិនោះ ។ ក្នុងឧទាហរណ៍ខាងលើនេះ ប្រសិនបើបានសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការកើតមានឡើងនូវសិទ្ធិទាមទារឱ្យបង់ប្រាក់ ១០ លានរៀល

នោះ ដែលមានខ្លឹមសារឧទាហរណ៍ថា បានបង្កើតកិច្ចសន្យាខ្ចីបរិភោគនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ ដោយមានទឹកប្រាក់ ១០ លានរៀល ជាដើម យើងនឹងអាចដឹងបានច្បាស់លាស់ថា សិទ្ធិដែលអះអាងដោយដើមចោទក្នុងបណ្តឹងនោះ គឺជាសិទ្ធិទាមទារឱ្យសងប្រាក់កំចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលបង្កើតនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ ដូច្នេះការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ និង ការសម្រេចសេចក្តីក្នុងរឿងក្តីនោះ នឹងត្រូវបានកំណត់ច្បាស់លាស់ ។ ដូច្នេះ នៅក្នុងពាក្យបណ្តឹង ការទាមទារតាមផ្លូវបណ្តឹងត្រូវសរសេរអំពីអង្គហេតុដែលអាចធ្វើការកំណត់នូវសិទ្ធិនោះ (អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ) ដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬ មានការមិនអាចបែងចែកច្បាស់លាស់នឹងសិទ្ធិដទៃទៀត ។

២. ចំណុចដែលត្រូវសរសេរ ក្រៅពីនេះ (មាត្រា ៧៥ កថាខណ្ឌទី ៣ និង ទី ៤)

ដើម្បីទទួលស្គាល់នូវសុពលភាពនៃពាក្យបណ្តឹង ត្រូវសរសេរអំពីចំណុចដែលចាំបាច់ ដូចដែលបានពន្យល់ក្នុង ១. ខាងលើនេះ ។ តាមរយៈពាក្យបណ្តឹងបែបនេះ តុលាការមិនអាចលើកបណ្តឹងនោះចោលបានទេ ហើយត្រូវបញ្ជូនទៅឱ្យចុងចម្លើយ (មាត្រា ៧៩ កថាខណ្ឌទី ១) ហើយដឹកនាំនីតិវិធីបណ្តឹងនោះ ។ ក៏ប៉ុន្តែ ឧទាហរណ៍មានពាក្យបណ្តឹងមួយដែលនៅក្នុងនោះ ដើមចោទបានសរសេរបង្ហាញអំពីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ហើយទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា "ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារថា ដើមចោទមានកម្មសិទ្ធិទៅលើដីទំហំ ១៦៥.០០ ម៉ែត្រការ៉េ ដែលមាននៅអាសយដ្ឋានលេខ ..... ផ្លូវ ...... សង្កាត់ .... ខណ្ឌ ..... ក្រុងភ្នំពេញ" ។ នេះគឺជាបណ្តឹងទាមទារឱ្យបញ្ជាក់សិទ្ធិ ដូច្នេះយោងតាមការពន្យល់ខាងលើនេះ (សូមមើលការពន្យល់ក្នុង ១. (៣)) តាមការសរសេរក្នុងចំណុចស្តីពីសាលក្រមដែលទាមទារឱ្យតុលាការចេញនេះ យើងអាចកំណត់បានអំពីសិទ្ធិ ដែលជាខ្លឹមសារនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ (កម្មវត្ថុនៃបណ្តឹង) ។ ក៏ប៉ុន្តែ ក្នុងករណីនេះ គេមិនអាចដឹងច្បាស់លាស់អំពីមូលហេតុដែលដើមចោទបានអះអាងនូវកម្មសិទ្ធិនោះទេ ហើយចុងចម្លើយក៏មិនអាចអះអាងអំពីអង្គហេតុដើម្បីការពារខ្លួនបានទេ ដូច្នេះចុងចម្លើយមិនអាចឆ្លើយតបនឹងបណ្តឹងនេះបានទេ ។ នាកាលបរិច្ឆេទដំបូង នៅតុលាការ ដើម្បីពន្យល់អំពីមូលហេតុសម្រាប់គាំទ្រការអះអាងសិទ្ធិរបស់ខ្លួន ដើមចោទបានថ្លែងការណ៍ថា ដីធ្លីនោះ គឺខ្លួនបានទិញពីកម្មសិទ្ធិករមុន នៅថ្ងៃទី ..... ខែ ..... ឆ្នាំ ..... (ការដាក់មធ្យោបាយតទល់គ្នា) ហើយទើបចុងចម្លើយអាចធ្វើការទទួលស្គាល់ ឬ បដិសេធនូវអង្គហេតុនោះបាន ឬក៏ឆ្លើយតបថា ការលក់ទិញនោះមោឃៈ ជាដើម (ការដាក់មធ្យោបាយការពារខ្លួន) ។

ប្រសិនបើអាចឆ្លើយភ្លាមៗបាន ដូចករណីខាងលើនេះ ជាការល្អ ក៏ប៉ុន្តែ អាចមានករណីដែលត្រូវស្រាវជ្រាវសិន ទើបអាចឆ្លើយតបបាន ដូច្នេះត្រូវកំណត់នូវកាលបរិច្ឆេទថ្មីដើម្បីត្រៀមឆ្លើយតបវិញ ហើយត្រូវលើកការឆ្លើយតបនោះរហូតដល់កាលបរិច្ឆេទថ្មីនេះ ដែលជាបញ្ហាមួយធ្វើឱ្យមានការយឺតយ៉ាវដល់បណ្តឹង ។ ដូច្នេះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចវិវាទឱ្យទាន់ពេលវេលា ហើយការពារនូវការអាក់រអួលនៃកាលបរិច្ឆេទ

នៅក្នុងពាក្យបណ្ដឹង ក្រៅពីសរសេរបញ្ជាក់អំពីសាលក្រមដែលទាមទារឱ្យតុលាការចេញ និង អង្គហេតុដែលចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គប្បីសរសេរឱ្យបានលំអិតអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារព្រមទាំងអង្គហេតុសំខាន់ៗដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ (អង្គហេតុប្រយោលដែលសំខាន់ៗ) និង ភស្តុតាង តាមចំណុចដែលត្រូវបញ្ជាក់ (មាត្រា ៧៥ កថាខណ្ឌទី ៣) ។ ការលើកពាក្យបណ្ដឹងចោល ដោយយកមូលហេតុថា មានកង្វះនូវចំណុចដែលចាំបាច់សរសេរក្នុងពាក្យបណ្ដឹងនោះ គឺអាចធ្វើទៅបានតែចំពោះកង្វះនូវចំណុចដែលត្រូវសរសេរបញ្ជាក់ប៉ុណ្ណោះ (មាត្រា ៧៨ កថាខណ្ឌទី ១ និង ទី ២) ដូច្នេះហើយ ចំណុចដែលមានខាងលើនេះ ទោះជាមិនបានសរសេរ ក៏ដោយ ក៏មិនអាចយកមកធ្វើជាមូលហេតុនៃការលើកបណ្ដឹងចោលបានទេ ។ ក្នុងន័យនេះ មាត្រា ៧៥ កថាខណ្ឌទី ៣ គឺជាបញ្ញត្តិណែនាំ ប៉ុន្តែ ហើយតាមគោលគំនិតដែលបានពន្យល់មុននេះ ទម្លាប់សរសេរនូវចំណុចដែលមានចែងក្នុងបញ្ញត្តិនេះ គឺជាការសំខាន់ ។ ម្យ៉ាងទៀត ការអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ (អង្គហេតុចម្បង) និង ការអះអាងអំពីអង្គហេតុដែលពាក់ព័ន្ធនឹងអង្គហេតុចម្បងនោះ (អង្គហេតុប្រយោល) គប្បីសរសេរបែងចែកឱ្យដាច់ពីគ្នា ។ ម្យ៉ាងទៀត ក្នុងពាក្យបណ្ដឹង ត្រូវសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដោយអាណត្តិ ព្រមទាំងលេខទូរស័ព្ទ (រួមទាំងលេខទូរសារ) ជាអាទិ៍ របស់ដើមចោទ ឬ អ្នកតំណាងដោយអាណត្តិនោះ ។ លើសពីនេះ ដើម្បីឱ្យអាចដឹកនាំបណ្ដឹងឱ្យបានទាន់ពេលវេលា ចាំបាច់ត្រូវមានភ្ជាប់ក្នុងពាក្យបណ្ដឹងនេះ នូវសេចក្ដីចម្លងនៃភស្តុតាងជាឯកសារសំខាន់ៗ ជាអាទិ៍ ផងដែរ ។

ជាទូទៅ ចំណុចក្រៅពីចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់ គេហៅថា ចំណុចដែលត្រូវសរសេរដោយស្ម័គ្រចិត្ត ។

## ផ្នែកទី ២ បណ្ដឹង និង ការទាមទារតាមផ្លូវបណ្ដឹង

### កថាភាគទី ១ អត្ថន័យនៃបណ្ដឹង

ខាងលើនេះ គឺជាការពន្យល់ត្រួសៗអំពីបណ្ដឹង បន្ទាប់មក តើ "បណ្ដឹង" មានអត្ថន័យយ៉ាងណាដែរ ? បណ្ដឹងគឺជាសកម្មភាពទាមទារមួយ (ពាក្យសុំ) ដែលដើមចោទ (ក្នុងករណីឧទាហរណ៍ខាងលើនេះ គឺ A ជាដើមចោទ) បានធ្វើឡើងចំពោះចុងចម្លើយ (ក្នុងករណីឧទាហរណ៍ខាងលើនេះ គឺ B ជាចុងចម្លើយ) ទៅតុលាការនៃការជំនុំជម្រះលើកទីមួយដែលត្រូវបានកំណត់ (ឧទាហរណ៍ សាលាដំបូងនៅភ្នំពេញ) ដោយបានលើកឡើងនូវការអះអាងអំពីអត្ថិភាព (ករណីឧទាហរណ៍នេះ) ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនកំណត់មួយ (សិទ្ធិទាមទារឱ្យសងប្រាក់កំចី ១០ លានរៀល ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដែលបានបង្កើតឡើងនាថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥) (ការអះអាងបែបនេះ ត្រូវហៅថា ការទាមទារតាមផ្លូវបណ្ដឹង) ហើយទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារកំណត់មួយ ដោយ

ផ្អែកលើការអះអាងទាំងនេះ ហើយជាគោលការណ៍ សកម្មភាពនៃបណ្តឹងនេះ ត្រូវធ្វើឡើងតាមវិធីដាក់ពាក្យបណ្តឹង ។ តាមរយៈការដាក់ពាក្យបណ្តឹងនេះ នីតិវិធីនៃបណ្តឹងនឹងត្រូវបានចាប់ផ្តើម ។

ជាបឋម បណ្តឹងគឺជាពាក្យសុំទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារកំណត់មួយ ។ តុលាការត្រូវចាំរហូតដល់បានទទួលពាក្យបណ្តឹង ទើបអាចចាប់ផ្តើមធ្វើការជំនុំជម្រះបណ្តឹងនោះបាន ម្យ៉ាងទៀត ជាគោលការណ៍ តុលាការអាចចេញសាលក្រមអំពីចំណុចដែលដើមចោទបានសុំដែលមាននៅក្នុងពាក្យបណ្តឹង ត្រឹមតែទំហំនៃការទាមទារដែលដើមចោទបានសុំដែលមាននៅក្នុងពាក្យបណ្តឹងនោះប៉ុណ្ណោះ (ដូច្នេះ ប្រសិនបើដើមចោទទាមទារតែឱ្យចុងចម្លើយសងប្រាក់ដើម ដែលជាប្រាក់កំចី ១០ លានរៀល ហើយទោះជាតុលាការបានទទួលស្គាល់នូវសិទ្ធិទាមទារការប្រាក់ ១ លានរៀលក៏ដោយ តុលាការមិនអាចចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់ ១ លានរៀលបានទេ ម្យ៉ាងទៀត ប្រសិនបើដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ ៨ លានរៀល ក្នុងចំណោមទឹកប្រាក់ ១០ លានរៀលនោះ តុលាការមិនអាចចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់លើសពី ៨ លានរៀលបានឡើយ (សូមមើលមាត្រា ១៨២ កថាខណ្ឌទី ២) ។ មានន័យថា គឺជាគោលការណ៍ "បើគ្មានបណ្តឹងទេ ក៏គ្មានមានសាលក្រមដែរ" ហើយគេហៅថា គោលការណ៍នៃសិទ្ធិចាត់ចែង ។

បន្ទាប់មក បណ្តឹងគឺជាសកម្មភាពដែលធ្វើឡើងចំពោះតុលាការ មិនមែនជាសកម្មភាពដែលទាមទារឱ្យចុងចម្លើយធ្វើសកម្មភាពណាមួយទេ ឧទាហរណ៍ មិនមែនជាសកម្មភាពទាមទារឱ្យទទួលស្គាល់ ឬ ឱ្យអនុវត្តកាតព្វកិច្ចទេ ។

## កថាភាគទី ២ ការទាមទារតាមផ្លូវបណ្តឹង និង កម្មវត្ថុនៃបណ្តឹង

ការទាមទារតាមផ្លូវបណ្តឹង អាចនិយាយថា ខ្លឹមសារនៃបណ្តឹង គឺអាចដឹងបានច្បាស់លាស់តាមរយៈអត្ថន័យនៃបណ្តឹង ។ មានន័យថា ការទាមទារតាមផ្លូវបណ្តឹង គឺជាការអះអាងស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នីតិឯកជនដែលបានកំណត់មួយ តាមរយៈបណ្តឹងរបស់ដើមចោទចំពោះចុងចម្លើយ ។ ការអះអាងនោះត្រូវ ឬ មិនត្រូវ គឺជាកម្មវត្ថុនៃការជំនុំជម្រះ និង សម្រេចសេចក្តីនៃបណ្តឹង ។ ពេលធ្វើការវិនិច្ឆ័យមើលថា តើការអះអាងនោះត្រឹមត្រូវ ឬ មិនត្រឹមត្រូវនោះ ប្រសិនបើទទួលស្គាល់ថា ការអះអាងសិទ្ធិនោះត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមតាមការទាមទារក្នុងបណ្តឹងរបស់ដើមចោទ តែផ្ទុយទៅវិញ ប្រសិនបើមិនទទួលស្គាល់ថា ការអះអាងសិទ្ធិនោះត្រឹមត្រូវទេ ត្រូវចេញសាលក្រមច្រានចោលការទាមទាររបស់ដើមចោទ ។ ដូច្នេះ ការទាមទារតាមផ្លូវបណ្តឹង = ការអះអាងអំពីសិទ្ធិ គឺជាខ្លឹមសារសារធាតុនៃបណ្តឹង ក៏ប៉ុន្តែត្រូវបែងចែកឱ្យដាច់គ្នា អំពីការទាមទារ និង បណ្តឹង ។

## ១. អត្ថន័យនៃការទាមទារតាមផ្លូវបណ្តឹង

ការទាមទារតាមផ្លូវបណ្តឹង ចាំបាច់ជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់សារធាតុដែលបានកំណត់ ។ គ្រាន់តែសរសេរថា "ដើមចោទមានសិទ្ធិទាមទារឱ្យចុងចម្លើយប្រគល់អាគារដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌនៃអចលនវត្ថុដែលមានភ្ជាប់ជាមួយ" គឺមិនគ្រប់គ្រាន់ទេ គឺត្រូវអះអាងថាដូចជា "ដោយសារតែអំឡុងពេលជួលក្នុងកតិសន្យាបានកន្លងផុតទៅហើយ ដូច្នេះ ដើមចោទមានសិទ្ធិទាមទារឱ្យចុងចម្លើយប្រគល់អាគារដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌនៃអចលនវត្ថុដែលមានភ្ជាប់ជាមួយ" ឬ "ដើមចោទមានសិទ្ធិទាមទារឱ្យចុងចម្លើយប្រគល់អាគារមកវិញ ដោយផ្អែកលើកម្មសិទ្ធិនៃអាគារដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌដែលមានភ្ជាប់ជាមួយ" ។ ការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុដែលបានកំណត់នោះ ដែលជាការទាមទារតាមផ្លូវបណ្តឹង គឺជាកម្មវត្ថុនៃការវិនិច្ឆ័យ និងសម្រេចសេចក្តីក្នុងបណ្តឹង ដូចដែលបានពន្យល់ខាងលើនេះ ហើយនេះគេហៅថា កម្មវត្ថុនៃបណ្តឹង ។ ក៏ប៉ុន្តែពាក្យ "កម្មវត្ថុនៃបណ្តឹង" អាចប្រើបានដើម្បីចង្អុលសិទ្ធិ និង ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ដែលត្រូវបានយកមកអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនោះ ។

បន្ទាប់មក ហេតុអ្វីបានជាការទាមទារតាមផ្លូវបណ្តឹង ចាំបាច់ត្រូវអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃ "សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុដែលបានកំណត់" ដូចជា សិទ្ធិទាមទារឱ្យសងវត្ថុជួលមកវិញ ឬ សិទ្ធិទាមទារឱ្យសងវត្ថុដែលជាកម្មសិទ្ធិមកវិញ ជាដើម ។ នេះគឺដោយសារតែ ដើម្បីធ្វើការវិនិច្ឆ័យថា តើការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទត្រូវ ឬ ខុស តុលាការត្រូវធ្វើការទទួលស្គាល់នូវអង្គហេតុដែលដើមចោទបានអះអាងដោយភស្តុតាង ហើយអនុវត្តច្បាប់សារធាតុចំពោះអង្គហេតុនោះ ដើម្បីវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលអះអាងដោយដើមចោទ (គោលការណ៍នៃការវិនិច្ឆ័យតាមច្បាប់) ។ ដោយសារតែច្បាប់សារធាតុបានចែងអំពីល័ក្ខខ័ណ្ឌនៃការបង្កើត ការប្តូរ ការរំលត់ ជាអាទិ៍ នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនីមួយៗ (ល័ក្ខខ័ណ្ឌគតិយុត្ត) ដូចជា សិទ្ធិទាមទារឱ្យសងវត្ថុជួលមកវិញ ឬ សិទ្ធិទាមទារឱ្យប្រគល់វត្ថុដែលជាកម្មសិទ្ធិមកវិញ ព្រមទាំងអានុភាពនៃសិទ្ធិនោះ ដែលមានការបង្កើត ការប្តូរ ការរំលត់ ជាអាទិ៍នៃសិទ្ធិនីមួយៗនោះ (អានុភាពគតិយុត្ត) ហេតុនេះហើយ ដើម្បីធ្វើការវិនិច្ឆ័យថា តើការអះអាងរបស់ដើមចោទត្រឹមត្រូវឬទេនោះដោយអនុវត្តច្បាប់សារធាតុ ការអះអាងនោះ គឺ ត្រូវជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តណាមួយដែលមានចែងក្នុងច្បាប់សារធាតុ ។

## ២. ភាពតែមួយនៃការទាមទារតាមផ្លូវបណ្តឹង

ចំពោះបញ្ហាថា តើការទាមទារតាមផ្លូវបណ្តឹងមានភាពដូចគ្នា ឬ មិនដូចគ្នា មិនត្រូវគ្នានឹងបញ្ហាថា តើសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុដែលបានអះអាងក្នុងខ្លឹមសារនោះមានភាពដូចគ្នា ឬ មិនដូចគ្នាទេ ។ ឧទាហរណ៍ ក្នុងករណីខាងលើនេះ រវាងបណ្តឹងរបស់ A ដែលទាមទារឱ្យ B សងប្រាក់ ១០ លានរៀល

ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានធ្វើឡើងនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ (បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក) និង បណ្តឹងរបស់ B ដែលបានធ្វើចំពោះ A ទាមទារឱ្យបញ្ជាក់នូវនត្ថិភាពនៃកាតព្វកិច្ចសងប្រាក់កំចី (បណ្តឹងទាមទារឱ្យការបញ្ជាក់សិទ្ធិ) សិទ្ធិដែលត្រូវបានអះអាងនោះ គឺជាសិទ្ធិដូចគ្នា គឺសិទ្ធិទាមទារឱ្យសងប្រាក់កំចីដោយផ្អែកលើកិច្ចសន្យាតែមួយ ក៏ប៉ុន្តែ បើគិតពីការទាមទារតាមផ្លូវបណ្តឹងវិញ ក្នុងករណីទីមួយ ភាគីអះអាងអំពីអត្ថិភាពនៃសិទ្ធិនេះ ដើម្បីចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់កំចី រីឯក្នុងករណីទីពីរវិញ ភាគីអះអាងនត្ថិភាពនៃសិទ្ធិនេះ ដើម្បីទាមទារឱ្យបញ្ជាក់ជាស្ថាពរនូវនត្ថិភាពនៃសិទ្ធិនេះ ដូច្នេះករណីទាំងពីរនេះខុសគ្នា ។ ដូច្នេះ ចំពោះបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកដោយផ្អែកលើសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកតាមផ្លូវច្បាប់សារធាតុដែលបានកំណត់ និង បណ្តឹងទាមទារឱ្យបញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ សិទ្ធិតាមផ្លូវច្បាប់សារធាតុដែលជាកម្មវត្ថុនៃការវិនិច្ឆ័យនៅក្នុងបណ្តឹងនោះ គឺ ដូចគ្នាទេ ក៏ប៉ុន្តែ បើគិតពីការទាមទារតាមផ្លូវបណ្តឹងវិញ គឺជាការទាមទារផ្សេងគ្នាទេ ។ ហេតុនេះហើយ ពេលធ្វើការវិនិច្ឆ័យថាជាបណ្តឹងជាន់គ្នា (មាត្រា ៨៣) ឬ វិនិច្ឆ័យអំពីវិសាលភាពដោយកម្មវិស័យភាពនៃអាជ្ញាអស់ជំនុំ (មាត្រា ១៩៤) ជាអាទិ៍ ចាំបាច់ត្រូវពិនិត្យមើលអំពីភាពដូចគ្នា ឬ មិនដូចគ្នានៃការទាមទារតាមផ្លូវបណ្តឹងផង ហើយក្រៅពីនេះ ត្រូវពិនិត្យមើលអំពីភាពដូចគ្នា ឬ មិនដូចគ្នានៃសិទ្ធិ ឬ កាតព្វកិច្ចតាមផ្លូវច្បាប់សារធាតុដែលត្រូវបានអះអាងផងដែរ ។

ម្យ៉ាងទៀត មានមតិខ្លះថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលបានកំណត់ គឺជាកម្មវត្ថុនៃការវិនិច្ឆ័យ ក៏ប៉ុន្តែ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះ មិនទាន់ត្រូវបានកំណត់ជាស្ថាពររវាងភាគីទេ ហេតុនេះហើយបានជាមានបណ្តឹងនោះ ដូច្នេះ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងនោះ គឺគ្រាន់តែជាការអះអាងរបស់ដើមចោទប៉ុណ្ណោះ មិនមែនជាសិទ្ធិពិតប្រាកដ ឬ ទំនាក់ទំនងគតិយុត្តពិតប្រាកដនៅឡើយទេ ។ ដូច្នេះ បើនិយាយឱ្យត្រឹមត្រូវទៅ កម្មវត្ថុនៃបណ្តឹង គឺជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដូចដែលបានពន្យល់ខាងលើនេះ ។

### ៣. គំនិតផ្ទុយគ្នា ស្តីពីភាពតែមួយនៃការទាមទារតាមផ្លូវបណ្តឹង

ស្តីពីការទាមទារតាមផ្លូវបណ្តឹង អាចមានបញ្ហាអំពីការកំណត់ការទាមទារនោះ (សូមមើលផ្នែកទី ៤) ហើយដោយផ្អែកទៅលើការទាមទារដែលបានកំណត់នោះ អានុភាពតាមផ្លូវច្បាប់ ត្រូវបានសម្រេច ដូចជា ការបញ្ចូលការទាមទារ (មាត្រា ៧៧) ការហាមបណ្តឹងជាន់គ្នា (មាត្រា ៨៣) ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង (មាត្រា ៨៤) ការហាមដាក់បណ្តឹងម្តងទៀត ក្រោយការដកពាក្យបណ្តឹង (មាត្រា ២១៨ កថាខណ្ឌទី ២) វិសាលភាពដោយកម្មវិស័យភាពនៃអាជ្ញាអស់ជំនុំ (មាត្រា ១៩៤) ជាដើម ។ ដូច្នេះ បទដ្ឋានស្តីពីបញ្ហាថា តើទំហំណា ទើបចាត់ទុកថា ជាកម្មវត្ថុបណ្តឹងតែមួយ មានន័យសំខាន់ណាស់ តាមច្បាប់នីតិវិធី ។ ហើយស្តីពីបទដ្ឋាននេះ មានមតិមួយថា ឱ្យធ្វើការសម្រេចនូវភាពតែមួយនៃការទាមទារតាមផ្លូវបណ្តឹង ចំពោះសិទ្ធិ ឬ

ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុនីមួយៗ ហើយក្រៅពីនេះ មានមតិមួយទៀតថា យកការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃឋានៈអរូបិយតាមផ្លូវច្បាប់ក្នុងការអាចទាមទារឱ្យផ្តល់តាវកាលិកកំណត់មួយ ដោយផ្អែកលើទំនាក់ទំនងនៃអង្គហេតុកំណត់មួយ យកមកធ្វើការកំណត់ភាពដូចគ្នានៃការទាមទារតាមផ្លូវបណ្តឹង ឬ មានមតិមួយទៀតថា ធ្វើការបែងចែកភាពដូចគ្នានៃការទាមទារតាមផ្លូវបណ្តឹង ដោយភាពដូចគ្នានៃខ្លឹមសារនៃសាលក្រមដែលត្រូវបានទាមទារក្នុងបណ្តឹង ព្រមទាំងទំនាក់ទំនងអង្គហេតុដែលត្រូវបានអះអាង ជាដើម ។ នៅប្រទេសអាល្លឺម៉ង់ ឬ បារាំង គេយកមតិក្រោយនេះមកប្រើ ក៏ប៉ុន្តែ នៅប្រទេសជប៉ុនវិញ គេយកមតិមុនមកអនុវត្តក្នុងកិច្ចការជាក់ស្តែង ។ ក្នុងសៀវភៅនេះ យើងខ្ញុំបកស្រាយដោយផ្អែកលើមតិមុនដែរ ។

## ផ្នែកទី ៣ ប្រភេទនៃបណ្តឹង

បណ្តឹងអាចបែងចែកជាច្រើនប្រភេទ ទៅតាមបទដ្ឋាននីមួយៗ ក៏ប៉ុន្តែ វិធីបែងចែកដែលជាមូលដ្ឋាន គឺការបែងចែកដោយយកប្រភេទ និង បែបយ៉ាងនៃការទាមទារតាមផ្លូវបណ្តឹង ដែលជាខ្លឹមសារនៃបណ្តឹង មកធ្វើជាបទដ្ឋាន មានន័យថា អាចបែងចែកជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក បណ្តឹងទាមទារឱ្យបញ្ជាក់ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ។

### កថាភាគទី ១ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

១. អត្ថន័យនៃបណ្តឹងទាមទារឱ្យផ្សល់តាវកាលិក

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក គឺជាបណ្តឹងមួយដែលទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកតាមផ្លូវច្បាប់សារធាតុដែលបានកំណត់ នៅក្នុងការទាមទារតាមផ្លូវបណ្តឹង ។ នៅក្នុងករណីឧទាហរណ៍ដែលបានលើកឡើង នៅភាគដើមនៃសៀវភៅនេះ A បានអះអាងចំពោះ B នូវសិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ១០ លានរៀល ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងនាថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ ហើយទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ B បង់ប្រាក់នោះ ។ ដូច្នេះហើយ ក្នុងករណីនេះ បណ្តឹងដែល A ត្រូវដាក់ គឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនោះតែម្តង ។ រីឯខ្លឹមសារនៃតាវកាលិកវិញ តាមធម្មតា ក្រៅពីការបង់ប្រាក់កំណត់មួយដូចករណីខាងលើនេះ អាចមានករណីច្រើន ដូចជា ការទាមទារឱ្យប្រគល់អចលនវត្ថុ ដូចជាដីធ្លី ផ្ទះសម្បែង ជាអាទិ៍ ការទាមទារឱ្យប្រគល់ចលនវត្ថុ ការទាមទារឱ្យបង្ហាញឆន្ទៈកំណត់មួយ (ឧទាហរណ៍ ការដាក់សំណូមពាក្យចុះបញ្ជី) ក៏ប៉ុន្តែ ក្រៅពីនេះ អាចមានការទាមទារឱ្យធ្វើសកម្មភាពណាមួយ ឬ ការទាមទារមិនឱ្យធ្វើសកម្មភាពណាមួយ ។

២. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន និង បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត

ចំពោះបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក មានបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន និង បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត ។

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន គឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកដែលដើមចោទបានដាក់ឡើង ដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះបានមកដល់ហើយ ។ រីឯបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគតវិញ គឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកដែលដើមចោទបានដាក់ឡើង ដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះមិនទាន់មកដល់នៅឡើយទេ ។ ក្នុងករណីដែលដើមចោទបានដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ដោយអះអាងអំពីសិទ្ធិទាមទារមួយ ដែលមិនទាន់ដល់ពេលកំណត់ត្រូវអនុវត្ត ហើយពេលដែលបណ្តឹងនោះកំពុងត្រូវបានតុលាការចាត់ការ ពេលកំណត់ត្រូវអនុវត្តនោះបានមកដល់ ជាលទ្ធផលបណ្តឹងនោះនឹងក្លាយទៅជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្នទៅវិញ ហេតុនេះហើយ ប្រសិនបើយើងគិតអំពីបញ្ហានេះផងដែរ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាបច្ចុប្បន្ន គឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនៃករណីដែលពេលកំណត់ត្រូវអនុវត្តសិទ្ធិទាមទារដែលអះអាងដោយដើមចោទបានមកដល់ មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការវិនិច្ឆ័យទៅលើអង្គហេតុ ។

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត គឺជាការទាមទារនូវសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិក ដោយមានការអះអាងនូវសិទ្ធិទាមទារដែលពេលកំណត់ត្រូវអនុវត្តមិនទាន់មកដល់ ហេតុនេះហើយ គេអាចដាក់ពាក្យបណ្តឹងបាន តែក្នុងករណីដែលមានការចាំបាច់ទាមទារបែបនេះជាមុនប៉ុណ្ណោះ (មាត្រា ៧៦) ។ ករណីដែលចាំបាច់ទាមទារបែបនេះជាមុន គឺជាករណីដូចជា ចំពោះកាតព្វកិច្ចដែលមានពេលកំណត់ស្ថាពរត្រូវបានកំណត់ តែអាចព្យាករណ៍បានថា ទោះជាដល់ពេលកំណត់ត្រូវសងក៏ដោយ ក៏កូនបំណុលមិនសងដែរ (ចុងចម្លើយមិនបានបង់ប្រាក់ដើម និង ការប្រាក់នៃប្រាក់កំចី ទោះជាពេលកំណត់ត្រូវសងបានកន្លងផុតហើយក៏ដោយ ដូច្នេះ ច្បាស់ជាកូនបំណុលនោះមិនបង់ការប្រាក់ដែលនឹងកើតឡើងនាអនាគតទេ ទោះជាដល់ពេលកំណត់ត្រូវសងក៏ដោយ ជាដើម) ឬ ករណីដែលអាចមានការខូចប្រយោជន៍ដល់ម្ចាស់បំណុល ដែលមិនអាចស្តារឡើងវិញបាន បើមិនបានទទួលការបង់នៅពេលកំណត់ត្រូវអនុវត្ត ដូចជាការបង់ប្រាក់អាហារកិច្ច ជាដើម ។ ដូច្នេះហើយ ចំពោះបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត ចាំបាច់ត្រូវមានផលប្រយោជន៍ពិសេសនៃបណ្តឹង ។

៣. សាលក្រមនៃបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

ចំពោះបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ប្រសិនបើមានការទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្តល់តាវកាលិក

ដែលមានខ្លឹមសារកំណត់មួយ (ការបង់ប្រាក់កំណត់មួយ ការប្រគល់វត្ថុ ជាអាទិ៍) តាមការទាមទាររបស់ដើមចោទ ។ សាលក្រមប្រភេទនេះ គេហៅថា សាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ។ សាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកមានអានុភាពកំណត់ជាស្ថាពរអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលអះអាងដោយដើមចោទ (នេះគេហៅថា អាជ្ញាអស់ជំនុំសារធាតុ ។ ស្តីពីអាជ្ញាអស់ជំនុំសារធាតុនេះ សូមមើលជំពូកទី ៤ ផ្នែកទី ១ កថាភាគទី ៣ ៣.) ហើយក្រៅពីនេះ មានអានុភាពអនុវត្ត មានន័យថា ដើមចោទអាចសម្រេចនូវសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយសាលក្រម តាមការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមនោះ ។ តាមធម្មតា លិខិតដែល ទទួលស្គាល់នូវអានុភាពអនុវត្តក្នុងន័យនេះ គេហៅថា លិខិតអនុវត្ត (សូមមើលមាត្រា ៣៥០ កថាខណ្ឌទី ១) ហើយសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក គឺជាឧទាហរណ៍ចម្បងនៃលិខិតអនុវត្ត (សូមមើលមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក និង ខ) ។

ប្រសិនបើមានការមិនអាចទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលអះអាងដោយដើមចោទ តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារថា "ច្រានចោលការទាមទាររបស់ដើមចោទ" ។ សាលក្រមច្រានចោលនូវការទាមទារនេះ ពុំមានអានុភាពអនុវត្តទេ ក៏ប៉ុន្តែ មានអាជ្ញាអស់ជំនុំសារធាតុដែលកំណត់ជាស្ថាពរនូវនត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ដែលអះអាងដោយដើមចោទ (ក្នុងករណីឧទាហរណ៍នេះ ពេលដែលសាលក្រមច្រានចោលនូវការទាមទាររបស់ A បានចូលជាស្ថាពរ អាជ្ញាអស់ជំនុំសារធាតុស្តីពីនត្ថិភាពនៃសិទ្ធិទាមទារឱ្យសងប្រាក់កំចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបង្កើតឡើងនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ ដែលអះអាងដោយ A នឹងកើតមានឡើង ហើយ A លែងអាចអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារនេះទៀតហើយ ។

## កថាភាគទី ២ បណ្តឹងទាមទារឱ្យបញ្ជាក់

### ១. អត្ថន័យនៃបណ្តឹងទាមទារឱ្យបញ្ជាក់

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងទាមទារឱ្យចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដោយផ្អែកលើការអះអាងរបស់ដើមចោទ នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តមួយកំណត់ដែលជាការទាមទារតាមផ្លូវបណ្តឹង ។ ក្នុងចំណោមនោះ បណ្តឹងដែលអះអាងនូវអត្ថិភាពនៃសិទ្ធិ ជាអាទិ៍ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់ដោយសកម្ម ហើយបណ្តឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិនោះ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់អសកម្ម ។

### ២. កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់

ជាគោលការណ៍ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់ស្តែង ។

ការទាមទារនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ជាបឋម ត្រូវធ្វើការអះអាងអំពី "អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត" ហើយជាគោលការណ៍ មិនអនុញ្ញាតឱ្យធ្វើការទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុទេ ។ ក៏ប៉ុន្តែ អាចមានករណីពិសេស គឺអាចមានការអនុញ្ញាតឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់នូវភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងគតិយុត្ត (សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន មាត្រា ១៣៤, ក្រមនីតិវិធីរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២៥៦ កថាខណ្ឌទី ១) ។ ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារ មានន័យថា តើលិខិតនោះ ត្រូវបានបង្កើតឡើងដោយផ្អែកលើឆន្ទៈរបស់ជនដែលបានធ្វើលិខិតនោះពិតមែន ឬទេ (ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការធ្វើឯកសារ) (សូមមើលមាត្រា ១៥៥) មិនមែនមានន័យថា ខ្លឹមសារដែលមានចុះក្នុងឯកសារនោះត្រូវនឹងអង្គហេតុជាក់ស្តែង ឬទេឡើយ ។ ភាពត្រឹមត្រូវនៃលិខិតនោះ គឺជាអង្គហេតុ ក៏ប៉ុន្តែ អាចអនុញ្ញាតពិសេសឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តនោះ គឺដោយសារតែប្រសិនបើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការបង្កើតលិខិតកិច្ចសន្យា ជាអាទិ៍ ត្រូវបានចូលជាស្ថាពរ តាមរយៈសាលក្រម រវាងភាគី នឹងអស់វិវាទ ដូច្នេះហើយ មានករណីច្រើនដែលវិវាទអំពីទំនាក់ទំនងគតិយុត្តនោះនឹងត្រូវបានដោះស្រាយ ឬ មានផលប្រយោជន៍ច្រើនក្នុងការដោះស្រាយវិវាទនោះ ។

ម្យ៉ាងទៀត ការទាមទារនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវជាការអះអាងនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត "នាពេលបច្ចុប្បន្ន" ហើយជាគោលការណ៍ គេមិនទទួលស្គាល់ឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអតីតកាល ឬ អនាគតកាលឡើយ ។ ក៏ប៉ុន្តែក្នុងករណីដែលការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអតីតកាល ឬ អនាគតកាលនោះ មានការចាំបាច់ ហើយសមស្រប ដើម្បីដោះស្រាយវិវាទតាមផ្លូវច្បាប់ដែលមានបច្ចុប្បន្ននេះ គេអាចអនុញ្ញាតពិសេស ឱ្យធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់បែបនេះបាន ។

លើសពីនេះ បណ្តឹងគឺត្រូវបានធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់ភាគី ក្នុងគោលបំណងដោះស្រាយវិវាទស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ (សូមមើលមាត្រា ២ កថាខណ្ឌទី ១ មាត្រា ៧៤) ហេតុនេះហើយ មិនអាចអនុញ្ញាតឱ្យទាមទារការបញ្ជាក់អំពីសុពលភាព ឬ មោឃភាពនៃបញ្ញត្តិច្បាប់អរូបិយទេ ។ ឧទាហរណ៍ មិនអនុញ្ញាតឱ្យដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃបញ្ញត្តិនៃព្រះរាជក្រិត្យណាមួយ ដោយអះអាងថា បញ្ញត្តិនោះមានភាពផ្ទុយនឹងបញ្ញត្តិច្បាប់ណាមួយទេ ។ ពេលធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិជាក់ស្តែងណាមួយ អាចមានករណីដែលតុលាការត្រូវធ្វើការជំនុំជម្រះ និង ធ្វើការវិនិច្ឆ័យអំពីសុពលភាព ឬ មោឃភាពនៃបញ្ញត្តិច្បាប់ណាមួយ ក៏ប៉ុន្តែការវិនិច្ឆ័យនោះ គឺគ្រាន់តែជាល័ក្ខខ័ណ្ឌជាមុន សម្រាប់ការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារតាមផ្លូវបណ្តឹង ដែលជាការអះអាងអំពីសិទ្ធិ ឬ កាតព្វកិច្ចជាក់លាក់ណាមួយប៉ុណ្ណោះ ។

៣. សាលក្រមនៃបណ្ដឹងទាមទារឱ្យបញ្ជាក់

ក្នុងបណ្ដឹងទាមទារឱ្យបញ្ជាក់ ពេលដែលទទួលស្គាល់ថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ (ពេលដែលទទួលស្គាល់ថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត មាន ឬ មិនមាន ដូចការអះអាងរបស់ដើមចោទ) តុលាការត្រូវចេញសាលក្រមដែលមានខ្លឹមសារបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តណាមួយដែលទាមទារដោយដើមចោទ ផ្ទុយទៅវិញ ប្រសិនបើមិនទទួលស្គាល់នូវភាពត្រឹមត្រូវនៃការទាមទារទេ តុលាការត្រូវចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ ។ គោលបំណងនៃបណ្ដឹងទាមទារឱ្យបញ្ជាក់ គឺជាការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តណាមួយ ដែលអះអាងដោយដើមចោទ ហើយសាលក្រមដែលទទួលស្គាល់ថា ការទាមទារនោះត្រឹមត្រូវ គឺជាសាលក្រមមួយដែលបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិជាក់លាក់នោះ ជាដើម ដូច្នេះគេឱ្យឈ្មោះថា សាលក្រមបញ្ជាក់ ។ សាលក្រមបញ្ជាក់មានអានុភាពថា ការវិនិច្ឆ័យស្ដីពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ ដែលជាខ្លឹមសារនៃសាលក្រមនោះ (ក្នុងករណីនៃបណ្ដឹងទាមទារឱ្យបញ្ជាក់ដោយអសកម្ម គឺការវិនិច្ឆ័យអំពីនត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត) មិនអាចយកធ្វើវិវាទម្ដងទៀតហើយ មានន័យថា មានអាជ្ញាអស់ជំនុំសារធាតុ (សូមមើលជំពូកទី ៤ ផ្នែកទី ១ កថាភាគីទី ៣ ៣.) ។ តាមរយៈឥទ្ធិពលនៃអាជ្ញាអស់ជំនុំនេះ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលមានក្នុងវិវាទរវាងភាគីនេះ នឹងក្លាយទៅជាស្ថាពរ ។ម្យ៉ាងទៀត ចំពោះសាលក្រម ច្រានចោលនូវការទាមទារ ការវិនិច្ឆ័យថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃការទាមទារនោះ ពុំមានអត្ថិភាព (ចំពោះករណីបណ្ដឹងទាមទារឱ្យបញ្ជាក់អសកម្ម គឺជាការវិនិច្ឆ័យថា ទំនាក់ទំនងគតិយុត្តនោះ មានអត្ថិភាព) អាជ្ញាអស់ជំនុំសារធាតុក៏កើតមានឡើងដែរ ។ សាលក្រមច្រានចោលនូវការទាមទារ ក៏មានលក្ខណៈជាសាលក្រមបញ្ជាក់ដែរ ។

ម្យ៉ាងទៀត ក្នុងករណីដែលអត្ថិភាព ឬ នត្ថិភាពនៃកាតព្វកិច្ច ជាចំណុចវិវាទ មានបណ្ដឹងទាមទារឱ្យបញ្ជាក់អសកម្មមួយប្រភេទ ដែលជនដែលត្រូវបានចង្អុលថា កូនបំណុល ដាក់ពាក្យបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច ក្នុងនាមជាដើមចោទ ។ សាលក្រមច្រានចោលនូវការទាមទារក្នុងបណ្ដឹងទាមទារឱ្យបញ្ជាក់នេះ នឹងមានអានុភាពជាអាជ្ញាអស់ជំនុំសារធាតុ ចំពោះការវិនិច្ឆ័យថា "កាតព្វកិច្ចដែលដើមចោទបានអះអាងថាពុំមាននោះ មានអត្ថិភាព" ។ ចំពោះចុងចម្លើយ សាលក្រមនេះគឺជាសាលក្រមបញ្ជាក់ជាស្ថាពរនូវអត្ថិភាពនៃសិទ្ធិលើបំណុល (សិទ្ធិទាមទារ) ក៏ប៉ុន្តែ នេះក៏ជាសាលក្រមបញ្ជាក់ ហើយពុំមានអានុភាពអនុវត្តទេ ហេតុនេះហើយ មិនអាចក្លាយទៅជាលិខិតអនុវត្ត (សូមមើលមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក) ដើម្បីសម្រេចសិទ្ធិលើបំណុល (សិទ្ធិទាមទារ) ដែលត្រូវបានទទួលស្គាល់ក្នុងសាលក្រមនោះឡើយ ។

## កថាភាគទី ៣ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

### ១. អត្ថន័យនៃបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រម ប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត (ការកើតមានឡើង ការប្តូរ ឬ ការរំលត់) ដោយផ្អែកលើការ អះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការ ទាមទារតាមផ្លូវបណ្តឹង ។ បណ្តឹងប្រភេទនេះ មានដូចជាបណ្តឹងសុំលែងលះគ្នា ។ ប្រសិនបើការព្រមព្រៀង លែងលះគ្នារវាងភាគីដែលមានទំនាក់ទំនងអាពាហ៍ពិពាហ៍ មិនអាចសម្រេចបានទេ ហើយក្នុងករណីដែលភាគី ខាងប្តី ឬ ខាងប្រពន្ធ ចង់លែងលះគ្នា ភាគីនោះត្រូវដាក់ពាក្យបណ្តឹងសុំលែងលះគ្នា ។ ក្នុងករណីនៃការលែង លះគ្នាតាមរយៈបណ្តឹងសុំលែងលះគ្នា ទាល់តែមានសាលក្រមលែងលះគ្នា ទើបមានអានុភាពបង្កើតនូវទំនាក់ ទំនងគតិយុត្ត ដែលរំលាយនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ ដែលមានពីមុនមករវាងដើមចោទ និង ចុងចម្លើយ ។ ទោះជាមានមូលហេតុលែងលះគ្នាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី (ក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ កថាខណ្ឌ ទី ១ ចំណុចទីមួយ) ហើយភាគីម្ខាងបានបង្ហាញឆន្ទៈលែងលះគ្នាក៏ដោយ មិនមានអានុភាពលែងលះគ្នាបាន ទេ ។ ដើម្បីឱ្យអានុភាពនៃការលែងលះគ្នា ដែលជាការរំលាយនូវចំណងអាពាហ៍ពិពាហ៍នោះកើតមានឡើង ទាល់តែតុលាការចេញសាលក្រមលែងលះគ្នា ។ ដូច្នេះហើយ ជាគោលករណ៍ ច្បាប់ទទួលស្គាល់នូវការបង្កើត ទំនាក់ទំនងគតិយុត្តថ្មី ដោយផ្អែកលើឆន្ទៈរបស់ភាគីណាម្ខាង ក៏ប៉ុន្តែ មានករណីមួយចំនួនដែល ដើម្បីឱ្យ អានុភាពនៃការបង្កើតទំនាក់ទំនងគតិយុត្តនោះមានកើតមានឡើង ការបង្ហាញឆន្ទៈរបស់ភាគីមិនមែនជាការ គ្រប់គ្រាន់ទេ គឺចាំបាច់មានបណ្តឹង ហើយឱ្យតុលាការចេញសាលក្រម ។ បណ្តឹងដែលទាមទារឱ្យចេញសាលក្រម ដែលមានអានុភាពបែបនេះ គេហៅថា បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ។

ស្តីពីទំនាក់ទំនងឋានៈបុគ្គល ដូចជា អាពាហ៍ពិពាហ៍ សុំកូន ជាដើម ឬ ស្តីពីទំនាក់ទំនងអង្គភាព ដូចជា ក្រុមហ៊ុន ឬ នីតិបុគ្គលផ្សេងទៀត ជាអាទិ៍ ជនដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងនោះមានច្រើនគ្នា ដូច្នេះហើយ គួរតែឱ្យអានុភាពនៃការផ្លាស់ប្តូរ (ការបង្កើត) ទំនាក់ទំនងគតិយុត្តនោះ កើតមានឡើង មិនមែនតែរវាងភាគីប៉ុណ្ណោះទេ គឺចំពោះទំនាក់ទំនងនឹងតតិយជនផងដែរ ។ ដូច្នេះហើយបានជាច្បាប់បានចែង ថា ការផ្លាស់ប្តូរនូវទំនាក់ទំនងគតិយុត្តនោះ នឹងមានអានុភាព ជាពិសេស ទាល់តែមានសាលក្រម ដោយផ្អែក ទៅលើបណ្តឹងដែលដាក់ដោយជនពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងទំហំកំណត់មួយ ។ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាប្រភេទនៃបណ្តឹងដែលត្រូវបានទទួលស្គាល់ក្នុងករណីបែបនេះ ។

ឧទាហរណ៍ កូនអត់ខាន់ស្លាអាចដាក់ពាក្យបណ្តឹងទាមទារឱ្យឪពុកទទួលស្គាល់ខ្លួនបាន (ក្រមរដ្ឋប្បវេណី មាត្រា ១០០១) ។ ក្នុងករណីនេះ ប្រសិនបើទំនាក់ទំនងបិតុភាព កើតមានឡើង តាមរយៈការទទួលស្គាល់នេះ អានុភាពនោះមិនត្រឹមតែមានចំពោះទំនាក់ទំនងឪពុក និង កូននេះទេ គឺមានអានុភាពចំពោះទំនាក់ទំនងនឹង

ញាតិ ឬ ទំនាក់ទំនងនឹងតតិយជនផងដែរ ។ ឧទាហរណ៍ ប្រសិនបើទំនាក់ទំនងរវាងឪពុក និង កូនកើតមានឡើងដោយសារការទទួលស្គាល់ ក្នុងករណីដែលឪពុកបានទទួលមរណភាព នឹងមានឥទ្ធិពលដល់ចំណែកមតិករបស់ប្រពន្ធរបស់ឪពុកនោះ ឬ របស់កូនផ្សេងទៀតផងដែរ ។ ម្យ៉ាងទៀត ក្នុងករណីដែលកូនដែលត្រូវបានទទួលស្គាល់នោះមានកូនដែរ អាហារកាតព្វកិច្ចចំពោះឪពុករបស់កូននោះ (ជីតា) អាចកើតមានឡើង ។ ក្នុងករណីដូចនេះ ប្រសិនបើធ្វើការវិនិច្ឆ័យផ្សេងៗគ្នាចំពោះទំនាក់ទំនងរវាងជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងបិតុភាពរវាងភាគី អាចមានការជ្រួលច្របល់ក្នុងទំនាក់ទំនងគតិយុត្តរវាងជនទាំងនោះ ។ តើអ្នកណាមានចំណែកមតិកប៉ុន្មានភាគ តើមានទំនាក់ទំនងញាតិរវាងអ្នកណា និង អ្នកណាដែរនោះ នឹងពុំមានភាពច្បាស់លាស់ទេ ។ ដូច្នេះ ច្បាប់ទទួលស្គាល់ឱ្យមានបណ្ដឹងទាមទារឱ្យទទួលស្គាល់ជាបណ្ដឹងបង្កើតទំនាក់ទំនងគតិយុត្ត ហើយទំនាក់ទំនងបិតុភាពនឹងកើតមានឡើង តែពេលមានសាលក្រមទទួលស្គាល់នូវបិតុភាពនេះ ដោយផ្អែកលើបណ្ដឹងនោះ ហើយអានុភាពនៃសាលក្រមនោះនឹងមានទៅលើជនដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍ទាំងអស់គ្នា (សេចក្ដីព្រាងច្បាប់ស្ដីពីនីតិវិធីបណ្ដឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា ១៦ កថាខណ្ឌទី ១) ។

ចំពោះសិទ្ធិបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដូចជាសិទ្ធិរំលាយកិច្ចសន្យាតាមផ្លូវច្បាប់ស្ដីពីសិទ្ធិលើទ្រព្យសម្បត្តិធម្មតា ឬ សិទ្ធិលុបចោលនូវកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ជាដើម ប្រសិនបើបុគ្គលឯកជនណាម្នាក់ដែល ជាអ្នកមានសិទ្ធិបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត បានបង្ហាញឆន្ទៈប្រើសិទ្ធិនោះ (ដូចជា ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ការបង្ហាញឆន្ទៈលុបចោល ជាអាទិ៍) អានុភាពនៃការបង្កើត ប្ដូរ ឬ រំលត់ នឹងកើតមានឡើង ។ ឧទាហរណ៍ ជនដែលបានលក់វត្ថុអ្វីមួយដោយធ្វើកិច្ចសន្យាលក់ដែលមានការឆបោក អាចលុបកិច្ចសន្យានោះ ចោល ដោយការបង្ហាញឆន្ទៈលុបកិច្ចសន្យាចោលដោយខ្លួនឯងបាន ។ ពេលនោះ ប្រសិនបើមានវិវាទ សាមីខ្លួនអាចដាក់ពាក្យបណ្ដឹងមួយទាមទារឱ្យតុលាការបញ្ជាក់ថា ខ្លួនជាម្ចាស់កម្មសិទ្ធិលើកម្មវត្ថុនៃការលក់ទិញនោះ ឬ ប្រសិនបើបានប្រគល់កម្មវត្ថុនោះទៅឱ្យភាគីម្ខាងទៀតរួចហើយ គាត់អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកបាន ដោយអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យសងវត្ថុមកវិញ ។ ក្នុងករណីនេះ មិនចាំបាច់ធ្វើបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដើម្បីលុបចោលនូវកិច្ចសន្យាលក់ទិញ ឬ ដើម្បីរំលាយកិច្ចសន្យានោះទេ ផ្ទុយទៅវិញ ការធ្វើបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត មិនត្រូវអនុញ្ញាតបានឡើយ ដោយសារតែមិនចាំបាច់ ឬ គ្មានផលប្រយោជន៍តាមផ្លូវច្បាប់ ។ បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត អាចត្រូវបានទទួលស្គាល់ លុះត្រាតែករណីដែលមិនមានអានុភាព ក្នុងការបង្កើតទំនាក់ទំនងគតិយុត្តបានដោយត្រឹមតែការបង្ហាញឆន្ទៈរបស់ភាគី ដោយផ្អែកទៅលើភាពចាំបាច់ ក្នុងការធ្វើឱ្យការផ្លាស់ប្ដូរទំនាក់ទំនងគតិយុត្ត មានអានុភាពដូចៗគ្នា ទៅលើទំនាក់ទំនងនឹងតតិយជនទូទៅ ។

២. កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត (ការទាមទារតាមផ្លូវបណ្តឹង)

ការទាមទារតាមផ្លូវបណ្តឹងនៃបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ត្រូវមានការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលបានកំណត់មួយ (សិទ្ធិលែងលះគ្នា សិទ្ធិលុបចោលអាពាហ៍ពិពាហ៍ សិទ្ធិទាមទារឱ្យទទួលស្គាល់កូន ជាដើម) ឬ ត្រូវមានការអះអាងអំពីអត្ថិភាពនៃមូលហេតុនៃការបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត (មូលហេតុនៃការលុបចោលនូវសេចក្តីសម្រេចរបស់មហាសន្និបាតនៃម្ចាស់ហ៊ុន មូលហេតុនៃការសុំជំនុំជម្រះសាជាថ្មីនៃសាលក្រមស្ថាពរ ជាដើម) ។ ហេតុនេះហើយ ទោះជាបណ្តឹងដែលមានគោលបំណងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្តដូចគ្នាក៏ដោយ តែប្រសិនបើពុំមានការអះអាងអំពីសិទ្ធិ និង មូលហេតុនៃការបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តទេ ហើយតុលាការពុំមានបទដ្ឋានតាមផ្លូវច្បាប់ណាមួយ ដើម្បីយកមកបង្កើតទំនាក់ទំនងគតិយុត្តិទេ ដូច្នេះករណីនេះ គេមិនហៅថា បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលបានពន្យល់នេះទេ ។ បណ្តឹងប្រភេទនេះ ត្រូវហៅថា "បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត តាមទម្រង់" ។ ឧទាហរណ៍ បណ្តឹងទាមទារឱ្យបញ្ជាក់ព្រំប្រទល់ដីដែលដីជាប់គ្នា ក្នុងសៀវភៅចុះបញ្ជី ឬ បណ្តឹងទាមទារឱ្យបែងចែកវត្ថុដែលជាកម្មសិទ្ធិអវិភាគ (ក្រមរដ្ឋប្បវេណី មាត្រា ២១១) ជាដើម គឺជាបណ្តឹងប្រភេទនេះ ។

ម្យ៉ាងទៀត សិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដែលត្រូវបានអះអាងក្នុងបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្ត មិនមានអានុភាពដោយតែការបង្ហាញឆន្ទៈរបស់ភាគីប៉ុណ្ណោះទេ ដូចដែលបានពន្យល់ខាងលើនេះ ហេតុនេះហើយ គេអាចហៅថា សិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដែលត្រូវអនុវត្តតែតាមផ្លូវតុលាការ ។

៣. សាលក្រមនៃបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

ចំពោះបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ពេលដែលតុលាការទទួលស្គាល់ថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមប្រកាសបង្កើត (ផ្លាស់ប្តូរ) នូវទំនាក់ទំនងគតិយុត្តកំណត់មួយតាមការទាមទារនោះ ។ សាលក្រមប្រភេទនេះ គេហៅថា សាលក្រមបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ។ សាលក្រមបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត មានអានុភាពប្រតិសកម្ម (ឧទាហរណ៍ សាលក្រមទទួលស្គាល់ សាលក្រមរំលាយចោលនូវសេចក្តីសម្រេចរបស់មហាសន្និបាតម្ចាស់ហ៊ុន ជាដើម) ឬ មានអានុភាពឆ្ពោះទៅអនាគត (ឧទាហរណ៍ សាលក្រមលែងលះគ្នា សាលក្រមលុបចោលអាពាហ៍ពិពាហ៍ ជាដើម) ក្នុងការបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្តដោយផ្ទាល់ តាមផ្លូវច្បាប់សារធាតុ ឬ តាមច្បាប់នីតិវិធី ទៅតាមខ្លឹមសារនៃសាលក្រមនោះ មានន័យថា មានអានុភាពបង្កើតទំនាក់ទំនងគតិយុត្ត (តើអានុភាពបង្កើតទំនាក់ទំនងគតិយុត្តនោះ ជាអានុភាពប្រតិសកម្ម ឬ យ៉ាងណាដែរនោះ ត្រូវបានកំណត់ដោយបញ្ញត្តិនៃច្បាប់សារធាតុ) ។ អានុភាពនៃសាលក្រមបង្កើតទំនាក់ទំនងគតិយុត្ត ដែលមានខ្លឹមសាររំលាយ

ចោលនូវចំណងអាពាហ៍ពិពាហ៍រវាងភាគី ដោយសាលក្រមលែងលះគ្នា នឹងកើតមានឡើងចំពោះតតិយជនទូទៅផងដែរ ។

សាលក្រមបង្កើត ប្តូរ ឬ រំលត់នូវទំនាក់ទំនងគតិយុត្ត នឹងបង្កើតជាអាជ្ញាអស់ជំនុំសាធាតុ ចំពោះការវិនិច្ឆ័យថា មានសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ឬ មានមូលហេតុបង្កើតទំនាក់ទំនងគតិយុត្ត ដែលដើមចោទបានអះអាង ។

ក្នុងបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ប្រសិនបើមិនទទួលស្គាល់នូវភាពត្រឹមត្រូវនៃការទាមទារដែលអះអាងដោយដើមចោទទេ តុលាការត្រូវចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ ។ សាលក្រមច្រានចោលនូវការទាមទារនៃបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តនេះ ពុំមានអានុភាពបង្កើតទំនាក់ទំនងគតិយុត្តទេ ក៏ប៉ុន្តែ ការវិនិច្ឆ័យថា ពុំមានសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត ឬ ពុំមានមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្ត នឹងមានអានុភាពជាអាជ្ញាអស់ជំនុំសារធាតុរវាងភាគី ។ លក្ខណៈនៃសាលក្រមច្រានចោលនេះគឺជាសាលក្រមបញ្ជាក់ ។

## ផ្នែកទី ៤ ការកំណត់នូវការទាមទារតាមផ្លូវបណ្តឹង

### កថាភាគទី ១ ភាពចាំបាច់នូវការកំណត់នូវការទាមទារ

ដូចដែលបានពន្យល់ខាងលើនេះ ក្នុងបណ្តឹងរដ្ឋប្បវេណី តុលាការធ្វើការវិនិច្ឆ័យជាលក្ខណៈសិទ្ធិសាធារណៈស្តីពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារតាមផ្លូវបណ្តឹង ដែលលើកឡើងដោយដើមចោទ តាមរយៈបណ្តឹង ។ តុលាការត្រូវធ្វើការវិនិច្ឆ័យទៅលើចំណុចដែលដើមចោទបានប្តឹងក្នុងការទាមទារតាមផ្លូវបណ្តឹងព្រមជាមួយគ្នានេះ តុលាការត្រូវចេញសាលក្រមស្តីពីចំណុចនេះ ( មាត្រា ១៨២ កថាខណ្ឌទី ១ និង ទី ២) ។ ហេតុនេះហើយ ក្នុងបណ្តឹង ដើមចោទត្រូវកំណត់នូវការទាមទារតាមផ្លូវបណ្តឹង ហើយបញ្ជាក់ឱ្យបានច្បាស់លាស់នូវកម្មវត្ថុដែលតុលាការត្រូវធ្វើការជំនុំជម្រះ និង ចេញសាលក្រម ។ ទាល់តែមានការកំណត់ឱ្យបានច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹងហើយ ទើបតុលាការអាចធ្វើការបញ្ជាក់ជាស្ថាពរនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលតុលាការត្រូវធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនោះ ។ ហើយម្យ៉ាងទៀត តាមរយៈការកំណត់ការទាមទារតាមផ្លូវបណ្តឹងនេះ អង្គហេតុដែលដើមចោទត្រូវអះអាង និង បញ្ជាក់ ដែលជាមូលហេតុនៃអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះ ( មធ្យោបាយតទល់ -- អង្គហេតុដែលជាមូលហេតុនៃការទាមទារ, អង្គហេតុនៃការតវ៉ាតប ជាអាទិ៍) និង អង្គហេតុដែលចុងចម្លើយត្រូវអះអាង និង បញ្ជាក់ដើម្បីការពារខ្លួន ( មធ្យោបាយការពារខ្លួន -- អង្គហេតុនៃការតវ៉ា, អង្គហេតុនៃការតវ៉ា ចំពោះការតវ៉ាតប ជាអាទិ៍) នឹងត្រូវបានកំណត់ ។ ការវិនិច្ឆ័យទៅលើបណ្តឹង គឺត្រូវចាប់ផ្តើមដោយការកំណត់នូវការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ ហើយបន្ទាប់មក ភាគីត្រូវធ្វើការអះអាង និង បញ្ជាក់ ជាបន្តបន្ទាប់ រហូតដល់

ការចេញសាលក្រម ។

លើសពីនេះ ដូចដែលបានពន្យល់ខាងលើនេះ (សូមមើលផ្នែកទី ២ កថាភាគីទី ២ ៣.) ការកំណត់នូវការទាមទារតាមផ្លូវបណ្តឹង គឺជាមូលដ្ឋាននៃទ្រឹស្តី ដើម្បីធ្វើការសម្រេចនូវអានុភាពតាមច្បាប់នីតិវិធីនៃបញ្ហានានា ដូចជា ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ (មាត្រា ៧៧) ការហាមបណ្តឹងជាន់គ្នា (មាត្រា ៨៣) ការបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង (មាត្រា ៨៤) ការហាមធ្វើបណ្តឹងម្តងទៀត ក្រោយការដកពាក្យបណ្តឹង (មាត្រា ២១៨ កថាខណ្ឌទី ២) វិសាលភាពជាក់លាក់នៃអានុភាពសារធាតុនៃអាជ្ញាអស់ជំនុំ (មាត្រា ១៩៤) ជាដើម ។

## កថាភាគទី ២ វិធីបញ្ជាក់នូវការទាមទារ

តើត្រូវធ្វើការបញ្ជាក់ការទាមទារតាមផ្លូវបណ្តឹងតាមវិធីណាខ្លះនោះ គឺ ត្រូវបានកំណត់ដោយកត្តាដែលកំណត់នូវភាពតែមួយនៃការទាមទារតាមផ្លូវបណ្តឹង (ការទាមទារតែមួយ ឬ ច្រើន ឬ ការទាមទារដូចគ្នា ឬ ផ្សេងគ្នា) ។ ការទាមទារ គឺជាការអះអាងនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តណាមួយតាមផ្លូវច្បាប់សារធាតុ ដែលដើមចោទទាមទារឱ្យតុលាការធ្វើការវិនិច្ឆ័យទៅលើទំនាក់ទំនងនឹងចុងចម្លើយ ។ ហេតុនេះហើយ កត្តាដែលសម្រេចអំពីភាពដូចគ្នានៃការទាមទារ គឺជាភាគី និង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ដែលភាគីបានអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនោះ ។ ដូច្នេះ ការបញ្ជាក់នូវការទាមទារ អាចបែងចែកជាការកំណត់ភាគី និង ការកំណត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលត្រូវបានអះអាង ។

### ១. ការកំណត់ភាគី

ភាគី គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង ហើយក្នុងករណីដែលដើមចោទ និង ចុងចម្លើយជារូបវន្តបុគ្គល ភាគីត្រូវបានកំណត់បញ្ជាក់ដោយការសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នកនោះ ហើយក្នុងករណីដែលជានីតិបុគ្គល ភាគីត្រូវបានកំណត់បញ្ជាក់ដោយការសរសេរនាមករណ៍ និង អាសយដ្ឋានរបស់នីតិបុគ្គលនោះ (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក) ។

### ២. ការកំណត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានអះអាង

(១) ការកំណត់ ដោយសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុដែលចាំបាច់ក្នុងការបញ្ជាក់នូវការទាមទារ

(ក) សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាខ្លឹមសារនៃការទាមទារតាមផ្លូវបណ្តឹង ត្រូវបានកំណត់ដោយ "សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" ដែលជាចំណុចចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ) ។ បើនិយាយ ម្យ៉ាងទៀត គឺ ចំណុចនៃបញ្ញត្តិនេះបញ្ជាឱ្យសរសេរនៅក្នុងពាក្យបណ្តឹង អំពីចំណុចគ្រប់គ្រាន់ដើម្បីអាចធ្វើការកំណត់បញ្ជាក់

ឱ្យបានគ្រប់គ្រាន់ នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃការជំនុំជម្រះ ។ ដូចដែលបានពន្យល់ខាងលើនេះ (សូមមើលផ្នែកទី ១ កថាភាគទី ២ ១. (៣)) ក្នុងបណ្តឹងទាមទារឱ្យបញ្ជាក់ មានតែចំណុចដែលបានសរសេរក្នុងសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញទេ ដែលអាចយកមកកំណត់បញ្ជាក់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុបាន ក៏ប៉ុន្តែ ក្នុងបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ឬ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត លុះត្រាតែបានសរសេរអំពីសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ព្រមជាមួយនឹងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ទើបអាចធ្វើការកំណត់បញ្ជាក់នូវបញ្ហាទាំងនោះបាន ។

(ខ) មូលហេតុដែលចាំបាច់ត្រូវសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារក្នុងពាក្យបណ្តឹង គឺដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬ ការមិនអាចបែងចែកច្បាស់លាស់បាននូវការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ ទៅនឹងការទាមទារផ្សេងទៀត ។ ដូច្នេះហើយ នេះមានន័យថា អង្គហេតុដែលអាចធ្វើការសំគាល់ កុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលបានអះអាងដោយដើមចោទ និង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដទៃទៀត ។ យើងអាចនិយាយផ្សេងទៀតថា ប្រសិនបើដើមចោទបានបង្ហាញលំអិតនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដោយសរសេរអំពីអង្គហេតុក្នុងកម្រិតនោះ នៅក្នុងពាក្យបណ្តឹង ពាក្យបណ្តឹងនោះនឹងស្របច្បាប់ ហើយតុលាការមិនអាចលើកចោលបានឡើយ ។

តាមធម្មតា អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ត្រូវមានរួមទាំងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយយោងតាមមាត្រា ៧៥ កថាខណ្ឌទី ៣ មិនត្រឹមតែអង្គហេតុដែលជាមូលហេតុនៃការទាមទារទេ គឺគប្បីសរសេរអំពីអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុដែលទាក់ទងនឹងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង ភស្តុតាង តាមចំណុចនីមួយៗដែលចាំបាច់ធ្វើការបញ្ជាក់ផងដែរ ។ ក៏ប៉ុន្តែ បញ្ញត្តិនេះទាមទារឱ្យសរសេរច្បាស់លាស់អំពីអង្គហេតុ និង ភស្តុតាងទាំងនេះ ដើម្បីបញ្ជាក់ឱ្យបានឆាប់រហ័សនូវចំណុចវិវាទ ហើយការពារកុំឱ្យមានការរអាក់រអួលក្នុងនីតិវិធី មិនមែនជាការចាំបាច់ដើម្បីធ្វើការបញ្ជាក់នូវការទាមទារទេ (សូមមើលផ្នែកទី ១ កថាភាគទី ២ ២.) ។

(២) ឧទាហរណ៍ជាក់ស្តែងនៃអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ដែលអះអាងដោយដើមចោទ គឺខុសគ្នាទៅតាមប្រភេទនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនីមួយៗ ។ ប្រសិនបើគិតមើលទៅតាមប្រភេទនៃសិទ្ធិទាំងនេះទៅ អាចមានដូចតទៅ :

(ក) ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទ ជាសិទ្ធិផ្តាច់មុខ ដូចជា សិទ្ធិប្រត្យក្ស (លើកលែងតែសិទ្ធិប្រាតិភោគិប្រត្យក្ស) សិទ្ធិដោយផ្អែកលើទំនាក់ទំនងញាតិ សិទ្ធិសន្តតិកម្ម ជាដើម សិទ្ធិនោះមិនអាចមានអត្ថិភាពជាន់គ្នានឹងសិទ្ធិដដែលផ្សេងនៅក្នុងកម្មវត្ថុតែមួយបានឡើយ (ឧទាហរណ៍ មិនអាចមានកម្មសិទ្ធិពីរលើ

ដីតែមួយបានឡើយ) ហេតុនេះហើយ ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិនោះ គ្រាន់តែសរសេរអំពីប្រធាននៃសិទ្ធិ (ឧទាហរណ៍ ដើមចោទ) កម្មវត្ថុនៃសិទ្ធិ (ឧទាហរណ៍ ដីធ្លីមួយ) ព្រមទាំងប្រភេទ និង ខ្លឹមសារនៃសិទ្ធិ (ឧទាហរណ៍ កម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ ជាដើម) ជាការគ្រប់គ្រាន់ ។

ម្យ៉ាងទៀត ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទ ជាសិទ្ធិប្រាតិភោគិប្រត្យក្ស ដូចជា ហ៊ីប៉ូតែក ជាអាទិ៍ សិទ្ធិច្រើនដែលមានប្រភេទតែមួយនោះ អាចមានអត្ថិភាពជាមួយគ្នាលើវត្ថុតែមួយ ហេតុនេះហើយ ដើម្បីធ្វើការបញ្ជាក់សិទ្ធិនោះ ចាំបាច់សរសេរក្រៅពីនេះ អំពីសិទ្ធិលើបំណុលដែលត្រូវបានធានា ព្រមទាំងលំដាប់នៃសិទ្ធិប្រាតិភោគនោះផងដែរ ។

(ខ) ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទ ជាសិទ្ធិលើបំណុល ឬ សិទ្ធិទាមទារ សិទ្ធិដែលមានខ្លឹមសារតែមួយរវាងភាគីដូចគ្នា អាចមានច្រើន ដោយមានមូលហេតុនៃការបង្កើតសិទ្ធិនោះផ្សេងគ្នា (ឧទាហរណ៍ រវាងភាគីដូចគ្នា សិទ្ធិទាមទារដែលមានខ្លឹមសារឱ្យបង់ប្រាក់ ១០ លានរៀល អាចមានអត្ថិភាពក្នុងនាមជាសិទ្ធិទាមទារឱ្យសងប្រាក់កំចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើងនាថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ ឬ ក្នុងនាមជាសិទ្ធិទាមទារប្រាក់លក់ទិញ ដោយផ្អែកលើកិច្ចសន្យាលក់ទិញដែលបានបង្កើតឡើងនាពេលវេលាផ្សេងទៀត ឬ សិទ្ធិទាមទារសំណងនៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ ជាដើម) ហេតុនេះហើយ ដើម្បីធ្វើការបញ្ជាក់សិទ្ធិនោះ ក្រៅពីការសរសេរអំពីអ្នកមានសិទ្ធិ (ឧទាហរណ៍ ដើមចោទ) អ្នកមានកាតព្វកិច្ច (ឧទាហរណ៍ ចុងចម្លើយ) តាវកាលិកដែលជាខ្លឹមសារនៃសិទ្ធិនោះ (ឧទាហរណ៍ ការបង់ប្រាក់ ១០ លានរៀល) ចាំបាច់ត្រូវសរសេរអំពីមូលហេតុនៃកំណើតនៃសិទ្ធិនោះ (ឧទាហរណ៍ កិច្ចសន្យាខ្ចីបរិភោគ កិច្ចសន្យាលក់ទិញ គ្រោះថ្នាក់ចរាចរណ៍ ដែលកើតឡើងនៅថ្ងៃទី .. ខែ .. ឆ្នាំ .. ជាដើម) ផងដែរ ។

(គ) ក្នុងករណីដែលសិទ្ធិអះអាងដោយដើមចោទ ជាសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស (ឧទាហរណ៍ សិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ [ក្រមរដ្ឋប្បវេណី មាត្រា ១៥៥] សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងដោយផ្អែកលើកម្មសិទ្ធិ [ក្រមរដ្ឋប្បវេណី មាត្រា ១៥៩ កថាខណ្ឌទី ១] សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ [ក្រមរដ្ឋប្បវេណី មាត្រា ២៣៧] ជាដើម) ដើម្បីធ្វើការបញ្ជាក់សិទ្ធិនោះ ត្រូវសរសេរអំពីអ្នកមានសិទ្ធិ (ឧទាហរណ៍ ដើមចោទ) អ្នកមានកាតព្វកិច្ច (ឧទាហរណ៍ ចុងចម្លើយ) ព្រមទាំងកម្មវត្ថុនៃសិទ្ធិ (ឧទាហរណ៍ ដីធ្លីជាក់លាក់ណាមួយ) សិទ្ធិប្រត្យក្សដែលជាមូលហេតុនៃសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស (ឧទាហរណ៍ កម្មសិទ្ធិ សិទ្ធិកាន់កាប់) និង តាវកាលិកដែលជាខ្លឹមសារនៃសិទ្ធិនោះ (ឧទាហរណ៍ ការប្រគល់ ការបញ្ឈប់ការរារាំង) ។

(ឃ) ចំពោះបណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ក្នុងករណីដែលដើមចោទអះអាងអំពីសិទ្ធិបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ឬ អះអាងអំពីមូលហេតុនៃការបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តនោះ ដើម្បីធ្វើការបញ្ជាក់នូវការទាមទារនោះ ចាំបាច់ត្រូវសរសេរអំពីអង្គហេតុដែលជាមូល

ហេតុនៃការកើតឡើងនូវសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្តនោះ ឬ នូវមូលហេតុបង្កើតទំនាក់ទំនងគតិយុត្តនោះ ដូចក្នុងករណីអះអាងសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ក្នុងបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកដែរ (ក្នុងករណី (ខ) ខាងលើនេះ) ។ ឧទាហរណ៍ សិទ្ធិលែងលះ ដែលជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត (សិទ្ធិទាមទារឱ្យលែងលះ) អាចកើតមានឡើងក្នុងនាមជាសិទ្ធិតាមផ្លូវច្បាប់សារធាតុផ្សេងគ្នា ទៅតាមមូលហេតុនៃការលែងលះនីមួយៗ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុចនីមួយៗ ហេតុនេះហើយ ការទាមទារលែងលះគ្នាដោយផ្អែកលើមូលហេតុដែលមានចែងក្នុងមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ក និង ការទាមទារលែងលះគ្នាដោយផ្អែកលើមូលហេតុដែលមានចែងក្នុងមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង គឺជាការអះអាងសិទ្ធិតាមផ្លូវច្បាប់សារធាតុផ្សេងៗគ្នា ។ ដូច្នេះ ក្នុងការទាមទារលែងលះគ្នាទាំងពីរនេះ សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ មានខ្លឹមសារដូចគ្នា គឺការប្រកាសនូវការលែងលះគ្នានៃប្តីប្រពន្ធតែមួយគូរនេះ ក៏ប៉ុន្តែ សិទ្ធិដែលត្រូវបានអះអាងជាការទាមទារតាមផ្លូវបណ្តឹង គឺជាសិទ្ធិតាមផ្លូវច្បាប់សារធាតុផ្សេងៗគ្នាទេ ។ ដូច្នេះ ដើម្បីធ្វើការបញ្ជាក់នូវការទាមទារតាមផ្លូវបណ្តឹង ក្នុងបណ្តឹងទាមទារលែងលះគ្នា គ្រាន់តែសរសេរអំពីភាគីទាំងពីរនៃចំណងអាពាហ៍ពិពាហ៍ និង ខ្លឹមសារនៃទំនាក់ទំនងគតិយុត្ត ដែលដើមចោទទាមទារឱ្យបង្កើត (ការលែងលះគ្នា = ការរំលាយនូវទំនាក់ទំនងអាពាហ៍ពិពាហ៍ឆ្ពោះទៅ អនាគត) នៅតែមិនគ្រប់គ្រាន់ទេ គឺចាំបាច់ត្រូវសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការលែងលះគ្នា ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុចនីមួយៗ ថែមទៀតទើបបាន ។

ប៉ុន្តែ បញ្ហានេះអាចខុសគ្នាតាមការបកស្រាយនៃក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ ។ ចំពោះរបបលែងលះគ្នា ក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ បានជ្រើសរើសយកគោលការណ៍នៃការបែកបាក់ទូទៅមកប្រើ ហើយល័ក្ខខ័ណ្ឌនៃការកើតមានឡើងនូវសិទ្ធិទាមទារលែងលះគ្នា មានចែងក្នុងមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ង ថា "ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថា អាចបដិទានឡើងវិញបាន" ហើយអាចបកស្រាយបានថា ខ្លឹមសារនៃបញ្ញត្តិនៃមាត្រា ៩៧៨ កថាខណ្ឌទី ១ ពីចំណុច ក ដល់ ចំណុច ឃ គឺជាឧទាហរណ៍នៃមូលហេតុនៃការលែងលះគ្នាដែលមានចែងក្នុងកថាខណ្ឌទី ១ ចំណុច ង ប៉ុណ្ណោះ ។ យោងតាមការបកស្រាយនេះ ក្នុងការទាមទារលែងលះគ្នា ដោយយកចំណុចណាមួយពី ក ដល់ ឃ មកធ្វើជាមូលហេតុសិទ្ធិទាមទារលែងលះគ្នាតាមផ្លូវច្បាប់សារធាតុ ដែលបានអះអាងនោះ គឺជាសិទ្ធិដូចគ្នានឹងសិទ្ធិទាមទារលែងលះគ្នាដោយផ្អែកលើចំណុច ង ។ ហេតុនេះហើយ ដើម្បីធ្វើការបញ្ជាក់នូវការទាមទារតាមផ្លូវបណ្តឹង ក្នុងបណ្តឹងទាមទារលែងលះគ្នា ត្រូវសរសេរអំពីភាគីទាំងសងខាងនៃអាពាហ៍ពិពាហ៍ និង ការទាមទារលែងលះគ្នានៃភាគីទាំងសងខាងនោះ មានន័យថា គ្រាន់តែសរសេរអំពីសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺជាការគ្រប់គ្រាន់ហើយ ។

៣. ការទាមទារមួយភាគ

ក្នុងការទាមទារតាមផ្លូវបណ្ដឹង ក្នុងករណីដែលដើមចោទបានអះអាងនូវមួយផ្នែកនៃសិទ្ធិលើបំណុលដែលទាមទារឱ្យផ្ដល់តាវកាលិកនូវវត្ថុដែលអាចបែងចែកបាន តាមចំនួន ដូចជាប្រាក់ ឬ វត្ថុជំនួស (វត្ថុដែលអាចកំណត់ដោយប្រភេទ គុណភាព ចំនួន ដូចជាប៊ីយែរមួយកែស ជាដើម) ហើយទាមទារឱ្យតុលាការចេញសាល-ក្រមចំពោះមួយភាគនោះប៉ុណ្ណោះ ការទាមទារនេះ គេហៅថា ការទាមទារមួយភាគ ។ នៅក្រៅបណ្ដឹងម្ចាស់បំណុលអាចអនុវត្តសិទ្ធិតែមួយភាគនៃសិទ្ធិលើបំណុលដែលអាចបែងចែក ហើយទាមទារឱ្យកូនបំណុលបំពេញកាតព្វកិច្ចមួយភាគនោះបាន ហេតុនេះហើយ តាមផ្លូវបណ្ដឹង អាចអនុញ្ញាតឱ្យដើមចោទធ្វើការទាមទារនូវសិទ្ធិតែមួយភាគនៃសិទ្ធិដែលអាចបែងចែកបានដូចនេះ ហើយទាមទារឱ្យតុលាការចេញសាលក្រមចំពោះមួយភាគនោះបាន ។ បញ្ហាដែលមានគឺ ក្នុងករណីដែលមានបណ្ដឹងទាមទារសិទ្ធិតែមួយភាគនៃសិទ្ធិលើបំណុលដែលអាចបែងចែកបាន ហើយតុលាការបានចេញសាលក្រមចំពោះតែសិទ្ធិមួយភាគនោះ ហើយក្រោយពីសាលក្រមនោះបានចូលជាស្ថាពរ ដើមចោទបានដាក់ពាក្យបណ្ដឹងទាមទារនូវសិទ្ធិនៃភាគដែលនៅសល់នោះម្ដងទៀត តើអាជ្ញាអស់ជំនុំសារធាតុនៃសាលក្រមមុនដែលត្រូវបានធ្វើឡើងចំពោះការទាមទារតែមួយភាគមុននោះ មានអានុភាពទៅលើបណ្ដឹងទាមទារនូវទឹកប្រាក់ដែលនៅសល់ក្រោយនោះដែរឬទេ ? ចំពោះបញ្ហានេះអាចមានមតិជាច្រើនខុសគ្នា ក៏ប៉ុន្តែ ក្នុងករណីនៃការដាក់បណ្ដឹង ដោយមានការបញ្ជាក់ច្បាស់លាស់ថាការទាមទារមុននោះគឺជាការទាមទារតែមួយភាគ គួរតែបកស្រាយថា អាជ្ញាអស់ជំនុំសារធាតុនៃសាលក្រមស្ថាពរនៃបណ្ដឹងនោះ ពុំមានអានុភាពទៅលើការទាមទារនៃភាគដែលនៅសល់នោះទេ ។ ឧទាហរណ៍ ក្នុងករណីដែលបានលើកឡើងនៅគន្លឹះទី ១ នៃសៀវភៅនេះ ប្រសិនបើ A បានប្ដឹងទាមទារតែទឹកប្រាក់ ៨ លានរៀល ក្នុងចំណោមប្រាក់កំចី ១០ លានរៀលនោះ (ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺ "ចុងចម្លើយត្រូវបង់ ៨ លានរៀល ទៅឱ្យដើមចោទ") កម្មវត្ថុនៃការជំនុំជម្រះក្នុងបណ្ដឹងនេះគឺសិទ្ធិទាមទារឱ្យសងប្រាក់ ៨ លានរៀល ក្នុងចំណោមប្រាក់កំចីចំនួន ១០ លានរៀល ហើយតុលាការត្រូវធ្វើការជំនុំជម្រះស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារលើទឹកប្រាក់ ៨ លានរៀលប៉ុណ្ណោះ ហើយចេញសាលក្រម ។ ដូច្នេះហើយ អានុភាពនៃសាលក្រមនោះ (អាជ្ញាអស់ជំនុំ) មានទៅលើតែចំពោះអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារឱ្យសងទឹកប្រាក់ ៨ លានរៀលនោះប៉ុណ្ណោះ តែពុំមានអានុភាពទៅលើអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារឱ្យសងទឹកប្រាក់ ២ លានរៀលដែលនៅសល់នោះទេ ។ យោងតាមគំនិតនេះ ក្នុងករណីដែលពុំមានការបង្ហាញថា ការទាមទារនៃប្រាក់ ៨ លានរៀល ជាទឹកប្រាក់មួយភាគនៃសិទ្ធិលើបំណុលឱ្យច្បាស់លាស់ទេ ក្រោយមកទៀត មិនអាចដាក់ពាក្យបណ្ដឹងទាមទារប្រាក់ ២ លានរៀលដែលជាភាគសំណល់ដោយអះអាងថា ទឹកប្រាក់ ៨ លានរៀលគឺជាមួយភាគនៃសិទ្ធិលើបំណុលតែមួយនោះបានទេ ។ ក៏ប៉ុន្តែចំពោះបញ្ហានេះ បើគេអនុញ្ញាតឱ្យធ្វើបណ្ដឹងទាមទារសិទ្ធិលើបំណុលតែមួយ ដោយបែងចែកជាច្រើនលើកទៅនឹងធ្វើឱ្យតុលាការ ព្រមទាំងចុងចម្លើយប្រើពេលវេលាច្រើន និង សោហ៊ុយច្រើនដែលឥតន័យ ដូច្នេះហើយ

មានមតិថា មិនត្រូវទទួលស្គាល់នូវបណ្ដឹងទាមទារភាគដែលនៅសល់បែបនេះទេ ឬ អាចមានមតិថា ប្រសិនបើដើមចោទបានចាញ់បណ្ដឹងទាមទារតែមួយភាគមុននោះ មានន័យថា តុលាការបានវិនិច្ឆ័យថា សិទ្ធិលើបំណុលទាំងមូលនោះពុំមានអត្ថិភាពទេ ដូច្នេះហើយ ក្នុងករណីនេះ ការទាមទារនូវទឹកប្រាក់ដែលនៅសល់នោះ មិនអាចអនុញ្ញាតបានឡើយ ដោយសារការបំពានទៅលើអាជ្ញាអស់ជំនុំនៃសាលក្រមនៃបណ្ដឹងមុន ជាដើម ។

៤. បែបផែនខុសគ្នានៃការទាមទារ

ដូចដែលបានពន្យល់ខាងលើនេះ ជាគោលការណ៍ ការទាមទារតាមផ្លូវបណ្ដឹង ត្រូវបានកំណត់ដោយការកំណត់បញ្ជាក់ភាគី និង ការកំណត់បញ្ជាក់នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលត្រូវបានអះអាងដោយបណ្ដឹង ។ ក៏ប៉ុន្តែ បើនិយាយឱ្យលំអិតទៅ ទោះជាមានការអះអាងសិទ្ធិដូចគ្នាក៏ដោយ ការទាមទារតាមផ្លូវបណ្ដឹងអាចខុសគ្នាទៅតាមបែបផែននៃការទាមទារនោះ មានន័យថា ខុសគ្នាទៅតាមការទាមទារឱ្យផ្ដល់តាវកាលិក ឬ ការទាមទារការឱ្យបញ្ជាក់ ឬ ការទាមទារឱ្យបង្កើតទំនាក់ទំនងគតិយុត្ត ។ ឧទាហរណ៍ "រវាងបណ្ដឹងរបស់ A ទាមទារឱ្យបញ្ជាក់នូវអត្ថិភាពនៃសិទ្ធិទាមទារឱ្យ B សងប្រាក់កំចី និង បណ្ដឹងរបស់ A ទាមទារឱ្យផ្ដល់តាវកាលិក ដោយផ្អែកលើសិទ្ធិទាមទារឱ្យសងប្រាក់កំចីដូចគ្នា" ឬក៏ "រវាងបណ្ដឹងរបស់ A ទាមទារឱ្យ B សងប្រាក់កំចី និង បណ្ដឹងរបស់ B ទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ចសងប្រាក់កំចីដូចគ្នាចំពោះ A" ភាគី និង សិទ្ធិដែលត្រូវបានអះអាង មានដូចគ្នាទេ ក៏ប៉ុន្តែ ម្ខាង គឺជាការទាមទារឱ្យបញ្ជាក់ រីឯម្ខាងទៀត គឺជាការទាមទារឱ្យផ្ដល់តាវកាលិក ហើយជាបែបផែននៃការទាមទារខុសគ្នា ដូច្នេះហើយ ត្រូវគិតថា ជាការទាមទារតាមផ្លូវបណ្ដឹងខុសគ្នា ។

## ផ្នែកទី ៥ ការទទួលពាក្យបណ្ដឹង និង អានុភាពនៃការដាក់ពាក្យបណ្ដឹង

### កថាភាគទី ១ ការចាត់ចែងពាក្យបណ្ដឹង

១. ការទទួលពាក្យបណ្ដឹង

ពេលដែលដើមចោទបានដាក់ពាក្យបណ្ដឹងទៅតុលាការ ដើម្បីចាប់ផ្ដើមនីតិវិធីនៃបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ១) ក្រឡាបញ្ជីដែលទទួលបន្ទុកក្នុងការទទួលពាក្យបណ្ដឹង ត្រូវបោះត្រាដែលបញ្ជាក់ថ្ងៃ-ខែ-ឆ្នាំ ដែលបានទទួលពាក្យបណ្ដឹងនោះ ដើម្បីបញ្ជាក់ឱ្យដឹងច្បាស់លាស់ថា បណ្ដឹងនោះត្រូវបានដាក់ពេលណា ហើយធ្វើសំណុំរឿងនៃបណ្ដឹងនោះ ដោយបន្ថែមក្រប ព្រមទាំងចុះលេខបណ្ដឹង ជាដើម ថែមទៀត ។ បន្ទាប់មក ក្រឡាបញ្ជីត្រូវបែងចែកសំណុំរឿងនៃបណ្ដឹងនោះ ទៅឱ្យចៅក្រមដែលត្រូវទទួលបន្ទុកនូវរឿងក្ដីនោះ តាមលំដាប់នៃការបែងចែករឿងក្ដីដែលកំណត់ប្រចាំឆ្នាំ ជាមុន ដោយប្រធានតុលាការ ។ ប្រសិនបើចៅក្រមនោះមានធុរៈមិនអាចចាត់ការបណ្ដឹងនោះបានទេ ត្រូវបែងចែកទៅឱ្យចៅក្រមផ្សេងទៀត ទៅតាមលំដាប់សម្រាប់ជំនួស ដែលត្រូវបានកំណត់ជាមុន ដោយប្រធានតុលាការ (មាត្រា ២៦ កថាខណ្ឌទី ១ និង ទី ២) ។ លំដាប់នេះ

អាចប្តូរបាននៅពាក់កណ្តាលឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ លុះត្រាតែមានមូលហេតុដែលពុំអាចជៀសវាងបាន ( មាត្រា ២៦ កថាខណ្ឌទី ៣) ។

២. ការពិនិត្យពាក្យបណ្តឹង

(១) អត្ថន័យនៃការពិនិត្យពាក្យបណ្តឹង

ចៅក្រមដែលទទួលនូវការបែងចែករឿងក្តី ត្រូវពិនិត្យមើលថា តើក្នុងពាក្យបណ្តឹងនោះ មានសរសេរនូវចំណុចដែលចាំបាច់ត្រូវសរសេរ (មាត្រា ៧៥ កថាខណ្ឌទី ២) ព្រមទាំងតើដើមចោទបានបង់ពន្ធសម្រាប់ការដាក់ពាក្យបណ្តឹង (មាត្រា ៦១ កថាខណ្ឌទី ១ និង ទី ២) ដែរឬទេ (មាត្រា ៧៨ កថាខណ្ឌទី ១) ។ ការពិនិត្យនេះ គឺជាការពិនិត្យស្តីពីភាពស្រប ឬ មិនស្របនឹងល័ក្ខខ័ណ្ឌនៃទម្រង់តែប៉ុណ្ណោះ ហើយមិនអនុញ្ញាតឱ្យពិនិត្យមើលថា តើស្របនឹងល័ក្ខខ័ណ្ឌផលប្រយោជន៍នៃបណ្តឹង ឬ ល័ក្ខខ័ណ្ឌបណ្តឹងផ្សេងទៀតឬទេ ឬក៏ការទាមទារតាមផ្លូវបណ្តឹងនោះ មានមូលហេតុត្រឹមត្រូវដែរឬទេ ជាអាទិ៍ ឡើយ ។

(២) ការបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹង

តាមលទ្ធផលនៃការពិនិត្យ ប្រសិនបើខ្វះចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ឬ ពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ ឬ មានកង្វះ ជាអាទិ៍ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យធ្វើការកែតម្រូវនូវចំណុចដែលខ្វះនោះ ដោយកំណត់នូវអំឡុងពេលសមរម្យដើម្បីកែតម្រូវ (មាត្រា ៧៨ កថាខណ្ឌទី ១) ។ ប្រសិនបើដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់នោះទេ តុលាការត្រូវលើកចោលពាក្យបណ្តឹងដោយដីកាសម្រេច ( មាត្រា ៧៨ កថាខណ្ឌទី ២) ។

ប្រសិនបើមានការមិនពេញចិត្តនឹងដីកាសម្រេចនេះ ដើមចោទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន (សូមមើលមាត្រា ២៥៩ កថាខណ្ឌទី ១ ចំណុច គ ស្តីពីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ។

ប្រសិនបើដើមចោទបានធ្វើការកែតម្រូវតាមការបង្គាប់ឱ្យធ្វើការកែតម្រូវ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ ហើយចាប់ផ្តើមការជំនុំជម្រះ ។

៣. ការបញ្ជូនពាក្យបណ្តឹង

ក្រោយការពិនិត្យពាក្យបណ្តឹង ប្រសិនបើតុលាការទទួលស្គាល់ថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមទម្រង់ ហើយទទួលពាក្យបណ្តឹងនោះ ក្រឡាបញ្ជី ( មាត្រា ២៤៦ កថាខណ្ឌទី ២) ត្រូវធ្វើការបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ (មាត្រា ៧៩ កថាខណ្ឌទី ១) ។ ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឱ្យដើមចោទត្រៀមនូវឯកសារចម្លងនៃពាក្យបណ្តឹងទៅតាមចំនួនដែលត្រូវការ តាមចំនួននៃចុងចម្លើយ ហើយបញ្ជូនឯកសារចម្លងនៃពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ (តុលាការត្រូវរក្សាទុកនូវឯកសារដើមនៃពាក្យបណ្តឹងនោះ) ។ ក្នុងករណីដែលមិនអាចធ្វើការបញ្ជូនបាន ដោយសារតែអាសយដ្ឋានរបស់ចុងចម្លើយដែលមានសរសេរក្នុងពាក្យបណ្តឹងនោះមិនត្រឹមត្រូវ ជាដើម តុលាការត្រូវបង្គាប់ឱ្យធ្វើការកែតម្រូវ ដោយកំណត់អំឡុងពេលដើម្បី

កែតម្រូវ ដូចក្នុងករណីដែលមានកង្វះក្នុងការសរសេរពាក្យបណ្តឹងដែរ (មាត្រា ៧៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ ក្នុងករណីដែលដើមចោទមិនបានបង់សោហ៊ុយចាំបាច់ជាមុន សម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹង ក៏ត្រូវចាត់ចែងដូចគ្នាដែរ (មាត្រា ៧៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។ ម្យ៉ាងទៀត ទោះបីជាដើមចោទបានខំប្រឹងប្រែងស្រាវជ្រាវរកអាសយដ្ឋាន លំនៅឋាន ឬ ទីកន្លែងផ្សេងទៀតដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹងក៏ដោយ តែរកមិនឃើញទេ ដើមចោទអាចដាក់ពាក្យសុំឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន (មាត្រា ២៥៥ កថាខណ្ឌទី ១ ចំណុច ក) ។ ទោះជាដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការក៏ដោយ ទំនាក់ទំនងគតិយុត្តនឹងកើតមានឡើងត្រឹមតែរវាងតុលាការ និង ដើមចោទតែប៉ុណ្ណោះ រហូតដល់ពេលដែលពាក្យបណ្តឹងនោះត្រូវបានបញ្ជូនទៅចុងចម្លើយ ។ តាមរយៈការបញ្ជូនពាក្យបណ្តឹងទៅឱ្យចុងចម្លើយចុងចម្លើយក៏នឹងក្លាយទៅជាប្រធាននៃនីតិវិធីនៃបណ្តឹងនោះ ហើយទំនាក់ទំនងគតិយុត្តរវាងភាគីទាំងបី គឺ តុលាការ ដើមចោទ និង ចុងចម្លើយ នឹងកើតមានឡើងពីពេលនោះ ។ ក្នុងន័យនេះ ការដាក់បណ្តឹង ត្រូវបានសម្រេចដោយការបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ ។

៤. ការកំណត់កាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការកោះហៅភាគី

ពេលដែលបណ្តឹងត្រូវបានដាក់ តុលាការត្រូវធ្វើការកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (កាលបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) កុំឱ្យមានការយឺតយ៉ាវ ហើយត្រូវកោះហៅភាគីសងខាង (មាត្រា ៨០ កថាខណ្ឌទី ១) ។ កាលបរិច្ឆេទនេះ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់ (មាត្រា ៨០ កថាខណ្ឌទី ២) ។ តាមការអនុវត្តជាក់ស្តែង ក្រោយពីបានពិនិត្យ ហើយបានទទួលពាក្យបណ្តឹង តុលាការត្រូវកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ហើយត្រូវធ្វើការបញ្ជូនពាក្យបណ្តឹង ព្រមជាមួយនឹងដីកាកោះហៅចុងចម្លើយឱ្យមកតុលាការតាមកាលបរិច្ឆេទកំណត់នេះ ។ ចំពោះដើមចោទវិញ ត្រូវបញ្ជូនដីកាកោះហៅនៃកាលបរិច្ឆេទនេះ ។ ម្យ៉ាងទៀត ប្រសិនបើដើមចោទពុំបានបង់សោហ៊ុយចាំបាច់សម្រាប់ការកោះហៅតាមកាលបរិច្ឆេទនេះ (ដូចជាសោហ៊ុយដើម្បីធ្វើការបញ្ជូនដីកាកោះហៅ ជាដើម) ជាមុន ហើយមិនធ្វើតាមការបង្គាប់ឱ្យបង់ជាមុននេះ តុលាការអាចវលើកចោលបណ្តឹងនោះ ដោយដីកាសម្រេច (ក៏ប៉ុន្តែ លុះត្រាតែគ្មានការតវ៉ាពីចុងចម្លើយ ។ សូមមើលមាត្រា ៨២ កថាខណ្ឌទី ១ ។ ក្នុងករណីដែលធ្វើការបញ្ជូនពាក្យបណ្តឹង ព្រមគ្នានឹងដីកាកោះហៅចុងចម្លើយស្តីពីកាលបរិច្ឆេទលើកដំបូង ប្រសិនបើពុំបានបង់សោហ៊ុយបញ្ជូនជាមុនទេ តុលាការមិនអាចធ្វើការបញ្ជូនពាក្យបណ្តឹងបានទេ ដូច្នេះហើយ យោងតាមមាត្រា ៧៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ តុលាការនឹងលើកចោលពាក្យបណ្តឹង) ។

## កថាភាគទី ២ អានុភាពនៃការដាក់បណ្តឹង

### ១. ការចាត់ការបណ្តឹងនឹងមានដំណើរការ

ក្រោយពីបានធ្វើការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយហើយ នៅតុលាការកំណត់នោះ ស្ថានភាពដែលតុលាការត្រូវជំនុំជម្រះ និង ចេញសាលក្រមស្តីពីការទាមទារតាមផ្លូវបណ្តឹងដែលអះអាងដោយដើមចោទនឹងកើតមានឡើង រវាងដើមចោទជាកំណត់ និង ចុងចម្លើយជាកំណត់នោះ ។ ស្ថានភាពនេះ គេហៅថាការចាត់ការបណ្តឹង ។

### ២. ការហាមធ្វើបណ្តឹងជាន់គ្នា

(១) ការកើតឡើងនៃការចាត់ការបណ្តឹងនេះ នឹងបង្កើតនូវអានុភាពមួយចំនួន ។ ក្នុងនោះ អានុភាពសំខាន់ជាងគេ គឺ ការហាមបណ្តឹងជាន់គ្នា (មាត្រា ៨៣) ។ ការហាមបណ្តឹងជាន់គ្នា មានន័យថា ចំពោះរឿងក្តីពាក់ព័ន្ធនឹងបណ្តឹងដែលតុលាការកំពុងចាត់ការ ភាគីមិនអាចដាក់ពាក្យបណ្តឹងម្តងទៀត ពាក់ព័ន្ធនឹងរឿងក្តីដដែលនោះទេ ។ នេះគឺដោយសារតែ មិនចាំបាច់ទទួលស្គាល់ឱ្យដើមចោទដាក់ពាក្យបណ្តឹងជាន់គ្នាទេ ហើយម្យ៉ាងទៀត ប្រសិនបើទទួលស្គាល់នូវបណ្តឹងជាន់គ្នា ចុងចម្លើយត្រូវឆ្លើយតបនឹងបណ្តឹងជាន់គ្នាយ៉ាងស្មុគស្មាញហើយតាមផ្លូវសេដ្ឋកិច្ចនៃបណ្តឹង ការធ្វើនីតិវិធីដដែលៗ គឺនាំឱ្យខាតប្រយោជន៍ លើសពីនេះ អាចមានករណីដែលមានសាលក្រមច្រើន ដែលមានខ្លឹមសារមិនស៊ីគ្នាក៏មានដែរ (ប៉ះពាល់ដល់អានុភាពអាជ្ញាអស់ជំនុំស្ថាពរនៃសាលក្រម) ។

ការហាមបណ្តឹងជាន់គ្នានេះ គឺជាការហាមនូវការដាក់ពាក្យបណ្តឹងក្រោយមួយដែលមានខ្លឹមសារដូចគ្នានឹងបណ្តឹងដែលបានដាក់មុនហើយដែលកំពុងត្រូវគេចាត់ការ ។ ប្រសិនបើបណ្តឹងមុន ត្រូវបានចាត់ការរួចរាល់ហើយ ហើយតុលាការបានចេញសាលក្រម បន្ទាប់មកសាលក្រមនោះបានចូលជាស្ថាពរ ការដាក់ពាក្យបណ្តឹងដែលមានខ្លឹមសារដដែលក្រោយពីនោះ គេមិនហៅថា បណ្តឹងជាន់គ្នា ហើយគេមិនហាមឱ្យដាក់ទេ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ អាជ្ញាអស់ជំនុំនៃសាលក្រមនៃបណ្តឹងមុន នឹងមានអានុភាពទៅលើបណ្តឹងដែលត្រូវបានដាក់ក្រោយ (មាត្រា ១៩៤) ហេតុនេះហើយ ខ្លឹមសារនៃសាលក្រមនៃបណ្តឹងមុន នឹងចងតុលាការនៃបណ្តឹងក្រោយ ។

(២) រឿងក្តីតែមួយដែលបានកំណត់ក្នុងការហាមបណ្តឹងជាន់គ្នានេះ គឺជាករណីដែលភាគីក្នុងបណ្តឹងមុន និងបណ្តឹងក្រោយមានដូចគ្នា ហើយសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ដែលត្រូវបានអះអាងក្នុងការទាមទារតាមផ្លូវបណ្តឹងនោះ ក៏ដូចគ្នា ។ ទោះជាតុលាការខុសគ្នាក៏ដោយ ក៏ប៉ុន្តែ ប្រសិនបើភាគី និង ការទាមទារតាមផ្លូវបណ្តឹងមានដូចគ្នា នេះគឺជាករណីតែមួយទេ ។ ឧទាហរណ៍ A បានប្តឹងទាមទារចំពោះ B ឱ្យសងប្រាក់កំចី ១០ លានរៀល ដែលបានខ្ចីនៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៥ ទៅសាលាដំបូងទីក្រុងភ្នំពេញ ហើយពេលដែលបណ្តឹងនេះកំពុងត្រូវបានចាត់ការ A បានដាក់បណ្តឹងនៃរឿងប្រាក់កំចីដដែលនេះ ទៅសាលាដំបូងខេត្តកណ្តាល ករណីបណ្តឹងក្រោយនេះនឹងប៉ះពាល់ដល់បញ្ញត្តិហាមបណ្តឹងជាន់គ្នា ដូច្នេះមិនអនុញ្ញាតឱ្យធ្វើបាន

ទេ ។ ទោះជាឋានៈរបស់ដើមចោទ និង ចុងចម្លើយ មានផ្ទុយទៅវិញ ក៏គេហៅថា បណ្ដឹងនៃរឿងតែមួយដែរ ។ ហេតុនេះហើយ ក្នុងករណីខាងលើនេះ ពេលដែលបណ្ដឹងទាមទារឱ្យសងប្រាក់ ១០ លានរៀល ដែលធ្វើឡើងដោយ A ចំពោះ B កំពុងត្រូវបានចាត់ការ ទោះបីជា B បានដាក់ពាក្យបណ្ដឹង ចំពោះ A ទាមទារឱ្យតុលាការធ្វើការបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិទាមទារឱ្យសងប្រាក់កំចី ១០ លានរៀល ដែលកើតឡើងនៅថ្ងៃទី ៣ ខែតុលា ឆ្នាំ ២០០៥ ក៏ដោយ បណ្ដឹងក្រោយនេះ គឺជាបណ្ដឹងជាន់គ្នា ដូច្នេះមិនអាចអនុញ្ញាតឱ្យដាក់បានឡើយ ។ ក្នុងករណីនេះក៏ដូចគ្នាដែរ រវាងបណ្ដឹងដែល A បានដាក់មុន និង បណ្ដឹងដែល B បានដាក់ក្រោយនោះ សិទ្ធិតាមផ្លូវច្បាប់សារធាតុ ដែលតុលាការត្រូវធ្វើការជំនុំជម្រះនោះ គឺដូចគ្នាទេ ដូច្នេះ ការជំនុំជម្រះនោះនឹងជាន់គ្នាឥតប្រយោជន៍ ហើយអាចមានករណីដែលតុលាការទាំងពីរចេញសាលក្រមផ្ទុយគ្នា បើឱ្យតុលាការទាំងពីរសម្រេច ។ ម្យ៉ាងទៀត ចំពោះ B វិញ ប្រសិនបើខ្លួនឈ្នះ ក្នុងបណ្ដឹងមុន នត្ថិភាពនៃករណីយកិច្ចសងប្រាក់ ១០ លានរៀល នឹងចូលជាស្ថាពរ ដូច្នេះមិនចាំបាច់ដាក់បណ្ដឹងផ្សេងទៀតឡើយ ។

៣. អានុភាពតាមផ្លូវច្បាប់សារធាតុ

ក្នុងការដាក់បណ្ដឹង ក្រៅពីអានុភាពតាមផ្លូវច្បាប់នីតិវិធីខាងលើនេះ មានអានុភាពនៃការផ្អាកអាជ្ញាយុកាល (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ ចំណុច ក, មាត្រា ៤៩១), អានុភាពនៃការគោរពអំឡុងពេល (ក្រមរដ្ឋប្បវេណី មាត្រា ៥៣៣ កថាខណ្ឌទី ៤, ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣១១ ជាអាទិ៍) ផងដែរ ។ នេះគឺអានុភាពដែលច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី ជាដើម) ទទួលស្គាល់ ដោយយកអង្គហេតុនៃការដាក់បណ្ដឹងមកធ្វើជាល័ក្ខខ័ណ្ឌតតិយុត្ត ដូច្នេះហើយ នេះគេហៅថា អានុភាពតាមផ្លូវច្បាប់សារធាតុនៃការដាក់បណ្ដឹង ។ អានុភាពទាំងនេះ នឹងកើតមានឡើងពេលដែលបានដាក់ពាក្យបណ្ដឹង (មាត្រា ៨៧) មានន័យថា ពេលដែលបានដាក់ពាក្យបណ្ដឹងជាក់ស្ដែង (ក្នុងករណីដែលជាការបន្ថែម ឬ ផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹង ឬ បណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី អានុភាពនឹងកើតមានឡើង ពេលដាក់ឯកសារដែលមានលក្ខណៈដូចពាក្យបណ្ដឹង) ។ ប្រសិនបើបកស្រាយថា អានុភាពនឹងកើតមានឡើងពេលធ្វើការបញ្ជូនទៅចុងចម្លើយវិញ ក្នុងករណីដែលការបញ្ជូននោះមានការយឺតយ៉ាវដោយមិនមែនជាការទទួលខុសត្រូវរបស់ដើមចោទ ពេលនោះដើមចោទបានដាក់ពាក្យបណ្ដឹងរួចហើយ តែអាជ្ញាយុកាលត្រូវបានសម្រេចទៅវិញ ឬ បានដាក់បណ្ដឹងហើយ ប៉ុន្តែ មិនបានទទួលនូវអានុភាពនៃការគោរពអំឡុងពេលទៅវិញ ។

## ជំពូកទី ២ ការជំនុំជម្រះលើបណ្ដឹង

### ផ្នែកទី ១ តួនាទីរបស់តុលាការ និង ភាគី នៅក្នុងការជំនុំជម្រះលើបណ្ដឹង

ការជំនុំជម្រះលើបណ្ដឹង ត្រូវប្រព្រឹត្តឡើងដោយការងារសហការគ្នា រវាងតុលាការ និង ភាគីទាំងសងខាង ដែលជាប្រធាននៃបណ្ដឹង ដោយផ្អែកលើការបែងចែកតួនាទីរៀងៗខ្លួន ។ បើពន្យល់ត្រួសៗទៅ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងអំពីការបែងចែកតួនាទី ឬក៏ហៅម៉្យាងទៀតថាសិទ្ធិអំណាចនិងការទទួលខុសត្រូវ ដោយបានកំណត់ដូចតទៅនេះ ។ ការគ្រប់គ្រងលើនីតិវិធី ការដឹកនាំនីតិវិធីឱ្យដើរទៅមុខ ព្រមទាំងការចាត់ចែងនិងរៀបចំការជំនុំជម្រះ គឺជាសិទ្ធិអំណាចនិងការទទួលខុសត្រូវចម្បង របស់តុលាការ ។ ដោយឡែក ការកំណត់នូវចំណុចដែលជាកម្មវត្ថុនៃការជំនុំជម្រះ និង នៃការសម្រេចសេចក្ដី ការបំភ្លឺអំពីអង្គហេតុនៃរឿងក្ដី និង ការផ្ដល់ឯកសារជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្ដី គឺជាសិទ្ធិអំណាចនិងការទទួលខុសត្រូវ របស់ភាគី ។

#### កថាភាគទី ១ ការដឹកនាំនីតិវិធី និង ការចាត់ចែងនិងរៀបចំការជំនុំជម្រះ

១. សិទ្ធិអំណាចរបស់តុលាការ ក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង

(១) ដូចបានពន្យល់ខាងលើនេះ ការគ្រប់គ្រងលើនីតិវិធី ការដឹកនាំនីតិវិធីឱ្យដើរទៅមុខ ព្រមទាំងការចាត់ចែងនិងរៀបចំការជំនុំជម្រះ គឺជាសិទ្ធិអំណាចនិងការទទួលខុសត្រូវ របស់តុលាការ ។ ដើម្បីធ្វើឱ្យការជំនុំជម្រះលើបណ្ដឹង ប្រព្រឹត្តទៅដោយពេញលេញ និង ឆាប់រហ័ស គេត្រូវធ្វើយ៉ាងណាឱ្យនីតិវិធីមានដំណើរការទៅមុខយ៉ាងលឿន ហើយធ្វើការចាត់ចែងឱ្យបានសមរម្យ ស្របទៅតាមស្ថានភាពនៃការជំនុំជម្រះ ។ ហេតុដូច្នេះហើយ សិទ្ធិអំណាចនៃការគ្រប់គ្រងលើនីតិវិធី ដែលបានផ្ដល់ទៅឱ្យតុលាការនេះ គេអាចហៅជាសរុបបានថា "សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង" ( មាត្រា ៨៩) ។

(២) ជាគោលការណ៍ សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង គឺជាសិទ្ធិអំណាចរបស់តុលាការ ហើយត្រូវអនុវត្តដោយតុលាការ (ឧទាហរណ៍ មាត្រា ៩០, មាត្រា ៩៤, មាត្រា ៩៩, មាត្រា ១០០ ជាដើម) ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីនៃការជំនុំជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចអនុវត្តសិទ្ធិអំណាចនេះបាន ក្នុងនាមក្រុមប្រឹក្សាជំនុំជម្រះទាំងមូល នៅក្នុងកាលៈទេសៈពិសេស (មាត្រា ៨៩ កថាខណ្ឌទី ១ និង ទី ២ ។ នៅក្នុងប្រព័ន្ធនៃការជំនុំជម្រះដោយចៅក្រមតែម្នាក់ សិទ្ធិអំណាចនឹងត្រូវអនុវត្តដោយចៅក្រមទោលនោះ ។ ហេតុនេះហើយ ការបែងចែកបែបនេះ ពុំមានន័យអ្វីទេ នៅក្នុងករណីនោះ) ។

(៣) ខ្លឹមសារនៃសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង មានវិសាលភាពគ្របដណ្ដប់ទៅលើដំណើរការទាំងមូលនៃការជំនុំជម្រះ មានដូចជា : ការកំណត់ និង ការប្ដូរកាលបរិច្ឆេទ (មាត្រា ១១៣, មាត្រា ២៤០

កថាខណ្ឌទី ១, មាត្រា ២៤១ ជាដើម) ការសម្រេចអំពីការពន្យារអំឡុងពេល (មាត្រា ៧៨, មាត្រា ២៤៤ ជាដើម) ដែលជាបញ្ហាទាក់ទងទៅនឹងដំណើរការទាំងស្រុងនៃនីតិវិធី, ការរៀបចំ និង ចាត់ចែងសកម្មភាពរបស់ភាគី នៅកាលបរិច្ឆេទដែលបានកំណត់ (មាត្រា ៨៩ កថាខណ្ឌទី ២, មាត្រា ១៣៨ កថាខណ្ឌទី ៦, មាត្រា ១៣៩ កថាខណ្ឌទី ៣ ជាដើម), ការបំបែក និងការរួមបញ្ចូលរឿងក្តី (មាត្រា ៩៥), ការចាត់វិធានការណ៍ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវរឿងក្តី (មាត្រា ៩០), និង ការលើកចោលនូវមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (មាត្រា ៩៤) ជាដើម ។

២. សិទ្ធិតវ៉ារបស់ភាគី ចំពោះសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្តឹង

ក្នុងករណីដែលភាគីយល់ឃើញថា ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ត្រូវបានបំពានដោយសារការដឹកនាំនីតិវិធីនៃបណ្តឹង របស់តុលាការ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានៅក្នុងនីតិវិធីនៃការទាញហេតុផល ឬ ដោយសារការអនុវត្តសិទ្ធិឱ្យបំភ្លឺ របស់តុលាការ ដែលមានចែងក្នុងមាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគីអាចប្តឹងតវ៉ាចំពោះការដឹកនាំនីតិវិធីនេះបាន (មាត្រា ៩១) ។ ក្នុងករណីដែលមានការប្តឹងតវ៉ាបែបនេះកើតឡើង តុលាការត្រូវសម្រេចសេចក្តីចំពោះបណ្តឹងតវ៉ានេះ ដោយដីកាសម្រេច ។

## កថាភាគទី ២ ការសម្រេច អំពីចំណុចដែលជាកម្មវត្ថុនៃការជំនុំជម្រះ និង ការសម្រេចសេចក្តី -- សិទ្ធិចាត់ចែងរបស់ភាគី

១. ការសម្រេចអំពីកម្មវត្ថុ និង ទំហំនៃការជំនុំជម្រះនិងការសម្រេចសេចក្តី ដោយភាគី

កម្មវត្ថុនៃការជំនុំជម្រះ និង ការចេញសាលក្រមនៅក្នុងបណ្តឹង គឺជាការទាមទារតាមផ្លូវបណ្តឹង ដែលបានធ្វើឡើងដោយដើមចោទ តាមរយៈការដាក់បណ្តឹង ។ តុលាការអាចចាប់ផ្តើមធ្វើការជំនុំជម្រះលើបណ្តឹងបាន តែនៅពេលណាដែលបានទទួលពាក្យបណ្តឹងរបស់ដើមចោទ ប៉ុណ្ណោះ ។ តុលាការ មិនអាចចាប់ផ្តើមនីតិវិធីនៃបណ្តឹងបានឡើយ ប្រសិនបើពុំមានពាក្យបណ្តឹងពីភាគីទេនោះ ។ម្យ៉ាងទៀត ជាគោលការណ៍ នៅពេលដែលមានការដាក់ពាក្យបណ្តឹង ហើយការជំនុំជម្រះត្រូវបានចាប់ផ្តើម ចំណុចដែលមានសរសេរនៅក្នុងពាក្យបណ្តឹង ឬ ការទាមទារនៅក្នុងបណ្តឹង អាចត្រូវបានជំនុំជម្រះ និង ចេញសាលក្រម តែត្រឹមទំហំដែលបានសុំប៉ុណ្ណោះ ។ ឧទាហរណ៍ ក្នុងករណីដែលដើមចោទគ្រាន់តែទាមទារសំណងនៃប្រាក់កំចីចំនួន ១០ លានរៀល តុលាការមិនអាចធ្វើការជំនុំជម្រះ និង សម្រេចសេចក្តីលើសិទ្ធិទាមទារថ្លៃលក់ ចំនួន ១០ លានរៀល ជា ជំនួសវិញបានទេ ។ ម្យ៉ាងទៀត ក្នុងករណីដែលដើមចោទគ្រាន់តែប្តឹងទាមទារសំណងប្រាក់ចំនួន ៨ លានរៀល ក្នុងចំណោមប្រាក់កំចីចំនួន ១០ លានរៀល តុលាការមិនអាចចេញសាលក្រមបង្គាប់ឱ្យមានការសងប្រាក់លើសពី ៨ លានរៀល ឡើយ បើទោះបីជាតុលាការយល់ឃើញថា ដើមចោទមានសិទ្ធិទាមទារសំណងប្រាក់រហូតដល់ចំនួន ១០ លានរៀល ក៏ដោយ (សូមមើលមាត្រា ១៨២ កថាខណ្ឌទី ២) ។ នេះមានន័យថា ភាគីមានសិទ្ធិ

សម្រេចអំពីកម្មវត្ថុ និង ទំហំនៃការជំនុំជម្រះ និង ការចេញសាលក្រម នៅក្នុងបណ្តឹង ។

២. ការបញ្ចប់បណ្តឹងដោយផ្អែកលើឆន្ទៈរបស់ភាគី

ម្យ៉ាងវិញទៀត ទោះបីជានីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើមហើយក៏ដោយ ដើមចោទអាចដកពាក្យបណ្តឹង និង បញ្ចប់បណ្តឹងបាន (ប៉ុន្តែ ក្នុងករណីជាក់លាក់មួយចំនួន ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ ។ សូម មើលមាត្រា ២១៧ កថាខណ្ឌទី ១ និង ទី ២ និង មាត្រា ២១៨) ។ លើសពីនេះទៅទៀត ភាគីអាចបញ្ចប់ បណ្តឹង ដោយមិនចាំបាច់រង់ចាំសាលក្រមចុងក្រោយបាន តាមរយៈការលះបង់ ឬ ការទទួលស្គាល់នូវ ការទាមទារ ឬ តាមរយៈការផ្សះផ្សាលើបណ្តឹង (មាត្រា ២២០, មាត្រា ២២១) ។

៣. គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និង មូលដ្ឋាននៃសិទ្ធិនេះ

ដូចបានពន្យល់ខាងលើនេះ គោលការណ៍ដែលអនុញ្ញាតឱ្យភាគីអាចធ្វើការសម្រេច (ការចាត់ចែង) ដោយ ផ្អែកលើឆន្ទៈរបស់ខ្លួន អំពីការចាប់ផ្តើមបណ្តឹង អំពីកម្មវត្ថុ និង ទំហំនៃការជំនុំជម្រះ និង ចេញសាលក្រម និង អំពីការបញ្ចប់បណ្តឹង គេហៅថា គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី ។

មូលដ្ឋាននៃការកំណត់យកគោលការណ៍នៃសិទ្ធិចាត់ចែង មកដាក់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺដោយ សារផ្អែកលើគោលការណ៍នៃស្វ័យភាពរបស់បុគ្គលឯកជន ។ មានន័យថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជា កម្មវត្ថុនៃបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានចាត់ចែងដោយសេរី ដោយផ្អែកតាមឆន្ទៈរបស់ភាគី ។ ហេតុដូច្នេះ ហើយ ការសង្គ្រោះតាមផ្លូវបណ្តឹង អាចធ្វើបានទៅតាមទំហំ និង ពេលវេលាដែលភាគីបានទាមទារ ។ ប្រសិន បើតុលាការ ដែលជាស្ថាប័នរបស់រដ្ឋ ចាប់ផ្តើមបណ្តឹង ហើយចេញសាលក្រម លើសពីទំហំដែលភាគីទាមទារ នោះត្រូវចាត់ទុកថាជាការរំលោភបំពានទៅលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ។

## កថាភាគទី ៣ ការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ

១. ភាពចាំបាច់នៃការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ

ដូចដែលបានពន្យល់ខាងលើរួចមកហើយ កម្មវត្ថុនៃបណ្តឹង គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលដើមចោទ បានអះអាងក្នុងការទាមទារតាមផ្លូវបណ្តឹង ។ ប៉ុន្តែ ដើម្បីឱ្យតុលាការអាចធ្វើការសម្រេចសេចក្តី អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះបាន ត្រូវតែមានការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តី ។ ទោះបីជា A បានដាក់ពាក្យបណ្តឹងចំពោះ B ដោយអះអាងទាមទារឱ្យ B សងប្រាក់ចំនួន ១០ លានរៀល ដែល ខ្លួនបានឱ្យខ្ចីនៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៩៥ ក៏ដោយ ក៏តុលាការមិនអាចសម្រេចសេចក្តីថាតើសិទ្ធិទាមទារ ប្រាក់កំចីចំនួន ១០ លានរៀល ដែល A បានអះអាងនោះ មានអត្ថិភាព ឬ គ្មាននោះដែរ លើកលែងតែ អង្គហេតុនៃរឿងក្តី ត្រូវបានបំភ្លឺ (អង្គហេតុថាតើ A ពិតជាបានឱ្យ B ខ្ចីប្រាក់ចំនួន ១០ លានរៀល នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៩៥ មែន ឬ មិនមែន) ។

២. សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគី ក្នុងការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ -- គោលការណ៍នៃការទាញហេតុផល

(១) ខ្លឹមសារនៃសិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគី

ក្រមនីតិវិធីរដ្ឋប្បវេណី ទទួលស្គាល់នូវសិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគី ក្នុងការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តី ឬ អាចហៅម្យ៉ាងទៀតបានថា សិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគី ក្នុងការផ្តល់សម្ភារៈ (ឯកសារ ជាដើម) ជាមូលដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងអង្គហេតុចាំបាច់ដើម្បីឱ្យតុលាការអាចចេញសាលក្រមបាន ។

ទីមួយ តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ (មាត្រា ៩៥) ។ មានន័យថា ភាគីមានសិទ្ធិសេរីភាពក្នុងការអះអាង ឬ មិនអះអាង នូវអង្គហេតុណាមួយ ហើយមានសិទ្ធិអំណាច ក្នុងការកំណត់នូវទំហំនៃអង្គហេតុដែលតុលាការត្រូវពិចារណា នៅពេលធ្វើការសម្រេចសេចក្តី ។ ម្យ៉ាងវិញទៀត បើទោះបីជាមានអង្គហេតុជាក់ស្តែង ដែលមានប្រយោជន៍សម្រាប់ភាគីក៏ដោយ តែបើភាគីមិនបានអះអាងទេ តុលាការមិនអាចពិនិត្យនូវអង្គហេតុនោះ ដើម្បីចេញសាលក្រមបានឡើយ ។ ការណ៍នេះធ្វើឱ្យភាគីរងនូវការខូចប្រយោជន៍ ដោយសារតែតុលាការមិនអាចទទួលស្គាល់នូវអានុភាពគតិយុត្តដែលមានប្រយោជន៍សម្រាប់ភាគីនោះ (ដូចជាការកកើត ឬ ការរលត់នៃសិទ្ធិជាអាទិ៍) ។ ដោយហេតុនេះហើយ ភាគីត្រូវទទួលខុសត្រូវធ្វើការអះអាងនូវអង្គហេតុដែលមានប្រយោជន៍ដល់ខ្លួន ប្រសិនបើខ្លួនចង់ឈ្នះក្តី ហើយការទទួលខុសត្រូវនេះ គេហៅថា "ការទទួលខុសត្រូវក្នុងការអះអាង" ។ ឧទាហរណ៍ ទោះបីជាមានអង្គហេតុថា ចុងចម្លើយបានសងប្រាក់កម្ចីនោះរួចហើយក៏ដោយ តែប្រសិនបើចុងចម្លើយមិនបានអះអាងទេ តុលាការមិនអាចយកអង្គហេតុនោះមកពិចារណាបានឡើយ ហើយដោយហេតុនេះ តុលាការមិនអាចទទួលស្គាល់ថា កាតព្វកិច្ចរបស់ចុងចម្លើយបានរលត់ដោយការសងនោះ បានទេ ។ ទោះបីជា តាមរយៈចម្លើយរបស់សាក្សី ធ្វើឱ្យតុលាការគិតថា ចុងចម្លើយបានសងបំណុលនោះរួចហើយក៏ដោយ តែប្រសិនបើភាគីមិនបានអះអាងអំពីអង្គហេតុនេះទេ តុលាការមិនអាចយកការគិតឃើញរបស់ខ្លួននេះ មកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីទៅលើអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទបានឡើយ (ក៏ប៉ុន្តែ ក្នុងករណីនេះ តុលាការត្រូវអនុវត្តសិទ្ធិឱ្យបំភ្លឺ ដូចមានពន្យល់នៅខាងក្រោយ) ។ អង្គហេតុ ដែលតុលាការមិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន លើកលែងតែមានការអះអាងពីភាគី គឺជាអង្គហេតុដែលមានភាពចាំបាច់ដោយផ្ទាល់ ដើម្បីធ្វើការកំណត់អំពីអានុភាពគតិយុត្តនៃការកកើត ឬ ការរលត់នៃសិទ្ធិ និង កាតព្វកិច្ច (ដែលគេហៅថា អង្គហេតុផ្ទាល់ ឬ អង្គហេតុចម្បង) ។ នៅពេលភាគីបានអះអាងនូវអង្គហេតុផ្ទាល់ហើយ ទោះបីជាមិនបានលើកឡើងអំពីអង្គហេតុ ដែលមានប្រយោជន៍ដល់ការសន្និដ្ឋានអំពីអត្ថិភាពនៃអង្គហេតុចម្បងនោះ (គេហៅថា អង្គហេតុប្រយោល) ក៏ដោយ ក៏តុលាការ

អាចយកអង្គហេតុប្រយោលនោះមកធ្វើជាមូលដ្ឋាននៃសាលក្រមបានដែរ ព្រោះថា អង្គហេតុប្រយោល មានលក្ខណៈដូចជាភស្តុតាងត្រង់ថា វាគឺជាឧបករណ៍ដែលបញ្ជាក់អំពីអត្ថិភាពនៃអង្គហេតុផ្ទាល់ ។

ទីពីរ ចំពោះអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលគ្មានវិវាទរវាងភាគី តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុនោះ ដោយភស្តុតាងទេ (មាត្រា ១២៣ កថាខណ្ឌទី ២, មាត្រា ៩៦ កថាខណ្ឌទី ១) ។ តាមក្រមនីតិវិធីរដ្ឋប្បវេណី ការសារភាព សំដៅទៅលើសេចក្តីថ្លែងការណ៍ ដែលតាមរយៈនោះ ភាគីទទួលស្គាល់ថា អង្គហេតុដែលមិនមានអំណោយផលល្អដល់ខ្លួន ហើយដែលភាគីម្ខាងទៀតបានអះអាង គឺជាអង្គហេតុពិត ។ ចំពោះអង្គហេតុដែលភាគីបានសារភាព មានន័យថា អង្គហេតុដែលភាគីម្ខាងបានអះអាង ហើយភាគីម្ខាងទៀតមិនតវ៉ា តុលាការពុំចាំបាច់ទទួលស្គាល់អង្គហេតុទាំងនោះដោយផ្អែកលើភស្តុតាងទេ ហើយតុលាការក៏មិនត្រូវទទួលស្គាល់អង្គហេតុដែលផ្ទុយពីអង្គហេតុទាំងនោះ តាមរយៈការពិនិត្យភស្តុតាងដែរ ។

ទីបី ចំពោះភស្តុតាងដើម្បីទទួលស្គាល់អង្គហេតុដែលមានវិវាទរវាងភាគី ជាដំបូង តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ (មាត្រា ១២៤ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ប្រសិនបើតុលាការពុំអាចសម្រេចថា ត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយផ្អែកលើភស្តុតាងដែលគូភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថាមានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន (មាត្រា ១២៤ កថាខណ្ឌទី ២) ។

ដូចបានពន្យល់ខាងលើ គោលការណ៍ដែលផ្តុកផ្តាក់ការបំភ្លឺអំពីអង្គហេតុនៃរឿងក្តី ដែលចាំបាច់ដើម្បីឱ្យតុលាការចេញសាលក្រម ទៅលើការអះអាងរបស់ភាគី (ទៅលើសេចក្តីថ្លែងការណ៍នានា ដូចជាការអះអាង ការសារភាព ការស្នើសុំឱ្យពិនិត្យភស្តុតាង ជាអាទិ៍) គេហៅថា "គោលការណ៍នៃការទាញហេតុផល" ។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថា ក្នុងចំណោមគោលការណ៍ខាងលើនេះករណីលើកលែងដ៏សំខាន់មួយ ត្រូវបានទទួលស្គាល់ចំពោះគោលការណ៍ទីបី ។ និយាយឱ្យចំទៅ គោលការណ៍នៃការទាញហេតុផលដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មិនគ្របដណ្តប់ទៅលើការពិនិត្យភស្តុតាងទេ ។

(២) មូលហេតុ និង ការកម្រិតទៅលើគោលការណ៍នៃការទាញហេតុផល

មូលហេតុនៃការប្រកាន់យកគោលការណ៍នៃការទាញហេតុផល នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គឺដោយសារថា ជាទូទៅ កម្មវត្ថុនៃបណ្តឹងរដ្ឋប្បវេណី គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលអាចចាត់ចែងដោយសេរី រវាងបុគ្គលឯកជន ។ ល្អិកណាដែលភាគីអាចចាត់ចែងដោយសេរី នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់ខ្លួនដែលជាកម្មវត្ថុនៃបណ្តឹង ទោះជាក្នុងករណីដែលអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះក្លាយជាបញ្ហាវិវាទនៅក្នុងបណ្តឹងក៏ដោយ ជាការប្រសើរគួរតែទុកឱ្យភាគីមានសេរីភាពក្នុងការកំណត់ថាអង្គហេតុណាខ្លះដែលខ្លួនត្រូវយកមកអះអាងដើម្បីធ្វើការបញ្ជាក់ និង ក្នុងការកំណត់ថា តើខ្លួនត្រូវធ្វើការ

តតាំងចំពោះការអះអាងអំពីអង្គហេតុរបស់ភាគីម្ខាងទៀត ត្រឹមកម្រិតណា ។ ជាងនេះទៅទៀត រដ្ឋពុំមានផលប្រយោជន៍ដោយផ្ទាល់ណាមួយ ចំពោះលទ្ធផលនៃការកំណត់អំពីសិទ្ធិវិវាទនៅក្នុងបណ្ដឹងឡើយ ។ បន្ថែមពីលើនេះ ចំពោះការបំភ្លឺអំពីអង្គហេតុ ដែលទាក់ទងទៅនឹងអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិបែបនេះ វិធីដែលល្បឿនក្នុងការស្វែងរកការពិតនោះ គឺត្រូវប្រគល់បញ្ហានេះទៅឱ្យភាគី ដែលបានដឹងច្បាស់អំពីស្ថានភាពពាក់ព័ន្ធ ។ ម៉្យាងទៀត ប្រសិនបើយកអង្គហេតុដែលមិនត្រូវបានបង្ហាញនៅក្នុងការអះអាងរបស់ភាគី ទៅធ្វើជាមូលដ្ឋាននៃការចេញសាលក្រមនោះ អាចនឹងនាំឱ្យភាគីមានការភ្ញាក់ផ្អើល តែប្រសិនបើទុកតួនាទីនេះឱ្យភាគីវិញ ទើបអាចចៀសវាងការប្រថុយប្រថាននេះបាន ។ ធ្វើដូច្នេះ គេនឹងអាចទទួលបាននូវលទ្ធផលដែលភាគីទាំងសងខាងពេញចិត្ត ។

គោលការណ៍នៃការទាញហេតុផល សន្មតថា កម្មវត្ថុនៃបណ្ដឹង គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលអាចចាត់ចែងដោយសេរីរវាងបុគ្គលឯកជន ។ ហេតុនេះហើយ គោលការណ៍នេះ មិនអាចអនុវត្តចំពោះបណ្ដឹងដែលមានកម្មវត្ថុជាសិទ្ធិ ឬ ទំនាក់ទងគតិយុត្ត ដែលមិនអាចចាត់ចែងបានដោយការព្រមព្រៀងរវាងភាគី ដូចជាទំនាក់ទំនងឋានៈបុគ្គល ជាអាទិ៍ បានឡើយ ។ ចំពោះបណ្ដឹងប្រភេទទាំងនេះ យកគោលការណ៍នៃការវិនិច្ឆ័យដែល តាមរយៈនោះ តុលាការ មានឆន្ទានុសិទ្ធិអាចនឹងយកអង្គហេតុដែលភាគីមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមបាន ហើយអង្គហេតុដែលពុំមានវិវាទរវាងភាគី អាចត្រូវបានទទួលស្គាល់ដោយផ្អែកលើភស្តុតាងបាន និង ម៉្យាងទៀត តុលាការអាចធ្វើការពិនិត្យភស្តុតាង តាមឆន្ទានុសិទ្ធិរបស់ខ្លួនបាន (គេហៅថា "គោលការណ៍នៃឆន្ទានុសិទ្ធិរបស់ចៅក្រម") (សូមមើលមាត្រា ១២ កថាខណ្ឌទី ១ និង មាត្រា ១៣ នៃសេចក្ដីព្រាងច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល) ។

បន្ថែមពីលើនេះ គោលការណ៍នៃការទាញហេតុផល គឺជាគោលការណ៍ដែលទាក់ទងទៅនឹងការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្ដី ។ ដោយឡែក ការវិនិច្ឆ័យតាមផ្លូវច្បាប់ ដូចជាការបកស្រាយ ឬ ការអនុវត្តច្បាប់ គឺជាបញ្ហាដែលតុលាការត្រូវចាត់ការដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**៣. កិច្ចសហការរបស់តុលាការ -- សិទ្ធិឱ្យបំភ្លឺ**

**(១) ការអនុវត្តសិទ្ធិឱ្យបំភ្លឺ នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់**

ទោះបីជាការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ ត្រូវបានផ្ទុកផ្ដាក់ជាសិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគីក៏ដោយ ក៏វាមិនមែនជាការប្រសើរឡើយ ដែលតុលាការ ក្នុងនាមជាស្ថាប័នរដ្ឋដែលត្រូវទទួលខុសត្រូវដោះស្រាយវិវាទរវាងបុគ្គលឯកជនដោយអនាគតិ (មិនលំអៀង) និង ត្រូវផ្ដល់ការការពារចំពោះភាគីដែលមានសិទ្ធិនោះ ត្រូវនៅស្ងៀមចាំតែឈរមើលនោះដែរ ។ តុលាការ ត្រូវសហការជាមួយភាគី ដើម្បីឱ្យភាគីអាចរៀបចំការអះអាងរបស់ខ្លួនបានហ្មត់ចត់ ។

ហេតុនេះហើយ បានជាមានបញ្ញត្តិចែងថា ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្តឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ ចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ( មាត្រា ៩០ កថាខណ្ឌទី ១) ។ ឧទាហរណ៍ ក្នុងករណីដែលមានចំណុចមិនច្បាស់លាស់ នៅក្នុងសេចក្តីថ្លែងការណ៍របស់ភាគី តុលាការអាចសួរភាគី អំពីចំណុចទាំងនោះ ដើម្បីបំភ្លឺឱ្យបានច្បាស់លាស់នូវគោលគំនិតនោះបាន ។ ម្យ៉ាងទៀត ក្នុងករណីដែលមានចំណុចមិនស្របគ្នា នៅក្នុងការអះអាងរបស់ភាគី តុលាការអាចចង្អុលប្រាប់អំពីចំណុចមិនស្របគ្នានោះ ដើម្បីឱ្យភាគីអាចបំពេញបន្ថែម ឬ កែតម្រូវការអះអាងរបស់ខ្លួនបាន ។ ជាងនេះទៅទៀត តុលាការអាចជម្រុញឱ្យភាគីលើកឡើងនូវអង្គហេតុថ្មី ឬ ផ្តល់នូវភស្តុតាងថ្មីបាន ត្រឹមកម្រិតដែលមិនលើសពីភាពយុត្តិធម៌ និង ភាពសមហេតុផល ។ ប៉ុន្តែ ទោះបីជាក្នុងករណីដែលតុលាការជម្រុញឱ្យភាគីលើកឡើងនូវអង្គហេតុថ្មីក៏ដោយ ប្រសិនបើភាគីមិនព្រមលើកឡើងទេ ក៏តុលាការមិនអាចយកអង្គហេតុថ្មីនោះមកធ្វើជាមូលដ្ឋាននៃសាលក្រមបានដែរ ។

សិទ្ធិអំណាចរបស់តុលាការបែបនេះ គេហៅថា "សិទ្ធិឱ្យបំភ្លឺ" ឬ "សិទ្ធិសួរសំនួរ" ។ ភាគី អាចស្នើសុំឱ្យតុលាការអនុវត្តនូវសិទ្ធិឱ្យបំភ្លឺ និង សួរសំនួរចាំបាច់ទៅភាគីម្ខាងទៀត នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នៅកាលបរិច្ឆេទនៃការទាញហេតុផលបាន ( មាត្រា ៩០ កថាខណ្ឌទី ២) ។

(២) ការបង្គាប់ឱ្យត្រៀមរៀបចំការបំភ្លឺ នៅក្រៅកាលបរិច្ឆេទ

លើសពីនេះទៅទៀត នៅក្រៅកាលបរិច្ឆេទ ពេលធ្វើការស្រាវជ្រាវអំពីឯកសារដែលបានដាក់ដោយភាគីជាដើម ប្រសិនបើតុលាការយល់ឃើញថា មានចំណុចមិនច្បាស់លាស់នៅក្នុងការអះអាង ឬ មានចំណុចខ្វះខាតនៅក្នុងការបញ្ជាក់របស់ភាគី តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺអំពីចំណុច ទាំងនោះ នៅកាលបរិច្ឆេទបន្ទាប់បាន ( មាត្រា ៩០ កថាខណ្ឌទី ៣) ។ ជាឧទាហរណ៍មួយចំពោះករណីទាំងនេះ គឺថា ទោះជាក្នុងករណីដែលភាគីមានអ្នកតំណាងដោយអាណត្តិនៅក្នុងរឿងក្តីក៏ដោយ តុលាការអាចបង្គាប់ឱ្យសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ចូលមកតុលាការ ដើម្បីឱ្យតុលាការសួរដោយផ្ទាល់ អំពីស្ថានភាពមួយចំនួន ឬ ឱ្យសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់នោះ ដាក់ឯកសារដើម ដូចជាកិច្ចសន្យាដែលបានលើកឡើង ជាអាទិ៍ ដើម្បីឱ្យតុលាការអាចយល់បានអំពីការអះអាងរបស់ភាគី ។

(៣) សិទ្ធិឱ្យបំភ្លឺ និង កាតព្វកិច្ចទាមទារឱ្យបំភ្លឺ

សិទ្ធិឱ្យបំភ្លឺ គឺជាសិទ្ធិអំណាចដែលត្រូវបានទទួលស្គាល់ចំពោះតុលាការ ដើម្បីបំពេញមុខងារក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ហើយ ក្នុងករណីមួយចំនួន តុលាការក៏មានកាតព្វកិច្ចទាមទារឱ្យភាគីធ្វើការបំភ្លឺដែរ ។ ក្នុងករណីដែលតុលាការចេញសាលក្រមដោយមិនបានអនុវត្តសិទ្ធិឱ្យបំភ្លឺ បើទុកណាជាខ្លួនមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺក៏ដោយ នោះសាលក្រមដែលបានចេញ គឺជាសាលក្រមដែលបំពានច្បាប់ ។ ហេតុដូច្នេះហើយ

ក្នុងករណីដែលការបំពានច្បាប់បែបនេះ បានប៉ះពាល់ទៅដល់សេចក្តីសម្រេចក្នុងសាលក្រមនោះ ភាគីដែលចាញ់ក្តី អាចទាមទារឱ្យលុបចោលសាលក្រមនោះបាន តាមរយៈបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (មាត្រា ២៨៤) ។

ចំពោះថា តើក្នុងករណីណាខ្លះដែលតុលាការមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺបែបនេះ គឺត្រូវកំណត់ទៅតាមខ្លឹមសារជាក់ស្តែងនៃរឿងក្តីនីមួយៗ និង ទៅតាមកាលៈទេសៈនៃការជំនុំជម្រះលើរឿងក្តីនីមួយៗ ។ ហេតុនេះហើយ បញ្ហានេះមានការពិបាកនឹងធ្វើការវែកញែកជាទូទៅណាស់ ។ ពេលខ្លះ មានកើតឡើងនូវបញ្ហាដែលថា ក្រោយពីបានពិនិត្យភស្តុតាងហើយ តុលាការអាចមើលឃើញយ៉ាងច្បាស់ថា មានអង្គហេតុផ្ទាល់មួយ ប៉ុន្តែភាគីដែលមានករណីយកិច្ចត្រូវលើកឡើងនូវអង្គហេតុនោះ បែរជាពុំបានអះអាងទៅវិញ ។ ដូច្នេះ មានសំនួរចោទឡើងថា តើតុលាការមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺ ដែរឬទេ នៅក្នុងករណីបែបនេះ (នៅក្នុងករណីនេះ ការលើកឡើង ឬ មិនលើកឡើងនូវអង្គហេតុរបស់ភាគី គឺជាកត្តាកំណត់លទ្ធផលនៃបណ្តឹង) ។ ដោយយោងទៅតាមដំណាក់កាលនៃរឿងក្តី ប្រសិនបើយល់ឃើញថា ភាគីនឹងមិនលើកឡើងនូវអង្គហេតុណាមួយឡើយ ប្រសិនបើតុលាការមិនអនុវត្តសិទ្ធិឱ្យបំភ្លឺទេនោះ គេអាចនិយាយបានថា ពេលនោះតុលាការត្រូវមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺ ។

## ផ្នែកទី ២ នីតិវិធីនៃការជម្រះក្តី

### កថាភាគទី ១ ការទាញហេតុផលដោយផ្ទាល់មាត់ និង ការរៀបចំ

១. គោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់

ក្រោយពីបានធ្វើការបញ្ជូនពាក្យបណ្តឹងហើយ ដោយមានការចូលរួមរបស់ភាគី តុលាការនឹងធ្វើការសម្រេចសេចក្តីអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ ហើយនឹងចេញសាលក្រម ។ ការសម្រេចសេចក្តីលើបណ្តឹងនេះ ត្រូវធ្វើឡើងតាមវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការវិនិច្ឆ័យ ដែលតាមរយៈនោះ សកម្មភាពរបស់តុលាការ និង ភាគី ដែលទាក់ទងនឹងការជំនុំជម្រះលើបណ្តឹង ជាពិសេសការធ្វើសេចក្តីថ្លែងការណ៍ (ការទាញហេតុផល) របស់ភាគី និង ការពិនិត្យភស្តុតាង ត្រូវធ្វើឡើង ដោយសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្តាប់សេចក្តីថ្លែងការណ៍នោះ ក្នុងសាលសវនាការសាធារណៈ នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន (មាត្រា ១១៥ កថាខណ្ឌទី ១ និង ទី ២) ។ គោលការណ៍នៃការជម្រះក្តីតាមវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់បែបនេះ គេហៅថា "គោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់" ។ ផ្ទុយទៅវិញ គោលការណ៍នៃការជម្រះក្តីលើបណ្តឹង តាមវិធីនៃការដាក់ឯកសារ និង ការពិនិត្យ និង អានឯកសារទាំងនោះ គេហៅថា "គោលការណ៍នៃការជម្រះក្តីដោយឯកសារ" ។

ក្រមនីតិវិធីរដ្ឋប្បវេណី តាមរយៈបញ្ញត្តិនៃមាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ និង មាត្រា ១១៥ កថាខណ្ឌទី ១ និង ទី ២ ដែលបានលើកឡើងខាងលើនេះ អនុម័តយកគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់ ដោយយកគោលការណ៍នៃការជម្រះក្តីដោយឯកសារ ចំពោះភាគខ្លះ ។ មានន័យថា ជាមូលដ្ឋានការជម្រះក្តីលើបញ្ហាដែលត្រូវសម្រេចដោយសាលក្រម (ដូចជា ការទាមទារតាមផ្លូវបណ្តឹង) ត្រូវធ្វើឡើងតាមវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលតាមរយៈនេះ ភាគីទាំងសងខាងត្រូវអង្គុយទល់មុខគ្នា ហើយត្រូវបង្ហាញការទាមទាររបស់ខ្លួន ការអះអាងអំពីអង្គហេតុ និង ការស្នើសុំឱ្យពិនិត្យភស្តុតាង ដោយផ្ទាល់ និង ដោយផ្ទាល់មាត់ ទៅកាន់តុលាការ នៅក្នុងសាលសវនាការសាធារណៈ (មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ និង មាត្រា ១១៥ កថាខណ្ឌទី ១ និង ទី ២) ។ ប៉ុន្តែ ម្យ៉ាងវិញទៀត ក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានចែងដែរថា ចំពោះសកម្មភាពសំខាន់ៗ ដូចជា ការដាក់ពាក្យបណ្តឹង (ចំពោះរឿងក្តីចំនួនទឹកប្រាក់តិច សូមមើលមាត្រា ២២៥ កថាខណ្ឌទី ១) ការបន្ថែម ឬ ការផ្លាស់ប្តូរវត្ថុនៃបណ្តឹង ការដកពាក្យបណ្តឹង និង ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យមានភាពច្បាស់លាស់ (មាត្រា ៧៥ កថាខណ្ឌទី ១, មាត្រា ៨៤ កថាខណ្ឌទី ២, មាត្រា ២១៧ កថាខណ្ឌទី ៣, មាត្រា ២៦៥ កថាខណ្ឌទី ១, មាត្រា ២៨៧ ជាអាទិ៍) ។ ក៏មានបញ្ញត្តិចែងផងដែរថា ដំណើរការ និង ខ្លឹមសារនៃការជម្រះក្តី ត្រូវបញ្ជាក់ដោយការកត់ត្រាក្នុងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៧, មាត្រា ១១៨ និង មាត្រា ១១៩) ។

២. ភាពចាំបាច់ និង ភាពមិនចាំបាច់ នៃការទាញហេតុផលដោយផ្ទាល់មាត់

(១) ដូចដែលបានពន្យល់ខាងលើ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា ចំពោះនីតិវិធីនៃការជម្រះក្តីទៅលើបញ្ហាដែលត្រូវសម្រេចដោយសាលក្រម (នីតិវិធីនៃការចេញសាលក្រម) ចាំបាច់ត្រូវតែធ្វើឡើងតាមរយៈការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ហេតុនេះហើយ ក្នុងករណីនេះ ចាំបាច់ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ (ការទាញហេតុផលដោយផ្ទាល់មាត់ជាចាំបាច់ ។ ក្នុងករណីមួយចំនួន អាចអនុញ្ញាតឱ្យចេញសាលក្រម ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។ សូមមើលមាត្រា ៨១, មាត្រា ២៦៨, មាត្រា ២៩៤ ជាអាទិ៍) ។ ក្នុងករណីដែលចាំបាច់ត្រូវធ្វើការជម្រះក្តីដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ មានតែអ្វីៗដែលត្រូវបានបង្ហាញនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដូចជាអង្គហេតុដែលភាគីបានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬ លទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះ ដែលតុលាការអាចយកមកធ្វើជាមូលដ្ឋាននៃការចេញសាលក្រមបាន ។

(២) ផ្ទុយទៅវិញ ចំពោះបញ្ហាដែលតុលាការត្រូវធ្វើការសម្រេចដោយដីកាសម្រេច ដូចជា ការបញ្ជូនរឿងក្តី (សូមមើលមាត្រា ២១) និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬ បណ្តឹងជិតចិត្តចៅក្រម (មាត្រា ៣០

កថាខណ្ឌទី ១) (ឬក៏រឿងក្តីដែលត្រូវសម្រេចដោយដីកាសម្រេច ដូចជា នីតិវិធីដាស់តឿន និង នីតិវិធីរក្សាការពារ ជាដើម ។ សូមមើលមាត្រា ៣១៩ និង មាត្រា ៥៣៥) ក្រមនីតិវិធីរដ្ឋប្បវេណី ទុកឱ្យតុលាការជាអ្នកសម្រេចដោយឆន្ទានុសិទ្ធិ ថាតើគួរធ្វើការជម្រះក្តីតាមការទាញហេតុផលដោយផ្ទាល់មាត់ ឬទេ (មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ នេះគឺដោយសារតែបញ្ហាដែលត្រូវសម្រេចដោយដីកាសម្រេច គឺជាបញ្ហាបន្ទាប់បន្សំ ដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិ និង កាតព្វកិច្ចរបស់ភាគី ឬ ជាបញ្ហាដែលត្រូវជំនុំជម្រះឱ្យបានឆាប់រហ័ស ។ នៅក្នុងករណីនេះ ទោះបីជាតុលាការបើកការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ ត្រូវចាត់ទុកថានោះគឺជាការទាញហេតុផលដោយផ្ទាល់មាត់តាមការស្ម័គ្រចិត្ត (ការទាញហេតុផលដោយផ្ទាល់មាត់ដោយស្ម័គ្រចិត្ត) ហើយចំពោះឯកសារផ្សេងៗដែលត្រូវបានដាក់ជាលាយលក្ខណ៍អក្សរ ក្រៅពីអ្វីដែលត្រូវបានបង្ហាញនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចយកមកធ្វើជាមូលដ្ឋាននៃការចេញដីកាសម្រេចនោះបាន ។ ប្រសិនបើមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនឹងធ្វើការជម្រះក្តីដោយឯកសារ ។ នៅក្នុងករណីនេះ ប្រសិនបើចាំបាច់ តុលាការអាចកោះហៅភាគីមកសួរដោយផ្ទាល់បាន ។ នីតិវិធីនេះ គេហៅថា "ការសួរ" (មាត្រា ១១៤ កថាខណ្ឌទី ២) ។

៣. ភាពចាំបាច់នៃការត្រៀមរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ -- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ឯកសារត្រៀម

(១) នៅពេលមានការដាក់ពាក្យបណ្តឹង តុលាការត្រូវធ្វើការជម្រះក្តី និង ចេញសាលក្រម ដោយការទាញហេតុផលដោយផ្ទាល់មាត់ ។ ដើម្បីធានាឱ្យបាននូវការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់មួយដែលជាទីពេញចិត្ត និង ដើម្បីទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិត ចាំបាច់ត្រូវមានការត្រៀមរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ ។ ក្នុងគោលបំណងនេះ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថានៅមុនការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១០៣) ។

(២) ជាងនេះទៅទៀត ក្រមនីតិវិធីរដ្ឋប្បវេណី ក៏បានបង្កើតនូវប្រព័ន្ធនៃឯកសារត្រៀម ដើម្បីប្រើប្រាស់ឱ្យមានប្រសិទ្ធិភាព នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។ មានន័យថា តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ១០១ កថាខណ្ឌទី ១) ។ ឯកសារត្រៀម គឺជាឯកសារដែលភាគីនីមួយៗ ជូនដំណឹងជាមុន ទៅតុលាការ និង ភាគីម្ខាងទៀត អំពីចំណុចដែលខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍ នៅកាលបរិច្ឆេទបន្ទាប់ ។ ឯកសារត្រៀម មានគោលបំណងធ្វើឱ្យតុលាការ និង ភាគីសងខាង អាចសម្រេចបាននូវការជម្រះក្តីមួយ ប្រកបដោយប្រសិទ្ធិភាព នៅកាលបរិច្ឆេទដែលបានកំណត់ ហើយឯកសារនេះ មិនមែនត្រូវបានប្រើប្រាស់តែនៅក្នុងការត្រៀមកាលបរិច្ឆេទ

នៃការទាញហេតុផលដោយផ្ទាល់មាត់នោះទេ គឺវាត្រូវបានប្រើប្រាស់នៅក្នុងការត្រៀមកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ ។

នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និង សេចក្ដីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត ( មាត្រា ១០១ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ការទទួលស្គាល់ ឬ មិនទទួលស្គាល់ នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង អង្គហេតុតវ៉ា ជាអាទិ៍ ( មាត្រា ១០១ កថាខណ្ឌទី ៣ ។ ដោយហេតុនេះហើយ ឯកសារត្រៀមបែបនេះ អាចហៅបានថា "ឯកសារចម្លើយ") ។ ក្នុងករណីដែលដើមចោទ បានសរសេរនៅក្នុងពាក្យបណ្ដឹង នូវចំណុចចាំបាច់នានា ( មាត្រា ៧៥ កថាខណ្ឌទី ២) និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ ព្រមទាំងអង្គហេតុសំខាន់ៗដែលទាក់ទងនឹងអង្គហេតុដែលទាមទារឱ្យមានការបញ្ជាក់ ( មាត្រា ៧៥ កថាខណ្ឌទី ៣) ការសរសេរនោះ មានអត្ថន័យជាការដាក់មធ្យោបាយតទល់ ។ ដូច្នេះ ពាក្យបណ្ដឹងដែលមានសរសេរនូវចំណុច និង អង្គហេតុទាំងនេះ ត្រូវចាត់ទុកជាឯកសារត្រៀមផងដែរ ( មាត្រា ៧៥ កថាខណ្ឌទី ៤) ។

ដោយសារថា ក្រមនីតិវិធីរដ្ឋប្បវេណី បានជ្រើសរើសយកគោលការណ៍នៃការជម្រះក្ដីដោយផ្ទាល់មាត់ ហេតុនេះហើយ ចំណុចទាំងឡាយដែលមានសរសេរនៅក្នុងឯកសារត្រៀម មិនអាចចាត់ទុកថាជាខ្លឹមសារនៃការទាញហេតុផលតែម្ដងបានទេ ។ ចំណុចនានាដែលមានសរសេរនៅក្នុងឯកសារត្រៀម ដែលត្រូវបានដាក់សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវយកទៅពិចារណា នៅពេលធ្វើការចាត់ចែង ឬ រៀបចំការអះអាង និង ភស្តុតាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើចំណុចទាំងនោះ ត្រូវបានភាគីថ្លែងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនោះ ។ ប៉ុន្តែ ប្រសិនបើចំណុចទាំងនោះ មិនត្រូវបានភាគីថ្លែងឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដោយចាត់ជាផ្នែកមួយនៃលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ចំណុចទាំងនោះមិនអាចយកទៅធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

## កថាភាគទី ២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១. អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

(១) នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកំពស់ និង សម្រួលដល់ការជម្រះក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងធ្វើការបំភ្លឺអំពីចំណុចវិវាទរវាងភាគី ដោយរៀបចំជាមុន នូវសេចក្ដីអះអាងរបស់ភាគី និង ធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវធ្វើការ

ពិនិត្យ (មាត្រា ១០៣) ។ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗដែលខ្លួនយល់ថាមានប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំគិតថាអង្គហេតុទាំងនោះ មាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ ។ នៅក្នុងពេលជាមួយគ្នា ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង ។ ក៏ប៉ុន្តែ ការធ្វើបែបនេះ នឹងនាំឱ្យការជម្រះក្តីមានភាពស្មុគស្មាញ និង អូសបន្លាយដោយឥតប្រយោជន៍ និង ធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការពិត ។ ហេតុដូច្នេះហើយ មុននឹងចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី និង ត្រូវបំភ្លឺនូវចំណុចវិវាទ តាមវិធីសាស្ត្រដូចតទៅ : (១) ស្នើឱ្យភាគីដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និង ផាត់ចោលនូវអង្គហេតុទាំងឡាយណាដែលភាគីធ្វើការអះអាងដូចគ្នា ចំពោះចំណុចជាសារវ័ន្តនៃការពិនិត្យភស្តុតាង ដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ (២) ជាងនេះទៅទៀត ចំពោះភស្តុតាងដែលត្រូវពិនិត្យទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានាឱ្យបាននូវការពិនិត្យដោយសមូហវិធី ដោយត្រូវយកចិត្តទុកដាក់តែទៅលើភស្តុតាងដែលសំខាន់ និង មានតម្លៃតែប៉ុណ្ណោះ (មាត្រា ១២៧) ។ ដោយសារហេតុផលនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីសម្រាប់ការត្រៀមទាញហេតុផល ។

នៅក្នុងកិច្ចការបណ្តឹងជាក់ស្តែងនៅកម្ពុជាកន្លងមក តុលាការរៀបចំនីតិវិធីមួយដែលហៅថា "នីតិវិធីស៊ើបសួរ" មុននឹងធ្វើការទាញហេតុផលដោយផ្ទាល់មាត់ (នីតិវិធីជំនុំជម្រះ) ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង នីតិវិធីស៊ើបសួរ បើមើលទៅដូចជាប្រហាក់ប្រហែលគ្នា នៅក្នុងលក្ខណៈដែលថានីតិវិធីទាំងពីរបែបនេះ ត្រូវធ្វើឡើងនៅមុនការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ ។ ក៏ប៉ុន្តែ នៅក្នុងនីតិវិធីស៊ើបសួរ តុលាការធ្វើការសាកសួរភាគី និង សាក្សីដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបើកចំហរជាសាធារណៈទេ ហើយតាមរយៈការធ្វើបែបនេះ តុលាការអាចក្តាប់បានច្បាស់ នូវទំនាក់ទំនងអង្គហេតុនៅក្នុងរឿងក្តីនោះ ។ អាស្រ័យហេតុនេះ នៅពេលតុលាការធ្វើការសាកសួរភាគីម្ខាង មិនចាំបាច់មានវត្តមានរបស់ភាគីម្ខាងទៀតទេ ហើយនៅពេលសាកសួរសាក្សី ក៏មិនចាំបាច់មានវត្តមានរបស់ភាគីណាម្ខាងដែរ ។ ក៏ប៉ុន្តែ ដោយផ្អែកលើគោលការណ៍នៃការជម្រះក្តីជាសាធារណៈ ការដែលតុលាការស្តាប់ការអះអាងរបស់ភាគី និង ពិនិត្យភស្តុតាងដើម្បីបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៅក្នុងរឿងក្តី នៅក្នុងសវនាការជាសាធារណៈ នោះគឺជាខ្លឹមសារសំខាន់នៅក្នុងការជម្រះក្តី ។ ម្យ៉ាងទៀត ភាគីដែលជាប្រធាននៃនីតិវិធីបណ្តឹង មានសិទ្ធិទាមទារឱ្យសាកសួរ (មាត្រា ៣ កថាខណ្ឌទី ១) ហើយការជម្រះក្តីលើបណ្តឹង ត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍ចំពោះមុខ (មាត្រា ៣ កថាខណ្ឌទី ២) ។ នៅក្នុង

ប្រទេសប្រជាធិបតេយ្យ និង នីតិរដ្ឋ នីតិវិធីស៊ើបសួរដែលធ្លាប់បានអនុវត្តពីមុន អាចខុសនឹងគោលការណ៍ជាមូលដ្ឋាននៃបណ្តឹងទាំងនេះ ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នីតិវិធីស៊ើបសួរដែលបានអនុវត្តពីមុន ត្រូវលុបចោល ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលត្រូវធ្វើឡើង នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន (មាត្រា ១០៥ កថាខណ្ឌទី ១ ។ ការធានានូវគោលការណ៍ចំពោះមុខ) ហើយនីតិវិធីនេះ មានគោលបំណងរៀបចំការអះអាងរបស់ភាគី និង កំណត់នូវភស្តុតាងដែលត្រូវពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដោយផ្អែកលើការពិភាក្សារវាងតុលាការ និង ភាគីទាំងសងខាង ។ ដូច្នេះ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានលក្ខណៈខុសគ្នាពីនីតិវិធីស៊ើបសួរត្រង់គោលបំណង និង ខ្លឹមសារនៃនីតិវិធីនោះ ដែលមិនត្រូវផ្ទុយនឹងគោលការណ៍នៃការជម្រះក្តីជាសាធារណៈ ការធានាសិទ្ធិរបស់ភាគីក្នុងការទាមទារឱ្យសាកសួរ និង គោលការណ៍ចំពោះមុខ ។

ចំពោះរឿងក្តីចំនួនទឹកប្រាក់តិច (ចាប់ពីមាត្រា ២២៣ ទៅ) ដែលមានគោលបំណងធ្វើការដោះស្រាយវិវាទឱ្យបានឆាប់រហ័ស តាមនីតិវិធីងាយស្រួល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ភ្លាម បន្ទាប់ពីការដាក់ពាក្យបណ្តឹង ដោយមិនចាំបាច់ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ។

២. កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

(១) ដូចបានពន្យល់ខាងលើ តុលាការ ត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ (មាត្រា ៨០ កថាខណ្ឌទី ២) ។ ការកំណត់បែបនេះ គឺចេញមកអំពីការគិតគូរដែលថា ចុងចម្លើយនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និង ថា ការចាប់ផ្តើមនីតិវិធី នឹងមិនមានការយឺតយ៉ាវ ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើង នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន (មាត្រា ១០៥ កថាខណ្ឌទី ១) ។ បានន័យថា គោលការណ៍ចំពោះមុខ (មាត្រា ៣ កថាខណ្ឌទី ២) ត្រូវបានធានាយ៉ាងពេញលេញ នៅក្នុងនីតិវិធីនេះ ។ ហេតុនេះ បន្ទាប់ពីបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ តុលាការត្រូវកោះហៅភាគីទាំងសងខាង ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ទោះបីជាភាគីម្ខាងមិនមានវត្តមានក៏ដោយ ក្នុងករណីដែលតុលាការបានបញ្ជូនដីកាកោះ និង បានផ្តល់ឱកាសឱ្យភាគីនោះបង្ហាញខ្លួនហើយ ។

(២) កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ (មាត្រា ១០៥ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ នេះគឺដោយសារតែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការគ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទ តាមរយៈការរៀបចំការអះអាងរបស់ភាគី និង គ្រាន់តែរៀបចំនូវភស្តុតាងដែលត្រូវពិនិត្យតែប៉ុណ្ណោះ ។ លើសពីនេះទៅទៀត នៅក្នុងករណីជាច្រើន ការធ្វើនីតិវិធីនេះ នៅក្រៅសាលសវនាការ ត្រូវបានចាត់ទុកថាជាការសមស្របហើយ (ដូចជាធ្វើនៅក្នុងបន្ទប់របស់

ចៅក្រម ជាដើម) ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ តុលាការអាចអនុញ្ញាតឱ្យជនដែលខ្លួនយល់ឃើញថា សមរម្យ ដូចជាសមាជិកគ្រួសាររបស់ភាគី ឬ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀត ចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន (មាត្រា ១០៥ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។ម្យ៉ាងទៀត សកម្មភាពដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវបានធ្វើសេចក្ដីថ្លែងការណ៍ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នាពេលក្រោយ និង ត្រូវបំភ្លឺអំពីបញ្ហាទាំងអស់នេះ នៅក្នុងសវនាការជាសាធារណៈ (មាត្រា ១១៦ កថាខណ្ឌទី ១) ។ ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ចូលស្ដាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ។ នៅពេលធ្វើការសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតនេះ តុលាការត្រូវពិចារណាអំពីមូលហេតុនៃការស្នើសុំចូលស្ដាប់ ព្រមទាំងមតិរបស់ភាគី ផងដែរ ។ ក្នុងករណីដែលការស្នើសុំចូលស្ដាប់ ត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការពាក់ព័ន្ធទៅនឹងរឿងក្ដី ជាគោលការណ៍ តុលាការអាចផ្ដល់ការអនុញ្ញាតចំពោះការស្នើសុំនោះបាន ប្រសិនបើការចូលស្ដាប់នោះ មិនទំនងជានឹងបង្កបញ្ហាដល់ការជម្រះក្ដីទេ ។ ប៉ុន្តែ ក្នុងករណីដែលយល់ឃើញថា ភាគីណាម្ខាងអាចរងការប៉ះពាល់ផ្លូវចិត្តដោយសារតែវត្តមានរបស់បុគ្គលដែលពាក់ព័ន្ធនោះ តុលាការមិនត្រូវអនុញ្ញាតឱ្យបុគ្គលនោះចូលស្ដាប់ទេ ។

(៣) តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ នៅរាល់កាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) (មាត្រា ១០៩) ។ នៅក្នុងកំណត់ហេតុនោះ ក្រឡាបញ្ជីត្រូវកត់ត្រានូវចំណុចនានា ដែលមានចែងនៅក្នុងមាត្រា ១១០ និង មាត្រា ១១១ ។ ចៅក្រម (ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្នុងករណីដែលត្រូវជម្រះក្ដីដោយក្រុមប្រឹក្សាជំនុំជម្រះ) និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ (មាត្រា ១១០ កថាខណ្ឌទី ២) ។ ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នោះត្រូវកត់សេចក្ដីប្ដឹងតវ៉ានោះ នៅក្នុងកំណត់ហេតុនោះ (មាត្រា ១១២ កថាខណ្ឌទី ១) ។ ថាតើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានធ្វើឡើង ដោយស្របទៅតាមរបៀបរបបដែលកំណត់ដោយច្បាប់ (ឧទាហរណ៍ អ្នកណាខ្លះបានមានវត្តមាន នីតិវិធីនោះត្រូវបានធ្វើនៅពេលណា ជាដើម) ដែរឬទេនោះ អាចបញ្ជាក់បាន តែដោយកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុណ្ណោះ (មាត្រា ១១២ កថាខណ្ឌទី ២) ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនោះ បានបាត់ ឬ វិនាស ។

### ៣. ការសាកល្បងផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សាជាដំបូងសិន លើកលែងតែក្នុងករណីដែលយល់ឃើញថាមិនសមរម្យ (មាត្រា ១០៤) ។ ដោយសារថា នីតិវិធីរដ្ឋប្បវេណី មានគោលបំណងធ្វើការកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់

ចែងបាន ដោយផ្អែកលើការព្រមព្រៀងរវាងភាគី ដូច្នេះ ទោះបីជានៅពេលដែលនីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើម ហើយក៏ដោយ ប្រសិនបើភាគីបានកំណត់ថាសិទ្ធិ ឬ កាតព្វកិច្ចនោះ មានអត្ថិភាព ឬ គ្មាន តាមរយៈការសះជា ហើយភាគីសម្រេចចិត្តបញ្ចប់វិវាទនោះ គេអាចនិយាយបានថា វាគឺជាលទ្ធផលដែលគួរឱ្យចង់បាន ។ ហេតុនេះ ហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជាសកម្មភាពដំបូងបំផុតនៃការជម្រះក្តី តុលាការត្រូវណែនាំឱ្យភាគីទាំងសងខាង សះជានឹងគ្នា (មាត្រា ១០៤) ។ ប៉ុន្តែ ផ្ទុយទៅវិញ ក្នុងករណីដែលតុលាការយល់ឃើញថា ការព្យាយាមសាកល្បងផ្សះផ្សា មិនសមរម្យទេ ដូចជា ក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង គឺជាប្រភេទនៃសិទ្ធិ ឬ កាតព្វកិច្ច ដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគីប៉ុណ្ណោះទេ ឬ ក្នុងករណីដែលអាកប្បកិរិយារបស់ភាគី បង្ហាញយ៉ាងច្បាស់ថា ពួកគេគ្មានឆន្ទៈធ្វើការផ្សះផ្សាទេនោះ តុលាការមិនចាំបាច់ណែនាំឱ្យភាគីសះជានឹងគ្នាឡើយ ។

ម្យ៉ាងទៀត ប្រសិនបើ តាមរយៈការវិនិច្ឆ័យអំពីស្ថានភាពនៃបណ្តឹង តុលាការយល់ឃើញថា វិវាទនោះអាចដោះស្រាយដោយការផ្សះផ្សាបាន តុលាការអាចសាកល្បងធ្វើការផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅពេលក្រោយមក ឬ នៅក្នុងនីតិវិធីនៃការទាញហេតុផលតែម្តង ក៏បាន (មាត្រា ៩៧) ។ នៅពេលណែនាំឱ្យភាគីសះជាគ្នា តុលាការអាចប្រើវិធីមួយ ដោយឱ្យភាគីម្ខាងចេញពីបន្ទប់ ហើយតុលាការស្តាប់ការអះអាងរបស់ភាគីម្ខាងទៀត និង ធ្វើដូច្នេះម្តងទៀតចំពោះភាគីម្ខាងទៀត (គេហៅថា "ការសួរឆ្លាស់គ្នា") ។ ក៏ប៉ុន្តែ បើប្រើវិធីនេះ ភាគីម្ខាងមិនអាចដឹងថាតើតុលាការ និង ភាគីម្ខាងទៀត បានពិគ្រោះគ្នាពីរឿងអ្វីខ្លះនោះទេ ហើយការណ៍នេះ នឹងធ្វើឱ្យនីតិវិធីនៃការផ្សះផ្សា មានភាពមិនច្បាស់លាស់ ។ ហេតុដូច្នេះ វិធីសាស្ត្រនេះ អាចប្រើបានតែក្នុងករណីដែលមានការព្រមព្រៀងច្បាស់លាស់រវាងភាគី ក្នុងការធ្វើបែបនេះ តែប៉ុណ្ណោះ ។

៤. ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល – ការរៀបចំនូវការអះអាង និង ភស្តុតាង និង ការកំណត់នូវចំណុចវិវាទ

(១) ពាក្យសុំលើអង្គសេចក្តីនៃរឿងក្តី

ក្នុងករណីដែលការផ្សះផ្សាមិនបានសម្រេចទេ តុលាការត្រូវចាប់ផ្តើមការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។ ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងធ្វើការរៀបចំនូវការអះអាងរបស់ភាគី ធ្វើការកំណត់នូវចំណុចវិវាទ និង ធ្វើការរៀបចំនូវភស្តុតាងដែលទាក់ទងទៅនឹងចំណុចវិវាទ នៅក្នុងនីតិវិធីនេះ តុលាការត្រូវបង្គាប់ឱ្យភាគីដាក់ជាមុន នូវការអះអាង និង ភស្តុតាង ដែលពួកគេមានបំណងនឹងដាក់នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។ ហេតុនេះហើយ ត្រង់ចំណុចនេះ ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងការបាត់សម

ធ្វើនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដែរ ។ ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវចាប់ផ្តើមដំបូងដោយសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង របស់ដើមចោទ និង អំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ (នៅក្នុងករណីជាក់ស្តែង ដើម្បីសាកល្បងធ្វើការផ្សះផ្សា ចាំបាច់ត្រូវដឹងជាមុនអំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។ ដូច្នេះ មុននឹងសាកល្បងធ្វើការផ្សះផ្សា តុលាការអាចបង្គាប់ឱ្យដើមចោទ ធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងបាន ។ ក្នុងករណីបែបនេះ តុលាការមិនចាំបាច់ឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងម្តងទៀត នៅក្រោយពេលសាកល្បងធ្វើការផ្សះផ្សាទេ) ។ ដោយសារថា សាលក្រមដែលដើមចោទទាមទារ មានសរសេរនៅក្នុងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការ ក្នុងពាក្យបណ្តឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ) ហេតុនេះហើយ ពាក្យសុំនេះ ត្រូវបានធ្វើឡើងក្នុងរូបភាពជាសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង ។ ដោយសេចក្តីថ្លែងការណ៍នេះ កម្មវត្ថុចម្បងសម្រាប់ការត្រៀមរៀបចំនៅពេលបន្តបន្ទាប់ទៀត ត្រូវបានកំណត់ ។ មានន័យថា នីតិវិធីជាបន្តបន្ទាប់ទៅទៀត ត្រូវរៀបចំឡើងដោយយោងទៅលើករណីដែលថា តើតុលាការគួរចេញសាលក្រមដែលដើមចោទបានទាមទារ ឬមិនគួរ ។ នៅពេលដែលបានធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹងហើយ លើកលែងតែករណីដែលចុងចម្លើយទទួលស្គាល់ការទាមទារ (មាត្រា ២២១ និង មាត្រា ២២២) ជាធម្មតា ចុងចម្លើយតែងតែដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ ដោយអះអាងថា ការទាមទារនោះពុំមានមូលដ្ឋានត្រឹមត្រូវ ឬ ដាក់ពាក្យសុំឱ្យតុលាការចេញសាលក្រមលើកបណ្តឹងចោល ដោយអះអាងថា ការបំពេញល័ក្ខខ័ណ្ឌក្នុងបណ្តឹង មិនបានគ្រប់គ្រាន់ (ប្រសិនបើបានដាក់ឯកសារចម្លើយ ពាក្យសុំនេះក៏នឹងត្រូវធ្វើឡើង ក្នុងរូបភាពជាសេចក្តីថ្លែងការណ៍អំពីឯកសារចម្លើយនោះដែរ) ។ ជាទូទៅ ពាក្យសុំ គឺជាសកម្មភាពដែលភាគីណាមួយទាមទារឱ្យតុលាការធ្វើសកម្មភាពជាក់លាក់ណាមួយ ។ ពាក្យសុំទាក់ទងទៅនឹងរឿងក្តីតែម្តង ដែលតុលាការត្រូវឆ្លើយតបតាមរយៈសាលក្រមចុងក្រោយ ដូចជាពាក្យសុំរបស់ដើមចោទឱ្យចេញសាលក្រមតាមពាក្យបណ្តឹង និង ពាក្យសុំរបស់ចុងចម្លើយឱ្យលើកចោលបណ្តឹង ឬ ឱ្យច្រានចោលការទាមទាររបស់ដើមចោទ គេហៅថា ពាក្យសុំលើអង្គសេចក្តីនៃរឿងក្តី ។

(២) ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

(ក) បន្ទាប់ពីបានដាក់ពាក្យសុំលើអង្គសេចក្តីនៃរឿងក្តីហើយ ដើមចោទនឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន ហើយចុងចម្លើយក៏នឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួនដែរ ។ សេចក្តីថ្លែងការណ៍របស់ដើមចោទ គេហៅថា មធ្យោបាយតទល់ (វិធីតទល់) រីឯសេចក្តីថ្លែងការណ៍របស់ចុងចម្លើយវិញ គេហៅថា មធ្យោបាយការពារខ្លួន (វិធីការពារខ្លួន) ។

នៅក្នុងចំណោមមធ្យោបាយតទល់របស់ដើមចោទ ជាដំបូង ដើមចោទធ្វើសេចក្តីថ្លែងការណ៍នូវការអះអាងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាការទាមទារតាមផ្លូវបណ្តឹង ។ ក៏ប៉ុន្តែ ដោយសារថា អត្ថិភាព ឬ

នត្ថិភាព នៃសិទ្ធិជាក់លាក់ណាមួយ មិនអាចទទួលស្គាល់ដោយផ្ទាល់បាន ហេតុនេះហើយ តុលាការត្រូវប្រើប្រាស់នូវវិធីធ្វើសេចក្ដីសន្និដ្ឋានតាមភាពសមហេតុផល ដើម្បីធ្វើការកំណត់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ ។ មានន័យថា ជាដំបូង ត្រូវកំណត់ថា តើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានបង្កើតឡើងពីមុនមកដែរឬទេ ហើយប្រសិនបើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានបង្កើតឡើង នោះត្រូវកំណត់ថា តើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានរលត់នាពេលក្រោយមកដែរឬទេ ។ ប្រសិនបើសិទ្ធិនោះ ត្រូវបានទទួលស្គាល់ថាបានបង្កើតឡើង តែមិនត្រូវបានទទួលស្គាល់ថាបានរលត់នាពេលក្រោយមកទេ សិទ្ធិនោះ ត្រូវបានវិនិច្ឆ័យថាមានអត្ថិភាពនៅពេលបច្ចុប្បន្ន ។ ហេតុនេះហើយ ដើម្បីឱ្យតុលាការសម្រេចថា សិទ្ធិដែលជាខ្លឹមសារនៃការទាមទាររបស់ខ្លួន មានអត្ថិភាព ដើមចោទត្រូវធ្វើការអះអាងអំពីអង្គហេតុមួយឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ដើម្បីឱ្យសិទ្ធិនោះមានអានុភាពតាមផ្លូវច្បាប់ (អង្គហេតុផ្ទាល់) ។ ឧទាហរណ៍ ក្នុងករណីដែល A អះអាងថា ខ្លួនមានសិទ្ធិទាមទារឱ្យ B បង់ប្រាក់ចំនួន ១០ លានរៀល ដែលជាថ្លៃលក់ទិញរថយន្ត A ត្រូវអះអាងអំពីអង្គហេតុដែលថា : កិច្ចសន្យាមួយនៃការលក់ទិញរថយន្តដែលជាកម្មសិទ្ធិរបស់ A ទៅឱ្យ B ក្នុងតម្លៃ ១០ លានរៀល ត្រូវបានបង្កើតឡើងរវាង A និង B នៅកាលបរិច្ឆេទជាក់លាក់មួយ ហើយពេលកំណត់ត្រូវបង់ប្រាក់ បានមកដល់ហើយ (សូមមើលមាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី) ។ ប្រសិនបើ B មិនទទួលស្គាល់នូវអង្គហេតុនេះ A ត្រូវផ្ដល់ភស្តុតាងដើម្បីបញ្ជាក់អំពីអង្គហេតុនេះ ។

ក្នុងការឆ្លើយតបទៅនឹងការអះអាងនេះ ចុងចម្លើយអាចនឹងធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យបង់ថ្លៃលក់ដែល A អះអាង ដោយលើកឡើងថា : (១) ខ្លួនធ្វើវិវាទអំពីអានុភាពកិច្ចសន្យា ដោយហេតុថា ទោះបីជាកិច្ចសន្យាត្រូវបានបង្កើតឡើងពិតមែនក៏ដោយ ប៉ុន្តែ មានការភ័ន្តច្រឡំនៅក្នុងការបង្ហាញឆន្ទៈ ដែល A គួរណាស់តែបានដឹង ហើយដោយហេតុនេះ ខ្លួននឹងលុបចោលកិច្ចសន្យា (សូមមើលមាត្រា ៣៤៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី) ឬ ម៉្យាងទៀត (២) កាតព្វកិច្ចបង់ប្រាក់ បានរលត់ទៅហើយ ព្រោះថ្លៃលក់ទិញនោះត្រូវបានបង់រួចរាល់ហើយ ឬ (៣) កាតព្វកិច្ចបង់ប្រាក់ បានរលត់ទៅហើយ ព្រោះអាជ្ញាយុកាលបានផុតទៅហើយ ហើយការផុតអាជ្ញាយុកាលនេះ ត្រូវបានលើកឡើង (មាត្រា ៤៣៣ ចំណុច ក និង ចំណុច ឃ និង មាត្រា ៤៨៦ នៃក្រមរដ្ឋប្បវេណី) ។ ការអះអាងទាំងអស់នេះ គឺជាមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ ហើយគេហៅថា "ការតវ៉ា (អង្គហេតុតវ៉ា)" ។ នៅក្នុងករណីនេះ ប្រសិនបើចុងចម្លើយមិនបានអះអាងអំពីអង្គហេតុដែលថា មានការភ័ន្តច្រឡំនៅក្នុងការបង្ហាញឆន្ទៈក្នុងការចុះកិច្ចសន្យា ហើយថា A គួរណាស់តែបានដឹងអំពីការណ៍នេះ ឬ អង្គហេតុដែលថា ថ្លៃលក់ទិញនោះ ត្រូវបានបង់រួចហើយ ទេនោះ នៅពេលចេញសាលក្រម តុលាការនឹងមិនយកអង្គហេតុទាំងនេះ ទៅធ្វើជាមូលដ្ឋាននៃសាលក្រមឡើយ នៅក្នុងគោលការណ៍នៃការទាញហេតុផល (ការទទួលខុសត្រូវក្នុងការអះអាង ។ សូមមើលជំពូកទី ២ នេះ ផ្នែកទី ១ កថាភាគទី ៣) ។ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ប្រសិនបើចុងចម្លើយមិនបានលើកឡើងនៅ

កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មិនបានអះអាងអំពីអង្គហេតុដែលថា ខ្លួនបានលើកឡើងអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ក្រៅកាលបរិច្ឆេទតុលាការ នោះចុងចម្លើយនឹងមិនទទួលបាននូវសាលក្រមដែលត្រូវនឹងចិត្តរបស់ខ្លួន ដោយផ្អែកលើអង្គហេតុនេះឡើយ (មាត្រា ៤៨៦ នៃក្រមរដ្ឋប្បវេណី) ។

ប្រសិនបើដើមចោទមិនទទួលស្គាល់អង្គហេតុតវ៉ាដែលជាមធ្យោបាយការពារខ្លួននេះ ចុងចម្លើយត្រូវស្នើសុំឱ្យពិនិត្យភស្តុតាង ដើម្បីបញ្ជាក់អំពីអង្គហេតុនេះ ។ ម្យ៉ាងទៀត ដើម្បីតទល់នូវការតវ៉ារបស់ចុងចម្លើយ ដើមចោទអាចលើកឡើងនូវអង្គហេតុផ្សេងទៀត ដែលអាចបដិសេធចោលនូវអានុភាពនៃការការតវ៉ានោះ ។ ឧទាហរណ៍ ដើម្បីបដិសេធការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដើមចោទអាចធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលជាមូលហេតុនៃការផ្អាកអាជ្ញាយុកាល (សូមមើល មាត្រា ៤៨៩ នៃក្រមរដ្ឋប្បវេណី) ។ នេះគេហៅថា "ការតវ៉ាឆ្លើយតបចំពោះការតវ៉ា" ។

(ខ) សេចក្តីថ្លែងការណ៍ដែលជាមធ្យោបាយតទល់ ឬ ការពារខ្លួន អាចបែងចែកជាការដាក់ពាក្យសុំ និង សេចក្តីថ្លែងការណ៍ផ្សេងទៀត ទៅតាមលក្ខណៈនៃសកម្មភាពរបស់ភាគី ។ ការដាក់ពាក្យសុំ និង សេចក្តីថ្លែងការណ៍ផ្សេងទៀត ដែលភាគីបានធ្វើ គេហៅថា "ការទាញហេតុផល" ។

ដូចបានពន្យល់ខាងលើ ពាក្យសុំ គឺជាសកម្មភាពរបស់ភាគីដែលទាមទារសុំឱ្យតុលាការធ្វើសកម្មភាពជាក់លាក់ណាមួយ ដូចជាការចេញសាលក្រម ការចេញដីកាសម្រេច ការពិនិត្យភស្តុតាង ការធ្វើសកម្មភាពចាំបាច់នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ ជាអាទិ៍ ។ ក្រៅពីពាក្យសុំលើអង្គសេចក្តីនៃរឿងក្តី ដែលជាពាក្យសុំឱ្យចេញសាលក្រមចុងក្រោយ មានពាក្យសុំមួយបែបទៀត គឺពាក្យសុំលើចំណុចបន្ទាប់បន្សំ ឬ លើចំណុចដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងការទាមទារ ដូចជា ពាក្យសុំឱ្យដកហូតសមត្ថកិច្ចជំនុំជម្រះ ពាក្យសុំប្តឹងជំទាស់ចៅក្រម និង ពាក្យសុំផ្ទេររឿងក្តី ជាអាទិ៍ ។ ពាក្យសុំទាំងនេះ គេហៅថា "ពាក្យសុំក្នុងបណ្តឹង (ពាក្យសុំតាមនីតិវិធី)" ។

សេចក្តីថ្លែងការណ៍ សំដៅទៅលើសកម្មភាពដែល តាមរយៈនោះ ភាគីធ្វើការរៀបរាប់ ឬ ផ្តល់នូវការយល់ឃើញ ឬ មតិរបស់ខ្លួន ទៅឱ្យតុលាការ ។ ក្នុងចំណោមនោះ ការរៀបរាប់អំពីការយល់ឃើញអង្គហេតុ ហៅថា "សេចក្តីថ្លែងការណ៍អំពីអង្គហេតុ" ចំណែកការរៀបរាប់អំពីការយល់ឃើញ និង មតិយោបល់តាមផ្លូវច្បាប់ ហៅថា "សេចក្តីថ្លែងការណ៍អំពីអង្គច្បាប់" ។ ក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងនេះ សេចក្តីថ្លែងការណ៍ដែលមិនមែនជាការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ហើយដែលរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬ មតិយោបល់តាមផ្លូវច្បាប់ គេហៅជាពិសេសថា "ការអះអាង" ។ ជាគោលការណ៍ នៅក្នុងនីតិវិធីនៃបណ្តឹងដែលធ្វើឡើងតាមគោលការណ៍នៃការទាញហេតុផល អង្គហេតុដែលមិនបានអះអាងដោយភាគី មិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបានទេ (មាត្រា ៩៥) ។ ហេតុនេះហើយ ការអះអាងអំពីអង្គហេតុ មានសារៈសំខាន់ ជាពិសេស នៅក្នុងចំណោមសកម្មភាពទាំងអស់ ។

(៣) ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

(ក) ភាគី ត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលសមរម្យ ទៅតាមដំណាក់កាលនៃរឿងក្តី (មាត្រា ៩៣) ។ នេះគឺជានិមិត្តរូបមួយនៃគោលការណ៍ជាមូលដ្ឋាន នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលថា ភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណី ដោយសុចរិត និង ស្មោះត្រង់ (មាត្រា ៤) ។ ក្នុងករណីដែលមានមូលហេតុសមរម្យពិសេស ភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលណាក៏បាន មុនពេលដែលការវិនិច្ឆ័យលើបណ្តឹងត្រូវបានបញ្ចប់ (គឺ មុនពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់) ។ ប៉ុន្តែ ប្រសិនបើពុំមានមូលហេតុពិសេសទេ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលសមរម្យទៅតាមដំណាក់កាលនៃការជម្រះក្តី ។ ពេលវេលាសមរម្យ សំដៅទៅលើឱកាស ឬ ដំណាក់កាល នៅក្នុងនីតិវិធីដែលត្រូវបានសន្និដ្ឋានថា គួរដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ដើម្បីដោះស្រាយវិវាទ ឱ្យបានលឿន និង ត្រឹមត្រូវ ។

ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលធ្វើឡើងដើម្បីបំភ្លឺជាមុន នូវចំណុចវិវាទ ដោយត្រូវរៀបចំការអះអាងរបស់ភាគី និង រៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីអាចរៀបចំការជម្រះក្តីឱ្យមានប្រសិទ្ធិភាព និង ដោយសមូហវិធី នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ហេតុនេះហើយ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនទាំងអស់ នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ លើកលែងតែក្នុងកាលៈទេសៈដែលមិនទាន់អាចដាក់បាននៅពេលនេះ ។ ដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ ភាគីត្រូវធ្វើការស្រាវជ្រាវជាមុន ឱ្យបានហ្មត់ចត់ អំពីទំនាក់ទំនងអង្គហេតុចំពោះសាក្សី ឬ ភស្តុតាងដទៃទៀត (មាត្រា ៩២) ។ ហេតុនេះហើយ ដូចដែលនឹងពន្យល់ខាងក្រោម ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ជាគោលការណ៍ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀត នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានឡើយ (មាត្រា ១០៨) ។

(ខ) នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីត្រូវលើកឡើងនូវការអះអាងរបស់ខ្លួន ឱ្យបានទាន់ពេលវេលា ត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ហើយត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងចំពោះអង្គហេតុដែលមានវិវាទ ។ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលបានដាក់ទៅតុលាការ យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួននោះ បាន តាមពាក្យសុំរបស់ភាគីម្ខាងទៀត ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង (មាត្រា ៩៤ កថាខណ្ឌទី ១) ។ នេះក៏ព្រោះថា ប្រសិនបើអនុញ្ញាតឱ្យភាគីណាម្ខាងដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ក្រោយពេលវេលាសមរម្យ ដោយមានបំណង ឬ ចេតនាធ្វើការអូសបន្លាយនីតិវិធីនៃបណ្តឹង នោះវាមិនត្រឹមតែធ្វើឱ្យរំខានដល់ភាគីម្ខាងទៀតប៉ុណ្ណោះទេ វាថែមទាំងជាបន្ទុកមួយ

ដ៏ធ្ងន់សម្រាប់តុលាការផងដែរ ដែលការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃប្រព័ន្ធតុលាការទាំងមូលតែម្តង ។ ក្នុងករណីដែលគោលគំនិត និង អត្ថន័យនៃមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលភាគីបានដាក់ មានភាពមិនច្បាស់លាស់ ហើយតុលាការបានទាមទារឱ្យបំភ្លឺ តែភាគីមិនផ្តល់ការបំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួន តាមកាលបរិច្ឆេទដែលបានកំណត់ឱ្យបំភ្លឺទេ តុលាការអាចលើកចោលនូវមធ្យោបាយតទល់ ឬ ការពារខ្លួននោះបាន ( មាត្រា ៩៤ កថាខណ្ឌទី ២) ។

**(៤) ការបញ្ជាក់អំពីចំណុចវិវាទ តាមរយៈការរៀបចំនូវការអះអាង និង ការរៀបចំភស្តុតាង**

(ក) នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពេលដែលភាគីបានដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ដូចបានពន្យល់ខាងលើនេះហើយ ពេលនោះ តុលាការត្រូវអនុវត្តសិទ្ធិឱ្យបំភ្លឺ និង រៀបចំមធ្យោបាយតទល់ ឬ ការពារខ្លួននោះ ជាពិសេស ត្រូវរៀបចំការអះអាងរបស់ភាគីទាំងសងខាង ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្តី ហើយតុលាការត្រូវរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។ នេះគឺជាផ្នែកសំខាន់បំផុតនៃការជម្រះក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ( មាត្រា ១០៣) ។

ជាទូទៅ ចំណុចទាំងឡាយណាដែលភាគីទាំងសងខាងប្រកែកគ្នា ( ជាធម្មតា គឺអង្គហេតុ) គេហៅថា ចំណុចវិវាទ ។ ក្នុងករណីដែលភាគីណាម្ខាង បានអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណីបែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀត ជាបួនប្រភេទ ។ ទី ១ ភាគីម្ខាងទៀតនោះ អាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ដែលការធ្វើបែបនេះ គេហៅថា ការបដិសេធ (ការមិនទទួលស្គាល់) ។ ទី ២ ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនេះ ដែលគេហៅថា ការសារភាព (សូមមើលមាត្រា ១២៣ កថាខណ្ឌទី ២) ។ ទី ៣ ភាគីនោះ អាចធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ដែលការធ្វើបែបនេះ គេហៅថា សេចក្តីថ្លែងការណ៍អំពីការមិនបានដឹង ។ ទី ៤ ចុងក្រោយគេ គឺករណីដែលភាគីនោះមិនឆ្លើយថាអ្វីទាំងអស់ ។ ក្នុងចំណោមករណីទាំងនេះ អង្គហេតុ គឺជាចំណុចវិវាទ នៅក្នុងករណីទី ១ តែនៅក្នុងករណីទី ២ អង្គហេតុ មិនមែនជាចំណុចវិវាទទេ ។ បញ្ហាកើតមានឡើងចំពោះករណីពីរចុងក្រោយ ។ នៅក្នុងករណីនៃការធ្វើសេចក្តីថ្លែងការណ៍អំពីការមិនបានដឹង ក្រមនីតិវិធីរដ្ឋប្បវេណីសន្មតអាកប្បកិរិយានោះថាជាការតវ៉ាចំពោះអង្គហេតុនោះ ( មាត្រា ៩៦ កថាខណ្ឌទី ២) ហើយ ចំពោះករណីដែលភាគីមិនឆ្លើយអ្វីទាំងអស់វិញ ត្រូវចាត់ទុកថា ភាគីបានសារភាពអំពីអង្គហេតុនោះ លើកលែងតែក្នុងករណីដែលតុលាការយល់ឃើញថា ភាគីនោះបានតវ៉ាចំពោះអង្គហេតុនោះ ដោយគិតពិចារណាអំពីអាកប្បកិរិយាទាំងស្រុងរបស់ភាគីនោះ (មាត្រា ៩៦ កថាខណ្ឌទី ១, ការចាត់ទុកថាបានសារភាព) ។ ហេតុនេះហើយ អង្គហេតុដែលភាគីឆ្លើយថាមិនបានដឹង នឹងក្លាយទៅជាចំណុចវិវាទ ។ ផ្ទុយទៅវិញ ប្រសិនបើពុំមានការឆ្លើយតបទេ ត្រូវចាត់ទុកថាជាការសារភាព ហើយអង្គហេតុនោះ នឹងមិនមែនជាចំណុចវិវាទឡើយ ។

តាមគោលការណ៍នៃការទាញហេតុផល អង្គហេតុដែលភាគីបានសារភាព (រួមទាំងអង្គហេតុដែលសន្មតថាបានសារភាព) មិនចាំបាច់ធ្វើការបញ្ជាក់ ដោយភស្តុតាងឡើយ (មាត្រា ១២៣ កថាខណ្ឌទី ២) ។

ដូច្នេះ ឧទាហរណ៍ថា A បានឱ្យ B ខ្ចីប្រាក់ចំនួន ១០ លានរៀល នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០០ ហើយ A មិនទាន់បានទទួលប្រាក់សំណងវិញនៅឡើយ បើទោះបីជាកាលកំណត់ត្រូវសង បានមកដល់តាំងពីថ្ងៃទី ១ ខែ មិថុនាម្ល៉េះក្តី ។ ក្នុងករណីនេះ ប្រសិនបើ A បានដាក់ពាក្យបណ្តឹងទាមទារឱ្យសងប្រាក់ ១០ លានរៀលនោះ ហើយ B បានថ្លែងថា គាត់មិនបានខ្ចីប្រាក់ពី A ចំនួន ១០ លានរៀលនោះទេ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០០ ពេលនោះ បញ្ហាដែលថាតើកិច្ចសន្យាខ្ចីប្រាក់ចំនួន ១០ លានរៀល ត្រូវបានធ្វើឡើងរវាង A និង B កាលពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០០ មែន ឬ មិនមែននោះ នឹងក្លាយទៅជាចំណុចវិវាទនៃរឿងក្តី ។ ក៏ប៉ុន្តែ នៅក្នុងករណីជាក់ស្តែង ចំណុចវិវាទពិតប្រាកដ (ចំណុចវិវាទស្នូល) មិនចាត់ទុកថាបានបញ្ជាក់តែដោយចំណុចនេះឡើយ ។ ប្រសិនបើ A អះអាងថា ខ្លួនបានឱ្យ B ខ្ចីប្រាក់ចំនួន ១០ លានរៀល តុលាការ យ៉ាងហោចណាស់ត្រូវបង្គាប់ឱ្យ A បំភ្លឺអំពីកាលៈទេសៈដែលនាំទៅដល់ការខ្ចីប្រាក់ ព្រមទាំងរឿងរ៉ាវលំអិតអំពីពេលវេលា ដែល A បានឱ្យប្រាក់ទៅ B ខ្ចី ជាអាទិ៍ ផងដែរ ។ ជាលទ្ធផល ឧទាហរណ៍ថា ក្នុងការឆ្លើយតបទៅនឹងការបង្គាប់ឱ្យបំភ្លឺ A បានថ្លែងថា តាមការពិត គឺ C ដែលជាកូនប្រុសច្បងរបស់ B ទេ ដែលបានមកកាន់ការិយាល័យរបស់ខ្លួន ហើយសុំខ្ចីប្រាក់ ក្នុងនាមរបស់ B ពោលគឺមិនមែន B ជាអ្នកមកខ្ចីដោយផ្ទាល់ឡើយ ។ A បានប្រគល់មូលប្បទានប័ត្រលើទឹកប្រាក់ចំនួន ១០ លានរៀល ទៅឱ្យ C ដោយសារថា C មានលិខិតប្រគល់សិទ្ធិតំណាងក្នុងនាមរបស់ B ហើយ A ជឿទុកចិត្តលើលិខិតនោះ ។ តុលាការ ត្រូវបង្គាប់ឱ្យ B ធ្វើការឆ្លើយតបចំពោះការអះអាងលើអង្គហេតុបែបនេះ របស់ A ។ ហេតុដូច្នេះ នៅក្នុងករណីនេះ ចំណុចវិវាទពិតប្រាកដនៃរឿងក្តី គឺនៅត្រង់ថាតើមានអង្គហេតុដែល B បានប្រគល់សិទ្ធិអំណាចឱ្យ C ធ្វើជាអ្នកតំណាងរបស់ខ្លួនដែរឬទេ ។ ជាងនេះទៅទៀត ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យ A ដាក់លិខិតប្រគល់សិទ្ធិតំណាងក្នុងនាមរបស់ B ដែលខ្លួនបានទទួលពី C នោះ និង បានបង្គាប់ឱ្យ B ធ្វើការបញ្ជាក់អំពីបញ្ហានេះ ប្រសិនបើ B បានបដិសេធអំពីភាពត្រឹមត្រូវនៃហត្ថលេខា នោះចំណុចវិវាទពិតប្រាកដ កាន់តែត្រូវបានបង្រួមតូចរហូតដល់ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃហត្ថលេខានៅលើលិខិតប្រគល់សិទ្ធិនោះហើយ ។

អាស្រ័យហេតុនេះ តុលាការ ធ្វើការកំណត់នូវចំណុចវិវាទនៃរឿងក្តីនេះ : តាមរយៈការបង្គាប់ឱ្យភាគីធ្វើការបំភ្លឺអំពីអង្គហេតុផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាមូលហេតុផ្ទាល់នៃការបង្កើតសិទ្ធិ ដែលដើមចោទបានអះអាង និង អំពីរឿងរ៉ាវលំអិតនៃរឿងក្តី និង តាមរយៈការបង្គាប់ឱ្យភាគីធ្វើការបន្ថែម កែប្រែ ឬ ដកចេញនូវការអះអាងរបស់ខ្លួន ។ មុខងារនេះរបស់តុលាការ គេហៅថា "ការរៀបចំការអះអាង" ឬ "ការរៀបចំចំណុចវិវាទ" ។ តាមរយៈមុខងារនេះ ចំណុចវិវាទពិតប្រាកដត្រូវបានកំណត់ និង ត្រូវបានទទួលស្គាល់រួមគ្នា ដោយតុលាការ និង ភាគីទាំងសងខាង ។

(ខ) ដូច្នេះ បន្ទាប់ពីបានកំណត់នូវចំណុចវិវាទពិតប្រាកដហើយ តុលាការត្រូវកំណត់នូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យ ។ យោងតាមឧទាហរណ៍ខាងលើនេះ គេអាចយល់បានថា ភស្តុតាងដែលត្រូវពិនិត្យ ប្រែប្រួលទៅតាមអ្វីដែលជាចំណុចវិវាទ ។ ក្នុងករណីដែលសុពលភាពនៃកិច្ចសន្យាខ្ចីបរិភោគ គឺជាចំណុចវិវាទ នោះលិខិតកិច្ចសន្យានោះ និង សាក្សីដែលបាននៅកន្លែងចុះកិច្ចសន្យា គឺជាភស្តុតាងដ៏សំខាន់ ។ រីឯ ក្នុងករណីដែលអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិតំណាងដែលប្រគល់ទៅឱ្យ C គឺជាចំណុចវិវាទវិញ នោះចាំបាច់ត្រូវធ្វើការសាកសួរ C ក្នុងឋានៈជាសាក្សី ។ ម្យ៉ាងទៀត ប្រសិនបើភាពត្រឹមត្រូវនៃហត្ថលេខារបស់ B នៅលើលិខិតប្រគល់សិទ្ធិ គឺជាចំណុចវិវាទវិញនោះ ការធ្វើកោសលវិច័យទៅលើអក្សរដៃ គឺជាការពិនិត្យភស្តុតាងយ៉ាងសំខាន់ ។ ចំណុចនេះក៏បញ្ជាក់ផងដែរ អំពីសារៈសំខាន់នៃការរៀបចំការអះអាង និង ការរៀបចំចំណុចវិវាទ នៅក្នុងការជម្រះក្ដីលើបណ្ដឹង ។

៥. សកម្មភាពបណ្ដឹងដែលអាចធ្វើបាន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើសកម្មភាពចាំបាច់នានា ដើម្បីរៀបចំការអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និង រៀបចំភស្តុតាងដែលត្រូវពិនិត្យនៅពេលទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ ក៏មានការដាក់កម្រិតមួយចំនួនទៅលើសកម្មភាពដែលអាចអនុញ្ញាតឱ្យធ្វើបានដែរ ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ មិនបើកជាសាធារណៈ ។ តុលាការអាចស្ដាប់ពាក្យសុំ និង ការអះអាងរបស់ភាគីសងខាង ហើយអាចចេញដីកាសម្រេចទៅលើការស្នើសុំឱ្យពិនិត្យភស្តុតាង (ឧទាហរណ៍ ដីកាសម្រេចទទួលយក ឬ មិនទទួលយកនូវភស្តុតាងដែលត្រូវបានស្នើសុំឱ្យពិនិត្យ ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ ដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ជាអាទិ៍ ។ សូមមើលមាត្រា ១២៦, មាត្រា ១៤៣ កថាខណ្ឌទី ១ និង មាត្រា ១៥២) ព្រមទាំងដីកាសម្រេចផ្សេងទៀត ដែលក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតឱ្យធ្វើ ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (សេចក្ដីសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យធ្វើការបន្ថែម ឬ ផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹង ដីកាសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យចូលរួមអន្តរាគមន៍ ជាអាទិ៍ ។ សូមមើលមាត្រា ៨៤ កថាខណ្ឌទី ៤ និង មាត្រា ៨៥ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត តុលាការក៏អាចធ្វើការពិនិត្យទៅលើភស្តុតាងជាឯកសារ ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និង ភស្តុតាង បានដែរ (មាត្រា ១០៦) ។ ជាមូលដ្ឋាន ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវបើកជាសាធារណៈទេ ក៏ប៉ុន្តែ ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដ តាមរយៈការរៀបចំការអះអាងរបស់ភាគី តុលាការចាំបាច់ត្រូវធ្វើការពិនិត្យលើឯកសារដែលភាគីបានដាក់ ហើយការពិនិត្យភស្តុតាងជាឯកសារនេះ ត្រូវធ្វើឡើងដោយចៅក្រមអានឯកសារនោះ ហេតុដូច្នេះហើយ អត្ថន័យនៃការពិនិត្យភស្តុតាងជាឯកសារនេះ នៅក្នុងសាលសវនាការជាសាធារណៈមិនសំខាន់ដូចការសាកសួរសាក្សីនោះទេ ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យតុលាការ

អាចធ្វើការពិនិត្យភស្តុតាងជាឯកសារ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ ។ ឧទាហរណ៍ ក្នុងករណីដែលចុងចម្លើយតវ៉ា ចំពោះអង្គហេតុនៃការបង្កើតកិច្ចសន្យាលក់ទិញ ហើយព្រមជាមួយគ្នានោះ ចុងចម្លើយអះអាងថា ទោះបីជាការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ក៏ដោយ ក៏ខ្លួនលុបចោលកិច្ចសន្យានោះ ដោយហេតុថា ការបង្ហាញឆន្ទៈបង្កើតកិច្ចសន្យានោះ ត្រូវបានធ្វើឡើងដោយការឆបោក ប្រសិនបើការបង្កើតកិច្ចសន្យាលក់ទិញនោះ ត្រូវបានទទួលស្គាល់ ដោយពិនិត្យលិខិតកិច្ចសន្យានោះដែលដើមចោទដាក់ទៅតុលាការ នោះតុលាការអាចប្រើវិធីនេះដើម្បីរៀបចំចំណុចវិវាទបាន ។ ក៏ប៉ុន្តែ ចំពោះការពិនិត្យភស្តុតាង ដូចជាការសាកសួរសាក្សី និង កោសលវិច័យជាអាទិ៍ មិនអាចធ្វើឡើងបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ។

៦. ការបំបែក និង ការរួមបញ្ចូលរឿងក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបំបែករឿងក្តីមួយ ទៅជារឿងក្តីផ្សេងៗ ហើយធ្វើការជម្រះក្តីលើរឿងក្តីទាំងនោះ ដោយដាច់ពីគ្នាបាន ។ នេះហៅថា ការបំបែករឿងក្តី (មាត្រា ៩៩ កថាខណ្ឌទី ១) ។ ឧទាហរណ៍ ប្រសិនបើនៅក្នុងបណ្តឹងតែមួយដើមចោទបានទាមទារឱ្យចុងចម្លើយសងប្រាក់កំចីផង និង បង់ប្រាក់ថ្លៃលក់ទិញផង (សូមមើលមាត្រា ៧៧) តុលាការ អាចបំបែកការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញ ចេញពីបណ្តឹងនោះ ហើយធ្វើការជម្រះក្តីដាច់ដោយឡែកបាន ។ បញ្ច្រាសទៅវិញ តុលាការក៏អាចរួមបញ្ចូលរឿងក្តីផ្សេងៗ ដែលកំពុងត្រូវបានចាត់ការនៅក្នុងតុលាការតែមួយ ហើយធ្វើការជម្រះក្តីសរុប ដោយនីតិវិធីតែមួយបានដែរ ។ នេះហៅថា ការរួមបញ្ចូលរឿងក្តី (មាត្រា ៩៩ កថាខណ្ឌទី ១) ។ ទោះបីជាក្នុងករណីដែលការទាមទារពីរយ៉ាង ត្រូវបានដាក់នៅក្នុងបណ្តឹងតែមួយក៏ដោយ ប្រសិនបើការទាមទារនីមួយៗ មានខ្លឹមសារពាក់ព័ន្ធគ្នាតែបន្តិចបន្តួច ហើយការជំនុំជម្រះលើការទាមទារមួយ អាចនឹងធ្វើបានឆាប់ជាងការទាមទារមួយទៀត នោះវាជាការសមស្របដែលត្រូវបំបែករឿងក្តី ។ម៉្យាងវិញទៀត ក្នុងករណីដែលរឿងក្តីជាច្រើនដែលមានខ្លឹមសារទាក់ទងគ្នា កំពុងត្រូវបានចាត់ការដាច់ដោយឡែកពីគ្នា ជាញឹកញាប់វាជារឿងសមហេតុផលក្នុងការជំនុំជម្រះរឿងក្តីទាំងអស់នេះរួមគ្នា តាមរយៈការរួមបញ្ចូលរឿងក្តី (សូមមើលមាត្រា ៩៩ កថាខណ្ឌទី ២) ។

៧. ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

(១) ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់

ពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនោះ (មាត្រា ១០៧) ។ បានន័យថា តុលាការ និង ភាគីសងខាង ត្រូវធ្វើការបញ្ជាក់ថាតើអង្គហេតុណាខ្លះដែលជាចំណុចវិវាទ

ហើយ ដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ហើយតុលាការ និង ភាគីសងខាង ត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសម្ងបវិធី នៅពេលទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ១២៧) ។

(២) ការកំណត់កាលបរិច្ឆេទលើកទីមួយនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីទាំងសងខាង ឱ្យមកចូលរួម នៅកាលបរិច្ឆេទដែលបានកំណត់នោះ (មាត្រា ១១៣) ។

៨. អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀត នៅដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវធ្វើឡើងនៅពេលបន្ទាប់មកបានទេ (មាត្រា ១០៨) ។ ប្រសិនបើអនុញ្ញាតឱ្យភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅក្រោយការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាននោះ ការដែលត្រូវកំណត់ចំណុចវិវាទឱ្យរួចរាល់តាមរយៈការរៀបចំនូវការអះអាងរបស់ភាគី និង ការបង្រួមភស្តុតាងដែលត្រូវពិនិត្យ នឹងពុំមានន័យខ្លឹមសារអ្វីឡើយ ។ បើគិតតាមគោលការណ៍នៃការដាក់ មធ្យោបាយតទល់ ឬ ការពារខ្លួននៅពេលសមរម្យ (មាត្រា ៩៣) ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ អានុភាពនេះ ក៏នឹងមានដូចគ្នាផងដែរ ទៅលើការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ (មាត្រា ២៧៤ កថាខណ្ឌទី ២) ។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលក្រោយបាន ក្នុងករណីដែលបញ្ហាដែលពាក់ព័ន្ធ គឺជាចំណុចដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ (ឧទាហរណ៍ អត្ថិភាព ឬ នត្ថិភាពនៃសមត្ថកិច្ចរបស់តុលាការ អត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះ ជាអាទិ៍ ។ មាត្រា ១៦ និង មាត្រា ២៧ កថាខណ្ឌទី ២) ក្នុងករណីដែលនីតិវិធីនៃបណ្ដឹង នឹងពុំមានភាពយឺតយ៉ាវខ្លាំង (ឧទាហរណ៍ ករណីដែលភាគីបានស្នើសុំឱ្យពិនិត្យភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន ដូចជាឯកសារដែលភាគីដាក់តាមខ្លួនមកតុលាការនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ សាក្សីដែលភាគីនាំមកតុលាការជាមួយ ជាដើម) ឬ ក្នុងករណីដែលភាគីបានធ្វើសេចក្ដីបញ្ជាក់ដំបូងថា មិនអាចដាក់ភស្តុតាងនៅមុនការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ និង ថា ការមិនអាចដាក់នេះ មិនមែនកើតចេញពីកំហុសធ្ងន់ធ្ងរ (ឧទាហរណ៍ ករណីដែលភាគីអះអាងអំពីអង្គហេតុដែលកើតឡើង នៅក្រោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ករណីស្នើសុំឱ្យពិនិត្យភស្តុតាងដែលទើបតែត្រូវបានរកឃើញជាអាទិ៍) ។

## កថាភាគទី ៣ ការទាញហេតុផលដោយផ្ទាល់មាត់

## ១. អត្ថន័យនៃការទាញហេតុផលដោយផ្ទាល់មាត់

ដូចបានពន្យល់ខាងលើរួចមកហើយ ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា ការជម្រះក្ដីលើបណ្ដឹង ត្រូវធ្វើឡើងដោយឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ( មាត្រា ១១៤ កថាខណ្ឌទី ១) ។ ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្ដី ដែលក្នុងនោះ សកម្មភាពរបស់តុលាការ និង សកម្មភាពរបស់ភាគី ចំពោះការជម្រះក្ដីនោះ ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្ដាប់សេចក្ដីថ្លែងការណ៍នោះ នៅសាលសវនាការដែលបើកចំហជាសាធារណៈ ( មាត្រា ១១៥ កថាខណ្ឌទី ២) នៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន ( មាត្រា ១១៥ កថាខណ្ឌទី ១) ។ មូលហេតុដែលក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ឱ្យធ្វើការជម្រះក្ដី តាមវិធីបែបនេះ គឺថា ជាចំណុចអាទិភាពទីមួយ តាមរយៈការចែងអំពីការជម្រះក្ដីជាសាធារណៈ ក្រមនេះមានគោលបំណងលុបបំបាត់នូវការជម្រះក្ដីសម្ងាត់ ដែលពុំមានយុត្តិធម៌ ។ ម្យ៉ាងទៀត ក្រមនេះ មានគោលដៅធានានូវគោលការណ៍ចំពោះមុខ និង ផ្ដល់ឱកាសឱ្យភាគីទាំងសងខាង អាចធ្វើសេចក្ដីថ្លែងការណ៍អំពីការអះអាងរបស់ពួកគេ ដោយយុត្តិធម៌ និង ស្មើភាពគ្នា ក៏ដូចជាផ្ដល់ឱកាសឱ្យភាគី អាចតវ៉ាចំពោះការអះអាងរបស់ភាគីម្ខាងទៀតដែរ ។ ជាងនេះទៅទៀត ក្រមនេះមានគោលបំណងធានាឱ្យបានថា តុលាការដែលចេញសាលក្រម ពិតជាបានស្ដាប់ការអះអាងរបស់ភាគីដោយផ្ទាល់ ដើម្បីសម្រួលដល់ការស្វែងរកការពិត ។ វិសាលភាពនៃការកំណត់ឱ្យធ្វើការជម្រះក្ដីនៅក្នុងសាលសវនាការជាសាធារណៈ តាមរយៈការទាញហេតុផលដោយផ្ទាល់មាត់បែបនេះ មានភាពខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយទៀត ។ ប៉ុន្តែ យ៉ាងណាក៏ដោយ នៅក្នុងនីតិវិធីរដ្ឋប្បវេណីនៃប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យជឿនលឿន ការជម្រះក្ដីដោយផ្ទាល់មាត់នៅក្នុងតុលាការសាធារណៈបែបនេះ អាចនិយាយបានថាជាទិដ្ឋភាពយ៉ាងសំខាន់នៃនីតិវិធីរដ្ឋប្បវេណី ។

## ២. ការជម្រះក្ដី នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់

### (១) សេចក្ដីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដែលបានធ្វើឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយយោងទៅតាមខ្លឹមសាររបស់វា មានលក្ខណៈប្រហាក់ប្រហែលទៅនឹងការហាត់សមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែរ ប៉ុន្តែ វាមិនអាចជំនួសឱ្យការទាញហេតុផលដោយផ្ទាល់មាត់ពិតប្រាកដនោះបានទេ ។ ជាគោលការណ៍ ការជម្រះក្ដីលើបណ្ដឹង ត្រូវធ្វើឡើងដោយការទាញហេតុផលដោយផ្ទាល់មាត់ (ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់ ។ មាត្រា ១១៤ កថាខណ្ឌទី ១) ។ អាស្រ័យហេតុនេះហើយ នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីទាំងសងខាង ឱ្យមកចូលរួមនៅកាលបរិច្ឆេទដែលបានកំណត់នោះ ដើម្បីធ្វើការជម្រះក្ដីដោយការទាញហេតុផលដោយផ្ទាល់មាត់

(មាត្រា ១១៣) ។ ក៏ប៉ុន្តែ ក្នុងករណីដែលពាក្យបណ្តឹង មិនបានបំពេញគ្រប់ល័ក្ខខ័ណ្ឌដំបូងនៃបណ្តឹងទេ (សូមមើលជំពូកទី ៣) ដោយមានភាពផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចចេញសាលក្រមលើកបណ្តឹងនោះចោល ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ៨១ ។ នៅមុនពេលចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងករណីដែលបណ្តឹងមានលក្ខណៈផ្ទុយនឹងច្បាប់យ៉ាងច្បាស់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្តឹងនោះចោល ដោយដីកាសម្រេច ដោយមិនឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន) ។

នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋម ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១១៦ កថាខណ្ឌទី ១) ។ នេះគឺជានីតិវិធីដែលនៅក្នុងនោះ សកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានលើកឡើងវិញម្តងទៀតសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីយកធ្វើជាមូលដ្ឋាននៃសាលក្រម ដោយចាត់ទុកថា សកម្មភាពទាំងនោះ សមមូលទៅនឹងសកម្មភាពដែលធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៅក្នុងតុលាការ ។ បើមិនធ្វើដូច្នេះទេ ទោះបីជាទាំងតុលាការ និង ភាគី បានដឹងជាស្រេចថា សកម្មភាពណាខ្លះដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏ដោយ ក៏សកម្មភាពទាំងនោះមិនអាចនឹងត្រូវបានយកទៅធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ដោយហេតុថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនត្រូវបានធ្វើឡើងជាសាធារណៈ ហើយក៏អាចមានករណីដែលថា ចៅក្រមដែលនឹងចេញសាលក្រមមិនមែនជាចៅក្រម ដែលបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ ។ ចំពោះសកម្មភាពដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់ធ្វើឡើងវិញទេ គឺគ្រាន់តែធ្វើសេចក្តីថ្លែងការណ៍សរុបអំពីសកម្មភាពទាំងនោះទៅបានហើយ ។

ពេលធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ពោលគឺត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីអង្គហេតុដែលជាចំណុចវិវាទ (មាត្រា ១១៦ កថាខណ្ឌទី ២) ។

(២) ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី

បន្ទាប់ពីការធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបន្តនីតិវិធីនៃការជម្រះក្តី ដោយការទាញហេតុផលដោយផ្ទាល់មាត់ ។ ភាគី អាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបាន ប៉ុន្តែ ការដាក់នេះ មិនត្រូវឱ្យផ្ទុយនឹងបញ្ញត្តិនៃមាត្រា ១០៨ ឡើយ (មាត្រា ១១៦ កថាខណ្ឌទី ៣) ។ ហេតុនេះហើយ មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី ដែលអាចដាក់បាន គឺមានតែមធ្យោបាយដូចតទៅនេះតែប៉ុណ្ណោះ : មធ្យោបាយតទល់ ឬ ការពារខ្លួន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវ

ដោយឆន្ទានុសិទ្ធិរបស់ខ្លួន មធ្យោបាយតទល់ ឬ ការពារខ្លួន ដែលមិនធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធី ទោះបីជាមធ្យោបាយនោះត្រូវបានលើកយកទៅពិនិត្យក៏ដោយ និង មធ្យោបាយតទល់ ឬ ការពារខ្លួន ដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ការមិនអាចដាក់មធ្យោបាយនោះនៅមុនការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន មិនមែនបណ្តាលមកពីកំហុសធ្ងន់ធ្ងរឡើយ ។ម្យ៉ាងទៀត ក្នុងករណីដែលភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបាន ភាគីត្រូវដាក់មធ្យោបាយនោះ នៅពេលសមរម្យ ក្នុងពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ។ ប្រសិនបើមធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីនោះ ត្រូវបានដាក់នៅក្រោយពេលសមរម្យ ហើយធ្វើឱ្យមានការយឺតយ៉ាវដល់ការបញ្ចប់នីតិវិធី តុលាការត្រូវលើកចោលមធ្យោបាយនោះ (មាត្រា ៩៣ និង មាត្រា ៩៤) ។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ពុំមានការបែងចែកជាដំណាក់កាលពិសេសអ្វីទេ ហើយក៏ពុំមានការកំណត់អំពីដំណាក់កាលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ទៅតាមប្រភេទនៃមធ្យោបាយទាំងនោះដែរ ។ បើទោះបីជាការទាញហេតុផលដោយផ្ទាល់មាត់ អាចត្រូវបានអូសបន្លាយទៅកាលបរិច្ឆេទជាច្រើនផ្សេងទៀតក៏ដោយ នីតិវិធីនោះ មិនធ្វើការពុះបំបែកជាដំណាក់កាល១ទៅតាមកាលបរិច្ឆេទនីមួយ១ទេ តែវាត្រូវបានចាត់ទុកថាជាការទាញហេតុផលដោយផ្ទាល់មាត់ទាំងមូលតែម្តង ។ នេះគេហៅថា "ភាពតែមួយនៃការទាញហេតុផលដោយផ្ទាល់មាត់" ។

ក្នុងករណីដែលមានការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី តុលាការត្រូវធ្វើការរៀបចំនូវចំណុចវិវាទ និង ភស្តុតាង នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ តែត្រឹមទំហំនៃមធ្យោបាយនោះតែប៉ុណ្ណោះ ។ ហេតុដូច្នេះហើយ នៅពេលចំណុចវិវាទ និង ភស្តុតាងដែលត្រូវពិនិត្យ ត្រូវបានកំណត់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់តែម្តង នោះតុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការពិនិត្យភស្តុតាង និង កោះហៅគូភាគីឱ្យចូលរួមនៅក្នុងការពិនិត្យភស្តុតាង (ភស្តុតាង និង នីតិវិធីនៃការពិនិត្យភស្តុតាង នឹងមានពន្យល់នៅក្នុងផ្នែកទី ៣ នៃជំពូកនេះ) ។

(៣) ការបំបែក និង ការបញ្ចូលរឿងក្តី

ទោះជានៅក្នុងដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ តុលាការអាចបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្តី ដោយដីកាសម្រេចបាន (មាត្រា ៩៩ កថាខណ្ឌទី ១) ។ ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យបញ្ចូលរឿងក្តីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមានឱកាសសាកសួរសាក្សី ដោយសារសាក្សីនោះត្រូវបានសាកសួររួចហើយមុនពេលបញ្ចូលរឿងក្តី បានដាក់ការស្នើសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះជាកំហិត នៅក្រោយពេលបញ្ចូលរឿងក្តី (មាត្រា ៩៩ កថាខណ្ឌទី ២) ។

៣. ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

បន្ទាប់ពីបានបញ្ចប់ការពិនិត្យភស្តុតាងហើយ តុលាការ ដែលអាចនឹងមានជំនឿទុកចិត្តទៅលើទំនាក់ទំនងអង្គហេតុនៃរឿងក្តីតាមរយៈការពិនិត្យភស្តុតាងនេះ ឬ ដោយផ្អែកតាមគោលការណ៍នៃទទួលខុសត្រូវក្នុងការបញ្ជាក់ ដែលនឹងមានពន្យល់នៅពេលក្រោយ ត្រូវមានតួនាទីចេញសាលក្រមទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ ចំពោះការទាមទាររបស់ដើមចោទ ។ នៅពេលនោះ តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ចេញសាលក្រមចុងក្រោយ (មាត្រា ១៨០ កថាខណ្ឌទី ១) ។ នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវប្រកាសអំពីការបញ្ចប់នោះ ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗ ធ្វើការទាញហេតុផលចុងក្រោយបាន នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៦ កថាខណ្ឌទី ៥) ។ ដោយសារថា ការទាញហេតុផលចុងក្រោយ គឺជាឱកាសដែលភាគីនីមួយៗអាចលើកឡើងនូវមតិចុងក្រោយរបស់ខ្លួន ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ដើមចោទ ដោយផ្អែកលើលទ្ធផលនៃការពិនិត្យភស្តុតាង ដូច្នេះ តុលាការ គួរតែផ្តល់ឱកាសឱ្យភាគីនីមួយៗលើកឡើងនូវការទាញហេតុផលចុងក្រោយរបស់ខ្លួន ឱ្យតែអាចធ្វើទៅបាន ។

ទោះបីជាការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ទៅហើយក្តី បើយល់ថាចាំបាច់ តុលាការអាចបើកឱ្យមានការទាញហេតុផលសាជាថ្មី នៅមុនពេលចេញសាលក្រមចុងក្រោយបាន (មាត្រា ១៨០ កថាខណ្ឌទី ៣) ។ លើសពីនេះទៅទៀត នៅក្រោយការពិនិត្យភស្តុតាង ប្រសិនបើតុលាការយល់ថាអង្គហេតុសំខាន់មួយបានកើតឡើង ហើយអង្គហេតុនោះ មិនត្រូវបានបញ្ចេញនៅក្នុងការទាញហេតុផលរបស់ភាគីទេ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅពេលនេះ វាផ្ទុយទៅនឹងក្របខ័ណ្ឌយុត្តិធម៌នោះ ហេតុដូច្នេះ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀតបាន ក្នុងករណីដែលតុលាការយល់ឃើញថាចាំបាច់ដើម្បីធ្វើនីតិវិធីម្តងទៀត ចាប់ពីការរៀបចំចំណុចវិវាទ (មាត្រា ១១៦ កថាខណ្ឌទី ៤) ។

## កថាភាគទី ៤ សំណុំរឿងនៃបណ្តឹង

### ១. អត្ថន័យនៃសំណុំរឿងនៃបណ្តឹង

សំណុំរឿងនៃបណ្តឹង សំដៅទៅលើសំណុំឯកសារសរុបដែលតុលាការបានរៀបចំនៅក្នុងនីតិវិធីនៃបណ្តឹង ដូចជា កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា ១០៩) កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៧) មូលសាលក្រម (មាត្រា ១៨៨ កថាខណ្ឌទី ១ និង មាត្រា ១៨៩) ជាដើម និង ឯកសារដែលភាគី និង ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀត បានដាក់ទៅតុលាការ ដូចជា ពាក្យបណ្តឹង (មាត្រា ៧៥ កថាខណ្ឌទី ១) ជាដើម ដែលត្រូវរក្សាទុកដោយតុលាការដែលទទួលបណ្តឹង ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីខ្លឹមសារនៃសកម្មភាពបណ្តឹងរបស់តុលាការ និង ភាគី និង ដើម្បីសម្រួលដល់ការរក្សាទុកនូវកំណត់ហេតុនោះ ការដាក់ពាក្យបណ្តឹង ការប្រកាសសាលក្រម និង សកម្មភាពសំខាន់ៗផ្សេងៗ

ទៀត ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា ៧៥ កថាខណ្ឌទី ១, មាត្រា ១៨៨ កថាខណ្ឌទី ១ ជាអាទិ៍) ឬ ត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ (មាត្រា ១១១ និង មាត្រា ១១៩ កថាខណ្ឌទី ១) ។ ពេលដែលនីតិវិធីបណ្តឹងមានដំណើរការទៅមុខ ឯកសារទាំងនេះកាន់តែមានចំនួនច្រើនឡើង នៅតុលាការដែលទទួលបណ្តឹងនោះ ហើយឯកសារទាំងនេះនឹងត្រូវបានចងក្រងជាសំណុំរឿងនៃបណ្តឹង ដើម្បីសម្រួលដល់ការប្រើប្រាស់របស់តុលាការ និង ដល់ការមើលរបស់ភាគី ។

២. ឯកសារដែលត្រូវចងក្រងជាសំណុំរឿងនៃបណ្តឹង

ឯកសារសំខាន់ៗ ដែលត្រូវចងក្រងជាសំណុំរឿងនៃបណ្តឹង មានដូចខាងក្រោមនេះ :

① ឯកសារដែលទាក់ទងទៅនឹងពាក្យសុំទាក់ទងនឹងចំណុចដែលត្រូវបានវិនិច្ឆ័យដោយសាលក្រម និង ឯកសារដែលទាក់ទងនឹងការអះអាង : ពាក្យបណ្តឹង ឯកសារចម្លើយ (មាត្រា ១០១ កថាខណ្ឌទី ៣) និង ឯកសារត្រៀម (មាត្រា ១០១ កថាខណ្ឌទី ១)

② កំណត់ហេតុ : កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

③ ឯកសារដែលទាក់ទងនឹងការបញ្ចប់នីតិវិធីនៃបណ្តឹង : មូលសាលក្រម កំណត់ហេតុនៃការសះជា (មាត្រា ២២២) លិខិតសុំដកពាក្យបណ្តឹង (មាត្រា ២១៧ កថាខណ្ឌទី ៣)

④ ឯកសារទាក់ទងទៅនឹងភស្តុតាង : លិខិតស្នើសុំឱ្យពិនិត្យភស្តុតាង (សូមមើលមាត្រា ១២៥) សេចក្តីចម្លងនៃភស្តុតាងជាឯកសារ (មាត្រា ១៤៨)

⑤ ឯកសារផ្សេងទៀត : លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ (មាត្រា ៥៣ កថាខណ្ឌទី ២) របាយការណ៍ស្តីពីការបញ្ជូន (មាត្រា ២៥៤ កថាខណ្ឌទី ២) .

៣. ការរក្សាទុកនូវសំណុំរឿងនៃបណ្តឹង

នៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ សំណុំរឿងនៃបណ្តឹង ត្រូវគ្រប់គ្រង និង រក្សាទុក នៅក្រោមការថែរក្សារបស់ក្រឡាបញ្ជី នៃតុលាការដែលកំពុងចាត់ការបណ្តឹងនោះ ។ ហេតុនេះហើយ នៅពេលធ្វើការផ្ទេររឿងក្តី (មាត្រា ២២ កថាខណ្ឌទី ៤) និង នៅពេលដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (មាត្រា ២៦៥ កថាខណ្ឌទី ១, មាត្រា ២៨៧ និង មាត្រា ៣០១ កថាខណ្ឌទី ១) ត្រូវធ្វើការផ្ញើជូនសំណុំរឿងនៃបណ្តឹងនោះ ។ ក្នុងករណីដែលរឿងក្តីត្រូវបានបញ្ចប់នៅតុលាការជាន់ខ្ពស់ សំណុំរឿងនៃបណ្តឹង នឹងមានចំនួនកាន់តែច្រើនឡើងនៅតុលាការជាន់ខ្ពស់នោះ ដោយសារពុំមានបញ្ញត្តិពិសេសណាមួយចែងអំពីការថែរក្សាសំណុំរឿងទាំងនោះឡើយ ។

ក្រឡាបញ្ជីនៃតុលាការដែលថែរក្សាសំណុំរឿង នឹងផ្តល់រូបមន្តអនុវត្តចាំបាច់ សម្រាប់ការអនុវត្តដោយបង្ខំ (មាត្រា ៣៥៤ កថាខណ្ឌទី ២) ។

## ៤. ការមើលសំណុំរឿងនៃបណ្ដឹង

នៅពេលជាមួយគ្នា មានការទាមទារឱ្យមានតម្លាភាពនៅក្នុងដំណើរការនៃនីតិវិធីផង និង មានការទាមទារឱ្យការពារព័ត៌មានឯកជន និង ការសម្ងាត់ពាណិជ្ជកម្មរបស់ភាគីនៃរឿងក្ដីផង ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា ភាគីនៃបណ្ដឹង និង តតិយជនដែលធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងបណ្ដឹង អាចទាមទារមើលសំណុំរឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ឯកសារចម្លងយថាភូតឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារឱ្យប្រគល់លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងបណ្ដឹងពីតុលាការបាន ដោយបង់ពន្ធ (មាត្រា ២៥៨ កថាខណ្ឌទី ១) ។ "ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់" គឺជាឯកសារនៃការចម្លងនូវរាល់ចំណុចទាំងអស់ដែលមាននៅក្នុងឯកសារដើម ។ "ឯកសារដកស្រង់" គឺជាឯកសារនៃការចម្លងផ្នែកណាមួយនៃឯកសារដើម ។ ដោយឡែក "ឯកសារចម្លងយថាភូត" គឺជាឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ដែលច្បាប់ទទួលស្គាល់ថា មានអានុភាពដូចឯកសារដើមដែរ ដោយជំនួសឯកសារដើម (មាត្រា ១៩០ កថាខណ្ឌទី ១ ជាដើម) ។ "លិខិតបញ្ជាក់អំពីចំណុចដែលពាក់ព័ន្ធនឹងបណ្ដឹង" មានដូចជា លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម លិខិតបញ្ជាក់អំពីការដែលគ្មានបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ លិខិតបញ្ជាក់អំពីភាពកំពុងត្រូវបានចាត់ការនៃរឿងក្ដីជាអាទិ៍ ។

# ផ្នែកទី ៣ ភស្តុតាង

## កថាភាគទី ១ ការបញ្ជាក់ និង ភស្តុតាង

### ១. ឯកសារ វត្ថុតាង ជាអាទិ៍ ដើម្បីបញ្ជាក់ (គោលការណ៍នៃការសម្រេចសេចក្ដីដោយភស្តុតាង)

ដើម្បីឱ្យចៅក្រមទទួលស្គាល់នូវអង្គហេតុ ជាគោលការណ៍ (ករណីលើកលែងនឹងមានពន្យល់នៅក្នុងទី ៣ ខាងក្រោមនេះ) ចាំបាច់ត្រូវធ្វើការបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះ មានន័យថា ចៅក្រមត្រូវមានការជឿជាក់ទៅលើអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះ ។ ឯកសារ និង វត្ថុតាង ជាអាទិ៍ ដែលមានភាពសំខាន់សម្រាប់ការបញ្ជាក់អង្គហេតុនេះ គឺជាភស្តុតាង ហើយការទទួលស្គាល់អង្គហេតុ ត្រូវផ្អែកលើភស្តុតាង (គោលការណ៍សម្រេចសេចក្ដីដោយភស្តុតាង មាត្រា ១២៣ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ក្នុងការទទួលស្គាល់អង្គហេតុ ចៅក្រម មិនត្រឹមតែពិចារណាអំពីភស្តុតាងប៉ុណ្ណោះទេ គឺអាចពិចារណាអំពីស្ថានភាពទាំងមូល ដែលបានលេចឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ (ខ្លឹមសារទាំងមូលនៃការទាញហេតុផល) ផងដែរ (មាត្រា ១២៣ កថាខណ្ឌទី ១) ។ ឧទាហរណ៍អំពីស្ថានភាពទាំងនោះ មានដូចជាបញ្ហាថាតើសេចក្ដីថ្លែងការណ៍ និង ការអះអាងរបស់ភាគី ឬ អ្នកតំណាងរបស់ភាគី មានភាពស៊ីសង្វាក់គ្នាដែរឬទេ និង ថាតើភាគីបានដកពាក្យ ឬ បានកែប្រែការអះអាងរបស់ខ្លួន ម្ដងហើយម្ដងទៀត

ដោយគ្មានមូលហេតុត្រឹមត្រូវ ដែរឬទេ ។ ដោយសារថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ ដូច្នេះ ស្ថានភាពដែលលេចឡើងក្នុងនីតិវិធីត្រៀមនេះក៏អាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃស្ថានភាពដែលបានលេចឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ដែរ ។

## ២. ពាក្យបច្ចេកទេសអំពីភស្តុតាង និង ការបញ្ជាក់

(១) អត្ថន័យនៃពាក្យភស្តុតាងនៅក្នុងចំណុច ១. ខាងលើនេះ គេហៅថា "មូលហេតុនៃភស្តុតាង" ។ ម្យ៉ាងវិញទៀត ក៏អាចមានករណីដែលពាក្យថា ភស្តុតាង ត្រូវបានប្រើប្រាស់ក្នុងន័យថាជា "ឧបករណ៍ភស្តុតាង (វិធីភស្តុតាង)" ផងដែរ ដែលមានន័យថាជាកម្មវត្ថុដែលតុលាការត្រូវធ្វើការពិនិត្យ ។ សាក្សី អ្នកជំនាញខាងកោសលវិច័យ ភាគីនៃបណ្តឹង (ភស្តុតាងជាមនុស្ស) ឯកសារភស្តុតាង និង វត្ថុដែលត្រូវត្រួតពិនិត្យ (ភស្តុតាងជាវត្ថុ) ស្ថិតនៅក្នុងប្រភេទ នៃ "ឧបករណ៍ភស្តុតាង (វិធីភស្តុតាង)" នេះ ។ លើសពីនេះទៅទៀត អ្វីដែលតុលាការបានទទួលដឹងឮ តាមរយៈការពិនិត្យឧបករណ៍ភស្តុតាង ហៅថា "ធនធានភស្តុតាង" ហើយក៏អាចមានករណីដែលពាក្យថា ភស្តុតាង ត្រូវបានប្រើនៅក្នុងន័យនេះផងដែរ ។ សេចក្តីថ្លែងការណ៍របស់សាក្សី ឬ ភាគីនៃបណ្តឹង យោបល់របស់អ្នកជំនាញខាងកោសលវិច័យ ចំណុចដែលមានសរសេរនៅក្នុងឯកសារណាមួយ លទ្ធផលនៃការត្រួតពិនិត្យ ជាដើម គឺជាធនធានភស្តុតាងនេះ ។

(២) ការបញ្ជាក់ សំដៅទៅលើការដែលធ្វើឱ្យតុលាការមានជំនឿទៅលើអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុណាមួយ ។ ដើម្បីនិយាយថាបានបញ្ជាក់ហើយ ចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យជនសាមញ្ញ មានការជឿជាក់ត្រឹមកម្រិតមួយ ដែលអាចផ្អែកដើម្បីសម្រេចអាកប្បកិរិយានៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ទៅលើការបញ្ជាក់នោះ ។ ហើយម្យ៉ាងទៀត ការបញ្ជាក់ត្រឹមកម្រិតនោះ ជាការគ្រប់គ្រាន់ហើយ ។ បើប្រៀបធៀបទៅនឹងកម្រិតនៃការបញ្ជាក់នេះ សេចក្តីបញ្ជាក់ដំបូង (Preliminary Showing, Glaubhaftmachung) មានន័យថាជាការធ្វើឱ្យតុលាការមានការជឿជាក់ថា អង្គហេតុជាក់លាក់ណាមួយ ទំនងជាការពិត ។ សេចក្តីបញ្ជាក់ដំបូង ត្រូវធ្វើឡើង ក្នុងករណីដែលត្រូវដឹកនាំនីតិវិធីឱ្យបានលឿន ហើយត្រូវមានពាក្យសុំរបស់ភាគីណាម្ខាង ដើម្បីបញ្ជាក់ថាមានមូលហេតុក្នុងការធ្វើបែបនោះ (មាត្រា ៣០ កថាខណ្ឌទី ៣, មាត្រា ១៦៥ កថាខណ្ឌទី ៣, មាត្រា ៥៤១ កថាខណ្ឌទី ៣ ជាអាទិ៍) ។

## ៣. ប្រភេទនៃភស្តុតាង

### (១) ភស្តុតាងផ្ទាល់ និង ភស្តុតាងប្រយោល

ភស្តុតាងផ្ទាល់ គឺជាភស្តុតាងដែលបញ្ជាក់ដោយផ្ទាល់ អំពីអត្ថិភាព ឬ នត្ថិភាព នៃអង្គហេតុផ្ទាល់ (អង្គហេតុចម្បង) ដែលឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌផ្ទាល់នៃអានុភាពគតិយុត្ត គឺការបង្កើត ការផ្លាស់ប្តូរ ឬ ការរំលត់សិទ្ធិ និង កាតព្វកិច្ច ។ ឧទាហរណ៍ នៅក្នុងករណីនៃបណ្តឹងដែល A ប្តឹងទាមទារឱ្យ B សងប្រាក់កំចីចំនួន ១០

លានរៀល ដែលខ្លួនបានឱ្យ B ខ្ចី លិខិតនៃកិច្ចសន្យាខ្ចីបរិភោគ និង សាក្សីដែលបានមានវត្តមាននៅកន្លែងធ្វើកិច្ចសន្យា គឺជាភស្តុតាងផ្ទាល់ដែលបញ្ជាក់អំពីអង្គហេតុនៃការបង្កើតកិច្ចសន្យាខ្ចីបរិភោគ ។

ភស្តុតាងប្រយោល គឺជាភស្តុតាងដែលបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាព នៃអង្គហេតុប្រយោល និង អង្គហេតុបន្ទាប់បន្សំ ដែលមានប្រយោជន៍ក្នុងការបញ្ជាក់អំពីអង្គហេតុផ្ទាល់ ។ ក្នុងករណីដែលពុំមានភស្តុតាងផ្ទាល់ទេ ចាំបាច់ត្រូវបញ្ជាក់អំពីអង្គហេតុប្រយោល ដោយផ្អែកលើភស្តុតាងប្រយោល ហើយត្រូវបញ្ជាក់អំពីអង្គហេតុផ្ទាល់ ដោយធ្វើការសន្និដ្ឋានអំពីអង្គហេតុផ្ទាល់ តាមរយៈការអនុវត្តរូបមន្តនៃបទពិសោធន៍ (វិធានតាមបទពិសោធន៍) ។ អង្គហេតុបន្ទាប់បន្សំ គឺជាអង្គហេតុស្ដីពីលក្ខណសម្បត្តិតាមផ្លូវច្បាប់ដែលអាចយកទៅប្រើជាភស្តុតាងបាន (អំណាច ឬ សមត្ថភាពជាភស្តុតាង) ឬ អង្គហេតុស្ដីពីអានុភាពដែលជួយឱ្យចៅក្រមមានការជឿជាក់ទៅលើអ្វីមួយ (តម្លៃជាភស្តុតាង) ។ ឧទាហរណ៍ អង្គហេតុបន្ទាប់បន្សំ មានដូចជាអង្គហេតុស្ដីពីភាពគួរឱ្យជឿបាននៃសេចក្ដីថ្លែងការណ៍របស់សាក្សី ឬ អង្គហេតុស្ដីពីបញ្ហាថាតើឯកសារណាមួយត្រូវបានបង្កើតឡើង ដោយត្រឹមត្រូវ ដែរឬទេ (សូមមើលមាត្រា ១៩៥) ។

(២) ភស្តុតាងជាមនុស្ស និង ភស្តុតាងជាវត្ថុ

ភស្តុតាងជាមនុស្ស សំដៅទៅលើមនុស្ស ក្នុងករណីដែលសាកសួរមនុស្សនោះ ដើម្បីយកសេចក្ដីថ្លែងការណ៍របស់មនុស្សនោះ មកធ្វើជាភស្តុតាង ។ ភស្តុតាងជាមនុស្ស មានដូចជាសាក្សី អ្នកជំនាញខាងកោសលវិច័យ ឬ សាមីភាគី (រួមទាំងអ្នកតំណាងដែលច្បាប់បានកំណត់ផងដែរ ។ សូមមើលមាត្រា ១៤២) ។ ឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលមានកម្មវត្ថុក្រៅពីមនុស្ស គេហៅថា ភស្តុតាងជាវត្ថុ ដែលមានដូចជាឯកសារ និង វត្ថុដែលត្រូវធ្វើការត្រួតពិនិត្យ ។ ទោះបីជាក្នុងករណីដែលកម្មវត្ថុនៃភស្តុតាង គឺជាមនុស្សក៏ដោយ ក្នុងករណីដែលសង្កេតពីអត្តចរិត តាមរយៈទឹកមុខរបស់បុគ្គលនោះ និង ការពិនិត្យស្នាមម្រាមដៃរបស់បុគ្គលនោះ ភស្តុតាងនោះ គឺជាភស្តុតាងជាវត្ថុដែរ ។

(៣) ភស្តុតាងស្រប និង ភស្តុតាងផ្ទុយ

ភស្តុតាងស្រប គឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវដាក់ដោយភាគី (ឧទាហរណ៍ A) ដើម្បីបញ្ជាក់អំពីអង្គហេតុផ្ទាល់ដែលខ្លួនមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ផ្ទាល់ខ្លួន ។ ចំណែកឯភស្តុតាងផ្ទុយ គឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវដាក់ដោយភាគីម្ខាងទៀត (ឧទាហរណ៍ B) ដែលធ្វើការតវ៉ាចំពោះអង្គហេតុដែលត្រូវបានអះអាងនោះ (មានន័យថា ធ្វើសេចក្ដីថ្លែងការណ៍ថា បដិសេធនូវអង្គហេតុ ឬ មិនបានដឹងអំពីអង្គហេតុនោះ (មាត្រា ៩៦ កថាខណ្ឌទី ២)) (ចំពោះការទទួលខុសត្រូវក្នុងការបញ្ជាក់ សូមមើលទី ៥ ខាងក្រោមនេះ) ។

គោលបំណងនៃភស្តុតាងស្រប គឺធ្វើឱ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់ ។ ផ្ទុយទៅវិញ ភស្តុតាងផ្ទុយ មានគោលបំណងរារាំងចៅក្រមមិនឱ្យមានការជឿជាក់ ដោយផ្អែកលើភស្តុតាងស្រប ឬ

ផ្លាស់ប្តូរការជឿជាក់ដែលចៅក្រមមានរួចហើយ ។ ភស្តុតាងស្រប អាចសម្រេចគោលបំណងរបស់វា តែក្នុងករណីដែលបានធ្វើឱ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់ណាមួយ តែប៉ុណ្ណោះ ។ ដោយឡែក ភស្តុតាងផ្ទុយ អាចសម្រេចគោលបំណងរបស់វា ដោយគ្រាន់តែធ្វើឱ្យការជឿជាក់របស់ចៅក្រមទៅលើអត្ថិភាពនៃអង្គហេតុនៅពេលនោះ មានភាពមិនច្បាស់លាស់ តែប៉ុណ្ណោះ ពោលគឺមិនចាំបាច់ធ្វើឱ្យចៅក្រមមានការជឿជាក់ ទៅលើនត្ថិភាពនៃអង្គហេតុទេ ។

## កថាភាគទី ២ កម្មវត្ថុនៃការបញ្ជាក់

នៅក្នុងនីតិវិធីនៃបណ្តឹង កម្មវត្ថុនៃការបញ្ជាក់ ច្រើនតែជាអង្គហេតុ ។ ក៏ប៉ុន្តែ នៅក្នុងករណីខ្លះ វិធានតាមបទពិសោធន៍ និង បញ្ញត្តិនៃច្បាប់ ក៏អាចជាកម្មវត្ថុនៃការបញ្ជាក់ដែរ ។

### ១. អង្គហេតុ

អង្គហេតុដែលជាកម្មវត្ថុនៃការបញ្ជាក់ មិនមែនមានត្រឹមតែអង្គហេតុផ្ទាល់ប៉ុណ្ណោះទេ គឺរួមបញ្ចូលទាំងអង្គហេតុប្រយោល និង អង្គហេតុបន្ទាប់បន្សំផងដែរ ។ ក៏ប៉ុន្តែ អង្គហេតុដែលភាគីបានសារភាពនៅតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង មិនចាំបាច់ធ្វើការបញ្ជាក់ទេ ( មាត្រា ១២៣ កថាខណ្ឌទី ២) ។

### ២. វិធានតាមបទពិសោធន៍

វិធានតាមបទពិសោធន៍ គឺជាចំណេះដឹង ឬ វិធាន ដែលទាក់ទងទៅនឹងទំនាក់ទំនងហេតុផល ឬ ចរិតលក្ខណៈ នៃហេតុការណ៍ ឬ វត្ថុផ្សេងៗ ដែលបានមកពីបទពិសោធន៍នីមួយៗ ។ វិធានតាមបទពិសោធន៍នៅក្នុងបណ្តឹង ត្រូវបានយកទៅប្រើជាទីសំអាងសំខាន់ នៅក្នុងការធ្វើសេចក្តីសន្និដ្ឋាន ដោយផ្អែកលើអង្គហេតុប្រយោល នូវអង្គហេតុប្រយោលផ្សេងទៀត ឬ អង្គហេតុចម្បង តាមរយៈតក្កសាស្ត្រ ។ ឧទាហរណ៍មួយលើបញ្ហានេះ គឺក្នុងករណីដែលវិធានតាមបទពិសោធន៍ទូទៅចំពោះចម្ងាយនៃស្នាមកង់រថយន្តដែលបានបន្សល់ទុកដោយការចាប់ហ្វ្រាំងនៅពេលបើកបរក្នុងល្បឿនជាក់លាក់ណាមួយ ត្រូវបានយកទៅប្រើប្រាស់ដើម្បីធ្វើការសន្និដ្ឋានអំពីល្បឿនរត់នៃរថយន្ត ដោយផ្អែកលើចម្ងាយជាក់ស្តែងនៃស្នាមកង់រថយន្តដែលបន្សល់ទុកនៅលើផ្ទៃនៃថ្នល់កៅស៊ូនៅពេលចាប់ហ្វ្រាំង ។

ចំពោះវិធានតាមបទពិសោធន៍ដែលប្រជាជនសាមញ្ញស្គាល់គ្រប់គ្នាថាជាសុភនិច្ឆ័យ ចៅក្រមអាចប្រើប្រាស់វិធានទាំងនោះ ដើម្បីទទួលស្គាល់អង្គហេតុណាមួយ ដោយមិនផ្អែកលើភស្តុតាងបាន ។ ផ្ទុយទៅវិញ ចំពោះវិធានតាមបទពិសោធន៍ដែលមានតែអ្នកជំនាញប៉ុណ្ណោះដែលដឹងនោះ តាមធម្មតា ត្រូវទទួលស្គាល់វិធាននោះដោយផ្អែកលើភស្តុតាងសិន ទើបអាចយកវិធានទាំងនោះទៅប្រើប្រាស់ដើម្បីទទួលស្គាល់អង្គហេតុបាន ។ វិធានតាមបទពិសោធន៍អំពីល្បឿនរបស់រថយន្ត លក្ខណៈនៃផ្ទៃថ្នល់កៅស៊ូ និង ចម្ងាយនៃស្នាមកង់រថយន្តដែល

បណ្តាលមកពីការចាប់ហ្វ្រាំងបន្ទាន់ ដូចបានលើកឡើងខាងលើ ក៏ជាឧទាហរណ៍នៃវិធានតាមបទពិសោធន៍ជំនាញដែរ ។ នៅក្នុងករណីជាច្រើន ដើម្បីបញ្ជាក់អំពីវិធាននៃបទពិសោធន៍ គេប្រើប្រាស់ប្រភេទនៃការពិនិត្យភស្តុតាង ដែលគេហៅថា កោសលវិច័យ ។

៣. បញ្ញត្តិច្បាប់

ដោយសារថា ចៅក្រមគឺជាអ្នកមានអាជីពវិជ្ជាជីវៈខាងច្បាប់ ចៅក្រមអាចអនុវត្តបញ្ញត្តិច្បាប់ និង ចេញសេចក្តីសម្រេចអំពីបញ្ញត្តិច្បាប់ ដោយផ្អែកលើចំណេះដឹងផ្ទាល់ខ្លួន ហើយជាទូទៅ ចៅក្រមត្រូវធ្វើបែបនេះ ។ ក៏ប៉ុន្តែ ចំពោះច្បាប់បរទេស លិខិតបទដ្ឋានរបស់រដ្ឋអំណាចមូលដ្ឋាន (ដីការបស់ខេត្ត ជាដើម) និង ច្បាប់ទំនៀមទំលាប់ ជាអាទិ៍ មិនមែនចៅក្រមអាចដឹងច្បាស់ទាំងអស់នោះទេ ហេតុនេះហើយ ចាំបាច់ត្រូវប្រើភស្តុតាងដើម្បីទទួលស្គាល់ច្បាប់ទាំងនោះ ។

## កថាភាគទី ៣ អង្គហេតុដែលមិនចាំបាច់ធ្វើការបញ្ជាក់

ទោះបីជាអង្គហេតុ គឺជាកម្មវត្ថុនៃការបញ្ជាក់ក៏ដោយ តែមិនមែនរាល់អង្គហេតុទាំងអស់ដែលបានអះអាងដោយភាគី សុទ្ធតែត្រូវបញ្ជាក់នោះទេ ។ អង្គហេតុដែលពុំមានវិវាទរវាងភាគី (អង្គហេតុដែលបានសារភាព និង អង្គហេតុដែលត្រូវបានចាត់ទុកថាបានសារភាព) និង អង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង តុលាការមិនចាំបាច់ធ្វើការបញ្ជាក់អង្គហេតុទាំងនេះដោយភស្តុតាងទេ ហើយត្រូវយកអង្គហេតុទាំងនេះ ទៅធ្វើជាមូលដ្ឋាននៃការចេញសាលក្រម (មាត្រា ១២៣ កថាខណ្ឌទី ២) ។

១. ការសារភាពតាមផ្លូវតុលាការ

(១) អត្ថន័យនៃការសារភាពតាមផ្លូវតុលាការ

ការសារភាពតាមផ្លូវតុលាការ សំដៅទៅលើសេចក្តីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់ថា អង្គហេតុណាមួយដែលធ្វើឱ្យខូចប្រយោជន៍របស់ខ្លួន ហើយដែលបានអះអាងដោយភាគីម្ខាងទៀត គឺជាការពិត នៅចំពោះមុខតុលាការ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ ដើម្បីអាចទទួលស្គាល់ថាជាការសារភាព សេចក្តីថ្លែងការណ៍របស់ភាគីទាំងសងខាងត្រូវមានលក្ខណៈស៊ីសង្វាក់គ្នា ក៏ប៉ុន្តែ គេមិនចាំបាច់គិតអំពីលំដាប់មុនក្រោយនៃសេចក្តីថ្លែងការណ៍ទាំងនោះទេ ។ ទោះបីជាក្នុងករណីដែល ភាគីម្ខាងបានធ្វើសេចក្តីថ្លែងការណ៍មួយដែលធ្វើឱ្យខូចប្រយោជន៍របស់ខ្លួន ហើយក្រោយមកទើបភាគីម្ខាង ទៀត បានលើកអង្គហេតុនោះឡើងក៏ដោយ ក៏អាចទទួលស្គាល់ថាជាការសារភាពដែរ (នេះហៅថា ការ សារភាពជាមុន) ។

កម្មវត្ថុនៃការសារភាព គឺអង្គហេតុ ។ ដោយសារថា ការបកស្រាយ និង ការអនុវត្តច្បាប់ គឺជាមុខងាររបស់ចៅក្រម ហេតុនេះហើយ ទោះបីជាក្នុងករណីដែលការអះអាងរបស់ភាគីសងខាងអំពីអត្ថិភាពនៃច្បាប់ ឬ ការ

បកស្រាយច្បាប់នោះ មានភាពស៊ីសង្វាក់គ្នាក៏ដោយ ក៏មិនអាចទទួលស្គាល់ថាជាការសារភាពឡើយ ។ បញ្ហាគឺ សេចក្តីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់ថា ការអះអាងរបស់ភាគីម្ខាងទៀតអំពីអត្ថិភាព ឬ នត្ថិភាពនៃ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត គឺជាការពិត ។ សេចក្តីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់អត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលភាគីម្ខាងទៀតបានលើកជាការទាមទារនៅក្នុងបណ្តឹង (សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹង) ថាជាការពិត គឺជាមូលហេតុនៃការបញ្ចប់នីតិវិធីនៃបណ្តឹង ដោយសារថា វាគឺជា ការទទួលស្គាល់ការទាមទារ (មាត្រា ២២១) ។ ម៉្យាងទៀត សេចក្តីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់ អត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាបុរេល័ក្ខខ័ណ្ឌនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុ នៃបណ្តឹង (ហៅថា ទំនាក់ទំនងគតិយុត្តដែលត្រូវបានសម្រេចជាមុន) ដែលភាគីម្ខាងទៀតបានលើកឡើង គេ ហៅថា "ការសារភាពអំពីសិទ្ធិ" ។ ឧទាហរណ៍ នៅក្នុងបណ្តឹងទាមទារឱ្យប្រគល់វត្ថុវិញដោយផ្អែកលើកម្មសិទ្ធិ (សូមមើលមាត្រា ១៩៥ នៃក្រមរដ្ឋប្បវេណី) ដើមចោទត្រូវអះអាងថាខ្លួនគឺជាកម្មសិទ្ធិករលើវត្ថុដែលជា កម្មវត្ថុនៃការទាមទារនោះ ។ ក្នុងករណីបែបនេះ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនទទួលស្គាល់ ថាដើមចោទពិតជាកម្មសិទ្ធិករនៃវត្ថុនោះមែន សេចក្តីថ្លែងការណ៍នេះ គឺជាការសារភាពអំពីសិទ្ធិ (ក្នុងករណីនេះ ចុងចម្លើយត្រូវអះអាងថា ខ្លួនមានមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់វត្ថុនោះ ដូចជាសិទ្ធិជួលវត្ថុនោះ ជាដើម) ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានការបកស្រាយជាច្រើន អំពីអានុភាពនៃការសារភាពអំពីសិទ្ធិ ។ ប៉ុន្តែ យ៉ាង ណាក៏ដោយ នៅក្នុងករណីដែលបានយល់ឃើញថា ភាគីណាម្ខាងបានទទួលស្គាល់ការអះអាងរបស់ភាគីម្ខាង ទៀត ថាជាការពិត ដោយផ្អែកលើការពិចារណាយ៉ាងហ្មត់ចត់អំពីខ្លឹមសាររបស់វានោះ គួរតែទទួលស្គាល់ថា ការសារភាពសិទ្ធិនេះ មានអានុភាពដូចជាការសារភាពអំពីអង្គហេតុដែរ ។ នៅក្នុងការបកស្រាយមួយផ្សេង ទៀត គេអាចទទួលស្គាល់អានុភាពនៃការសារភាពតាមផ្លូវតុលាការ ត្រឹមកម្រិតដែលទទួលស្គាល់ថា ភាគីបាន ទទួលស្គាល់ការអះអាងអំពីអង្គហេតុនេះ ថាជាការពិត ដោយចាត់ទុកថាការអះអាងអំពីទំនាក់ទំនងគតិយុត្ត ដែលត្រូវបានសម្រេចជាមុន រួមមានការអះអាងអំពីអង្គហេតុ ។

មានសំណួរមួយចោទឡើងថា អានុភាពនៃការសារភាពដែលបានកំណត់នៅក្នុងមាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានកម្រិតត្រឹមតែចំពោះការសារភាពអំពីអង្គហេតុផ្ទាល់ ឬ ព្រមទាំងចំពោះ ការសារភាពអំពីអង្គហេតុប្រយោល និង អំពីអង្គហេតុបន្ទាប់បន្សំ ឬយ៉ាងណា ។ ប៉ុន្តែ តាមគោលការណ៍ នៃការទាញហេតុផល (ផ្នែកទី ១ កថាភាគទី ៣) តុលាការមិនអាចយកអង្គហេតុដែលភាគីមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ហើយអង្គហេតុនេះ គឺ សំដៅទៅលើអង្គហេតុផ្ទាល់តែប៉ុណ្ណោះ ។ ហេតុនេះហើយ នៅទីនេះ គួរបកស្រាយថា អានុភាពដែលបានកំណត់នៅក្នុងមាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានចំពោះអង្គហេតុផ្ទាល់តែប៉ុណ្ណោះ ។

(២) អានុភាពនៃការសារភាពតាមផ្លូវតុលាការ

គេអាចពិចារណាអំពីអានុភាពនៃការសារភាពតាមផ្លូវតុលាការ ដោយធ្វើការបែងចែកជា អានុភាពចំពោះតុលាការ និង អានុភាពចំពោះភាគី ។

ជាបឋម ចំពោះតុលាការ នៅពេលដែលមានការសារភាពតាមផ្លូវតុលាការ អង្គហេតុដែលបានសារភាពនោះត្រូវដកចេញពីវង្វង់នៃកម្មវត្ថុនៃការបញ្ជាក់ ហើយតុលាការមិនអាចធ្វើការទទួលស្គាល់ផ្សេងពីនេះបាន ទេ ។ ក្នុងន័យនេះ ការសារភាពតាមផ្លូវតុលាការ មានអានុភាពដកសិទ្ធិធ្វើការសម្រេចរបស់តុលាការ និង មានអានុភាពចងតុលាការ (មាត្រា ១២៣ កថាខណ្ឌទី ២) ។ ផ្ទុយទៅវិញ ការសារភាពក្រៅផ្លូវតុលាការមានអត្ថន័យត្រឹមតែជាអង្គហេតុប្រយោល ដែលធ្វើឱ្យតុលាការអាចសន្និដ្ឋានអំពីអត្ថិភាពនៃអង្គហេតុដែលបានសារភាពប៉ុណ្ណោះ ។ អានុភាពនេះ គឺជាអានុភាពដ៏សំខាន់នៃការសារភាពតាមផ្លូវតុលាការ ហើយគឺជាផ្នែកមួយនៃខ្លឹមសាររបស់គោលការណ៍នៃការទាញហេតុផល ។

បន្ទាប់មក ចំពោះភាគីវិញ ការសារភាពតាមផ្លូវតុលាការ មានអានុភាពចងភាគីដែលបានសារភាព និង អានុភាពដែលមិនអនុញ្ញាតឱ្យភាគីអាចដកការសារភាព ឬ ធ្វើសេចក្តីថ្លែងការណ៍ផ្សេងដែលផ្ទុយពីការសារភាពនោះឡើយ ។ ប្រសិនបើអនុញ្ញាតឱ្យភាគីអាចដកការសារភាពវិញបានដោយសេរី បើទោះបីជាភាគីបានធ្វើការសារភាពដោយផ្អែកលើការទទួលខុសត្រូវផ្ទាល់ខ្លួនក៏ដោយនោះ អង្គហេតុដែលបានសារភាពហើយ នឹងត្រូវបញ្ជាក់ជាថ្មី ដែលការណ៍នេះនឹងធ្វើឱ្យការជម្រះក្តីមានភាពច្របូកច្របល់ និង យឺតយ៉ាវ ហើយនឹងធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត (ផលប្រយោជន៍ក្នុងការមិនចាំបាច់បញ្ជាក់អំពីអង្គហេតុនោះ) ។ ហេតុនេះហើយ ផ្អែកតាមគោលការណ៍នៃការហាមការក្រឡាស់សំដី (ការហាមការធ្វើសេចក្តីថ្លែងការណ៍ផ្ទុយនឹងសេចក្តីថ្លែងការណ៍មុន) តាមធម្មតា ការសារភាពតាមផ្លូវតុលាការ មិនអាចដកវិញបានទេ ។ ករណីលើកលែងដែលអាចដកការសារភាពវិញបាន គឺមានតែករណីដូចតទៅនេះ តែប៉ុណ្ណោះ : (១) ភាគីម្ខាងទៀតពុំតវ៉ា (២) ការសារភាពផ្ទុយនឹងការពិត ដោយការភ័ន្តច្រឡំ និង (៣) ការសារភាពនេះបណ្តាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ (មាត្រា ១២៣ កថាខណ្ឌទី ៣) ។

២. ការចាត់ទុកថាបានសារភាព

ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ (មាត្រា ៩៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ នេះគេហៅថាការចាត់ទុកថាបានសារភាព ។ ក៏ប៉ុន្តែ បញ្ញត្តិបែបនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុនោះ (មាត្រា ៩៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

ដូចជាការសារភាពដែរ ការចាត់ទុកថាបានសារភាព មានអានុភាពចងតុលាការ (មាត្រា ១២៣ កថាខណ្ឌ

ទី ២) តែពុំមានអានុភាពចងភាគីដែលត្រូវបានចាត់ទុកថាបានសារភាពទេ ។ ភាគីអាចតវ៉ាចំពោះអង្គហេតុដែលត្រូវបានចាត់ទុកថាបានសារភាព នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅពេលក្រោយមក ឬ នៅក្នុងការទាញហេតុផលដោយផ្ទាល់ នៅពេលក្រោយមក ។ ប៉ុន្តែ ភាគីមិនអាចតវ៉ាចំពោះអង្គហេតុដែលត្រូវបានចាត់ទុកថាបានសារភាពនោះបានទេ ប្រសិនបើយល់ឃើញថា ការតវ៉ាបែបនោះត្រូវបានធ្វើឡើងនៅក្រោយពេលសមរម្យ ( មាត្រា ៩៤) ។

ក្នុងករណីដែលចុងចម្លើយអវត្តមាននៅពេលទាញហេតុផលដោយផ្ទាល់មាត់ ជាគោលការណ៍ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពថា ការអះអាងអំពីអង្គហេតុរបស់ភាគីម្ខាងទៀត គឺជាការពិត ( មាត្រា ២០១ ។ សូមមើលការពន្យល់អំពីសាលក្រមកំបាំងមុខ) ។

៣. អង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង

អង្គហេតុបែបនេះ ត្រូវបានបែងចែកជា អង្គហេតុដែលគេដឹងឮគ្រប់គ្នាជាសាធារណៈ និង អង្គហេតុដែលតុលាការអាចដឹងបាននៅក្នុងការបំពេញតួនាទីវិជ្ជាជីវៈរបស់ខ្លួន ។ មូលហេតុដែលអាចទទួលស្គាល់អង្គហេតុទាំងនេះដោយមិនចាំបាច់ផ្អែកលើភស្តុតាង គឺថា អង្គហេតុទាំងនេះ គឺជាអង្គហេតុដែលចៅក្រមណាម្នាក់ក៏អាចដឹងបាន ហើយដោយហេតុនេះ ជាសត្យានុម័ត ការទទួលស្គាល់ដោយសមរម្យនូវអង្គហេតុ ត្រូវបានធានាដោយមិនចាំបាច់ពឹងផ្អែកលើភស្តុតាងទេ ។

(១) អង្គហេតុដែលគេដឹងឮគ្រប់គ្នា

អង្គហេតុដែលគេដឹងឮគ្រប់គ្នា គឺជាអង្គហេតុដែលសាធារណៈជនទូទៅបានដឹងឮ ដូចជា ឧប្បត្តិហេតុល្បីនៅក្នុងប្រវត្តិសាស្ត្រ គ្រោះមហន្តរាយធម្មជាតិ ឬ ឧប្បត្តិហេតុធំៗដទៃទៀត ។ ប៉ុន្តែ ទោះបីជាអង្គហេតុដែលគេដឹងឮគ្រប់គ្នាក៏ដោយ ក៏វាអាចនឹងផ្ទុយពីការពិតបានដែរ ហើយហេតុនេះ អាចអនុញ្ញាតឱ្យផ្តល់ភស្តុតាងផ្ទុយចំពោះអង្គហេតុនោះបាន ។

(២) អង្គហេតុដែលតុលាការអាចដឹងបាន នៅក្នុងការបំពេញតួនាទីវិជ្ជាជីវៈរបស់ខ្លួន

អង្គហេតុទាំងនេះ គឺជាអង្គហេតុដែលចៅក្រមទទួលបន្ទុកធ្វើការជម្រះក្តី អាចដឹងបាន នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដូចជា កាលបរិច្ឆេទនៃការបញ្ជូនពាក្យបណ្តឹង ការបង្គាប់ឱ្យបង្ហាញឯកសារ... 

អង្គហេតុទាំងនេះ គឺជាអង្គហេតុដែលចៅក្រមទទួលបន្ទុកធ្វើការជម្រះក្តី អាចដឹងបាន នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដូចជា កាលបរិច្ឆេទនៃការបញ្ជូនពាក្យបណ្តឹង ការបង្ហាញឆន្ទៈតាមច្បាប់សារធាតុនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ការសម្រេចសេចក្តីដោយចៅក្រមនេះនៅក្នុងរឿងក្តីផ្សេង និង ការប្រកាសអំពីធនក្ស័យដែលធ្វើឡើងក្រោមរូបភាពជាការប្រកាសជាសាធារណៈនៅតុលាការ ជាអាទិ៍ ។ អង្គហេតុដែលចៅក្រមបានដឹង នៅក្រៅវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួន ( អង្គហេតុដែលចៅក្រមដឹងដោយខ្លួនឯង) មិនរាប់បញ្ចូលទៅក្នុងប្រភេទនៃអង្គហេតុនេះទេ ។

## កថាភាគទី ៤ គោលការណ៍នៃជំនឿឧកចិត្តដោយសេរី

## ១. អត្ថន័យនៃគោលការណ៍នៃជំនឿទុកចិត្តដោយសេរី

គោលការណ៍នៃជំនឿទុកចិត្តដោយសេរី គឺជាគោលការណ៍ដែលតាមរយៈនោះ ក្នុងការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលជាមូលដ្ឋាននៃសាលក្រម ចៅក្រមត្រូវបានអនុញ្ញាតឱ្យធ្វើការវាយតម្លៃ និង សម្រេចដោយសេរី ទៅលើលទ្ធផលនៃការពិនិត្យភស្តុតាង និង ទៅលើបញ្ហាព្រមទាំងកាលៈទេសៈទាំងអស់ដែលបានលេចឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ ហើយអនុញ្ញាតឱ្យចៅក្រមធ្វើការសម្រេចអំពីភាពពិត ឬ ភាពមិនពិតនៃការអះអាងអំពីអង្គហេតុ ដោយផ្អែកលើជំនឿទុកចិត្តដោយសេរីរបស់ចៅក្រម (មាត្រា ១៨៤) ។ ដោយឡែក គោលការណ៍នៃការកំណត់ភស្តុតាងដោយច្បាប់ គឺជាគោលការណ៍ដែលចៅក្រម ត្រូវបានចងដោយច្បាប់ តាមលក្ខណៈដែលថា អង្គហេតុត្រូវបានទទួលស្គាល់ដោយការកំណត់ជាមុន នូវតម្លៃនៃសម្ភារៈជាភស្តុតាងតាមផ្លូវច្បាប់ ដូចជាថា ត្រូវមានភស្តុតាងណាកំណត់ជាក់លាក់ ដើម្បីទទួលស្គាល់អង្គហេតុណាមួយ (ឧទាហរណ៍ មានបញ្ញត្តិដែលចែងថា ត្រូវមានចម្លើយស្របគ្នាពីកសិណសាក្សីច្រើននាក់) ហើយអង្គហេតុជាក់លាក់ណាមួយ ត្រូវទទួលស្គាល់ ក្នុងករណីដែលមានភស្តុតាងកំណត់ជាក់លាក់ ។ ក្នុងសង្គមបច្ចុប្បន្ន ដែលមានសភាពកាន់តែស្មុគ្រស្មាញ និង មិនទៀតទាត់ គេមិនអាចបំភ្លឺការពិតនៃរឿងក្តី ដោយផ្អែកតែលើវិធាននៃភស្តុតាងដែលមានតែបន្តិចបន្តួច និង ងាយស្រួលតែប៉ុណ្ណោះទេ ។ ហេតុនេះហើយ ជំនួសឱ្យគោលការណ៍នៃការកំណត់ភស្តុតាងដោយច្បាប់ ច្បាប់សម័យទំនើប ជាគោលការណ៍ បានប្រកាន់យកគោលការណ៍នៃជំនឿទុកចិត្តដោយសេរី គឺទុកឱ្យចៅក្រមធ្វើការវាយតម្លៃទៅលើភស្តុតាង ដោយផ្អែកលើជំនឿទុកចិត្តដោយសេរីរបស់ខ្លួន ដោយច្បាប់នេះ ផ្តល់ការទុកចិត្តទៅលើមនសិការ និង បទពិសោធន៍របស់ចៅក្រម ។ មានបញ្ញត្តិចែងថា ការអនុលោមទៅតាមបញ្ញត្តិស្តីពីទម្រង់នៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ អាចបញ្ជាក់បាន តែតាមរយៈកំណត់ហេតុ តែប៉ុណ្ណោះ (មាត្រា ១១២ កថាខណ្ឌទី ២ និង មាត្រា ១១៧ កថាខណ្ឌទី ២) ។ នេះគឺជាការដាក់កម្រិតទៅលើគោលការណ៍នៃជំនឿទុកចិត្តដោយសេរីរបស់ចៅក្រម ។

## ២. ការវាយតម្លៃដោយសេរី

តាមគោលការណ៍នៃជំនឿទុកចិត្តដោយសេរីរបស់ចៅក្រម ការកំណត់ថាតើធនធានភស្តុតាង (លទ្ធផលនៃការពិនិត្យភស្តុតាង) ដែលបានមកពីការពិនិត្យភស្តុតាង មាន ឬ គ្មានប្រយោជន៍ចំពោះការទទួលស្គាល់អង្គហេតុណាមួយ (សមត្ថភាព ឬ អំណាចភស្តុតាង/តម្លៃជាភស្តុតាង) ក៏ដូចជាការកំណត់អំពីទំហំនៃប្រយោជន៍របស់ធនធានភស្តុតាង (លទ្ធផលនៃការពិនិត្យភស្តុតាង) ទាំងនោះ ត្រូវបានទុកឱ្យស្ថិតនៅក្រោមការវាយតម្លៃដោយសេរី របស់ចៅក្រម ។ ចំពោះការកំណត់ថាតើបញ្ហា និង កាលៈទេសៈដែលបានលេចឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ ណាខ្លះ ដែលត្រូវយកទៅពិចារណា និង ថាតើត្រូវវាយតម្លៃយ៉ាងណាចំពោះទំនាក់ទំនងនៃបញ្ហា និង កាលៈទេសៈទាំងនោះ ជាមួយនឹងធនធានភស្តុតាង (លទ្ធផលនៃការពិនិត្យ

ភស្តុតាង) នោះ ក៏ត្រូវស្ថិតនៅក្រោមការវាយតម្លៃដោយសេរី របស់ចៅក្រមដែរ ។

ជាទូទៅ ភាគីនីមួយៗ ស្នើសុំឱ្យពិនិត្យភស្តុតាង ដើម្បីអះអាងអំពីអង្គហេតុដែលមានប្រយោជន៍ដល់ខ្លួន និង បញ្ជាក់អំពីអង្គហេតុនោះ ។ នៅពេលស្នើសុំឱ្យពិនិត្យភស្តុតាង ភាគីដែលស្នើសុំ ត្រូវបំភ្លឺអំពីទំនាក់ទំនងនៃភស្តុតាងនោះ ទៅនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយភស្តុតាងនោះ ( មាត្រា ១២៥ កថាខណ្ឌទី ២) ។ នេះហៅថា គោលបំណងនៃការបញ្ជាក់ ។ ប៉ុន្តែ តាមគោលការណ៍នៃជំនឿទុកចិត្តដោយសេរី តុលាការមិនត្រូវបានចងដោយគោលបំណងនៃការបញ្ជាក់របស់ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាងទេ ចំពោះប្រភេទនៃអង្គហេតុដែលត្រូវទទួលស្គាល់ដោយផ្អែកលើលទ្ធផលនៃការពិនិត្យភស្តុតាង ជាអាទិ៍ ។ ម្យ៉ាងទៀត តុលាការក៏អាចទទួលស្គាល់អង្គហេតុដែលបានអះអាងដោយភាគីម្ខាង ( អង្គហេតុដែលមានប្រយោជន៍ដល់ភាគីម្ខាងនោះ) តាមរយៈភស្តុតាងដែលស្នើសុំឱ្យពិនិត្យដោយភាគីម្ខាងទៀតដែរ ។ ភស្តុតាងដែលបានធ្វើការពិនិត្យម្តងរួចហើយ ជាទូទៅ អាចយកទៅប្រើជាមធ្យោបាយដើម្បីទទួលស្គាល់អង្គហេតុដែលភាគីណាម្ខាងបានអះអាង បាន ។ នេះហៅថា គោលការណ៍នៃការប្រើភស្តុតាងជារួម ។

៣. ការកម្រិតចំពោះគោលការណ៍នៃជំនឿទុកចិត្តដោយសេរី

ទោះជាយ៉ាងណាក៏ដោយ គោលការណ៍នៃជំនឿទុកចិត្តដោយសេរី មិនអនុញ្ញាតឱ្យចៅក្រមធ្វើតាមអំពើចិត្តរបស់ខ្លួន ក្នុងការទទួលស្គាល់អង្គហេតុ និង ក្នុងការដាក់ជំនឿទុកចិត្ត នោះទេ ។ តាមគោលការណ៍នៃជំនឿទុកចិត្តដោយសេរី ការទទួលស្គាល់អង្គហេតុ និង ការធ្វើជំនឿទុកចិត្ត ត្រូវធ្វើឡើង តាមការវាយតម្លៃដោយត្រឹមត្រូវទៅលើភស្តុតាង និង តាមការសន្និដ្ឋាន ដែលស្របនឹងវិធានតាមបទពិសោធន៍ និង វិធានសមហេតុផល ។ ការទទួលស្គាល់អង្គហេតុដែលមិនបំពេញតាមល័ក្ខខ័ណ្ឌទាំងនេះ និង ដែលមិនសមហេតុផលយ៉ាងជាក់ស្តែងចំពោះមនុស្សទូទៅ ត្រូវបានវាយតម្លៃថាខុសច្បាប់ និង ត្រូវកែតម្រូវនៅតុលាការនៃបណ្តឹងសារទុក្ខ ( មាត្រា ២៩៦ កថាខណ្ឌទី ១) ។

## កថាភាគទី ៥ ការទទួលខុសត្រូវក្នុងការបញ្ជាក់

១. អត្ថន័យនៃការទទួលខុសត្រូវក្នុងការបញ្ជាក់

នៅក្នុងនីតិវិធីនៃបណ្តឹង អាចមានករណីដែល ទោះបីជាបានធ្វើការជម្រះក្តីដោយហ្មត់ចត់យ៉ាងណាក៏ដោយ ក៏មិនអាចទទួលស្គាល់អំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុដែលចាំបាច់សម្រាប់កំណត់អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលបានអះអាងដោយដើមចោទ នៅក្នុងបណ្តឹង បានដែរ ។ នៅក្នុងករណីបែបនេះ ប្រសិនបើអនុញ្ញាតឱ្យតុលាការបញ្ចប់នីតិវិធីនៃបណ្តឹងដោយមិនចេញសាលក្រម ដោយសំអាងថាមិនអាចកំណត់អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិបាន ព្រោះអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ មានភាពមិនច្បាស់លាស់នោះ វិវាទរវាងភាគី មិនអាចដោះស្រាយបានឡើយ ហើយក៏មិនអាចផ្តល់ការសង្គ្រោះដល់ភាគីដែលមានសិទ្ធិនោះដែរ ។ ហេតុនេះហើយ

ទោះបីជាក្នុងករណីបែបនេះក៏ដោយ ដើម្បីអាចចេញសាលក្រមបាន ប្រព័ន្ធនៃការកំណត់ការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានបង្កើតឡើងដើម្បីអាចកំណត់អំពីការបានបង្កើត ឬ មិនបានបង្កើតអានុភាពគតិយុត្តបាន ដោយធ្វើការសន្មតអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

មានន័យថា ក្នុងករណីដែលអង្គហេតុចាំបាច់ដើម្បីកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃអានុភាពគតិយុត្តណាមួយ (ឧទាហរណ៍ដូចជា ការកកើត ឬ ការរលត់សិទ្ធិ) មិនអាចកំណត់បាននៅក្នុងបណ្ដឹងទេនោះ ប្រព័ន្ធនៃការកំណត់ការទទួលខុសត្រូវក្នុងការបញ្ជាក់ អាចផ្ដល់លទ្ធភាពឱ្យគេអាចសម្រេចអំពីការបានបង្កើត ឬ មិនបានបង្កើតនូវអានុភាពគតិយុត្តនោះបាន ដោយសន្មតថាវាធ្វើឱ្យខូចផលប្រយោជន៍ដល់ភាគីណាមួយ ហើយធ្វើបែបនេះ តុលាការនឹងអាចចេញសេចក្ដីសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិបាន ។ នៅក្នុងប្រព័ន្ធនេះ ប្រសិនបើអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុណាមួយ ត្រូវបានសន្មតថានឹងធ្វើឱ្យខូចប្រយោជន៍ដល់ភាគីណាម្ខាង ភាគីនោះត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុនោះ ។ នេះគឺចេញមកពីគំនិតដែលថា ទោះជាភាគីត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ក៏ដោយ បើភាគីមិនបានធ្វើការបញ្ជាក់នោះទេ ហេតុនេះហើយបានជាអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះ ត្រូវបានសន្មត ដោយធ្វើឱ្យខូចប្រយោជន៍ដល់ភាគីនោះ ។ ក៏ប៉ុន្តែ នៅក្នុងករណីជាក់ស្ដែង ការទទួលខុសត្រូវក្នុងការបញ្ជាក់ គឺជាការទទួលខុសត្រូវលើលទ្ធផល ដែលមិនសុទ្ធតែផ្អែកទៅលើកំហុស ឬ ការធ្វេសប្រហែសរបស់ភាគីដែលមានបន្ទុក នៅក្នុងការដាក់ភស្តុតាងឡើយ ។

ដោយសារថា ការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានប្រើប្រាស់ នៅក្នុងករណីដែលអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុណាមួយ នៅតែមានភាពមិនច្បាស់លាស់ បើទោះបីជាបានធ្វើការពិនិត្យភស្តុតាងដោយហ្មត់ចត់យ៉ាងណាក៏ដោយ ដូច្នេះហើយ ត្រូវកំណត់ថាតើដើមចោទ ឬ ចុងចម្លើយ ដែលត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់នៅក្នុងបណ្ដឹង ។ ចំពោះអង្គហេតុតែមួយ មិនអាចមានករណីដែលដើមចោទត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អត្ថិភាព ហើយចុងចម្លើយត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់នត្ថិភាពនៃអង្គហេតុដដែលនោះទេ ។ នៅក្នុងករណីដែលមានវិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុណាមួយនៅក្នុងបណ្ដឹង ភាគីទាំងសងខាង នឹងដាក់ភស្តុតាងដើម្បីបញ្ជាក់ថា ការអះអាងអង្គហេតុរបស់ខ្លួន ជាការពិត ឬ មិនពិត ។ ចំពោះភាគីដែលត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អង្គហេតុនោះ មិនអាចសម្រេចគោលបំណងបានឡើយ ប្រសិនបើមិនអាចធ្វើឱ្យចៅក្រមជឿទុកចិត្តថាការអះអាងរបស់ខ្លួនគឺជាការពិតទេនោះ ។ ផ្ទុយទៅវិញ ដោយយោងទៅតាមការទទួលខុសត្រូវក្នុងការបញ្ជាក់ ភាគីម្ខាងទៀតអាចសម្រេចនូវគោលបំណងរបស់ខ្លួនបាន ដោយការធ្វើឱ្យចៅក្រមមានភាពមិនច្បាស់លាស់អំពីអត្ថិភាពនៃអង្គហេតុនោះ គឺមិនចាំបាច់ធ្វើឱ្យចៅក្រមជឿទុកចិត្តថា សេចក្ដីថ្លែងការណ៍របស់ខ្លួនគឺជាការពិតនោះទេ ។ ដូចបានពន្យល់ពីខាងដើម ភស្តុតាងដែលភាគីដែលមានការទទួលខុសត្រូវក្នុងការបញ្ជាក់ត្រូវដាក់ ហៅថា "ភស្តុតាងស្រប" ចំណែកឯ ភស្តុតាងដែលភាគីម្ខាងទៀតត្រូវដាក់ ហៅថា "ភស្តុតាងផ្ទុយ" ។

ការទទួលខុសត្រូវក្នុងការបញ្ជាក់ ដែលមានន័យខុសគ្នាពីការទទួលខុសត្រូវក្នុងការអះអាង មិនមែនជា

លក្ខណៈពិសេសនៃគោលការណ៍នៃការទាញហេតុផលឡើយ ។ តាមប្រព័ន្ធតុលាការដែលយកគោលការណ៍នៃការស្វែងរកអង្គហេតុដោយឆន្ទានុសិទ្ធិរបស់ចៅក្រម ដែលតុលាការធ្វើការស្រាវជ្រាវអំពីអង្គហេតុ និង ពិនិត្យភស្តុតាង តាមឆន្ទានុសិទ្ធិរបស់ខ្លួននោះ ក៏អាចមានករណីដែលអត្ថិភាពនៃអង្គហេតុណាមួយ មានភាពមិនច្បាស់លាស់ដែរ ហើយក្នុងករណីបែបនេះ ក៏ចាំបាច់ត្រូវធ្វើការសន្មតអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះ តាមរយៈការទទួលខុសត្រូវក្នុងការបញ្ជាក់ដែរ ។

២. ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់

(១) អត្ថន័យនៃការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់

បញ្ញត្តិនៃច្បាប់ដែលកំណត់ថាតើភាគីណាមួយដែលត្រូវមានការទទួលខុសត្រូវក្នុងការបញ្ជាក់ ហៅថា "ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់" ។ ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ មិនត្រូវបានធ្វើឡើងដោយផ្អែកទៅលើលក្ខណៈនៃអង្គហេតុដែលពាក់ព័ន្ធនោះទេ ។ ការកំណត់នេះ ត្រូវធ្វើឡើងដោយផ្អែកលើមធ្យោបាយនៃការកំណត់ល័ក្ខខ័ណ្ឌគតិយុត្តនៃបញ្ញត្តិច្បាប់ ដើម្បីធ្វើការសម្រេចទៅលើអានុភាពគតិយុត្តនៃការបង្កើត ឬ ការរលត់សិទ្ធិណាមួយ ។ មានន័យថា បញ្ញត្តិច្បាប់សារធាតុនីមួយៗ មានចែងអំពីល័ក្ខខ័ណ្ឌគតិយុត្តនានា ដើម្បីឱ្យអានុភាពគតិយុត្តណាមួយកើតឡើង ហើយតាមរយៈនេះ គេដឹងថា បញ្ញត្តិច្បាប់សារធាតុនោះ មានគោលគំនិតថា ប្រសិនបើអង្គហេតុណាមួយដែលឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌគតិយុត្តទាំងនោះកើតមានឡើង នោះអានុភាពគតិយុត្តដែលមានចែងនោះ ត្រូវកើតឡើង ។ អាស្រ័យហេតុនេះហើយ ក្នុងករណីដែលមានបញ្ញត្តិដែលចែងយ៉ាងច្បាស់នៅក្នុងច្បាប់សារធាតុ (ឧទាហរណ៍ មាត្រា ៧៤៣ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី) ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវយោងទៅតាមបញ្ញត្តិនោះ ។ ហើយប្រសិនបើពុំមានបញ្ញត្តិចែងច្បាស់លាស់ទេ ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ជាគោលការណ៍ត្រូវធ្វើឡើងដោយផ្អែកលើលំដាប់សមហេតុផលនៃការអនុវត្តបញ្ញត្តិច្បាប់សារធាតុ និង ទៅតាមវិធីនៃការកំណត់ល័ក្ខខ័ណ្ឌគតិយុត្ត នៅក្នុងបញ្ញត្តិច្បាប់សារធាតុនីមួយៗ ។ ជាក់ស្តែង ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានកំណត់ ដោយគិតពិចារណាអំពីគោលនយោបាយ ដូចជាសមធម៌រវាងភាគីទាំងពីរនៅក្នុងដំណើរការរឿងក្តី ការដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ឬ មានភាពងាយស្រួលក្នុងការអះអាងអំពីសិទ្ធិនៅក្នុងនីតិវិធីនៃបណ្តឹង ជាអាទិ៍ ។ អាស្រ័យហេតុនេះហើយ ក្នុងករណីដែលពុំមានភាពច្បាស់លាស់ថាតើអង្គហេតុណាមួយដែលច្បាប់សារធាតុកំណត់ថាជាល័ក្ខខ័ណ្ឌគតិយុត្ត ដើម្បីឱ្យអានុភាពគតិយុត្តណាមួយកើតឡើង ហើយការបញ្ជាក់ត្រូវធ្វើឡើងដោយផ្អែកលើការបកស្រាយនោះ ខ្លឹមសារនៃច្បាប់សារធាតុនោះ និង ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវកំណត់ដោយផ្អែកលើការពិចារណាអំពីចំណុចទាំងអស់នេះ ។

(២) គោលការណ៍មូលដ្ឋាន នៃការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់

ជាទូទៅ ភាគីដែលអះអាងអំពីអត្ថិភាពនៃសិទ្ធិណាមួយ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុ

ដែលជាល័ក្ខខ័ណ្ឌគតិយុត្តនៃបញ្ញត្តិច្បាប់ដែលចែងអំពីការបង្កើត (ឬ ធ្វើលទ្ធកម្ម) សិទ្ធិនោះ ។ ឧទាហរណ៍ ក្នុងករណីដែលដើមចោទដាក់ពាក្យបណ្តឹងអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យបង់ថ្លៃលក់ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ដើមចោទនោះត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អង្គហេតុដែលថា កិច្ចសន្យាលក់ទិញមួយ ដែលជាល័ក្ខខ័ណ្ឌនៃការបង្កើតសិទ្ធិទាមទារនោះ ត្រូវបានបង្កើតឡើង ។ ប៉ុន្តែ ក្នុងករណីដែលមានបញ្ញត្តិច្បាប់មួយផ្សេងទៀត ចែងអំពីមូលហេតុដែលរារាំងមិនឱ្យអានុភាពគតិយុត្តនៃការបង្កើតសិទ្ធិ កើតឡើង ដើមចោទពុំទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុដែលជាមូលហេតុនៃការរារាំងនោះទេ ។ ចំពោះអង្គហេតុដែលជាមូលហេតុនៃការរារាំងនេះ ភាគីដែលធ្វើការតវ៉ាចំពោះអត្ថិភាពនៃសិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ ។ ឧទាហរណ៍ ប្រសិនបើមានចំណុចវិវាទជាអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃមោឃភាពកិច្ចសន្យាលក់ទិញនោះ ដូចជាការបង្ហាញឆន្ទៈមិនពិត (មាត្រា ៣៥២ នៃក្រមរដ្ឋប្បវេណី) ជាអាទិ៍ ចុងចម្លើយត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអត្ថិភាពនៃមូលហេតុនៃមោឃភាពនោះ ។ ម្យ៉ាងទៀត ដោយសារថា ការរលត់សិទ្ធិដែលធ្លាប់ត្រូវបានបង្កើតម្តងហើយ គឺជាអានុភាពគតិយុត្តថ្មីនោះ ភាគីដែលអះអាងអំពីការរលត់សិទ្ធិនោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុនៃមូលហេតុនៃការរលត់សិទ្ធិ ។ ឧទាហរណ៍ ការសងកាតព្វកិច្ច ការលុបចោលកិច្ចសន្យា ការរំលាយកិច្ចសន្យា ឬ ការលើកឡើងនូវអាជ្ញាយុកាលនៃការរលត់សិទ្ធិ ជាអាទិ៍ ។ ប៉ុន្តែ នៅក្នុងករណីបែបនេះ ប្រសិនបើមានបញ្ញត្តិច្បាប់ផ្សេងចែងអំពីមូលហេតុដែលរារាំងមិនឱ្យអានុភាពគតិយុត្តនៃការរលត់សិទ្ធិ កើតឡើង ភាគីដែលធ្វើវិវាទអំពីអានុភាពនៃការរលត់សិទ្ធិនោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុដែលជាមូលហេតុនៃការរារាំងនោះ ។ ឧទាហរណ៍ ក្នុងករណីដែលភាគីអះអាងថា អានុភាពនៃការលុបចោលកិច្ចសន្យា មិនបានកើតឡើងទេ ដោយសារមានការផ្តល់សច្ចានុមតិ (មាត្រា ៣៥៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី) ឬ ភាគីអះអាងថា អាជ្ញាយុកាលនៃការរលត់សិទ្ធិ មិនទាន់សម្រេចនៅឡើយ ដោយសារមានមូលហេតុនៃការផ្អាកអាជ្ញាយុកាល (មាត្រា ៤៨៩ នៃក្រមរដ្ឋប្បវេណី) នោះអង្គហេតុនៃការផ្តល់សច្ចានុមតិ និង អង្គហេតុដែលជាមូលហេតុនៃការផ្អាកអាជ្ញាយុកាល គឺជាអង្គហេតុដែល ភាគីដែលធ្វើវិវាទអំពីអានុភាពនៃការរលត់សិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ ។

ម្យ៉ាងទៀត ចំពោះបញ្ញត្តិច្បាប់ដែលមានវាក្យខណ្ឌទី ១ ដែលចែងអំពីគោលការណ៍ និង វាក្យខណ្ឌទី ២ ដែលចែងអំពីករណីលើកលែង (proviso, អញ្ញត្រកម្មដែលចាប់ផ្តើមពីពាក្យ "ប៉ុន្តែ") ភាគីដែលអះអាងអំពីអានុភាពគតិយុត្តដែលអាចទទួលស្គាល់ ដោយការអនុវត្តវាក្យខណ្ឌទី ១ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អង្គហេតុជាល័ក្ខខ័ណ្ឌដែលចែងនៅក្នុងវាក្យខណ្ឌទី ១ នោះ ចំណែកឯ ភាគីដែលធ្វើវិវាទអំពីអានុភាពគតិយុត្តនោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុដែល លើកលែងដោយវាក្យខណ្ឌទី ២ ។ ឧទាហរណ៍ នៅក្នុងបញ្ញត្តិដែលចែងថា "ការលុបចោលនូវកិច្ចសន្យា ដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន ។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការឆបោក

មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ" (មាត្រា ៣៨៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី) ចំពោះអង្គហេតុនៃការឆបោក និង អង្គហេតុនៃការបង្ហាញឆន្ទៈចំពោះការលុបចោលកិច្ចសន្យា ភាគីដែលអះអាងអំពីការលុបចោលកិច្ចសន្យានោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ ហើយដោយឡែក ចំពោះអង្គហេតុនៃ "ភាពសុចរិត និង គ្មានកំហុស" ចំពោះការឆបោកនោះ ភាគីដែលធ្វើវិវាទអំពីអានុភាពនៃការលុបចោលនោះ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ ។

ជាសង្ខេប គេអាចនិយាយថា ភាគីនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុដែលត្រូវនឹងល័ក្ខខ័ណ្ឌគតិយុត្តនៃបញ្ញត្តិច្បាប់ដែលផ្តល់អានុភាពគតិយុត្តដែលមានប្រយោជន៍ដល់ខ្លួន ។

៣. ការសន្និដ្ឋានតាមផ្លូវច្បាប់ និង ការប្តូរនូវការទទួលខុសត្រូវក្នុងការបញ្ជាក់

(១) ការសន្និដ្ឋានតាមផ្លូវច្បាប់ និង ការសន្និដ្ឋានលើអង្គហេតុ

"ការសន្និដ្ឋានតាមផ្លូវច្បាប់" គឺជាការសន្និដ្ឋានក្នុងករណីដែលបញ្ញត្តិច្បាប់ចែងថា "ក្នុងករណីដែលមានអង្គហេតុ a ត្រូវសន្និដ្ឋានថា មានអង្គហេតុ b" ។ ការសន្និដ្ឋានតាមផ្លូវច្បាប់ត្រូវបានចែងឡើងក្នុងគោលបំណងទទួលស្គាល់នូវការកើតឡើងនៃអានុភាពគតិយុត្តដែលកំណត់ដោយច្បាប់នោះ ក្នុងករណីដែលមានការពិបាកនឹងធ្វើការបញ្ជាក់ស្តីពីអង្គហេតុដែលជាល័ក្ខខ័ណ្ឌគតិយុត្តនៃច្បាប់មួយ (ក្នុងឧទាហរណ៍ខាងលើនេះ គឺអង្គហេតុ b) ដែលមានខ្លឹមសារថា ប្រសិនបើអាចបញ្ជាក់អង្គហេតុដទៃ (ក្នុងឧទាហរណ៍ខាងលើនេះ គឺអង្គហេតុ a) នឹងមានន័យដូចគ្នានឹងការបញ្ជាក់អង្គហេតុ (b) ដែលជាល័ក្ខខ័ណ្ឌគតិយុត្តដែរ ។ ឧទាហរណ៍ ក្នុងករណីដែលមានបញ្ញត្តិថា "ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ២០ ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ" (សូមមើលក្រមរដ្ឋប្បវេណី មាត្រា ១៦២ កថាខណ្ឌទី ១) ហើយក្រៅពីនេះ មានបញ្ញត្តិមួយទៀតដែលចែងថា "ប្រសិនបើមានភស្តុតាងដែលបញ្ជាក់ថា បានកាន់កាប់នៅពេលមួយ និង នៅពេលមួយផ្សេងទៀតដែលក្រោយពេលនោះ អ្នកកាន់កាប់នោះត្រូវបានសន្និដ្ឋានថា បានកាន់កាប់ជាប់រហូតក្នុងអំឡុងពេលនោះ" (សូមមើលក្រមរដ្ឋប្បវេណី មាត្រា ២៣៤ កថាខណ្ឌទី ៣) ភាគីដែលបានអះអាងអំពីលទ្ធកម្មដោយអាជ្ញាយុកាលនូវនៃលទ្ធកម្មសិទ្ធិនូវកម្មសិទ្ធិលើអចលនវត្ថុ តាមការពិត ត្រូវធ្វើការបញ្ជាក់ថា បានកាន់កាប់អចលនវត្ថុនោះ ក្នុងអំឡុងពេល ២០ ឆ្នាំ ជាប់គ្នា ប៉ុន្តែ ប្រសិនបើគ្រាន់តែធ្វើការបញ្ជាក់ថា បានកាន់កាប់នៅ ពេលកំណត់មួយនាអតីតកាល ហើយថែមទាំងបញ្ជាក់អង្គហេតុនៃការកាន់កាប់នៅពេល ២០ ឆ្នាំ ក្រោយពីនោះ គឺអាចសន្និដ្ឋានតាមផ្លូវច្បាប់ថា បានកាន់កាប់ក្នុងអំឡុងពេលរវាងពេលទាំងពីរនោះ ដូច្នេះហើយ តុលាការអាចទទួលស្គាល់នូវអានុភាពគតិយុត្ត ដែលជាលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល ដោយមិនចាំបាច់ធ្វើការបញ្ជាក់ផ្សេងទៀតទេ (ក្នុងការពន្យល់នេះ មិនគិតដល់ល័ក្ខខ័ណ្ឌនៃឆន្ទៈយកជាកម្មសិទ្ធិ ឬ ការកាន់កាប់ដោយសន្តិវិធី និង ដឹងឮជាសាធារណៈទេ) ។

បញ្ញត្តិច្បាប់ដែលចែងអំពីការសន្និដ្ឋានតាមផ្លូវច្បាប់នេះ ត្រូវហៅថា "បញ្ញត្តិសន្និដ្ឋាន" រីឯអង្គហេតុដែលជា

បុរេល័ក្ខខ័ណ្ឌនៃការសន្មតនេះ ត្រូវហៅថា "អង្គហេតុជាបុរេល័ក្ខខ័ណ្ឌ" (ក្នុងករណីខាងលើនេះ គឺអង្គហេតុ a) ហើយអង្គហេតុដែលត្រូវបានសន្មត ត្រូវហៅថា "អង្គហេតុសន្មត" (ក្នុងករណីខាងលើនេះ គឺ អង្គហេតុ b) ។

ការសន្មតតាមផ្លូវច្បាប់ គឺមានអានុភាពតាមផ្លូវច្បាប់ខុសពីការសន្មតអំពីអង្គហេតុ ក្នុងករណីដែលសន្និដ្ឋានអំពីអង្គហេតុផ្សេងមួយពីអង្គហេតុអ្វីមួយ ដោយប្រើរូបមន្តនៃបទពិសោធន៍ (វិធានតាមបទពិសោធន៍) ដូច្នេះត្រូវចែកឱ្យដាច់អំពីការសន្មតតាមផ្លូវច្បាប់ និង ការសន្មត (សន្និដ្ឋាន) អំពីអង្គហេតុ ។ ការសន្និដ្ឋានដោយប្រើវិធានតាមបទពិសោធន៍ ត្រូវហៅថា "ការសន្មតលើអង្គហេតុ" ហើយនេះគ្រាន់តែជាការទទួលស្គាល់នូវអង្គហេតុដោយជំនឿទុកចិត្តរបស់ចៅក្រមប៉ុណ្ណោះ ។

(២) អានុភាពនៃការសន្មតតាមផ្លូវច្បាប់

ប្រសិនបើមានបញ្ញត្តិសន្មតតាមផ្លូវច្បាប់ ក្នុងករណីដែលភាគីបានបញ្ជាក់អំពីអង្គហេតុដែលជាបុរេល័ក្ខខ័ណ្ឌ (a) ជំនួសការបញ្ជាក់អំពីអង្គហេតុ (b) ដែលត្រូវជាល័ក្ខខ័ណ្ឌគតិយុត្តនៃបញ្ញត្តិច្បាប់ដើម តុលាការអាចទទួលស្គាល់នូវអានុភាពគតិយុត្តដែលអះអាងនោះបាន ក៏ប៉ុន្តែ ភាគីម្ខាងទៀតអាចបដិសេធនូវការសន្មតនោះដោយការបញ្ជាក់អំពីនត្ថិភាពនៃអង្គហេតុគតិយុត្តដែលជាល័ក្ខខ័ណ្ឌចម្បង (b) បាន ។ ក្នុងករណីនេះ ភាគីម្ខាងទៀតត្រូវធ្វើឱ្យចៅក្រមមានជំនឿទុកចិត្តទៅលើនត្ថិភាពនៃអង្គហេតុគតិយុត្តដែលជាល័ក្ខខ័ណ្ឌចម្បង ។ បើនិយាយពីឧទាហរណ៍នៃអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិវិញ ប្រសិនបើភាគីម្ខាងទៀតបានបញ្ជាក់ថា នាកណ្តាលអំឡុងពេលនោះ ភាគីដែលបានអះអាងអំពីអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ មិនបានកាន់កាប់អចលនវត្ថុនោះទេ ភាគីនោះនឹងអាចបដិសេធនូវការសន្មតនោះបាន តែដើម្បីធ្វើដូច្នេះបាន ទាល់តែធ្វើឱ្យចៅក្រមមានជំនឿថា ភាគីនោះមិនបានកាន់កាប់អចលនវត្ថុនោះ នាកណ្តាលអំឡុងពេលនោះទេ ។ មានន័យថា ដើម្បីបដិសេធនូវការសន្មត ភាគីម្ខាងទៀតត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់អំពីអង្គហេតុផ្ទុយនឹងល័ក្ខខ័ណ្ឌគតិយុត្តចម្បង ។ ហេតុដូច្នេះ បញ្ញត្តិសន្មត អនុញ្ញាតឱ្យភាគីដែលអះអាងអំពីអានុភាពគតិយុត្តដែលចែងដោយច្បាប់ណាមួយធ្វើការជ្រើសរើសនូវអង្គហេតុដែលជាកម្មវត្ថុនៃការបញ្ជាក់ (អាចបញ្ជាក់អំពី a ក៏បាន ឬ b ក៏បាន) ហើយប្រសិនបើបានធ្វើការបញ្ជាក់នូវអង្គហេតុជាបុរេល័ក្ខខ័ណ្ឌ ការទទួលខុសត្រូវក្នុងការបញ្ជាក់ចំពោះអង្គហេតុគតិយុត្តដែលជាល័ក្ខខ័ណ្ឌចម្បង (អង្គហេតុសន្មត) នឹងត្រូវបានប្តូរ ហើយមានអានុភាពឱ្យភាគីម្ខាងទៀតទទួលខុសត្រូវក្នុងការបញ្ជាក់អំពីនត្ថិភាពនៃអង្គហេតុសន្មតនោះ ។

ក្នុងករណីដែលល័ក្ខខ័ណ្ឌគតិយុត្តចម្បង មានអង្គហេតុច្រើន ការប្តូរនូវការទទួលខុសត្រូវក្នុងការបញ្ជាក់ដូចគ្នានេះ នឹងអាចកើតមានឡើងដូចគ្នា ប្រសិនបើមានបញ្ញត្តិចែងថា ឱ្យតែមានអង្គហេតុណាមួយក្នុងចំណោមនោះ គេអាចសន្មតអំពីអត្ថិភាពនៃអង្គហេតុដទៃទៀតបាន ។ ឧទាហរណ៍ ល័ក្ខខ័ណ្ឌគតិយុត្តនៃលទ្ធកម្មកម្មសិទ្ធិនៃអចលនវត្ថុ គឺការកាន់កាប់ជាបន្តបន្ទាប់គ្នាចំនួន ២០ ឆ្នាំ ហើយក្រៅពីនេះ មានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិ ព្រមទាំងជាការកាន់កាប់ដោយសន្តិវិធី និង ជាសាធារណៈ ក៏ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើ

មានបញ្ញត្តិដែលចែងថា "អ្នកកាន់កាប់ត្រូវបានសន្មតថា កាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ" ឬក៏ "អ្នកកាន់កាប់ត្រូវបានសន្មតថា កាន់កាប់ដោយសុចរិត ដោយសន្តិវិធី និង ជាសាធារណៈ" (សូមមើលក្រមរដ្ឋប្បវេណី មាត្រា ២៣៤ កថាខណ្ឌទី ១ និង ទី ២) ប្រសិនបើភាគីដែលអះអាងអំពីលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល បានធ្វើការបញ្ជាក់អំពីអង្គហេតុនៃការកាន់កាប់ ទោះបីជាមិនធ្វើការបញ្ជាក់អំពីអង្គហេតុនៃការកាន់កាប់ដោយមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិ ដោយសន្តិវិធី និង ជាសាធារណៈក៏ដោយ ក៏គេអាចទទួលស្គាល់នូវអានុភាពនៃលទ្ធកម្មកម្មសិទ្ធិដែរ ។ រីឯភាគីម្ខាងទៀតដែលតទល់អំពីលទ្ធកម្មនៃកម្មសិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការបញ្ជាក់ស្ដីពីការកាន់កាប់ដោយពុំមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិ ឬ ការកាន់កាប់មិនមែនដោយសន្តិវិធី និង មិនមែនជាសាធារណៈ ។ ក៏ប៉ុន្តែ ការសន្មតក្នុងករណីនេះ គឺជាការយកអង្គហេតុមួយភាគក្នុងចំណោមអង្គហេតុដែលជាល័ក្ខខ័ណ្ឌគតិយុត្តចម្បង ទៅធ្វើការសន្មតអំពីអង្គហេតុមួយភាគផ្សេងទៀត ហើយនេះគឺខុសពីការសន្មតតាមផ្លូវច្បាប់ ដែលយកអង្គហេតុផ្សេងមកធ្វើជាអង្គហេតុជាបុរេល័ក្ខខ័ណ្ឌ ។

ចំពោះចំណុចខាងលើនេះ ក្នុងការសន្មត (សន្និដ្ឋាន) លើអង្គហេតុនេះ ពុំមានអានុភាពប្ដូរនូវការទទួលខុសត្រូវក្នុងការបញ្ជាក់ទេ ។

## កថាភាគទី ៦ ការពន្យល់ត្រួសៗអំពីនីតិវិធីនៃការពិនិត្យភស្តុតាង

១. បទប្បញ្ញត្តិទូទៅស្ដីពីការពិនិត្យភស្តុតាង

ការពិនិត្យភស្តុតាង គឺជានីតិវិធីដើម្បីទទួលនូវធនធានភស្តុតាង ដូចជាចម្លើយជាកសិណសាក្សី មតិយោបល់នៃកោសលវិច័យ សេចក្ដីថ្លែងការណ៍របស់សាមីភាគី ខ្លឹមសារដែលសរសេរក្នុងឯកសារ លទ្ធផលនៃការពិនិត្យជាអាទិ៍ មកពីវិធីភស្តុតាង ដូចជាសាក្សី អ្នកធ្វើកោសលវិច័យ សាមីភាគី ឯកសារ ឬ វត្ថុដែលត្រូវបានពិនិត្យជាអាទិ៍ ។

ជាគោលការណ៍ ការពិនិត្យភស្តុតាងត្រូវធ្វើ តាមពាក្យសុំរបស់ភាគី (ការស្នើសុំពិនិត្យភស្តុតាង) (មាត្រា ១២៤ កថាខណ្ឌទី ១ ។ គោលការណ៍នៃការទាញហេតុផល) ។ ក៏ប៉ុន្តែ ប្រសិនបើតុលាការមិនអាចធ្វើការវិនិច្ឆ័យថា ត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវភាពពិតនៃការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថា មានការចាំបាច់ផ្សេងទៀត តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន (មាត្រា ១២៤ កថាខណ្ឌទី ២) ។ម្យ៉ាងទៀត ការស្នើសុំឱ្យពិនិត្យភស្តុតាងអាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បានដែរ (មាត្រា ១២៥ កថាខណ្ឌទី ៣) ។

តុលាការត្រូវធ្វើការពិនិត្យភស្តុតាងដែលភាគីស្នើសុំឱ្យពិនិត្យ (មាត្រា ១២៦ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ ចំពោះភស្តុតាងដែលគ្មានទំនាក់ទំនងនឹងអង្គហេតុដែលនឹងត្រូវបញ្ជាក់ និង ភស្តុតាងដែលតុលាការយល់

ឃើញថា មិនចាំបាច់ តុលាការមិនចាំបាច់ធ្វើការពិនិត្យទេ (មាត្រា ១២៦ វាក្យខណ្ឌទី ២) ។ ម្យ៉ាងទៀត ការស្នើសុំឱ្យពិនិត្យភស្តុតាងដែលយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (មាត្រា ៩៤) ឬ ការស្នើសុំឱ្យពិនិត្យភស្តុតាងដែលខុសទម្រង់ តុលាការត្រូវលើកចោល ដូច្នេះ មិនចាំបាច់ធ្វើការពិនិត្យឡើយ ។

២. ការសាកសួរសាក្សី

សាក្សី គឺជាតតិយជនដែលត្រូវតុលាការបង្គាប់ឱ្យធ្វើសេចក្តីរាយការណ៍ជូនតុលាការ ស្តីពីអង្គហេតុនៃអតីតកាលដែលខ្លួនបានជួបប្រទះដោយខ្លួនឯង នៅក្រៅបណ្តឹង ។ សេចក្តីថ្លែងការណ៍របស់សាក្សី គេហៅថា ចម្លើយជាកសិណសាក្សី ហើយការពិនិត្យភស្តុតាងដើម្បីយកចម្លើយជាកសិណសាក្សីនោះ ធ្វើជាធនធានភស្តុតាង គឺជាការសាកសួរសាក្សី ។

នៅកម្ពុជា ជនដែលស្ថិតនៅក្រោមសិទ្ធិជំនុំជម្រះនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានករណីយកិច្ចធ្វើជាសាក្សីទាំងអស់គ្នា (មាត្រា ១៣២ កថាខណ្ឌទី ១) ។ ជនដែលត្រូវបានកោះហៅជាសាក្សី មានករណីយកិច្ចត្រូវបង្ហាញខ្លួនចំពោះមុខតុលាការ ជាគោលការណ៍ ត្រូវធ្វើសម្បថ (មាត្រា ១៣៧) ហើយត្រូវឆ្លើយជាកសិណសាក្សី ។ ក្នុងករណីដែលសាក្សីមិនមានវត្តមានចំពោះមុខតុលាការតាមការកោះហៅ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចបង្គាប់ឱ្យនាំខ្លួនសាក្សីនោះបាន (មាត្រា ១៣២ កថាខណ្ឌទី ២) ។ សាក្សីត្រូវធ្វើសេចក្តីរាយការណ៍នូវអង្គហេតុដែលខ្លួនបានជួបផ្ទាល់ ហើយមិនអាចឱ្យអ្នកផ្សេងជំនួសខ្លួនបានឡើយ ។ ម្យ៉ាងវិញទៀត សាក្សីអាចបដិសេធក្នុងការផ្តល់ចម្លើយជាកសិណសាក្សីបាន ចំពោះចំណុចដែលអាចធ្វើឱ្យសាមីខ្លួន ឬសហព័ទ្ធរបស់សាក្សី ឬ ញាតិដទៃទៀត ទទួលរងគ្រោះនូវការចោទប្រកាន់ពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ឬ ចំពោះចំណុចដែលត្រូវជាការសម្ងាត់ក្នុងមុខនាទីរបស់សាក្សី (មាត្រា ១៣៤ សិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី) ។

ការសាកសួរសាក្សី ត្រូវធ្វើឡើង ជាគោលការណ៍ នៅតុលាការដែលចាត់ការបណ្តឹងនោះ (តុលាការដែលបានទទួលបណ្តឹង) នៅក្នុងសាលសវនាការដែលបើកឡើងជាសាធារណៈ ក៏ប៉ុន្តែ ក្នុងករណីដែលសាក្សីមិនអាចបង្ហាញខ្លួនចំពោះមុខតុលាការ ដោយសារជម្ងឺ ឬ ដោយសារចាស់ជរា តុលាការអាចធ្វើការសាកសួរពិសេសក្រៅតុលាការបាន (មាត្រា ១៣៦ កថាខណ្ឌទី ១) ។ ក្នុងករណីនេះ តុលាការអាចឱ្យចៅក្រមម្នាក់ក្នុងចំណោមចៅក្រមដែលជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះ (គេហៅថា ចៅក្រមទទួលបញ្ជា) ឬ ឱ្យចៅក្រមនៃតុលាការផ្សេង (ឧទាហរណ៍ តុលាការដែលនៅជិតលំនៅឋានរបស់សាក្សី) (ត្រូវហៅថា ចៅក្រមដែលទទួលនូវការប្រគល់សិទ្ធិ) ទៅសាកសួរសាក្សីបាន (មាត្រា ១៣៦ កថាខណ្ឌទី ២) ។

៣. ការសាកសួរភាគី

ការសាកសួរភាគី គឺជាការពិនិត្យភស្តុតាងដែលធ្វើឡើងដោយតុលាការ ដើម្បីទទួលនូវធនធានភស្តុតាងដោយយកសាមីភាគីមកធ្វើជាវិធីភស្តុតាង ដោយឱ្យធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបផ្ទាល់

នោះ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ ។ ការសាកសួរភាគី គឺជានីតិវិធីដែលមានគោលបំណង ទទួលយកនូវធនធានភស្តុតាង ដោយយកសាមីភាគីជាកម្មវត្ថុនៃការពិនិត្យ ។ ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ របស់ភាគីក្នុងការសាកសួរភាគីនេះ គឺជាធនធានភស្តុតាង ហើយមានអត្ថន័យខុសគ្នានឹងការអះអាងរបស់ ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ។ ឧទាហរណ៍ នៅក្នុងការសាកសួរភាគី ទោះជាភាគីបានថ្លែងការណ៍ស្របទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ដែលធ្វើឱ្យ ខូចផលប្រយោជន៍របស់ខ្លួនក៏ដោយ ក៏សេចក្តីថ្លែងការណ៍នោះមិនមែនក្លាយទៅជាការសារភាពតាមផ្លូវបណ្តឹង ទេ គឺការថ្លែងការណ៍នោះគ្រាន់តែជាធនធានភស្តុតាងមួយដែលចៅក្រមនឹងធ្វើការវាយតម្លៃដោយជំនឿទុក ចិត្តរបស់ខ្លួនប៉ុណ្ណោះ ។ម្យ៉ាងទៀត ផ្ទុយទៅវិញ ក្រោមគោលការណ៍នៃការទាញហេតុផល ទោះជាធ្វើ សេចក្តីថ្លែងការណ៍អំពីអង្គហេតុណាមួយនៅពេលសាកសួរភាគីក៏ដោយ តែប្រសិនបើមិនបានអះអាងក្នុងការ ទាញហេតុផលរបស់ភាគីទេ តុលាការមិនអាចយកមកគិតពិចារណាជាធនធានសម្រាប់ធ្វើការវិនិច្ឆ័យក្នុងការ ចេញសាលក្រមបានឡើយ (សូមមើលផ្នែកទី ១ កថាភាគទី ៣) ។

នីតិវិធីដើម្បីយកសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដែលច្បាប់បានកំណត់ របស់អសមត្ថជនក្នុងការធ្វើបណ្តឹង ដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាល ជាដើម (អ្នកមានអំណាចមេបា, អ្នកអាណាព្យាបាល) ឬ អ្នកតំណាងដែលតំណាងឱ្យនីតិបុគ្គល (នាយកប្រតិបត្តិសហគ្រាស ជាដើម) មកធ្វើជាធនធានភស្តុតាង មិនមែនត្រូវធ្វើជាការសាកសួរសាក្សីទេ គឺត្រូវធ្វើតាមនីតិវិធីសាកសួរភាគី ដោយចាត់ទុកថា ជនទាំងនោះ មានលក្ខណៈប្រហាក់ប្រហែលនឹងសាមីភាគីដែរ (មាត្រា ១៤២) ។

## ៤. កោសល្យវិច័យ

កោសល្យវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការកំណត់ឱ្យតតិយជន (អ្នកជំនាញខាងកោសល្យវិច័យ) ដែលមានចំណេះវិជ្ជា និង បទពិសោធន៍ពិសេស ឱ្យធ្វើរបាយការណ៍អំពីវិធានតាមបទពិសោធន៍ដែលខ្លួនបានដឹង តាមចំណេះវិជ្ជារបស់ខ្លួន ឬ ធ្វើរបាយការណ៍អំពីការវិនិច្ឆ័យ ឬ យោបល់ដែលបានមកពីការអនុវត្តវិធានតាម បទពិសោធន៍ជំនាញ ចំពោះអង្គហេតុជាក់ស្តែងដែលជាបញ្ហានៅក្នុងបណ្តឹងនោះ ។ តុលាការជាអ្នកកំណត់អ្នក ជំនាញខាងធ្វើកោសល្យវិច័យ (មាត្រា ១៤៤ កថាខណ្ឌទី ១) ហើយជនដែលមានចំណេះវិជ្ជា និង បទពិសោធន៍ មានករណីយកិច្ចត្រូវធ្វើកោសល្យវិច័យ (មាត្រា ១៤៤ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ តាមធម្មតា ក្រៅពីជនដែលតុលាការបានកំណត់ជាអ្នកធ្វើកោសល្យវិច័យនេះ ក៏មានជនផ្សេងទៀត ដែលមានចំណេះវិជ្ជា និង បទពិសោធន៍ប្រហាក់ប្រហែលគ្នាដែរ ហេតុនេះហើយ មិនចាំបាច់ធ្វើការពិនិត្យភស្តុតាងដោយមានការបង្ខំឱ្យ អ្នកធ្វើកោសល្យវិច័យនោះ ចូលតុលាការដូចសាក្សីទេ (មាត្រា ១៤៧ មានចែងថាឱ្យមិនអនុវត្តដូចគ្នា តាម មាត្រា ១៣២ កថាខណ្ឌទី ២) ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលមានហេតុរារាំងដល់សច្ចភាពនៃការធ្វើ កោសល្យវិច័យរបស់អ្នកជំនាញ ភាគីអាចប្តឹងជំទាស់ចោលអ្នកធ្វើកោសល្យវិច័យនោះបាន (មាត្រា ១៤៥) ។

## ៥. ភស្តុតាងជាឯកសារ

(១) ទស្សនៈ

ជាទូទៅ វត្ថុរូបីយ (មិនត្រឹមតែជាក្រដាស់ទេ រួមទាំងវត្ថុធ្វើពីឈើ ជាដើម) ដែលបង្ហាញនូវទស្សនៈកំណត់មួយរបស់បុគ្គលណាកំណត់ ដោយអក្សរ ឬ ដោយសញ្ញាផ្សេង (ឧទាហរណ៍ អក្សរសម្រាប់អ្នកពិការភ្នែក) គេហៅថា ឯកសារ ។ ភស្តុតាងជាឯកសារ គឺជាការពិនិត្យភស្តុតាងដោយការអានឯកសារ ហើយយកខ្លឹមសារដែលសរសេរនៅក្នុងនោះ មកធ្វើជាធនធានភស្តុតាង ។

(២) សមត្ថភាព/អំណាចភស្តុតាង នៃភស្តុតាងនៃឯកសារ

អានុភាពនៃឯកសារសម្រាប់ការបញ្ជាក់អង្គហេតុដែលកំពុងមានវិវាទ មានន័យថា សមត្ថភាព/អំណាចភស្តុតាង នៃភស្តុតាងជាឯកសារ អាចបែងចែកជាពីរចំណុច គឺ (១) ការបង្ហាញនូវខ្លឹមសារនៃមនោគមវិជ្ជាកំណត់មួយ ឬ ឆន្ទៈរបស់ជនពិសេសណា (តាមធម្មតា របស់អ្នកដែលធ្វើឯកសារនោះ) និង (២) ប្រយោជន៍នៃខ្លឹមសារនៃមនោគមវិជ្ជា ឬ ឆន្ទៈនោះ ក្នុងការបញ្ជាក់នូវអង្គហេតុដែលមានវិវាទ ។ ទីមួយ ហៅថា សមត្ថភាព/អំណាចជាទម្រង់នៃភស្តុតាងជាទម្រង់ ហើយទីពីរវិញ ត្រូវហៅថា សមត្ថភាព/អំណាចជាសារធាតុនៃភស្តុតាង ។ ឧទាហរណ៍ ទោះជាមានឯកសារមួយដែលមានសរសេរថា "បានខ្ចីប្រាក់ ១០ លានរៀល" ក៏ដោយ តែដើម្បីឱ្យឯកសារនោះមានតម្លៃជាភស្តុតាងបញ្ជាក់អង្គហេតុថា B បានខ្ចីប្រាក់ពី A ១០ លានរៀល នៅក្នុងបណ្តឹងទាមទារឱ្យសងប្រាក់កំចីដែលធ្វើឡើងដោយ A ចំពោះ B ជាបឋម ឯកសារនោះត្រូវមានសរសេរអំពីខ្លឹមសារនៃឆន្ទៈរបស់ B ។ ប្រសិនបើ C ជាអ្នកធ្វើឯកសារនោះទៅវិញ ទោះជាមានសរសេរថា "បានខ្ចីប្រាក់ ១០ លានរៀល" ក៏ដោយ ក៏ឯកសារនោះពុំមានតម្លៃជាភស្តុតាងដើម្បីបញ្ជាក់អង្គហេតុខ្ចីប្រាក់ពី A របស់ B ទេ ។ ហេតុនេះហើយ ចំពោះឯកសារ ជាបឋម សមត្ថភាព/អំណាចជាទម្រង់នៃភស្តុតាង គឺជាបញ្ហា ហើយប្រសិនបើមានការទទួលស្គាល់នូវសមត្ថភាព/អំណាចជាទម្រង់នៃភស្តុតាងនោះ ទើបបន្ទាប់មក អាចគិតអំពីបញ្ហាទាក់ទងនឹងសមត្ថភាព/អំណាចជាសារធាតុនៃភស្តុតាងថាតើខ្លឹមសារនៃការសរសេរនៅក្នុងឯកសារនោះ មានប្រយោជន៍ក្នុងការបញ្ជាក់អង្គហេតុនោះ ឬទេ ។

ដើម្បីទទួលស្គាល់ថា ឯកសារមួយមានសមត្ថភាព/អំណាចជាទម្រង់នៃភស្តុតាង ទាល់តែឯកសារនោះជាឯកសារដែលត្រូវបានបង្កើតឡើងត្រឹមត្រូវ ។ ភាពត្រឹមត្រូវក្នុងការបង្កើតឯកសារ មានន័យថា ឯកសារនោះត្រូវបានបង្កើតឡើងដោយជនជាក់លាក់ ដូចដែលបានអះអាងដោយភាគីដែលបានស្នើសុំឱ្យពិនិត្យភស្តុតាងនោះ ។ ក្នុងករណីឧទាហរណ៍ខាងលើនេះគឺ ប្រសិនបើ A បានអះអាងថា B ជាអ្នកធ្វើឯកសារនេះ ហើយបានស្នើសុំឱ្យពិនិត្យភស្តុតាង ពេលណាទទួលស្គាល់ថាជាឯកសារដែលធ្វើឡើងដោយ B មែន អាចនិយាយថា ជាឯកសារដែលបានធ្វើឡើងត្រឹមត្រូវ ។ ដូច្នេះ ក្នុងករណីដែលចង់ធ្វើការបញ្ជាក់នូវអង្គហេតុកំណត់មួយតាមរយៈឯកសារទីមួយ ទាល់តែត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើងដោយផ្អែកលើឆន្ទៈរបស់ជនជាក់លាក់

មានន័យថា ត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើងត្រឹមត្រូវ (មាត្រា ១៩៥ កថាខណ្ឌទី ១) ។ ស្តីពីការបញ្ជាក់នូវភាពត្រឹមត្រូវនៃការបង្កើតឯកសារវិញ ដូចដែលបានពន្យល់ខាងក្រោមនេះ គឺឯកសារអាចចែកជាពីរប្រភេទ គឺឯកសារសាធារណៈ និង ឯកសារឯកជន ហើយត្រូវបានបញ្ញត្តិខុសគ្នា ទៅតាមប្រភេទនៃឯកសារនោះ ។

(៣) ប្រភេទនៃឯកសារ

(ក) ឯកសារសាធារណៈ និង ឯកសារឯកជន

ឯកសារដែលធ្វើឡើងដោយមន្ត្រីរាជការក្នុងការបំពេញមុខនាទីរបស់ខ្លួន ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន (ឧទាហរណ៍ដូចជា មូលសាលក្រម, កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់, ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃបញ្ជីអត្រានុកូលដ្ឋាន, ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ នៃសៀវភៅគោលបញ្ជីដីធ្លី ជាអាទិ៍) គឺជាឯកសារសាធារណៈ ហើយឯកសារក្រៅពីនេះ គឺជាឯកសារឯកជន ។ ចំពោះឯកសារសាធារណៈ បើទទួលស្គាល់តាមទម្រង់ និង ខ្លឹមសារនៃឯកសារនោះ ថា ឯកសារនោះត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទី ភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះ ត្រូវបានសន្មត (មាត្រា ១៩៥ កថាខណ្ឌទី ២) ហេតុនេះហើយ អ្នកស្នើសុំឱ្យពិនិត្យឯកសារនោះ មិនចាំបាច់ធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះទេ (ក្នុងករណីដែលមានការសង្ស័យអំពីភាពត្រឹមត្រូវក្នុងការបង្កើតឯកសារសាធារណៈ សូមមើលមាត្រា ១៩៥ កថាខណ្ឌទី ៣) ។ ផ្ទុយទៅវិញ ចំពោះឯកសារឯកជន ចាំបាច់ត្រូវធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះ ក៏ប៉ុន្តែ ប្រសិនបើនៅក្នុងឯកសារឯកជននោះ មានហត្ថលេខារបស់សាមីខ្លួន ឬរបស់អ្នកតំណាង (អ្នកដែលបានធ្វើឯកសារ) ភាពត្រឹមត្រូវក្នុងការបង្កើតឯកសារនោះ ត្រូវបានសន្មត (មាត្រា ១៩៥ កថាខណ្ឌទី ៤) ។ ដូច្នេះហើយ ភាគីម្ខាងទៀតដែលធ្វើវិវាទអំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារឯកជនបែបនេះ ចាំបាច់ត្រូវធ្វើការបញ្ជាក់ថា ឯកសារនោះត្រូវបានបង្កើតឡើង ដោយខុសពីឆន្ទៈរបស់អ្នកដែលបានធ្វើឯកសារ ។

(ខ) ឯកសារចាត់ចែង និង ឯកសាររបាយការណ៍

ក្នុងករណីដែលសកម្មភាពគតិយុត្ត ជាដើម ដោយឯកសារ (ដូចជា មតកសាសន៍ រូបិយាណត្តិ លិខិតកិច្ចសន្យា ជាដើម) ឯកសារនោះត្រូវហៅថាជាឯកសារចាត់ចែង ។ ឯកសារក្រៅពីនេះ ដូចជាវិក័យប័ត្រ សំបុត្រពេទ្យ សំបុត្រ កំណត់ប្រចាំថ្ងៃ កំណត់ហេតុ ជាដើម ដែលមានសរសេរអំពីការយល់ដឹងស្តីពីអង្គហេតុ ការវិនិច្ឆ័យ មនោគមវិជ្ជា ចំណាប់អារម្មណ៍ ជាដើម របស់អ្នកធ្វើឯកសារ គេហៅថា ឯកសាររបាយការណ៍ ។ ចំពោះឯកសារចាត់ចែង ប្រសិនបើបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះហើយ សកម្មភាពគតិយុត្ត ដែលជាខ្លឹមសារនៅក្នុងឯកសារនោះ ក៏ត្រូវបានបញ្ជាក់ថា ត្រូវបានធ្វើឡើងដែរ ។ ចំពោះឯកសាររបាយការណ៍វិញ ទោះជាបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះក៏ដោយ ក៏សមត្ថភាព/អំណាច

ជាសារធាតុនៃភស្តុតាង មានការខុសគ្នាទៅតាមខ្លឹមសារនៃការសរសេរក្នុងឯកសារនោះ ។

(គ) ច្បាប់ដើម (ឯកសារដើម) ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់

ច្បាប់ដើម (ឯកសារដើម) គឺមានន័យថា ជាសំណៅដើម ឬ ឯកសារពិត ។ រីឯឯកសារចម្លងដែលមានសេចក្តីបញ្ជាក់វិញ គឺជាឯកសារដែលបានចម្លងតាមខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម) ទាំងស្រុងតែម្តង ហើយដែលជាឯកសារបញ្ជាក់អំពីអត្ថិភាព ព្រមទាំងខ្លឹមសារនៃច្បាប់ដើម (ឯកសារដើម) នោះ ។ រីឯឯកសារចម្លងយថាភូតវិញ គឺជាឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ដែលបានធ្វើឡើងដើម្បីឱ្យមានអានុភាពតាមផ្លូវច្បាប់ ដូចច្បាប់ដើម (ឯកសារដើម) ដែរ ។ ឧទាហរណ៍ ក្នុងការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតដែលមានអានុភាពអនុវត្ត នៃលិខិតអនុវត្តផងដែរ (មាត្រា ៣៤៩ កថាខណ្ឌទី ២) ។

៦. ការត្រួតពិនិត្យ

ការត្រួតពិនិត្យ (មាត្រា ១៦១) គឺជាការពិនិត្យភស្តុតាងដើម្បីទទួលបាននូវធនធានភស្តុតាង ដោយការត្រួតពិនិត្យនូវភិនភាគ ឬ បាតុភូតនៃវត្ថុដោយផ្ទាល់ ដោយចៅក្រម ដោយប្រើវិញ្ញាណប្រាំរបស់ខ្លួន (ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, កាយវិញ្ញាណ, ឃានវិញ្ញាណ, ជិវ្ហាវិញ្ញាណ) ហើយវត្ថុ ឬ មនុស្ស ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យនោះ គេហៅថា វត្ថុដែលត្រូវត្រួតពិនិត្យ ។

## កថាភាគទី ៧ នីតិវិធីថែរក្សាការពារភស្តុតាង

១. ភាពចាំបាច់នៃការថែរក្សាការពារភស្តុតាង

ការពិនិត្យភស្តុតាង ជាគោលការណ៍ គឺត្រូវធ្វើឡើងនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ បន្ទាប់ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ ក៏ប៉ុន្តែ ក្នុងករណីពិសេសដែលប្រសិនបើចាំឱ្យដល់ដំណាក់កាលនោះទៅ នឹងអាចមានការមិនអាច ឬ មានការពិបាកនឹងពិនិត្យភស្តុតាងបាន ។ ឧទាហរណ៍ អាចមានករណីដែលជនដែលនឹងក្លាយជាសាក្សី អាចទទួលមរណភាព ដោយសារមានជម្ងឺធ្ងន់ ឬ គ្រោះថ្នាក់ ឬ អាចមានករណីដែលជននោះនឹងចេញទៅបរទេស ឬ ករណីដែលអាចមានការលួចកែឯកសារ ឬ អាចមានការផ្លាស់ប្តូរស្ថានភាពនៃកន្លែងដែលត្រូវធ្វើការត្រួតពិនិត្យ ជាដើម ។ ក្នុងករណីដូចនេះ ចាំបាច់ត្រូវធ្វើការពិនិត្យភស្តុតាងជាមុន ដើម្បីរក្សាលទ្ធផលនោះ ហើយនេះគឺជានីតិវិធីថែរក្សាការពារភស្តុតាង (មាត្រា ១៦៣ កថាខណ្ឌទី ១) ។

នីតិវិធីថែរក្សាការពារភស្តុតាង គឺជានីតិវិធីឯករាជ្យពីបណ្តឹងដែលមាននោះ ទោះជាបានធ្វើក្រោយពីការដាក់ពាក្យបណ្តឹងក៏ដោយ ។ បណ្តឹងដើមដែលត្រូវការប្រើភស្តុតាងដែលបានរក្សាការពារនេះ ក្នុងនីតិវិធីនេះ គេហៅថា បណ្តឹងអង្គសេចក្តី (មាត្រា ១៦៣ កថាខណ្ឌទី ២ និង ទី ៣, មាត្រា ១៧២) ។

## ២. ការចាប់ផ្តើមនីតិវិធី

(១) នីតិវិធីថែរក្សាការពារភស្តុតាងអាចចាប់ផ្តើមមុនពេលដាក់ពាក្យបណ្តឹងក៏បាន ក្រោយពេលដាក់ពាក្យបណ្តឹង តែមុនពេលដល់ដំណាក់កាលនៃការពិនិត្យភស្តុតាងក៏បាន ។ ជាគោលការណ៍ នីតិវិធីនេះត្រូវចាប់ផ្តើមតាមពាក្យសុំរបស់ភាគី ប៉ុន្តែ ក្រោយពេលមានពាក្យបណ្តឹង ប្រសិនបើយល់ឃើញថាមានការចាំបាច់ តុលាការអាចចាប់ផ្តើមដោយឆន្ទានុសិទ្ធិបាន (មាត្រា ១៦៧) ។

ពាក្យសុំស្តីពីនីតិវិធីថែរក្សាការពារភស្តុតាង ដែលបានដាក់មុនពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើទៅសាលាដំបូងដែលមានសមត្ថកិច្ចនៅទីសំណាក់របស់បុគ្គលដែលត្រូវទទួលនូវការសាកសួរ ឬ របស់បុគ្គលដែលជាម្ចាស់ឯកសារ ឬ នៅទីកន្លែងដែលមានវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ (មាត្រា ១៦៤ កថាខណ្ឌទី ២) ។ ពាក្យសុំស្តីពីនីតិវិធីថែរក្សាការពារភស្តុតាង ដែលបានដាក់ក្រោយពេលដាក់ពាក្យបណ្តឹង ជាគោលការណ៍ត្រូវធ្វើទៅតុលាការនៃលំដាប់ថ្នាក់ដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់ (មាត្រា ១៦៤ កថាខណ្ឌទី ១) ។ តុលាការដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់ គឺជាសាលាដំបូង ក្នុងករណីមុនពេលចេញសាលក្រម ទោះជាបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក្នុងការជំនុំជម្រះលើកទីមួយហើយក៏ដោយ ពីព្រោះអាចមានការទាញហេតុផលសាជាថ្មីឡើងវិញ ហើយប្រើភស្តុតាងនោះ (មាត្រា ១៨០ កថាខណ្ឌទី ៣) ហើយជាសាលាឧទ្ធរណ៍ ក្នុងករណីក្រោយចេញសាលក្រម ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការចាំបាច់ធ្វើការពិនិត្យភស្តុតាងជាបន្ទាន់ ទោះជានៅក្រោយពេលបានដាក់ពាក្យបណ្តឹងក៏ដោយ ក៏អាចដាក់ពាក្យសុំឱ្យថែរក្សាការពារភស្តុតាងទៅសាលាដំបូងដែលបានកំណត់ក្នុងមាត្រា ១៦៤ កថាខណ្ឌទី ២ បានដែរ (មាត្រា ១៦៤ កថាខណ្ឌទី ៣) ។

(២) ពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (មាត្រា ១៦៥ កថាខណ្ឌទី ១) ។ ក្នុងពាក្យសុំនោះ ត្រូវសរសេរអំពីចំណុចដែលមានចែងក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ២ មាត្រា ១៦៥ ។ ចំពោះមូលហេតុនៃការថែរក្សាការពារភស្តុតាង មានន័យថា ភាពចាំបាច់នៃការថែរក្សាការពារភស្តុតាង ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង (មាត្រា ១៦៥ កថាខណ្ឌទី ៣) ។ ចំពោះដីកាសម្រេចលើកចោលនូវពាក្យសុំនោះ អ្នកដាក់ពាក្យសុំអាចប្តឹងជំទាស់បាន (មាត្រា ១៦៨) ។

ពេលដាក់ពាក្យសុំថែរក្សាការពារភស្តុតាង មុនការដាក់ពាក្យបណ្តឹង អាចមានករណីដែលមិនដឹងថា អ្នកណាត្រូវជាភាគីម្ខាងទៀត ។ ឧទាហរណ៍ ពេលដែលជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍បានដាក់ពាក្យសុំឱ្យថែត្រួតពិនិត្យកន្លែងកើតគ្រោះថ្នាក់ចរាចរណ៍ក្នុងនាមជាការថែរក្សាការពារភស្តុតាង អាចមានករណីដែលមិនទាន់ដឹងច្បាស់ថា អ្នកណាជាចារី ។ ក្នុងករណីនេះ អាចដាក់ពាក្យបណ្តឹងដោយមិនចាំបាច់កំណត់ថា អ្នកណាជាភាគីម្ខាងទៀតបាន ហើយតុលាការអាចជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀតបាន (មាត្រា ១៦៦) ។ ក្នុងករណីនេះ តុលាការត្រូវឱ្យអ្នកដាក់ពាក្យសុំ ធ្វើការបញ្ជាក់ដំបូងអំពីការ

ដែលមិនអាចកំណត់ថា អ្នកណាជាភាគីម្ខាងទៀត ហើយត្រូវឱ្យអ្នកដាក់ពាក្យសុំនោះបង់ប្រាក់កម្រៃសម្រាប់អ្នកតំណាងពិសេសនោះជាមុន ។

៣. ការធ្វើការពិនិត្យភស្តុតាង

ជាគោលការណ៍ ការធ្វើការពិនិត្យភស្តុតាងនេះ ត្រូវធ្វើដូចនីតិវិធីពិនិត្យភស្តុតាងធម្មតាដែរ ( មាត្រា ១៦៣ កថាខណ្ឌទី ១) ។ នៅកាលបរិច្ឆេទនៃការពិនិត្យភស្តុតាង ត្រូវកោះហៅអ្នកដាក់ពាក្យសុំ និង ភាគីម្ខាងទៀត ។ ក្នុងករណីដែលមានការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់ជនដែលនឹងក្លាយជាភាគីម្ខាងទៀត ត្រូវកោះហៅអ្នកតំណាងពិសេសនោះ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានភាពបន្ទាន់ តុលាការអាចធ្វើការពិនិត្យភស្តុតាងដោយមិនចាំបាច់កោះហៅជនទាំងនោះក៏បានដែរ ( មាត្រា ១៦៩) ។ ពេលធ្វើការពិនិត្យភស្តុតាង ត្រូវធ្វើកំណត់ហេតុស្តីពីការពិនិត្យភស្តុតាងនោះ ។

៤. ការប្រើលទ្ធផលនៃការពិនិត្យភស្តុតាង

លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារនេះ មានអានុភាពជាភស្តុតាង នៅក្នុងបណ្តឹងអង្គសេចក្តី ( មាត្រា ១៦៣ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការពិនិត្យភស្តុតាងនោះ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងអង្គសេចក្តី ( មាត្រា ១៦៣ កថាខណ្ឌទី ៣) ។ នេះគឺដើម្បីបង្ហាញលទ្ធផលនៃការពិនិត្យភស្តុតាងដែលបានធ្វើក្នុងនីតិវិធីថែរក្សាការពារភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយយកលទ្ធផលនោះមកធ្វើជាមូលដ្ឋាននៃសាលក្រម ដោយចាត់ទុកថា មានអានុភាពដូចគ្នានឹងសកម្មភាពដែលបានធ្វើឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ដែរ ( មានគោលបំណងដូចគ្នានឹងសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលបានកំណត់នៅក្នុងមាត្រា ១១៦ កថាខណ្ឌទី ១) ។ ពេលចាប់ផ្តើមចាត់ការបណ្តឹងអង្គសេចក្តី តុលាការដែលបានធ្វើការពិនិត្យភស្តុតាង ត្រូវផ្ញើកំណត់ហេតុស្តីពីការពិនិត្យភស្តុតាងទៅតុលាការនៃបណ្តឹងអង្គសេចក្តី ( មាត្រា ១៧២) ។ លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារ នៅតែមានអានុភាពទោះជាក្រោយពេលនោះ អាចធ្វើការពិនិត្យភស្តុតាងនោះនៅក្នុងបណ្តឹងអង្គសេចក្តីក៏ដោយ ក៏ប៉ុន្តែ ក្នុងករណីដែលបានធ្វើការសាកសួរសាក្សីនៅក្នុងនីតិវិធីនៃការថែរក្សាការពារភស្តុតាង ប្រសិនបើមានការស្នើសុំពីភាគី តុលាការត្រូវធ្វើការសាកសួរសាក្សីនោះម្តងទៀត នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ( មាត្រា ១៧១) ។ សោហ៊ុយនៃការថែរក្សាការពារភស្តុតាង គឺជាមួយភាគនៃប្រាក់ប្រដាប់ក្តីនៃបណ្តឹងអង្គសេចក្តី ។

## ផ្នែកទី ៤ កាលបរិច្ឆេទ អំឡុងពេល ការបញ្ជូន

### កថាភាគទី ១ កាលបរិច្ឆេទ

១. អត្ថន័យនៃកាលបរិច្ឆេទ

កាលបរិច្ឆេទគឺជាពេលវេលាដែលត្រូវបានកំណត់ដើម្បីធ្វើសកម្មភាពទាក់ទងនឹងបណ្តឹង ដោយមានការចូលរួមរបស់ភាគី និង ជនដទៃទៀតដែលមានទំនាក់ទំនងនឹងបណ្តឹង ។ តុលាការជាអ្នកដឹកនាំនីតិវិធីបណ្តឹងដោយកំណត់អំពីកាលបរិច្ឆេទបើកធ្វើការជំនុំជម្រះ និង អំពីខ្លឹមសារនៃសកម្មភាពជំនុំជម្រះក្នុងកាលបរិច្ឆេទនីមួយៗ ហើយម្យ៉ាងទៀត ក៏មានការកម្រិតយ៉ាងតឹងរ៉ឹងមិនឱ្យភាគីប្តូរនូវកាលបរិច្ឆេទដែលតុលាការបានកំណត់ទៅតាមកាលៈទេសៈរបស់ខ្លួន ។ នេះគេហៅថា គោលការណ៍ដឹកនាំនីតិវិធីដោយឆន្ទានុសិទ្ធិ ។ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គេបានជ្រើសរើសគោលការណ៍ដឹកនាំនីតិវិធីដោយឆន្ទានុសិទ្ធិនេះ គឺដោយសារដើម្បីសម្រេចនូវការដឹកនាំបណ្តឹងមួយឱ្យបានលឿន និង ឱ្យមានប្រសិទ្ធិភាពល្អ ។

២. ការកំណត់កាលបរិច្ឆេទ

ជាគោលការណ៍ តុលាការត្រូវកំណត់កាលបរិច្ឆេទ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ (មាត្រា ២៤០ កថាខណ្ឌទី ១) ។ ការកំណត់កាលបរិច្ឆេទ ត្រូវធ្វើ ដោយបង្ហាញឱ្យបានច្បាស់លាស់អំពីទីកន្លែង ថ្ងៃ-ខែ-ឆ្នាំ និង ពេលវេលា ។ តាមធម្មតា ត្រូវកំណត់ពេលវេលាក្រៅពីថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សំរាកផ្សេងទៀត លើកលែងតែក្នុងករណីដែលមិនអាចជៀសវាងបាន (មាត្រា ២៤០ កថាខណ្ឌទី ២) ។ សកម្មភាពបណ្តឹងដែលធ្វើឡើងនៅពេលដែលមិនត្រូវបានកំណត់ជាកាលបរិច្ឆេទ គ្មានមានអានុភាព ។

៣. ការប្តូរកាលបរិច្ឆេទ

ការប្តូរកាលបរិច្ឆេទ គឺជាការលុបចោលនូវដីកាសម្រេចស្តីពីការកំណត់កាលបរិច្ឆេទមួយ ហើយកំណត់កាលបរិច្ឆេទមួយផ្សេងទៀត មុនពេលចាប់ផ្តើមកាលបរិច្ឆេទដែលបានកំណត់មុន ។ ក្នុងករណីដែលបានបើកធ្វើសកម្មភាពបណ្តឹងតាមកាលបរិច្ឆេទហើយ តែមិនបានចប់សព្វគ្រប់ ហើយពេលនោះ តុលាការបានកំណត់កាលបរិច្ឆេទមួយផ្សេងទៀត ដើម្បីបន្តសកម្មភាពបណ្តឹងនោះ នេះគេហៅថា ការបន្តកាលបរិច្ឆេទ ហើយនេះខុសពីការប្តូរកាលបរិច្ឆេទ ។ ប្រសិនបើមានការប្តូរកាលបរិច្ឆេទដែលបានកំណត់ម្តងរួចទៅហើយ ឱ្យបានងាយស្រួល នោះសាលសវនាការដែលតុលាការបានរៀបចំត្រៀមទុកជាមុន ព្រមទាំងមន្ត្រីធ្វើការងារពាក់ព័ន្ធដែលត្រៀមនោះ នឹងក្លាយទៅជាអត់ប្រយោជន៍ ហើយនឹងធ្វើឱ្យរំខានដល់ភាគី ឬ ដល់ជនដែលមានទំនាក់ទំនងដទៃទៀត ដូច្នេះហើយ ល័ក្ខខ័ណ្ឌដើម្បីប្តូរនេះត្រូវបានកំណត់ទៅតាមដំណាក់កាលនីមួយៗនៃបណ្តឹង ។

ល័ក្ខខ័ណ្ឌដើម្បីប្តូរកាលបរិច្ឆេទដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនជាតឹងតែងទេ ហើយទោះជាពុំមានមូលហេតុពិសេសក៏ដោយ ឱ្យតែមានការព្រមព្រៀងពីភាគី គឺអាចប្តូរបាន (មាត្រា ២៤១ កថាខណ្ឌទី ៣) ។ នេះគឺដោយសារតែកាលបរិច្ឆេទដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានកំណត់ដោយមិនគិតដល់កាលៈទេសៈរបស់ភាគី ។ ផ្ទុយទៅវិញ កាលបរិច្ឆេទក្រោយពីនេះ ប្រសិនបើពុំមានមូលហេតុដែលមិនអាចជៀសវាងបានទេ មិនអនុញ្ញាតឱ្យប្តូរឡើយ (មាត្រា ២៤១ កថាខណ្ឌទី ២) ។ នេះគឺដោយសារតែកាលបរិច្ឆេទក្រោយពីនេះ ត្រូវបានកំណត់ដោយមានការពិចារណាអំពីមតិរបស់ភាគី ព្រមទាំង

ដំណើរការនៃបណ្តឹង ។

## កថាភាគទី ២ អំឡុងពេល

### ១. អត្ថន័យនៃអំឡុងពេល

អំឡុងពេល គឺជាដំណើរការនៃពេលវេលាកំណត់មួយ ។ អំឡុងពេលមានពីរប្រភេទ គឺ អំឡុងពេលដែលត្រូវបានកំណត់សម្រាប់សកម្មភាពបណ្តឹងដែលធ្វើដោយតុលាការ និង អំឡុងពេលត្រូវបានកំណត់សម្រាប់សកម្មភាពរបស់ភាគី ឬ អ្នកដទៃទៀតដែលមានទំនាក់ទំនង ។ ចំពោះករណីនៃអំឡុងពេលសម្រាប់សកម្មភាពរបស់តុលាការ ទោះជាសកម្មភាពរបស់តុលាការត្រូវបានធ្វើហួសអំឡុងពេលនោះក៏ដោយ ក៏ភាពខុសច្បាប់ពុំកើតមានឡើងទេ ក៏ប៉ុន្តែ ចំពោះករណីនៃអំឡុងពេលសម្រាប់សកម្មភាពរបស់ភាគី ឬ អ្នកដទៃទៀតវិញ បើមិនបានធ្វើសកម្មភាពកំណត់មួយ ក្នុងអំឡុងពេលដែលបានកំណត់នោះទេ នឹងមានការខូចប្រយោជន៍ ដោយសារតែបាត់បង់នូវឱកាសធ្វើសកម្មភាពនោះ ជាដើម ។ ឧទាហរណ៍នៃករណីទីមួយមានដូចជា កាលបរិច្ឆេទនៃការប្រកាសសាលក្រម (មាត្រា ១៨៧) ជាអាទិ៍ រីឯករណីទីពីរវិញមានដូចជា អំឡុងពេលកែតម្រូវពាក្យបណ្តឹង (មាត្រា ៧៨) អំឡុងពេលដាក់ឯកសារត្រៀម (មាត្រា ១០២) អំឡុងពេលប្តឹងឧទ្ធរណ៍ (មាត្រា ២៦៤) ជាដើម ។

### ២. ការគណនានៃអំឡុងពេល

ការគណនានៃអំឡុងពេល ត្រូវអនុលោមទៅតាមបញ្ញត្តិស្តីពីអំឡុងពេលនៃក្រមរដ្ឋប្បវេណី (មាត្រា ២៤៣ កថាខណ្ឌទី ១) ។ ជាគោលការណ៍ មិនត្រូវរាប់បញ្ចូលថ្ងៃដំបូង ក្នុងការគណនាអំឡុងពេលនោះទេ (មាត្រា ៣៣១ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ប្រសិនបើថ្ងៃចុងក្រោយនៃអំឡុងពេល ត្រូវជាថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀត អំឡុងពេលត្រូវចប់នាថ្ងៃបន្ទាប់នៃថ្ងៃនោះ (មាត្រា ២៤៣ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ស្តីពីអំឡុងពេលប្តឹងឧទ្ធរណ៍ ប្រសិនបើការបញ្ជូនមូលសាលក្រមត្រូវបានធ្វើនៅថ្ងៃទី ១ ខែ មេសា អំឡុងពេលនឹងចាប់ផ្តើមមានដំណើរការពីថ្ងៃបន្ទាប់ គឺថ្ងៃទី ២ ខែ មេសា ហើយអំឡុងពេលនោះនឹងត្រូវចប់មួយខែក្រោយ គឺនៅពេលដែលផុតថ្ងៃទី ១ ខែ ឧសភា តែប្រសិនបើថ្ងៃទី ១ ខែ ឧសភា ត្រូវជាថ្ងៃសៅរ៍ អំឡុងពេលនេះនឹងត្រូវចប់នៅពេលផុតថ្ងៃទី ៣ ខែ ឧសភា ទៅវិញ ។

### ៣. ការពន្យារអំឡុងពេល

តុលាការអាចធ្វើការពន្យារពេលនៃអំឡុងពេលដែលច្បាប់បានកំណត់ ឬ ដែលខ្លួនបានកំណត់បានតែក្នុងករណីដែលមានការមិនអាចជៀសវាងបាន (មាត្រា ២៤៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ករណីដែលមិនអាចជៀសវាងបាន គឺ ឧទាហរណ៍ដូចជា ក្រោយពីការកំណត់នូវអំឡុងពេលដាក់ឯកសារត្រៀមចំពោះចុងចម្លើយ មានការផ្លាស់ប្តូរនូវចំណុចវិវាទសំខាន់ៗដោយសារតែដើមចោទបានបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុ

បណ្ដឹងនោះ ជាដើម ។ ក៏ប៉ុន្តែ ក្នុងករណីដែលអំឡុងពេលនោះត្រូវបានកំណត់ពិសេសដោយច្បាប់ ដូចជាអំឡុងពេលនៃការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាដើម ( មាត្រា ២៦៤, មាត្រា ២៨៦) មិនអាចទទួលស្គាល់នូវការពន្យារនៃអំឡុងពេលនោះបានទេ ( មាត្រា ២៤៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

៤. ការបំពេញសកម្មភាពបណ្ដឹងនៅពេលក្រោយ

ទោះជាក្នុងករណីដែលមិនអនុញ្ញាតឱ្យពន្យារអំឡុងពេល ដូចដែលមានចែងក្នុងមាត្រា ២៤៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ក៏ដោយ ប្រសិនបើភាគីមិនអាចគោរពតាមអំឡុងពេលនោះ ដោយគ្មានកំហុសទេ ចាំបាច់ត្រូវមានវិធីសង្គ្រោះផ្សេង ។ ដូច្នេះ បានជាមានរបបបំពេញសកម្មភាពបណ្ដឹងនៅពេលក្រោយ ( មាត្រា ២៤៥) ។ ឧទាហរណ៍ ក្នុងករណីដែលមិនអាចធ្វើបណ្ដឹងឧទ្ធរណ៍បាន ពីព្រោះមានការយឺតយ៉ាវនៃសំបុត្រដែលផ្ញើតាមប៉ុស្តិ៍ ដោយសារភ្លៀងខ្យល់ខ្លាំងពេក ភាគីអាចធ្វើបណ្ដឹងឧទ្ធរណ៍បាន ក្នុងអំឡុងពេលមួយសប្ដាហ៍ ក្រោយពីភ្លៀងខ្យល់នោះរាំង ( មាត្រា ២៤៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក្នុងករណីដែលភាគីនៅបរទេស អំឡុងពេលនេះគឺ ២ ខែ ( មាត្រា ២៤៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

## កថាភាគទី ៣ ការបញ្ជូន

១. អត្ថន័យនៃការបញ្ជូន

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្ដឹង ចំពោះភាគី និង អ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ។ ការទទួលនូវការបញ្ជូន គឺជាការដាក់ខ្លួនក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការ ហេតុនេះហើយ ការធ្វើការបញ្ជូន ចំពោះជនដែលមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្ដីរបស់តុលាការកម្ពុជា មិនអាចធ្វើបានទេ លើកលែងតែក្នុងករណីដែលជននោះយល់ព្រមទទួលការបញ្ជូនដោយស្ម័គ្រចិត្ត ។ ការបញ្ជូននេះ ត្រូវបានភ្ជាប់នូវអានុភាពគតិយុត្តផ្សេងៗទៀត ។ មានដូចជា តាមរយៈការបញ្ជូននេះ អំឡុងពេលដែលអាចប្ដឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់បាន នឹងចាប់ផ្ដើមមានដំណើរការ ( មាត្រា ២៦៤, មាត្រា ២៨៦) ។ ការបញ្ជូននេះត្រូវបានបែងចែកដាច់ពីការជូនដំណឹងធម្មតាត្រង់ចំណុចស្ដីពីវិធី ឬ ស្ដីពីអានុភាពទាំងនេះ ។

២. ស្ថាប័នដែលធ្វើការបញ្ជូន

ស្ថាប័នដែលធ្វើការបញ្ជូន គឺមាន មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន និង មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ។ មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន គឺក្រឡាបញ្ជី ( មាត្រា ២៤៦ កថាខណ្ឌទី ២) ។ មុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន គឺការធ្វើ ឬ ការផ្ដល់សេចក្ដីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូន ហើយប្រគល់អំណាចនៃការបញ្ជូនឯកសារនោះទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ហើយបន្ទាប់មក ទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ក្រោយការប្រតិបត្តិ ហើយធ្វើ

ការរក្សារបាយការណ៍នោះជាមួយនឹងសំណុំរឿង ជាដើម ។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន មានដូចជា មន្ត្រីប៉ុស្តិ៍ប្រៃសនីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី ជាដើម (មាត្រា ២៤៦ កថាខណ្ឌទី ៣) ។ មុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺការបញ្ជូនជាក់លាក់ចំពោះជនដែលត្រូវទទួល ការធ្វើរបាយការណ៍អំពីការបញ្ជូន (មាត្រា ២៥៤) ហើយដាក់របាយការណ៍នោះទៅតុលាការ ជាដើម ។ ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លង (មាត្រា ២៤៧ កថាខណ្ឌទី ២) លើកលែងតែករណីដែលបានកំណត់ពិសេសដោយច្បាប់ ។

៣. ការបញ្ជូនដោយការប្រគល់

ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើតាមវិធីប្រគល់ឯកសារទៅឱ្យជនដែលត្រូវទទួលនូវការបញ្ជូន ហើយនេះគេហៅថា ការបញ្ជូនដោយការប្រគល់ (មាត្រា ២៤៧ កថាខណ្ឌទី ១) ។ ជាគោលការណ៍ ទីកន្លែងដែលត្រូវធ្វើការបញ្ជូនដោយការប្រគល់ គឺលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន (មាត្រា ២៤៩) ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវទទួលការបញ្ជូន (មាត្រា ២៥០ កថាខណ្ឌទី ១) ត្រូវធ្វើការបញ្ជូនទៅទីកន្លែងដែលបានជូនដំណឹងនោះ (មាត្រា ២៥០ កថាខណ្ឌទី ៤) ។ បែបផែនពិសេសនៃការបញ្ជូនដោយប្រគល់ មានដូចខាងក្រោមនេះ :

(១) ការបញ្ជូនដោយការជួបប្រទះ

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ពុំច្បាស់លាស់ថា មានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ នៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលបានជួបជននោះបាន លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូននោះ ។ម្យ៉ាងទៀត ទោះបីជាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការច្បាស់លាស់ នៅក្នុងប្រទេសកម្ពុជា ឬ មានការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏អាចធ្វើការបញ្ជូននៅទីកន្លែងដែលបានជួបប្រទះជននោះបានដែរ ប្រសិនបើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូនទេ ។ នេះគេហៅថា ការបញ្ជូនដោយការជួបប្រទះ (មាត្រា ២៥១) ។

(២) ការបញ្ជូនដោយបង្គ្រប់កិច្ច

ប្រសិនបើមិនបានជួបជនដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូនទេ អាចប្រគល់ឯកសារនោះទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន ។ នេះគេហៅថា ការបញ្ជូនដោយបង្គ្រប់កិច្ច (មាត្រា ២៥២ កថាខណ្ឌទី ១) ។

(៣) ការបញ្ជូនដោយទុកចោល

ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ ជនដែលត្រូវទទួលការបញ្ជូនដោយការបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូននោះ ដោយគ្មានមូលហេតុត្រឹមត្រូវទេ អាចទុកឯកសារដែលបានបញ្ជូននោះចោលនៅទីកន្លែងនោះបាន ហើយកិច្ចការនេះមានអានុភាពជាការបញ្ជូនដែរ ។ នេះគេហៅថា ការបញ្ជូនដោយការទុកចោល

( មាត្រា ២៥២ កថាខណ្ឌទី ២) ។

៤. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ក្នុងករណីដែល ទោះបីជាបានខំប្រឹងប្រែងស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏មិនអាចដឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬ ក្នុងករណីដែលមិនអាចធ្វើការបញ្ជូនទៅបរទេសដោយការប្រគល់កិច្ចការ ជាដើម ដែលជាករណីដែលគ្មានវិធីអ្វីផ្សេងទៀតសម្រាប់ធ្វើការបញ្ជូនទេ ជាទីបញ្ចប់ អាចទទួលស្គាល់ឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន ( មាត្រា ២៥៥) ។ ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយវិធីដែលក្រឡាបញ្ជីបិទប្រកាសនៅទីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ ឬ ទីកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប ដែលប្រកាសថា ក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលធ្វើការបញ្ជូន ហើយអាចប្រគល់ឯកសារនោះឱ្យជនដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បានដែរ ( មាត្រា ២៥៦ កថាខណ្ឌទី ១ និង ទី ២) ។ លើសពីនេះ តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ ( មាត្រា ២៥៦ កថាខណ្ឌទី ៣) ។

ការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ ជាគោលការណ៍ ត្រូវធ្វើដោយក្រឡាបញ្ជីតុលាការ តាមពាក្យសុំរបស់ភាគី ( មាត្រា ២៥៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ គឺជារបបចាំបាច់មួយ ដើម្បីឱ្យដើមចោទអាចធ្វើបណ្តឹង ទោះជាក្នុងករណីដែលមិនបានដឹងឱ្យបានច្បាស់លាស់នូវលំនៅឋាន ជាដើម របស់ចុងចម្លើយក៏ដោយ ក៏ប៉ុន្តែ មិនមានការរំពឹងថា ជនដែលត្រូវទទួលនោះ អាចដឹងអំពីអង្គហេតុនៃការបញ្ជូននេះពិតប្រាកដទេ ដូច្នេះហើយ អាចមានករណីដែលដើមចោទខិលខូចប្រើរបបនេះ ក្នុងគោលគំនិតទុច្ចរិត ។ ហេតុនេះហើយ ត្រូវបកស្រាយល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ២៥៥ កថាខណ្ឌទី ១ ពីចំណុច ក ដល់ចំណុច ឃ ឱ្យបានប្រិតប្រៀន ។ ពេលដែលទទួលស្គាល់ថាចាំបាច់ ដើម្បីជៀសវាងនូវការយឺតយ៉ាវក្នុងដំណើរការនៃនីតិវិធី តុលាការអាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនដោយការផ្សាយជាសាធារណៈ ដោយឆន្ទានុសិទ្ធិបាន ( មាត្រា ២៥៥ កថាខណ្ឌទី ២) ។

ការបញ្ជូនដោយការផ្សាយជាសាធារណៈ នឹងមានអានុភាពជាការបញ្ជូន នៅក្រោយអំឡុងពេលពីរសប្តាហ៍កន្លងហួស ដោយគិតពីថ្ងៃដែលបានបិទប្រកាសនោះ ( មាត្រា ២៥៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ ការបញ្ជូនតាមការផ្សាយជាសាធារណៈពីលើកទីពីរទៅ នឹងមានអានុភាពពីថ្ងៃបន្ទាប់ពីការបិទប្រកាសនោះ ( មាត្រា ២៥៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

# ជំពូកទី ៣ ល័ក្ខខ័ណ្ឌបណ្ដឹង

## ផ្នែកទី ១ អត្ថន័យនៃល័ក្ខខ័ណ្ឌបណ្ដឹង

### កថាភាគទី ១ ល័ក្ខខ័ណ្ឌបណ្ដឹងដែលជាល័ក្ខខ័ណ្ឌមូលដ្ឋាននៃសាលក្រមនៃបណ្ដឹងអង្គសេចក្ដី

សាលក្រមដែលតុលាការបានវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ (ឬ ទំនាក់ទំនងគតិយុត្ត) ដែលដើមចោទអះអាងជាការទាមទារតាមផ្លូវបណ្ដឹង ដោយធ្វើការទទួលស្គាល់នូវការទាមទារ ឬ ច្រានចោលនូវការទាមទារ គេហៅថា សាលក្រមដែលសម្រេចអំពីអង្គសេចក្ដី ។ ដើម្បីចេញសាលក្រមដែលសម្រេចអំពីអង្គសេចក្ដី ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌជាកំណត់ ដូចជា សិទ្ធិជម្រះក្ដី សមត្ថកិច្ច ឬ សមត្ថភាពភាគី ជាដើម ។ បុរេល័ក្ខខ័ណ្ឌជាមូលដ្ឋានដែលចាំបាច់ដើម្បីចេញសាលក្រមដែលសម្រេចអំពីអង្គសេចក្ដី គេហៅថា "ល័ក្ខខ័ណ្ឌបណ្ដឹង" ។

ដើម្បីគ្រប់គ្រងរបបបណ្ដឹងឱ្យមានប្រសិទ្ធិភាពល្អ តុលាការមិនអាចយកវិវាទទាំងអស់ដែលកើតមានឡើងក្នុងជីវភាពសង្គម មកធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលអះអាងដោយដើមចោទទាំងអស់បានទេ ។ ហេតុនេះហើយ ត្រូវកម្រិតត្រឹមតែករណីដែលតុលាការពិតជាមានភាពចាំបាច់ត្រូវធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលអះអាងដោយដើមចោទ ។ ដើម្បីធ្វើដូច្នេះបាន ទាល់តែប្រើទស្សនៈស្ដីពីល័ក្ខខ័ណ្ឌបណ្ដឹង ។

### កថាភាគទី ២ ការចាត់ចែងក្នុងករណីដែលមានកង្វះល័ក្ខខ័ណ្ឌបណ្ដឹង

ល័ក្ខខ័ណ្ឌបណ្ដឹង គឺជាល័ក្ខខ័ណ្ឌដើម្បីចេញសាលក្រមដែលសម្រេចអំពីអង្គសេចក្ដី ដូច្នេះហើយ ទោះជាបណ្ដឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ក៏ជាគោលការណ៍ តុលាការត្រូវប្រយ័ត្នមើលថា តើស្របល័ក្ខខ័ណ្ឌបណ្ដឹងដែរឬទេ ដោយឆន្ទានុសិទ្ធិ ។ ទោះជាកំពុងធ្វើការវិនិច្ឆ័យអំពីអង្គសេចក្ដីក៏ដោយ ក្នុងករណីដែលបានដឹងថា មានកង្វះល័ក្ខខ័ណ្ឌបណ្ដឹងអ្វីមួយ តុលាការមិនត្រូវបន្តការវិនិច្ឆ័យអំពីអង្គសេចក្ដីនោះទេ គឺ ត្រូវចេញសាលក្រមលើកចោលបណ្ដឹងនោះ ។

## ផ្នែកទី ២ ប្រភេទនៃល័ក្ខខ័ណ្ឌបណ្ដឹង

### កថាភាគទី ១ ល័ក្ខខ័ណ្ឌសកម្ម និង ល័ក្ខខ័ណ្ឌអកម្ម

ល័ក្ខខ័ណ្ឌបណ្ដឹងមានពីរប្រភេទគឺ "អត្ថិភាពនៃល័ក្ខខ័ណ្ឌនោះគឺជាល័ក្ខខ័ណ្ឌបណ្ដឹង" និង "នត្ថិភាពនៃល័ក្ខខ័ណ្ឌនោះគឺជាល័ក្ខខ័ណ្ឌបណ្ដឹង" ។ ឧទាហរណ៍នៃល័ក្ខខ័ណ្ឌប្រភេទទីមួយ មានដូចជា សិទ្ធិជម្រះក្ដី សមត្ថកិច្ច

សមត្ថភាពភាគី ផលប្រយោជន៍ក្នុងការធ្វើបណ្តឹង ជាអាទិ៍ ។ រីឯឧទាហរណ៍នៃល័ក្ខខ័ណ្ឌប្រភេទទីពីរវិញ មានដូចជា ការចាត់ការបណ្តឹងផ្សេងអំពីរឿងក្តីតែមួយ អត្ថិភាពនៃកិច្ចសន្យាមជ្ឈត្តកម្មរវាងភាគី ជាដើម ។ ក្នុងករណីនៃល័ក្ខខ័ណ្ឌប្រភេទទីពីរវិញ ឧទាហរណ៍ ប្រសិនបើមានបណ្តឹងផ្សេងដែលកំពុងត្រូវបានចាត់ការ ចំពោះរឿងក្តីដដែល ឬ មានកិច្ចសន្យាមជ្ឈត្តកម្មរវាងភាគី បណ្តឹងនោះត្រូវបានលើកចោល ។

## កថាភាគទី ២ ល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចតវ៉ា

បន្ទាប់មក ល័ក្ខខ័ណ្ឌបណ្តឹងអាចចែកជាពីរ គឺល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចតវ៉ា ដែលជាការបែងចែកតាមភាពចាំបាច់ស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ ឬទេ ដោយមិនចាំបាច់ មានការបង្ហាញប្រាប់ពីភាគី ។

ល័ក្ខខ័ណ្ឌបណ្តឹងភាគច្រើន ត្រូវបានទទួលស្គាល់ ដោយសារមានការទាមទារសម្រាប់ប្រយោជន៍សាធារណៈ ដើម្បីដឹកនាំរបបបណ្តឹងឱ្យបានត្រឹមត្រូវ និង ឱ្យមានប្រសិទ្ធិភាពល្អ ហេតុនេះហើយ ជាគោលការណ៍ តុលាការត្រូវស្រាវជ្រាវស្តីពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌនោះ ដោយមិនចាំបាច់មានការទាមទារពីភាគី ។ ហេតុនេះហើយ ល័ក្ខខ័ណ្ឌបណ្តឹងភាគច្រើន ជាល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ។

ក៏ប៉ុន្តែ ក្នុងល័ក្ខខ័ណ្ឌបណ្តឹង អាចមានល័ក្ខខ័ណ្ឌដែលត្រូវបានទទួលស្គាល់ដើម្បីជាផលប្រយោជន៍របស់ចុងចម្លើយ ។ ចំពោះល័ក្ខខ័ណ្ឌបណ្តឹងដូចនេះ តុលាការត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌនោះ តែពេលណាមានការបង្ហាញពីចុងចម្លើយថា មានកង្វះនូវល័ក្ខខ័ណ្ឌប៉ុណ្ណោះ ។ ប្រសិនបើចុងចម្លើយមិនបានអះអាងទេ តុលាការមិនចាំបាច់ពិចារណាដល់ចំណុចនេះទេ ពីព្រោះចុងចម្លើយមិនបានធ្វើការអះអាងដោយសកម្មនូវផលប្រយោជន៍របស់ខ្លួន ហេតុដូច្នេះ រដ្ឋមិនចាំបាច់គិតពិចារណាអំពីបញ្ហានេះ ហើយតុលាការអាចចេញសាលក្រមដែលសម្រេចអំពីអង្គសេចក្តី ដោយមិនចាំបាច់ពិចារណាអំពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌនោះទេ ។ ល័ក្ខខ័ណ្ឌបណ្តឹងប្រភេទនេះ គេហៅថាល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចតវ៉ា ។ កិច្ចសន្យាមជ្ឈត្តកម្ម ឬ ការសន្យាពិសេសមិនដាក់ពាក្យបណ្តឹង គឺជាឧទាហរណ៍នៃល័ក្ខខ័ណ្ឌបណ្តឹងដែលជាចំណុចតវ៉ានេះ ។

## កថាភាគទី ៣ ល័ក្ខខ័ណ្ឌបណ្តឹងសំខាន់ៗ

ល័ក្ខខ័ណ្ឌបណ្តឹងសំខាន់ៗមានដូចតទៅ :

(១) ការដាក់ពាក្យបណ្តឹង និង ការបញ្ជូនពាក្យបណ្តឹង ដែលមានសុពលភាព

(២) មានភាគីត្រឹមត្រូវ ហើយមានសមត្ថភាពភាគី

(៣) ចុងចម្លើយស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់ព្រះរាជាណាចក្រកម្ពុជា

(៤) តុលាការដែលចាត់ការ ត្រូវមានសមត្ថកិច្ចលើរឿងក្តីនោះ

(៥) មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹង មានន័យថា មានផលប្រយោជន៍ ឬ ភាពចាំបាច់ តាមផ្លូវច្បាប់រវាងភាគីនៃបណ្តឹង ក្នុងការទាមទារសាលក្រមស្តីពីការទាមទារតាមផ្លូវបណ្តឹងដែលត្រូវបានបង្ហាញក្នុងបណ្តឹងដោយដើមចោទ ។

## ផ្នែកទី ៣ ផលប្រយោជន៍ក្នុងការធ្វើបណ្តឹង

### កថាភាគទី ១ ផលប្រយោជន៍ស្តីពីកម្មវត្ថុនៃបណ្តឹង និង ផលប្រយោជន៍ស្តីពីប្រធាន

ល័ក្ខខ័ណ្ឌបណ្តឹងមានប្រភេទជាច្រើនដូចដែលបានពន្យល់ខាងលើនេះ ក៏ប៉ុន្តែ ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងនេះបន្ទាប់ពីនេះ សូមពន្យល់ពិសេសស្តីពីផលប្រយោជន៍ក្នុងការធ្វើបណ្តឹង ដែលច្រើនតែមានបញ្ហា ។

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដើម្បីការពារជនដែលមានសិទ្ធិ ក៏ប៉ុន្តែ ដើម្បីអាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការធ្វើបណ្តឹងនោះបាន ជាបឋម ដើមចោទទាល់តែមានផលប្រយោជន៍ និង ភាពចាំបាច់ត្រឹមត្រូវក្នុងការទាមទារឱ្យការពារតាមរយៈសាលក្រម ចំពោះសិទ្ធិដែលខ្លួនអះអាងតាមបណ្តឹង បន្ទាប់មក ចាំបាច់ត្រូវមានភាពត្រឹមត្រូវ និង មានអត្ថន័យ ក្នុងការចេញសាលក្រមស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ដោយយកដើមចោទ និង ចុងចម្លើយនោះជាភាគី ។ ដូច្នេះ ផលប្រយោជន៍នៃការធ្វើបណ្តឹង ក៏អាចបែងចែកជាពីរបានដែរ ។ ទីមួយគឺ ផលប្រយោជន៍ត្រឹមត្រូវចំពោះកម្មវត្ថុនៃបណ្តឹង និងទីពីរគឺ ផលប្រយោជន៍ត្រឹមត្រូវចំពោះប្រធាននៃបណ្តឹង ។

### កថាភាគទី ២ ផលប្រយោជន៍ត្រឹមត្រូវស្តីពីកម្មវត្ថុនៃបណ្តឹង (ផលប្រយោជន៍នៃការធ្វើបណ្តឹង ក្នុងន័យចង្អៀត)

ផលប្រយោជន៍ត្រឹមត្រូវស្តីពីកម្មវត្ថុនៃបណ្តឹងគឺមានន័យថា ការទាមទារតាមផ្លូវបណ្តឹង ដែលជាខ្លឹមសារនៃបណ្តឹង មានលក្ខណៈទូទៅស្របនឹងការទាមទារឱ្យចេញសាលក្រម ព្រមទាំងមានការចាំបាច់ ឬ ផលប្រយោជន៍ក្នុងការទាមទារឱ្យចេញសាលក្រមចំពោះការទាមទារនោះ ។ ឧទាហរណ៍ ចំពោះបណ្តឹងដែលមានការទាមទារតាមផ្លូវបណ្តឹង ដោយអះអាងអំពីសិទ្ធិបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ដែលបង្កើតនូវអានុភាពគតិយុត្តដោយគ្រាន់តែមានការបង្ហាញឆន្ទៈរបស់ភាគី ដូចជាសិទ្ធិលុបចោលកិច្ចសន្យា សិទ្ធិរំលាយកិច្ចសន្យា ជាដើមការទាមទារនោះមានកង្វះលក្ខណៈទូទៅស្របនឹងការទាមទារឱ្យចេញសាលក្រម ហេតុដូច្នេះ គ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឡើយ ។ ម្យ៉ាងទៀត បណ្តឹងដែលទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលពុំមានវិវាទរវាងភាគី ក៏មានកង្វះនូវភាពចាំបាច់ក្នុងការទាមទារឱ្យចេញសាលក្រម ហេតុនេះហើយបានជាពុំមានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងឡើយ ។

ផលប្រយោជន៍ត្រឹមត្រូវស្តីពីកម្មវត្ថុនៃបណ្តឹង អាចបែងចែកជា ល័ក្ខខ័ណ្ឌរួមនៃបណ្តឹងទាំងមូល និង

ជាល័ក្ខខ័ណ្ឌពិសេសតាមប្រភេទនីមួយៗនៃបណ្តឹងបាន ។

១. ផលប្រយោជន៍ស្តីពីកម្មវត្ថុរួមនៃបណ្តឹងទាំងមូល

(១) ការទាមទារត្រូវមានខ្លឹមសារជាការអះអាងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់លាក់ ( មាត្រា ៧៤) ។

ក្នុងករណីដែលខ្លឹមសារនៃការទាមទារ គ្រាន់តែជាការអះអាងអំពីផលប្រយោជន៍ តាមការជាក់ស្តែង ឬ តាមផ្លូវសេដ្ឋកិច្ច ឬ តាមផ្លូវសិល្បៈ ឬ វិទ្យាសាស្ត្រ ឬ គ្រាន់តែជាការអះអាងអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃមតិតាមផ្លូវច្បាប់ដែលមានលក្ខណៈអរូបីយ គ្មានផលប្រយោជន៍ (គ្មានលក្ខណៈ) ក្នុងការទាមទារឱ្យចេញសាលក្រមចំពោះការទាមទារទាំងនោះ ។

(២) ច្បាប់មិនហាមការធ្វើបណ្តឹងចំពោះការទាមទារនោះ

ឧទាហរណ៍នៃករណីដែលហាមមិនឱ្យធ្វើបណ្តឹងតាមផ្លូវច្បាប់ មានដូចជា ការហាមបណ្តឹងជាន់គ្នា ( មាត្រា ៨៣), ការហាមដាក់បណ្តឹងដូចគ្នាម្តងទៀត ក្នុងករណីដកពាក្យបណ្តឹង ក្រោយពីបានចេញសាលក្រមចុងក្រោយអំពីអង្គសេចក្តី ( មាត្រា ២១៨ កថាខណ្ឌទី ២), ការហាមបណ្តឹងផ្សេងទៀត ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ១៧ កថាខណ្ឌទី ១ និង ទី ២) ។

(៣) គ្មានស្ថានភាពពិសេសដែលធ្វើឱ្យបាត់បង់នូវភាពចាំបាច់ក្នុងការដាក់ពាក្យបណ្តឹង

ឧទាហរណ៍ ក្នុងករណីដែលដើមចោទបានទទួលសាលក្រមឈ្នះក្តីដែលបានចូលជាស្ថាពររួចហើយ ប្រសិនបើដើមចោទនោះដាក់ពាក្យបណ្តឹងជាថ្មីម្តងទៀតចំពោះការទាមទារដដែល ជាគោលការណ៍ គ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងទេ ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីបង្អាកនូវអាជ្ញាយុកាលជាថ្មីម្តងទៀត (ក្រមរដ្ឋប្បវេណី មាត្រា ៤៨៦ ចំណុច ក) ជាដើម អាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការធ្វើបណ្តឹងជាករណីពិសេសបាន ។ ម្យ៉ាងទៀត ក្នុងករណីដែលមានមធ្យោបាយពិសេសផ្សេងក្រៅពីបណ្តឹង ដើម្បីសង្គ្រោះសិទ្ធិដែលបានអះអាងដោយដើមចោទ គឺមិនមានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងទេ ។ ឧទាហរណ៍ ប្រសិនបើដើមចោទអាចអនុវត្តដោយបង្ខំបានភ្លាម ចំពោះចុងចម្លើយ ដោយទទួលនូវការផ្តល់រូបមន្តអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៣៥៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះមិនអាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការធ្វើបណ្តឹងទេ ។

(៤) គ្មានកិច្ចសន្យាមជ្ឈត្តកម្ម ឬ ការព្រមព្រាងមិនឱ្យធ្វើបណ្តឹង ចំពោះរឿងក្តីនោះ

២. ផលប្រយោជន៍ស្តីពីកម្មវត្ថុពិសេស តាមប្រភេទនីមួយៗនៃបណ្តឹង

(១) បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

(ក) ក្នុងចំណោមបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកបច្ចុប្បន្ន គឺជាការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលពេលកំណត់ត្រូវអនុវត្តបានមកដល់ហើយ ដូច្នេះហើយ ប្រសិនបើគ្រាន់តែទទួលស្គាល់នូវផលប្រយោជន៍រួមជាក់ស្តែងដែលបានរៀបរាប់ខាងលើនេះប៉ុណ្ណោះ ផលប្រយោជន៍

ក្នុងការធ្វើបណ្តឹង អាចត្រូវបានទទួលស្គាល់ដោយស្វ័យប្រវត្តិ ។

(ខ) ផ្ទុយទៅវិញ ចំពោះបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាអនាគត ពេលកំណត់ត្រូវអនុវត្តសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកដែលត្រូវបានអះអាងដោយដើមចោទ មិនទាន់មកដល់ទេ ហេតុនេះហើយ កាតព្វកិច្ចផ្តល់តាវកាលិករបស់ចុងចម្លើយមិនទាន់កើតមានឡើងនៅឡើយទេ ហេតុដូច្នេះ ផលប្រយោជន៍ក្នុងការធ្វើបណ្តឹងអាចត្រូវបានទទួលស្គាល់ "លុះត្រាតែមានភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារជាមុន" (មាត្រា ៧៦) ។ ឧទាហរណ៍ ករណីដែល ដោយសារតែចុងចម្លើយបានធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារតែម្តង ដូច្នេះ ទោះបីជាពេលកំណត់ត្រូវអនុវត្តមកដល់ក៏ដោយ ក៏មិនអាចរំពឹងថា ចុងចម្លើយនឹងអនុវត្តកាតព្វកិច្ចផ្តល់តាវកាលិកនោះបាន ឬ ករណីដែលមានភាពចាំបាច់ត្រូវតែអនុវត្ត នៅពេលកំណត់ត្រូវអនុវត្ត តាមលក្ខណៈនៃសិទ្ធិ ដូចជាសិទ្ធិទាមទារប្រាក់អាហារការពូកិច្ច ជាដើម គឺជាករណីដែលអនុញ្ញាតឱ្យប្តឹងទាមទារឱ្យផ្តល់តាវកាលិកនាអនាគត ។ ទោះជាបានទទួលសាលក្រមឈ្នះបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាអនាគតក៏ដោយ ក៏ការអនុវត្តដោយបង្ខំ ដោយផ្អែកលើសាលក្រមនោះ នឹងអាចធ្វើបានតែពេលកំណត់ត្រូវអនុវត្តនោះ បានមកដល់ ឬ ពេលដែលល័ក្ខខ័ណ្ឌត្រូវបានសម្រេច (មាត្រា ៣៥៦ កថាខណ្ឌទី ១, មាត្រា ៣៦១ កថាខណ្ឌទី ១) ។

(២) បណ្តឹងទាមទារឱ្យបញ្ជាក់

បណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងដែលមានគោលបំណងជួយសង្គ្រោះសិទ្ធិដែលត្រូវគេបំពាន ឬ ដែលអាចត្រូវគេបំពានសព្វថ្ងៃនេះ ហេតុនេះហើយ សិទ្ធិ (ឬ ទំនាក់ទំនងគតិយុត្ត) ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ជាគោលការណ៍ ចាំបាច់ត្រូវជាសិទ្ធិដែលមានបច្ចុប្បន្ននេះ ។ម្យ៉ាងទៀត ក្នុងបណ្តឹងទាមទារឱ្យបញ្ជាក់ ចាំបាច់ត្រូវមានផលប្រយោជន៍ក្នុងការបញ្ជាក់ជាស្ថាពរដោយភ្លាមៗអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ តាមរយៈសាលក្រម ។ ដើម្បីឱ្យមានផលប្រយោជន៍ក្នុងការបញ្ជាក់ជាស្ថាពរដោយភ្លាមៗបាន (១) ត្រូវមានវិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ រវាងដើមចោទ និង ចុងចម្លើយ ហើយ (២) ឋានៈតាមផ្លូវច្បាប់របស់ដើមចោទមានភាពមិនច្បាស់លាស់ ឬ អស្ថិរភាព ដោយសារវិវាទនេះ ហើយ (៣) ដើម្បីលុបបំបាត់ចោលនូវស្ថានភាពមិនច្បាស់លាស់ ឬ អស្ថិរភាពនោះ ការទទួលនូវអាជ្ញាអស់ជំនុំនៃសាលក្រម (មាត្រា ១៩៨) មានប្រសិទ្ធិភាព និង ភាពសមរម្យ ។ ផលប្រយោជន៍ត្រឹមត្រូវដែលចាំបាច់ចំពោះសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់នោះ ត្រូវហៅថា "ផលប្រយោជន៍ក្នុងការបញ្ជាក់" ។

(៣) បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត ត្រូវបានទទួលស្គាល់ លុះត្រាតែករណីដែលមានបញ្ញត្តិច្បាប់ដែលមានចែងច្បាស់លាស់ប៉ុណ្ណោះ ហេតុនេះហើយ ប្រសិនបើដើមចោទអះអាងអំពីអត្ថិភាពនៃមូលហេតុនៃការបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលបានកំណត់នៅក្នុងច្បាប់ ជាគោលការណ៍ អាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការធ្វើបណ្តឹងបាន ។

## កថាភាគទី ៣ ផលប្រយោជន៍ត្រឹមត្រូវស្តីពីប្រធាននៃបណ្តឹង (លក្ខណៈជាភាគី)

### ១. អត្ថន័យនៃលក្ខណៈជាភាគី

ផលប្រយោជន៍ត្រឹមត្រូវស្តីពីប្រធាននៃបណ្តឹង គឺជាផលប្រយោជន៍ក្នុងការធ្វើបណ្តឹង ដែលត្រូវបានទទួលស្គាល់ ដោយពិនិត្យមើលថា ដើម្បីធ្វើការកំណត់ជាស្ថាពរដោយសាលក្រមអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលត្រូវបានអះអាងដោយដើមចោទ តើគួរកំណត់អ្នកណាជាដើមចោទ និង អ្នកណាជាចុងចម្លើយ ដើម្បីឱ្យមានប្រសិទ្ធិភាព និង ឱ្យត្រឹមត្រូវ ជាងគេ ។ ឧទាហរណ៍ ក្នុងករណីដែលត្រូវកំណត់ជាស្ថាពរដោយសាលក្រមអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារឱ្យសងប្រាក់កំចីរបស់ A ចំពោះ B តាមធម្មតា គេទទួលស្គាល់ការកំណត់ថា A ជាដើមចោទ ហើយ B ជាចុងចម្លើយ ជាការត្រឹមត្រូវ និង មានប្រសិទ្ធិភាពជាងគេ ។ ទោះជាជនក្រៅពី A បានដាក់ពាក្យបណ្តឹងក្នុងនាមជាដើមចោទក៏ដោយ ក៏តាមធម្មតា គ្មានផលប្រយោជន៍ឱ្យតុលាការទទួលយកបណ្តឹងនោះមកវិនិច្ឆ័យ ហើយចេញសាលក្រមឡើយ ម្យ៉ាងទៀត ក្នុងករណីដែលជនក្រៅពី B ជាចុងចម្លើយក្នុងបណ្តឹងនោះ ក៏ដូចគ្នាដែរ ។ ហេតុនេះហើយ ពេលតុលាការធ្វើការវិនិច្ឆ័យតាមនីតិវិធីបណ្តឹង និង ចេញសាលក្រមអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលត្រូវបានអះអាងក្នុងបណ្តឹងនោះ លក្ខណៈអាចធ្វើជាភាគីនៃបណ្តឹង ក្នុងន័យថា ប្រសិនបើជននោះជាដើមចោទ ឬ ចុងចម្លើយ គេអាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការចេញសាលក្រមអំពីអង្គសេចក្តី ត្រូវហៅថា លក្ខណៈជាភាគី ។ មានន័យថា លក្ខណៈជាភាគី គឺជាលក្ខណៈចាំបាច់ក្នុងការទាមទារឱ្យតុលាការចេញសាលក្រមអំពីអង្គសេចក្តី ចំពោះការទាមទារតាមផ្លូវបណ្តឹង ក្នុងឋានៈជាដើមចោទ ឬ ចុងចម្លើយ ។ លក្ខណៈដើម្បីធ្វើជាដើមចោទ ត្រូវហៅថា លក្ខណៈជាដើមចោទ ហើយលក្ខណៈចាំបាច់ដើម្បីឱ្យជននោះអាចក្លាយជាចុងចម្លើយ ត្រូវហៅថា លក្ខណៈជាចុងចម្លើយ ។ ជនដែលមានលក្ខណៈជាភាគី គឺជាភាគីដែលស្របលក្ខណៈក្នុងការទាមទារនោះ ។

លក្ខណៈជាភាគី គឺជាលក្ខណៈដែលចាំបាច់ក្នុងការទាមទារតាមផ្លូវបណ្តឹងជាកំណត់ ហើយត្រូវចែកឱ្យដាច់ពីសមត្ថភាពភាគី ដែលចាំបាច់ដើម្បីធ្វើជាដើមចោទ ឬ ជាចុងចម្លើយនៃរឿងក្តីរដ្ឋប្បវេណីទូទៅ ដោយមិនគិតថាជារឿងក្តីអ្វី ឬ ជាការទាមទារអ្វីទេ ។

### ២. ជនដែលជាភាគីត្រឹមត្រូវ

#### (១) គោលការណ៍ទូទៅ

ជាទូទៅ ជនដែលមានផលប្រយោជន៍ផ្ទុយគ្នាតាមផ្លូវច្បាប់ ចំពោះការកំណត់ជាស្ថាពរនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលត្រូវបានអះអាងដោយបណ្តឹង គឺជាភាគីត្រឹមត្រូវ (ស្របលក្ខណៈ) ។ តាមធម្មតា ជនដែលតាំងខ្លួនជាម្ចាស់សិទ្ធិនៃសិទ្ធិដែលត្រូវបានអះអាងតាមបណ្តឹង គឺជាដើមចោទត្រឹមត្រូវ រីឯ ជនដែលត្រូវបានអះអាងថា ជាអ្នកមានកាតព្វកិច្ចចំពោះសិទ្ធិនោះ គឺជាចុងចម្លើយត្រឹមត្រូវ ។ ក្នុងករណីដែលបានកំណត់ថា សិទ្ធិនោះមាន ឬ គ្មានអត្ថិភាព ផលប្រយោជន៍ជាសារធាតុ ដែលបានមកពីការកំណត់នោះ គឺត្រូវបានទៅ

លើជនទាំងនោះ ។

ក្នុងបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ជនដែលបានអះអាងថា សាមីខ្លួនជាអ្នកមានសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក ជាជនមានលក្ខណៈជាដើមចោទ ហើយជនដែលត្រូវដើមចោទអះអាងថា ជាជនមានកាតព្វកិច្ចចំពោះសិទ្ធិនោះ គឺជាជនមានលក្ខណៈជាចុងចម្លើយ ។ ក្នុងបណ្តឹងទាមទារឱ្យបញ្ជាក់ ជនដែលមានផលប្រយោជន៍ក្នុងការបញ្ជាក់ដោយសាលក្រម នូវសិទ្ធិដែលជាកម្មវត្ថុនៃការបញ្ជាក់ (ផលប្រយោជន៍ក្នុងការបញ្ជាក់) គឺជាជនដែលមានលក្ខណៈជាដើមចោទ រីឯជនដែលត្រូវបានទទួលស្គាល់នូវផលប្រយោជន៍ក្នុងការបញ្ជាក់រវាងជននោះ គឺជាជនដែលមានលក្ខណៈជាចុងចម្លើយ ។ ឧទាហរណ៍ ប្រសិនបើមានវិវាទអំពីកម្មសិទ្ធិលើអចលនវត្ថុមួយរវាង A និង B ការដែលអាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការធ្វើបណ្តឹងទាមទារឱ្យបញ្ជាក់អំពីកម្មសិទ្ធិ (ផលប្រយោជន៍ក្នុងការបញ្ជាក់) របស់ A គឺមានតែករណីដែល B ជាចុងចម្លើយទេ ប្រសិនបើ C ដែលពុំមានវិវាទអំពីកម្មសិទ្ធិរបស់ A ជាចុងចម្លើយវិញ គឺមិនអាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការធ្វើបណ្តឹងទេ ។ ដូចករណីនេះ ក្នុងបណ្តឹងទាមទារឱ្យបញ្ជាក់ ជនដែលបង្កើតនូវផលប្រយោជន៍ក្នុងការបញ្ជាក់ គឺជាជនដែលមានលក្ខណៈជាចុងចម្លើយ ។ ក្នុងបណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តវិញ តាមធម្មតា ជនដែលត្រូវក្លាយជាដើមចោទ ឬ ចុងចម្លើយ ត្រូវបានកំណត់ច្បាស់លាស់នៅក្នុងបញ្ញត្តិនៃច្បាប់ដែលទទួលស្គាល់នូវបណ្តឹងប្រភេទនេះ (ក្រមរដ្ឋប្បវេណី មាត្រា ៩៥៧, មាត្រា ៩៧៥, មាត្រា ៩៨៧, មាត្រា ៩៨៨, មាត្រា ៩៩៨, សេចក្តីព្រាងក្រមនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៦ ជាអាទិ៍) ហេតុដូច្នេះ ជនដែលមានចែងក្នុងនោះ គឺជាជនដែលមានលក្ខណៈជាភាគី ។

ប្រសិនបើមានកង្វះលក្ខណៈជាភាគី តែតុលាការមិនឃើញកង្វះនោះ ហើយបានចេញសាលក្រមអំពីអង្គសេចក្តី ភាគីនីមួយៗអាចទាមទារឱ្យលុបចោលសាលក្រមនេះ ដោយបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ ក៏ប៉ុន្តែ ប្រសិនបើសាលក្រមនេះបានចូលជាស្ថាពរ មិនអាចយកកង្វះលក្ខណៈជាភាគីនោះ មកធ្វើជាមូលហេតុនៃនៃការជំនុំជម្រះសាជាថ្មីបានទេ (សូមមើលមាត្រា ៣០៧) ។

**(២) ការទទួលបន្ទុកនីតិវិធីនៃបណ្តឹងដោយតតិយជន**

ក្នុងករណីពិសេស តតិយជនអាចមានលក្ខណៈជាភាគីក្នុងបណ្តឹងពាក់ព័ន្ធនឹងសិទ្ធិដែលត្រូវបានអះអាងដោយបណ្តឹងបាន ដោយជំនួសជនមានផលប្រយោជន៍ជាសារធាតុអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ ឬ ដោយមានឋានៈស្មើនឹងជននោះ ។ ក្នុងករណីនេះ ប្រសិនបើមើលពីខាងតតិយជនដែលត្រូវក្លាយទៅជាភាគីវិញ តតិយជននោះត្រូវបានទទួលស្គាល់នូវលក្ខណៈសម្បត្តិអាចធ្វើបណ្តឹងអំពីសិទ្ធិ ឬ ផលប្រយោជន៍របស់អ្នកដទៃ ហេតុដូច្នេះ ត្រូវហៅថា ការទទួលបន្ទុកនីតិវិធីនៃបណ្តឹងដោយតតិយជន ។ ក្នុងករណីនៃការទទួលបន្ទុកនីតិវិធីនៃបណ្តឹងដោយតតិយជន អាជ្ញាអស់ជំនុំនៃសាលក្រមដែលទទួលដោយភាគី មានអានុភាពទៅលើជនដែលមានផលប្រយោជន៍ដើមដែរ (មាត្រា ១៩៨ ចំណុច ខ) ។ ក្នុងករណីនៃការទទួលបន្ទុកនីតិវិធីនៃបណ្តឹង

ដោយតតិយជន តតិយជននោះត្រូវក្លាយជាភាគីនៃបណ្តឹង គឺខុសពីការតំណាង ។

(ក) ក្នុងករណីដែលសិទ្ធិគ្រប់គ្រង និង ចាត់ចែងទ្រព្យសម្បត្តិ ត្រូវបានផ្តល់ដល់តតិយជន ក្រៅពីប្រធាន ដែលមានសិទ្ធិលើទ្រព្យសម្បត្តិនោះ បណ្តឹងអំពីទ្រព្យសម្បត្តិនោះក៏ត្រូវធ្វើឡើងដោយតតិយជននោះ ក្នុងនាមជាភាគីដែរ ។ ឧទាហរណ៍មានដូចជា ករណីដែលម្ចាស់បំណុលនៃការអនុវត្តបានរឹបអូសសិទ្ធិលើបំណុលជាប្រាក់របស់កូនបំណុលនៃការអនុវត្ត នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ ហើយធ្វើបណ្តឹងដើម្បីប្រមូលសិទ្ធិលើបំណុលដែលបានរឹបអូសនោះ (មាត្រា ៤១០ កថាខណ្ឌទី ១, មាត្រា ៤១២), ឬ ករណីដែលម្ចាស់បំណុលធ្វើបណ្តឹងដោយអនុវត្តសិទ្ធិរបស់កូនបំណុលដោយឧបាទេសកម្ម ដោយផ្អែកលើសិទ្ធិឧបាទេសកម្មរបស់ម្ចាស់បំណុល ជាដើម ។

(ខ)ម្យ៉ាងទៀត មានករណីពិសេសដែលទទួលស្គាល់ថា ជនដែលមានមុខងារកំណត់មួយ អាចក្លាយជាភាគីជំនួសប្រធាននៃសិទ្ធិ ឬ កាតព្វកិច្ចដើមបាន ។ ឧទាហរណ៍មួយគឺ ចំពោះរឿងក្តីទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលជនដែលមានលក្ខណៈជាភាគីពីដើម បានទទួលមរណភាព នោះតំណាងអយ្យការត្រូវក្លាយជាភាគី (សេចក្តីព្រាងក្រមនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ៦ កថាខណ្ឌទី ៣) ។

(គ) ក្នុងករណីដែលត្រូវបានទទួលស្គាល់ថា ជនដែលមានលក្ខណៈជាភាគីដើមអាចផ្តល់ឱ្យតតិយជននូវលក្ខណៈធ្វើបណ្តឹងនោះ ដោយឆន្ទៈរបស់ខ្លួននោះ ក៏តតិយជននោះនឹងក្លាយជាអ្នកទទួលបន្ទុកនីតិវិធីនៃបណ្តឹងដែរ ។ ការទទួលបន្ទុកនីតិវិធីនៃបណ្តឹងបែបនេះ ត្រូវហៅថា ការទទួលបន្ទុកនីតិវិធីនៃបណ្តឹងដោយស្ម័គ្រចិត្ត ។ បណ្តឹងដោយភាគីដែលត្រូវបានជ្រើសរើស គឺជាឧទាហរណ៍មួយ (មាត្រា ៤២ កថាខណ្ឌទី ១) ។ តើត្រូវមានល័ក្ខខ័ណ្ឌអ្វីខ្លះ ដើម្បីឱ្យអាចផ្តល់នូវលក្ខណៈសម្បត្តិដល់តតិយជនធ្វើបណ្តឹង ដោយឆន្ទៈរបស់ជនដែលមានលក្ខណៈជាភាគី ? ចំណុចនេះចាំបាច់ត្រូវគិតឱ្យបានហ្មត់ចត់ ។

# ជំពូកទី ៤ ការបញ្ចប់បណ្តឹង

## ផ្នែកទី ១ សាលក្រមចុងក្រោយ

### កថាភាគទី ១ ការបញ្ចប់បណ្តឹងដោយសាលក្រមចុងក្រោយ

១. អត្ថន័យ និង ប្រភេទនៃសាលក្រមចុងក្រោយ

ដោយព្រោះបណ្តឹងត្រូវបានចាប់ផ្តើម ដោយការទាមទាររបស់ដើមចោទ តាមរយៈពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់ណាមួយ ជាគោលការណ៍ បណ្តឹងត្រូវបញ្ចប់ដោយសាលក្រមរបស់តុលាការដែលជាការឆ្លើយតបចំពោះការទាមទាររបស់ដើមចោទនោះ ។

នៅពេលដែលការវិនិច្ឆ័យចប់ ជាមួយការបញ្ចប់នូវការទាញហេតុផល និង ការពិនិត្យភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ កំណត់កាលបរិច្ឆេទសម្រាប់ការប្រកាសសាលក្រម និង ត្រូវប្រកាសសាលក្រម (មាត្រា ១៨០ កថាខណ្ឌទី ១) ។ ពេលដែលសាលក្រមនោះចូលជាស្ថាពរ គោលដៅនៃបណ្តឹងក៏ត្រូវបានសម្រេច ហើយបណ្តឹងនោះត្រូវចប់ ។ ក៏ប៉ុន្តែ សាលក្រមដែលមានអានុភាពបញ្ចប់បណ្តឹង ចាំបាច់ត្រូវជាសាលក្រមបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគ ។ សាលក្រមដែលបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគនោះ គេហៅថា សាលក្រមចុងក្រោយ ។ សាលក្រមចុងក្រោយ អាចចែកជាប្រភេទដូចតទៅ :

សាលក្រមចុងក្រោយប្រភេទទីមួយ គឺជាសាលក្រមលើកបណ្តឹងចោល ដោយមិនធ្វើការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ដោយមកពីមូលហេតុខ្វះល័ក្ខខ័ណ្ឌបណ្តឹង ។ នៅក្នុងករណីនេះ ដោយព្រោះបណ្តឹងចប់ភ្លាមបន្ទាប់ពីការវិនិច្ឆ័យទៅលើអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្តឹង សាលក្រមបែបនេះ គេហៅថា "សាលក្រមនីតិវិធី" ។

សាលក្រមប្រភេទទីពីរ គឺជាសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ ចំពោះបណ្តឹងដែលគ្មានភាពខ្វះខាតនៃល័ក្ខខ័ណ្ឌបណ្តឹង ។ សាលក្រមប្រភេទនេះហៅថា "សាលក្រមទទួលស្គាល់ការទាមទារ" ។

ទីបី គឺជាសាលក្រមសម្រេចមិនទទួលស្គាល់ការទាមទាររបស់ដើមចោទ ចំពោះបណ្តឹងដែលគ្មានភាពខ្វះខាតនៃល័ក្ខខ័ណ្ឌបណ្តឹង ។ សាលក្រមបែបនេះហៅថា "សាលក្រមច្រានចោលការទាមទារ" ។

សាលក្រមទទួលស្គាល់ការទាមទារ និង សាលក្រមច្រានចោលការទាមទារ គេហៅរួមថា "សាលក្រមលើអង្គសេចក្តី" ។ សាលក្រមទាំងពីរនេះ គឺជាសាលក្រមបង្ហាញអំពីការសម្រេចសេចក្តីរបស់តុលាការស្តីពីភាពត្រឹមត្រូវនៃការទាមទារ ដែលជាកម្មវត្ថុដើមនៃបណ្តឹង ហើយដោយបែបនោះ សាលក្រមទាំងនោះខុសគ្នាពីសាលក្រមលើបណ្តឹង ដែលមានតែការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្តឹងប៉ុណ្ណោះ ។ ហេតុដូច្នេះ គេហៅថា សាលក្រមលើអង្គសេចក្តី ក្នុងន័យថាជាសាលក្រមដែលសម្រេចអំពីអង្គសេចក្តីនៃរឿងក្តី ។

២. សាលក្រមរបៀប

(១) អត្ថន័យនៃសាលក្រមរបៀប

សាលក្រមដែលគ្មានអានុភាពបញ្ចប់បណ្ដឹងទេ ហើយដែលសម្រេចសេចក្ដីចំពោះចំណុចដែលជាបុរេល័ក្ខខ័ណ្ឌសម្រាប់ការចេញសាលក្រមចុងក្រោយ គេឱ្យឈ្មោះថា "សាលក្រមរបៀប" (មាត្រា ១៨១) ។ ដោយព្រោះសាលក្រមរបៀប មានគោលបំណងរៀបចំ និង សម្រួលធ្វើឱ្យការវិនិច្ឆ័យបណ្ដឹងមានសណ្ដាប់ធ្នាប់ តុលាការអាចចេញសាលក្រមរបៀបបានតែចំពោះចំណុចដែលត្រូវនឹងគោលបំណងនោះប៉ុណ្ណោះ ។

(២) ចំណុចដែលអាចចេញសាលក្រមរបៀបបាន

ចំណុចដែលអាចចេញសាលក្រមរបៀបបានគឺ មានបី ។ ដោយសារថាតុលាការមានឆន្ទានុសិទ្ធិ ក្នុងការសម្រេចថា គួរចេញសាលក្រមរបៀប ឬទេនោះ សាលក្រមរបៀបមិនសុទ្ធតែចាំបាច់ត្រូវធ្វើចំពោះរាល់ចំណុចទាំងនោះទេ ។

(ក) អត្ថិភាពនៃការទាមទារ នៅក្នុងករណីដែលកម្មវត្ថុនៃបណ្ដឹងគឺជាសិទ្ធិទាមទារ ហើយដែលមានវិវាទលើអត្ថិភាព និង ចំនួនទឹកប្រាក់នៃការទាមទារ (មាត្រា ១៨១ ចំណុច ក)

ឧទាហរណ៍ ក្នុងករណីនៃបណ្ដឹងទាមទារឱ្យសងនូវសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល បើមានវិវាទចំពោះបញ្ហាដែលពាក់ព័ន្ធនឹងអត្ថិភាពនៃសិទ្ធិទាមទារនូវសំណងនៃការខូចខាត ដូចជាអត្ថិភាព ឬនត្ថិភាពនៃកំហុស និង ទំនាក់ទំនងហេតុផលរវាងអំពើ និង ការខូចខាត ជាអាទិ៍ ហើយព្រមជាមួយគ្នានេះមានវិវាទចំពោះចំនួនទឹកប្រាក់សំណងនៃការខូចខាតផងនោះ តុលាការអាចធ្វើការវិនិច្ឆ័យអំពីបញ្ហាដែលពាក់ព័ន្ធនឹងអត្ថិភាពនៃសិទ្ធិទាមទារសំណងនោះជាមុន ។ ហើយប្រសិនបើតុលាការទទួលនូវអត្ថិភាពនោះ តុលាការចេញសាលក្រមទទួលស្គាល់អំពីអត្ថិភាពនៃសិទ្ធិទាមទារសំណងនោះ ។ សាលក្រមបែបនេះ គឺជាសាលក្រមរបៀប (ប៉ុន្តែ ប្រសិនបើតុលាការមិនអាចទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិទាមទារនោះ តុលាការត្រូវចេញសាលក្រមចុងក្រោយដែលច្រានចោលការទាមទារនោះ) ។ ក្នុងករណីដែលយល់ឃើញថា ការវិនិច្ឆ័យស្ដីពីទឹកប្រាក់សំណងនៃការខូចខាត មានភាពស្មុគស្មាញ ហើយត្រូវចំណាយសោហ៊ុយ និង ពេលវេលាច្រើន ប្រសិនបើបានធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិទាមទារ តំណាលគ្នាជាមួយនឹងចំនួនទឹកប្រាក់នោះដែរ តែទីបញ្ចប់ សម្រេចថា មិនទទួលស្គាល់សិទ្ធិទាមទារនោះ ដោយមូលហេតុថា គ្មានកំហុសនៅក្នុងអំពើនោះជាដើមទៅ ធ្វើឱ្យការវិនិច្ឆ័យស្ដីពីចំនួនទឹកប្រាក់ នឹងក្លាយទៅជាសកម្មភាពមួយឥតប្រយោជន៍ទៅវិញ ។ ដូច្នេះហើយ ក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតឱ្យតុលាការចេញសាលក្រមរបៀប ដើម្បីជៀសវាងនូវបញ្ហានេះ ។

(ខ) មធ្យោបាយតទល់ ឬ ការការពារខ្លួន ដែលអាចវិនិច្ឆ័យដោយឯករាជ្យបាន (មាត្រា ១៨១ ចំណុច ខ)

មធ្យោបាយតទល់ និង ការការពារខ្លួនដែលឯករាជ្យ គឺជាមធ្យោបាយដែលបណ្ដាលឱ្យមានអានុភាពគតិយុត្តឯករាជ្យមួយ ចំពោះការបង្កើត ការផ្លាស់ប្ដូរ ឬ ការរំលាយសិទ្ធិ ក្នុងចំណោមមធ្យោបាយតទល់ និង ការការ

ខ្លួនទាំងអស់ដែលទាក់ទងនឹងការទាមទារតាមផ្លូវបណ្ដឹង ។ នៅក្នុងបណ្ដឹងទាមទារនូវសំណងនៃការខូចខាត ដោយមានមូលហេតុបំពានកម្មសិទ្ធិ ការអះអាងអំពីមូលហេតុធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ដូចជា ការបង្កើតកិច្ចសន្យាលក់ទិញ ឬ ការសម្រេចនូវអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ជាដើម (មធ្យោបាយតទល់) និង ការអះអាងអំពីការរំលាយ ឬ ការលុបចោលនូវកិច្ចសន្យាលក់ទិញ ជាដើម ដើម្បីធ្វើវិវាទចំពោះការអះអាងអំពីមូលហេតុធ្វើលទ្ធកម្មនូវកម្មសិទ្ធិ (មធ្យោបាយតទល់) គឺជាឧទាហរណ៍នៃមធ្យោបាយតទល់ និង ការពារខ្លួនដែលអាចវិនិច្ឆ័យដោយឯករាជ្យបាន ។

(គ) អត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្ដឹង (មាត្រា ១៨១ ចំណុច គ)

ក្នុងករណីដែលមានវិវាទស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃល័ក្ខខ័ណ្ឌបណ្ដឹង ដូចជា អំពីអត្ថិភាពនៃសមត្ថកិច្ចជំនុំជម្រះក្ដីអន្តរជាតិលើរឿងក្ដី ឬ អំពីអត្ថិភាពនៃលក្ខណសម្បត្តិជាភាគីនៃដើមចោទ ឬ ចុងចម្លើយ ជាដើម តុលាការអាចចេញសាលក្រមរបៀប ដើម្បីដោះស្រាយវិវាទអំពីចំណុចនេះជាមុនបាន ។ ក៏ប៉ុន្តែ តុលាការអាចចេញសាលក្រមរបៀប តែចំពោះករណីដែលបានទទួលស្គាល់ថា ល័ក្ខខ័ណ្ឌបណ្ដឹងត្រូវបានបំពេញហើយតែប៉ុណ្ណោះ ។ ដោយហេតុនោះ ប្រសិនបើចៅក្រមវិនិច្ឆ័យថា ល័ក្ខខ័ណ្ឌបណ្ដឹងមិនគ្រប់គ្រាន់ទេ តុលាការត្រូវចេញសាលក្រមចុងក្រោយដែលលើកចោលបណ្ដឹងនោះ ។

(ឃ) ហេតុដែលទាក់ទងនឹងការបញ្ចប់បណ្ដឹង (មាត្រា ១៨១ ចំណុច ឃ)

បើទោះជាមើលទៅហាក់ដូចជាបណ្ដឹងចប់ហើយ ដោយសារការដកពាក្យបណ្ដឹង ការសះជាតាមផ្លូវបណ្ដឹង ឬ ដោយហេតុផលណាមួយផ្សេងក៏ដោយ ក៏អាចមានករណីដែលមានការអះអាងអំពីមោឃភាពនៃសកម្មភាពនោះ ហើយមានវិវាទកើតឡើងចំពោះបញ្ហាថាតើបណ្ដឹងនោះចប់ហើយ ឬនៅ ។ ក្នុងករណីនេះ ប្រសិនបើភាគីដាក់ពាក្យសុំឱ្យកំណត់កាលបរិច្ឆេទ ដោយអះអាងថា បណ្ដឹងនោះនៅតែចាត់ការដោយតុលាការ ពេលនោះ តុលាការត្រូវកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវវិនិច្ឆ័យអំពីសុពលភាព ឬ មោឃភាពនៃសកម្មភាពដែលជាមូលហេតុនៃការបញ្ចប់បណ្ដឹងនោះ ។ ប្រសិនបើវិនិច្ឆ័យថា សកម្មភាពដែលបញ្ចប់បណ្ដឹងនោះ មោឃៈ តុលាការត្រូវប្រកាសអំពីមោឃភាពនោះដោយសាលក្រមរបៀប ។ នេះគឺជាសាលក្រមរបៀបស្ដីពីការបញ្ចប់បណ្ដឹង ។ ក្នុងករណីដែលបានទទួលស្គាល់ថា មូលហេតុនៃការបញ្ចប់បណ្ដឹងមានសុពលភាព តុលាការត្រូវចេញសាលក្រមចុងក្រោយដោយមានខ្លឹមសារថា "បណ្ដឹងត្រូវបានបញ្ចប់ដោយការដកពាក្យបណ្ដឹង (ឬក៏ ដោយការសះជា ជាដើម)" ។

(៣) អានុភាពនៃសាលក្រមរបៀប

ដោយហេតុថា សាលក្រមរបៀប មានគោលបំណងសម្រេចសេចក្ដីចំពោះចំណុចដែលជាបុរេល័ក្ខខ័ណ្ឌនៃសាលក្រមចុងក្រោយ មុននឹងចេញសាលក្រមចុងក្រោយនោះ ដូច្នេះ ពេលដែលតុលាការបានចេញសាលក្រមរបៀបហើយ សាលក្រមរបៀបនេះ ត្រូវចងតុលាការ ហើយពេលចេញសាលក្រមចុងក្រោយ តុលាការមិនអាច

សម្រេចដោយផ្ទុយនឹងអ្វីដែលសម្រេចដោយសាលក្រមរបៀបនេះបានទេ ។ ដូច្នេះ ភាគីក៏មិនអាចធ្វើការអះអាងដែលផ្ទុយនឹងសាលក្រមរបៀបនេះ ដោយផ្អែកលើមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលអាចត្រូវបានដាក់មុនពេលចេញសាលក្រមរបៀបបានឡើយ ។

ក៏ប៉ុន្តែ ដោយសារតែសាលក្រមរបៀបពុំមានអានុភាពអ្វីផ្សេង ក្រៅពីអានុភាពដើម្បីត្រៀមចេញសាលក្រមចុងក្រោយនៃការជំនុំជម្រះនៅថ្នាក់នោះទេនោះ វាពុំមានអាជ្ញាអស់ជំនុំ ឬ អានុភាពអនុវត្តទេ ។ ម្យ៉ាងទៀតចំពោះសាលក្រមរបៀប មិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានបានទេ (មាត្រា ២៦០ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមចុងក្រោយ តុលាការនៃបណ្តឹងឧទ្ធរណ៍ក៏ត្រូវពិនិត្យមើលពីភាពត្រឹមត្រូវ នៃសាលក្រមរបៀបនោះដែរ (មាត្រា ២៦២) ។

## កថាភាគទី ២ ការបង្កើតសាលក្រម

### ១. ការបង្កើតនូវខ្លឹមសារនៃសាលក្រម

ជាគោលការណ៍ សាលក្រមត្រូវធ្វើឡើងដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១, លើកលែងតែករណីដូចចែងក្នុងមាត្រា មាត្រា ៨១ ជាអាទិ៍) ។ ហេតុនេះហើយខ្លឹមសារនៃសាលក្រមត្រូវបានបង្កើតឡើងដោយយកធនធានបណ្តឹង ដែលត្រូវបានដាក់ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ។ ពេលណាខ្លឹមសារនៃសាលក្រមនោះត្រូវបានបង្កើតឡើងហើយ ខ្លឹមសារទាំងនោះត្រូវសរសេរបង្ហាញក្នុងលិខិតសាលក្រម តាមទម្រង់ដែលមានចែងក្នុងមាត្រា ១៨៩ ។ ចំណុចដូចខាងក្រោម ត្រូវសរសេរចូលទៅក្នុងលិខិតសាលក្រម ។ ម្យ៉ាងទៀតបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ស្តីពីការធ្វើសាលក្រម (មាត្រា ១១៤ កថាខណ្ឌទី ១ និង ពីមាត្រា ១៨៦ ដល់មាត្រា ១៩០) ក៏ត្រូវអនុវត្តដូចគ្នាចំពោះសាលក្រមរបៀបដែរ ។ ការពន្យល់ខាងក្រោម មានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងសាលក្រមចុងក្រោយ ។

① តុលាការ

② ថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

③ ភាគី (ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីដែលមានអ្នកតំណាងដែលច្បាប់បានកំណត់)

④ អង្គហេតុ និង ចំណុចវិវាទ

⑤ សំអាងហេតុ

⑥ សេចក្តីសម្រេចបញ្ចប់ ។

### ២. ការបង្កើតលិខិតសាលក្រម

(១) អង្គហេតុ និង ចំណុចវិវាទ

ជាបឋម ត្រូវសរសេរអំពីការទាមទាររបស់ដើមចោទ បន្ទាប់មក ត្រូវសង្ខេបរឿងក្តីនោះ ដោយបញ្ជាក់ថា តើរឿងក្តីនោះជាបណ្តឹងដែលទាក់ទងនឹងការទាមទារអ្វី ។ បន្ទាប់មកទៀត សរសេរបញ្ជាក់អំពីអង្គហេតុដែលគ្មានវិវាទ និង រៀបរាប់អំពីចំណុចវិវាទដែលជាបញ្ហារវាងភាគី ដោយផ្អែកលើលទ្ធផលនៃការរៀបចំនូវការអះអាងរបស់ភាគី ក្នុងដំណាក់កាលនៃការវិនិច្ឆ័យ ។

(២) សំអាងហេតុ

ត្រូវចុះអំពីការវិនិច្ឆ័យរបស់តុលាការចំពោះចំណុចវិវាទ ។ ឧទាហរណ៍ ក្នុងរឿងក្តីដែល A បានទាមទារឱ្យ B សងប្រាក់កំចី ១០ លានរៀល តែ B បានអះអាងតវ៉ាថា ខ្លួនបានសងរួចហើយ តុលាការត្រូវសរសេរចូលថា តើតុលាការទទួលស្គាល់នូវអង្គហេតុសងប្រាក់ ដោយភស្តុតាងអ្វីខ្លះ ឬ ត្រូវសរសេរអំពីលទ្ធផលនៃការអនុវត្ត ឬ ការបកស្រាយក្រមរដ្ឋប្បវេណី ចំពោះចំណុចវិវាទតាមផ្លូវច្បាប់ ស្តីពីការសងនោះ ជាដើម ។ ដូច្នេះហើយ នៅចំណុច "សំអាងហេតុ" ត្រូវសរសេរបញ្ជាក់អំពីមូលហេតុ (សំអាងហេតុ) សម្រាប់ការវិនិច្ឆ័យដែលបានចុះនៅក្នុងសេចក្តីសម្រេចបញ្ចប់ ដោយចុះអំពីចំណុចវិវាទ និង ការវិនិច្ឆ័យចំពោះចំណុចវិវាទនេះ ។

(៣) សេចក្តីសម្រេចបញ្ចប់

សេចក្តីសម្រេចបញ្ចប់ចុះអំពីការសរុបសេចក្តីចំពោះការវិនិច្ឆ័យរបស់តុលាការ មានន័យថា ជាការសរុបនូវការឆ្លើយតប ចំពោះការទាមទារនូវសាលក្រមដែលមានខ្លឹមសារកំណត់មួយ ដែលដើមចោទបានសរសេរក្នុងវគ្គ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ" នៃពាក្យបណ្តឹង ។ ក្នុងករណីឧទាហរណ៍ខាងលើ ប្រសិនបើតុលាការ ទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ក្នុងវគ្គ "សេចក្តីសម្រេចបញ្ចប់" តុលាការត្រូវសរសេរថា "ចុងចម្លើយត្រូវបង់ប្រាក់ ១០ លានរៀល ទៅដើមចោទ ។ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ" ។ ផ្ទុយទៅវិញ ប្រសិនបើតុលាការច្រានចោលនូវការទាមទាររបស់ដើមចោទវិញ តុលាការត្រូវសរសេរថា "ច្រានចោលនូវការទាមទាររបស់ដើមចោទ ។ ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ" ។ ប្រសិនបើតុលាការភ្ជាប់នូវការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន ជាមួយនឹងសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន (មាត្រា ១៩៦) តុលាការត្រូវសរសេរនៅក្រោមសេចក្តីសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះថា "ប្រសិនបើដើមចោទបានដាក់ប្រាតិភោគចំនួន ១០ ម៉ឺនរៀល សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន" ។

(៤) ចំណុចដទៃទៀត

ត្រូវសរសេរចូលអំពីតុលាការ អំពីថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង អំពីភាគី ។ ត្រូវកត់ចូលនូវឈ្មោះតុលាការដែលបានចេញសាលក្រម ឧទាហរណ៍ដូចជា សាលាដំបូងក្រុងភ្នំពេញ ជាដើម ។ ការត្រូវចុះថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺដើម្បីឱ្យបានច្បាស់លាស់អំពីមូលដ្ឋាននៃពេលវេលាសម្រាប់

កំណត់នូវអាជ្ញាអស់ជំនុំនៃសាលក្រម ។ ចៅក្រមដែលចេញសាលក្រម ត្រូវចុះហត្ថលេខា នៅក្នុងលិខិតសាលក្រមនោះ ( មាត្រា ១៨៩ កថាខណ្ឌទី ៣) ។

៣. ការបង្កើតសាលក្រម

ក្រោយពីបានធ្វើលិខិតសាលក្រម តុលាការត្រូវប្រកាសសាលក្រមនោះ ។ ជាគោលការណ៍ តុលាការត្រូវប្រកាសសាលក្រម ក្នុងអំឡុងពេលមួយខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧) ។ ការប្រកាសត្រូវធ្វើឡើងតាមវិធីដូចតទៅ : នៅកាលបរិច្ឆេទនៃការប្រកាសសាលក្រម ប្រធានក្រុមប្រឹក្សាជំនុំជម្រះ (ក្នុងករណីដែលការវិនិច្ឆ័យធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះ) ឬ ចៅក្រម (ចំពោះករណីការវិនិច្ឆ័យធ្វើឡើងដោយចៅក្រមទោល) អានសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រមដើមឱ្យឮៗ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ (មាត្រា ១៨៨ កថាខណ្ឌទី ១) ។ តុលាការមិនចាំបាច់អានអំពីសំអាងហេតុនៃសាលក្រមក៏បានដែរ ក៏ប៉ុន្តែ ក្នុងករណីដែលមានអ្នកចូលស្ដាប់ច្រើនគ្នា ឬ ក្នុងករណីដែលភាគីចង់ឱ្យពន្យល់ជាសាធារណៈអំពីសំអាងហេតុនោះ នៅសាលសវនាការ ជាដើម តុលាការអាចអានសំអាងហេតុនោះទាំងមូល ឬ ខ្លឹមសារសង្ខេបនៃសំអាងហេតុនោះឮៗបាន តាមឆន្ទានុសិទ្ធិ ( មាត្រា ១៨៨ កថាខណ្ឌទី ៣) ។ សាលក្រមនឹងមិនអាចត្រូវបានបង្កើតបានឡើយ រហូតទាល់តែការប្រកាសបានត្រូវធ្វើឡើង ។ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនអនុសារសាលក្រមទៅឱ្យភាគីក្នុងអំឡុងរយៈពេលពីរអាទិត្យ គិតបន្ទាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ ( មាត្រា ១៩០) ។

## កថាភាគទី ៣ អានុភាពនៃសាលក្រមចុងក្រោយ

ពេលដែលសាលក្រមចុងក្រោយត្រូវបានបង្កើតហើយ អានុភាពផ្សេងៗនឹងកើតមានឡើង ។ ជាក់ស្ដែងដូចជា អត្តពន្ធភាព អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ អានុភាពអនុវត្ត អានុភាពនៃការបង្កើត (ឬ ផ្លាស់ប្ដូរ ឬ រំលត់) សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ជាដើម ។ ក្នុងចំណោមនោះ អានុភាពបីដំបូង គឺជាអានុភាពរួម ចំពោះរាល់សាលក្រមទាំងអស់ ដោយឡែក អានុភាពនៃការអនុវត្ត ត្រូវកើតឡើង ចំពោះសាលក្រមបង្គាប់ឱ្យផ្ដល់តាវកាលិក ហើយអានុភាពនៃការបង្កើត (ឬ ផ្លាស់ប្ដូរ ឬ រំលត់) សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ត្រូវកើតឡើង ចំពោះសាលក្រមបង្កើត (ឬ ផ្លាស់ប្ដូរ ឬ រំលត់) សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ។

១. អត្តពន្ធភាព

(១) អត្ថន័យនៃអត្តពន្ធភាព

សាលក្រមនឹងត្រូវបានបង្កើតឡើងដោយការប្រកាស ហើយបន្ទាប់មក សាលក្រមនោះនឹងចងតុលាការដែលចេញសាលក្រមនោះ ហើយមិនអនុញ្ញាតឱ្យលុបចោល ឬ ប្ដូរបានឡើយ ។ នេះគឺដោយសារតែ សាលក្រមគឺជាការសំដែងចេញមកខាងក្រៅ នៃការវិនិច្ឆ័យដោយសិទ្ធិអំណាចសាធារណៈ ម្យ៉ាងទៀត ប្រសិនបើតុលាការអាច

លុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដោយងាយស្រួលទៅ នឹងធ្វើឱ្យបាត់បង់នូវស្ថិរភាពគតិយុត្ត ហើយធ្វើឱ្យខូចកិត្យានុភាពរបស់តុលាការទៀតផង ។ អានុភាពចងបែបនេះ គេហៅថា អត្តពន្ធភាពនៃសាលក្រម ( មាត្រា ១៩១) ។

(២) ដីកាសម្រេចកែតម្រូវ

បើទោះបីជាសាលក្រមមានអត្តពន្ធភាពក៏ដោយ ក៏ប៉ុន្តែ ប្រសិនបើនៅក្នុងសាលក្រមនោះ មានការគណនាខុស មានកំហុសខាងសំណេរ ឬ ក៏កំហុសជាក់ស្តែងស្រដៀងគ្នានេះផ្សេងទៀត ជាដើម តុលាការអាចធ្វើការកែតម្រូវបាន តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ( មាត្រា ១៩២) ។ នេះគឺដោយសារតែជាកំហុសច្បាស់លាស់ ហើយបើទោះជាអនុញ្ញាតឱ្យកែតម្រូវក៏ដោយ ក៏មិនធ្វើឱ្យមានការប៉ះពាល់ទៅដល់ស្ថិរភាពគតិយុត្តដែរ ។ ដើម្បីធ្វើការកែតម្រូវ តុលាការត្រូវសម្រេចសេចក្តីអំពីកន្លែងដែលត្រូវកែតម្រូវ និងអំពីរបៀបដែលត្រូវកែតម្រូវយ៉ាងណាវិញ ។ សេចក្តីសម្រេចនេះ ហៅថា "ដីកាសម្រេចកែតម្រូវ" ។

ឧទាហរណ៍ នៅក្នុងចំណុច "សំអាងហេតុ" នៃមូលសាលក្រម មានសរសេរដោយមានបង្ហាញពីមូលដ្ឋាននៃការគណនាថា "ចុងចម្លើយមានករណីយកិច្ចត្រូវបង់ប្រាក់ ១០ លានរៀល ជាសំណងនៃការខូចខាតទៅឱ្យដើមចោទ" ក៏ប៉ុន្តែ នៅក្នុង "សេចក្តីសម្រេចបញ្ចប់" មានសរសេរថា "ចុងចម្លើយត្រូវបង់ប្រាក់ ១ លានរៀល ទៅឱ្យដើមចោទ" ទៅវិញ ដែលក្នុងករណីនេះ គេឃើញច្បាស់ណាស់ថា តួលេខនៅក្នុងសេចក្តីសម្រេចបញ្ចប់ខុស ។ ក្នុងករណីដូចនេះ តុលាការអាចចេញដីកាសម្រេចកែតម្រូវទៅ តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីប្តូរចំនួនទឹកប្រាក់ "១ លានរៀល" ដែលបានចុះក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមនោះ ទៅជា "១០ លានរៀល" វិញ ។

២. អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់

(១) អត្ថន័យនៃអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់

សាលក្រមចូលជាស្ថាពរ នៅពេលដែលគេមិនអាចទាមទារឱ្យលុបសាលក្រមនោះចោល ដោយបណ្តឹងឧបាស្រ័យធម្មតា ដូចជា ការប្តឹងឧទ្ធរណ៍ ឬ ការប្តឹងសាទុក្ខបាន ។ ដោយសារតែគេអាចចាត់ទុកបានថា នេះជាលទ្ធផលនៃសេចក្តីវិនិច្ឆ័យដែលមានអានុភាពចង ដែលរារាំងសូម្បីតែតុលាការដែលមានថ្នាក់ខ្ពស់ជាង ក៏មិនអាចលុបចោលនូវសេចក្តីសម្រេចនោះបានដែរនោះ គេអាចនិយាយបានថា អានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់កើតមានឡើង ។ អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់នៃសាលក្រមនេះ គឺជាល័ក្ខខ័ណ្ឌមូលដ្ឋាននៃការកើតមានឡើងនូវអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ អានុភាពអនុវត្ត និង អានុភាពនៃការបង្កើត ផ្លាសប្តូរ ឬ រំលត់សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ។

(២) ពេលដែលសាលក្រមចូលជាស្ថាពរ

សាលក្រមនឹងចូលជាស្ថាពរ នៅពេលដូចខាងក្រោមនេះ :

(ក) ក្នុងករណីដែលភាគីដែលមានសិទ្ធិធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មិនបានប្ដឹងឧបាស្រ័យក្នុងអំឡុងពេលដែលបានកំណត់ឱ្យប្ដឹងឧបាស្រ័យទេ សាលក្រមត្រូវចូលជាស្ថាពរ នៅពេលដែលអំឡុងពេលនោះបានកន្លងផុតទៅ (មាត្រា ១៩៣ កថាខណ្ឌទី ១) ។ ក្នុងករណីដែលភាគីអាចប្ដឹងទាស់បាន ចំពោះសាលក្រមកំបាំងមុខ (មាត្រា ២០៤ កថាខណ្ឌទី ១) តែភាគីបែរជាមិនបានធ្វើបណ្ដឹងទាស់ក្នុងអំឡុងពេលដែលបានកំណត់នោះ (ពីរសប្ដាហ៍ ដោយគិតពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ) ក៏ដោយ ក៏សាលក្រមកំបាំងមុខមិនទាន់ចូលជាស្ថាពរទេ ពីព្រោះភាគីនៅមានសិទ្ធិប្ដឹងឧទ្ធរណ៍ ក្នុងអំឡុងពេលប្ដឹងឧទ្ធរណ៍ (១ ខែ ដោយគិតពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រម) ទៀត ។ ដូច្នេះហើយ ទាល់តែអំឡុងពេលប្ដឹងឧទ្ធរណ៍នោះបានកន្លងផុតទៅ ទើបសាលក្រមនោះចូលជាស្ថាពរ ។

(ខ) ទោះជាមុនផុតអំឡុងពេលប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទៅក៏ដោយ ប្រសិនបើភាគីដែលមានសិទ្ធិធ្វើបណ្ដឹងឧបាស្រ័យបានបោះបង់ចោលនូវសិទ្ធិនោះ សាលក្រមត្រូវចូលជាស្ថាពរនៅពេលដែលមានការបោះបង់ចោលនូវសិទ្ធិនោះ (មាត្រា ២៦៣ និង មាត្រា ២៨៦) ។ ហើយបើភាគីអាចប្ដឹងទាស់ ចំពោះសាលក្រមកំបាំងមុខបាន សាលក្រមត្រូវចូលជាស្ថាពរ នៅពេលដែលមានការបោះបង់សិទ្ធិធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ផង សិទ្ធិប្ដឹងទាស់ផង ។

(គ) ក្រោយពីការប្រកាសសាលក្រមចុងក្រោយ ប្រសិនបើភាគីទាំងសងខាងបានព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍ សាលក្រមនោះត្រូវចូលជាស្ថាពរ ពេលដែលមានការព្រមព្រៀងនោះ (មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ក) ។ ក្នុងករណីនេះក៏ដូចគ្នាដែរ បើអាចប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខបាន សាលក្រមនោះត្រូវចូលជាស្ថាពរ នៅពេលដែលភាគីព្រមព្រៀងផងដែរថា មិនប្ដឹងទាស់ ក្រៅពីការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍ ។

(ឃ) បើមានពាក្យបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានភាពត្រឹមត្រូវតាមច្បាប់ នៅក្នុងអំឡុងពេលកំណត់សម្រាប់បណ្ដឹងឧបាស្រ័យនោះ ការចូលជាស្ថាពរនៃសាលក្រម នឹងត្រូវបង្អាក់ (មាត្រា ១៩៣ កថាខណ្ឌទី ២) ។ ក្នុងករណីនេះ ប្រសិនបើសាលក្រមដែលច្រានចោលបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយសារថា គ្មានមូលហេតុប្ដឹងឧបាស្រ័យ ឬ សាលក្រមដែលលើកចោលបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយសារបណ្ដឹងឧបាស្រ័យនោះមិនត្រឹមត្រូវតាមច្បាប់ បានចូលជាស្ថាពរ ពេលនោះ សាលក្រមដើមនៃបណ្ដឹងនោះក៏ចូលជាស្ថាពរទន្ទឹមគ្នាដែរ ។ ប្រសិនបើបណ្ដឹងទាស់ត្រូវបានធ្វើឡើងត្រឹមត្រូវតាមច្បាប់ ក្នុងអំឡុងពេលកំណត់សម្រាប់បណ្ដឹងទាស់ ហើយនីតិវិធីនៃបណ្ដឹងត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមានកើតឡើង (មាត្រា ២០៨ កថាខណ្ឌទី ១) សាលក្រមកំបាំងមុខនោះ ត្រូវចូលជាស្ថាពរព្រមគ្នានឹងពេលដែលសាលក្រមប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះ ចូលជាស្ថាពរ (មាត្រា ២០៩ កថាខណ្ឌទី ១) ។ ក្នុងករណីដែលមានដីកាសម្រេចលើកចោលនូវបណ្ដឹងទាស់ ដោយសារបណ្ដឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ ឬ ដីកាសម្រេចច្រានចោលនូវបណ្ដឹងទាស់ ដោយសារថា គ្មានមូលហេតុប្ដឹងទាស់ (មាត្រា ២០៧ កថាខណ្ឌទី

១) ភាគីដែលបានដាក់បណ្តឹងទាស់ អាចប្តឹងឧទ្ធរណ៍បាន ក្នុងអំឡុងពេល ១ ខែ ដោយគិតពីថ្ងៃដែលបានទទួលនូវការជូនដំណឹងអំពីដីកាសម្រេចនោះ ហេតុនេះហើយ ពេលវេលានៃការចូលជាស្ថាពរនៃសាលក្រមកំបាំងមុខ គឺដូចក្នុងចំណុច (ក) ខាងលើនេះដែរ ។

៣. អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

(១) អត្ថន័យនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

ប្រសិនបើបញ្ហាដែលបានវិនិច្ឆ័យដោយសាលក្រមចុងក្រោយដែលបានចូលជាស្ថាពរ បានក្លាយជាបញ្ហាក្នុងបណ្តឹងមួយផ្សេងទៀត ភាគីមិនត្រូវអនុញ្ញាតឱ្យធ្វើការការអះអាងដែលមានភាពផ្ទុយគ្នានឹងការវិនិច្ឆ័យដែលបានធ្វើហើយក្នុងសាលក្រមស្ថាពរទេ ហើយតុលាការក៏មិនត្រូវអនុញ្ញាតឱ្យធ្វើការវិនិច្ឆ័យដែលមានភាពផ្ទុយគ្នានឹងការវិនិច្ឆ័យដែលបានធ្វើហើយក្នុងសាលក្រមស្ថាពរនោះឡើយ ។ អានុភាពនៃការវិនិច្ឆ័យនៅក្នុងសាលក្រមស្ថាពរ ដែលចងនូវខ្លឹមសារនៃការវិនិច្ឆ័យក្រោយពេលនោះ ត្រូវហៅថា អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ (មាត្រា ១៩៤) ។

មូលហេតុដែលទទួលស្គាល់នូវអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនេះមានដូចតទៅ : ប្រសិនបើសាលក្រមស្ថាពរមិនមានអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ភាគីដែលចាញ់បណ្តឹង អាចនឹងធ្វើបណ្តឹងជាបន្តបន្ទាប់គ្នាមិនដាច់ រហូតដល់តុលាការទទួលស្គាល់នូវការអះអាងរបស់ខ្លួន ហេតុនេះ ជាលទ្ធផល វិវាទនឹងមិនដែលអាចត្រូវបានដោះស្រាយចប់ឡើយ ។ ហើយ ម្យ៉ាងទៀត ប្រសិនបើតុលាការអាចធ្វើការវិនិច្ឆ័យដែលមានភាពផ្ទុយគ្នានឹងសាលក្រមស្ថាពរទៅ ស្ថិរភាពគតិយុត្តនឹងត្រូវបំផ្លាញ ហើយគោលបំណងនៃប្រព័ន្ធបណ្តឹង ក៏មិនអាចសម្រេចបានដែរ ។ ដូច្នេះហើយ ដើម្បីការពារកុំឱ្យមានភាពច្រំដែលឥតទំនងចំពោះវិវាទតែមួយ ហើយដើម្បីឱ្យមានស្ថិរភាពគតិយុត្ត គេទទួលស្គាល់នូវអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនេះ ។

ឱ្យតែសាលក្រមចុងក្រោយបានចូលជាស្ថាពរ ទោះជាសាលក្រមបញ្ជាក់ ឬ សាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិកក៏ដោយ ឬ សាលក្រមបង្កើតទំនាក់ទំនងគតិយុត្តក៏ដោយ សុទ្ធតែមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុទាំងអស់ ។ ឧទាហរណ៍ ក្នុងបណ្តឹងទាមទារឱ្យបញ្ជាក់នូវកម្មសិទ្ធិលើដី ដែល A បានប្តឹងចំពោះ B ប្រសិនបើសាលក្រមដែលទទួលស្គាល់នូវការទាមទាររបស់ A បានចូលជាស្ថាពរ អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនឹងកើតមានឡើង ចំពោះការវិនិច្ឆ័យដែលទទួលស្គាល់ថា A ជាម្ចាស់កម្មសិទ្ធិលើដីនោះ ។ ម្យ៉ាងទៀត ក្នុងបណ្តឹងទាមទារឱ្យសងប្រាក់កំចីចំនួន ១០ លានរៀល ដែល A បានធ្វើចំពោះ B ប្រសិនបើសាលក្រមដែលច្រានចោលនូវការទាមទាររបស់ A នោះបានចូលជាស្ថាពរ ការវិនិច្ឆ័យអំពីនត្ថិភាពនៃសិទ្ធិទាមទារឱ្យសងប្រាក់កំចីចំនួន ១០ លានរៀល របស់ A ចំពោះ B នោះ មានអានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ។

ដោយព្រោះអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មានអានុភាពខ្លាំងក្លាដូចរៀបរាប់ខាងលើ ដូច្នេះហើយ បានជាវិសាលភាពនៃអានុភាពនោះត្រូវតែកំណត់ន័យឱ្យច្បាស់លាស់ ។ ដូចមានសរសេរនៅខាងក្រោមនេះ

វិសាលភាពនៃអានុភាពរបស់អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ត្រូវបានកម្រិត ដោយផ្អែកលើទស្សនៈវិស័យ បី គឺ : ពេលវេលា កម្មវត្ថុ និង បុគ្គល (ប្រធាន) ។ កម្រិតទាំងនេះគេហៅថា វិសាលភាពនៃពេលវេលា វិសាលភាពនៃកម្មវត្ថុ និង វិសាលភាពនៃប្រធាន ។

(២) វិសាលភាពនៃពេលវេលាដែលមានអានុភាពនៃអាជ្ញាអស់ជំនុំជាសារធាតុ (វិសាលភាពនៃពេលវេលានៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ)

(ក) វិសាលភាពនៃពេលវេលានៃអាជ្ញាអស់ជំនុំជាសារធាតុនេះ មានប្រភពពីបញ្ហាថាតើសាលក្រមស្ថាពរវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹង ដោយយកពេលវេលាណាមួយជាមូលដ្ឋាន ។ ដោយព្រោះសិទ្ធិ ឬ ទំនាក់គតិយុត្តផ្នែករដ្ឋប្បវេណី មានការផ្លាស់ប្តូរទៅតាមពេលវេលា ហេតុនេះហើយ សិទ្ធិ ឬ ទំនាក់គតិយុត្តដែលត្រូវបានកំណត់ជាស្ថាពរ ដោយអាជ្ញាអស់ជំនុំជាសារធាតុនោះ គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តក្នុងពេលវេលាកំណត់ច្បាស់មួយតែប៉ុណ្ណោះ ។ ឧទាហរណ៍ទោះបី A មានសិទ្ធិលើបំណុលចំពោះ B នៅពេលមួយក៏ដោយ ប្រសិនបើ B បានសងឱ្យ A ហើយសិទ្ធិលើបំណុលនោះក៏ត្រូវរលត់ដែរ ។ ឧទាហរណ៍មួយទៀត ប្រសិនបើ A មានកម្មសិទ្ធិលើដីមួយឡូតិ៍នៅពេលមួយក៏ដោយ ក៏កម្មសិទ្ធិនោះ នឹងត្រូវផ្ទេរទៅអ្នកដទៃដែរ បើមានការលក់ទិញ ឬ សន្តតិកម្មនៅក្រោយពេលនោះ ។ ជាសរុបមក មានន័យថា អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រម មានអានុភាពចងនៃវិនិច្ឆ័យស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹងនាពេលវេលាកំណត់មួយ ។

(ខ) តើពេលណាជាពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ? តុលាការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ដោយផ្អែកលើធនធានបណ្តឹងដែលត្រូវបានដាក់មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុ ។ ហេតុដូច្នេះ អាជ្ញាអស់ជមនុំជាលក្ខណៈជាសារធាតុ យកពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុ មកធ្វើជាមូលដ្ឋាន ។ មានន័យថា អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ កំណត់ជាស្ថាពរ នូវអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុ (មាត្រា ១៩៤ កថាខណ្ឌទី ២) ហើយពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុ ត្រូវហៅថាជាពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំ ។

(គ) ជាលទ្ធផលនៃអត្ថិភាពនៃពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ក្នុងករណីដែលភាគីចាញ់ក្តី ដោយមិនបានដាក់នូវការអះអាង ឬ ភស្តុតាងដែលអាចដាក់ នៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុទេ ភាគីនោះមិនអនុញ្ញាតឱ្យនឹងធ្វើវិវាទចំពោះអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនោះ ដោយដាក់ការអះអាង ឬ ភស្តុតាងនោះ នៅពេលក្រោយ ។ នេះគឺដោយសារតែ

ប្រសិនបើអនុញ្ញាតឱ្យធ្វើដូច្នេះទៅ វានឹងបាត់បង់នូវអត្ថន័យនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុហើយ ។ ដូច្នេះ ទោះបីជាភាគីមាន ឬ គ្មានកំហុសចំពោះការមិនបានដាក់ការអះអាង ឬ ភស្តុតាង មុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុក៏ដោយ ក៏ការដាក់ការអះអាង ឬ ភស្តុតាងទាំងនេះ ត្រូវបានរារាំងដោយអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុដែរ ។ អានុភាពនេះ ត្រូវបានហៅថា "អានុភាពបង្ខាំងនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ" ។ ប៉ុន្តែ បើទោះជាសាលក្រមបានចូលជាស្ថាពរហើយក៏ដោយ ចំពោះហេតុដែលកើតមានឡើង ក្រោយពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះទៅលើអង្គហេតុ ដែលជាពេលវេលាជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ក៏ភាគីអាចដាក់ការអះអាង ឬ ដាក់ភស្តុតាងនោះបានដែរ ។

(៣) កម្មវត្ថុដែលមានអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ (វិសាលភាពនៃកម្មវត្ថុនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ)

(ក) កម្មវត្ថុដែលមានអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ត្រូវបានកម្រិតទៅលើត្រឹមតែសេចក្ដីវិនិច្ឆ័យអំពីការទាមទារ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមប៉ុណ្ណោះ ហើយអានុភាពនេះ ពុំមានទៅលើសេចក្ដីវិនិច្ឆ័យ ក្នុងសំអាងហេតុនៃសាលក្រមនោះទេ (មាត្រា ១៩៤ កថាខណ្ឌទី ៣) ។ ចំពោះសាលក្រមបណ្ដឹងអង្គសេចក្ដី សេចក្ដីវិនិច្ឆ័យនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម គឺជាការវិនិច្ឆ័យអំពីការទាមទាររបស់ដើមចោទ ។ ការដែលមិនឱ្យអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មានអានុភាពទៅលើសេចក្ដីវិនិច្ឆ័យនៅក្នុងសំអាងហេតុ គឺដោយសារតែមូលហេតុដូចតទៅ : ដោយសារតែសេចក្ដីសន្និដ្ឋាននៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម គឺជាមានសារៈសំខាន់បំផុតសម្រាប់ភាគី ហើយប្រសិនបើឱ្យវិសាលភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ លាតសន្ធឹងទៅដល់សេក្ដីវិនិច្ឆ័យក្នុងសំអាងហេតុទៀតនោះ ភាគីពិតជាខំប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីទទួលបាននូវសេចក្ដីវិនិច្ឆ័យដែលមានផលប្រយោជន៍ដល់ខ្លួនដែលពាក់ព័ន្ធសូម្បីទៅនឹងបុរេលក្ខខ័ណ្ឌដែលមិនទាក់ទងជាមួយនឹងចំណុចវិវាទជាក់ស្ដែងសោះនោះ ។ ម្យ៉ាងទៀត ប្រសិនបើឱ្យអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មានអានុភាពទៅលើសេចក្ដីវិនិច្ឆ័យក្នុងសំអាងហេតុទៅ តុលាការក៏លែងអាចធ្វើការវិនិច្ឆ័យមួយ ដែលមានសភាពបត់បែនបានហើយ ។ ដោយសារតែមូលហេតុនេះហើយបានជាត្រូវកម្រិតវិសាលភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ឱ្យត្រឹមសេចក្ដីវិនិច្ឆ័យក្នុងសេចក្ដីសម្រេចបញ្ចប់ប៉ុណ្ណោះ ។

(ខ) ដោយសារសេចក្ដីវិនិច្ឆ័យរបស់តុលាការនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម គឺជាការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី ឬ ច្បាប់ភូមិបាលជាអាទិ៍) វិសាលភាពនៃអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ គឺដូចគ្នានឹងវិសាលភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់សារធាតុ ។ ហេតុដូច្នេះ ក្នុងករណីដែលមានសិទ្ធិទាមទារពីរ រវាងគូភាគីដូចគ្នា

ដែលមានខ្លឹមសារនៃតាវកាលិកតែមួយដូចគ្នា បើទោះជាតុលាការបានចេញសាលក្រមច្រានចោលនូវការទាមទាររបស់ដើមចោទ ក្នុងបណ្ដឹងដែលដើមចោទដាក់ ដោយអះអាងអំពីសិទ្ធិទាមទារណាមួយ ហើយសាលក្រមនោះចូលជាស្ថាពរក៏ដោយ ក៏អានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមស្ថាពរនោះ ពុំមានអានុភាពទៅលើសិទ្ធិទាមទារមួយទៀតឡើយ ។ ឧទាហរណ៍ ក្នុងបណ្ដឹងដែល A បានដាក់ ដោយអះអាងអំពីសិទ្ធិទាមទារឱ្យសងប្រាក់កំចី ១០ លានរៀល ចំពោះ B ទោះជាសាលក្រមច្រានចោលនូវការទាមទារនោះបានចូលជាស្ថាពរក៏ដោយ ក៏អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនោះ ពុំមានអានុភាពទៅលើសិទ្ធិទាមទារឱ្យសងទឹកប្រាក់ ១០ លានរៀល ដោយផ្អែកលើសេចក្ដីចម្រើនដោយឥតហេតុ ដោយយកមោឃភាពនៃកិច្ចសន្យាខ្ចីបរិភោគនោះ មកធ្វើជាមូលហេតុពុំមានសុពលភាពដែរ ។ ហេតុនេះហើយ A មិនត្រូវបានហាមឃាត់មិនឱ្យដាក់បណ្ដឹងម្ដងទៀត ដើម្បីទាមទារឱ្យ B បង់ប្រាក់ ១០ លានរៀល ដោយអះអាងនូវសិទ្ធិទាមទារឱ្យសងសេចក្ដីចំរើនឥតហេតុឡើយ ។ ម្យ៉ាងទៀត អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមស្ថាពរដែលច្រានចោលនូវការទាមទារឱ្យប្រគល់អាគារមកវិញ ដោយផ្អែកលើកម្មសិទ្ធិ ពុំមានអានុភាពទៅលើសិទ្ធិទាមទារឱ្យប្រគល់នូវអាគារដដែល ដោយផ្អែកលើការបញ្ចប់នៃភតិសន្យាទេ ។ ក្នុងន័យនេះ វិសាលភាពដែលអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុខុសៗគ្នា អាស្រ័យទៅលើភាពដូចគ្នា ឬ មិនដូចគ្នានៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់សារធាតុ ។

(គ) ហេតុនេះហើយ ការដែលវិសាលភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ត្រូវបានកម្រិត ចំពោះតែវិសាលភាពនៃការវិនិច្ឆ័យនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ស្ដីពីការទាមទារនោះ មិនមែនមានន័យថា គ្រាន់តែមើលសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមទៅ យើងអាចដឹងបានអំពីវិសាលភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនោះបានទេ ដោយហេតុថា មានករណីដែលសេចក្ដីសម្រេចបញ្ចប់មិនបង្ហាញច្បាស់ៗថា អ្វីទៅជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមច្បាប់សារធាតុ ដែលជាកម្មវត្ថុនៃបណ្ដឹងនោះទេ ។ ឧទាហរណ៍ ប្រសិនបើសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម មានសរសេរថា "ចុងចម្លើយត្រូវបង់ប្រាក់ ១០ លានរៀលទៅឱ្យដើមចោទ" ក៏ដោយ សិទ្ធិនោះ អាចជាសិទ្ធិទាមទារឱ្យសងប្រាក់កំចី ឬ អាចជាសិទ្ធិទាមទារឱ្យសងសេចក្ដីចម្រើនដោយឥតហេតុក៏បាន ។ ដើម្បីឱ្យដឹងថា ជាសិទ្ធិណាមួយនោះ ចាំបាច់ត្រូវមើលអង្គហេតុ ឬ សំអាងហេតុដែលមានសរសេរក្នុងសាលក្រមនោះ ។ មានន័យថា អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មានអានុភាពត្រឹមតែការវិនិច្ឆ័យនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមក៏ពិតមែន ក៏ប៉ុន្តែ ដើម្បីកំណត់នូវខ្លឹមសារ ឬ វិសាលភាពនៃការវិនិច្ឆ័យនៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនោះ មានករណីខ្លះដែលចាំបាច់ត្រូវពិចារណាមើលនូវសេចក្ដីវិនិច្ឆ័យដែលមានសរសេរក្នុងសំអាងហេតុនៃសាលក្រមដែរ ។

(ឃ) មានករណីលើកលែងពិសេសនៃគោលការណ៍ "អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មិនមានអានុភាពចំពោះការវិនិច្ឆ័យនៅក្នុងសំអាងហេតុនៃសាលក្រម" ដែរ ។ ការវិនិច្ឆ័យចំពោះការតវ៉ាអំពីការទូទាត់ គឺជា

ការវិនិច្ឆ័យនៅក្នុងសំអាងហេតុនៃសាលក្រម ក៏ប៉ុន្តែ ការវិនិច្ឆ័យថា គ្មានសិទ្ធិលើបំណុលតបទេ ត្រូវបង្កើតអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ (មាត្រា ១៩៤ កថាខណ្ឌទី ៤) ។ ការទូទាត់ គឺខុសពីការតវ៉ាដទៃទៀត ដែលតាមរយៈនេះ ភាគីយកអានុភាពនៃការរលត់សិទ្ធិដែលដើមចោទអះអាងក្នុងនាមជាកម្មវត្ថុតាមផ្លូវបណ្ដឹង មកធ្វើជាការតវ៉ា ដោយយកសិទ្ធិលើបំណុលតបដែលគ្មានពាក់ព័ន្ធនឹងមូលហេតុនៃការកើតឡើងនៃសិទ្ធិដែលអះអាងនោះ មកធ្វើការទូទាត់ (ក្រមរដ្ឋប្បវេណី មាត្រា ៤៦៤ កថាខណ្ឌទី ១) ។ ដូច្នេះ ប្រសិនបើមិនទទួលស្គាល់នូវអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ចំពោះការវិនិច្ឆ័យអំពីសិទ្ធិលើបំណុលតបទេ វិវាទស្ដីពីការទាមទារ នឹងត្រូវប្ដូរទៅជាវិវាទស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិលើបំណុលតបទៅវិញ ហើយអាចធ្វើឱ្យបាត់បង់នូវប្រសិទ្ធិភាពជាក់ស្ដែងនៃការដោះស្រាយវិវាទដោយសាលក្រម ។ ឧទាហរណ៍ ពេល A ដាក់ពាក្យបណ្ដឹងអះអាងសិទ្ធិទាមទារឱ្យសងប្រាក់កំចីចំនួន ១០ លានរៀល ពី B នោះ B បានអះអាងអំពីការតវ៉ាថា ខ្លួនទូទាត់សិទ្ធិទាមទាររបស់ A ជាមួយសិទ្ធិលើបំណុលតបជាទឹកប្រាក់ថ្លៃលក់ចំនួន ១២ លានរៀល ដែលខ្លួនមាន ។ ក្នុងបណ្ដឹងនេះ ប្រសិនបើតុលាការមិនទទួលស្គាល់នូវអត្ថិភាពនៃសិទ្ធិលើបំណុលទាមទារឱ្យបង់ថ្លៃលក់ ដែលអះអាងដោយ B ទេ A អាចឈ្នះក្ដីបាន ដោយសារ ការតវ៉ាអំពីការទូទាត់របស់ B នោះគ្មានមូលដ្ឋាន ។ ក្រោយពី B បានសងប្រាក់ ១០ លានរៀល ទៅ A ហើយ B បានដាក់ពាក្យបណ្ដឹងទាមទារ ចំពោះ A ឱ្យសងប្រាក់ដោយអះអាងអំពីសិទ្ធិលើបំណុលនៃថ្លៃលក់ទិញដដែលនោះ ។ ប្រសិនបើការវិនិច្ឆ័យថា សិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញរបស់ B ក្នុងសំអាងហេតុនៃសាលក្រមនៃបណ្ដឹងមុន ពុំមានអានុភាពជាអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុទេ ជាលទ្ធផល B អាចធ្វើបណ្ដឹងទាមទារយកលុយ ១០ លានរៀលនោះមកវិញបាន ដោយយកសិទ្ធិលើបំណុលនៃប្រាក់ថ្លៃលក់ទិញដដែលមកធ្វើជាមូលហេតុ ។ ផ្ទុយទៅវិញ ក្នុងបណ្ដឹងមុន ប្រសិនបើតុលាការបានចេញសាលក្រមច្រានចោលនូវការទាមទាររបស់ A ដោយសំអាងហេតុថា សិទ្ធិលើបំណុលរបស់ B ចំពោះកិច្ចសន្យាទិញលក់មានអត្ថិភាព ហើយសិទ្ធិទាមទារឱ្យសងប្រាក់កំចីរបស់ A បានរលត់ ដោយការទូទាត់ ហើយសាលក្រមនោះបានចូលជាស្ថាពរ ប៉ុន្តែ ប្រសិនបើការវិនិច្ឆ័យនៅក្នុងសំអាងហេតុនៃសាលក្រមនៃបណ្ដឹងមុន ថា សិទ្ធិទាមទារឱ្យសងប្រាក់កំចីរបស់ A ត្រូវបានទូទាត់ទាំងស្រុងជាមួយនឹងសិទ្ធិលើបំណុលចំពោះថ្លៃលក់របស់ B ក្នុងតម្លៃជាទឹកប្រាក់ស្មើគ្នា (មានន័យថា ក្នុងកម្រិតនៃ ១០ លានរៀល) មិនមានអានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុទេ B អាចដាក់ពាក្យបណ្ដឹងប្រឆាំងនឹង A ដើម្បីទាមទារឱ្យសងទឹកប្រាក់ ១២ លានរៀលនោះបាន ហើយជាលទ្ធផល គឺ B អាចអនុវត្តសិទ្ធិលើបំណុលក្នុងក្របខណ្ឌ ១០ លានរៀលនោះបានដល់ទៅពីរដង ។ ដោយសារតែ A ច្បាស់ជាមិនទទួលយកនូវលទ្ធផលនេះទេនោះ វិវាទរវាងភាគីចំពោះអត្ថិភាពនៃបំណុលលើការទិញលក់ នឹងកើតមានឡើង ។ នេះគឺដោយសារតែមធ្យោបាយការពារខ្លួនដោយយកការទូទាត់ ខុសពីការសង ការលុបចោលនូវកិច្ចសន្យា ឬ អាជ្ញាយុកាលនៃការរលត់សិទ្ធិ មានលក្ខណៈពិសេស ត្រង់ចំណុចថា នៅក្នុងនោះ យកសិទ្ធិមួយផ្សេងដែល

ឯករាជ្យពីសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង មកធ្វើការលត់សិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង ហើយយកការលត់សិទ្ធិនោះ មកធ្វើការអះអាងជាមធ្យោបាយការពារខ្លួន ។

ដោយសារតែហេតុនេះហើយ បានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅពេលដែលមានការអះអាងការតវ៉ាអំពីការទូទាត់ អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ត្រូវកើតមានឡើងចំពោះការវិនិច្ឆ័យនៅក្នុងសំអាងហេតុនៃសាលក្រមស្ថាពរដែលវិនិច្ឆ័យថា សិទ្ធិលើបំណុលតបគ្មានអត្ថិភាព (បើទោះជាការទូទាត់ត្រូវបានទទួលស្គាល់ក៏ដោយ ក៏នឹងមានសេចក្តីសម្រេចថា គ្មានអត្ថិភាពនៃសិទ្ធិលើបំណុលតប នៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ដែរ) ។ ក៏ប៉ុន្តែ អានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនោះ ត្រូវបានកម្រិតចំពោះការវិនិច្ឆ័យត្រឹមតែទំហំនៃទឹកប្រាក់ដែលតតាំងដោយការទូទាត់នោះប៉ុណ្ណោះ (ក្នុងឧទាហរណ៍ខាងលើនេះ គឺជាការវិនិច្ឆ័យត្រឹមតែនត្ថិភាពនៃសិទ្ធិលើបំណុលរបស់ B ត្រឹមទំហំ ១០ លានរៀលប៉ុណ្ណោះ) ។ លើសពីនោះទៅទៀត ពីព្រោះអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ កើតមានឡើង តែពេលមានវិនិច្ឆ័យពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ នៃការទូទាត់តែប៉ុណ្ណោះ ដូច្នេះ អានុភាពនេះ នឹងមិនអាចកើតមានឡើង នៅពេលដែលការទូទាត់នោះត្រូវបានបដិសេធ ដោយសារតែគ្មានភាពសមស្របដើម្បីទូទាត់ (សូមមើលក្រមរដ្ឋប្បវេណី ពីមាត្រា ៤៦៧ ដល់មាត្រា ៤៧០) ។

(៤) ប្រធានដែលមានអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ (វិសាលភាពនៃប្រធាននៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ)

(ក) ភាគី

ចំពោះបញ្ហាថា តើអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ កើតមានឡើងរវាងអ្នកណា និង អ្នកណាវិញ គឺជា "បញ្ហាវិសាលភាពដោយអញ្ញថាភាព នៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ" ។ ជាគោលការណ៍ អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ នៃសាលក្រម មានអានុភាពរវាងភាគី (ដើមចោទ និង ចុងចម្លើយ) (មាត្រា ១៩៨ ចំណុច ក) ដែលមានឈ្មោះ នៅក្នុងលិខិតសាលក្រម (មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច គ) នោះ ។ វិវាទរដ្ឋប្បវេណី គឺជាវិវាទឯកជន ហេតុនេះហើយ វាគឺជាការគ្រប់គ្រាន់ហើយដែលត្រូវដោះស្រាយតែរវាងភាគីនៅក្នុងវិវាទ ។ លើសពីនោះ ប្រសិនបើអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មានអានុភាពរហូតទៅដល់ជនដែលមិនបានចូលរួមក្នុងបណ្តឹងទៀតនោះ វាជាការបំពានសិទ្ធិពឹងពាក់តុលាការរបស់ជននោះ (សូមមើលមាត្រា ២ កថាខណ្ឌទី ២ និង មាត្រា ៣ កថាខណ្ឌទី ១) ។ គោលការណ៍នេះគេហៅថា "គោលការណ៍មិនដាច់ខាតនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ" ។ ក៏ប៉ុន្តែ មានករណីពិសេស ដូចតទៅដែរ ដែលអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រម មានអានុភាពទៅលើជនក្រៅពីភាគីដែលមានឈ្មោះ នៅក្នុងលិខិតសាលក្រម ។

(ខ) ជនដែលមានផលប្រយោជន៍ជាសារវ័ន្តក្នុងករណីដែលជនដទៃទទួលបន្ទុកបណ្តឹង

ទី ១ គឺជាតតិយជន ក្នុងករណីដែលជនម្នាក់ដើរតួជាដើមចោទ ឬ ចុងចម្លើយជំនួសតតិយជននោះ (មាត្រា ១៩៨ ចំណុច ខ) ។ មានន័យថា ក្នុងករណីដែលជនដទៃទទួលបន្ទុកបណ្ដឹង អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមដែលទទួលដោយជនទទួលបន្ទុកបណ្ដឹងក្នុងនាមជាភាគី នឹងមានអានុភាពចំពោះជនដែលមានផលប្រយោជន៍ជាសារវ័ន្ត ផងដែរ ។ ឧទាហរណ៍ នៅក្នុងរបបជ្រើសរើសភាគី (មាត្រា ៤២) ជនដែលត្រូវបានជ្រើសរើស ក្លាយជាដើមចោទនៅក្នុងការធ្វើសកម្មភាពនៃបណ្ដឹងសម្រាប់អ្នកតែងតាំងដែលមានផលប្រយោជន៍រួម ។ នេះជាប្រភេទមួយនៃការទទួលបន្ទុកបណ្ដឹង (ដោយស្ម័គ្រចិត្ត) ។ ក្នុងករណីនេះ អ្នកដែលត្រូវបានជ្រើសរើស បានធ្វើជាដើមចោទសម្រាប់អ្នកជ្រើសរើស ហេតុនេះហើយ វិសាលភាពនៃអានុភាពសាលក្រមលាតសន្ធឹងទៅដល់អ្នកជ្រើសរើសដែរ ។ ចំពោះការទទួលបន្ទុកបណ្ដឹងដោយតតិយជន សូមមើលជំពូកទី ៣ ផ្នែកទី ៣ កថាភាគទី ៣. ២. (២) ខ) ។

(គ) ទី ២ គឺអ្នកទទួលបន្ត នៅក្រោយពេលបណ្ដឹងត្រូវបានចាត់ការ (មាត្រា ១៩៨ ចំណុច គ) ។ អ្នកទទួលបន្តគឺសំដៅទៅលើជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្ដឹង ក្រោយពេលបណ្ដឹងត្រូវបានចាត់ការ ។ ការទទួលបន្តនេះមានពីរប្រភេទ : ការទទួលបន្តទូទៅ (ការទទួលបន្តសកល) គឺអ្នកទទួលបន្តទទួលនូវសិទ្ធិ ឬ កាតព្វកិច្ចទាំងអស់របស់អ្នកដែលត្រូវបានបន្ត ដូចជាសន្តតិកម្ម និង ការរួមបញ្ចូលសហគ្រាស ជាដើម និង ការទទួលបន្តពិសេស ដែលជាការទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចជាក់លាក់ណាមួយ ដូចជា អនុប្បទាននូវសិទ្ធិលើបំណុល ឬ ការទទួលកាតព្វកិច្ច ជាដើម ។ ករណីទាំងពីរនេះអាចធ្វើឡើងដោយមធ្យោបាយទទួលបន្ត ។ វាមិនមែនជាបញ្ហាទេ ចំពោះមូលហេតុនៃការទទួលបន្ត បើទោះជាអនុប្បទានដោយស្ម័គ្រចិត្ត ដោយមានការព្រមព្រៀងពីភាគី ឬ ក៏ជាអនុប្បទានដោយបង្ខំដោយសកម្មភាពរបស់រដ្ឋក៏ដោយ (ការផ្ទេរដោយការដាក់លក់ឡាយឡុង ជាដើម) ។

(ឃ) ទី ៣ គឺជាបុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍របស់ភាគីនៃបណ្ដឹង ជាដើម (មាត្រា ១៩៨ ចំណុច ឃ) ។ វត្ថុដែលជាកម្មវត្ថុនៃបណ្ដឹង គឺជាវត្ថុជាក់លាក់ ក្នុងករណីដែលកម្មវត្ថុនៃបណ្ដឹង ជាសិទ្ធិទាមទារមានគោលបំណងផ្ដល់តាវកាលិតនូវវត្ថុជាក់លាក់នោះ ។ បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុ គឺជាជនដែលកាន់កាប់វត្ថុសម្រាប់អ្នកដទៃ ដូចជា និយោជិត អ្នកនៅជាមួយ ឬ អ្នកគ្រប់គ្រងថែរក្សាវត្ថុ ជាដើម ។ ដោយសារអ្នកទាំងនេះ ពុំមានផលប្រយោជន៍ដូចជាសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើវត្ថុនោះសម្រាប់ខ្លួនផ្ទាល់ទេ ហេតុនេះហើយ គួរតែឱ្យអាជ្ញាអស់ជំនុំលក្ខណៈសារធាតុមានអានុភាពទៅលើអ្នកទាំងនេះផងដែរ ហើយដែលការអនុវត្តបែបនេះ ក៏ មិនមានបង្កឱ្យមានគ្រោះថ្នាក់អ្វីដែរ ។

(ង) ករណីពិសេសទី ៤ គឺជាការពន្លាតនូវវិសាលភាពនៃអានុភាពនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុចំពោះតតិយជនទូទៅ ក្នុងករណីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល (សេចក្ដីព្រាងក្រមនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ១៦ កថាខណ្ឌទី ១) ។ ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល នៅពេលដែលតុលាការ

កំណត់ជាស្ថាពរអំពីអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គលដែលជាកម្មវត្ថុនៃបណ្តឹងនោះ វានឹងមិនទំនងទេដែលអានុភាពអាជ្ញាអស់ជំនុំ ចំពោះករណីនីមួយៗ រវាងជនដែលកំណត់មួយចំនួនដែលមានដូចជាភាគីជាដើម នោះ ហេតុនោះវាចាំបាច់ដែលអានុភាពត្រូវមានវិសាលភាពលាតសន្ធឹងទៅចំពោះតតិយជនទូទៅផ្សេងទៀតដូចៗគ្នាដែរ ។ ឧទាហរណ៍ បើបុត្តភាពរវាង A និង C កើតឡើង ចំពោះទំនាក់ទំនងរវាង A និង B ប៉ុន្តែបុត្តភាពរវាង A និង C គ្មានអត្ថិភាពចំពោះទំនាក់ទំនងរវាង A និង តតិយជនផ្សេងទៀតទេ ជីវភាពក្នុងសង្គមពិតជាច្របូកច្របល់ហើយ ។ ដោយហេតុនេះ អានុភាពនៃសាលក្រមស្ថាពរ នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ត្រូវតែពង្រីកវិសាលភាពរបស់វាទៅដល់តតិយជនទូទៅផងដែរ ។

(៥) មុខងារនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

(ក) ទម្រង់នៃមុខងារ

ប្រសិនបើអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលកំណត់ដោយសាលក្រមស្ថាពរក្លាយជាចំណុចវិវាទ នៅក្នុងបណ្តឹងលើកក្រោយ ភាគីមិនអាចធ្វើវិវាទដោយអះអាងថា ការវិនិច្ឆ័យនៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមស្ថាពរនោះ ដោយផ្អែកទៅលើការអះអាង ឬ ភស្តុតាងដែលកើតមានមុនពេលកំណត់ដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុបានទេ (អានុភាពបង្អាក់នៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ) ។ អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ មានអានុភាពចងតុលាការដែរ ដូច្នេះតុលាការក៏មិនអាចធ្វើការវិនិច្ឆ័យផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមស្ថាពរបានឡើយ (អានុភាពចងនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ) ។

ការប្តឹងម្តងទៀតអំពីសិទ្ធិ និង ទំនាក់ទំនងគតិយុត្តមួយដែលត្រូវបានវិនិច្ឆ័យរួចហើយនៅក្នុងសាលក្រមស្ថាពរមួយ មិនមែនផ្ទុយនឹងច្បាប់ដោយស្វ័យប្រវត្តិឡើយ ។ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមនីតិឯកជនដែលជាកម្មវត្ថុនៃសាលក្រមនៃបណ្តឹងរដ្ឋប្បវេណី អាចមានការផ្លាស់ប្តូរដោយកិច្ចសន្យា ឬ ដោយសន្តតិកម្មជាដើម គេអនុញ្ញាតឱ្យធ្វើបណ្តឹងចំពោះខ្លឹមសារនៃសាលក្រមស្ថាពរបាន ដោយលើកឡើងនូវមូលហេតុថ្មីដែលកើតមានឡើងនៅក្រោយពេលវេលាជាមូលដ្ឋាននោះ ។ ហេតុនេះហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យថាតើមានល័ក្ខខ័ណ្ឌថ្មីកើតឡើងក្រោយពេលវេលាដែលជាមូលដ្ឋាននោះដែរឬទេ ហើយប្រសិនបើយល់ឃើញថាមិនមានល័ក្ខខ័ណ្ឌនោះទេ តុលាការត្រូវវិនិច្ឆ័យដោយយោងតាមអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនោះ ។ម្យ៉ាងវិញទៀត បើទោះជាសាលក្រមច្រានចោលការទាមទារនៃបណ្តឹងមុន បានចូលជាស្ថាពរហើយក៏ដោយតុលាការក៏អាចចេញសាលក្រមមួយទទួលស្គាល់នូវការទាមទារនោះបានដែរ ប្រសិនបើតុលាការយល់ឃើញថាសិទ្ធិរបស់ដើមចោទត្រូវបានទទួលស្គាល់ ដោយហេតុថា មានមូលហេតុថ្មីកើតឡើងក្រោយពេលវេលាជាមូលដ្ឋាននោះ ។ ផ្ទុយទៅវិញ ក្នុងករណីដែលតុលាការមិនទទួលស្គាល់នូវមូលហេតុថ្មីនេះទេ តុលាការត្រូវច្រានចោលនូវការទាមទារនោះ ដោយយោងទៅតាមអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ។

(ខ) ការពិចារណាដោយឆន្ទានុសិទ្ធិ

អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ គឺជារបបដែលបង្កើតឡើងដើម្បីឱ្យមានស្ថិរភាពក្នុងជីវភាពគតិយុត្តរបស់ប្រជាជាតិទាំងមូល គឺ មិនមែនសម្រាប់បម្រើផលប្រយោជន៍ឯកជនរបស់ភាគីឡើយ ហេតុនេះហើយ បើទោះជាពុំមានការអះអាងរបស់ភាគីក៏ដោយ ក៏តុលាការត្រូវគោរពនូវអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុដោយឆន្ទានុសិទ្ធិរបស់ខ្លួន ហើយភាគីក៏មិនអាចរួចផុតពីចំណងនៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនោះ ដោយការព្រមព្រៀងណាមួយបានឡើយ ។ ក៏ប៉ុន្តែ ភាគីអាចផ្លាស់ប្តូរទំនាក់ទំនងនៃសិទ្ធិដែលបានកំណត់ដោយអាជ្ញាអស់ជំនុំនោះ ដោយកិច្ចសន្យាបាន ។ ក្នុងករណីនេះ អត្ថិភាពនៃកិច្ចសន្យានោះ គឺជាមូលហេតុថ្មីដែលកើតមានឡើងក្រោយពេលវេលាជាមូលដ្ឋាននោះ ។

(គ) អានុភាពនៃសាលក្រមដែលផ្ទុយនឹងអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

ទោះបីជាសាលក្រមមួយបានចេញផ្ទុយនឹងអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុក៏ដោយ ក៏មិនមែនមានន័យថាសាលក្រមនោះ នឹងក្លាយជាសាលក្រមមោឃៈឡើយ ប៉ុន្តែ ភាគីអាចសុំលុបសាលក្រមនោះបាន ដោយបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុច ៣) ។

៤. អានុភាពអនុវត្ត

តាមធម្មតា អានុភាពដែលអាចសម្រេចនូវសិទ្ធិទាមទារឱ្យផ្តល់គាវកាលិក ដែលមានសរសេរនៅក្នុងឯកសារណាមួយ ហៅថា "អានុភាពអនុវត្ត" ហើយឯកសារដែលត្រូវបានទទួលស្គាល់នូវអានុភាពអនុវត្ត ហើយនឹងក្លាយទៅជាមូលដ្ឋានគតិយុត្តនៃការអនុវត្តដោយបង្ខំនោះ គេហៅថា "លិខិតអនុវត្ត" (មាត្រា ៣៥០ កថាខណ្ឌទី ១) ។ សាលក្រមបង្គាប់ឱ្យផ្តល់គាវកាលិក មានអានុភាពអនុវត្ត ហើយអាចសម្រេចបាននូវសិទ្ធិទាមទារឱ្យផ្តល់គាវកាលិកដែលជាខ្លឹមសារនៃសាលក្រមនោះ ដោយការអនុវត្តដោយបង្ខំ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក និង ខ) ។ ក្នុងចំណោមសាលក្រមទាំងអស់ មានតែសាលក្រមបង្គាប់ឱ្យផ្តល់គាវកាលិកប៉ុណ្ណោះទេ ដែលមានអានុភាពអនុវត្ត ។ ឧទាហរណ៍ ក្នុងបណ្តឹងរបស់ A ទាមទារឱ្យ B សងប្រាក់កំចី ១០ លានរៀល ប្រសិនបើសាលក្រមដែលទទួលស្គាល់នូវការទាមទាររបស់ A បានចូលជាស្ថាពរហើយ ប៉ុន្តែ B នៅតែមិនបានសងប្រាក់ ១០ លានរៀលនោះដោយស្ម័គ្រចិត្តទៀត A អាចសម្រេចនូវសិទ្ធិនោះដោយការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅតុលាការ ។ ជាគោលការណ៍ អានុភាពអនុវត្តនៃសាលក្រមត្រូវកើតឡើង នៅពេលដែលអានុភាពអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុកើតមានឡើង មានន័យថា គឺនៅពេលដែលសាលក្រមចុងក្រោយបានចូលជាស្ថាពរ (មាត្រា ១៩៥) ។ ករណីលើកលែង គឺជាសាលក្រមបង្គាប់ឱ្យផ្តល់គាវកាលិក ដែលមានភ្ជាប់នូវការប្រកាសការអនុវត្តបណ្តោះអាសន្ន ដែលពន្យល់ខាងក្រោម ។

៥. អានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

អានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាអានុភាពបង្កើត ផ្លាស់ប្តូរ ឬ រំលត់នូវស្ថានភាពគតិយុត្ត តាមផ្លូវច្បាប់សារធាតុ ដោយផ្ទាល់ ដោយសាលក្រម ។ ក្នុងចំណោមសាលក្រមទាំងអស់ សាលក្រមដែលមានអានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺមានតែសាលក្រមបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តដែលទទួលស្គាល់នូវការទាមទារនៃបណ្តឹងទាមទារឱ្យបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តទេ ។ អានុភាពបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត នឹងកើតមានឡើង នៅពេលដែលសាលក្រមបង្គាប់ឱ្យបង្កើត ផ្លាស់ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្តបានចូលជាស្ថាពរ ។ ឧទាហរណ៍ ក្នុងករណីដែលមានបណ្តឹងធ្វើឡើងដោយ A ដែលជាប្រពន្ធ ប្តឹងលែងលះគ្នាចំពោះ B ដែលជាប្តី ប្រសិនបើតុលាការទទួលស្គាល់នូវការទាមទាររបស់ A ហើយបានចេញសាលក្រមថា "ដើមចោទ A និង ចុងចម្លើយ B ត្រូវលែងលះគ្នា" ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាង A និង B នឹងត្រូវរលាយ នៅពេលដែលសាលក្រមនោះបានចូលជាស្ថាពរ ។

## កថាភាគទី ៤ សាលក្រមកំបាំងមុខ

### ១. អវត្តមាននៃភាគី និង ដំណើរការនៃនីតិវិធី

#### (១) គោលការណ៍ភាគី និង ដំណើរការនៃនីតិវិធី

នីតិវិធីនៃបណ្តឹងរដ្ឋប្បវេណី បានជ្រើសរើសយកគោលការណ៍ចំពោះមុខ (មាត្រា ៣ កថាខណ្ឌទី ២) និង គោលការណ៍នៃការទាញហេតុផល (មាត្រា ៩៥, មាត្រា ១២៤ កថាខណ្ឌទី ១) មកធ្វើជាមូលដ្ឋាន ហើយ ភាគីត្រូវមានវត្តមាននៅតុលាការនៅកាលបរិច្ឆេទ និង ធ្វើការអះអាងអង្គហេតុ ស្នើដាក់របៀបបញ្ជាក់ភស្តុតាង និង ធ្វើសកម្មភាពបណ្តឹងផ្សេងៗ ដោយសកម្ម ទើបតុលាការអាចប្រមូលនូវធនធានចាំបាច់ ដើម្បីចេញសាលក្រមបាន ។ ប្រសិនបើភាគីអវត្តមាននៅកាលបរិច្ឆេទទៅ អាចមានមានការខ្វះខាតក្នុងការប្រមូលធនធានចាំបាច់ដើម្បីសម្រេចសេចក្តី ក៏ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើមានការបើកកាលបរិច្ឆេទជាថ្មីទៀត ដោយគ្រាន់តែពន្យារកាលបរិច្ឆេទតែប៉ុណ្ណោះទៅ គឺអាចមានបញ្ហា ។ នីតិវិធីបណ្តឹង នឹងមានដំណើរការយឺតយ៉ាវ ហើយអាចធ្វើឱ្យខូចប្រយោជន៍ដល់ភាគីម្ខាងទៀត ប្រសិនបើភាគីណាមួយអវត្តមាន ហើយប្រសិនបើភាគីទាំងសងខាងអវត្តមានទៅវិញ ជាទូទៅ អាចធ្វើឱ្យមានផលវិបត្តិចំពោះបុគ្គលដទៃទៀតដែលប្រើប្រព័ន្ធតុលាការ មានន័យថា អាចធ្វើឱ្យខូចប្រយោជន៍ប្រជាជនទូទៅ ។ ម្យ៉ាងទៀត អាចមានភាគីដែលអវត្តមានដើម្បីតែពន្យារនូវការចេញសាលក្រមដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ ។ ដូច្នេះ ក្រមនីតិវិធីរដ្ឋប្បវេណី បានចែងអំពីវិធីចាត់ចែង ក្នុងករណីដែលភាគីអវត្តមាន ។ ម្យ៉ាងទៀត ពាក្យ "អវត្តមាន" ខាងក្រោយនេះ មិនមានន័យត្រឹមតែភាគីមិនមានវត្តមានតាមកាលបរិច្ឆេទប៉ុណ្ណោះទេ គឺមានរួមទាំងករណីដែលភាគីមានវត្តមាននៅកាលបរិច្ឆេទ តែមិនបានធ្វើសកម្មភាពបណ្តឹងដែលត្រូវធ្វើក្នុងកាលបរិច្ឆេទនោះដែរ ។

(២) ករណីដែលភាគីទាំងសងខាងអវត្តមាន

ក្នុងករណីដែលភាគីទាំងសងខាង អវត្តមាននៅកាលបរិច្ឆេទនៃបណ្តឹងរដ្ឋប្បវេណី (កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទឆ្លើយទាញហេតុផលដោយផ្ទាល់មាត់) ភាគច្រើន គឺដោយសារតែភាគីទាំងសងខាងពុំមានចិត្តចង់ធ្វើឱ្យបណ្តឹងមានដំណើរការ ។ ក្នុងករណីដូចនេះ ការចាត់ការបណ្តឹងដោយមិនជំរុញឱ្យការវិនិច្ឆ័យមានដំណើរការទៅមុខទេ នឹងទៅជាបន្ទុកមួយដ៏ធ្ងន់សម្រាប់រដ្ឋ ទោះជាគិតតែការគ្រប់គ្រងសំណុំរឿងប៉ុណ្ណោះក៏ដោយ ។ ដូច្នេះហើយ ក្នុងករណីដែលភាគីទាំងសងខាងអវត្តមាន ប្រសិនបើគ្មានភាគីណាមួយដាក់ពាក្យសុំឱ្យកំណត់កាលបរិច្ឆេទថ្មីទៀត ក្នុងអំឡុងពេលមួយខែទេ ត្រូវចាត់ទុកថា បានដកពាក្យបណ្តឹងនោះ (មាត្រា ២១៩ វាក្យខណ្ឌទី ១) ។ ប៉ុន្តែ តុលាការអាចកំណត់កាលបរិច្ឆេទថ្មីបាន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនចាំបាច់រង់ចាំពាក្យសុំរបស់ភាគីក៏បានដែរ ។ ទោះជាក្នុងករណីដែលភាគីបានដាក់ពាក្យសុំក៏ដោយ ឬ ទោះជាដោយឆន្ទានុសិទ្ធិក៏ដោយ ក្នុងករណីដែលភាគីទាំងសងខាងអវត្តមានម្តងទៀតនៅកាលបរិច្ឆេទថ្មីដែលបានកំណត់នេះ ក៏ត្រូវចាត់ទុកថា បានដកពាក្យបណ្តឹងដែរ (មាត្រា ២១៩ វាក្យខណ្ឌទី ២) ។

(៣) ករណីដែលភាគីម្ខាងអវត្តមាន

ចំពោះការចាត់ចែងករណីដែលដើមចោទ ឬ ចុងចម្លើយតែម្ខាង អវត្តមាននៅកាលបរិច្ឆេទ វិធីតាក់តែងច្បាប់នៃប្រទេសនីមួយៗ អាចចែកជាពីរប្រភេទបាន ។ វិធីទីមួយ គឺឱ្យភាគីដែលមានវត្តមាន ឱ្យធ្វើសកម្មភាពបណ្តឹងរបស់ខ្លួន ហើយបន្តនូវការវិនិច្ឆ័យ ហើយចេញសាលក្រមធម្មតា (គោលការណ៍នៃការចេញសាលក្រមចំពោះមុខ) ហើយវិធីមួយទៀត គឺ បញ្ចប់ការវិនិច្ឆ័យដោយមូលហេតុអវត្តមាន ហើយចេញសាលក្រមដែលខូចប្រយោជន៍ដល់ភាគីអវត្តមាន (ក្នុងករណីដែលដើមចោទអវត្តមាន គឺសាលក្រមច្រានចោលនូវការទាមទារ, ក្នុងករណីដែលចុងចម្លើយអវត្តមាន គឺសាលក្រមទទួលស្គាល់នូវការទាមទារ) (គោលការណ៍នៃការចេញសាលក្រមកំបាំងមុខ) ។ ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនសព្វថ្ងៃនេះ បានជ្រើសរើសយកគោលការណ៍នៃការចេញសាលក្រមចំពោះមុខ ក៏ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាវិញ បានជ្រើសរើសយកគោលការណ៍នៃការចេញសាលក្រមកំបាំងមុខ ដូចរបបចាស់នៅកម្ពុជា ឬ ដូចច្បាប់បារាំង អាល្លឺម៉ង់ ជាដើមដែរ (ពីមាត្រា ២00 ដល់មាត្រា ២១២) ។ ក្រោមគោលការណ៍នៃការចេញសាលក្រមកំបាំងមុខ តាមធម្មតា គេអនុញ្ញាតឱ្យប្តឹងឧបាស្រ័យសង្ខេបដែលត្រូវហៅថា "បណ្តឹងទាស់" ចំពោះសាលក្រមកំបាំងមុខ ហើយប្រសិនបើមានបណ្តឹងទាស់ នីតិវិធីនៃបណ្តឹងនោះ នឹងត្រូវត្រឡប់ទៅស្ថានភាពមុនពេលអវត្តមាន ហើយតុលាការនៃថ្នាក់ជំនុំជម្រះដដែលត្រូវបន្តនូវការវិនិច្ឆ័យ ។ ក៏ប៉ុន្តែ ក្រោមគោលការណ៍នៃការចេញសាលក្រមកំបាំងមុខ អាចមានបញ្ហាដែលភាគីបានអវត្តមាន ហើយធ្វើបណ្តឹងទាស់ជាបន្តបន្ទាប់ ដើម្បីបង្អូសបន្លាយបណ្តឹងនោះ ។ ហេតុនេះហើយ

បានជា ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មានការកម្រិតនូវករណីដែលអាចដាក់ពាក្យបណ្ដឹងទាស់បាន ( មាត្រា ២០៤ កថាខណ្ឌទី ១) ។

២. នីតិវិធីរហូតដល់ការចេញសាលក្រមកំបាំងមុខ

(១) ករណីដែលដើមចោទអវត្តមាន

ក្នុងករណីដែលដើមចោទអវត្តមាន នៅកាលបរិច្ឆេទលើកទីមួយនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវចេញសាលក្រមកំបាំងមុខ ដែលមានខ្លឹមសារច្រានចោលនូវការទាមទាររបស់ដើមចោទ ( មាត្រា ២០០ កថាខណ្ឌទី ១) ។ នេះគឺដោយសារតែយល់ឃើញថា ច្បាស់ជាដើមចោទគ្មានឆន្ទៈបន្តនីតិវិធីទេ ហេតុនេះហើយ គួរតែចេញសាលក្រមច្រានចោលនូវការទាមទារ ដោយមិនចាំបាច់បើកការទាញហេតុផលដោយផ្ទាល់មាត់ទេ ។

ក្នុងករណីដែលដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ក៏ដូចគ្នាដែរ ( មិនត្រឹមតែកាលបរិច្ឆេទលើកទីមួយទេ គឺរួមទាំងកាលបរិច្ឆេទបន្តនីតិវិធីផងដែរ) តុលាការត្រូវចេញសាលក្រមកំបាំងមុខ ច្រានចោលនូវការទាមទាររបស់ដើមចោទ ( មាត្រា ២០០ កថាខណ្ឌទី ៣) ។

ក្នុងករណីដែលដើមចោទបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទីមួយនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តែមិនបានបង្ហាញនៅកាលបរិច្ឆេទបន្តនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការមិនត្រូវចេញសាលក្រមកំបាំងមុខទេ គឺអាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន ( មាត្រា ២០០ កថាខណ្ឌទី ២) ។ ដើមចោទមិនបានបង្ហាញខ្លួននេះ គឺអាចដោយសារតែគេយល់ឃើញថា ការរៀបចំនូវចំណុចវិវាទក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ គឺ ការអវត្តមាននេះ អាចមិនមែនបានបង្ហាញថា គេគ្មានឆន្ទៈបន្តនីតិវិធីទេ ។

(២) ក្នុងករណីដែលចុងចម្លើយអវត្តមាន

ក្នុងករណីដែលចុងចម្លើយអវត្តមាន នៅកាលបរិច្ឆេទលើកទីមួយនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមិនអាចចេញសាលក្រមកំបាំងមុខភ្លាមៗបានទេ គឺត្រូវបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកំណត់កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ( មាត្រា ២០១) ។ ទោះជាអង្គហេតុដែលដើមចោទបានអះអាងនោះ សុទ្ធតែជារឿងពិតក៏ដោយ ក៏អាចមានករណីដែលការទាមទាររបស់ដើមចោទ មិនអាចត្រូវបានទទួលស្គាល់ដែរ ហេតុនេះហើយ ទោះជាចុងចម្លើយអវត្តមានក៏ដោយ ក៏មិនអាចអនុញ្ញាតឱ្យតុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទភ្លាមៗ ដោយមិនបានឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បានទេ ។

ក្នុងករណីដែលចុងចម្លើយអវត្តមាននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីដែលចុងចម្លើយនោះបានធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម

សម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីមុនមក (មាត្រា ២០១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ចេញ ចុងចម្លើយត្រូវចាត់ទុកថា បានសារភាពនូវសេចក្តីថ្លែងការណ៍អំពីអង្គហេតុរបស់ដើមចោទ ។ បន្ទាប់មក ប្រសិនបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមកំបាំងមុខ ទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ហើយប្រសិនបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រមធម្មតា ច្រានចោលនូវការទាមទាររបស់ដើមចោទ (មាត្រា ២០១ កថាខណ្ឌទី ២) ។

(៣) ករណីដែលមិនអនុញ្ញាតឱ្យចេញសាលក្រមកំបាំងមុខ

ទោះជាដើមចោទ ឬ ចុងចម្លើយមិនបង្ហាញខ្លួននៅកាលបរិច្ឆេទក៏ដោយ ក្នុងករណីណាមួយខាងក្រោមនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ (មាត្រា ២០២ ចំណុច ក ដល់ ចំណុច គ) ។

① ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់

② ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន

③ ក្នុងករណីដែលជាបណ្តឹងមិនស្របច្បាប់

ម្យ៉ាងទៀត ក្នុងករណីដែលខ្លឹមសារនៃសេចក្តីថ្លែងការណ៍ដែលដើមចោទបានធ្វើ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន មិនត្រូវបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះទេ ក៏តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ (មាត្រា ២០២ ចំណុច ឃ) ។ ប្រសិនបើចេញសាលក្រមកំបាំងមុខ ដោយចាត់ទុកថា ចុងចម្លើយបានសារភាពអំពីសេចក្តីថ្លែងការណ៍របស់ដើមចោទនៅកាលបរិច្ឆេទនោះទៅ ចំពោះចុងចម្លើយ គឺដូចជាការវាយឆ្មក់មួយដែរ ហេតុនេះហើយ ដើម្បីជៀសវាងនូវការវាយឆ្មក់នេះ មិនអាចអនុញ្ញាតឱ្យតុលាការចេញសាលក្រមកំបាំងមុខទេ ។ ឧទាហរណ៍ ចំពោះបណ្តឹងដែលចំណុចនីមួយៗដែលត្រូវបានសរសេរក្នុងពាក្យបណ្តឹង គ្មានភាពស៊ីសង្វាក់គ្នា ទោះបីជាដើមចោទអះអាងអង្គហេតុដែលមិនត្រូវបានសរសេរនៅក្នុងឯកសារត្រៀម នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលដើមចោទបានចូលរួម តែចុងចម្លើយមិនបានបង្ហាញខ្លួន ហើយបណ្តឹងនេះមានភាពស៊ីសង្វាក់គ្នាវិញ ដោយសារការអះអាងអង្គហេតុថ្មីនោះក៏ដោយ ក៏តុលាការមិនអាចចេញសាលក្រមកំបាំងមុខដែលទទួលស្គាល់ការទាមទាររបស់ដើមចោទឡើយ ដោយសារការណ៍ដែលដើមចោទនឹងអះអាងអង្គហេតុនោះមិនត្រូវបានជូនដំណឹងជាមុនទៅចុងចម្លើយ ។ ក្នុងករណីនេះ ដោយសារបណ្តឹងរបស់ដើមចោទ មានភាពស៊ីសង្វាក់គ្នាវិញ ដោយការអះអាងអង្គហេតុថ្មី តុលាការមិនអាចចេញសាលក្រមដែលច្រានចោលការទាមទារបានឡើយ ហេតុដូច្នេះ តុលាការត្រូវបន្តនីតិវិធីនៃការវិនិច្ឆ័យ ។

(៤) ការពន្យារកាលបរិច្ឆេទ

ទោះជាក្នុងករណីដែលដើមចោទ ឬ ចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទក៏ដោយ ប្រសិនបើយល់ឃើញថា អំឡុងពេលរវាងកាលបរិច្ឆេទ និង ពេលដែលបានកោះហៅនោះ ខ្លីពេក ឬ យល់ឃើញថា ភាគីមិនអាចបង្ហាញខ្លួនដោយគ្មានកំហុសទេ តុលាការអាចពន្យារពេលកាលបរិច្ឆេទ ហើយកំណត់នូវកាលបរិច្ឆេទថ្មីដោយមិនចេញសាលក្រមកំបាំងមុខ ដើម្បីធ្វើការវិនិច្ឆ័យបន្តទៀត ( មាត្រា ២០៣) ។

៣. បណ្តឹងឧបាស្រ័យចំពោះសាលក្រមកំបាំងមុខ

(១) ការប្តឹងទាស់

ភាគីដែលទទួលសាលក្រមកំបាំងមុខ ដោយសារតែការអវត្តមាននៅកាលបរិច្ឆេទ អាចទាមទារឱ្យតុលាការនៃបណ្តឹងថ្នាក់ជម្រះក្តីដដែល ឱ្យធ្វើការវិនិច្ឆ័យសាជាថ្មី ដោយបណ្តឹងទាស់បាន ។ ក៏ប៉ុន្តែ បណ្តឹងទាស់អាចអនុញ្ញាតឱ្យដាក់បានតែក្នុងករណីដែលភាគីអវត្តមាន ដោយសារមានហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន ( មាត្រា ២០៤ កថាខណ្ឌទី ១) ។ម្យ៉ាងទៀត បណ្តឹងទាស់នោះ ត្រូវដាក់ក្នុងអំឡុងពេល ២ សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃសាលក្រមកំបាំងមុខ (ក្នុងករណីដែលការបញ្ជូន ត្រូវបានធ្វើដោយការបញ្ជូនតាមការផ្សាយជាសាធារណៈ ឬ តាមរយៈការបញ្ជូននៅបរទេស គឺត្រូវធ្វើក្នុងអំឡុងពេលដែលតុលាការបានកំណត់នៅក្នុងសាលក្រមកំបាំងមុខ) ( មាត្រា ២០៤ កថាខណ្ឌទី ២ និង ទី ៣) ហើយពាក្យបណ្តឹងទាស់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ( មាត្រា ២០៥) ។

ក្នុងករណីដែលមានពាក្យបណ្តឹងទាស់ តុលាការត្រូវពិនិត្យនូវចំណុចដែលបានសរសេរក្នុងពាក្យបណ្តឹងទាស់ ហើយប្រសិនបើមានចំណុចខ្វះខាត ត្រូវបង្គាប់ឱ្យភាគីដែលដាក់ពាក្យបណ្តឹងទាស់នោះ កែតម្រូវ ហើយប្រសិនបើភាគីមិនបានកែតម្រូវទេ តុលាការត្រូវលើកបណ្តឹងទាស់នោះចោល ដោយដីកាសម្រេច ( មាត្រា ២០៦ កថាខណ្ឌទី ១ និង ទី ២) ។ ប្រសិនបើពាក្យបណ្តឹងទាស់គ្មានចំណុចខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះ ទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទដើម្បីវិនិច្ឆ័យបណ្តឹងទាស់នោះ និង កោះហៅគូភាគី ( មាត្រា ២០៦ កថាខណ្ឌទី ៤) ។

(២) ការវិនិច្ឆ័យបណ្តឹងទាស់ និង នីតិវិធីក្រោយពេលនោះ

ចំពោះការប្តឹងទាស់ តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ( មាត្រា ២០៧ កថាខណ្ឌទី ១) អំពីភាពត្រឹមត្រូវនៃបណ្តឹងទាស់ (តើមានការគោរពអំឡុងពេលដាក់ឬទេ តើចំណុចដែលសរសេរក្នុងពាក្យបណ្តឹងទាស់នោះ ស្របតាមការកំណត់នៃច្បាប់ឬទេ) ព្រមទាំងអំពីបញ្ហាថា តើការដាក់បណ្តឹងទាស់នោះ ដោយមូលហេតុត្រឹមត្រូវឬទេ ( មាត្រា ២០៤ កថាខណ្ឌទី ១) ។ ចំពោះបណ្តឹងទាស់ដែលមិនស្របច្បាប់ តុលាការត្រូវលើកចោលដោយដីកាសម្រេច រីឯចំពោះបណ្តឹងទាស់ដែលត្រូវបានធ្វើឡើងដោយមិនផ្អែកលើមូលហេតុត្រឹមត្រូវទេ តុលាការត្រូវច្រានចោលបណ្តឹងទាស់នោះដោយដីកាសម្រេច ( មាត្រា ២០៧ កថាខណ្ឌទី ២) ។

ប្រសិនបើបណ្តឹងទាស់នោះស្របច្បាប់ ព្រមទាំងមានមូលហេតុត្រឹមត្រូវផង នីតិវិធីនៃបណ្តឹងនោះ ត្រូវបាន

ត្រឡប់ទៅសភាពដើម មុនការអវត្តមាននោះវិញ ( មាត្រា ២០៨ កថាខណ្ឌទី ១) ។ ដូច្នេះ តុលាការត្រូវចាប់ផ្តើមឡើងវិញនូវនីតិវិធីដែលបានធ្វើនាពេលអវត្តមាននោះ (នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់) ហើយធ្វើការកំណត់នូវកាលបរិច្ឆេទថ្មី ដើម្បីបន្តការវិនិច្ឆ័យនោះ (មាត្រា ២០៨ កថាខណ្ឌទី ២) ។ ក្នុងករណីដែលសាលក្រមដែលតុលាការនឹងចេញ ដោយផ្អែកលើការវិនិច្ឆ័យក្រោយពេលបន្តនីតិវិធីនោះ មានលទ្ធផលដូចគ្នានឹងសាលក្រមកំបាំងមុខនោះ តុលាការត្រូវចេញសាលក្រមចុងក្រោយដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ (មាត្រា ២០៩ កថាខណ្ឌទី ១) ។ ប្រសិនបើមានលទ្ធផលមិនត្រូវគ្នាទេ តុលាការត្រូវចេញសាលក្រមថ្មី ដែលលុបចោលនូវសាលក្រមកំបាំងមុខ ហើយធ្វើការវិនិច្ឆ័យដោយផ្ទាល់ ចំពោះការទាមទាររបស់ដើមចោទ នៅក្នុងសាលក្រមថ្មីនោះ ( មាត្រា ២០៩ កថាខណ្ឌទី ២) ។

ក្នុងករណីដែលភាគីដែលបានដាក់ពាក្យបណ្តឹងទាស់ មិនបង្ហាញខ្លួនម្តងទៀត នៅក្នុងនីតិវិធីដែលត្រូវបានចាប់ផ្តើមម្តងទៀតនោះ ត្រូវចាត់ទុកដូចដែលបានពន្យល់ក្នុង ២. (១) ដល់ (៣) ខាងលើនេះ ហើយតុលាការអាចចេញសាលក្រមកំបាំងមុខក្រោយល័ក្ខខ័ណ្ឌដូចគ្នាបាន ។ ក៏ប៉ុន្តែ ចំពោះសាលក្រមកំបាំងមុខដែលបានចេញដោយតុលាការ ដោយមានមូលហេតុអវត្តមាននៅកាលបរិច្ឆេទលើកដំបូងនៃនីតិវិធីដែលត្រូវបានចាប់ដើមឡើងវិញ របស់ភាគីដែលបានដាក់ពាក្យបណ្តឹងទាស់ ភាគីនោះមិនអាចប្តឹងទាស់បានទៀតទេ (មាត្រា ២១១ កថាខណ្ឌទី ២) ។ នេះគឺជាបទដ្ឋានដែលមានគោលបំណងការពារកុំឱ្យមានការអវត្តមាន ហើយដាក់បណ្តឹងទាស់ ជាបន្តបន្ទាប់ ដើម្បីបន្ទាយនីតិវិធី ។

(៣) ការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខ

តាមធម្មតា ចំពោះសាលក្រមកំបាំងមុខ ក៏អាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានដែរ (ប្តឹងឧទ្ធរណ៍ ឬ ប្តឹងសាទុក្ខ) (តម្រូវឱ្យមានល័ក្ខខ័ណ្ឌទូទៅស្តីពីការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ។ ភាគីដែលបានទទួលសាលក្រមកំបាំងមុខ ដោយសារអវត្តមានរបស់ខ្លួន អាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ដោយមិនបាច់ធ្វើបណ្តឹងទាស់ដូចដែលបានពន្យល់ខាងលើនេះក៏បាន (ដោយបោះបង់ចោលនូវឱកាសក្នុងការទទួលការវិនិច្ឆ័យដោយតុលាការថ្នាក់ដដែល) ។ ម្យ៉ាងទៀត ក្នុងករណីដែលបានប្តឹងទាស់ ហើយត្រូវតុលាការច្រានចោល ឬ លើកចោល ក៏អាចដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានដែរ ។ ចំពោះអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ ត្រូវបានគណនា ដោយគិតចាប់ពីថ្ងៃដែលបានជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់នោះ ( មាត្រា ២៦៤ កថាខណ្ឌទី ១, មាត្រា ២៨៦) ហេតុនេះហើយ អាចរង់ចាំមើលលទ្ធផលនៃបណ្តឹងទាស់ហើយ ទើបដាក់បណ្តឹងឧបាស្រ័យក៏ទាន់ដែរ (ក៏ប៉ុន្តែ ការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មុនពេលជូនដំណឹងអំពីដីកាសម្រេចច្រានចោល ឬ លើកចោលនូវបណ្តឹងទាស់នោះ ក៏មានសុពលភាពដែរ ។ មាត្រា ២៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២, មាត្រា ២៨៦) ។

## កថាភាគទី ៥ ការសម្រេចសេចក្តីបន្ទាប់បន្សំដែលភ្ជាប់ជាមួយនឹងសាលក្រមចុងក្រោយ

### ១. ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

#### (១) អត្ថន័យនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន គឺជាសេចក្តីសម្រេចដែលផ្តល់ឱ្យសាលក្រមចុងក្រោយដែលមិនទាន់ចូលជាស្ថាពរ នូវអានុភាពអនុវត្ត ដូចក្នុងករណីដែលសាលក្រមនោះបានចូលជាស្ថាពរដែរ ។ ដូចដែលបានពន្យល់មុននេះ អានុភាពអនុវត្តនឹងកើតមានឡើង ជាគោលការណ៍ នៅពេលដែលសាលក្រមចុងក្រោយចូលជាស្ថាពរ ហេតុនេះហើយ ប្រសិនបើភាគីចាញ់ក្តីបានដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហើយការចូលជាស្ថាពរនៃសាលក្រមនោះនឹងមានការយឺតយ៉ាវ អានុភាពអនុវត្តក៏នឹងកើតមានឡើង ដោយយឺតយ៉ាវដែរ ដូច្នេះហើយ ការសម្រេចសិទ្ធិរបស់អ្នកឈ្នះក្តីក៏មានការយឺតទៅតាមនោះដែរ ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ ប្រសិនបើសាលក្រមនោះមានកំហុស ភាគីចាញ់ក្តីត្រូវមានឱកាសអាចទាមទារឱ្យលុបចោលនូវសាលក្រមនោះ ដោយបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ ដូច្នេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានត្រៀមនូវរបបប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដើម្បីសម្របសម្រួលរវាងផលប្រយោជន៍ក្នុងការសម្រេចនូវសិទ្ធិរបស់ភាគីឈ្នះក្តីឱ្យបានទាន់ពេលវេលា និង ផលប្រយោជន៍ក្នុងការសុំឱ្យលុបចោលនូវសាលក្រមដែលមានកំហុស ដោយបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ របស់ភាគីចាញ់ក្តី (មាត្រា ១៩៦, មាត្រា ២៧១, មាត្រា ២៩៨, មាត្រា ៣២៨) ។ សាលក្រមដែលភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន មានអានុភាពអនុវត្ត ទោះបីជាសាលក្រមនោះមិនទាន់ចូលជាស្ថាពរក៏ដោយ ហើយនឹងក្លាយទៅជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ខ) ។

#### (២) ល័ក្ខខ័ណ្ឌនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវបានទទួលស្គាល់ចំពោះសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ (មាត្រា ១៩៦ កថាខណ្ឌទី ១) ។ ការកម្រិតត្រឹមតែសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិនេះ គឺដោយសារតែ ទោះបីជាក្នុងករណីដែលសាលក្រមដែលភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបានលុបចោលដោយសាលដីកានៃតុលាការជំនុំជម្រះថ្នាក់លើ ក្រោយការអនុវត្តដោយបង្ខំដោយសាលក្រមនោះក៏ដោយ ប្រសិនបើសាលក្រមនោះសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ ករណីភាគច្រើន មានការងាយស្រួលក្នុងការធ្វើបដិទានស្ថានភាពដើមវិញ ឬ អាចសងនូវសំណងនៃការខូចខាតដែលចុងចម្លើយបានទទួល ជាទឹកប្រាក់បាន ។

ដើម្បីឱ្យតុលាការអាចភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបាន ទាល់តែមានការទទួលស្គាល់ថាមានការចាំបាច់ ។ ម្យ៉ាងទៀត ក្នុងករណីដែលភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តុលាការអាចដាក់ល័ក្ខខ័ណ្ឌឱ្យដើមចោទឈ្នះក្តី ដាក់ប្រាតិភោគបាន ។ ពេលធ្វើការវិនិច្ឆ័យអំពីភាពចាំបាច់ប្រកាសឱ្យអនុវត្ត

ជាបណ្តោះអាសន្ន ឬ ភាពចាំបាច់ឱ្យដាក់ប្រាតិភោគនោះ តុលាការត្រូវពិនិត្យមើលអំពីស្ថានភាពទូទៅ ដូចជា ភាពចាំបាច់ក្នុងការសម្រេចឱ្យបានទាន់ពេលវេលានូវសិទ្ធិរបស់ដើមចោទឈ្នះក្តី ឬ ទំហំនៃការខូចខាតដែលភាគីចាញ់ក្តីត្រូវទទួល ជាដើម ។

(៣) នីតិវិធីប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវធ្វើឡើងដោយពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ ។ ករណីដែលត្រូវភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន គឺទីមួយ មានករណីដែលបានប្រកាសព្រមជាមួយនឹងសាលក្រមចុងក្រោយ នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមចុងក្រោយនោះផ្ទាល់តែម្តង (មាត្រា ១៩៦ កថាខណ្ឌទី ២) ។ ឧទាហរណ៍ នៅក្នុងកថាខណ្ឌទី ១ នៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រម បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ ១០ លានរៀលចំពោះដើមចោទ ហើយនៅក្នុងកថាខណ្ឌទី ២ ប្រកាសថា "សេចក្តីសម្រេចនៃកថាខណ្ឌទី ១ អាចអនុវត្តជាបណ្តោះអាសន្នបាន" ។ ទីពីរ គឺ ករណីដែលប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយដីកាសម្រេចឯករាជ្យមួយផ្សេង (មាត្រា ១៩៦ កថាខណ្ឌទី ៤, មាត្រា ២៧១, មាត្រា ២៩៨, មាត្រា ៣២៨) ។ ពេលធ្វើការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន តុលាការអាចប្រកាសចំពោះភាគីចាញ់ក្តីថា ខ្លួនអាចរួចផុតពីការអនុវត្តជាបណ្តោះអាសន្នបាន ប្រសិនបើភាគីនោះដាក់ប្រាតិភោគកំណត់មួយ (មាត្រា ១៩៦ កថាខណ្ឌទី ២) ។

(៤) អានុភាពនៃការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ប្រសិនបើមានភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នទៅ សាលក្រមនោះនឹងមានអានុភាពអនុវត្តដោយភ្លាម ហើយអានុភាពនោះមិនអាចបង្អាក់បានដោយបណ្តឹងឧទ្ធរណ៍ (មាត្រា ២៦០) បណ្តឹងសាទុក្ខ (មាត្រា ២៨៣) ឬ បណ្តឹងទាស់ (មាត្រា ២០៤) ចំពោះសាលក្រមនោះ ក្រោយពេលចេញសាលក្រមនោះទេ ។ ក៏ប៉ុន្តែ តុលាការនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងសាទុក្ខ ឬ តុលាការដែលទទួលបណ្តឹងទាស់ អាចចេញដីកាសម្រេចបង្គាប់ឱ្យផ្អាក ឬ លុបចោលការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយពិនិត្យតាមស្ថានភាពផ្សេងៗ (មាត្រា ៣៦៦ កថាខណ្ឌទី ១ ពីចំណុច ខ ដល់ ចំណុច ឃ និង កថាខណ្ឌទី ២ ។ ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ក៏ដូចគ្នាដែរ ។ មាត្រា ៣២៩, មាត្រា ៣៣១, មាត្រា ៣៦៦ កថាខណ្ឌទី ១ ចំណុច ខ) ហើយប្រសិនបើមានដីកាសម្រេចទាំងនេះ នីតិវិធីអនុវត្តដោយបង្ខំនីមួយៗនឹងត្រូវផ្អាក ឬ ត្រូវបានលុបចោល (មាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច ឆ, កថាខណ្ឌទី ២ ចំណុច ក) ។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការជាន់ខ្ពស់បានប្រកាសសាលដីកាដែលសម្រេច ផ្លាស់ប្តូរការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ផ្លាស់ប្តូរសាលក្រម ឬ សាលដីកាដែលភ្ជាប់នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

នោះ ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ នឹងត្រូវបាត់អានុភាពត្រឹមកម្រិតនៃការផ្លាស់ប្តូរនោះ (មាត្រា ១៩៧ កថាខណ្ឌទី ១) ។

២. ការសម្រេចសេចក្តីអំពីប្រាក់ប្រដាប់ក្តី

(១) អត្ថន័យ

នៅក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រមចុងក្រោយ តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីប្រាក់ប្រដាប់ក្តីទាំងអស់នៃថ្នាក់ជំនុំជម្រះនោះ ដោយកំណត់ថា តើត្រូវឱ្យភាគីណាទទួលបន្ទុកប៉ុន្មាន (ការសម្រេចសេចក្តីលើបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្តី) ដោយគ្មានពាក់ព័ន្ធនឹងការដាក់ពាក្យសុំរបស់ភាគីទេ (មាត្រា ៦៥ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការជាន់ខ្ពស់ បានផ្លាស់ប្តូរនូវសេចក្តីសម្រេចអង្គសេចក្តី តុលាការនោះត្រូវធ្វើការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីនៃរឿងក្តីសរុប រួមទាំងការជំនុំជម្រះដោយតុលាការដើម និង តុលាការនៃថ្នាក់ជំនុំជម្រះនោះ (មាត្រា ៦៥ កថាខណ្ឌទី ២) ។ ជាទូទៅ ក្នុងសាលក្រមដែលដើមចោទឈ្នះទាំងស្រុង ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់ចុងចម្លើយ រីឯក្នុងសាលក្រមដែលចុងចម្លើយឈ្នះទាំងស្រុង ប្រាក់ប្រដាប់ក្តីគឺជាបន្ទុកទាំងស្រុងរបស់ដើមចោទ ។ ផ្ទុយទៅវិញ ក្នុងករណីនៃសាលក្រមចាញ់មួយភាគ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួល ដោយឆន្ទានុសិទ្ធិរបស់ខ្លួន (មាត្រា ៦៤ កថាខណ្ឌទី ១) ។ ចំពោះសេចក្តីសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីនៅក្នុងសាលក្រម មិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដាច់ដោយឯងបានទេ (មាត្រា ២៦១, មាត្រា ២៨៦) ។

(២) ការកំណត់នូវចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តី

ការសម្រេចសេចក្តីអំពីប្រាក់ប្រដាប់ក្តី ដែលតុលាការត្រូវធ្វើជាបន្ទាប់បន្សំក្នុងសាលក្រមចុងក្រោយ គឺជាការកំណត់តែអ្នកដែលទទួលបន្ទុកប្រាក់ប្រដាប់ក្តី និង ចំណែកនៃបន្ទុកនោះប៉ុណ្ណោះ ហើយមិនកំណត់នូវចំនួនទឹកប្រាក់នោះទេ ។ នេះគឺដោយសារតែក្រោយការប្រកាសសាលក្រម ក៏ត្រូវមានចំណាយប្រាក់ប្រដាប់ក្តីទៅលើបណ្តឹងនោះដែរ ហើយការកំណត់នូវចំនួនទឹកប្រាក់នោះ មានលក្ខណៈបច្ចេកទេសស្មុគ្រស្មាញផង ហេតុនេះហើយប្រសិនបើធ្វើការគណនាក្នុងសាលក្រមនោះទៅ អាចធ្វើឱ្យមានការយឺតយ៉ាវដល់ការបញ្ចប់នៃបណ្តឹងអង្គសេចក្តី ។ ដូច្នេះ ដើម្បីកំណត់នូវចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ នីតិវិធីធ្វើការកំណត់នូវចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តី ត្រូវបានរៀបចំឡើង (មាត្រា ៦៦ កថាខណ្ឌទី ១) ។ មានន័យថា ភាគីនីមួយៗបានចេញសោហ៊ុយចាំបាច់ដើម្បីដំណើរការនៃនីតិវិធីបណ្តឹង ក៏ប៉ុន្តែ តាមរយៈការសម្រេចសេចក្តីកំណត់នូវបន្ទុកនៃប្រាក់ប្រដាប់ក្តីដែលសម្រេចថា តើភាគីណាទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីប៉ុន្មាននោះ ភាគីម្ខាងនឹងមានសិទ្ធិទាមទារឱ្យភាគីម្ខាងទៀតសងមកវិញនូវសោហ៊ុយដែលខ្លួនបានចេញហើយ ។ សិទ្ធិនេះគេហៅថា សិទ្ធិទាមទារឱ្យសងនូវប្រាក់ប្រដាប់ក្តី ។

ក្នុងករណីដែលភាគីនីមួយៗត្រូវទទួលបន្ទុកមួយភាគនៃប្រាក់ប្រដាប់ក្តី ក្នុងអត្រាកំណត់នីមួយៗ ភាគីដែលបានចេញសោហ៊ុយលើសបន្ទុកដែលខ្លួនត្រូវទទួលរួចហើយ នឹងបានទទួលសិទ្ធិទាមទារឱ្យសងនូវប្រាក់ប្រដាប់ក្តី ចំពោះភាគដែលបានបង់លើសនោះ ។ ភាគីដែលបានទទួលសិទ្ធិទាមទារឱ្យសងនូវប្រាក់ប្រដាប់ក្តី អាចដាក់ពាក្យសុំឱ្យធ្វើការកំណត់នូវចំនួនទឹកប្រាក់ប្រដាប់ក្តី ចំពោះក្រឡាបញ្ជីនៃតុលាការនៃការជំនុំជម្រះលើកទីមួយនៃបណ្តឹងអង្គសេចក្តី ក្រោយពេលដែលការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តីមានអានុភាពអនុវត្ត ។ ជាគោលការណ៍ នីតិវិធីកំណត់នូវចំនួនទឹកប្រាក់ប្រដាប់ក្តី ត្រូវធ្វើ ដោយតែឯកសារប៉ុណ្ណោះ ។ ការចាត់ចែងរបស់ក្រឡាបញ្ជីអំពីការកំណត់នូវចំនួនទឹកប្រាក់ប្រដាប់ក្តី នឹងមានអានុភាព ដោយការជូនដំណឹងតាមរបៀបដែលអាចចាត់ទុកថាសមរម្យ (មាត្រា ៦៦ កថាខណ្ឌទី ៣) ។ ការចាត់ចែងរបស់ក្រឡាបញ្ជីអំពីការកំណត់នូវចំនួនទឹកប្រាក់ប្រដាប់ក្តី នឹងក្លាយទៅជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ង) ។ ម្យ៉ាងទៀត ប្រាក់ប្រដាប់ក្តីដែលមានក្នុងនេះ គឺជាសោហ៊ុយដែលបានកំណតពីមាត្រា ៦១ ដល់ មាត្រា ៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី (មាត្រា ៥៩) រីឯកម្រៃមេធាវី ក្នុងករណីដែលភាគីបានជ្រើសតាំងមេធាវីជាអ្នកតំណាងដោយអាណត្តិវិញ មិនមែនជាប្រាក់ប្រដាប់ក្តីទេ គឺជាបន្ទុករបស់ភាគីនោះ ។

### ៣. ការសង្គ្រោះលើបណ្តឹង

#### (១) គោលគំនិតនៃរបបសង្គ្រោះលើបណ្តឹង

ដើម្បីធ្វើបណ្តឹង ភាគីត្រូវបង់ប្រាក់ប្រដាប់ក្តីជាមុន ឬ ត្រូវចំណាយប្រាក់ប្រដាប់ក្តី ក៏ប៉ុន្តែ ប្រសិនបើអនុវត្តគោលការណ៍នេះជ្រុលពេកទៅ នឹងមិនអាចធានាសិទ្ធិពឹងពាក់តុលាការជាក់ស្តែង (មាត្រា ២ កថាខណ្ឌទី ២) ចំពោះជនដែលគ្មានទ្រព្យធននឹងបង់ប្រាក់ដែលចាំបាច់ដើម្បីធ្វើនីតិវិធីបណ្តឹង ឬ សម្រាប់ត្រៀមធ្វើបណ្តឹង ឬ ចំពោះជនដែលបង់សោហ៊ុយនេះទៅ នឹងជួបការលំបាកយ៉ាងធ្ងន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅ ។ ហេតុនេះហើយ របបផ្តល់ការសង្គ្រោះលើបណ្តឹង ត្រូវបានរៀបចំសម្រាប់អ្នកទាំងនេះ ។

#### (២) ល័ក្ខខ័ណ្ឌសង្គ្រោះលើបណ្តឹង (មាត្រា ៦៩ កថាខណ្ឌទី ១)

ល័ក្ខខ័ណ្ឌដើម្បីទទួលស្គាល់នូវការសង្គ្រោះលើបណ្តឹង គឺទី ១ គ្មានលទ្ធភាពទ្រព្យធននឹងបង់ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និង ប្រព្រឹត្តទៅនៃនីតិវិធីបណ្តឹង ឬ អាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់ប្រាក់នេះ ។ "ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និង ប្រព្រឹត្តទៅនៃនីតិវិធីបណ្តឹង" នៅក្នុងនេះមានរួមទាំងប្រាក់ប្រដាប់ក្តីតុលាការ (មាត្រា ៦១, មាត្រា ៦២) ប្រាក់ប្រដាប់ក្តីភាគី (មាត្រា ៦៣) និងសោហ៊ុយផ្សេងទៀតទាំងអស់ផងដែរ ។ តាមធម្មតា ជនដែលមានល័ក្ខខ័ណ្ឌនេះ គឺជារូបវន្តបុគ្គល ក៏ប៉ុន្តែចំពោះនីតិបុគ្គលក៏ដោយ ក៏អាចមានករណីដែលនីតិបុគ្គលអាចស្របនឹងល័ក្ខខ័ណ្ឌនេះដែរ បើមិនអាចបង់ប្រាក់ខែឱ្យនិយោជិតបាន ជាដើម ។ ល័ក្ខខ័ណ្ឌទី ២ គឺ មិនច្បាស់ជាគ្មានលទ្ធភាពនឹងឈ្នះក្តី ។ ល័ក្ខខ័ណ្ឌនេះមិនត្រូវគិតតឹងរ៉ឹងរហូតទាល់តែមានលទ្ធភាពនឹងឈ្នះក្តីទេ គឺត្រូវគិតធូរជាង ។ ល័ក្ខខ័ណ្ឌផ្តល់នូវការសង្គ្រោះ គឺ

អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង (មាត្រា ៦៩ កថាខណ្ឌទី ៣) ។ ការសម្រេចសេចក្តីអំពីការផ្តល់នូវការសង្គ្រោះលើបណ្តឹង ត្រូវធ្វើដោយដីកាសម្រេច តាមពាក្យសុំរបស់ភាគី តាមថ្នាក់នៃការជំនុំជម្រះនីមួយៗ (មាត្រា ៦៩ កថាខណ្ឌទី ១ និង ទី ២) ។

(៣) ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្តឹង (មាត្រា ៧០)

ជាគោលការណ៍ ខ្លឹមសារនៃជំនួយសង្គ្រោះលើបណ្តឹង គឺការអនុគ្រោះឱ្យពន្យារពេលបង់ប្រាក់ប្រដាប់ក្តីតុលាការ ក៏ប៉ុន្តែ ប្រសិនបើយល់ឃើញថាសមរម្យ ដោយគិតពិចារណាអំពីលទ្ធភាពទ្រព្យធនរបស់ភាគី ជាអាទិ៍ នៅពេលដែលអានុភាពនៃការពន្យារពេលនោះបានរលត់ តុលាការអាចអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការនោះបាន (មាត្រា ៧០ កថាខណ្ឌទី ១) ។ កម្មវត្ថុនៃការផ្តល់នូវជំនួយសង្គ្រោះ ត្រូវកម្រិតត្រឹមប្រាក់ប្រដាប់ក្តីតុលាការ ក្នុងចំណោមប្រាក់ប្រដាប់ក្តីផ្សេងៗ ។ ចំពោះដីកាសម្រេចផ្តល់នូវការសង្គ្រោះលើបណ្តឹងអាចប្តឹងជំទាស់បាន (មាត្រា ៧០ កថាខណ្ឌទី ៤) ។ ការផ្តល់នូវជំនួយសង្គ្រោះលើបណ្តឹងនេះ គឺជាជំនួយផ្តាច់មុខលើបុគ្គល ដូច្នេះ សន្តតិជន ជាអាទិ៍ មិនអាចទទួលបន្តបានឡើយ (មាត្រា ៧០ កថាខណ្ឌទី ២) ។

## កថាភាគទី ៦ ដីកាសម្រេច

១. អត្ថន័យនៃដីកាសម្រេច

ក្នុងចំណោមសេចក្តីសម្រេចរបស់ស្ថាប័នតុលាការ ក្រៅពីសាលក្រម ឬ សាលដីកា មានដីកាសម្រេច ។ ដីកាសម្រេច គឺជាសេចក្តីសម្រេចរបស់តុលាការ ឬ ចៅក្រម ដែលអាចធ្វើបានដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៧៩ កថាខណ្ឌទី ២, មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ដីកាសម្រេចដែលធ្វើដោយចៅក្រម សំដៅទៅលើដីកាសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ក្នុងករណីដែលតុលាការជំនុំជម្រះរឿងក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ (មាត្រា ៨៩) និង ដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ (មាត្រា ១៣៦ កថាខណ្ឌទី ២, មាត្រា ២៤០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២, មាត្រា ២៥៣ កថាខណ្ឌទី ២ ជាអាទិ៍) ។ បញ្ញត្តិស្តីពីសាលក្រមត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេច លើកលែងតែបញ្ញត្តិស្តីពីសាលក្រមនោះ មានភាពផ្ទុយពីលក្ខណៈនៃដីកាសម្រេច (មាត្រា ២១៦) ។ សាលក្រម និង ដីកាសម្រេច មានភាពខុសគ្នាត្រង់ចំណុចដូចតទៅ ។

២. ចំណុចខុសគ្នានឹងសាលក្រម

(១) នីតិវិធីនៃការបង្កើត

ដើម្បីចេញសាលក្រម ជាគោលការណ៍ ត្រូវធ្វើការវិនិច្ឆ័យដោយការទាញហេតុផលដោយផ្ទាល់មាត់ ក៏ប៉ុន្តែដីកាសម្រេចវិញ អាចចេញបានដោយផ្អែកលើការវិនិច្ឆ័យលើឯកសារ ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញ

ហេតុផលដោយផ្ទាល់មាត់ ( មាត្រា ១១៤ កថាខណ្ឌទី ១) ។ ដើម្បីចេញដីកាសម្រេច អាចបើកការទាញហេតុផលដោយផ្ទាល់មាត់បានដែរ ក៏ប៉ុន្តែ ទោះជាក្នុងករណីនេះក៏ដោយ មិនមែនអាចប្រើត្រឹមតែធនធានសម្រាប់ធ្វើការសម្រេចសេចក្តីដែលត្រូវបានលេចឡើង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះទេ គឺតុលាការអាចពិចារណាដល់ធនធានជាឯកសារដែលត្រូវបានដាក់ជូនតុលាការដែរ ។ ម្យ៉ាងទៀត ក្នុងករណីដែលមិនបានឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការអាចកោះហៅភាគីនៅកាលបរិច្ឆេទ និង សួរភាគីនោះបាន ( មាត្រា ១១៤ កថាខណ្ឌទី ២) ។

(២) ចំណុចដែលត្រូវសម្រេចសេចក្តី

ដីកាសម្រេច អាចប្រើបានសម្រាប់ធ្វើការសម្រេចសេចក្តីចំពោះចំណុចបន្ទាប់បន្សំតាមផ្លូវនីតិវិធី ដែលពុំមានពាក់ព័ន្ធនឹងសិទ្ធិ ឬ កាតព្វកិច្ចរបស់ភាគី តាមផ្លូវច្បាប់សារធាតុ ឬ ប្រើសម្រាប់ធ្វើការសម្រេចសេចក្តីទៅលើចំណុចដែលចាំបាច់សម្រេចសេចក្តីឱ្យបានទាន់ពេលវេលា ( មាត្រា ២១, មាត្រា ៣០ កថាខណ្ឌទី ១, មាត្រា ៤៥, មាត្រា ៦៩ កថាខណ្ឌទី ១, មាត្រា ៣៣៧ កថាខណ្ឌទី ១, មាត្រា ៥៣៥ កថាខណ្ឌទី ១ ជាអាទិ៍) ។

(៣) វិធីជូនដំណឹងអំពីសេចក្តីសម្រេច ជាដើម

សាលក្រម ត្រូវបានជូនដំណឹង ដោយការប្រកាសនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ព្រមទាំងការបញ្ជូនលិខិតសាលក្រម ( មាត្រា ១៨៦, មាត្រា ១៨៨ កថាខណ្ឌទី ១, មាត្រា ១៩០) រីឯ ចំពោះដីកាសម្រេចវិញ អាចធ្វើការជូនដំណឹងដោយវិធីដែលតុលាការទទួលស្គាល់ថាសមរម្យបាន ហើយពេលធ្វើការជូនដំណឹង ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីហេតុការណ៍ និង វិធីជូនដំណឹងនោះ ដាក់ក្នុងសំណុំរឿង ( មាត្រា ២១៣ កថាខណ្ឌទី ១ និងទី ៣) ។ ដីកាសម្រេច មិនចាំបាច់សរសេរជាលាយល័ក្ខណ៍អក្សរជាដាច់ខាតទេ ( មាត្រា ២១៣ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធីនៃបណ្តឹង អាចលុបចោលនៅពេលណាក៏បានដែរ ( មាត្រា ២១៤) ។

## ផ្នែកទី ២ មូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងដោយមិនធ្វើទៅតាមសាលក្រម

### កថាភាគទី ១ មូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងនីមួយៗ

ជាគោលការណ៍ នីតិវិធីបណ្តឹងត្រូវបញ្ចប់ដោយសាលក្រមចុងក្រោយ ក៏ប៉ុន្តែ មូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងមានមិនត្រឹមប៉ុណ្ណោះទេ គឺអាចទទួលស្គាល់នូវការបញ្ចប់នីតិវិធីបណ្តឹងដោយសកម្មភាពរបស់ភាគីបាន ។ នេះគឺជាខ្លឹមសារមួយភាគនៃគោលការណ៍នៃសិទ្ធិចាត់ចែង ហើយនេះក៏ជាការអនុវត្តតាមគោលការណ៍នៃស្វ័យភាពរបស់បុគ្គលឯកជននៅក្នុងនីតិវិធីបណ្តឹងដែរ ។ ម្យ៉ាងទៀត ក៏មានការបញ្ចប់នីតិវិធីបណ្តឹងដោយការកើតមានឡើងនូវមូលហេតុកំណត់មួយដែរ ។

ចំពោះមូលហេតុនៃការបញ្ចប់នីតិវិធីបណ្តឹងទៅ យើងអាចសង្ខេបដូចតទៅបាន :

① ការបញ្ចប់ដោយសកម្មភាពរបស់តុលាការ (សាលក្រម) :

ការចូលជាស្ថាពរនៃសាលក្រមចុងក្រោយ

② ការបញ្ចប់ដោយសកម្មភាពរបស់ភាគី :

ការដកពាក្យបណ្តឹង, ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ, ការសះជាតាមផ្លូវបណ្តឹង

③ ការបញ្ចប់ដោយស្វ័យប្រវត្តិ ដោយសារការកើតមានឡើងនៃមូលហេតុកំណត់មួយ :

ការរួមបញ្ចូលនូវឋានៈរបស់ភាគីទាំងសងខាង, ការពុំមានអ្នកទទួលបន្តក្នុងករណីដែលភាគីណាម្ខាងបានទទួលមរណភាព

ក្នុងចំណោមមូលហេតុខាងលើនេះ សាលក្រមចុងក្រោយដែលកំណត់នៅក្នុង ① មានរួមទាំងសាលក្រមដែលសម្រេចអំពីអង្គសេចក្តីដែលទទួលស្គាល់ ឬ ច្រានចោលនូវការទាមទារ និង សាលក្រមលើកចោលបណ្តឹងផងដែរ ។

## កថាភាគទី ២ ការបញ្ចប់នីតិវិធីបណ្តឹងដោយស្វ័យប្រវត្តិ

ក្នុងករណីដែលភាគីបានទទួលមរណភាព ឬ បានរលត់ដោយសារការរួមបញ្ចូលនៃនីតិបុគ្គល ហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង ឬ សិទ្ធិ ឬ កាតព្វកិច្ចនោះបានធ្លាក់ទៅលើបុគ្គលតែម្នាក់ នីតិវិធីនៃបណ្តឹងនោះនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ (មាត្រា ១៧៤) ។ ដូច្នេះ ការបញ្ចប់នីតិវិធីបណ្តឹងដោយស្វ័យប្រវត្តិមានពីរករណី ។

ទីមួយ គឺ ករណីដែលភាគីណាម្ខាងបានទទួលមរណភាព ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះ ។ តាមធម្មតា ទោះជាភាគីណាម្ខាងបានទទួលមរណភាពក៏ដោយ សន្តតិជន ជាអាទិ៍ នឹងទទួលបន្តនូវនីតិវិធីនៃបណ្តឹង (មាត្រា ១៧៣ កថាខណ្ឌទី ១ និង ទី ២) ដូច្នេះ នីតិវិធីនៃបណ្តឹងនោះមិនត្រូវបានបញ្ចប់ទេ ។ ក៏ប៉ុន្តែ អាចមានករណីដែលពុំមានអ្នកដែលត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹង ដោយសារលក្ខណៈនៃសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង ។ មានឧទាហរណ៍ដូចជាករណីដែលភាគីណាម្ខាងបានទទួលមរណភាព នៅពេលដែលបណ្តឹងទាមទារលែងលះគ្នាកំពុងតែត្រូវបានចាត់ការ ជាដើម ។

ទីពីរ គឺ ករណីដែលភាគីណាម្ខាងបានទទួលមរណភាព ឬ បានរលត់ដោយសារការរួមបញ្ចូលនៃនីតិបុគ្គល ហើយសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនោះ ត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់ ។ នេះគឺជាករណីដែលដើមចោទ និង ចុងចម្លើយបានក្លាយទៅជាបុគ្គលតែម្នាក់ ដោយសារតែភាគីណាម្ខាងបានទទួលបន្តនូវឋានៈតាមផ្លូវបណ្តឹង របស់ភាគីម្ខាងទៀត ដោយសារសន្តតិកម្ម ឬ ការរួមបញ្ចូលនៃនីតិបុគ្គល ។

ក្នុងករណីទាំងនេះ គ្មានន័យអ្វីទៀត នឹងបន្តនីតិវិធីនៃបណ្តឹងទេ ដូច្នេះហើយ បណ្តឹងនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ ។ ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវការបញ្ចប់នៃនីតិវិធីបណ្តឹងនោះ តុលាការត្រូវចេញ

សាលក្រមដែលមានខ្លឹមសារថា "បណ្ដឹងត្រូវបានបញ្ចប់ដោយសារមរណភាពនៃភាគី" ឬ "បណ្ដឹងត្រូវបានបញ្ចប់ដោយសារតែសិទ្ធិ និង កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងនោះ ត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់" ។

## កថាភាគទី ៣ ការដកពាក្យបណ្ដឹង

### ១. អត្ថន័យនៃការដកពាក្យបណ្ដឹង

ការដកពាក្យបណ្ដឹង គឺជាសកម្មភាពដកមួយភាគ ឬ ទាំងស្រុងនូវពាក្យសុំទាមទារឱ្យចេញសាលក្រមតាមរយៈបណ្ដឹង ដោយដើមចោទ ។ បណ្ដឹងគឺជាសកម្មភាពដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារកំណត់មួយ ហេតុនេះហើយ ការដកពាក្យបណ្ដឹងនោះ ក៏ជាគោលការណ៍ អាចធ្វើទៅបានតែដោយឆន្ទៈរបស់ដើមចោទប៉ុណ្ណោះ ( មាត្រា ២១៧ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ក្រោយពីចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្ដី មានន័យថា អំពីការទាមទាររបស់ដើមចោទ ឬ បានធ្វើសេចក្ដីថ្លែងការណ៍អំពីអង្គសេចក្ដីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីដកពាក្យបណ្ដឹង ចាំបាច់ត្រូវមានការយល់ព្រមពីចុងចម្លើយ ( មាត្រា ២១៧ កថាខណ្ឌទី ២) ។

ការដកពាក្យបណ្ដឹង គឺជាសកម្មភាពបណ្ដឹងរបស់ដើមចោទ ដែលត្រូវបានធ្វើឡើងនៅក្នុងនីតិវិធីនៃបណ្ដឹង ។ ហេតុនេះហើយ ត្រូវបែងចែកឱ្យដាច់ពីការព្រមព្រៀងដកពាក្យបណ្ដឹងដែលភាគីទាំងសងខាងធ្វើឡើង ក្រៅពីនីតិវិធីនៃបណ្ដឹង ។ តាមរយៈការដកពាក្យបណ្ដឹងនេះ ការចាត់ការបណ្ដឹងនឹងត្រូវរលាយ ។ តែផ្ទុយទៅវិញ ការព្រមព្រៀងដកពាក្យបណ្ដឹងក្រៅនីតិវិធីបណ្ដឹង គឺគ្រាន់តែជាកិច្ចសន្យាមួយតាមផ្លូវនីតិឯកជនប៉ុណ្ណោះ ហេតុនេះហើយ ពុំអាចបង្កើតនូវអានុភាពតាមផ្លូវច្បាប់នីតិវិធី ដូចជាការរំលាយការចាត់ការបណ្ដឹង ជាអាទិ៍ទេ ។

### ២. ល័ក្ខខ័ណ្ឌ និង វិធីដកបណ្ដឹង

(១) ដើមចោទអាចដកពាក្យបណ្ដឹងពេលណាក៏បាន រហូតដល់ពេលដែលសាលក្រមចុងក្រោយចូលជាស្ថាពរ ( មាត្រា ២១៧ កថាខណ្ឌទី ១) ។ ទោះបីជាសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាសរួចហើយក៏ដោយ ក៏ដើមចោទអាចដកពាក្យបណ្ដឹងបានដែរ មុនពេលសាលក្រមនោះចូលជាស្ថាពរ ឬ នៅពេលដែលបណ្ដឹងនោះត្រូវបានចាត់ការដោយតុលាការនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។ ប៉ុន្តែ នៅក្នុងដំណាក់កាលនៃការជំនុំជម្រះបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ក៏អាចដកពាក្យបណ្ដឹងឧបាស្រ័យបានដែរ ហេតុនេះហើយ សូមប្រយ័ត្នកុំឱ្យច្រឡំអំពីការដាក់ពាក្យបណ្ដឹង និង ការដកពាក្យបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។ ឧទាហរណ៍ នៅដំណាក់កាលនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ប្រសិនបើបានដកពាក្យបណ្ដឹង បណ្ដឹងនោះត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ( មាត្រា ២១៨ កថាខណ្ឌទី ១) ដូច្នេះ សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវក្លាយជាមោឃៈ ។ ផ្ទុយទៅវិញ ប្រសិនបើបានដកពាក្យបណ្ដឹងឧទ្ធរណ៍ទៅវិញ គឺត្រូវចាត់ទុកថា គ្មានបណ្ដឹងឧទ្ធរណ៍ទេ ហើយសាលក្រមនៃការជំនុំជម្រះលើកទី ១ នឹងចូលជាស្ថាពរ ។

(២) ការដកពាក្យបណ្ដឹង គឺជាសកម្មភាពបណ្ដឹងឯកតោភាគីរបស់ដើមចោទ ក៏ប៉ុន្តែ ដូចដែលបានពន្យល់ខាងលើនេះ ក្នុងករណីដែលចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្ដី ឬ បានធ្វើសេចក្ដីថ្លែងការណ៍អំពីអង្គសេចក្ដី ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ការដកពាក្យបណ្ដឹងក្រោយពេលនោះ មិនត្រូវមានអានុភាពទេ ប្រសិនបើពុំមានការយល់ព្រមពីចុងចម្លើយ (មាត្រា ២១៧ កថាខណ្ឌទី ២) ។ នេះគឺដោយសារតែចុងចម្លើយឆ្លើយតបនឹងការទាមទាររបស់ដើមចោទ មានន័យថា ចុងចម្លើយក៏មានផលប្រយោជន៍ក្នុងការទទួលសាលក្រមឈ្នះក្ដីចំពោះបណ្ដឹងនោះដែរ ដូច្នេះហើយ ការទទួលស្គាល់នូវការបំបាត់នូវផលប្រយោជន៍របស់ចុងចម្លើយនោះ តាមឆន្ទៈរបស់ដើមចោទតែប៉ុណ្ណោះ មានភាពផ្ទុយនឹងសមភាព និង យុត្តិធម៌ ។

(៣) ការដកពាក្យបណ្ដឹង ជាគោលការណ៍ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ (មាត្រា ២១៧ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ នៅកាលបរិច្ឆេទនៃការផ្សះផ្សា អាចដកពាក្យបណ្ដឹងដោយផ្ទាល់មាត់ក៏បានដែរ (មាត្រា ២១៧ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។ ពេលដែលមានការដកពាក្យបណ្ដឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្ដឹងនៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នៅក្នុងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១១ ចំណុច ឃ, មាត្រា ១១៩ កថាខណ្ឌទី ១ ចំណុច ក) ដើម្បីកុំឱ្យមានវិវាទនាពេលក្រោយ ។ កាលបរិច្ឆេទនៃការផ្សះផ្សា គឺជាមួយប្រភេទនៃកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ តាមលក្ខណៈនៃកាលបរិច្ឆេទនោះ ហេតុនេះហើយ ក្នុងករណីដែលមានការដកពាក្យបណ្ដឹងដោយផ្ទាល់មាត់ នាកាលបរិច្ឆេទនៃការផ្សះផ្សា ចាំបាច់ត្រូវចុះនូវចំណុចនេះ នៅក្នុងកំណត់ហេតុ ។

(៤) ក្នុងករណីដែលចាំបាច់មានការយល់ព្រមពីចុងចម្លើយ ដើម្បីដកពាក្យបណ្ដឹង ទោះជាចុងចម្លើយមិនយល់ព្រមជាក់ស្ដែងក៏ដោយ ក្នុងករណីដូចតទៅ ត្រូវចាត់ទុកដូចជាមានការយល់ព្រមដែរ ។ ទីមួយ គឺ ករណីដែលដើមចោទដាក់លិខិតដកពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរទៅតុលាការ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូននូវលិខិតនេះទៅឱ្យចុងចម្លើយ (មាត្រា ២១៧ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ ប្រសិនបើចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល ២ សប្ដាហ៍ គិតពីថ្ងៃដែលបានទទួលនូវការបញ្ជូនលិខិតនោះទេ ត្រូវចាត់ទុកថា បានយល់ព្រមចំពោះការដកពាក្យបណ្ដឹងនោះ (មាត្រា ២១៧ កថាខណ្ឌទី ៥ វាក្យខណ្ឌទី ១) ។ ទីពីរ គឺ ក្នុងករណីដែលដើមចោទបានដកពាក្យបណ្ដឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា តែចុងចម្លើយអវត្តមាននៅកាលបរិច្ឆេទនោះ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុដែលបានចុះសេចក្ដីថ្លែងការណ៍អំពីការដកពាក្យបណ្ដឹងនោះ ទៅឱ្យចុងចម្លើយ (មាត្រា ២១៧ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១) ។ ក្នុងករណី

ដែលចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល ២ សប្តាហ៍ ពីថ្ងៃដែលបានទទួលនូវការបញ្ជូននោះ ក៏ត្រូវចាត់ទុកថា ចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនោះដែរ ( មាត្រា ២១៧ កថាខណ្ឌទី ៥ វាក្យខណ្ឌទី ២) ។ ទីបី គឺ ក្នុងករណីដែលដើមចោទបានដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍ ហើយចុងចម្លើយមានវត្តមាននៅកាលបរិច្ឆេទនោះ ប្រសិនបើចុងចម្លើយមិនបានតវ៉ាក្នុងអំឡុងពេល ២ សប្តាហ៍ គិតពីកាលបរិច្ឆេទនោះ ត្រូវចាត់ទុកថា ចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្តឹងនោះ ( មាត្រា ២១៧ កថាខណ្ឌទី ៥ វាក្យខណ្ឌទី ២) ។

(៥) ការដកពាក្យបណ្តឹង គឺជាសកម្មភាពបណ្តឹង ហេតុនេះហើយ ដើម្បីធ្វើសកម្មភាពនេះ ដើមចោទចាំបាច់ត្រូវមានសមត្ថភាពក្នុងការធ្វើបណ្តឹង ( មាត្រា ៣២ កថាខណ្ឌទី ២ និង ទី ៣) ។ម្យ៉ាងទៀត អ្នកតំណាងដោយអាណត្តិដែលបានទទួលការប្រគល់សិទ្ធិ ( អាណត្តិ) ជាគោលការណ៍ អាចដកពាក្យបណ្តឹងបាន ( មាត្រា ៥៤ កថាខណ្ឌទី ១) ។ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិជាមេធាវី ជាគោលការណ៍ ភាគីមិនអាចកម្រិតនូវទំហំនៃសិទ្ធិតំណាងរបស់អ្នកនោះទេ ក៏ប៉ុន្តែ ការដកពាក្យបណ្តឹង គឺជាសកម្មភាពដ៏សំខាន់មួយ ដែលដកនូវការទាមទារឱ្យតុលាការចេញសាលក្រមតាមរយៈបណ្តឹង ដូច្នេះហើយ ជាករណីពិសេស អាចធ្វើការកម្រិតសិទ្ធិតំណាងនោះ ហើយមិនផ្តល់សិទ្ធិដកពាក្យបណ្តឹងបាន ( មាត្រា ៥៤ កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ធ្វើនីតិវិធីនៃបណ្តឹង ចាំបាច់ត្រូវមានការប្រគល់សិទ្ធិពិសេស ដើម្បីដកពាក្យបណ្តឹង ( មាត្រា ៣៣ កថាខណ្ឌទី ២ ចំណុច ក) ។

### ៣. អានុភាពនៃការដកពាក្យបណ្តឹង

#### (១) ការរលាយជាប្រតិសកម្មនៃការចាត់ការបណ្តឹង

ពេលដែលមានការដកពាក្យបណ្តឹង ផ្នែកដែលត្រូវបានដកពាក្យណ្តឹងនោះ ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ( មាត្រា ២១៨ កថាខណ្ឌទី ១) ។ ក្នុងករណីដែលដើមចោទបានអះអាងទាមទារឱ្យបញ្ជាក់កម្មសិទ្ធិនៃអចលនវត្ថុ និង ការទាមទារឱ្យសងប្រាក់កំចី ក្នុងបណ្តឹងតែមួយ ( មាត្រា ៧៧) ប្រសិនបើដើមចោទដកពាក្យបណ្តឹងត្រឹមតែការទាមទារនូវការបញ្ជាក់អំពីកម្មសិទ្ធិ នោះចំពោះផ្នែកនៃការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិ ការចាត់ការបណ្តឹងត្រូវរលាយ រីឯចំពោះការទាមទារឱ្យសងប្រាក់កំចី នីតិវិធីត្រូវបន្ត ។ តាមរយៈការដកពាក្យបណ្តឹងនេះ បណ្តឹងនេះនឹងត្រូវបានចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ហេតុនេះហើយ សកម្មភាពរបស់តុលាការ និង ភាគី ដូចជាសាលក្រម ឬ ការដាក់មធ្យោបាយតទល់និងការពារខ្លួន ដែលត្រូវបានធ្វើរហូតដល់ពេលដកពាក្យបណ្តឹងនោះ នឹងបាត់បង់អានុភាពទាំងអស់ជាប្រតិសកម្ម ។

#### (២) ការហាមនូវការដាក់ពាក្យបណ្តឹងដូចគ្នាម្តងទៀត

ជាគោលការណ៍ ទោះជាបានដកពាក្យបណ្តឹងក៏ដោយ ក៏ភាគីអាចដាក់ពាក្យបណ្តឹងដដែលម្តងទៀតបានដែរ ។ ក៏ប៉ុន្តែ ក្នុងករណីដែលដើមចោទបានដកពាក្យបណ្តឹងក្រោយពីចេញសាលក្រមចុងក្រោយអំពីអង្គសេចក្តីចំពោះ

បណ្ដឹងរួចហើយ ដើមចោទដែលបានដកបណ្ដឹងនោះ មិនអាចធ្វើបណ្ដឹងដូចគ្នាម្ដងទៀតបានឡើយ (មាត្រា ២១៨ កថាខណ្ឌទី ២) ។ បណ្ដឹងដូចគ្នាមានន័យថា ជាបណ្ដឹងដែលមានគូភាគី និង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង ដូចគ្នា ។ នេះគឺដោយសារតែ ដើមចោទបានទាមទារឱ្យតុលាការចេញសាលក្រមអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាកំណត់ណាមួយ ហើយតុលាការបានចេញសាលក្រមដោយឆ្លើយតបចំពោះការទាមទារនោះរួចហើយ តែផ្ទុយទៅវិញ ដើមចោទបានដកនូវការទាមទារនោះទៅវិញ ហើយបានធ្វើឱ្យសាលក្រមនោះមោឃៈ ហេតុនេះហើយ មិនត្រូវទទួលស្គាល់នូវការដាក់ពាក្យបណ្ដឹងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដដែលនោះម្ដងទៀតឡើយ ។ ហេតុដូច្នេះ ប្រសិនបើយល់ឃើញថា មានផលប្រយោជន៍ត្រឹមត្រូវក្នុងការទាមទារឱ្យចេញសាលក្រមជាថ្មីម្ដងទៀត ដោយសារស្ថានភាពនៅពេលដែលដើមចោទបានដកពាក្យបណ្ដឹង និង ស្ថានភាពនៅពេលដែលដើមចោទនោះមានបំណងដាក់ពាក្យបណ្ដឹងវិញម្ដងទៀត មានភាពខុសគ្នា នោះមិនត្រូវហាមការធ្វើបណ្ដឹងម្ដងទៀតឡើយ ។ ឧទាហរណ៍ A បានដាក់ពាក្យបណ្ដឹងទាមទារចំពោះ B ឱ្យសងប្រាក់កំចី ១០ លានរៀល ហើយតុលាការបានចេញសាលក្រមទទួលស្គាល់នូវការទាមទាររបស់ A ទាំងស្រុងរួចហើយ ។ ក្រោយពេលនោះ នៅពេលដែលបណ្ដឹងឧទ្ធរណ៍កំពុងត្រូវបានចាត់ការ A និង B បានធ្វើកិច្ចសន្យាសះជាក្រៅផ្លូវតុលាការដោយព្រមព្រៀងគ្នាថា B សងប្រាក់កំចីនោះដោយកាត់សងបណ្ដើរៗ ដូច្នេះហើយ A បានដកពាក្យបណ្ដឹង ។ ក៏ប៉ុន្តែ ក្រោយមកទៀត B មិនបានគោរពតាមកិច្ចសន្យាដោយមិនបានសងបណ្ដើរៗ ហើយ A បានដាក់ពាក្យបណ្ដឹងម្ដងទៀត ។ ក្នុងករណីនេះ មិនត្រូវហាមឃាត់ការធ្វើបណ្ដឹងម្ដងទៀតរបស់ A នេះឡើយ ។

(៣) ការសងពន្ធដាក់ពាក្យបណ្ដឹង

ប្រសិនបើដើមចោទបានដកពាក្យបណ្ដឹង មុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលលើកដំបូង ភាគីអាចទាមទារឱ្យតុលាការសងមកវិញ នូវចំនួនពាក់កណ្ដាលនៃពន្ធដាក់ពាក្យបណ្ដឹងដែលខ្លួនបានបង់ (មាត្រា ៦១ កថាខណ្ឌទី ៨ ចំណុច ខ) ។

## កថាភាគទី ៤ ការលះបង់ និង ការទទួលស្គាល់នូវការទាមទារ

### ១. អត្ថន័យនៃការលះបង់ និង ការទទួលស្គាល់នូវការទាមទារ

ការលះបង់ចោលនូវការទាមទារ គឺជាសេចក្ដីថ្លែងការណ៍តាមផ្លូវបណ្ដឹងរបស់ដើមចោទ ដែលទទួលស្គាល់ខ្លួនឯងថា ការទាមទារតាមផ្លូវបណ្ដឹងរបស់ខ្លួន ពុំមានមូលហេតុត្រឹមត្រូវ (ក្នុងករណីធម្មតា មានន័យថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលខ្លួនអះអាងដោយបណ្ដឹង គ្មានអត្ថិភាព) ។ ការទទួលស្គាល់នូវការទាមទារ គឺជាសេចក្ដីថ្លែងការណ៍តាមផ្លូវបណ្ដឹងរបស់ចុងចម្លើយ ដែលទទួលស្គាល់ដោយគ្មានល័ក្ខខ័ណ្ឌ ថា ការទាមទារតាមផ្លូវបណ្ដឹងរបស់ដើមចោទមានមូលហេតុត្រឹមត្រូវ (តាមធម្មតា មានន័យថា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែល

ដើមចោទអះអាង មានអត្ថិភាព) ។

ដូច្នេះហើយ ការលះបង់ ឬ ការទទួលស្គាល់ គឺជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹង ដែលមានខ្លឹមសារថា ភាគីម្ខាងទទួលស្គាល់នូវភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ជាការធ្វើឱ្យខូចប្រយោជន៍ខ្លួន ហើយ វិវាទរវាងភាគីទាំងសងខាង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារនេះ ត្រូវបានដោះស្រាយ ដោយសេចក្តីថ្លែងការណ៍នោះ ហេតុនេះហើយ បណ្តឹងត្រូវបញ្ចប់ ដោយមិនចាំបាច់រង់ចាំសាលក្រមទេ (សូម មើលមាត្រា ២២២) ។

ការលះបង់ និង ការទទួលស្គាល់នូវការទាមទារ គឺជាសេចក្តីថ្លែងកាណ៍ដែលធ្វើឱ្យមានការខូចដល់ផល ប្រយោជន៍របស់ខ្លួន មិនមែនចំពោះអះអាងអំពីអង្គហេតុទេ គឺចំពោះការទាមទាររបស់ដើមចោទផ្ទាល់តែម្តង (ការអះអាងអំពីសិទ្ធិ) ដូច្នេះមានភាពខុសនឹងការសារភាពតាមផ្លូវបណ្តឹង ។

២. ល័ក្ខខ័ណ្ឌ និង វិធីធ្វើការលះបង់ និង ការទទួលស្គាល់នូវការទាមទារ

(១) ល័ក្ខខ័ណ្ឌអំពីសមត្ថភាពរបស់ភាគី និង ការតំណាង

ការលះបង់ និង ការទទួលស្គាល់នូវការទាមទារ គឺជាសកម្មភាពបណ្តឹង ហេតុនេះហើយភាគីចាំបាច់ត្រូវមាន សមត្ថភាពក្នុងការធ្វើបណ្តឹង ដើម្បលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ ។ ជាគោលការណ៍ អ្នកតំណាង ដោយអាណត្តិដែលបានទទួលការប្រគល់សិទ្ធិ (អាណត្តិ) អាចលះបង់ និង ទទួលស្គាល់នូវការទាមទារបាន (មាត្រា ៥៤ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ប្រសិនបើអ្នកតំណាងដោយអាណត្តិ ជាមេធាវី ជាគោលការណ៍ ភាគីមិនអាចធ្វើការកម្រិតនូវទំហំនៃសិទ្ធិអំណាចនោះបានទេ ក៏ប៉ុន្តែ ការលះបង់ និង ការទទួលស្គាល់នូវ ការទាមទារ គឺជាសកម្មភាពដែលបង្កើតនូវអានុភាពដ៏ធ្ងន់ធ្ងរដូចការចាត់ចែងនៃសិទ្ធិ ឬ ការទទួលបន្ទុកនូវ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង ហេតុនេះហើយ ជាករណីពិសេស អាចធ្វើការកម្រិតនូវសិទ្ធិតំណាងដើម្បី ធ្វើការលះបង់ និង ការទទួលស្គាល់នូវការទាមទារបាន (មាត្រា ៥៤ កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ចាំបាច់ត្រូវទទួលនូវការប្រគល់សិទ្ធិពិសេស ដើម្បី ធ្វើការលះបង់ និង ការទទួលស្គាល់នូវការទាមទារ (មាត្រា ៣៣ កថាខណ្ឌទី ២ ចំណុច ក) ។

(២) ល័ក្ខខ័ណ្ឌអំពីការទាមទារ

(ក) កុំឱ្យមានកង្វះនូវល័ក្ខខ័ណ្ឌបណ្តឹង

ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ មានអានុភាពដូចគ្នានឹងសាលក្រមច្រានចោលនូវការទាមទារ ឬ សាលក្រមទទួលស្គាល់នូវការទាមទារដែរ (មាត្រា ២២២) ដូច្នេះហើយ ដើម្បីឱ្យការលះបង់ ឬ ការទទួល ស្គាល់នូវការទាមទារនោះមានសុពលភាព ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌបណ្តឹង ដែលជាល័ក្ខខ័ណ្ឌចំបាច់ដើម្បីចេញ សាលក្រមដែលសម្រេចអំពីអង្គសេចក្តី ។ ក្នុងករណីដែលមានកង្វះល័ក្ខខ័ណ្ឌបណ្តឹង ទោះជាមានការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារក៏ដោយ ក៏ត្រូវលើកចោលបណ្តឹងនោះដែរ ។

(ខ) ខ្លឹមសារនៃការទាមទារត្រូវជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដល់ភាគីអាចចាត់ចែងបានដោយសេរី

ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ បង្កើតនូវអានុភាពដូចគ្នានឹងការចាត់ចែងដោយសេរីនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទ ។ ហេតុនេះហើយ ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ អាចធ្វើទៅបានតែចំពោះបណ្ដឹងដែលយកគោលការណ៍នៃសិទ្ធិចាត់ចែងជាមូលដ្ឋាន ។ ឧទាហរណ៍ ប្រសិនបើមានបណ្ដឹងទាមទារឱ្យសងប្រាក់កម្ចី ដូចករណីឧទាហរណ៍ដែលមាននៅភាគដំបូងនៃសៀវភៅនេះ A អាចលះបង់ចោលនូវការទាមទារបាន រីឯ B វិញ អាចទទួលស្គាល់នូវការទាមទារបាន ។ ផ្ទុយទៅវិញ ចំពោះបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានកម្មវត្ថុជាទំនាក់ទំនងនៃឋានៈបុគ្គលដែលភាគីពុំត្រូវបានទទួលស្គាល់នូវសេរីភាពក្នុងការចាត់ចែង ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ មិនត្រូវបានអនុញ្ញាតឡើយ (សេចក្ដីព្រាងច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ១២ កថាខណ្ឌទី ២) ។

(គ) ការទាមទារនោះមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ

(៣) វិធីធ្វើការលះបង់ និង ធ្វើការទទួលស្គាល់នូវការទាមទារ

ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវធ្វើឡើង ដោយធ្វើសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់ ចំពោះមុខចៅក្រម នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា (មាត្រា ២២១) ។

៣. អានុភាពនៃការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ

ពេលដែលមានសេចក្ដីថ្លែងការណ៍អំពីការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ តុលាការត្រូវស្រាវជ្រាវមើលថា តើមានល័ក្ខខ័ណ្ឌដូចដែលបានពន្យល់មុនឬទេ ។ ប្រសិនបើតុលាការទទួលស្គាល់ថា មានល័ក្ខខ័ណ្ឌត្រឹមត្រូវក្នុងការលះបង់ ឬ ទទួលស្គាល់នូវការទាមទារ ក្រឡាបញ្ជីត្រូវចុះក្នុងកំណត់ហេតុស្ដីពីចំណុចនេះ (មាត្រា ១០៩, មាត្រា ១១១ ចំណុច ឃ, មាត្រា ១១៧ កថាខណ្ឌទី ១, មាត្រា ១១៩ កថាខណ្ឌទី ១ ចំណុច ក) ។ ពេលដែលបានចុះអំពីការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ នៅក្នុងកំណត់ហេតុនៃកាលបរិច្ឆេទ កំណត់ហេតុនោះ មានអានុភាពដូចសាលក្រមស្ថាពរដែរ (មាត្រា ២២២) ។ មានន័យថា ប្រសិនបើកំណត់ហេតុនោះក្លាយជាបានការហើយ បណ្ដឹងនោះនឹងត្រូវបញ្ចប់ ។ ម្យ៉ាងទៀត កំណត់ហេតុដែលបានចុះអំពីការលះបង់នូវការទាមទារ មានអានុភាពដូចសាលក្រមស្ថាពរដែលច្រានចោលនូវការទាមទារដែរ រីឯកំណត់ហេតុដែលបានចុះអំពីការទទួលស្គាល់នូវការទាមទារ មានអានុភាពដូចសាលក្រមស្ថាពរដែលទទួលស្គាល់នូវការទាមទារដែរ ។ ដូច្នេះហើយ កំណត់ហេតុដែលបានចុះអំពីការទទួលស្គាល់នូវការទាមទារឱ្យផ្ដល់តាវកាលិក មានអានុភាពអនុវត្ត ដូច្នេះអាចក្លាយទៅជាលិខិតអនុវត្តបាន (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឈ) ។ ប៉ុន្តែ ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ គឺជាសកម្មភាពរបស់ភាគី ហើយខុសពីសាលក្រមស្ថាពរដែលតុលាការទទួលស្គាល់អង្គហេតុដោយភស្តុតាង ហើយសម្រេចសេចក្ដីស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដោយ

អនុវត្តច្បាប់ចំពោះអង្គហេតុនេះ ហេតុនេះហើយ ត្រូវបកស្រាយថា កំណត់ហេតុទាំងនេះ មិនត្រូវបង្កើតនូវអានុភាពអស់ជំនុំជាលក្ខណៈសារធាតុទេ ( មាត្រា ១៩៤ កថាខណ្ឌទី ១) ។ ចំពោះចំណុចនេះ សូមមើលការបកស្រាយស្ដីពីអានុភាពនៃការសះជាតាមផ្លូវបណ្ដឹង ដែលនឹងពន្យល់បន្ទាប់នេះ ។

## កថាភាគទី ៥ ការសះជាតាមផ្លូវបណ្ដឹង

### ១. អត្ថន័យនៃការសះជាតាមផ្លូវបណ្ដឹង

ការសះជាតាមផ្លូវបណ្ដឹង គឺជាសកម្មភាពដែលដើមចោទ និង ចុងចម្លើយធ្វើសម្បទានគ្នាទៅវិញទៅមក (លះបង់រៀង១ខ្លួន) នូវការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង និង ព្រមព្រៀងបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្ដឹង ហើយធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនោះដោយឯកភាពគ្នាចំពោះមុខតុលាការ ។ ហេតុនេះហើយ មានភាពខុសពីកិច្ចសន្យាសះជា ដែលភាគីធ្វើឡើងក្រៅបណ្ដឹង ( ក្រមរដ្ឋប្បវេណី មាត្រា ៧២៤) ។

ទោះជាក្រោយការដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីក៏ដោយ ប្រសិនបើភាគីទាំងសងខាងអាចបញ្ចប់វិវាទតាមរយៈការព្រមព្រៀងបាន លទ្ធផលនេះគឺជាលទ្ធផលមួយល្អប្រសើរបំផុតចំពោះភាគីទាំងសងខាងផង ចំពោះរដ្ឋផង ។ ខ្លឹមសារនៃការសះជា អាចនឹងត្រូវបានអនុវត្តបានច្រើន ហើយភាគីទាំងសងខាងនឹងអាចរក្សានូវទំនាក់ទំនងគ្នាល្អនាអនាគត ហើយលើសពីនេះ មិនមានបញ្ហាប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ផង ដូច្នេះអាចសង្ឃឹមនូវការបញ្ចប់បណ្ដឹងឱ្យបានឆាប់រហ័សផង ។ ហេតុដូច្នេះ ក្រមនីតិវិធីរដ្ឋប្បវេណីមានចែងថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ពេលចាប់ផ្ដើមនីតិវិធី តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សាជាមុនសិន លើកលែងតែក្នុងករណីដែលយល់ឃើញថា មិនសមរម្យ ដូចជាពេលដែលបានយល់ឃើញច្បាស់លាស់ថាចុងចម្លើយពុំមានឆន្ទៈឆ្លើយតបនឹងការផ្សះផ្សាទេ ជាដើម ( មាត្រា ១០៤) ។ ម្យ៉ាងទៀត ទោះជាក្រោយការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏ដោយ ប្រសិនបើយល់ឃើញថា អាច និង គួរតែដោះស្រាយវិវាទដោយការផ្សះផ្សា តុលាការអាចសាកល្បងធ្វើការផ្សះផ្សាពេលណាក៏បានដែរ ( មាត្រា ៩៧) ។

### ២. ល័ក្ខខ័ណ្ឌ និង វិធីនៃការសះជាតាមផ្លូវបណ្ដឹង

#### (១) ល័ក្ខខ័ណ្ឌស្ដីពីការទាមទារ

(ក) ការសះជាតាមផ្លូវបណ្ដឹង នឹងធ្វើឱ្យមានការចាត់ចែងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង ហេតុនេះហើយ ត្រូវអនុញ្ញាតឱ្យផ្សះផ្សាបានតែក្នុងបណ្ដឹងដែលយកគោលការណ៍នៃសិទ្ធិចាត់ចែង មកធ្វើជាមូលដ្ឋាន ។ ដូច្នេះ ចំពោះបណ្ដឹងទាក់ទំនងនឹងឋានៈបុគ្គល ដែលយកទំនាក់ទំនងនឹងឋានៈបុគ្គល មកធ្វើជាកម្មវត្ថុនៃបណ្ដឹងនោះ មិនអាចផ្សះផ្សាបានទេ ( ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ១២ កថាខណ្ឌ ទី ២) ។

(ខ) ការសះជាតាមផ្លូវបណ្តឹង ក៏មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ ប្រសិនបើបានសរសេរនៅក្នុងកំណត់ហេតុ (មាត្រា ២២២) ហេតុនេះហើយ ដើម្បីឱ្យការសះជានេះមានអានុភាព ជាគោលការណ៍ ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌបណ្តឹងដែលជាល័ក្ខខ័ណ្ឌដើម្បីចេញសាលក្រមសម្រេចអំពីអង្គសេចក្តីនៃបណ្តឹងនោះ ។ ក៏ប៉ុន្តែ ចំពោះការសះជា ភាគីទាំងសងខាងបានព្រមព្រៀងគ្នាបញ្ចប់វិវាទ ដូច្នេះ ទោះបីជាមានកិច្ចសន្យាមជ្ឈត្តកម្ម ឬ ការព្រមព្រៀងអំពីការមិនដាក់បណ្តឹងក៏ដោយ ក៏ភាគីអាចសះជាគ្នាតាមផ្លូវបណ្តឹងបានដែរ ។ ម្យ៉ាងទៀត ដើម្បីសះជា មិនចាំបាច់មានសមត្ថកិច្ច (លើកលែងតែសមត្ថកិច្ចផ្តាច់មុខ) ឬ មិនចាំបាច់មានអត្ថិភាពនៃផលប្រយោជន៍ស្តីពីកម្មវត្ថុនៃបណ្តឹងទេ ។

(២) ល័ក្ខខ័ណ្ឌស្តីពីខ្លឹមសារ

ការសះជាតាមផ្លូវបណ្តឹង គឺជាការព្រមព្រៀងបញ្ចប់វិវាទ ដោយធ្វើសម្បទានគ្នាទៅវិញទៅមកនូវការអះអាងរបស់ខ្លួនដែលទាក់ទងនឹងការទាមទារតាមផ្លូវបណ្តឹង ។ កម្រិតនៃការធ្វើសម្បទាននោះ មិនមែនជាបញ្ហាទេ ។ ឧទាហរណ៍ ក្នុងបណ្តឹងទាមទារឱ្យសងប្រាក់កំចី ១០ លានរៀល ចុងចម្លើយទទួលស្គាល់នូវកាតព្វកិច្ចសង ហើយដើមចោទបានផ្តល់នូវប្រយោជន៍នៃការកំណត់ពេល ដោយអនុញ្ញាតឱ្យសងបណ្តាក់ ១០ ដង គឺ ១ លានរៀល ក្នុង ១ ខែ ឬ ក្នុងបណ្តឹងពាក់ព័ន្ធនឹងភតិសន្យានៃអចលនវត្ថុ ដែលភតិបតីបានទាមទារឱ្យប្រគល់អចលនវត្ថុវិញ ដោយអះអាងថា ខ្លួនបានរំលាយកិច្ចសន្យាដោយសារតែភតិកៈមិនបានបង់ថ្លៃឈ្នួល ដើមចោទបានធ្វើសម្បទាន (លះបង់ផលប្រយោជន៍របស់ខ្លួន) ដោយលើកលែងកាតព្វកិច្ចបង់ថ្លៃឈ្នួលដែលមិនទាន់បង់ ហើយផ្តល់អំឡុងពេលសម្រាប់ប្រគល់អចលនវត្ថុវិញ រយៈពេល ៣ ខែ រីឯចុងចម្លើយវិញក៏ទទួលស្គាល់នូវការបញ្ចប់ភតិសន្យាដោយការរំលាយកិច្ចសន្យា ដោយមានមូលហេតុមិនបានបង់ថ្លៃឈ្នួល ហើយសន្យាថា ៣ ខែក្រោយ ខ្លួននឹងប្រគល់អចលនវត្ថុនោះវិញ ជាអាទិ៍ ។ ការសះជាដែលមានខ្លឹមសារថា ភាគីម្ខាងគ្រាន់តែធ្វើសម្បទានចំពោះបន្ទុកនូវប្រាក់ប្រដាប់ក្តីប៉ុណ្ណោះ ក៏អាចធ្វើបានដែរ ។ ប៉ុន្តែ នេះក៏ដូចករណីនៃការលះបង់ ឬ ទទួលស្គាល់នូវការទាមទារដែរ គឺ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលកំណត់ក្នុងការសះជានោះ ចាំបាច់ត្រូវមានលក្ខណៈដែលអាចអនុញ្ញាតឱ្យធ្វើទៅបានតាមច្បាប់ ហើយមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ ។

(៣) ល័ក្ខខ័ណ្ឌស្តីពីសមត្ថភាពរបស់ភាគី និង ការតំណាង

ការសះជាតាមផ្លូវបណ្តឹង ក៏ជាសកម្មភាពបណ្តឹងមួយដែរ ហេតុនេះហើយ ដើម្បីសះជា ភាគីចាំបាច់ត្រូវមានសមត្ថភាពក្នុងការធ្វើបណ្តឹង ។ អ្នកតំណាងដោយអាណត្តិដែលបានទទួលការប្រគល់សិទ្ធិ ជាគោលការណ៍ អាចសះជាតាមផ្លូវបណ្តឹងបាន (មាត្រា ៥៤ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ប្រសិនបើអ្នកតំណាងដោយអាណត្តិជាមេធាវី ជាគោលការណ៍ ភាគីនីមួយៗមិនអាចកម្រិតនូវទំហំនៃសិទ្ធិតំណាងនោះទេ ក៏ប៉ុន្តែ ការផ្សះផ្សាតាមផ្លូវបណ្តឹង គឺជាសកម្មភាពមួយដែលចាត់ចែងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង ហើយ

ធ្វើឱ្យមានអានុភាពដ៏ធ្ងន់ធ្ងរ ហេតុនេះហើយ អាចកម្រិតនូវសិទ្ធិតំណាង ជាករណីពិសេសបាន (មាត្រា ៥៤ កថាខណ្ឌទី ៣) ។ ម្យ៉ាងទៀត ដើម្បីធ្វើសកម្មភាពផ្សះផ្សាតាមផ្លូវបណ្ដឹង ជននៅក្រោមហិតូបត្ថម្ភ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវមានការប្រគល់នូវសិទ្ធិពិសេស (មាត្រា ៣៣ កថាខណ្ឌទី ២ ចំណុច ក) ។

(៤) វិធីផ្សះផ្សាតាមផ្លូវបណ្ដឹង

ដើម្បីធ្វើការផ្សះផ្សាតាមផ្លូវបណ្ដឹង ភាគីទាំងសងខាងចាំបាច់ត្រូវបង្ហាញខ្លួននៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ហើយព្រមព្រៀងដោយផ្ទាល់មាត់ ស្ដីពីការបញ្ចប់នូវវិវាទ ដោយធ្វើសម្បទានគ្នាទៅវិញទៅមកនូវការអះអាងរៀង១ខ្លួន (មាត្រា ២២០ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ប្រសិនបើយល់ឃើញថាសមរម្យ ដូចជាករណីដែលសាកល្បងផ្សះផ្សា នៅពេលធ្វើការពិនិត្យភស្តុតាងក្រៅតុលាការ ជាអាទិ៍ តុលាការអាចធ្វើការសាកល្បងផ្សះផ្សានៅក្រៅតុលាការបាន (មាត្រា ២២០ កថាខណ្ឌទី ២) ។

៣. អានុភាពនៃការសះជាតាមផ្លូវបណ្ដឹង

(១) អានុភាពនៃការបញ្ចប់បណ្ដឹង

ប្រសិនបើការសះជាតាមផ្លូវបណ្ដឹងត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ (មាត្រា ១១១ ចំណុច ឃ, មាត្រា ១១៩ កថាខណ្ឌទី ១ ចំណុច ក) កំណត់ត្រានេះ ត្រូវបានទទួលស្គាល់ថា មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ (មាត្រា ២២២) ។ ដោយសារតែវិវាទរវាងគូភាគីបានបញ្ចប់ដោយសារការសះជា ហើយគ្មានន័យក្នុងការបន្តបណ្ដឹងនោះ ហេតុនេះហើយ ជាលទ្ធផលនៃអានុភាពនៃការសះជាតាមផ្លូវបណ្ដឹង បណ្ដឹងត្រូវបញ្ចប់ ។ ប្រសិនបើមានវិវាទស្ដីពីសុពលភាពនៃការសះជាតាមផ្លូវបណ្ដឹង មុននឹងធ្វើកំណត់ហេតុ នោះតុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើការទាញហេតុផលដោយផ្ទាល់មាត់ ។ ក្នុងករណីដែលបានវិនិច្ឆ័យថា ការសះជានោះគ្មានសុពលភាពទេ តុលាការអាចចេញសាលក្រមរបៀបអំពីបញ្ហានេះ ហើយបន្តបណ្ដឹងបាន (មាត្រា ១៨១ ចំណុច ឃ) ។

(២) អានុភាពអនុវត្ត

ក្នុងករណីដែលមានចុះអំពីសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកជាក់ស្ដែង ដោយកំណត់ពេលអនុវត្ត ឬ បែបផែននៃការអនុវត្ត កំណត់ហេតុស្ដីពីការសះជា ត្រូវមានអានុភាពអនុវត្ត ។ ដូច្នេះ នេះគឺជាលិខិតអនុវត្ត ដែលភាគីអាចសម្រេចនូវសិទ្ធិទាមទារនោះ តាមរយៈការអនុវត្តដោយបង្ខំ (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឈ) ។

(៣) អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ

(ក) ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២ មានចែងថា ក្នុងករណីដែលមានការសះជាតាមផ្លូវបណ្ដឹង ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានោះមាន "អានុភាពដូចគ្នានឹងសាលក្រមស្ថាពរ" ។ ក៏ប៉ុន្តែ អានុភាព

ដូចគ្នានឹងសាលក្រមស្ថាពរនេះ មិនមានរួមទាំងអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ (មាត្រា ១៩៤ កថាខណ្ឌទី ១) ឡើយ ។ មានន័យថា ទោះបីជាការសះជាតាមផ្លូវបណ្ដឹង ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុក៏ដោយ ក៏កំណត់ត្រានោះពុំមានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុឡើយ ។ មូលហេតុមានដូចតទៅ : ការសះជាតាមផ្លូវបណ្ដឹង គឺជាការបញ្ចប់វិវាទ ដោយកំណត់នូវទំនាក់ទំនងគតិយុត្តរវាងភាគីទាំងសងខាង ទៅតាមខ្លឹមសារនៃការសះជា ដោយផ្អែកលើការព្រមព្រៀងរបស់ភាគីជាមូលដ្ឋាន ដូច្នេះ មានភាពខុសគ្នាពីសកម្មភាពដែលតុលាការទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាង ហើយអនុវត្តច្បាប់ចំពោះអង្គហេតុទាំងនោះ ហើយកំណត់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដូចសាលក្រមស្ថាពរទេ ។ ប្រសិនបើការសះជាបានសម្រេចហើយ ទោះបីជាទំនាក់ទំនងគតិយុត្តរវាងភាគី ត្រូវបានកំណត់ទៅតាមខ្លឹមសារនោះក៏ដោយ នេះគឺជាការដែលយកការព្រមព្រៀងរបស់ភាគីមកធ្វើជាមូលដ្ឋានតែប៉ុណ្ណោះ ដូច្នេះ ប្រសិនបើការបង្ហាញឆន្ទៈដែលបង្កើតនូវខ្លឹមសារនៃការព្រមព្រៀង មានមូលហេតុនៃមោឃភាព ឬ ការលុបចោល ដូចជាការភាន់ច្រឡំ ឬ ការឆបោក ជាអាទិ៍ ការសះជានោះត្រូវក្លាយទៅជាមោឃៈ ដោយស្វ័យប្រវត្តិ ឬ ដោយការលុបចោល ។ ក៏ប៉ុន្តែ ប្រសិនបើចាត់ទុកថា កំណត់ត្រាក្នុងកំណត់ហេតុនៃការសះជា មានអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ឧទាហរណ៍ ក្នុងករណីដែលមានកំណត់ត្រាអំពីអត្ថិភាពនៃកាតព្វកិច្ចសងប្រាក់កំចី ឬ កាតព្វកិច្ចចេញពីអចលនវត្ថុណាមួយ ភាគីនឹងមិនអាចធ្វើវិវាទនៅពេលក្រោយ ដោយផ្អែកលើមូលហេតុដែលមានមុនពេលវេលាដែលជាមូលដ្ឋាននៃអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ (ការភាន់ច្រឡំ និង ការឆបោក គឺជាមូលហេតុដែលបានកើតឡើងមុនពេលវេលាជាមូលដ្ឋាន) (សូមមើលការពន្យល់នៅក្នុងជំពូកទី ៤ ផ្នែកទី ១ កថាភាគទី ៣ "អានុភាពនៃសាលក្រមចុងក្រោយស្ថាពរ" "៣. អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ") ។ ហើយលទ្ធផលនេះផ្ទុយនឹងលក្ខណៈនៃការសះជាដែលបានពន្យល់ខាងលើនេះ ហេតុដូច្នេះ មិនអាចទទួលស្គាល់នូវអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ ចំពោះកំណត់ត្រាក្នុងកំណត់ហេតុនៃការសះជាបានឡើយ ។

(ខ) ហេតុដូច្នេះ ប្រសិនបើការបង្ហាញឆន្ទៈក្នុងការសះជាតាមផ្លូវបណ្ដឹង មានវិការៈ ភាគីអាចអះអាងនូវមោឃភាព ឬ ការលុបចោលការសះជានោះ ដោយយកវិការៈក្នុងការបង្ហាញឆន្ទៈនេះមកជាមូលហេតុនៅពេលក្រោយបាន ។ វិធីអះអាងនូវមោឃភាពនៃការសះជាមានដូចជា ភាគីអាចដាក់ពាក្យសុំឱ្យតុលាការកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីបន្តនូវនីតិវិធីបណ្ដឹងបាន ដោយលើកឡើងនូវមូលហេតុថា បណ្ដឹងមិនទាន់ត្រូវបានបញ្ចប់ដោយសារមោឃភាពនៃការសះជា ។ ប្រសិនបើមានពាក្យសុំឱ្យកំណត់នូវកាលបរិច្ឆេទដោយមានមូលហេតុនេះ តុលាការចាំបាច់ត្រូវកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយនៅកាលបរិច្ឆេទនេះ ត្រូវធ្វើការវិនិច្ឆ័យថា តើការសះជានោះមានសុពលភាព ឬទេជាមុនសិន ។ ប្រសិនបើយល់ឃើញថា ការសះជានោះមោឃៈ តុលាការត្រូវបញ្ជាក់ថា បណ្ដឹងនោះមិនទាន់ត្រូវបានបញ្ចប់ ដោយចេញសាលក្រមរបៀប (មាត្រា ១៨១ ចំណុច ឃ) ឬ ដោយវិធីដទៃទៀត ហើយ

បន្តការវិនិច្ឆ័យបណ្តឹងនោះ ។ ផ្ទុយទៅវិញ ប្រសិនបើយល់ឃើញថា ការសះជានោះមានសុពលភាព តុលាការត្រូវចេញសាលក្រមចុងក្រោយ ដែលប្រកាសនូវការបញ្ចប់បណ្តឹងដោយការសះជានោះ ។ ក្រៅពីនេះ ភាគីអាចធ្វើការអះអាងមោឃភាពនៃការសះជាតាមផ្លូវបណ្តឹង ដោយដាក់បណ្តឹងទាមទារឱ្យបញ្ជាក់នូវមោឃភាពនៃការសះជាក៏បានដែរ (សូមមើលមាត្រា ៣៧០ កថាខណ្ឌទី ១ ចំណុច គ) ហើយលើសពីនេះ អាចដាក់បណ្តឹងតវ៉ាចំពោះការទាមទារ (មាត្រា ៣៦៣ កថាខណ្ឌទី ១) ដើម្បីទប់ស្កាត់នូវការអនុវត្តដោយបង្ខំដែលយកកំណត់ហេតុនៃការសះជា ធ្វើជាលិខិតអនុវត្តនោះបាន ហើយអះអាងអំពីនត្ថិភាពនៃសិទ្ធិទាមទារតាមកំណត់ហេតុ ដោយយកមោឃភាពនៃការសះជាជាមូលហេតុ ។

(៤) ប្រាក់ប្រដាប់ក្តី

ក្នុងករណីដែលបណ្តឹងត្រូវបានបញ្ចប់ដោយការសះជា ត្រូវកំណត់ថា តើភាគីណាត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តី ដោយការព្រមព្រៀង ។ ក្នុងករណីដែលពុំមានការព្រមព្រៀងស្តីពីការទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តីនេះទេ ភាគីម្នាក់ៗត្រូវទទួលបន្ទុករៀងៗខ្លួន (មាត្រា ៦៥ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។ ក្នុងករណីដែលការសះជាបានសម្រេចមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទអាចទទួលមកវិញបាននូវចំនួនពាក់កណ្តាលនៃពន្ធនៃការដាក់ពាក្យបណ្តឹងដែលបានបង់រួចហើយ តាមពាក្យសុំ (មាត្រា ៦១ កថាខណ្ឌទី ៨ ចំណុច ខ) ។

# ជំពូកទី ៥ ភាពមានកម្មវត្ថុច្រើន ឬ ភាពមានប្រធានច្រើននាក់ក្នុងបណ្តឹង

## ផ្នែកទី ១ ភាពមានកម្មវត្ថុច្រើនក្នុងបណ្តឹង

### កថាភាគទី ១ ការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង

១. អត្ថន័យនៃការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង

ការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង គឺជាការបង្ហាញសរុបនូវការទាមទារតាមផ្លូវបណ្តឹងច្រើនចំណុចតាំងពីដំបូង នៅក្នុងបណ្តឹងមួយ ដែលធ្វើឡើងដោយដើមចោទម្នាក់ ចំពោះចុងចម្លើយម្នាក់ ហើយទាមទារឱ្យចេញសាលក្រមចំពោះការទាមទារទាំងនោះ ។ ក្នុងករណីដែលបណ្តឹងត្រូវបានដាក់ ដោយដើមចោទច្រើននាក់ ឬចំពោះចុងចម្លើយច្រើននាក់ ក៏ការទាមទារច្រើនចំណុចក្លាយទៅជាកម្មវត្ថុនៃបណ្តឹងផងដែរ ប៉ុន្តែ ក្នុងករណី នេះប្រធាននៃបណ្តឹងក៏មានច្រើននាក់ដែរ ។ ម្យ៉ាងទៀត ក្នុងករណីដែលដើមចោទបានបន្ថែមនូវការទាមទារថ្មីទៀត លើការទាមទារពីមុន ឬ ប្តូរការទាមទារដែលបានធ្វើពីមុន ទៅនឹងការទាមទារថ្មី នៅពេលដែលបណ្តឹងកំពុងត្រូវបានចាត់ការ នេះក៏ជាករណីដែលកម្មវត្ថុនៃបណ្តឹងនោះមានការទាមទារច្រើនចំណុចដែរ ប៉ុន្តែករណីនេះ គេហៅថា ការបន្ថែម ឬ ការផ្លាស់ប្តូរនៃកម្មវត្ថុនៃបណ្តឹង ហើយត្រូវចែកឱ្យដាច់ពីបណ្តឹងដែលបង្ហាញការទាមទារច្រើនចំណុចជាកម្មវត្ថុនៃបណ្តឹងតាំងពីដំបូង ។ ដើម្បីឱ្យបានដឹងច្បាស់លាស់អំពីគោលគំនិតនេះ ការរួមបញ្ចូលនៃកម្មវត្ថុនៃបណ្តឹងដែលបានពន្យល់នេះ គេអាចហៅថា ការរួមបញ្ចូលនូវកម្មវត្ថុបណ្តឹងតាំងពីដើម ។

២. ល័ក្ខខ័ណ្ឌនៃការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹង

(១) ការទាមទារច្រើនចំណុច អាចត្រូវបានវិនិច្ឆ័យដោយនីតិវិធីប្រភេទដូចគ្នា (មាត្រា ៧៧)

នីតិវិធីបណ្តឹងរដ្ឋប្បវេណីធម្មតា និង នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឬ នីតិវិធីបណ្តឹងរដ្ឋបាល គឺជានីតិវិធីប្រភេទផ្សេង១គ្នា ។ ការចាំបាច់ត្រូវវិនិច្ឆ័យដោយនីតិវិធីបណ្តឹងប្រភេទដូចគ្នា គឺដើម្បីធ្វើការវិនិច្ឆ័យនូវការទាមទារច្រើនចំណុចដោយគោលការណ៍រួមគ្នា ។ ឧទាហរណ៍ នីតិវិធីបណ្តឹងរដ្ឋប្បវេណីធម្មតា គឺត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមដោយវិធីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ ដោយយកគោលការណ៍នៃសិទ្ធិចាត់ចែង និង គោលការណ៍នៃការទាញហេតុផល ជាមូលដ្ឋាន រីឯនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលវិញ ជាគោលការណ៍ គឺជានីតិវិធីធ្វើជាសម្ងាត់ (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា ១៥) ដោយយកគោលការណ៍នៃការស្រាវជ្រាវដោយឆន្ទានុសិទ្ធិធ្វើជាមូលដ្ឋាន (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា ១២ កថាខណ្ឌទី ២, មាត្រា ១៣) ហេតុនេះហើយ ការទាមទារដែលត្រូវបានវិនិច្ឆ័យដោយនីតិវិធីរដ្ឋប្បវេណីធម្មតា

ឧទាហរណ៍ដូចជា ការទាមទារឱ្យសងប្រាក់កម្ចី និង ការទាមទារដែលត្រូវបានវិនិច្ឆ័យដោយនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល ឧទាហរណ៍ដូចជា ការទាមទារលែងលះគ្នា មិនអាចរួមបញ្ចូលគ្នាបានទេ ។ ប៉ុន្តែសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មានចែងជាករណីពិសេសនៃគោលការណ៍នេះ ដោយទទួលស្គាល់នូវការរួមបញ្ចូលនូវការទាមទារស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ការទាមទារស្តីពីសំណងនៃការខូចខាតដែលកើតឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារស្តីពីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គលនោះ ទោះបីជាមិនមែនជាការទាមទារដែលត្រូវបានវិនិច្ឆ័យដោយនីតិវិធីបណ្តឹងប្រភេទដូចគ្នាក៏ដោយ (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា ១០) ។ ឧទាហរណ៍បណ្តឹងលែងលះគ្នា និង ការទាមទារនូវជម្ងឺចិត្តដោយសារការលែងលះគ្នា គឺជាករណីពិសេសនេះ ។ គោលគំនិតនេះ គឺជាការទទួលស្គាល់នូវការវិនិច្ឆ័យ និង ចេញសាលក្រម ដោយរួមបញ្ចូលនូវការទាមទារដែលមានទំនាក់ទំនងខ្លាំង ។ ក្នុងករណីនេះ ការវិនិច្ឆ័យស្តីពីចំណុចរួមនៃការទាមទារទាំងពីរនេះ ត្រូវធ្វើតាមគោលការណ៍នៃនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល រីឯចំណុចក្រៅពីនេះវិញ ត្រូវធ្វើតាមនីតិវិធីនៃការវិនិច្ឆ័យដែលបានកំណត់ចំពោះចំណុចនីមួយៗនោះ ។

(២) ការទាមទារនីមួយៗ តុលាការដែលទទួលពាក្យបណ្តឹងត្រូវមានសមត្ថកិច្ច

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១១ តុលាការដែលមានសមត្ថកិច្ចលើការទាមទារមួយ ក៏ត្រូវមានសមត្ថកិច្ចលើការទាមទារផ្សេងទៀត ដែលត្រូវបានរួមបញ្ចូលនោះ ហេតុនេះហើយ ជាធម្មតា ស្របនឹងល័ក្ខខ័ណ្ឌនេះ ។ ប៉ុន្តែ ត្រូវបកស្រាយថា មិនអាចអនុវត្តមាត្រា ១១ នេះ ចំពោះការទាមទារដែលតុលាការដទៃទៀតមានសមត្ថកិច្ចផ្តាច់មុខទេ (មាត្រា ១០, មាត្រា ៣០៩ ជាអាទិ៍) ។

៣. បែបយ៉ាងនៃការរួមបញ្ចូលនូវការទាមទារ

(១) ការរួមបញ្ចូលធម្មតា

ការរួមបញ្ចូលធម្មតា គឺជាបែបយ៉ាងនៃការរួមបញ្ចូលដើម្បីទាមទារឱ្យធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះទាមទារនីមួយៗ ដែលមានចំណាត់ថ្នាក់ស្មើគ្នា និង គ្មានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក ។ ឧទាហរណ៍ការរួមបញ្ចូលនូវការទាមទារឱ្យសងប្រាក់កម្ចី និង ការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិដីធ្លី ឬ ការរួមបញ្ចូលនូវការទាមទារឱ្យប្រគល់អាគារវិញ និង ការទាមទារនូវប្រាក់សំណងការខូចខាតដែលស្មើនឹងថ្លៃឈ្នួលអាគារនោះរហូតដល់ពេលប្រគល់អាគារនោះមកវិញ គឺជាករណីបែបនេះ ។ ក្នុងករណីនៃការរួមបញ្ចូលរបៀបនេះ តុលាការចាំបាច់ត្រូវចេញសាលក្រមស្តីពីការទាមទារនីមួយៗ ។

(២) ការរួមបញ្ចូលត្រៀម

ការរួមបញ្ចូលត្រៀម គឺជាបែបយ៉ាងនៃការរួមបញ្ចូលដើម្បីត្រៀមសម្រាប់ករណីដែលតុលាការមិនទទួលស្គាល់នូវការទាមទារទីមួយ ដោយដាក់ពាក្យសុំទាមទារឱ្យចេញសាលក្រមជាមុនចំពោះការទាមទារទីពីរ ។

ការទាមទារទីមួយ ត្រូវហៅថាជាការទាមទារចម្បង រីឯការទាមទារទីពីរ ត្រូវហៅថាជាការទាមទារត្រៀម ។ ប្រសិនបើការទាមទារចម្បងត្រូវបានទទួលស្គាល់ដោយតុលាការ ដើមចោទនឹងមិនទាមទារឱ្យចេញសាលក្រមចំពោះការទាមទារត្រៀមទេ ហេតុនេះហើយ មានន័យថា ពាក្យសុំទាមទារឱ្យចេញសាលក្រមចំពោះការទាមទារត្រៀម យកការទទួលស្គាល់នូវការទាមទារចម្បងមកធ្វើជាល័ក្ខខ័ណ្ឌរំលាយ ។ ឧទាហរណ៍ អ្នកលក់វត្ថុបានទាមទារជាចម្បង នូវការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញ ដោយផ្អែកលើសុពលភាពនៃកិច្ចសន្យាលក់ទិញ ហើយព្រមជាមួយគ្នានេះ បានប្ដឹងទាមទារត្រៀមនូវការទាមទារឱ្យប្រគល់វិញនូវវត្ថុដែលបានប្រគល់ទៅឱ្យអ្នកទិញរួចហើយ ដើម្បីត្រៀមក្នុងករណីដែលតុលាការច្រានចោលការទាមទារចម្បង ដោយយល់ឃើញថា កិច្ចសន្យាលក់ទិញនោះមោឃៈ ។ នេះគេហៅថា ការរួមបញ្ចូលត្រៀម ។ ក្នុងករណីនៃការរួមបញ្ចូលរបៀបនេះ ប្រសិនបើទទួលស្គាល់នូវការទាមទារចម្បង តុលាការមិនត្រូវចេញសាលក្រមចំពោះការទាមទារត្រៀម ហើយប្រសិនបើច្រានចោលនូវការទាមទារចម្បង តុលាការត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះការទាមទារត្រៀម ។

(៣) ការរួមបញ្ចូលតាមជំរើស

ការរួមបញ្ចូលតាមជំរើស គឺជាការរួមបញ្ចូលបែបយ៉ាងមួយដែលចំពោះដើមចោទ ប្រសិនបើតុលាការទទួលស្គាល់នូវការទាមទារណាមួយក្នុងចំណោមការទាមទារច្រើនដែលត្រូវបានរួមបញ្ចូល គោលបំណងនៃបណ្ដឹងត្រូវបានសម្រេច ដូច្នេះដើមចោទនឹងមិនទាមទារឱ្យចេញសាលក្រមចំពោះការទាមទារដទៃទៀត ។ មានន័យថា ពាក្យសុំឱ្យចេញសាលក្រមចំពោះការទាមទារនីមួយៗ យកការទទួលស្គាល់នូវការទាមទារណាមួយក្នុងចំណោមការទាមទារទាំងអស់នោះ មកធ្វើជាល័ក្ខខ័ណ្ឌរំលាយ ។ ការរួមបញ្ចូលតាមជំរើស ត្រូវបានទទួលស្គាល់ក្នុងករណីដែលដាក់ពាក្យបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក ដោយអះអាងសិទ្ធិទាមទារច្រើនដែលមានកម្មវត្ថុនៃតាវកាលិកតែមួយ ឬ ក្នុងករណីដែលដាក់ពាក្យបណ្ដឹងទាមទារឱ្យបង្កើត ផ្លាស់ប្ដូរ ឬ រំលាយទំនាក់ទំនងគតិយុត្ត ដោយអះអាងនូវសិទ្ធិបង្កើត ផ្លាស់ប្ដូរ ឬ រំលាយទំនាក់ទំនងគតិយុត្តច្រើន ដែលមានគោលបំណងបង្កើត ផ្លាស់ប្ដូរ ឬ រំលាយទំនាក់ទំនងគតិយុត្តតែមួយ ។ ឧទាហរណ៍នៃករណីនេះមានដូចជា បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិកដែលទាមទារឱ្យប្រគល់វត្ថុតែមួយ ដោយអះអាងនូវសិទ្ធិទាមទារឱ្យប្រគល់វិញនូវវត្ថុនោះដោយផ្អែកលើកម្មសិទ្ធិ (ក្រមរដ្ឋប្បវេណី មាត្រា ១៥៥) និង អះអាងនូវសិទ្ធិទាមទារឱ្យប្រគល់វិញនូវវត្ថុនោះដោយផ្អែកលើការកាន់កាប់ (ក្រមរដ្ឋប្បវេណី មាត្រា ២៣៧) ឬ បណ្ដឹងទាមទារលែងលះគ្នាដោយអះអាងនូវមូលហេតុនៃការលែងលះគ្នាច្រើន (ក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុចនីមួយៗ) ។ ប្រសិនបើទទួលស្គាល់នូវការទាមទារណាមួយក្នុងចំណោមការទាមទារច្រើន តុលាការមិនត្រូវចេញសាលក្រមចំពោះការទាមទារផ្សេងទៀតដែលនៅសល់ ហើយប្រសិនបើសម្រេចឱ្យដើមចោទចាញ់ តុលាការត្រូវច្រានចោលនូវការទាមទារទាំងអស់ ។

៤. ការវិនិច្ឆ័យ និង សាលក្រម

(១) ការស្រាវជ្រាវអំពីល័ក្ខខ័ណ្ឌរួមបញ្ចូលគ្នា

ជាបឋម តុលាការត្រូវធ្វើការវិនិច្ឆ័យថា តើស្របល័ក្ខខ័ណ្ឌនៃការរួមបញ្ចូលដែរឬទេ ហើយក្នុងករណីដែលមិនស្របល័ក្ខខ័ណ្ឌទេ តុលាការត្រូវចាត់ទុកថា មានពាក្យបណ្តឹងច្រើនផ្សេងគ្នាចំពោះការទាមទារនីមួយៗ ហើយត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះបណ្តឹងនីមួយៗនោះ ដោយនីតិវិធីផ្សេងៗគ្នា ។ ក្នុងករណីដែលតុលាការផ្សេងមានសមត្ថកិច្ចផ្តាច់មុខ ចំពោះការទាមទារណាមួយ តុលាការត្រូវផ្ទេររឿងក្តីដែលយកការទាមទារនោះជាកម្មវត្ថុ ទៅតុលាការដែលមានសមត្ថកិច្ចនោះ ( មាត្រា ១៨ កថាខណ្ឌទី ១) ។

(២) ការវិនិច្ឆ័យរួមគ្នា

ប្រសិនបើមានភាពស្របល័ក្ខខ័ណ្ឌនៃការរួមបញ្ចូលហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះការទាមទារច្រើនចំណុចដែលត្រូវបានរួមបញ្ចូលនោះ ដោយនីតិវិធីដូចគ្នា ។ ការទាញហេតុផល និង ការពិនិត្យភស្តុតាង ក៏ត្រូវធ្វើរួមគ្នា ចំពោះការទាមទារច្រើនចំណុចនោះ ។ ក្នុងករណីនៃការរួមបញ្ចូលធម្មតា ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចបំបែកការទាមទារមួយភាគ ចេញពីការទាមទារដែលត្រូវបានរួមបញ្ចូលនោះ ហើយចាត់ការជាបណ្តឹងផ្សេងបាន ( មាត្រា ៩៩ កថាខណ្ឌទី ១) ។

(៣) សាលក្រម

(ក) ប្រសិនបើបញ្ចប់នូវការវិនិច្ឆ័យដែលចាំបាច់ ហើយមានស្ថានភាពអាចចេញសាលក្រមបាន ចំពោះការទាមទារមួយ ក្នុងចំណោមការទាមទារច្រើនដែលត្រូវបានរួមបញ្ចូលនោះ តុលាការអាចចេញសាលក្រមតែចំពោះការទាមទារនោះបាន ( មាត្រា ១៨០ កថាខណ្ឌទី ២) ។ នេះគេហៅថា ការចេញសាលក្រមមួយផ្នែក ។ ប៉ុន្តែ ក្នុងករណីនៃការរួមបញ្ចូលត្រៀម ឬ នៃការរួមបញ្ចូលតាមជំរើស តុលាការមិនត្រូវបានអនុញ្ញាតឱ្យចេញសាលក្រមមួយផ្នែកបានឡើយ ។

(ខ) ប្រសិនបើការវិនិច្ឆ័យដែលចាំបាច់ចំពោះការទាមទារទាំងអស់ដែលត្រូវបានរួមបញ្ចូល ត្រូវបានបញ្ចប់សព្វគ្រប់ហើយ តុលាការចាំបាច់ត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់នោះ ( សូមមើលមាត្រា ១៨០ កថាខណ្ឌទី ១) ។ សាលក្រមដែលបញ្ឈប់បណ្តឹងទាំងមូលនៅក្នុងថ្នាក់នៃការជំនុំជម្រះនោះ ត្រូវហៅថា សាលក្រមសម្រេចទាំងមូល ។ ក្នុងករណីនៃការរួមបញ្ចូលត្រៀម ពេលចេញសាលក្រមទទួលស្គាល់នូវការទាមទារចម្បង មិនចាំបាច់ចេញសាលក្រមចំពោះការទាមទារត្រៀមទេ ហើយក្នុងករណីនៃការរួមបញ្ចូលតាមជំរើស ពេលដែលចេញសាលក្រមទទួលស្គាល់ការទាមទារណាមួយ មិនចាំបាច់ចេញសាលក្រមចំពោះការទាមទារដែលនៅសល់ក្រៅពីនោះទេ ។ ហេតុនេះហើយ សាលក្រមទាំងនេះក៏បញ្ឈប់នីតិវិធីបណ្តឹងទាំងមូលនៅក្នុងថ្នាក់នៃការជំនុំជម្រះនោះដែរ ហេតុនេះហើយ សាលក្រមទាំងនេះ ក៏ជាសាលក្រមសម្រេចទាំងមូលដែរ ។

ប្រសិនបើមានការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមសម្រេចទាំងមូល បណ្តឹងនោះទាំងមូលនឹងត្រូវផ្ទេរទៅការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ។ ក្នុងការរួមបញ្ចូលត្រៀម ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលទទួលស្គាល់នូវការទាមទារចម្បង ការទាមទារត្រៀមក៏ត្រូវផ្ទេរទៅការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែរ ហេតុនេះហើយ ប្រសិនបើលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រម ចំពោះការទាមទារត្រៀម ។ ក្នុងការរួមបញ្ចូលតាមជំរើស ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលទទួលស្គាល់នូវការទាមទារមួយ ការទាមទារដែលនៅសល់ក្រៅពីនេះ ក៏ត្រូវផ្ទេរទៅការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែរ ហេតុនេះហើយ ប្រសិនបើលុបចោលនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ តុលាការនៃបណ្តឹងឧទ្ធរណ៍ក៏ត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះការទាមទារដែលនៅសល់នោះដែរ ។

## កថាភាគទី ២ ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង

១. អត្ថន័យនៃការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង

(១) ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និង ការបន្ថែម ឬ ការផ្លាស់ប្តូរនូវទំហំនៃការវិនិច្ឆ័យ និង ការចេញសាលក្រម

ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង គឺជាការផ្លាស់ប្តូរនូវ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ" ឬ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ដែលបានសរសេរនៅក្នុងពាក្យបណ្តឹង ដោយដើមចោទ ក្រោយពេលដាក់ពាក្យបណ្តឹង ហើយតាមរយៈការផ្លាស់ប្តូរនេះ ត្រូវផ្លាស់ប្តូរសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង ឬ ត្រូវផ្លាស់ប្តូរនូវទំហំនៃការវិនិច្ឆ័យ និង ចេញសាលក្រមអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះ (មាត្រា ៨៤) ។ ឧទាហរណ៍ ដើមចោទដាក់ពាក្យបណ្តឹងមួយដែលទាមទារនូវសាលក្រមដែលបញ្ជាក់ថា អចលនវត្ថុជាកំណត់ណាមួយជាកម្មសិទ្ធិរបស់ដើមចោទ តែដើមចោទបានផ្លាស់ប្តូរទៅជាការទាមទារនូវសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក ដោយមានខ្លឹមសារបង្គាប់ឱ្យសងនូវសំណងនៃការខូចខាត ដោយយកការបំពានកម្មសិទ្ធិជាមូលហេតុ ជាដើម ។ តាមរយៈការផ្លាស់ប្តូរនេះ កម្មវត្ថុនៃបណ្តឹងត្រូវបានផ្លាស់ប្តូរពីកម្មសិទ្ធិនៃអចលនវត្ថុ ទៅសិទ្ធិទាមទារសំណងការខូចខាតទៅវិញ ។ ម្យ៉ាងទៀត ដើមចោទបានអះអាងអំពីសិទ្ធិឱ្យសងប្រាក់កំចី ហើយទាមទារឱ្យសង ១០ លានរៀល តែបានចុះបន្ថយទឹកប្រាក់នៃការទាមទារនោះទៅ ៨ លានរៀល ឬ តម្លើងទៅ ១៥ លានរៀល ក៏ជាការផ្លាស់ប្តូរបណ្តឹងដែរ ។ ក្នុងករណីនេះ ពុំមានការផ្លាស់ប្តូរសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងទេ តែមានការផ្លាស់ប្តូរនូវទំហំនៃការវិនិច្ឆ័យ និង ចេញសាលក្រម ។

(២) ការបន្ថែមនូវការទាមទារ និង ការផ្លាស់ប្តូរនូវការទាមទារ

មានករណីដែលការទាមទារដំបូងនៃបណ្តឹង គឺ ការបញ្ជាក់នូវកម្មសិទ្ធិនៃអចលនវត្ថុ តែដើមចោទបានបន្ថែមនូវការទាមទារនូវសំណងការខូចខាត ដោយយកការបំពាននៃអចលនវត្ថុជាមូលហេតុ (ការបន្ថែមនូវការទាមទារ) និង ករណីដែលមានការប្តូរពីការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិ ទៅការទាមទារនូវសំណងការខូចខាត (ការផ្លាស់ប្តូរការទាមទារ) ។ ការផ្លាស់ប្តូរនូវការទាមទារ គឺជាការបន្ថែមនូវការទាមទារថ្មី ហើយព្រមជាមួយគ្នានេះ ដកបណ្តឹងអំពីការទាមទារចាស់ ។

២. ល័ក្ខខ័ណ្ឌនៃការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង

(១) ចាំបាច់ស្របនឹងល័ក្ខខ័ណ្ឌទូទៅនៃការរួមបញ្ចូលនូវការទាមទារ (មាត្រា ៧៧)

ករណីរួមបញ្ចូលដោយបន្ថែមនូវការទាមទារ ក៏ដូចករណីផ្លាស់ប្តូរនូវការទាមទារដែរ ការទាមទារថ្មី ទាំងការទាមទារដើម ត្រូវបាននិនិច្ឆ័យដោយនីតិវិធីបណ្តឹងដូចគ្នា ហេតុដូច្នេះ មិនអាចអនុញ្ញាតឱ្យធ្វើការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងបានទេ ប្រសិនបើការទាមទារទាំងនោះមិនមែនត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមដោយនីតិវិធីប្រភេទដូចគ្នាទេ ។

(២) ចាំបាច់ត្រូវនៅមុនការបញ្ចប់ទាញហេតុផលដោយផ្ទាល់មាត់ នៃការវិនិច្ឆ័យទៅលើអង្គហេតុ (មាត្រា ៨៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១)

ស្តីពីការទាមទារថ្មី ចាំបាច់ត្រូវធ្វើការវិនិច្ឆ័យស្តីពីអង្គហេតុថ្មីទៀត ហេតុនេះហើយ ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងអាចអនុញ្ញាតឱ្យធ្វើបាន តែពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការក្នុងការវិនិច្ឆ័យទៅលើអង្គហេតុទេ ។ ទោះបីជាការវិនិច្ឆ័យនៃការជំនុំជម្រះលើកទី ១ ត្រូវបានបញ្ចប់ក៏ដោយ នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ក៏អាចបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងបានដែរ ។

(៣) មិនត្រូវមានការប្តូរនូវមូលដ្ឋាននៃការទាមទារ (មាត្រា ៨៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១)

ដើម្បីអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹង ការទាមទារថ្មី និង ការទាមទារដើម ត្រូវតែជាការទាមទារដែលកើតឡើងដោយទំនាស់តែមួយ ឬ ទំនាស់តគ្នា ក្នុងជីវភាពសង្គម ហើយថែមទាំងមានចំណុចវិវាទសំខាន់ៗរួមផងដែរ ហេតុនេះហើយចាំបាច់ត្រូវអាចប្រើនូវឯកសារបណ្តឹង និង ធនធានភស្តុតាងដែលមានមុនពេលបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងបាន ក្នុងការវិនិច្ឆ័យក្រោយពេលបន្ថែម ឬ ផ្លាស់ប្តូរនោះ ។ ចំពោះដើមចោទសាមីខ្លួនបានដាក់ពាក្យបណ្តឹងរួចហើយ ហេតុដូច្នេះ គេច្បាស់ជាចង់ឱ្យតុលាការសម្រេចអំពីការទាមទារដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹងនោះ តាមរយៈសាលក្រមនៃបណ្តឹងនោះ ក៏ប៉ុន្តែ ផ្ទុយទៅវិញ ចំពោះចុងចម្លើយវិញ ការពង្រីក ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងដោយមិនសមរម្យ អាចនឹងធ្វើឱ្យមានការពិបាកនឹងការពារខ្លួន ។ ដូច្នេះ ល័ក្ខខ័ណ្ឌ "មិនមានការផ្លាស់ប្តូរនូវមូលដ្ឋាននៃការទាមទារ" នេះ គឺជាវិធីមួយដើម្បីសម្របសម្រួលផលប្រយោជន៍របស់ភាគីទាំងសងខាង ។ ឧទាហរណ៍នៃករណីដែលមិនមានការផ្លាស់ប្តូរនូវមូលដ្ឋាននៃការទាមទារមានដូចជា ករណីដែលបន្ថែមការទាមទារសំណងនៃការខូចខាត ដោយយកការបំពានកម្មសិទ្ធិមកជាមូលហេតុ

ថែមទៅលើការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិ ករណីដែលបន្ថែមការទាមទារឱ្យសងការប្រាក់ ទៅលើការទាមទារឱ្យសងប្រាក់ដើម ឬ ករណីផ្លាស់ប្តូរការទាមទារ ពីការទាមទារឱ្យប្រគល់វត្ថុណាមួយ ទៅការទាមទារសំណងការខូចខាត ដោយសារការវិនាសនៃវត្ថុ នៅពេលកំពុងចាត់ការបណ្តឹង ជាដើម ។

(៤) មិនត្រូវធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធីទេ ( មាត្រា ៨៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)

តាមទ្រឹស្តី មិនមានការផ្លាស់ប្តូរនូវមូលដ្ឋាននៃការទាមទារទេ ក៏ប៉ុន្តែ មានករណីដែលការទាមទារពីដើមអាចត្រូវបានបញ្ចប់ការវិនិច្ឆ័យភ្លាម១បាន តែចាំបាច់មានការវិនិច្ឆ័យឱ្យសមស្របចំពោះការទាមទារថ្មី ។ ក្នុងករណីនេះ តុលាការអាចមិនអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរបាន ដោយយកមូលហេតុថា ការបន្ថែម ឬ ការផ្លាស់ប្តូរនោះ នឹងធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធីបណ្តឹង ។ ក្នុងករណីបែបនេះ ដើមចោទអាចដាក់ពាក្យបណ្តឹងដោយឡែក ចំពោះការទាមទារថ្មីនោះ ។

(៥) ការទាមទារថ្មី មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃទៀត

៣. វិធីធ្វើការផ្លាស់ប្តូរបណ្តឹង

ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ( មាត្រា ៨៤ កថាខណ្ឌទី ២) ។ នេះគឺដោយសារតែ ជាសារធាតុ ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង គឺដូចជាការដាក់ពាក្យបណ្តឹងថ្មីដែរ ។ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនឯកសារនោះ ទៅភាគីម្ខាងទៀត ( មាត្រា ៨៤ កថាខណ្ឌទី ៣) ។

៤. ការចាត់ចែងអំពីការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង

ប្រសិនបើការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង មានកង្វះនូវល័ក្ខខ័ណ្ឌនៃការបន្ថែម ឬ ការផ្លាស់ប្តូរ តុលាការត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹង តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ( មាត្រា ៨៤ កថាខណ្ឌទី ៤) ។ ប្រសិនបើយល់ឃើញថា ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងនោះស្របល័ក្ខខ័ណ្ឌ តុលាការត្រូវធ្វើការវិនិច្ឆ័យការទាមទារថ្មីនេះ ហើយចេញសាលក្រម ។ ក្នុងករណីនៃការផ្លាស់ប្តូរនូវការទាមទារនៃបណ្តឹង ប្រសិនបើចុងចម្លើយបានឆ្លើយតបចំពោះអង្គសេចក្តីរហូតដល់ពេលមានការផ្លាស់ប្តូរនោះ អានុភាពនៃការដកការទាមទារដើម មិនកើតមានឡើងទេ បើចុងចម្លើយមិនយល់ព្រម (សូមមើលមាត្រា ២១៧ កថាខណ្ឌទី ២) ហេតុដូច្នេះ តុលាការត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះការទាមទារទាំងដើម ទាំងថ្មី ដោយចាត់ទុកថាជាការបន្ថែមនូវការទាមទារ ។

## កថាភាគទី ៣ បណ្តឹងតប

### ១. អត្ថន័យនៃបណ្តឹងតប

បណ្តឹងតប គឺជាបណ្តឹងដែលចុងចម្លើយបានធ្វើឡើងចំពោះដើមចោទ នៅក្នុងនីតិវិធីនៃបណ្តឹង នៅពេលបណ្តឹងដែលដើមចោទធ្វើឡើង កំពុងតែត្រូវបានចាត់ការ ។ ចំពោះបណ្តឹងតប បណ្តឹងដែលដាក់ដោយដើមចោទ

ហើយកំពុងតែត្រូវបានចាត់ការនោះ ត្រូវហៅថា បណ្តឹងដើម ។ បណ្តឹងតប គឺជាបណ្តឹងថ្មីដែលធ្វើដោយចុងចម្លើយនៃបណ្តឹងដើម (ដើមចោទនៃបណ្តឹងតប) ចំពោះដើមចោទនៃបណ្តឹងដើម (ចុងចម្លើយនៃបណ្តឹងតប) ហើយមិនមែនជាមធ្យោបាយការពារខ្លួនចំពោះបណ្តឹងដើមទេ ។

២.ល័ក្ខខ័ណ្ឌនៃបណ្តឹងតប

(១) ការទាមទារនៃបណ្តឹងតប ចាំបាច់ត្រូវជាការទាមទារដែលត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រម ដោយនីតិវិធីបណ្តឹងប្រភេទដូចគ្នានឹងការទាមទារនៃបណ្តឹងដើម ហើយការប្តឹងតប មិនត្រូវបានហាមឃាត់

ការទាមទារនៃបណ្តឹងតប និង ការទាមទារនៃបណ្តឹងដើម ត្រូវតុលាការធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមដោយនីតិវិធីដូចគ្នា ហេតុនេះហើយ ចាំបាច់ត្រូវមានល័ក្ខខ័ណ្ឌទូទៅនៃការរួមបញ្ចូលនូវការទាមទារ ។ ក៏ប៉ុន្តែ ប្រសិនបើច្បាប់បានចែងពិសេស ហាមមិនឱ្យធ្វើបណ្តឹងតប (ឧទាហរណ៍ មាត្រា ២២៧) មិនអនុញ្ញាតឱ្យធ្វើបណ្តឹងតបឡើយ ។

(២) លុះត្រាតែបណ្តឹងដើមកំពុងត្រូវបានចាត់ការ ហើយត្រូវស្ថិតនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការវិនិច្ឆ័យទៅលើអង្គហេតុ (មាត្រា ៨៦ កថាខណ្ឌទី ១)

ទោះជាក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១ ក៏ដោយ ក៏ចុងចម្លើយអាចប្តឹងតបបានដែរ បើបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ហើយកំពុងត្រូវបានចាត់ការដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ ។ ក៏ប៉ុន្តែ ដើម្បីដាក់បណ្តឹងតបនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ចាំបាច់ត្រូវមានការយល់ព្រមពីដើមចោទដែលជាភាគីម្ខាងទៀត (មាត្រា ២៧៦ កថាខណ្ឌទី ១) ។ នេះគឺដើម្បីការពារផលប្រយោជន៍នៃថ្នាក់នៃការជម្រះក្តីរបស់ដើមចោទ (ផលប្រយោជន៍នេះ គឺ ការអាចទទួលនូវការជំនុំជម្រះ និង ចេញសាលក្រម នៅក្នុងបីថ្នាក់ ពីការជំនុំជម្រះលើកទីមួយ ដល់ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ) ដោយសារតែបានរំលងចោលនូវការជំនុំជម្រះលើកទី ១ ចំពោះការទាមទារនៃបណ្តឹងតប ។ ដូច្នេះ ប្រសិនបើដើមចោទមិនបានតវ៉ា ហើយបានទាញហេតុផលលើអង្គសេចក្តីនៃបណ្តឹងតប ត្រូវចាត់ទុកថា បានយល់ព្រមអំពីការដាក់បណ្តឹងតបដោយមិនចាំបាច់មានការបង្ហាញនូវឆន្ទៈយល់ព្រមច្បាស់លាស់ទេ (មាត្រា ២៧៦ កថាខណ្ឌទី ២) ។

(៣) ការទាមទារនៃបណ្តឹងតប ចាំបាច់ត្រូវមានទំនាក់ទំនងនឹងការទាមទារនៃបណ្តឹងដើម ឬ មានទំនាក់ទំនងនឹងមធ្យោបាយការពារខ្លួនចំពោះការទាមទារនៃបណ្តឹងដើម (មាត្រា ៨៦ កថាខណ្ឌទី ១)

បណ្តឹងតប គឺជាពាក្យសុំឱ្យតុលាការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះការទាមទារថ្មី នៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ ដូចការបន្ថែម ឬ ការផ្លាស់ប្តូរការទាមទារ ហេតុនេះហើយ ល័ក្ខខ័ណ្ឌនៃបណ្តឹងតបនេះ គឺត្រូវបានកំណត់ដូចគ្នានឹងល័ក្ខខ័ណ្ឌនៃការបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងដោយដើមចោទដែរ ។ មានន័យថា មិនចាំបាច់ទទួលស្គាល់រហូតដល់ការទាមទារដែលគ្មានទាក់ទងនឹងការទាមទារនៃបណ្តឹងដើមទេ ។ "ការទាមទារនៃបណ្តឹងតប ទាក់ទងនឹងការទាមទារនៃបណ្តឹងដើម" មានន័យថា ការទាមទារនៃបណ្តឹងដើម និង ការទាមទារ

នៃបណ្ដឹងតប ពាក់ព័ន្ធនឹងកម្មវត្ថុដូចគ្នា ឬ កើតឡើងពីអង្គហេតុដូចគ្នា ដូចជា ករណីដែលបណ្ដឹងដើម និង បណ្ដឹងតប មានខ្លឹមសារទាមទារឱ្យបញ្ជាក់នូវកម្មសិទ្ធិលើកម្មវត្ថុដូចគ្នា ឬ ករណីដែលបណ្ដឹងដើម និង បណ្ដឹងតប មានខ្លឹមសារទាមទារនូវសំណងការខូចខាតដោយមូលហេតុគ្រោះថ្នាក់ចរាចរណ៍ដូចគ្នា ជាដើម ។ "ការទាមទារនៃបណ្ដឹងតបទាក់ទងនឹងមធ្យោបាយការពារខ្លួនចំពោះការទាមទារនៃបណ្ដឹងដើម" មានដូចជា ករណីដែលអះអាងអង្គហេតុតវ៉ាអំពីការទូទាត់សិទ្ធិលើបំណុលរបស់ដើមចោទ ដោយយកសិទ្ធិលើបំណុលរបស់ចុងចម្លើយ ហើយដាក់បណ្ដឹងតបទាមទារឱ្យសងប្រាក់ដែលនៅសល់ពីការទូទាត់នោះមកវិញ ឬ ករណីដែលអះអាងអង្គហេតុតវ៉ាអំពីការលុបចោលកិច្ចសន្យាលក់ទិញដោយយកការឆបោកជាមូលហេតុ ចំពោះបណ្ដឹងដើមដែលទាមទារឱ្យបង់ប្រាក់លក់ទិញ ហើយដាក់បណ្ដឹងតបទាមទារឱ្យសងនូវសំណងការខូចខាត ដោយសារការឆបោកនោះ ជាដើម ។

(៤) ការទាមទារនៃបណ្ដឹងតប មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការដទៃទៀត (មាត្រា ៨៦ កថាខណ្ឌ ទី ១ វាក្យខណ្ឌទី ២)

(៥) នីតិវិធីបណ្ដឹងមិនមានការយឺតយ៉ាវខ្លាំង ដោយសារការដាក់បណ្ដឹងតប (មាត្រា ៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)

សូមមើលការពន្យល់មុនអំពីការបន្ថែម ឬ ការផ្លាស់ប្ដូរបណ្ដឹង ។

៣. វិធីដាក់ពាក្យបណ្ដឹងតប និង ការចាត់ចែងបណ្ដឹងតប

ចំពោះវិធីនៃការប្ដឹងតប ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីបណ្ដឹងដើម (មាត្រា ៨៦ កថាខណ្ឌទី ២) ។ ក្នុងករណីដែលមិនស្របនឹងល័ក្ខខ័ណ្ឌនៃបណ្ដឹងតប តុលាការត្រូវបំបែកចែករឿងក្ដីនោះ (មាត្រា ៩៩ កថាខណ្ឌទី ១) ហើយចាត់ចែងបណ្ដឹងតបជាបណ្ដឹងឯករាជ្យមួយ និង ត្រូវធ្វើការវិនិច្ឆ័យផ្សេងពីគ្នា ។ ក្នុងករណីដែលតុលាការផ្សេង មានសមត្ថកិច្ចផ្ដាច់មុខ តុលាការត្រូវផ្ទេរបណ្ដឹងតបនោះ ទៅតុលាការនោះ ។ ក្នុងករណីដែលស្របល័ក្ខខ័ណ្ឌបណ្ដឹងតប តុលាការត្រូវធ្វើការវិនិច្ឆ័យ និង ចេញសាលក្រមអំពីបណ្ដឹងដើម និង បណ្ដឹងតប ដោយនីតិវិធីដូចគ្នា ។

## កថាភាគទី ៤ បណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី

១. អត្ថន័យនៃបណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី

បណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី គឺជាបណ្ដឹងទាមទារឱ្យបញ្ជាក់ដែលត្រូវបានដាក់ដោយដើមចោទ ឬ ចុងចម្លើយ នៅពេលបណ្ដឹងកំពុងត្រូវចាត់ការ ដើម្បីទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលផ្សេងពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង ហើយដែលជាមូលដ្ឋាននៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹងនោះ

(មាត្រា ៨៥) ។ ឧទាហរណ៍ ពេលដែលកំពុងតែធ្វើការវិនិច្ឆ័យបណ្ដឹងទាមទារឱ្យប្រគល់វិញនូវវត្ថុដែលជាកម្មសិទ្ធិរបស់ដើមចោទ ប្រសិនបើមានវិវាទថា តើដើមចោទជាកម្មសិទ្ធិករនៃកម្មវត្ថុនោះឬទេ ពេលនោះដើមចោទបានធ្វើបណ្ដឹងទាមទារការបញ្ជាក់កម្មសិទ្ធិ ឬ ចុងចម្លើយបានធ្វើបណ្ដឹងទាមទារការបញ្ជាក់នត្ថិភាពនៃកម្មសិទ្ធិរបស់ដើមចោទ នេះគឺជាករណីនៃបណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី ។

បណ្ដឹងនេះ គឺជាការបន្ថែមកម្មវត្ថុនៃបណ្ដឹងមួយប្រភេទ ប្រសិនបើដើមចោទប្ដឹង ហើយគឺជាបណ្ដឹងតបមួយប្រភេទ ប្រសិនបើចុងចម្លើយប្ដឹង ។ ប៉ុន្តែ ច្បាប់កំណត់នូវល័ក្ខខ័ណ្ឌ សម្រាប់ករណីពិសេសនៃការបន្ថែមបណ្ដឹង ឬ បណ្ដឹងតប ។

២. ល័ក្ខខ័ណ្ឌនៃបណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី

(១) ទាល់តែបណ្ដឹងកំពុងត្រូវបានចាត់ការក្នុងការជំនុំជម្រះលើអង្គហេតុ ហើយស្ថិតនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

(២) ទាល់តែទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាមូលដ្ឋាននៃការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង (មាត្រា ៨៥ កថាខណ្ឌទី ១)

(៣) ការទាមទារឱ្យបញ្ជាក់ មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការដទៃទៀត (មាត្រា ៨៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)

៣. វិធីដាក់ពាក្យបណ្ដឹង និង នីតិវិធីបណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី

បណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ហើយក្រឡាបញ្ជី ត្រូវធ្វើការបញ្ជូនលិខិតនោះទៅឱ្យភាគីម្ខាងទៀត (តាមការអនុវត្តដូចគ្នានូវបញ្ញត្តិនៃមាត្រា ៨៤ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ ដោយយោងតាមមាត្រា ៨៥ កថាខណ្ឌទី ២) ។ ក្រៅពីនេះ សូមមើលការពន្យល់ខាងលើ អំពីការបន្ថែម ឬ ការផ្លាស់ប្ដូរបណ្ដឹង និង បណ្ដឹងតប ។

## ផ្នែកទី ២ ភាពមានប្រធានច្រើននាក់ក្នុងបណ្ដឹង

### កថាភាគទី ១ សហបណ្ដឹង

១. អត្ថន័យនៃសហបណ្ដឹង

សហបណ្ដឹង គឺជាបណ្ដឹងដែលមានដើមចោទច្រើននាក់ ឬ មានចុងចម្លើយច្រើននាក់ ។ ក្នុងសហបណ្ដឹង ភាគីដែលនៅខាងដូចគ្នា គេហៅថា អ្នកធ្វើសហបណ្ដឹង ហើយប្រសិនបើអ្នកធ្វើសហបណ្ដឹងជាដើមចោទ គេហៅថា សហដើមចោទ ហើយប្រសិនបើអ្នកធ្វើសហបណ្ដឹងជាចុងចម្លើយ គេហៅថា សហចុងចម្លើយ ។ តាមរយៈការវិនិច្ឆ័យ និង ចេញសាលក្រមរួម ដោយនីតិវិធីបណ្ដឹងតែមួយ ស្ដីពីការទាមទារដោយដើមចោទច្រើននាក់ ឬ ស្ដីពី

ការទាមទារចំពោះចុងចម្លើយច្រើននាក់ សហបណ្តឹងមានផលប្រយោជន៍ក្នុងការសន្សំកម្លាំង និង សន្សំចំណាយរបស់ភាគី និង របស់តុលាការ ហើយអាចការពារកុំឱ្យមានភាពមិនស៊ីគ្នា និង ប៉ះទង្គិចគ្នានៃសាលក្រម ។

២. ប្រភេទនៃសហបណ្តឹង

(១) សហបណ្តឹងធម្មតា

(ក) អត្ថន័យនៃសហបណ្តឹងធម្មតា

សហបណ្តឹងធម្មតា គឺជាសហបណ្តឹងប្រភេទមួយ ក្នុងចំណោមសហបណ្តឹង ដែលមានការទាមទារផ្សេងៗគ្នារវាងអ្នកធ្វើសហបណ្តឹងម្នាក់ៗ និង ភាគីម្ខាងទៀត ហើយដែលអាចចេញសាលក្រមដាច់ដោយឡែកពីគ្នាចំពោះការទាមទារនីមួយៗ ហើយមិនចាំបាច់កំណត់ឱ្យចាញ់ ឬ ឱ្យឈ្នះចំពោះការទាមទារទាំងអស់ ដោយមានលទ្ធផលតែមួយទេ ។ សហបណ្តឹងធម្មតាគឺជាប្រភេទនៃសហបណ្តឹងមួយដែលមានភាពខុសគ្នានឹងសហបណ្តឹងចាំបាច់ ។ សហបណ្តឹងធម្មតាគឺជាការរួមបញ្ចូលក្នុងបណ្តឹងតែមួយ នូវការទាមទារច្រើនរវាងភាគីច្រើននាក់ដែលអាចប្តឹងបាន ឬ អាចត្រូវបានប្តឹងផ្សេងៗគ្នា ។ ឧទាហរណ៍ មានដូចជាបណ្តឹងដែលម្ចាស់ហាងធ្វើឡើងដោយយកអ្នកទិញទំនិញមកជាចុងចម្លើយ ដើម្បីទាមទារឱ្យអ្នកទិញទំនិញច្រើននាក់នោះ បង់ថ្លៃលក់ទំនិញដែលអ្នកទិញទំនិញនីមួយៗបានទិញ ក្នុងបណ្តឹងតែមួយ ឬ បណ្តឹងដែលទាមទារនូវសំណងនៃការខូចខាតដែលមានជនរងគ្រោះច្រើននាក់ ជាដើមចោទ ហើយចារី ជាចុងចម្លើយ ជាដើម ។

(ខ) ការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះសហបណ្តឹងធម្មតា

ក្នុងសហបណ្តឹងធម្មតា សកម្មភាពបណ្តឹងដែលធ្វើដោយបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ដូចជាការអះអាងអង្គហេតុ ការសារភាពតាមផ្លូវបណ្តឹង ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ ការសះជាតាមផ្លូវបណ្តឹង ការដកពាក្យបណ្តឹង ជាដើម មិនមានឥទ្ធិពលចំពោះអ្នកធ្វើសហបណ្តឹងដទៃទេ ។ សកម្មភាពបណ្តឹងរបស់ភាគីម្ខាងទៀត ចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ក៏ដូចគ្នាដែរ (មាត្រា ៤០) ។ ម្យ៉ាងទៀត ហេតុនៃការផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង (មាត្រា ១៧៣, មាត្រា ១៧៧) ដែលកើតមានឡើងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង គ្រាន់តែផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង ក្នុងទំនាក់ទំនងរវាងអ្នកធ្វើសហបណ្តឹងនោះ និង ភាគីម្ខាងទៀតប៉ុណ្ណោះ ហើយពុំមានឥទ្ធិពលទៅលើអ្នកធ្វើសហបណ្តឹងដទៃទៀតទេ ។ តុលាការ អាចបំបែកនូវការទាមទារពាក់ព័ន្ធនឹងអ្នកធ្វើសហបណ្តឹងមួយចំនួន ទៅជាបណ្តឹងមួយផ្សេងទៀត ដោយដីកាសម្រេចបាន (មាត្រា ៩៩) ។ ប៉ុន្តែ ប្រសិនបើនីតិវិធីមានដំណើរការជាសហបណ្តឹង ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការពិនិត្យភស្តុតាង ត្រូវធ្វើពេលជាមួយគ្នាក្នុងកាលបរិច្ឆេទរួម ។ ដូច្នេះ ស្តីពីចំណុចវិវាទរួមរវាងអ្នកធ្វើសហបណ្តឹងនីមួយៗ និង ភាគីម្ខាងទៀត ជំនឿទុកចិត្តរបស់តុលាការនឹងមានឯកភាព ។

តុលាការត្រូវធ្វើការទទួលស្គាល់អង្គហេតុ ដោយផ្អែកលើជំនឿទុកចិត្តដែលត្រូវបានធ្វើឡើងដោយមាន

ឯកភាពនេះ ហើយចេញសាលក្រមចំពោះការទាមទារនីមួយៗ ហេតុនេះហើយ តាមធម្មតា ក្នុងករណីដែលការទាមទាររបស់អ្នកធ្វើសហបណ្តឹងនីមួយៗ ឬ ការទាមទារចំពោះអ្នកធ្វើសហបណ្តឹងនីមួយៗ មានការពាក់ព័ន្ធគ្នាទៅវិញទៅមក គ្មានករណីដែលសាលក្រមមានខ្លឹមសារដែលមានភាពផ្ទុយគ្នា ឬ ប៉ះពាល់គ្នាទេ ។ ក៏ប៉ុន្តែប្រសិនបើបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង បានសារភាពតាមផ្លូវបណ្តឹង ឬ ព្រងើយកន្តើយក្នុងការអះអាងអង្គហេតុ ខ្លឹមសារនៃសាលក្រមអាចមានផ្សេងៗពីគ្នាបាន ។ ម្យ៉ាងទៀត ទោះជាក្នុងករណីដែលតុលាការបានវិនិច្ឆ័យដោយសាលក្រមតែមួយព្រមគ្នា ចំពោះការទាមទារដែលទាក់ទងនឹងអ្នកធ្វើសហបណ្តឹងនីមួយៗក៏ដោយ ដោយសារតែអានុភាពនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មានភាពខុសគ្នាសម្រាប់អ្នកធ្វើសហបណ្តឹងម្នាក់ៗ ពេលដែលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ក៏ផ្សេងគ្នាដែរ ។

ដូច្នេះ ក្នុងសហបណ្តឹងធម្មតា ឋានៈរបស់អ្នកធ្វើសហបណ្តឹងមានឯករាជ្យគ្នាទៅវិញទៅមក ហើយគេអាចហៅបានថា គោលការណ៍ឯករាជ្យភាពនៃអ្នកធ្វើសហបណ្តឹង ។

(២) សហបណ្តឹងចាំបាច់

(ក) សហបណ្តឹងចាំបាច់ពីរប្រភេទ

ក្នុងចំណោមសហបណ្តឹង សហបណ្តឹងចាំបាច់ គឺជាសហបណ្តឹងដែលសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង ត្រូវបានសម្រេចជាស្ថាពររួមគ្នាដោយមានឯកភាពចំពោះអ្នកធ្វើសហបណ្តឹងទាំងអស់ (មាត្រា ៤១) ។ ឈ្មោះសហបណ្តឹងចាំបាច់ គឺឃើញដូចជា សំដៅទៅលើករណីដែលបុគ្គលច្រើនរូបចាំបាច់ដាក់ពាក្យបណ្តឹងដោយរួមគ្នាក្នុងនាមជាដើមចោទ ឬ ករណីដែលចាំបាច់ដាក់ពាក្យបណ្តឹងដោយយកបុគ្គលច្រើនរូបមកជាចុងចម្លើយ មានន័យថា មានតែបណ្តឹងដែលចាំបាច់ត្រូវដាក់ជាសហបណ្តឹងប៉ុណ្ណោះ ក៏ប៉ុន្តែ ក្រៅពីនេះ មាត្រា ៤១ ត្រូវអនុវត្តចំពោះករណីដែលដើមចោទ អាចដាក់ពាក្យបណ្តឹងតែឯង ឬ អាចយកចុងចម្លើយតែឯងបានដែរ តែប្រសិនបើក្លាយទៅជាសហបណ្តឹង ត្រូវសម្រេចជាស្ថាពរនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង ។ ហេតុនេះហើយ ប្រសិនបើដាក់ឈ្មោះសហបណ្តឹងចាំបាច់ ចំពោះករណីដែលត្រូវអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤១ ទៅ សហបណ្តឹងចាំបាច់នេះ អាចបែងចែកជា ២ ប្រភេទ ។

① ប្រភេទទី ១ គឺជាសហបណ្តឹងចាំបាច់ដែលមានតែបុគ្គលច្រើនរូបរួមគ្នាទេដែលអាចប្តឹង ឬ អាចត្រូវបានគេប្តឹង ហើយប្រសិនបើបុគ្គលនីមួយៗប្តឹង ឬ ត្រូវបានប្តឹងដោយឯកឯងវិញ បណ្តឹងនោះនឹងខ្វះលក្ខណសម្បត្តិជាភាគី ហើយត្រូវច្រានចោលដោយសារតែមិនស្របច្បាប់ ។ ឧទាហរណ៍ បណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលធ្វើឡើងដោយតតិយជន អំពីទំនាក់ទំនងឋានៈបុគ្គលរវាងអ្នកដទៃ ដូចជាបណ្តឹងទាមទារឱ្យបញ្ជាក់មោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយតតិយជនជាដើម ត្រូវយកភាគីទាំងអស់នៃទំនាក់ទំនងឋានៈបុគ្គលនោះ ជាចុងចម្លើយ (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា ៦ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត បណ្តឹងទាមទារឱ្យបែងចែក

វត្ថុកម្មសិទ្ធិអវិភាគ ដែលធ្វើឡើងដោយម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ (ក្រមរដ្ឋប្បវេណី មាត្រា ២១២) ត្រូវធ្វើឡើងចំពោះម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀតទាំងអស់ ។ នេះគឺ ប្រសិនបើធ្វើការកំណត់នូវជាស្ថាពរនូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹងនោះ ឱ្យភាពខុសគ្នាចំពោះភាគីនីមួយៗទៅតាមលក្ខណៈនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះ អាចធ្វើឱ្យមានការជ្រួលច្របល់ដែលជាការពិបាកខ្លាំងដល់ជីវភាពក្នុងសង្គម ។ ហេតុដូច្នេះ ប្រភេទនៃសហបណ្តឹងចាំបាច់ដើមនេះ អាចហៅថា សហបណ្តឹងចាំបាច់ដោយពិត (Materiellrechtlich notwendige Streitgenossenshaft, Notwendige Streitgenossenshaft im eigehtlichen Sinne) ក្នុងន័យថា មានភាពចាំបាច់ធ្វើជាសហបណ្តឹង តាមលក្ខណៈដើមនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ។

② ប្រភេទមួយទៀត គឺជាសហបណ្តឹងចាំបាច់ដែលក្នុងចំណោមបុគ្គលច្រើននាក់ ម្នាក់ៗអាចធ្វើបណ្តឹងដាច់ដោយឡែកពីគ្នាបាន ក៏ប៉ុន្តែ ពេលដែលបណ្តឹងត្រូវបានដាក់ជាសហបណ្តឹង មានការចាំបាច់ត្រូវចេញសាលក្រមជារួម ចំពោះសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃការទាមទារ ។ ទោះបីជាភាគីម្ខាងធ្វើបណ្តឹងដោយឯកឯងក៏ដោយ ក៏មានករណីខ្លះដែលបញ្ញត្តិច្បាប់កំណត់ថា អានុភាពនៃសាលក្រមមានទៅលើតតិយជន និង ភាគីម្ខាងទៀតដែរ ។ ក្នុងករណីនេះ ប្រសិនបើតតិយជនដែលត្រូវទទួលអានុភាពនៃសាលក្រមនោះ ក្លាយទៅជាអ្នកធ្វើសហបណ្តឹង សហបណ្តឹងនោះគឺជាសហបណ្តឹងចាំបាច់ ។ ឧទាហរណ៍នៃករណីនេះ មានដូចជា បណ្តឹងទាមទារឱ្យលុបចោលនូវសេចក្តីសម្រេចរបស់មហាសន្និបាតរបស់ម្ចាស់ហ៊ុន ដែលត្រូវបានដាក់ពាក្យបណ្តឹងដោយម្ចាស់ហ៊ុនច្រើននាក់ ឬ បណ្តឹងទាមទារឱ្យបញ្ជាក់នូវមោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដែលត្រូវបានដាក់ពាក្យបណ្តឹងដោយញាតិច្រើននាក់ (សេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា ១៦ កថាខណ្ឌទី ១) ។ ម្ចាស់ហ៊ុនតែម្នាក់ក៏ដោយ ក៏អាចដាក់ពាក្យបណ្តឹងទាមទារឱ្យលុបចោលនូវសេចក្តីសម្រេចរបស់មហាសន្និបាតនៃម្ចាស់ហ៊ុនតែម្នាក់ឯងបានដែរ ឬ ញាតិក៏អាចដាក់ពាក្យបណ្តឹងទាមទារឱ្យបញ្ជាក់នូវមោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ឱ្យលុបចោលនូវអាពាហ៍ពិពាហ៍តែឯងក៏បានដែរ ប្រសិនបើយកប្តីប្រពន្ធនោះមកធ្វើជាសហចុងចម្លើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលម្ចាស់ហ៊ុនច្រើននាក់ ឬ ញាតិច្រើននាក់បានដាក់ពាក្យបណ្តឹង ដោយតាំងខ្លួនជាសហដើមចោទ តុលាការត្រូវចេញសាលក្រមជារួមចំពោះម្ចាស់ហ៊ុន ឬ ញាតិច្រើននាក់នោះ ។ ប្រសិនបើចេញសាលក្រមផ្សេងៗគ្នាដោយគ្មានឯកភាព ចំពោះម្ចាស់ហ៊ុននីមួយៗ ឬ ចំពោះញាតិនីមួយៗ ដើមចោទម្នាក់ៗនឹងទទួលនូវអានុភាពនៃសាលក្រម មិនត្រូវគ្នានឹងអានុភាពនៃសាលក្រមដែលត្រូវបានទទួលដោយដើមចោទដទៃទៀត ដូច្នេះហើយ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង នឹងមិនអាចកំណត់ជាស្ថាពរបានឡើយ ។ ប្រភេទសហបណ្តឹងចាំបាច់នេះ អាចហៅបានថា ឧបសហបណ្តឹងចាំបាច់ (សហបណ្តឹងចាំបាច់ដោយប្រភេទដូចគ្នា Prozeßlrechtlich notwendige Streitgenossenshaft, Besondere Streitgenossenshaft) ។

(ខ) ការវិនិច្ឆ័យសហបណ្តឹងចាំបាច់

ក្នុងសហបណ្តឹងចាំបាច់ តុលាការត្រូវចេញសាលក្រមជារួមចំពោះអ្នកធ្វើសហបណ្តឹងទាំងអស់ ហេតុដូច្នេះ មានសេចក្តីតម្រូវការតាមច្បាប់ឱ្យមានឯកភាពស្តីពីធនធានមូលដ្ឋាននៃសាលក្រម និង ស្តីពីដំណើរការបណ្តឹង ។ ដូច្នេះ សកម្មភាពដែលបានធ្វើដោយបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ហើយដែលមានផលប្រយោជន៍ដល់ភាគីអ្នកធ្វើសហបណ្តឹង (សេចក្តីថ្លែងការណ៍មិនទទួលស្គាល់អង្គហេតុណាមួយ ឬ ការអះអាងអង្គហេតុតវ៉ា ជាដើម) ត្រូវមានអានុភាពចំពោះអ្នកធ្វើសហបណ្តឹងទាំអស់ ដូចសកម្មភាពដែលបុគ្គលទាំងអស់គ្នាបានធ្វើដែរ ផ្ទុយទៅវិញ សកម្មភាពដែលធ្វើឱ្យខាតផលប្រយោជន៍ដល់ភាគីអ្នកធ្វើសហបណ្តឹង (ការសារភាពតាមផ្លូវតុលាការ ការលះបង់ ឬ ការទទួលស្គាល់នូវការទាមទារ ជាដើម) នឹងពុំមានអានុភាពឡើយ ប្រសិនបើបុគ្គលទាំងអស់នោះមិនបានធ្វើសកម្មភាពនោះដោយរួមគ្នាទេ (មាត្រា ៤១ កថាខណ្ឌទី ១) ។ សកម្មភាពដែលបានធ្វើដោយបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង ក៏មិនមានអានុភាពចំពោះបុគ្គលនោះដែរ ។ ផ្ទុយទៅវិញ សកម្មភាពបណ្តឹងដែលធ្វើដោយភាគីម្ខាងទៀត ទោះជាមានផលប្រយោជន៍ ឬ ធ្វើឱ្យខូចផលប្រយោជន៍ក៏ដោយ ប្រសិនបើបានធ្វើចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង អានុភាពនៃសកម្មភាពនោះនឹងកើតឡើងចំពោះអ្នកធ្វើបណ្តឹងទាំងអស់គ្នា (មាត្រា ៤១ កថាខណ្ឌទី ២) ។ម្យ៉ាងទៀត ក្នុងករណីដែលហេតុដែលនាំឱ្យផ្អាក ឬ បង្អង់នីតិវិធីនៃបណ្តឹង បានកើតឡើងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹង នីតិវិធីបណ្តឹងនោះ ត្រូវផ្អាក ឬ ត្រូវបង្អង់ ចំពោះបុគ្គលទាំងអស់ (មាត្រា ៤១ កថាខណ្ឌទី ៣) ។

៣. ករណីដែលមានសហបណ្តឹង

(១) ការរួមបញ្ចូលនូវប្រធាននៃបណ្តឹង

(ក) តាមធម្មតា សហបណ្តឹងកើតមានឡើង ក្នុងករណីដែលពាក្យបណ្តឹងរួមតែមួយត្រូវបានដាក់ ដោយដើមចោទច្រើននាក់ ឬ ដោយយកបុគ្គលច្រើននាក់មកធ្វើជាចុងចម្លើយ តាំងពីដំបូង ។ ករណីនេះ ត្រូវហៅថា ការរួមបញ្ចូលប្រធាននៃបណ្តឹង ។

(ខ) ដើម្បីឱ្យអនុញ្ញាតឱ្យរួមបញ្ចូលប្រធាននៃបណ្តឹង ចាំបាច់ត្រូវមានភាពស្របនឹងករណីណាមួយ ខាងក្រោមនេះ (មាត្រា ៣៩) :

① ករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង ដូចគ្នា ចំពោះអ្នកធ្វើសហបណ្តឹង (មាត្រា ៣៩ ចំណុច ក)

ឧទាហរណ៍មានដូចជា ការទាមទារដោយម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុមួយ ឬ ការទាមទារចំពោះម្ចាស់កម្មសិទ្ធិអវិភាគ ការទាមទារឱ្យអនុវត្តកាតព្វកិច្ចចំពោះកូនបំណុលនៃតព្វកិច្ចដោយសាមគ្គីភាពច្រើននាក់ ការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិលើវត្ថុតែមួយចំពោះបុគ្គលច្រើននាក់ ជាដើម ។

② ករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង ផ្អែកលើមូលហេតុដូចគ្នា លើអង្គហេតុ និង អង្គច្បាប់ (មាត្រា ៣៩ ចំណុច ខ)

ឧទាហរណ៍ចម្បង គឺជាការទាមទារឱ្យសងសំណងនៃការខូចខាតដោយជនរងគ្រោះច្រើននាក់ ចំពោះចារី ដោយផ្អែកលើគ្រោះថ្នាក់តែមួយ ហើយក្រៅពីនេះ មានឧទាហរណ៍ដូចជា ការរួមបញ្ចូលនូវការទាមទារឱ្យប្រគល់វត្ថុដែលជាកម្មសិទ្ធិមកវិញ ចំពោះបុគ្គលម្នាក់ និង ការទាមទារឱ្យសងសំណងនៃការខូចខាត ដោយផ្អែកលើការបំពានកម្មសិទ្ធិចំពោះអ្នកដទៃ ជាដើម ។

③ ករណីដែលសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង មានប្រភេទដូចគ្នា ហើយផ្អែកលើមូលហេតុដែលមានប្រភេទដូចគ្នា លើអង្គហេតុ និង អង្គច្បាប់ (មាត្រា ៣៩ ចំណុច គ)

ករណីនេះ ខុសពីករណី② គឺឱ្យតែមូលហេតុប្រភេទដូចគ្នាលើអង្គហេតុ និង លើអង្គច្បាប់ ជាការគ្រប់គ្រាន់ ។

ឧទាហរណ៍ ការទាមទារឱ្យបង់ថ្លៃឈ្នួលផ្ទះដែលមានការយឺតយ៉ាវក្នុងការបង់ ដែលធ្វើដោយភតិបតីនៃអាគារប៊ុលឌិញមួយខ្នង ចំពោះភតិកៈច្រើននាក់ ឬ ការទាមទារឱ្យបង់ថ្លៃលក់ទិញ ដោយអ្នកលក់ទំនិញប្រភេទដូចគ្នា ចំពោះអ្នកទិញច្រើននាក់ដែលទិញទំនិញនោះ ជាដើម ។

ការរួមបញ្ចូលនូវប្រធាននៃបណ្តឹង មានការរួមបញ្ចូលនូវការទាមទារដែរ ហេតុនេះហើយ នៅពេលដែលដាក់ពាក្យបណ្តឹងជាក់ស្តែងនៃការរួមបញ្ចូលប្រធាន ចាំបាច់ត្រូវស្របនឹងល័ក្ខខ័ណ្ឌនៃការរួមបញ្ចូលនូវកម្មវត្ថុនៃបណ្តឹងថែមទៀត (មាត្រា ៧៧) ។

(២) បណ្តឹងដែលយកដើមចោទ និង ចុងចម្លើយមកធ្វើជាសហចុងចម្លើយ

(ក) ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥១ កថាខណ្ឌទី ១ មានចែងថា "តតិយជនដែលអះអាងថា ចំពោះសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងរវាងភាគីដទៃ សិទ្ធិទាំងមូល ឬ មួយភាគជាសិទ្ធិរបស់ខ្លួន អាចដាក់ពាក្យបណ្តឹងចំពោះភាគីទាំងសងខាងនៃបណ្តឹងខាងលើនោះ ជាសហចុងចម្លើយ ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ដែលបានទទួលពាក្យបណ្តឹងរវាងភាគីដទៃនោះ នៅពេលបណ្តឹងនោះកំពុងនៅក្រោមការចាត់ការរបស់តុលាការណាមួយ" ។ ក្នុងបញ្ញត្តិនេះ មានចែងអំពីករណីពិសេសនៃការរួមបញ្ចូលនូវប្រធាននៃបណ្តឹង ហើយតាមរយៈការរួមបញ្ចូលនេះ សហបណ្តឹងត្រូវបានកើតឡើង ។ បណ្តឹងនេះត្រូវបានធ្វើឡើងដោយតតិយជន ចំពោះដើមចោទ និង ចុងចម្លើយ ដែលជាភាគីនៃបណ្តឹងដែលកំពុងត្រូវបានចាត់ការ ដោយអះអាងថា សិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងដែលកំពុងត្រូវបានចាត់ការនោះ ជាសិទ្ធិរបស់ខ្លួន ហេតុនេះហើយ ករណីនេះស្របនឹងល័ក្ខខ័ណ្ឌទូទៅនៃការរួមបញ្ចូលនូវប្រធានដោយស្វ័យប្រវត្តិ (មាត្រា ៣៩ កថាខណ្ឌទី ១) ដូច្នេះ ទោះបីជាគ្មានបញ្ញត្តិនៃមាត្រា ៥១ កថាខណ្ឌទី ១ ក៏ដោយ ក៏អាចអនុញ្ញាតឱ្យរួមបញ្ចូលនូវប្រធាននៃបណ្តឹងបែបនេះបានដែរ ។ មាត្រា ៥១ កថាខណ្ឌទី ១ មានន័យសំខាន់ត្រង់ចំណុចដែលកំណត់ពិសេសនូវតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងប្រភេទនេះ ដោយឱ្យអាចដាក់ពាក្យបណ្តឹងទៅតុលាការនៃការជំនុំជម្រះលើកទី ១ ដែលទទួលពាក្យបណ្តឹងរវាងភាគីដទៃនោះ ។ សមត្ថកិច្ចពិសេសនេះ អាចត្រូវបានទទួលស្គាល់ លុះត្រាតែបណ្តឹងរវាងភាគីដទៃកំពុងត្រូវបានចាត់ការ ទោះបីត្រូវបានចាត់ការក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ក៏ដោយ ឬ ក្នុងការជំនុំជម្រះ

បណ្ដឹងសាទុក្ខក៏ដោយ ។

(ខ) ករណីដែលអះអាងថា សិទ្ធិទាំងមូល ឬ មួយភាគនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្ដឹងរវាងអ្នកដទៃ ជាសិទ្ធិរបស់ខ្លួន គឺមានដូចជា ករណីដែលមានបណ្ដឹងរបស់ A ទាមទារឱ្យបញ្ជាក់កម្មសិទ្ធិនៃអចលនវត្ថុមួយ ចំពោះ B ហើយបន្ទាប់មក C អះអាងថា ខ្លួនជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុនោះ ឬ ករណីដែលមានបណ្ដឹងរបស់ A ទាមទារចំពោះ B ឱ្យសងប្រាក់កំចី ហើយបន្ទាប់មក C អះអាងថា ខ្លួនមានសិទ្ធិទាមទារឱ្យសងប្រាក់កំចីនោះជាដើម ។ ករណីទាំងនេះ គឺជាករណីដែលមានវិវាទរវាងបុគ្គលបីនាក់ ស្ដីពីសិទ្ធិមួយ ហេតុនេះហើយ ដើម្បីកំណត់ទំនាក់ទំនងគតិយុត្តរវាងអ្នកទាំងបីនោះដោយកុំឱ្យមានភាពមិនរលូន គួរតែវិនិច្ឆ័យ និង ចេញសាលក្រមដោយរួមបញ្ចូលបណ្ដឹងរវាង A និង B និង បណ្ដឹងរបស់ C ចំពោះ A និង B ជាមួយគ្នា ។ ដូច្នេះ មាត្រា ៥១ កថាខណ្ឌទី ២ មានចែងថា ប្រសិនបើបណ្ដឹងរវាងភាគីដទៃនោះ កំពុងត្រូវបានចាត់ការ នៅក្នុងការជំនុំជម្រះលើកទី ១ តុលាការដែលទទួលពាក្យបណ្ដឹងពីតតិយជននោះ អាចបញ្ចូលបណ្ដឹងទាំងពីរ ជាមួយគ្នាបាន (មាត្រា ៩៩ កថាខណ្ឌទី ១) ។ អត្ថន័យនៃការទទួលស្គាល់នូវសមត្ថកិច្ចពិសេសនេះ មានសារៈប្រយោជន៍ជាពិសេស ក្នុងករណីដែលអាចរួមបញ្ចូលដូចនេះ ។

(៣) ករណីដទៃទៀត

ក្រៅពីនេះ សហបណ្ដឹងក៏អាចកើតមានឡើងដែរ ក្នុងករណីដែលមានការទទួលស្គាល់ការចូលរួមអន្តរាគមន៍ក្នុងសហបណ្ដឹង (មាត្រា ៤៩) ឬ ករណីនៃការរួមបញ្ចូលរឿងក្ដីដែលមានភាគីផ្សេងគ្នា (មាត្រា ៩៩) ជាដើមផងដែរ ។

## កថាភាគទី ២ ការជ្រើសរើសភាគី

### ១. អត្ថន័យនៃការជ្រើសរើសភាគី

ការជ្រើសរើសភាគី គឺជារបបជ្រើសរើសបុគ្គលតែម្នាក់ ឬ មួយចំនួន ជាភាគី ពីក្នុងចំណោមបុគ្គលច្រើននាក់ ដើម្បីឱ្យបុគ្គលនោះធ្វើសកម្មភាពបណ្ដឹងសម្រាប់បុគ្គលទាំងអស់ ក្នុងករណីដែលបុគ្គលច្រើននាក់នោះមានផលប្រយោជន៍រួម ហើយត្រូវប្ដឹង ឬ ត្រូវឱ្យគេប្ដឹងរួមជាមួយគ្នា (មាត្រា ៤២) ។ តាមរយៈរបបនេះ ឧទាហរណ៍ ចំពោះករណីដែលមានអ្នកបរិភោគ ១០០ នាក់ បានទិញទំនិញមួយដោយតម្លៃថ្លៃហួសហេតុ ដោយមានកិច្ចព្រមព្រៀងអំពីតម្លៃខុសច្បាប់មួយ គេអាចជ្រើសរើសបុគ្គលចំនួនតែ ៥ នាក់ ក្នុងចំណោមអ្នកបរិភោគទាំងនោះ ឱ្យធ្វើជាសហដើមចោទ និង ដាក់ពាក្យបណ្ដឹងចំពោះក្រុមហ៊ុនលក់ទំនិញនោះ ដោយអះអាងសិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត សម្រាប់អ្នកបរិភោគ ១០០ នាក់បាន ។ ចំពោះករណីដែលមានជនរងគ្រោះច្រើននាក់ដោយសារគ្រោះថ្នាក់យន្តហោះមួយ ក៏ដូចគ្នាដែរ ។ ក្នុងករណីនេះ បុគ្គលដែលត្រូវបានជ្រើសរើសជាភាគីសម្រាប់ធ្វើបណ្ដឹង ត្រូវហៅថា ភាគីដែលត្រូវបានជ្រើសរើស រីឯបុគ្គលដែលបានជ្រើសរើស

ភាគី ដើម្បីឱ្យភាគីនោះធ្វើបណ្តឹងអំពីសិទ្ធិរបស់ខ្លួន ត្រូវហៅថា អ្នកជ្រើសរើស ។ តាមរយៈរបបនេះ បណ្តឹងនឹងត្រូវបានសម្រួល ហើយម្យ៉ាងទៀត អ្នកជ្រើសរើសអាចរួចផុតពីបន្ទុកធ្វើបណ្តឹង ។

បណ្តឹងដែលធ្វើដោយភាគីដែលត្រូវបានជ្រើសរើស គឺជាប្រភេទមួយនៃការទទួលបន្ទុកក្នុងការធ្វើបណ្តឹងដោយតតិយជន ហើយការទទួលបន្ទុកក្នុងការធ្វើបណ្តឹងដោយអាណត្តិ ។ អានុភាពនៃសាលក្រមដែលភាគីដែលត្រូវបានជ្រើសរើសបានទទួល ក៏មានចំពោះអ្នកជ្រើសរើសដែរ (មាត្រា ១៩៨ ចំណុច ខ) ។ ម្យ៉ាងទៀត ក្នុងករណីដែលភាគីដែលត្រូវបានជ្រើសរើសមានចំនួនច្រើននាក់ ហើយត្រូវបានជ្រើសរើសពីក្នុងចំណោមអ្នកដែលមានសិទ្ធិដែលមានទំហំស្មើគ្នា សហបណ្តឹងនេះត្រូវក្លាយទៅជាសហបណ្តឹងចាំបាច់ដោយពិត (Materiell-rechtlich notwendige Streitgenossenshaft, Notwendige Streitgenossenshaft im eigehtlichen Sinne) ។

## ២. ល័ក្ខខ័ណ្ឌនៃការជ្រើសរើស

ករណីដែលអាចអនុញ្ញាតឱ្យជ្រើសរើសភាគីបាន គឺជាករណីដែលបុគ្គលច្រើននាក់ដែលមានផលប្រយោជន៍រួមត្រូវក្លាយជាដើមចោទទាំងអស់គ្នា ឬ ចុងចម្លើយទាំងអស់គ្នា (មាត្រា ៤២ កថាខណ្ឌទី ១) ។ ផលប្រយោជន៍រួម គឺជាករណីដែលការទាមទាររបស់បុគ្គលច្រើននាក់ ឬ ការទាមទាររបស់ភាគីម្ខាងទៀតចំពោះបុគ្គលច្រើននាក់ ផ្អែកលើមូលហេតុដូចគ្នាលើអង្គហេតុ និង អង្គច្បាប់ (មាត្រា ៣៩ ចំណុច ខ) ហើយអង្គហេតុដែលជាមូលហេតុនោះ ជាចំណុចវិវាទសំខាន់សម្រាប់វិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារ ។

ការជ្រើសរើស អាចធ្វើបានមុនពេលចាប់ផ្តើមបណ្តឹងក៏បាន ឬ ក្រោយពេលចាប់ផ្តើមធ្វើបណ្តឹងក៏បាន ។ ក្នុងករណីដែលបណ្តឹងបានចាប់ផ្តើម ហើយបានធ្វើការជ្រើសរើសពេលបណ្តឹងនោះកំពុងត្រូវបានចាត់ការ ភាគីដែលបានធ្វើការជ្រើសរើសនោះ ត្រូវដកខ្លួនចេញពីបណ្តឹងដោយស្វ័យប្រវត្តិ (មាត្រា ៤២ កថាខណ្ឌទី ២) ។

## ៣. សកម្មភាពជ្រើសរើស

ការជ្រើសរើស គឺជាសកម្មភាពបណ្តឹងឯករាជ្យរបស់អ្នកជ្រើសរើសម្នាក់ៗ ហើយមិនអាចធ្វើការជ្រើសរើសដោយយកមតិភាគច្រើនបានទេ ។ ម្យ៉ាងទៀត អ្នកជ្រើសរើសម្នាក់ៗមិនចាំបាច់ជ្រើសរើសបុគ្គលដូចគ្នាទេ គឺឧទាហរណ៍ ក្នុងចំណោមអ្នកដែលមានផលប្រយោជន៍រួមច្រើននាក់ បុគ្គលមួយចំនួននោះ អាចជ្រើសរើស A ហើយបុគ្គលផ្សេងទៀត អាចជ្រើសរើស B ក៏បានដែរ ។ ក្នុងករណីនេះ A និង B ជាអ្នកទទួលបន្ទុកបណ្តឹងសម្រាប់អ្នកជ្រើសរើសរបស់ខ្លួននីមួយៗ ។ សកម្មភាពជ្រើសរើសនេះ អាចលុបចោល ឬ អាចផ្លាស់ប្តូរ (លុបចោលនូវការជ្រើសរើសមុន ហើយធ្វើការជ្រើសរើសបុគ្គលផ្សេង) នៅពេលណាក៏បានដែរ (មាត្រា ៤២ កថាខណ្ឌទី ៣) ។

ពេលដែលបណ្តឹងកំពុងតែត្រូវបានចាត់ការ ក្នុងករណីដែលភាគីដែលត្រូវបានជ្រើសរើសមួយចំនួន បានទទួលមរណភាព ឬ បាត់បង់នូវលក្ខណសម្បត្តិជាអ្នកដែលត្រូវបានជ្រើសរើស ដោយការលុបចោលសកម្មភាពជ្រើសរើស ភាគីដែលត្រូវបានជ្រើសរើសដែលនៅសល់ នឹងធ្វើសកម្មភាពបណ្តឹងសម្រាប់អ្នកជ្រើសរើសទាំងអស់

(មាត្រា ៤២ កថាខណ្ឌទី ៤) ។ ប្រសិនបើភាគីដែលត្រូវបានជ្រើសរើសទាំងអស់ បានបាត់បង់នូវលក្ខណសម្បត្តិ នីតិវិធីបណ្តឹងត្រូវផ្អាក ហើយអ្នកជ្រើសរើសទាំងអស់ ឬ អ្នកដែលត្រូវបានជ្រើសរើសថ្មី ត្រូវទទួលបណ្តឹងបន្តទៀត (មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច ង. កថាខណ្ឌទី ២ ចំណុច ង) ។

## កថាភាគទី ៣ ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង

### ១. អត្ថន័យ និង ប្រភេទនៃការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង

ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង គឺជាការចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលត្រូវបានចាត់ការរវាងអ្នកដទៃ ដោយតតិយជននៅក្រៅបណ្តឹងនោះ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន នៅពេលដែលខ្លួនមានទំនាក់ទំនងនៃផលប្រយោជន៍នឹងលទ្ធផលនៃបណ្តឹងនោះ ។ ការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ដែលក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាត មាន (១) "ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង" ដែលតតិយជនចូលរួមអន្តរាគមន៍ ក្នុងនាមជាអ្នកធ្វើសហបណ្តឹង ជាមួយដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងដែលកំពុងត្រូវបានចាត់ការ (មាត្រា ៤៩) (២) "ការចូលរួមជួយអន្តរាគមន៍" ដើម្បីជួយឱ្យភាគីណាម្ខាងអាចឈ្នះបណ្តឹង (មាត្រា ៤៣) និង (៣) "ការចូលរួមអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង" ដែលជាករណីពិសេសនៃការចូលរួមជួយអន្តរាគមន៍ (មាត្រា ៤៨) ។

### ២. ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង

#### (១) អត្ថន័យនៃការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង

ដូចដែលបានពន្យល់ខាងឡើនេះហើយ ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង គឺជាការចូលរួមអន្តរាគមន៍ដោយតតិយជន ក្នុងនាមជាសហដើមចោទ ឬ ជាសហចុងចម្លើយ ក្នុងបណ្តឹងរវាងអ្នកដទៃដែលតុលាការកំពុងចាត់ការ ។ ករណីដែលអាចអនុញ្ញាតនូវការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹងបាន គឺជាករណីដែលអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងរវាងអ្នកដទៃ ត្រូវបានកំណត់ជាស្ថាពរជារួមរវាងភាគីម្ខាងនៃបណ្តឹងនោះ និង តតិយជន មានន័យថា ករណីដែល ប្រសិនបើចេញសាលក្រមស្តីពីបណ្តឹងដែលកំពុងត្រូវបានចាត់ការនោះទៅ អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមនោះ នឹងមានចំពោះតតិយជនដែលចង់ចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះដែរ ។ តតិយជនបែបនេះ មិនអាចតទល់គ្នាស្តីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងរវាងអ្នកដទៃ ដោយសារអាជ្ញាអស់ជំនុំនៃសាលក្រមស្តីពីបណ្តឹងរវាងអ្នកដទៃនោះ ហេតុនេះហើយ ត្រូវផ្តល់ឱកាសឱ្យសាមីខ្លួនការពារផលប្រយោជន៍របស់ខ្លួន តាមរយៈការចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដោយតាំងខ្លួនជាសហដើមចោទ ឬ សហចុងចម្លើយ ។ ការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង គឺជារបបមួយដែលទទួលស្គាល់ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ ។ ឧទាហរណ៍ ដូចជាករណីដែលម្ចាស់បំណុលដែលរឹបអូសសិទ្ធិលើបំណុល បានដាក់ពាក្យបណ្តឹងទាមទារឱ្យប្រមូលសិទ្ធិបំណុល ចំពោះកូនបំណុលទី ៣ (កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអស់) ហើយម្ចាស់បំណុល

ផ្សេងទៀតដែលរំលោភបំពាន ឬ បង្អាក់បន្ទុកដំណើរ បានចូលរួមអន្តរាគមន៍នៅក្នុងបណ្តឹងនោះ (មាត្រា ៤១២ កថាខណ្ឌទី ១ និង ទី ២) ឬ ករណីដែលមានបណ្តឹងទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដែលបានដាក់ដោយញាតិណាម្នាក់ ហើយញាតិដទៃទៀតបានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះ ក្នុងនាមជាសហដើមចោទ ។

(២) ការវិនិច្ឆ័យ និង ចេញសាលក្រមចំពោះសហបណ្តឹងដែលមានការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹង

ប្រសិនបើទទួលស្គាល់នូវការចូលរួមអន្តរាគមន៍ក្នុងបណ្តឹងទៅ អ្នកចូលរួមអន្តរាគមន៍នោះ និង ភាគីណាម្ខាង (គេហៅថា អ្នកដែលត្រូវបានចូលរួមអន្តរាគមន៍) ក្លាយទៅជាសហដើមចោទ ឬ សហចុងចម្លើយ ។ រវាងសហដើមចោទ ឬ រវាងសហចុងចម្លើយនេះ មានទំនាក់ទំនងដែលសាលក្រមដែលបុគ្គលម្នាក់ទទួល ត្រូវមានអានុភាពទៅលើបុគ្គលម្ខាងទៀត ហេតុនេះហើយ សហបណ្តឹងនេះគឺជាឧបសហបណ្តឹងចាំបាច់ (សហបណ្តឹងចាំបាច់ដោយប្រភេទដូចគ្នា Prozeßlrechtlich notwendige Streitgenossenshaft, Besondere Streitgenossenshaft) ហើយចំពោះការវិនិច្ឆ័យនៃបណ្តឹងនេះ ត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤១ ។ សាលក្រមត្រូវមានខ្លឹមសារជារួម ចំពោះសហដើមចោទ ឬ សហចុងចម្លើយ ។ ក្នុងករណីដែលពាក្យសុំចូលរួមអន្តរាគមន៍មិនស្របនឹងល័ក្ខខ័ណ្ឌនៃការចូលរួមអន្តរាគមន៍ក្នុងសហបណ្តឹងទេ តុលាការត្រូវចេញសាលក្រមលើកចោលនូវពាក្យសុំចូលរួមអន្តរាគមន៍នោះ ។

៣. ការចូលរួមជួយអន្តរាគមន៍

(១) អត្ថន័យនៃការចូលរួមជួយអន្តរាគមន៍

ការចូលរួមជួយអន្តរាគមន៍ គឺជាការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ដោយតតិយជនដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ តាមផ្លូវច្បាប់ អំពីលទ្ធផលនៃបណ្តឹងរវាងអ្នកដទៃនោះ ដើម្បីជួយភាគីណាម្ខាងនៃបណ្តឹងនោះ (មាត្រា ៤៣) ។ តតិយជនដែលចូលរួមជួយអន្តរាគមន៍ ត្រូវហៅថា អ្នកចូលរួមជួយអន្តរាគមន៍ រីឯភាគីដែលត្រូវបានអ្នកនោះជួយ ត្រូវហៅថា អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ។ ការចូលរួមជួយអន្តរាគមន៍របស់អ្នកចូលរួមជួយអន្តរាគមន៍ មានគោលបំណងការពារផលប្រយោជន៍របស់ខ្លួន តាមរយៈការជួយឱ្យអ្នកដែលត្រូវបានធ្វើអន្តរាគមន៍ឈ្នះបណ្តឹង ហេតុដូច្នេះ អ្នកចូលរួមជួយអន្តរាគមន៍ មិនមែនក្លាយជាភាគីនៃបណ្តឹងទេ ។

(២) ល័ក្ខខ័ណ្ឌនៃការចូលរួមជួយអន្តរាគមន៍

(ក) ចាំបាច់ត្រូវមានបណ្តឹងរវាងអ្នកដទៃ ដែលកំពុងត្រូវបានចាត់ការ

ការចូលរួមជួយអន្តរាគមន៍ អាចធ្វើបាន លុះត្រាតែមានបុរេល័ក្ខខ័ណ្ឌ គឺ ត្រូវមានបណ្តឹងរវាងអ្នកដទៃដែលកំពុងត្រូវបានចាត់ការ ។ ចំពោះអ្នកធ្វើសហបណ្តឹងម្នាក់ បណ្តឹងរវាងអ្នកធ្វើសហបណ្តឹងផ្សេង និង ភាគីម្ខាងទៀត ក៏ជាបណ្តឹងរវាងអ្នកដទៃដែលកំពុងតែត្រូវបានចាត់ការដែរ ដូច្នេះហើយ អ្នកធ្វើសហបណ្តឹងអាចចូលរួមជួយអន្តរាគមន៍សម្រាប់អ្នកធ្វើសហបណ្តឹងដទៃ ឬ សម្រាប់ភាគីម្ខាងទៀតបាន ។

(ខ) ចាំបាច់ត្រូវមានទំនាក់ទំនងនឹងផលប្រយោជន៍តាមផ្លូវច្បាប់ អំពីលទ្ធផលនៃបណ្តឹង

ការដែលមានទំនាក់ទំនងនឹងផលប្រយោជន៍តាមផ្លូវច្បាប់ អំពីលទ្ធផលនៃបណ្ដឹង គឺជា ការមានទំនាក់ទំនង ដែលអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ កាតព្វកិច្ច នៃសាមីខ្លួនជនដែលចូលរួមជួយអន្តរាគមន៍ ត្រូវបានកំណត់តាមផ្លូវច្បាប់សារធាតុ ដោយអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្ដឹងរវាងអ្នកដទៃ ។ ក្នុងករណីដែលមានទំនាក់ទំនងបែបនេះ អាចទទួលស្គាល់បាននូវផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍ ។ ឧទាហរណ៍ ក្នុងករណីដែលបណ្ដឹងរបស់ម្ចាស់បំណុលដែលទាមទារឱ្យអនុវត្តកាតព្វកិច្ចធានាចំពោះអ្នកធានា កំពុងត្រូវបានចាត់ការ ប្រសិនបើតុលាការទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ចធានានោះទៅ កូនបំណុលដែលមានកាតព្វកិច្ចចម្បង ត្រូវទទួលបន្ទុកនូវករណីយកិច្ចសងសំណងចំពោះអ្នកធានាវិញ (ក្រមរដ្ឋប្បវេណី មាត្រា ៩១១ កថាខណ្ឌទី ១) ហេតុនេះហើយ កូនបំណុលដែលមានកាតព្វកិច្ចចម្បងនោះ អាចត្រូវបានទទួលស្គាល់នូវផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍ សម្រាប់ភាគីអ្នកធានា ។ ផ្ទុយទៅវិញ គ្រាន់តែជាមិត្តភក្តិជិតស្និទ្ធ ឬ ញាតិរបស់ភាគី មិនអាចចាត់ទុកថា មានទំនាក់ទំនងនឹងផលប្រយោជន៍តាមផ្លូវច្បាប់បានទេ ដូច្នេះមិនអាចទទួលស្គាល់នូវផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍បានទេ ។ ក៏ប៉ុន្តែ ដើម្បីទទួលស្គាល់នូវផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍ តតិយជនមិនចាំបាច់ទទួលអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមនៃបណ្ដឹងរវាងអ្នកដទៃទេ ។

(៣) នីតិវិធីនៃការចូលរួមជួយអន្តរាគមន៍

ដើម្បីចូលរួមជួយអន្តរាគមន៍ ត្រូវដាក់ពាក្យសុំចូលរួមជួយអន្តរាគមន៍ ជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ ។ ពាក្យសុំចូលរួមជួយអន្តរាគមន៍ ត្រូវមានការបញ្ជាក់ឱ្យច្បាស់លាស់ថា តើចូលរួមជួយអន្តរាគមន៍សម្រាប់ភាគីណា ព្រមទាំងមូលហេតុ (តើមានទំនាក់ទំនងនឹងផលប្រយោជន៍អំពីលទ្ធផលនៃបណ្ដឹងយ៉ាងណា) នៃការចូលរួមជួយអន្តរាគមន៍នោះផង (មាត្រា ៤៤ កថាខណ្ឌទី ១) ។ ពាក្យសុំចូលរួមជួយអន្តរាគមន៍ អាចធ្វើឡើងបាន ព្រមជាមួយគ្នានឹងសកម្មភាពបណ្ដឹងដែលអ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើបាន ដូចជាការអះអាងអង្គហេតុ ឬ ការស្នើសុំឱ្យធ្វើការសាកសួរសាក្សី (មាត្រា ៤៤ កថាខណ្ឌទី ២) ។ មានតែករណីដែលមានពាក្យតវ៉ាចំពោះការចូលរួមជួយអន្តរាគមន៍ពីអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ឬ ពីភាគីម្ខាងទៀតទេ ដែលតុលាការត្រូវស្រាវជ្រាវថា តើអ្នកចូលរួមជួយអន្តរាគមន៍ មានផលប្រយោជន៍ក្នុងការចូលរួមជួយអន្តរាគមន៍ឬទេ ហើយត្រូវធ្វើការវិនិច្ឆ័យដោយដីកាសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍នោះ (មាត្រា ៤៥ កថាខណ្ឌទី ១ និង ទី ២) ។ ចំពោះដីកាសម្រេចនេះ ភាគី ឬ អ្នកចូលរួមជួយអន្តរាគមន៍អាចប្ដឹងជំទាស់បាន (មាត្រា ៤៥ កថាខណ្ឌទី ៣) ។ ប្រសិនបើមានការតវ៉ាចំពោះការចូលរួមជួយអន្តរាគមន៍ ទោះជាចេញដីកាសម្រេចមិនអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍ទៀតក៏ដោយ ក៏អ្នកចូលរួមជួយអន្តរាគមន៍នៅតែអាចធ្វើសកម្មភាពបណ្ដឹងបាន មុនដីកាសម្រេចនោះចូលជាស្ថាពរ (មាត្រា ៤៦ កថាខណ្ឌទី ៣ ម្យ៉ាងទៀត សូមមើលកថាខណ្ឌទី ៤ នៃមាត្រាដដែលផងដែរ) ។

(៤) ឋានៈនៃអ្នកចូលរួមជួយអន្តរាគមន៍

អ្នកចូលរួមជួយអន្តរាគមន៍អាចធ្វើសកម្មភាពបណ្តឹងទាំងអស់ ដូចជាការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ការដាក់ពាក្យសុំតវ៉ា ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីឱ្យអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ឈ្នះក្តី (មាត្រា ៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ អ្នកចូលរួមជួយអន្តរាគមន៍ គឺគ្រាន់តែមានឋានៈដែលស្ថិតនៅក្រោមអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ក្នុងនាមជាអ្នកជំនួយម្នាក់ប៉ុណ្ណោះ ហេតុដូច្នេះសកម្មភាព ដែលអ្នកចូលរួមជួយអន្តរាគមន៍ត្រូវមានកម្រិត ។

① សកម្មភាពណាដែលអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍មិនអាចធ្វើបាន នៅពេលដែលអ្នកចូលរួមជួយអន្តរាគមន៍ បានចូលរួមជួយអន្តរាគមន៍ អ្នកចូលរួមជួយអន្តរាគមន៍នោះក៏មិនអាចធ្វើបានឡើយ (មាត្រា ៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ឧទាហរណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែល ប្រសិនបើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ដាក់ តុលាការនឹងលើកចោល ដោយសារដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (មាត្រា ៩៤ កថាខណ្ឌទី ១) អ្នកចូលរួមជួយអន្តរាគមន៍ក៏មិនអាចដាក់បានឡើយ ឬ ប្រសិនបើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍មិនបានប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ នៅក្នុងអំឡុងពេលដែលអាចប្តឹងឧបាស្រ័យនោះ អ្នកចូលរួមជួយអន្តរាគមន៍ក៏មិនអាចដាក់បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានឡើយ ។

② សកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ពុំមានអានុភាពឡើយ ប្រសិនបើសកម្មភាពបណ្តឹងនោះបានប៉ះពាល់ប្រឆាំងនឹងសកម្មភាពបណ្តឹងរបស់អ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ (មាត្រា ៨៦ កថាខណ្ឌទី ២) ។ ឧទាហរណ៍ ទោះបីជាអ្នកចូលរួមជួយអន្តរាគមន៍បានធ្វើការបដិសេធនូវអង្គហេតុដែលអះអាងដោយភាគីម្ខាងទៀតក៏ដោយ តែប្រសិនបើអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ បានសារភាពតាមផ្លូវបណ្តឹង អានុភាពនៃការបដិសេធនោះនឹងគ្មានអត្ថិភាព ។

③ តាមលក្ខណៈនៃការចូលរួមជួយអន្តរាគមន៍ អ្នកចូលរួមជួយអន្តរាគមន៍ មិនអាចធ្វើសកម្មភាពដែលធ្វើឱ្យខូចប្រយោជន៍ដល់អ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ឬ មិនអាចធ្វើសកម្មភាពផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងបានឡើយ ។ ឧទាហរណ៍ ការសារភាពតាមផ្លូវបណ្តឹង ការដកពាក្យបណ្តឹង ការលះបង់នូវការទាមទារ ការទទួលស្គាល់នូវការទាមទារ ការសះជាតាមផ្លូវបណ្តឹង ការបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុបណ្តឹង ការដាក់ពាក្យបណ្តឹងតបជាដើម មិនអាចធ្វើបានឡើយ ។

(៥) អានុភាពនៃសាលក្រមចំពោះអ្នកចូលរួមជួយអន្តរាគមន៍

(ក) អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមដែលបានចេញចំពោះបណ្តឹងដែលមានការចូលរួមជួយអន្តរាគមន៍ មិនមានអានុភាពទៅលើអ្នកចូលរួមជួយអន្តរាគមន៍ទេ (សូមមើលមាត្រា ១៩៨ ចំណុចទីមួយ១) ។ ក៏ប៉ុន្តែ ប្រសិនបើសាលក្រមដែលសម្រេចឱ្យអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ចាញ់ បានចូលជាស្ថាពរ រវាងអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ និង ភាគីម្ខាងទៀត ខ្លឹមសារនៃការវិនិច្ឆ័យនៃសាលក្រមនោះ នឹងចង

អ្នកចូលរួមជួយអន្តរាគមន៍ក្នុងទំនាក់ទំនងជាមួយនឹងអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ហើយអ្នកចូលរួមជួយអន្តរាគមន៍មិនអាចធ្វើការអះអាងដែលប៉ះពាល់ដល់ការវិនិច្ឆ័យនោះ ចំពោះអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍បានឡើយ (មាត្រា ៤៧) ។ ឧទាហរណ៍ ពេលដែលបណ្ដឹងរបស់ម្ចាស់បំណុលដែលទាមទារឱ្យអ្នកធានាអនុវត្តកាតព្វកិច្ចធានា កំពុងតែត្រូវបានចាត់ការ កូនបំណុលដែលមានកាតព្វកិច្ចចម្បងបានចូលរួមជួយអន្តរាគមន៍សម្រាប់ភាគីអ្នកធានា ហើយបានធ្វើវិវាទប្រឆាំងនឹងការទាមទាររបស់ភាគីម្ខាងទៀត ដោយរួមជាមួយគ្នានឹងអ្នកធានាដែលជាអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ដោយអះអាងថា គ្មានកាតព្វកិច្ចធានា ដោយសារគ្មានកាតព្វកិច្ចចម្បង ក៏ប៉ុន្តែ ចុងបញ្ចប់ សាលក្រមដែលសម្រេចឱ្យអ្នកធានាចាញ់ក្ដី ដោយទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ចចម្បង និង អត្ថិភាពនៃការធានាកាតព្វកិច្ចបានចូលជាស្ថាពរ (បណ្ដឹងមុន) ។ បន្ទាប់ពីនោះ ក្នុងករណីដែលអ្នកធានាបានអនុវត្តកាតព្វកិច្ចធានាចំពោះម្ចាស់បំណុល ហើយបានដាក់ពាក្យបណ្ដឹងទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បងសងសំណងវិញ កូនបំណុលដែលមានកាតព្វកិច្ចចម្បងនោះ មិនអាចធ្វើវិវាទអំពីអត្ថិភាពនៃករណីយកិច្ចសងសំណង ដោយអះអាងអំពីនត្ថិភាពនៃកាតព្វកិច្ចចម្បង នៅពេលមានបណ្ដឹងមុននោះ ។ ចំណងនៃសាលក្រមជាស្ថាពរ ចំពោះអ្នកចូលរួមជួយអន្តរាគមន៍នោះ ត្រូវហៅថា អានុភាពនៃការចូលរួមអន្តរាគមន៍នៃសាលក្រម ។

(ខ) អានុភាពនៃការចូលរួមអន្តរាគមន៍នៃសាលក្រម គឺជាអានុភាពពិសេសដែលត្រូវបានទទួលស្គាល់ដោយមានមូលហេតុថា ដោយសារតែអ្នកចូលរួមជួយអន្តរាគមន៍បានជួយដល់អ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ ហើយបានរួមគ្នាធ្វើនីតិវិធីបណ្ដឹងជាមួយគ្នា ហេតុនេះហើយ ជាលទ្ធផល ពេលដែលសាលក្រមដែលសម្រេចសេចក្ដីឱ្យអ្នកដែលត្រូវគេចូលរួមជួយអន្តរាគមន៍ចាញ់ បានចូលជាស្ថាពរ គួរតែឱ្យអ្នកចូលរួមជួយអន្តរាគមន៍ទទួលខុសត្រូវក្នុងការចាញ់ក្ដី ដើម្បីឱ្យមានស្មើភាពគ្នា ។ ចំណុចនេះគឺខុសគ្នានឹងអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រម ដែលមានទៅលើភាគីនៃបណ្ដឹង ។ អានុភាពនៃការចូលរួមជួយអន្តរាគមន៍នេះ ត្រូវបានទទួលស្គាល់ដោយសារមានភាពចាំបាច់ក្នុងការធ្វើឱ្យមានសមភាពរវាងអ្នកចូលរួមជួយអន្តរាគមន៍ និង អ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ហេតុនេះហើយ អានុភាពនេះត្រូវបានទទួលស្គាល់ មិនត្រឹមតែការវិនិច្ឆ័យដែលមានក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមស្ថាពរទេ គឺមានអានុភាពទៅលើការវិនិច្ឆ័យដែលមានក្នុងសំអាងហេតុនៃសាលក្រមដែរ ។ ផ្ទុយទៅវិញ ក្នុងករណីដែលមានស្ថានភាពដូចជា អ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ បានធ្វើសកម្មភាពដែលប៉ះពាល់ប្រឆាំងនឹងសកម្មភាពរបស់អ្នកចូលរួមជួយអន្តរាគមន៍ ឬ បានរារាំងដល់សកម្មភាពរបស់អ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ ឬ មិនបានធ្វើសកម្មភាពដែលមានតែអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ទេដែលអាចធ្វើបាន ដោយចេតនា ឬ ដោយកំហុស ជាដើម ការដាក់បន្ទុកឱ្យអ្នកចូលរួមជួយអន្តរាគមន៍ ទទួលខុសត្រូវនូវការចាញ់ក្ដី នឹងធ្វើឱ្យមានភាពផ្ទុយនឹងសមធម៌ ហេតុនេះហើយ អានុភាពនៃការចូលរួមជួយអន្តរាគមន៍ពុំកើតមានឡើងទេ (មាត្រា ៤៧ ចំណុចទីមួយ) ។

(៦) ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង

(ក) ក្នុងចំណោមការចូលរួមជួយអន្តរាគមន៍ ក្នុងករណីដែលអាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រម ដែលត្រូវបានចេញចំពោះអ្នកត្រូវគេចូលរួមជួយអន្តរាគមន៍ និង ភាគីម្ខាងទៀត មានចំណងដល់អ្នកចូលរួមជួយអន្តរាគមន៍ និង ភាគីម្ខាងទៀត ចាំបាច់ទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការធ្វើបណ្តឹងខ្លាំងជាងករណីធម្មតាចំពោះអ្នកចូលរួមជួយអន្តរាគមន៍ ។ ដូច្នេះ ក្នុងករណីនេះ អ្នកចូលរួមជួយអន្តរាគមន៍នឹងបានទទួលនូវឋានៈប្រហាក់ប្រហែលគ្នានឹងអ្នកធ្វើសហបណ្តឹងចាំបាច់ដែរ (មាត្រា ៤១ និង មាត្រា ៤៨ កថាខណ្ឌទី ១) ។ ការចូលរួមជួយអន្តរាគមន៍បែបនេះ ត្រូវហៅថា ការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង (មាត្រា ៤៨) ។ ឧទាហរណ៍ មានដូចជាបណ្តឹងទាមទារប្រមូលបំណុលដែលម្ចាស់បំណុលដែលបានរឹបអូសសិទ្ធិលើបំណុល តាមការអនុវត្តដោយបង្ខំ បានធ្វើឡើងចំពោះកូនបំណុលទី ៣ (មាត្រា ៤១២ កថាខណ្ឌទី ១) ប្រសិនបើមានការចូលរួមជួយអន្តរាគមន៍ ដោយកូនបំណុលនៃការអនុវត្តដែលបានទទួលនូវការរឹបអូសសិទ្ធិលើបំណុលរបស់ខ្លួន ឬ ករណីដែលអ្នកដែលបានទទួលអនុប្បទាននូវវត្ថុវិវាទនៃបណ្តឹងដែលកំពុងត្រូវបានចាត់ការ ឬ ទទួលអនុប្បទានសិទ្ធិ ឬ កាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹងដែលកំពុងត្រូវបានចាត់ការ ពីភាគីនៃបណ្តឹងនោះ បានចូលរួមជួយអន្តរាគមន៍សម្រាប់ភាគីដែលជាអនុប្បទាយីនោះ (មាត្រា ៨៨ កថាខណ្ឌទី ៣, ចំពោះចំណុចនេះ សូមមើលការពន្យល់ខាងក្រោយ) ជាដើម ។ ចំណុចខុសគ្នារវាងការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង និង ការចូលរួមក្នុងសហបណ្តឹង គឺ ចំពោះករណីនៃការចូលរួមក្នុងសហបណ្តឹង អ្នកចូលរួមអន្តរាគមន៍ ត្រូវមានលក្ខណសម្បត្តិជាភាគី ចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងដែលកំពុងត្រូវបានចាត់ការរវាងអ្នកដទៃ ផ្ទុយទៅវិញ ចំពោះករណីនៃការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង មិនចាំបាច់មានលក្ខណសម្បត្តិជាភាគីទេ ។

(ខ) ក្នុងការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង ① ទោះបីជាសកម្មភាពបណ្តឹងរបស់អ្នកចូលរួមជួយអន្តរាគមន៍ មានការប៉ះពាល់ប្រឆាំងនឹងសកម្មភាពបណ្តឹងរបស់អ្នកត្រូវគេចូលរួមអន្តរាគមន៍ក៏ដោយ ក៏សកម្មភាពនោះនឹងមានអានុភាពដែរ ប្រសិនបើមានផលប្រយោជន៍ដល់អ្នកត្រូវគេចូលរួមអន្តរាគមន៍ (មាត្រា៤៨ កថាខណ្ឌទី ២ ដែលមានចែងមិនឱ្យអនុវត្តតាមមាត្រា ៤៦, ម្យ៉ាងទៀត សូមមើលមាត្រា ៤១ កថាខណ្ឌទី ១ ផងដែរ) ។ ឧទាហរណ៍ ទោះបីជាអ្នកត្រូវគេចូលរួមអន្តរាគមន៍បានលះបង់សិទ្ធិប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ក៏ដោយ ក៏អ្នកចូលរួមអន្តរាគមន៍អាចធ្វើបណ្តឹងឧបាស្រ័យដែលមានសុពលភាពបានដែរ រីឯ អ្នកត្រូវគេចូលរួមអន្តរាគមន៍មិនត្រូវបានអនុញ្ញាតឱ្យដកពាក្យបណ្តឹងឧបាស្រ័យនោះបានឡើយ ។ ម្យ៉ាងទៀត អំឡុងពេលដែលអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់របស់អ្នកចូលរួមជួយអន្តរាគមន៍ ត្រូវគណនាឯករាជ្យ ដាច់ពីអំឡុងពេលនៃការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់របស់អ្នកត្រូវគេចូលរួមអន្តរាគមន៍ ។ ក្នុងករណីដែលមូលហេតុនៃការផ្អាក ឬ បង្អង់នីតិវិធីបណ្តឹង កើតឡើងចំពោះអ្នកចូលរួមជួយ

អន្តរាគមន៍ នីតិវិធីបណ្តឹងនោះត្រូវផ្អាក ឬ តុលាការអាចបង្គាប់ឱ្យបង្អង់នីតិវិធីបណ្តឹង. ចំពោះទំនាក់ទំនងនឹងអ្នកត្រូវគេចូលរួមអន្តរាគមន៍ផងដែរ ។ ② ផ្ទុយទៅវិញ ករណីដែលអានុភាពនៃការចូលរួមអន្តរាគមន៍មិនកើតមានឡើង ត្រូវបានកម្រិត (ការមិនអនុវត្ត មាត្រា ៤៧ ចំណុច ខ និង គ ដោយយោងតាមមាត្រា ៤៨ កថាខណ្ឌទី ២) ។

(៧) ការជូនដំណឹងអំពីបណ្តឹង

(ក) ការជូនដំណឹងអំពីបណ្តឹង គឺជាការជូនដំណឹងអំពីអង្គហេតុនៃការចាត់ការបណ្តឹង ចំពោះតតិយជនដែលភាគីយល់ឃើញថា អាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលកំពុងត្រូវបានចាត់ការ ដើម្បីផ្តល់ឱកាសឱ្យតតិយជននោះអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹង (មាត្រា ៥០ កថាខណ្ឌទី ១) ។ ការជូនដំណឹងអំពីបណ្តឹងមានមុខងារ ①ផ្តល់ឱកាសឱ្យតតិយជន (អ្នកទទួលការជូនដំណឹង) អាចការពារផលប្រយោជន៍របស់ខ្លួន តាមរយៈការចូលរួមអន្តរាគមន៍ក្នុងបណ្តឹង និង ②ឱ្យភាគីដែលបានជូនដំណឹង (អ្នកជូនដំណឹង) អាចរួចផុតពីការបាត់បង់ផលប្រយោជន៍ ឬ អាចរក្សានូវឋានៈដែលទាញផលប្រយោជន៍មកខ្លួន នៅក្នុងបណ្តឹងដែលនឹងអាចកើតឡើងនាអនាគត ជាមួយអ្នកទទួលការជូនដំណឹង ដោយឱ្យមានអានុភាពនៃការចូលរួមអន្តរាគមន៍ ដល់អ្នកទទួលការជូនដំណឹង ទោះបីជាក្នុងករណីដែលអ្នកទទួលការជូនដំណឹងនោះ មិនបានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងក៏ដោយ ។

(ខ) ការជូនដំណឹងអំពីបណ្តឹង ត្រូវធ្វើឡើង ដោយដាក់លិខិតជាលាយល័ក្ខណ៍អក្សរដែលបញ្ជាក់អំពីមូលហេតុក្នុងការជូនដំណឹងអំពីបណ្តឹង (មូលហេតុដែលអ្នកទទួលការជូនដំណឹងអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹង) ព្រមទាំងស្ថានភាពនៃដំណើរការនៃបណ្តឹង ទៅតុលាការ ។ ក្រៅពីនេះ ក្នុងលិខិតជូនដំណឹងត្រូវសរសេរនូវឈ្មោះ ឬ នាមករណ៍របស់ភាគីនៃបណ្តឹង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង និង ឈ្មោះ ឬ នាមករណ៍ ព្រមទាំងអាសយដ្ឋានរបស់អ្នកដែលត្រូវទទួលការជូនដំណឹង ។ តុលាការត្រូវបញ្ជូនលិខិតនៃការជូនដំណឹងនោះ ទៅឱ្យអ្នកដែលត្រូវទទួលការជូនដំណឹង ព្រមទាំងភាគីម្ខាងទៀត (មាត្រា ៥០ កថាខណ្ឌទី ២) ។

(គ) អ្នកទទួលដំណឹងនោះ មិនមែនក្លាយទៅជាអ្នកចូលរួមជួយអន្តរាគមន៍ ដោយស្វ័យប្រវត្តិ តាមរយៈការជូនដំណឹងទេ ឬ មិនត្រូវបានបង្ខំឱ្យចូលរួមជួយអន្តរាគមន៍ជាដាច់ខាតទេ តែទោះជាមិនបានចូលរួមក៏ដោយក៏អ្នកទទួលការជូនដំណឹងត្រូវបានចាត់ទុកថា បានចូលរួមអន្តរាគមន៍នៅពេលដែលអ្នកនោះអាចចូលរួមបាន ហើយនឹងទទួលនូវអានុភាពនៃការចូលរួមអន្តរាគមន៍នៃសាលក្រម (មាត្រា ៥០ កថាខណ្ឌទី ៣, មាត្រា ៤៧) ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកធានា បានជូនដំណឹងអំពីបណ្តឹង ទៅឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅពេលដែលបណ្តឹងដែលម្ចាស់បំណុលទាមទារឱ្យអ្នកធានាអនុវត្តកាតព្វកិច្ចធានា កំពុងត្រូវបានចាត់ការ ទោះបីជាកូនបំណុលដែលមានកាតព្វកិច្ចចម្បងមិនបានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងនោះក៏ដោយ ប្រសិនបើអ្នកធានា

បានចាញ់ក្ដី ក្រោយពេលនោះ ហើយទាមទារសំណងពីកូនបំណុលដែលមានកាតព្វកិច្ចចម្បងមកវិញ ក៏កូនបំណុលដែលមានកាតព្វកិច្ចចម្បងមិនអាចអះអាងអំពីនត្ថិភាពនៃកាតព្វកិច្ចចម្បង នៅពេលដែលមានក្ដីបណ្ដឹងមុននោះបានឡើយ ។

## កថាភាគទី ៤ ការទទួលបន្តនូវបណ្ដឹង

### ១. អត្ថន័យនៃការទទួលបន្តនូវបណ្ដឹង

ការទទួលបន្តនូវបណ្ដឹង គឺជាការណ៍ដែលតតិយជនទទួលបន្តនូវឋានៈជាភាគីបណ្ដឹង ក្រោយការកើតឡើងនៃការចាត់ការបណ្ដឹង ហើយក្រោយពីនោះ តតិយជននោះនឹងបន្តនូវបណ្ដឹងក្នុងនាមជាភាគីបណ្ដឹង ។ ក្នុងករណីនេះ លទ្ធផលនៃសកម្មភាពបណ្ដឹងដែលបានធ្វើដោយភាគីពីមុនមក ក៏ត្រូវបានបន្តដោយភាគីថ្មីដែរ ទោះបីជាសកម្មភាពនោះ មានផលប្រយោជន៍ដល់ភាគីក៏ដោយ ឬ ធ្វើឱ្យបាត់បង់ផលប្រយោជន៍ដល់ភាគីក៏ដោយ ។

### ២. ករណីដែលការទទួលបន្តនូវបណ្ដឹងកើតឡើង

ការទទួលបន្តនូវបណ្ដឹង ត្រូវកើតឡើង ក្នុងករណីដែល នៅពេលដែលបណ្ដឹងមួយកំពុងត្រូវបានចាត់ការ ភាគីនៃបណ្ដឹងនោះបានបាត់បង់នូវឋានៈ ដែលជាមូលហេតុនៃលក្ខណសម្បត្តិដែលអាចក្លាយជាភាគីនៃបណ្ដឹងចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹងនោះ (លក្ខណសម្បត្តិជាភាគី) ហើយឋានៈនោះត្រូវបានផ្ទេរទៅតតិយជន ។ ករណីដូចខាងក្រោមនេះ គឺជាករណីដែលមានការទទួលបន្តនូវបណ្ដឹង ។

①ករណីដែលភាគីបានទទួលមរណភាព

សន្តតិជន ឬ បុគ្គលដែលបានទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងដោយច្បាប់ ឬបទដ្ឋានផ្សេង ត្រូវទទួលបន្តនូវបណ្ដឹង ( មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច ក, កថាខណ្ឌទី ២ ចំណុច ក) ។

②ករណីដែលមានការរលត់នីតិបុគ្គលដែលជាភាគី ដោយការរួមបញ្ចូលនីតិបុគ្គល

នីតិបុគ្គលដែលទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹងក្រោយពេលរួមបញ្ចូលនីតិបុគ្គលត្រូវទទួលបន្តនូវបណ្ដឹងដែរ ( មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច ខ, កថាខណ្ឌទី ២ ចំណុច ខ) ។

③ ករណីដែលភាគីដែលទទួលបន្ទុកក្នុងការធ្វើបណ្ដឹង ដោយផ្អែកលើលក្ខណសម្បត្តិដែលបានកំណត់ ដូចជាអ្នកប្រតិបត្តិមតកសាសន៍ ជាអាទិ៍ បានបាត់បង់នូវលក្ខណសម្បត្តិនោះ

បុគ្គលដែលបានទទួលនូវលក្ខណសម្បត្តិនោះជាថ្មី ត្រូវទទួលបន្តនូវនៃបណ្ដឹង ( មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច ឃ, កថាខណ្ឌទី ២ ចំណុច ឃ) ។

④ករណីដែលបណ្ដឹងត្រូវបានធ្វើដោយភាគីដែលត្រូវបានជ្រើសរើស ហើយដែលភាគីដែលត្រូវបានជ្រើសរើសទាំងអស់នោះ បានបាត់បង់នូវលក្ខណសម្បត្តិនោះ

អ្នកដែលបានជ្រើសរើសទាំងអស់ ឬ ភាគីដែលត្រូវបានជ្រើសរើសសាជាថ្មីទាំងអស់ ត្រូវទទួលបន្តនូវបណ្តឹង (មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច ង, កថាខណ្ឌទី ២ ចំណុច ង) ។

៣. ការទទួលបន្តនូវបណ្តឹង និង ការផ្អាកនីតិវិធីនៃបណ្តឹង

(១) ការផ្អាក និង ការទទួលបន្តនីតិវិធីនៃបណ្តឹង

ប្រសិនបើអង្គហេតុដែលជាមូលហេតុនៃការទទួលបន្តនូវបណ្តឹង ដូចជាមរណភាពរបស់ភាគី ជាដើម បានកើតឡើង ការទទួលបន្តនូវបណ្តឹងនឹងកើតឡើងដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់មានសកម្មភាពរបស់តុលាការ ឬ របស់ភាគីទេ ។ ប៉ុន្តែ ដោយសារបុគ្គលដែលទទួលបន្តនូវបណ្តឹង មិនមែនជាភាគីពីមុនមកទេ តាមធម្មតា បុគ្គលនោះមិនអាចត្រៀមដើម្បីធ្វើសកម្មភាពចាំបាច់តាមផ្លូវនីតិវិធីនៃបណ្តឹងភ្លាមៗបានទេ ។ ហេតុដូច្នេះ ក្រមនីតិវិធីរដ្ឋប្បវេណីចែងថា ក្នុងករណីដែលអង្គហេតុដែលជាមូលហេតុនៃការទទួលបន្តនូវបណ្តឹង កើតឡើង នីតិវិធីនៃបណ្តឹងត្រូវផ្អាកដោយស្វ័យប្រវត្តិ ។ នេះគឺជាការផ្អាកនីតិវិធីនៃបណ្តឹង (មាត្រា ១៧៣) ។ នីតិវិធីបណ្តឹងដែលបានផ្អាក នឹងត្រូវបន្តឡើងវិញ ក្នុងករណីដែលមានពាក្យសុំទទួលបន្តនីតិវិធីនៃបណ្តឹង ពីអ្នកទទួលបន្ត ឬ ពីភាគីម្ខាងទៀត (មាត្រា ១៧៥) ឬ ក្នុងករណីដែលតុលាការចេញដីកាសម្រេចបង្គាប់ឱ្យបន្តនីតិវិធីនៃបណ្តឹង (មាត្រា ១៧៦) ។

(២) ទំនាក់ទំនងរវាងការទទួលបន្តនូវបណ្តឹង និង ការផ្អាកនិងទទួលបន្តនីតិវិធីនៃបណ្តឹង

រវាងការទទួលបន្តនូវបណ្តឹង និង ការផ្អាកនិងទទួលបន្តនីតិវិធីនៃបណ្តឹង មានទំនាក់ទំនងជិតស្និទ្ធណាស់ក៏ប៉ុន្តែ ការទទួលបន្តនូវបណ្តឹង គឺជាបញ្ហាពាក់ព័ន្ធនឹងឋានៈរបស់ភាគី រីឯការផ្អាក និង ទទួលបន្តនីតិវិធីនៃបណ្តឹងវិញ គឺជាបញ្ហាពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធីបណ្តឹង ដូច្នេះត្រូវបែងចែកដាច់ដោយឡែកពីគ្នា ។ ការផ្អាកនីតិវិធីនៃបណ្តឹង គឺជារបបមួយដើម្បីផ្តល់នូវអំឡុងពេលត្រៀម ចំពោះអ្នកទទួលបន្តនីតិវិធីថ្មី ក្នុងករណីដែលមានការផ្លាស់ប្តូរអ្នកធ្វើនីតិវិធីនៃបណ្តឹង ហើយក៏អាចកើតឡើងដែរ ទោះបីជាពុំមានការទទួលបន្តនូវបណ្តឹងក៏ដោយ (មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច គ) ។ ផ្ទុយទៅវិញ ទោះបីជាមានការទទួលបន្តនូវបណ្តឹងដោយសារមរណភាពរបស់ភាគី ជាអាទិ៍ ក៏ដោយ តែប្រសិនបើភាគីមានអ្នកតំណាងដោយអាណត្តិ នោះសិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិនោះមិនរលត់ដោយសារមរណភាពរបស់ភាគី ជាអាទិ៍ នោះទេ គឺសិទ្ធិអំណាចនោះនៅតែមានអត្ថិភាពដដែលសម្រាប់អ្នកទទួលបន្តនូវបណ្តឹង (មាត្រា ៥៥) ដូច្នេះ ពុំមានការផ្លាស់ប្តូរអ្នកធ្វើនីតិវិធីនៃបណ្តឹងទេ ហើយមិនចាំបាច់ឱ្យមានអំឡុងពេលត្រៀម ហេតុដូច្នេះ នីតិវិធីនៃបណ្តឹងក៏មិនផ្អាកឡើយ (មាត្រា ១៧៣ កថាខណ្ឌទី ៣) ។

៤. ការអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ និង ការទទួលបន្តនូវបណ្តឹង (មាត្រា ៨៨)

(១) ការអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ នៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ

នៅពេលដែលបណ្តឹងកំពុងតែត្រូវបានចាត់ការ អាចមានករណីដែលភាគីធ្វើអនុប្បទាននូវសិទ្ធិដែលជាកម្មវត្ថុ

នៃបណ្តឹងនោះ ទៅឱ្យតតិយជន ឬ ធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ផ្ទេរការកាន់កាប់នូវវត្ថុនោះទៅឱ្យតតិយជន ជាដើម ។ ឧទាហរណ៍ ករណីដែលម្ចាស់កម្មសិទ្ធិដីធ្លីឈ្មោះ A បានដាក់ពាក្យបណ្តឹងទាមទារចំពោះម្ចាស់កម្មសិទ្ធិនៃអាគារដែលសាងសង់លើដីធ្លីនោះ ឱ្យរុះរើអាគារ ហើយប្រគល់ដីធ្លីនោះមកខ្លួនវិញ ហើយពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការ ចុងចម្លើយ B បានធ្វើអនុប្បទាននូវអាគារនោះទៅឱ្យតតិយជន C ហើយបានផ្ទេរការកាន់កាប់ដីធ្លីនោះទៅ C (ការធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ) ឬ ករណីដែលអ្នកលក់ D បានដាក់ពាក្យបណ្តឹងទាមទារចំពោះអ្នកទិញ E ឱ្យបង់ថ្លៃលក់ទិញ ហើយពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការ ដើមចោទ D បានធ្វើអនុប្បទាននូវសិទ្ធិទាមទារឱ្យបង់ថ្លៃលក់ទិញទៅឱ្យតតិយជន F (ការធ្វើអនុប្បទាននូវសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង) ជាដើម ។ ក្នុងករណីទាំងនេះ ប្រសិនបើគ្មានបញ្ញត្តិពិសេសទេ ការទាមទារឱ្យរុះរើអាគារ និង ប្រគល់ដីធ្លីរបស់ A ចំពោះ B ឬ ការទាមទារឱ្យបង់ថ្លៃលក់ទិញរបស់ D ចំពោះ E មិនអាចត្រូវបានទទួលស្គាល់ទេ ។ ក៏ប៉ុន្តែ ធ្វើដូច្នេះទៅ សេចក្តីរំពឹងថានឹងឈ្នះបណ្តឹងរបស់ A ឬ E នឹងត្រូវបាត់បង់ ហើយ A និង E នោះត្រូវទទួលបន្ទុកក្នុងការធ្វើបណ្តឹងជាថ្មី ឬ ក្នុងការឆ្លើយតបចំពោះបណ្តឹងថ្មី ។

ដើម្បីជៀសវាងនូវស្ថានភាពបែបនេះ អាចមានគំនិតមួយទៀត គឺ មិនអនុញ្ញាតឱ្យធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ឬ សិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង ពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការ ។ ក៏ប៉ុន្តែ ក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យភាគីធ្វើអនុប្បទាន ឬ ផ្ទេរនូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ ទោះជាបណ្តឹងកំពុងត្រូវបានចាត់ការក៏ដោយ (មាត្រា ៨៨ កថាខណ្ឌទី ១) តែដើម្បីជៀសវាងនូវបញ្ហាបែបនេះ ក្រមនេះក៏បានចែងថា ការធ្វើអនុប្បទាន ឬ ការផ្ទេរនូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ នៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ ពុំមានឥទ្ធិពលទៅលើបណ្តឹងទេ (មាត្រា ៨៨ កថាខណ្ឌទី ២) ។ " ការធ្វើអនុប្បទាន ឬ ការផ្ទេរនូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ពុំមានឥទ្ធិពលទៅលើបណ្តឹង" មានន័យថា ក្នុងឧទាហរណ៍ខាងលើនេះ ក្រោយពេល B ធ្វើអនុប្បទានអាគារទៅ C បុគ្គលដែលបំពានកម្មសិទ្ធិដីធ្លីរបស់ A ដោយសារមានកម្មសិទ្ធិលើអាគារដែលបានសាងសង់លើដីរបស់ A មិនមែន B ទេ គឺ C ក៏ប៉ុន្តែ ចំពោះទំនាក់ទំនងនឹងបណ្តឹងនេះវិញ B នៅតែមានលក្ខណសម្បត្តិជាចុងចម្លើយដូចពីមុនដដែល ហើយ A នៅតែអាចបន្តបណ្តឹងស្របច្បាប់ ដោយយក B ជាចុងចម្លើយដដែល ។ ក្នុងករណីនេះ កម្មវត្ថុនៃបណ្តឹង គឺជាសិទ្ធិទាមទាររបស់ A ចំពោះ C ឱ្យរុះរើអាគារ ហើយប្រគល់ដីមកវិញ តែ B ត្រូវធ្វើបណ្តឹងបន្តសម្រាប់ C ។ C ត្រូវជាអ្នកទទួលបន្តពី B ក្រោយពីបណ្តឹងត្រូវបានចាត់ការ ហេតុនេះហើយ អាជ្ញាអស់ជំនុំជាលក្ខណៈសារធាតុ និង អានុភាពអនុវត្តនៃសាលក្រមដែលត្រូវបានធ្វើឡើងដោយមាន B ជាចុងចម្លើយ ក៏មានចំពោះ C ដែរ (មាត្រា ១៩៨ ចំណុច គ, មាត្រា ៣៥១ កថាខណ្ឌទី ១ ចំណុច គ វាក្យខណ្ឌទី ២) ។ ដូច្នេះហើយ A អាចអនុវត្តដោយបង្ខំចំពោះ C បាន ដោយទទួលនូវលិខិតអនុវត្តពិសេស (មាត្រា ៣៥៦ កថាខណ្ឌទី ២) ដោយផ្អែកលើសាលក្រមសម្រេចឱ្យ A

ឈ្មោះចំពោះ B ។ រីឯករណីមួយទៀតក៏ដូចគ្នាដែរ ក្រោយពេលបានធ្វើអនុប្បទានសិទ្ធិទាមទារឱ្យបង់ថ្លៃលក់ទិញទៅឱ្យ F ក៏ដោយ ក៏ D មិនបាត់បង់នូវលក្ខណសម្បត្តិជាដើមចោទ ហើយត្រូវបន្តបណ្តឹងនោះសម្រាប់ F ។ អានុភាពអស់ជំនុំជាលក្ខណៈសារធាតុនៃសាលក្រមដែលតុលាការបានចេញចំពោះ D និង E ក៏មានអានុភាពទៅលើ F ដែរ ហេតុនេះហើយ ប្រសិនបើ E បានទទួលសាលក្រមឈ្នះបណ្តឹង E មិនត្រូវបានប្តឹងសាជាថ្មី ដោយ F ទេ ។ ផ្ទុយទៅវិញ ប្រសិនបើ D បានឈ្នះបណ្តឹង F ក៏អាចអនុវត្តដោយបង្ខំចំពោះ E បាន ដោយទទួលនូវលិខិតអនុវត្តពិសេស ។

ដូច្នេះហើយ អនុប្បទានិកនៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ មិនអាចធ្វើបណ្តឹងដោយខ្លួនឯង ក្នុងនាមជាភាគីបានទេ ក៏ប៉ុន្តែ ប្រសិនបើបានចូលរួមជួយអន្តរាគមន៍ខាងភាគីអនុប្បទាយី ការចូលរួមជួយអន្តរាគមន៍នេះក្លាយទៅជាការចូលរួមជួយអន្តរាគមន៍ក្នុងលក្ខណៈដូចជាសហបណ្តឹង (មាត្រា ៤៨ កថាខណ្ឌទី ៣) ដូច្នេះអនុប្បទានិកនោះអាចធ្វើសកម្មភាពបណ្តឹងដោយផ្អែកលើឆន្ទៈរបស់ខ្លួនបានខ្លះៗ ។

(២) ចំណុចខុសគ្នាទៅនឹងការទទួលបន្តនូវបណ្តឹង

អនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ ដែលអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៨៨ តាមពិត អាចចាត់ទុកបានដែរថា ជាករណីមួយដែលភាគីនៃបណ្តឹងបានបាត់បង់នូវឋានៈដែលជាមូលហេតុនៃលក្ខណសម្បត្តិជាភាគីនៃបណ្តឹង ចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងនោះ (លក្ខណសម្បត្តិជាភាគី) ពេលបណ្តឹងកំពុងត្រូវបានចាត់ការ ហើយឋានៈនោះត្រូវបានផ្ទេរទៅតតិយជន ដូចដែលបានពន្យល់ក្នុងវគ្គ ២. ខាងលើនេះ ។ ក៏ប៉ុន្តែ ករណីនៃអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាអាទិ៍ ខុសពីករណីដែលការទទួលបន្តនូវបណ្តឹងកើតឡើង គឺជាការផ្ទេរឋានៈជាកំណត់ដែលជាមូលហេតុនៃលក្ខណសម្បត្តិជាភាគី មានន័យថា គឺជាការផ្ទេរត្រឹមតែឋានៈជាកំណត់នោះប៉ុណ្ណោះទេ ហើយខុសនឹងការផ្ទេរជាសកលនូវសិទ្ធិ និង កាតព្វកិច្ចដូចជាសន្តតិកម្ម ឬ ការរួមបញ្ចូល ជាដើម ឬ ការផ្ទេរលក្ខណសម្បត្តិជាអ្នកទទួលបន្ទុកបណ្តឹង ។ មានន័យថា ក្នុងចំណោមករណីទាំងឡាយដែលភាគីនៃបណ្តឹងបានបាត់បង់នូវឋានៈដែលជាមូលហេតុនៃលក្ខណសម្បត្តិដែលអាចធ្វើជាភាគីនៃបណ្តឹង (លក្ខណសម្បត្តិជាភាគី) ចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងនោះ នៅពេលបណ្តឹងកំពុងត្រូវបានចាត់ការ ហើយឋានៈនោះត្រូវបានផ្ទេរទៅតតិយជន ក្រមនីតិវិធីរដ្ឋប្បវេណីនេះមិនទទួលស្គាល់នូវការទទួលបន្តនូវឋានៈជាភាគី ចំពោះការផ្ទេរសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាកំណត់ណាមួយ ហើយឱ្យភាគីពីមុនរក្សាទុកនូវឋានៈនោះដដែល ។ នេះគឺដោយសារតែមានករណីច្រើនដែលភាគីម្ខាងទៀត ឬ តុលាការមិនអាចដឹងបានថា មានការផ្ទេរសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាកំណត់ ហេតុនេះហើយ ប្រសិនបើឱ្យអនុប្បទានិកទទួលបន្តនូវបណ្តឹងនោះទៅ ទំនាក់ទំនងបណ្តឹងនឹងមានកាន់តែភាពស្មុគស្មាញខ្លាំងឡើង ហើយអាចមានករណីដែលមិនអាចទទួលលទ្ធផលសមស្របបាន ។

## ជំពូកទី ៦ បទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច

### កថាភាគទី ១ គោលគំនិត និង កម្មវត្ថុនៃនីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច

ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ២ ជំពូកទី ៧ មានចែងអំពីនីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច ដែលជានីតិវិធីពិសេស ដើម្បីដោះស្រាយឱ្យបានឆាប់រហ័សនូវវិវាទចំនួនទឹកប្រាក់តិចដែលមានតម្លៃសេដ្ឋកិច្ចទាប តាមនីតិវិធីសង្ខេប (មាត្រា ២២៣) ។ គោលគំនិតនៃការបង្កើតនីតិវិធីនៃរឿងក្តីទឹកប្រាក់តិច គឺការបង្កើតនូវនីតិវិធីដោះស្រាយឱ្យបានងាយស្រួល និង ឆាប់រហ័សនូវវិវាទស្តីពីការបង់ទឹកប្រាក់ចំនួនតិចដែលកើតឡើងច្រើននៅក្នុងជីវភាពសង្គមប្រជាពលរដ្ឋរស់នៅ ដើម្បីឱ្យប្រជាពលរដ្ឋធម្មតាអាចយករឿងក្តីដែលជាប់ជិតស្និទ្ធនឹងជីវភាពរបស់ខ្លួនឡើងតុលាការ និង ទទួលនូវការសង្គ្រោះសិទ្ធិរបស់ខ្លួន ។ យោលតាមគោលគំនិតនេះ ក្រមនីតិវិធីរដ្ឋប្បវេណីបានបង្កើតបញ្ញត្តិពិសេសជាច្រើនដែលផ្សេងពីនីតិវិធីបណ្តឹងធម្មតា ដើម្បីឱ្យអាចទទួលនូវសាលក្រមរបស់តុលាការ ដោយចំណាយពេលវេលា និង សោហ៊ុយដែលសមស្របនឹងតម្លៃសេដ្ឋកិច្ចនៃរឿងក្តី ចំពោះនីតិវិធីបណ្តឹងចំនួនទឹកប្រាក់តិច (បញ្ញត្តិនីមួយៗ នៃគន្ថីទី ២ ជំពូកទី ៧) ។ ចំពោះចំណុចដែលពុំបានចែងនៅក្នុងជំពូកទី ៧ ត្រូវអនុវត្តតាមបញ្ញត្តិទូទៅដែលមានចែងរហូតដល់ជំពូកទី ៦ ។

រឿងក្តីដែលអាចប្រើនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចបាន គឺរឿងក្តីដែលមានគោលបំណងទាមទារឱ្យបង់ជាប្រាក់ ហើយដែលចំនួនទឹកប្រាក់នៃកម្មវត្ថុនៃបណ្តឹងនោះ មិនលើសពី ១ លាន រៀល (មាត្រា ២២៤ កថាខណ្ឌទី ១) ។

### កថាភាគទី ២ បញ្ញត្តិពិសេសស្តីពីនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច

១. បញ្ញត្តិពិសេសស្តីពីការដាក់ពាក្យធ្វើបណ្តឹង

នៅក្នុងនីតិវិធីនៃបណ្តឹងធម្មតា ការដាក់ពាក្យបណ្តឹងត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរទៅតុលាការ (មាត្រា ៧៥ កថាខណ្ឌទី ១) ប៉ុន្តែ ក្នុងនីតិវិធីបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច អាចដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់បានដែរ (មាត្រា ២២៥ កថាខណ្ឌទី ១) ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់ដើមចោទក្នុងកំណត់ហេតុ ហើយកំណត់ហេតុនេះ ត្រូវបានចាត់ទុកថាជាពាក្យបណ្តឹង (មាត្រា ២២៥ កថាខណ្ឌទី ៣) ។ នេះគឺដើម្បីឱ្យប្រជាជនដែលមិនចេះអក្សរក៏អាចទាមទារឱ្យតុលាការការពារសិទ្ធិរបស់ខ្លួនបាន ។

ម្យ៉ាងទៀត ពេលដែលដាក់ពាក្យបណ្តឹង ទោះជាដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរក៏ដោយ ឬ ដោយផ្ទាល់មាត់ក៏ដោយ ដើមចោទមិនចាំបាច់បញ្ជាក់អំពីខ្លឹមសារនៃសាលក្រមដែលខ្លួនទាមទារ ឬ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារទេ (សូមមើលមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ) គ្រាន់តែបង្ហាញឱ្យច្បាស់លាស់អំពីចំណុចសំខាន់ៗនៃវិវាទជាការគ្រប់គ្រាន់ (មាត្រា ២២៥ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ

ដើម្បីទាមទារឱ្យតុលាការធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្ដីតាមនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ដើមចោទត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីចំណុចនេះ នៅពេលដាក់ពាក្យបណ្ដឹង (មាត្រា ២២៤ កថាខណ្ឌទី ២) ។

២. បញ្ញត្តិពិសេសស្ដីពីការវិនិច្ឆ័យ

(១) ភាពមិនចាំបាច់មាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ចំពោះនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ហើយការវិនិច្ឆ័យ ត្រូវធ្វើនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ (សូមមើលមាត្រា ២៣៩) ។ រឿងក្ដីដែលត្រូវបានវិនិច្ឆ័យតាមនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ជាទូទៅ គឺជារឿងក្ដីដែលមានទំនាក់ទំនងអង្គហេតុមិនស្មុគស្មាញទេ ដូច្នេះ មិនចាំបាច់ធ្វើការរៀបចំចំណុចវិវាទ ឬ ភស្ដុតាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ។ ហេតុដូច្នេះ ពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ តុលាការត្រូវកំណត់ឱ្យបានឆាប់រហ័សនូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយកោះហៅភាគីទាំងសងខាង (មាត្រា ២២៨) ។

(២) ការចង្អុលបង្ហាញនូវនីតិវិធី

ពេលធ្វើការកោះហៅតាមកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវប្រគល់ទៅភាគីនូវលិខិតជាលាយលក្ខណ៍អក្សរ ដែលពន្យល់នូវអត្ថន័យនៃនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច (មាត្រា ២២៦ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត នៅពេលដំបូងនៃកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពន្យល់ភាគីនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ២២៦ កថាខណ្ឌទី ២ ចំណុចនីមួយៗ (មាត្រា ២២៦ កថាខណ្ឌទី ២) ។

(៣) គោលការណ៍នៃការជំនុំជម្រះតាមកាលបរិច្ឆេទតែមួយថ្ងៃ

ក្នុងនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ជាគោលការណ៍ តុលាការត្រូវបញ្ចប់នូវការជំនុំជម្រះ នៅកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ២២៩ កថាខណ្ឌទី ១) ។ មានន័យថា ជាគោលការណ៍ កាលបរិច្ឆេទសម្រាប់ធ្វើការវិនិច្ឆ័យ មានតែមួយដងប៉ុណ្ណោះ ។ នេះគឺជាគោលគំនិតដែលឱ្យធ្វើនីតិវិធី ដោយសង្ខេប និង ឱ្យបានឆាប់រហ័ស ។ ដោយសារតែមានការចាំបាច់ធ្វើការវិនិច្ឆ័យ តាមកាលបរិច្ឆេទតែមួយ ក្នុងនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ចុងចម្លើយមិនអាចប្ដឹងតបបានទេ (មាត្រា ២២៧) ។

(៤) ការកម្រិតនូវការពិនិត្យភស្ដុតាង ជាអាទិ៍

ការពិនិត្យភស្ដុតាង អាចធ្វើបានចំពោះតែភស្ដុតាងដែលអាចពិនិត្យបានភ្លាមៗប៉ុណ្ណោះ (មាត្រា ២៣១) ។ ពេលធ្វើការស្នើសុំឱ្យធ្វើការសាកសួរសាក្សី ភាគីមិនចាំបាច់ដាក់ឯកសារដែលកំណត់អំពីចំណុចត្រូវសាកសួរទេ (មាត្រា ២៣២ កថាខណ្ឌទី ១, ហើយក្រៅពីនេះ សូមមើលមាត្រា ១៣៨ កថាខណ្ឌទី ២) គឺ គ្រាន់តែនាំសាក្សីទៅចូលរួមក្នុងកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយស្នើសុំឱ្យធ្វើការសាកសួរ

សាក្សីដោយផ្ទាល់មាត់ពេលនោះបានហើយ ។ តុលាការអាចធ្វើការសាកសួរសាក្សី ដោយមិនចាំបាច់ឱ្យអ្នកនោះធ្វើសម្បថបាន ( មាត្រា ២៣២ កថាខណ្ឌទី ២) ។

៣. បញ្ញត្តិពិសេសស្តីពីសាលក្រម

(១) ភាពមិនមានការចាំបាច់ដាច់ខាតក្នុងការធ្វើលិខិតសាលក្រម

ជាគោលការណ៍ តុលាការត្រូវប្រកាសសាលក្រមភ្លាមៗ ក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ ( មាត្រា ២៣៦ កថាខណ្ឌទី ១) ។ ក្នុងករណីនេះ តុលាការអាចប្រកាសសាលក្រម ដោយប្រាប់សេចក្តីសម្រេចបញ្ចប់ និង ខ្លឹមសារនៃសំអាងហេតុបាន ( មាត្រា ២៣៦ កថាខណ្ឌទី ២) ដោយមិនចាំបាច់ធ្វើលិខិតសាលក្រម ( មាត្រា ១៨៨ និង ១៨៩) ។ ក្នុងករណីនេះ តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីឱ្យធ្វើកំណត់ហេតុជំនួសលិខិតសាលក្រម ( មាត្រា ២៣៦ កថាខណ្ឌទី ៣) ។ នៅក្នុងសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ឬ កំណត់ហេតុជំនួសសាលក្រម ត្រូវសរសេរថាជាសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ( មាត្រា ២៣៦ កថាខណ្ឌទី ៤) ។

(២) ការពន្យារពេល និង ការកំណត់នូវការសងបណ្តើរៗ ក្នុងសាលក្រម

ក្នុងករណីដែលតុលាការចេញសាលក្រមទទួលស្គាល់នូវការទាមទារ ហើយប្រសិនបើយល់ឃើញថា ចាំបាច់ពិសេស ដោយគិតពិចារណានូវលទ្ធភាពទ្រព្យធនរបស់ចុងចម្លើយ ជាដើម តុលាការអាចកំណត់នូវពេលត្រូវបង់ប្រាក់ ឬ អាចកំណត់ការបង់ប្រាក់ដោយកាត់សងបណ្តើរៗ ក្នុងគោលបំណងពន្យារពេល ក្នុងអំឡុងពេលមិនលើសពី ៣ ឆ្នាំ បន្ទាប់ពីថ្ងៃដែលតុលាការប្រកាសសាលក្រមបាន ( មាត្រា ២៣៧ កថាខណ្ឌទី ១ ចំណុច ក និង ចំណុច ខ) ។ ម្យ៉ាងទៀត ព្រមជាមួយនឹងការកំណត់ទាំងនេះ តុលាការអាចកំណត់ថា ប្រសិនបើចុងចម្លើយបង់ប្រាក់តាមពេលវេលាដែលបានកំណត់ ឬ បង់ប្រាក់ដោយកាត់សងបណ្តើរៗតាមការកំណត់នេះ ចុងចម្លើយនឹងត្រូវបានអនុគ្រោះចំពោះកាតព្វកិច្ចនៃការសងប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ ដែលកើតឡើងក្រោយពេលដាក់ពាក្យបណ្តឹងបាន ( មាត្រា ២៣៧ កថាខណ្ឌទី ១ ចំណុច គ) ។ ប៉ុន្តែ នៅពេលកំណត់នូវការបង់ប្រាក់ដោយកាត់សងបណ្តើរៗ តុលាការត្រូវកំណត់អំពីការបាត់បង់ផលប្រយោជន៍នៃពេលកំណត់ ក្នុងករណីដែលចុងចម្លើយមិនសង ( មាត្រា ២៣៧ កថាខណ្ឌទី ២) ។ ក្នុងបណ្តឹងចំនួនទឹកប្រាក់តិច គោលបំណងដែលទទួលស្គាល់ឱ្យតុលាការអាចចេញសាលក្រមដែលផ្លាស់ប្តូរខ្លឹមសារនៃសិទ្ធិតាមផ្លូវច្បាប់សារធាតុ ដែលជាកម្មវត្ថុនៃបណ្តឹងដូចនេះបាន គឺ ប្រសិនបើចុងចម្លើយអាចអនុវត្តដោយស្ម័គ្រចិត្តបានដោយងាយស្រួល នូវកាតព្វកិច្ចដែលត្រូវបានទទួលស្គាល់ដោយសាលក្រម នេះក៏ជាផលប្រយោជន៍សម្រាប់ដើមចោទដែរ ។

(៣) បណ្តឹងឧបាស្រ័យចំពោះសាលក្រម

ចំពោះសាលក្រមចុងក្រោយនៃរឿងក្តីចំនួនទឹកប្រាក់តិច ភាគីមិនអាចប្តឹងឧបាស្រ័យបានឡើយ លើកលែងតែការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ( មាត្រា ២៣៨) ។ នេះគឺដោយសារតែមានគោលបំណងឱ្យមាន

ការជួយសង្គ្រោះសិទ្ធិដោយងាយស្រួល និង ឱ្យបានឆាប់រហ័យ តាមរយៈនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ។

## កថាភាគទី ៣ ទំនាក់ទំនងរវាងនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច និង នីតិវិធីធម្មតា

១. នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច និង ការជ្រើសរើសដោយភាគី

នីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច គឺជានីតិវិធីងាយស្រួល និង ឆាប់រហ័សដែលស្រួលប្រើប្រាស់សម្រាប់ប្រជាជនទូទៅ ក៏ប៉ុន្តែ មានការកម្រិតនូវការធានាសិទ្ធិមូលដ្ឋានរបស់ភាគីចំពោះនីតិវិធី ឱ្យតិចជាងនីតិវិធីបណ្តឹងធម្មតា ដូចជា ការវិនិច្ឆ័យ ជាគោលការណ៍ ត្រូវធ្វើតែមួយកាលបរិច្ឆេទប៉ុណ្ណោះ ភស្តុតាងដែលអាចដាក់បានមានការកម្រិត ឬ ជាគោលការណ៍ មិនអាចប្តឹងឧបាស្រ័យបានចំពោះសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ជាដើម ។ ដូច្នេះ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី មានត្រៀមនូវនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចសម្រាប់រឿងក្តីទាមទារឱ្យសងទឹកប្រាក់តិច ក៏ប៉ុន្តែ តើចង់ប្រើនីតិវិធីនេះ ឬ ប្រើនីតិវិធីធម្មតា គឺជាជម្រើសរបស់ភាគី ។

ជាបឋម ចំពោះរឿងក្តីទាមទារឱ្យបង់ប្រាក់ដែលមានចំនួនមិនលើសពី ១ លានរៀល ពេលដាក់ពាក្យបណ្តឹង ដើមចោទអាចជ្រើសរើសដោយសេរីបាន នូវការទាមទារឱ្យវិនិច្ឆ័យ និង សម្រេចសេចក្តីដោយនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ឬ ក៏ទាមទារឱ្យវិនិច្ឆ័យ និង ចេញសាលក្រមដោយនីតិវិធីធម្មតា ។ ទោះបីជារឿងក្តីទាមទារឱ្យសងប្រាក់ចំនួនតិចក៏ដោយ ប្រសិនបើដើមចោទចង់ឱ្យតុលាការវិនិច្ឆ័យដោយប្រុងប្រយ័ត្ន តាមនីតិវិធីបណ្តឹងធម្មតា ដើមចោទនោះអាចដាក់ពាក្យបណ្តឹងតាមនីតិវិធីបណ្តឹងធម្មតាបាន ។ ដូច្នេះហើយ ក្នុងករណីដែលដើមចោទជ្រើសរើសនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច ក្រមនេះបានចែងថា ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីជម្រើសនេះ ពេលដាក់ពាក្យបណ្តឹង ( មាត្រា ២២៤ កថាខណ្ឌទី ២) ។

ចំពោះរឿងក្តីទាមទារឱ្យបង់ប្រាក់មិនលើសពី ១ លានរៀល ប្រសិនបើអនុញ្ញាតឱ្យដើមចោទជ្រើសរើសនីតិវិធីបណ្តឹងធម្មតាបាន ដូចដែលបានពន្យល់ខាងលើនេះ នោះគួរតែអនុញ្ញាតឱ្យចុងចម្លើយអាចជ្រើសរើសដូចគ្នា ដើម្បីរក្សាសមភាពរវាងភាគីទាំងសងខាង ។ ហេតុដូច្នេះ ក្នុងករណីដែលចុងចម្លើយត្រូវបានប្តឹង តាមនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច ប្រសិនបើចុងចម្លើយមានគំនិតចង់ឱ្យតុលាការធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីដោយនីតិវិធីបណ្តឹងធម្មតា ចុងចម្លើយនោះអាចធ្វើសេចក្តីថ្លែងការណ៍ឱ្យផ្ទេរបណ្តឹងទៅនីតិវិធីធម្មតា មុនពេលធ្វើការទាញហេតុផលនៅកាលបរិច្ឆេទទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ( មាត្រា ២៣៣ កថាខណ្ឌទី ១) ។ ក្នុងករណីដែលមានសេចក្តីថ្លែងការណ៍បែបនេះ បណ្តឹងនោះត្រូវផ្ទេរទៅនីតិវិធីបណ្តឹងធម្មតានាពេលនោះ ( មាត្រា ២៣៥ កថាខណ្ឌទី ១) ។ ចំពោះវិធីនៃការធ្វើសេចក្តីថ្លែងការណ៍ និង ការជូនដំណឹងទៅឱ្យភាគីម្ខាងទៀត សូមមើលមាត្រា ២៣៣ កថាខណ្ឌទី ២ និង ទី ៣ ។

ហេតុនេះហើយ នីតិវិធីបណ្ដឹងចំនួនទឹកប្រាក់តិច ត្រូវបានអនុវត្តតែក្នុងករណីដែលទាំងដើមចោទ ទាំងចុងចម្លើយ បានជ្រើសរើសយកនីតិវិធីនេះ ។ នេះគឺដោយសារតែ ទោះជារឿងក្ដីចំនួនទឹកប្រាក់តិចក៏ដោយ នីតិវិធីបណ្ដឹងធម្មតា គឺជានីតិវិធីជាមូលដ្ឋាន ។

២. ការផ្ទេរបណ្ដឹងទៅនីតិវិធីធម្មតា ដោយដីកាសម្រេចរបស់តុលាការ

ទោះបីជាភាគីទាំងសងខាងបានជ្រើសរើសយកនីតិវិធីនៃរឿងក្ដីចំនួនទឹកប្រាក់តិចក៏ដោយ ក្នុងករណីដែលយល់ឃើញថា ①រឿងក្ដីនោះមិនអាចក្លាយជាកម្មវត្ថុនៃបណ្ដឹងចំនួនទឹកប្រាក់តិច តាមផ្លូវច្បាប់ ②ការកោះហៅចុងចម្លើយតាមកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ អាចធ្វើទៅបានដោយតែវិធីបញ្ជូនតាមការផ្សាយជាសាធារណៈប៉ុណ្ណោះ (ករណីនេះ អាចព្យាករបានថា ចុងចម្លើយពុំមានឱកាសនឹងប្រើសិទ្ធិជ្រើសរើសទេ) ③ការជំនុំជម្រះ និង សម្រេចសេចក្ដីតាមនីតិវិធីនៃបណ្ដឹងរឿងក្ដីទឹកប្រាក់តិច មិនសមរម្យដោយសាររឿងក្ដីនោះមានភាពស្មុគស្មាញ ជាដើម តុលាការត្រូវចេញដីកាសម្រេចថា ការជំនុំជម្រះ និងការសម្រេចសេចក្ដីលើបណ្ដឹងត្រូវធ្វើតាមនីតិវិធីធម្មតា (មាត្រា ២៣៤ កថាខណ្ឌទី ១) ។ ក្នុងករណីដែលមានដីកាសម្រេចនេះ បណ្ដឹងត្រូវបានផ្ទេរទៅនីតិវិធីបណ្ដឹងធម្មតា នាពេលចេញដីកាសម្រេចនោះ (មាត្រា ២៣៥ កថាខណ្ឌទី ១) ។

នេះគឺដោយសារតែ ទោះបីជាភាគីទាំងសងខាងចង់ធ្វើបណ្ដឹងតាមនីតិវិធីនៃរឿងក្ដីចំនួនទឹកប្រាក់តិចក៏ដោយ ប្រសិនបើយល់ឃើញថា គួរតែជំនុំជម្រះ និង សម្រេចសេចក្ដីដោយនីតិវិធីដែលមានការធានានូវសិទ្ធិមូលដ្ឋានចំពោះនីតិវិធី តុលាការត្រូវធ្វើការជំនុំជម្រះ និង សម្រេចសេចក្ដីដោយនីតិវិធីបណ្ដឹងធម្មតា ។

# គន្ថីទី ៤ នីតិវិធីនៃការជំនុំជម្រះនៅតុលាការជាន់ខ្ពស់

## ជំពូកទី ១ អត្ថន័យនៃបណ្តឹងឧទ្ធរណ៍ទៅតុលាការជាន់ខ្ពស់

### ១. ទស្សនៈនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាវិធីធ្វើឧបាស្រ័យទាមទារដោយភាគី ទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬ ផ្លាស់ប្តូរនូវសេចក្តីសម្រេច (សាលក្រម សាលដីកា ឬ ដីកាសម្រេច) ដែលចេញដោយតុលាការថ្នាក់ក្រោម នៅមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ (មាត្រា ២៥៩) ។ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អាចធ្វើទៅបាន តែមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរតែប៉ុណ្ណោះ ។ ពេលដែលមានបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ សេចក្តីសម្រេចដើមមិនចូលជាស្ថាពរ រហូតដល់ដំណើរការឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះបានបញ្ចប់ (មាត្រា ១៩៣ កថាខណ្ឌទី ២) ។ ផ្ទុយទៅវិញ គេអាចនិយាយបានថា ការចូលជាស្ថាពរនៃសេចក្តីសម្រេចមួយ គឺជាស្ថានភាពមួយដែលសេចក្តីសម្រេចនោះ មិនអាចធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (មាត្រា ៣០៧ និង មាត្រា ៣១៧) គឺជាការប្តឹងឧបាស្រ័យ ចំពោះសាលក្រមដែលបានចូលជាស្ថាពរហើយ ហេតុដូច្នេះ មិនមែនជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ ។

### ២. គោលបំណងនៃរបបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

ដរាបណាការសម្រេចសេចក្តីធ្វើឡើងដោយមនុស្ស ការវិនិច្ឆ័យខុស ឬ ការភ័ន្តច្រឡំតែងកើតមានដោយជៀសមិនរួច ។ ក៏ប៉ុន្តែ ប្រសិនបើទុកឱ្យស្ថានភាពនៅតែដូច្នេះ កំហុសនោះ គឺមិនត្រឹមតែបំពានសិទ្ធិរបស់ភាគីប៉ុណ្ណោះទេ គឺធ្វើឱ្យបាត់នូវជំនឿទុកចិត្តចំពោះប្រព័ន្ធតុលាការនោះតែម្តង ។ ដូច្នេះហើយ ចាំបាច់ត្រូវមាននូវប្រព័ន្ធមួយ ដែលតាមរយៈនោះ តុលាការជាន់ខ្ពស់អាចនឹងពិនិត្យមើលនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន តាមពាក្យសុំរបស់ភាគីម្ខាងដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចនោះ ហើយប្រសិនបើសេចក្តីសម្រេចថ្នាក់ក្រោមនោះ មិនត្រឹមត្រូវ តុលាការថ្នាក់ខ្ពស់ជាងនោះ អាចធ្វើការកែប្រែ ឬ លុបចោលនូវសេចក្តីសម្រេចនោះបាន ។ នេះគេហៅថា "របបប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់" ។ ដោយសាររបបប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាប្រព័ន្ធមួយដែលតុលាការជាន់ខ្ពស់កែតម្រូវនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយរង់ចាំពាក្យសុំឧបាស្រ័យ ហេតុដូច្នេះ យើងអាចហៅផងដែរថា របបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាយន្តការមួយសម្រាប់ធ្វើការសង្គ្រោះសិទ្ធិភាគីឱ្យរួចផុតពីឥទ្ធិពលនៃការវិនិច្ឆ័យខុស ឬ កំហុសក្នុងនីតិវិធីនៃការជំនុំជម្រះ ។

ម្យ៉ាងទៀត តាមរយៈការអនុញ្ញាតឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានរឿងក្តីជាច្រើនដែលត្រូវបានពិនិត្យ និង ធ្វើការជំនុំជម្រះសារឡើងវិញ ដោយតុលាការជាន់ខ្ពស់មួយចំនួនតូច ហើយចុងបំផុត

គឺត្រូវជម្រះដោយតុលាការជាន់ខ្ពស់ដែលមានតែមួយចុងក្រោយគេ គឺតុលាការកំពូល ។ ជាលទ្ធផល ការបកស្រាយ និង អនុវត្តច្បាប់តែមួយផ្សេងៗគ្នា នៅតុលាការជាន់ទាបដ៏ច្រើននោះ នឹងត្រូវបានបង្រួបបង្រួមឱ្យក្លាយទៅជាការបកស្រាយ និង អនុវត្តតែមួយដោយតុលាការកំពូល ។ ក្នុងន័យនេះ ក្នុងការច្របាច់បញ្ចូលគ្នានូវប្រព័ន្ធជម្រះក្តី ដែលមានបីថ្នាក់ របបបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានតួនាទីធ្វើការរួមបញ្ចូលនូវការបកស្រាយច្បាប់នៃប្រទេសកម្ពុជា ហើយដោយសារប្រព័ន្ធនោះ គឺអាចធានានូវប្រព័ន្ធគតិយុត្តដែលប្រកបដោយស្ថិរភាព មានសណ្តាប់ធ្នាប់ និង ប្រកបដោយតុល្យភាព សម្រាប់ពលរដ្ឋកម្ពុជា ។

៣. ប្រភេទនៃបណ្តឹងឧបាស្រ័យ

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មាន ៣ ប្រភេទ គឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ និង បណ្តឹងជំទាស់ (មាត្រា ២៥៩ កថាខណ្ឌទី ១) ។ បណ្តឹងឧទ្ធរណ៍ និង បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម ឬ សាលដីកា (មាត្រា ២៥៩ កថាខណ្ឌទី ១ ចំណុច ក និង ខ) រីឯបណ្តឹងជំទាស់វិញ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេច (មាត្រា ២៥៩ កថាខណ្ឌទី ១ ចំណុច គ) ។

ដូចដែលបានរៀបរាប់ខាងលើនេះ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មានប្រភេទផ្សេងៗ ដោយបែងចែកតាមប្រភេទនៃសេចក្តីសម្រេចដើម ហេតុដូច្នេះ បុគ្គលដែលមានបំណងដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ត្រូវជ្រើសរើសប្រភេទនៃបណ្តឹងឧបាស្រ័យត្រឹមត្រូវ ដោយស្របទៅតាមប្រភេទនៃសេចក្តីសម្រេចដើម ។

## ជំពូកទី ២ បណ្ដឹងឧទ្ធរណ៍

### កថាភាគទី ១ ការធ្វើបណ្ដឹងឧទ្ធរណ៍

១. សេចក្ដីសម្រេចដែលអាចប្ដឹងឧទ្ធរណ៍បាន

បណ្ដឹងឧទ្ធរណ៍ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូង ។ ដូច្នេះ បណ្ដឹងឧទ្ធរណ៍អាចនឹងធ្វើឡើងបានតែចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ របស់សាលាដំបូងតែប៉ុណ្ណោះ ( មាត្រា ២៥៩ កថាខណ្ឌទី ១) ។ ចំពោះសាលក្រមរបៀប ( មាត្រា ១៨១) មិនអាចប្ដឹងឧទ្ធរណ៍ដោយឯករាជ្យបានឡើយ ។ ក៏ប៉ុន្តែ បណ្ដឹងឧទ្ធរណ៍មិនត្រូវបានអនុញ្ញាតឱ្យធ្វើ ប្រសិនបើក្រោយពេលចេញសាលក្រមចុងក្រោយនោះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថា មិនធ្វើការប្ដឹងឧទ្ធរណ៍ទេ ប៉ុន្តែ រក្សាទុកសិទ្ធិធ្វើបណ្ដឹងសាទុក្ខផ្ទាល់ទៅតុលាការកំពូលតែម្ដង (គេហៅថា ការព្រមព្រៀងផ្លោះទៅបណ្ដឹងសាទុក្ខ) ( មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ក និង កថាខណ្ឌទី ២ ក្នុងករណីនេះ បណ្ដឹងសាទុក្ខអាចធ្វើបាន) ឬ ប្រសិនបើសាលក្រមនោះជាសាលក្រមចុងក្រោយនៃរឿងក្ដីរដ្ឋប្បវេណី ឬ រឿងក្ដីពាណិជ្ជកម្ម ដែលមានតម្លៃកម្មវត្ថុនៃបណ្ដឹងមិនលើស ៥ លានរៀលទេនោះ ( មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ខ) ។ម្យ៉ាងទៀត បណ្ដឹងឧបាស្រ័យចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ដែលបានចេញក្នុងនាមជាការសម្រេចសេចក្ដីនៃការជំនុំជម្រះលើកទី ១ អាចប្ដឹងបានត្រឹមតែសាទុក្ខប៉ុណ្ណោះ ( មាត្រា ២៥៩ កថាខណ្ឌទី ១ ចំណុច ខ) ។ ចំពោះសេចក្ដីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្ដី មិនអាចប្ដឹងឧទ្ធរណ៍ដោយឯករាជ្យតែឯកឯងបានឡើយ ( មាត្រា ២៦១) ។

ម្យ៉ាងទៀត ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ ចេញសាលក្រមកំបាំងមុខ ( មាត្រា ២០០, មាត្រា ២០១) ទោះបីជាល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ២០៤ ត្រូវបានបំពេញក៏ដោយក៏ភាគីអាចលះបង់ផលប្រយោជន៍ក្នុងការបន្តឱ្យវិនិច្ឆ័យនៅថ្នាក់ដដែលដោយដាក់បណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ ហើយអាចប្ដឹងឧទ្ធរណ៍បានដែរ ។ ប្រសិនបើល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ២០៤ នោះ មិនត្រូវបានបំពេញ ភាគីមិនអាចប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខបានឡើយ ហេតុដូច្នេះបណ្ដឹងឧទ្ធរណ៍ គឺជាវិធីតែមួយនៃបណ្ដឹងឧបាស្រ័យចំពោះសាលក្រមកំបាំងមុខនោះ ។

២. សិទ្ធិប្ដឹងឧទ្ធរណ៍

ដើមចោទ ឬ ចុងចម្លើយដែលបាត់បង់នូវផលប្រយោជន៍ដោយសារតែសាលក្រមនៃការជំនុំជម្រះលើកទី ១ មានសិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ ។ ការណ៍ដែលបាត់បង់នូវផលប្រយោជន៍នោះ ត្រូវហៅថា មានផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យ ។ ជាគោលការណ៍ បើយកខ្លឹមសារនៃសាលក្រមដែលដើមចោទ ឬ ចុងចម្លើយនៃការជំនុំជម្រះលើកទី ១ ដែលប្ដឹងឧទ្ធរណ៍ បានទាមទារឱ្យតុលាការចេញ នៅក្នុងការជំនុំជម្រះលើកទី ១ មក

ប្រៀបធៀបជាមួយនឹងសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយក្នុងករណីដែលសាលក្រមនោះ មានទំហំតូច ជាងការទាមទាររបស់ភាគីនោះ ទើបផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យ ត្រូវបានទទួលស្គាល់ ។ ហេតុដូច្នេះ ជាគោលការណ៍ ភាគីដែលឈ្នះក្ដីទាំងស្រុងនៅក្នុងការជំនុំជម្រះលើកទី ១ គ្មានផលប្រយោជន៍ក្នុងការប្ដឹង ឧបាស្រ័យ មានន័យថា គ្មានសិទ្ធិប្ដឹងឧទ្ធរណ៍ទេ ។ ប្រសិនបើភាគីនោះប្ដឹងឧទ្ធរណ៍ បណ្ដឹងឧទ្ធរនោះនឹងត្រូវបាន លើកចោល ដោយសារបណ្ដឹង ឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយនឹងច្បាប់ ។

សិទ្ធិប្ដឹងឧទ្ធរណ៍ មិនអាចកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងជាមុនរវាងភាគីសងខាងថា មិនប្ដឹង ឧទ្ធរណ៍ ។ ការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍នេះ មានលក្ខណៈខុសពីការព្រមព្រៀងផ្លោះទៅបណ្ដឹងសាទុក្ខ គឺ បិទសិទ្ធិប្ដឹងសាទុក្ខផងដែរ ។ ហេតុដូច្នេះ ប្រសិនបើការព្រមព្រៀងមិនប្ដឹងឧទ្ធរណ៍ ត្រូវបានបង្កើតឡើង ដោយមានសុពលភាព សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវចូលជាស្ថាពរ នៅពេលដែលប្រកាស សាលក្រមនោះ ។

សិទ្ធិប្ដឹងឧទ្ធរណ៍នឹងកើតឡើងចំពោះបុគ្គលដែលរៀបរាប់ខាងលើនោះ ដោយការប្រកាសសាលក្រមនៃការ ជំនុំជម្រះលើកទី ១ ។ ប៉ុន្តែ ក្រោយពេលសិទ្ធិប្ដឹងឧទ្ធរណ៍កើលឡើង ភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ អាច លះបង់នូវសិទ្ធិនេះបានដែរ ( មាត្រា ២៦៣ កថាខណ្ឌទី ១) ។ ការលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ ត្រូវធ្វើឡើងតាម សេចក្ដីថ្លែងការណ៍ ។ ប្រសិនបើភាគីលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍ក្រោយពេលដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ សេចក្ដី ថ្លែងការណ៍អំពីការលះបង់សិទ្ធិប្ដឹងឧទ្ធរណ៍នោះ ត្រូវធ្វើឡើងជាមួយគ្នានឹងការដកពាក្យបណ្ដឹងឧទ្ធរណ៍ ( មាត្រា ២៦៣ កថាខណ្ឌទី ២) ។

៣. អំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ ខែ ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិត សាលក្រម នៃការជំនុំជម្រះលើកទី ១ ឬ ពីថ្ងៃដែលដីកាសម្រេចច្រានចោល ឬ លើកចោល ( មាត្រា ២០៧ កថាខណ្ឌទី ២) នូវបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ( មាត្រា ២០៤) ត្រូវបានជូនដំណឹង ( មាត្រា ២៦៤ កថាខណ្ឌទី ១) ។ ចំពោះសាលក្រមកំបាំងមុខ ប្រសិនបើអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ ត្រូវគណនា ដោយ គិតពីថ្ងៃដែលទទួលនូវការបញ្ជូននៃលិខិតសាលក្រមកំបាំងមុខ ក្នុងករណីដែលភាគីបានប្ដឹងទាស់ ដោយគិតថា អាចប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ ( មាត្រា ២០៤) តែតុលាការលើកចោល ឬ ច្រានចោលពាក្យ បណ្ដឹងទាស់ នោះអាចមានករណីដែលមិនអាចប្ដឹងឧទ្ធរណ៍បាន ដោយសារអំឡុងពេល ១ ខែ បានកន្លងហួស ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃលិខិតសាលក្រមកំបាំងមុខនោះ ។ ហេតុដូច្នេះ អំឡុងពេល សម្រាប់ប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខ ត្រូវគណនា ដោយគិតពីថ្ងៃដែលទទួលការជូនដំណឹងអំពី ដីកាសម្រេចច្រានចោល ឬ លើកចោលនូវពាក្យបណ្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខនោះ ។

អំឡុងពេល ១ ខែនេះ មិនអាចពន្យារបានឡើយ ( មាត្រា ២៦៤ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ក្នុងករណី

ដែលភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ មិនអាចប្ដឹងឧទ្ធរណ៍បានក្នុងអំឡុងពេលនេះ ដោយមូលហេតុដែលមិនមែនជាកំហុសរបស់ខ្លួនទេ ភាគីនោះអាចបំពេញនូវសកម្មភាពបណ្ដឹងពេលក្រោយបាន ក្នុងអំឡុងពេល ១ សប្ដាហ៍ក្រោយពីមូលហេតុនោះបានរលត់ហើយ (មាត្រា ២៤៥) ។ ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ក្នុងករណីនេះ ភាគីគ្រាន់តែដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ជាធម្មតា ក្នុងអំឡុងពេលមួយសប្ដាហ៍គិតពីថ្ងៃដែលហេតុដែលនាំឱ្យខកខាននោះបានរលត់ និង ភាគីត្រូវធ្វើការអះអាង និង បញ្ជាក់ដោយភស្តុតាងថា ការមិនអាចធ្វើបណ្ដឹងឧទ្ធរណ៍ ក្នុងអំឡុងពេលកំណត់នោះបាន មិនមែនដោយសារកំហុសរបស់ខ្លួនទេ ជាការគ្រប់គ្រាន់ ។

ប្រសិនបើអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍កន្លងហួស ភាគីដែលមានសិទ្ធិប្ដឹងឧទ្ធរណ៍ បាត់បង់សិទ្ធិនោះ ។ ហេតុដូច្នេះ ប្រសិនបើពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ ក្រោយអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍កន្លងហួស បណ្ដឹងឧទ្ធរណ៍នោះ នឹងត្រូវបានលើកចោលដោយសាលដីកា ដោយសារបណ្ដឹងឧទ្ធរណ៍នោះមានលក្ខណៈផ្ទុយនឹងច្បាប់ (មាត្រា ២៦៨) ។ ម្យ៉ាងទៀត ក្រោយពេលសាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រូវបានប្រកាស ទោះបីជាមិនទាន់ទទួលការបញ្ជូនសាលក្រមក៏ដោយ ក៏ភាគីអាចប្ដឹងឧទ្ធរណ៍ដោយស្របច្បាប់បានដែរ (មាត្រា ២៦៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

៤. របៀបធ្វើបណ្ដឹងឧទ្ធរណ៍

ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ (មាត្រា ២៦៥ កថាខណ្ឌទី ១) ។ នៅក្នុងពាក្យបណ្ដឹងឧទ្ធរណ៍ ក្រៅពីឈ្មោះ (ឬ នាមករណ៍) និង អាសយដ្ឋានរបស់ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ ភាគីត្រូវសរសេរនូវសញ្ញាណសាលក្រមនៃការជំនុំជម្រះលើកតី ១ និង សេចក្ដីដែលប្ដឹងឧបាស្រ័យចំពោះសាលក្រមនោះ (មាត្រា ២៦៥ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ជាការល្អ នៅក្នុងពាក្យបណ្ដឹងឧទ្ធរណ៍ គួរតែសរសេរឱ្យបានក្បោះក្បាយអំពីមូលហេតុដែលទាមទារឱ្យលុបចោល ឬ ឱ្យផ្លាស់ប្ដូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ (មាត្រា ២៦៥ កថាខណ្ឌទី ៣) ។ ប្រសិនបើមិនបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារនោះទេ អ្នកធ្វើបណ្ដឹងឧទ្ធរណ៍ត្រូវដាក់លិខិតជាលាយលក្ខណ៍អក្សរដែលសរសេរអំពីមូលហេតុនោះ ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍នេះ (មាត្រា ២៦៥ កថាខណ្ឌទី ៣) ។ ពាក្យបណ្ដឹងឧទ្ធរណ៍នេះត្រូវដាក់ទៅតុលាការដើមដែលបានធ្វើការជំនុំជម្រះលើកទី ១ (មាត្រា ២៦៥ កថាខណ្ឌទី ១) ។ ពេលដែលបានទទួលពាក្យបណ្ដឹងឧទ្ធរណ៍នេះ តុលាការនៃការជំនុំជម្រះលើកទី ១ ត្រូវផ្ញើពាក្យបណ្ដឹងឧទ្ធរណ៍នេះ និង សំណុំរឿងទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ឱ្យបានឆាប់រហ័ស (មាត្រា ២៦៥ កថាខណ្ឌទី ១) ។

ពេលដែលបានទទួលពាក្យបណ្ដឹងឧទ្ធរណ៍ហើយ តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍នោះ ហើយប្រសិនបើពិនិត្យទៅឃើញថា មានចំណុចខ្វះខាត តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបង្គាប់ឱ្យភាគីធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងនោះ (មាត្រា ២៦៦ កថាខណ្ឌទី ១) ។ បើទោះជាមានការបង្គាប់ឱ្យ

កែតម្រូវក៏ដោយ តែដើមបណ្តឹងឧទ្ធរណ៍មិនព្រមកែតម្រូវទេ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវលើកចោលពាក្យបណ្តឹងឧទ្ធរណ៍នោះ ដោយដីកាសម្រេច ( មាត្រា ២៦៦ កថាខណ្ឌទី ២) ។ ចំណុចនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលដើមបណ្តឹងឧទ្ធរណ៍មិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្តឹងឧទ្ធរណ៍នោះ ( មាត្រា ២៦៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ប្រសិនបើពាក្យបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រឡាបញ្ជីត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នោះទៅឱ្យចុងបណ្តឹងឧទ្ធរណ៍ ( មាត្រា ២៦៧ កថាខណ្ឌទី ១) ។ ក្នុងករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍ (រាប់បញ្ចូលនូវករណីដែលភាគីមិនបានបង់ប្រាក់ប្រដាប់ក្តីដែលចាំបាច់ដើម្បីបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍) ត្រូវអនុលោមទៅតាមករណីដែលពាក្យបណ្តឹងឧទ្ធរណ៍មិនត្រឹមត្រូវតាមទម្រង់ច្បាប់ ( មាត្រា ២៦៦) ( មាត្រា ២៦៧ កថាខណ្ឌទី ២) ។

### ៥. អានុភាពនៃការដាក់ពាក្យបណ្តឹង

#### (១) អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម

ពេលដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើ ក្នុងអំឡុងពេលដែលកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍ ទោះជាអំឡុងពេលដែលកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍នោះបានកន្លងផុតទៅហើយក៏ដោយ ក៏សាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) មិនចូលជាស្ថាពរដែរ ( មាត្រា ១៩៣ កថាខណ្ឌទី ២) ។ នេះគេហៅថា "អានុភាពបង្អាក់នូវការចូលជាស្ថាពរនៃការប្តឹងឧទ្ធរណ៍" ។ ប្រសិនបើសាលក្រមដើម មិនភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ( មាត្រា ១៩៦) អានុភាពអនុវត្ត ក៏មិនត្រូវកើតឡើងឡើយ (សូមមើលមាត្រា ១៩៥) ។

#### (២) អានុភាពនៃការផ្ទេរការជម្រះក្តី

ពេលដែលមានបណ្តឹងឧទ្ធរណ៍ ការចាត់ការនៃការទាមទារដែលបានជំនុំជម្រះក្នុងសាលក្រមដើមត្រូវផ្ទេរពីសាលាជំនុំជម្រះលើកទី ១ ទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ ។ នេះគេហៅថា "អានុភាពនៃការផ្ទេរការជម្រះក្តីដោយបណ្តឹងឧទ្ធរណ៍" ។ ដោយសារអានុភាពនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវវិនិច្ឆ័យអំពីការទាមទារនោះ ។

#### (៣) ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍

ថ្វីបើដើមបណ្តឹងឧទ្ធរណ៍ប្តឹងឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រមដើមក៏ដោយ ក៏ "អានុភាពនៃការបង្អាក់នូវការចូលជាស្ថាពរនៃសាលក្រម" និង "អានុភាពនៃការផ្ទេរការជម្រះក្តី" កើតមានឡើង ចំពោះការទាមទារទាំងអស់ដែលបានសម្រេចនៅក្នុងសាលក្រមដើមដែរ ។ នេះគេហៅថា "ភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍" ។ ដូច្នេះ នៅពេលមានបណ្តឹងឧទ្ធរណ៍ ដោយហេតុថាសាលក្រមដើមត្រូវបានរាំងនូវអានុភាពចូលជាស្ថាពរ ហើយសូម្បីតែផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍បានឈ្នះក្តី ក៏ត្រូវបានបង្អាក់មិនឱ្យចូលជាស្ថាពរដែរនោះ ដើមបណ្តឹងឧទ្ធរណ៍ មិនអាចនឹងធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមដើមបានទេ ប្រសិនបើមិនមានការប្រកាសឱ្យធ្វើការអនុវត្តជាបណ្តោះអាសន្ន ទៅលើផ្នែកដែលខ្លួនឈ្នះនៅក្នុងសាលក្រមទេនោះ ។ ឧទាហរណ៍ថា ដើមចោទបានប្តឹងមួយដោយរួមបញ្ចូលនូវការទាមទារឱ្យសងប្រាក់កំចីចំនួន ១០ លានរៀល និង ការទាមទារ

ឱ្យបញ្ជាក់អំពីកម្មសិទ្ធិនៃអចលនវត្ថុមួយហើយ ចុងចម្លើយបានដាក់បណ្តឹងតបដែលទាមទារឱ្យបញ្ជាក់ថា ខ្លួនមានកម្មសិទ្ធិលើអចលនវត្ថុដដែលនោះ ពេលនោះតុលាការសម្រេចទទួលស្គាល់សិទ្ធិលើបំណុល ១០ លានរៀលរបស់ដើមចោទ តែច្រានចោលនូវការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិលើអចលនវត្ថុរបស់ដើមចោទនោះ ហើយសម្រេចទទួលស្គាល់នូវការទាមទារនៃបណ្តឹងតបរបស់ចុងចម្លើយ ។ ក្នុងករណីបែបនេះ ប្រសិនបើដើមចោទដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ដោយធ្វើឧបាស្រ័យចំពោះផ្នែកដែលច្រានចោលនូវការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិរបស់ខ្លួន និង ផ្នែកដែលទទួលស្គាល់ការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិរបស់ចុងចម្លើយនោះ សាលក្រមទាំងមូលដែលមានខ្លឹមសារបីចំណុចនោះនឹងត្រូវរារាំងនូវការចូលជាស្ថាពរ ហើយត្រូវផ្ទេរទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ជាលទ្ធផល ដើមចោទមិនអាចធ្វើការអនុវត្តសិទ្ធិទាមទារឱ្យចុងចម្លើយសងប្រាក់កំចី ដោយផ្អែកលើសាលក្រមដើមនោះបានទេ ។ ក៏ប៉ុន្តែ ប្រសិនបើចុងចម្លើយ មិនធ្វើឧបាស្រ័យចំពោះការទាមទារឱ្យសងប្រាក់កំចីនេះទេ ដើមចោទអាចដាក់ពាក្យសុំទៅតុលាការនៃបណ្តឹងឧទ្ធរណ៍ សុំឱ្យប្រកាសនូវការអនុវត្តជាបណ្តោះអាសន្នទៅលើតែផ្នែកនៃសិទ្ធិលើបំណុលដែលសម្រេចដោយសាលក្រមដើមបាន ( មាត្រា ២៧១ កថាខណ្ឌទី ១) បើធ្វើដូច្នោះទោះបីជា សាលក្រមនោះមិនទាន់ចូលជាស្ថាពរក៏ដោយ ក៏អាចអនុវត្តដោយបង្ខំបានដែរ ។

ម្យ៉ាងទៀត ក្នុងចំណោមសាលក្រមដើម ចំពោះផ្នែកដែលដើមបណ្តឹងឧទ្ធរណ៍មិនបានធ្វើឧបាស្រ័យ ភាគីមិនចាំបាច់ធ្វើការទាញហេតុផល ( មាត្រា ២៧២ កថាខណ្ឌទី ១) ហើយតុលាការក៏មិនអាចផ្លាស់ប្តូរការវិនិច្ឆ័យអំពីផ្នែកនោះនៅក្នុងសាលក្រមដើម (មាត្រា ២៧៨) ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ ក៏ការវិនិច្ឆ័យអំពីផ្នែកនោះនៅក្នុងសាលក្រមដើម មិនត្រូវចូលជាស្ថាពរដោយឯកឯងឡើយ ។ ប៉ុន្តែ ក្នុងករណីដែលមានការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍ ចំពោះផ្នែកណាមួយនៃការទាមទារ ឬ ភាគីសងខាងលះបង់សិទ្ធិប្តឹងឧទ្ធរណ៍ និង សិទ្ធិប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ (ដែលមានការពន្យល់នៅខាងក្រោម) ចំពោះផ្នែកណាមួយនៃការទាមទារ នោះផ្នែកនោះនៃសាលក្រមដើម ត្រូវចូលជាស្ថាពរ ។

### ៦. ការដកពាក្យបណ្តឹងឧទ្ធរណ៍

ពាក្យបណ្តឹងឧទ្ធរណ៍អាចដកវិញបាន រហូតដល់ពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបានចេញ ( មាត្រា ២៦៩ កថាខណ្ឌទី ១) ។ ការដកពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ប៉ុន្តែ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្តឹងឧទ្ធរណ៍ អាចធ្វើដោយផ្ទាល់មាត់បាន ( មាត្រា ២៦៩ កថាខណ្ឌទី ២) ។ ការដកពាក្យបណ្តឹងឧទ្ធរណ៍មួយផ្នែក គឺ មោឃៈ ដោយសារគោលការណ៍នៃភាពអវិភាគនៃបណ្តឹងឧទ្ធរណ៍ ។

តាមរយៈការដកពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងឧទ្ធរណ៍ ត្រូវបានចាត់ទុកថា មិនបានចាត់ការនៅតុលាការនៃបណ្តឹងឧទ្ធរណ៍តាំងពីដំបូង ( មាត្រា ២៦៩ កថាខណ្ឌទី ៣) ។ ប្រសិនបើមានការដកពាក្យបណ្តឹងឧទ្ធរណ៍

សាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) ត្រូវចូលជាស្ថាពរ នៅពេលដែលអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍កន្លងហួស ។ ប្រសិនបើការដកពាក្យបណ្ដឹងឧទ្ធរណ៍នោះបានធ្វើឡើងក្រោយអំឡុងពេលដែលកំណត់សម្រាប់ធ្វើបណ្ដឹងឧទ្ធរណ៍ ពេលនោះសាលក្រមនៃតុលាការជំនុំជម្រះលើកទី ១ នឹងចូលជាស្ថាពរ ។

ដោយខុសពីការដកពាក្យបណ្ដឹង (មាត្រា ២៧១) ដែលជាការដកពាក្យសុំឱ្យតុលាការនៃការជំនុំជម្រះលើកទី ១ ចេញសាលក្រម ការដកពាក្យបណ្ដឹងឧទ្ធរណ៍ មិនមានឥទ្ធិពលអ្វីទៅលើសាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) ហើយមិនឱ្យមានការខូចផលប្រយោជន៍ដល់ចុងបណ្ដឹងឧទ្ធរណ៍ទេ ហេតុដូច្នេះ មិនចាំបាច់មានការយល់ព្រមពីចុងបណ្ដឹងឧទ្ធរណ៍ឡើយ (មាត្រា ២៦៩ មិនបានចែងថា "បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២១៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ" ទេ) ។ ក្រោយពេលដកពាក្យបណ្ដឹងឧទ្ធរណ៍ បើអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍មិនទាន់កន្លងផុតទេ ភាគីម្ខាងទៀត ព្រមទាំងដើមបណ្ដឹងឧទ្ធរណ៍ដែលបានដកពាក្យបណ្ដឹងឧទ្ធរណ៍ម្ដងហើយ ក៏អាចប្ដឹងឧទ្ធរណ៍បានដែរ ។

ប្រសិនបើភាគីសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ត្រូវចាត់ទុកថា ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ (មាត្រា ២៦៩ កថាខណ្ឌទី ៤) ដោយអនុលោមទៅតាមករណីនៃការដកពាក្យបណ្ដឹង (មាត្រា ២១៩) ។

## កថាភាគទី ២ ការប្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ

ដូចដែលបានពន្យល់រួចមកហើយ ពេលដែលមានបណ្ដឹងឧទ្ធរណ៍ ការទាមទារទាំងមូលដែលត្រូវបានវិនិច្ឆ័យដោយសាលក្រមនៃសាលាជម្រះក្ដីលើកទីមួយដែលត្រូវបានប្ដឹងឧបាស្រ័យ ត្រូវផ្ទេរទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ (ភាពអវិភាគនៃអានុភាពនៃការផ្ទេរការជម្រះក្ដី) ។ ដូច្នេះ ចុងបណ្ដឹងឧទ្ធរណ៍អាចឆ្លៀតឱកាសនេះដើម្បីធ្វើឧបាស្រ័យទាមទារឱ្យផ្លាស់ប្ដូរនូវភាគនៃសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលខ្លួនបាត់បង់នូវផលប្រយោជន៍ឱ្យទទួលបានប្រយោជន៍នោះវិញ (មាត្រា ២៧០) ។ នេះគេហៅថា "បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ" ។ នេះគឺជាយន្តការមួយការពារភាគីម្ខាង ពីការខាតបង់ប្រយោជន៍ពីស្ថានភាពដែលសាលក្រមនៃការជំនុំជម្រះលើកទី ១ បានទទួលស្គាល់នូវការទាមទារមួយភាគ ឬ ច្រានចោលនូវការទាមទារមួយភាគរបស់ដើមចោទ ហើយប្រសិនបើភាគីណាម្ខាងគិតឃើញថា បើភាគីម្ខាងទៀត ស្កប់ចិត្តនឹងសាលក្រមនោះ ខ្លួនក៏មិនប្ដឹងឧទ្ធរណ៍ដែរ ។ ឧទាហរណ៍ ក្នុងករណីខាងលើដដែល ចុងចម្លើយបានចាញ់ក្ដីចំពោះការទាមទារឱ្យសងប្រាក់កំចី ប៉ុន្តែចុងចម្លើយបានឈ្នះចំពោះការទាមទារឱ្យបញ្ជាក់កម្មសិទ្ធិអចលនវត្ថុ ។ ក្នុងករណីនេះ ប្រសិនបើចុងចម្លើយគិតថា បើដើមចោទស្កប់ចិត្តនឹងសាលក្រមនោះហើយមិនប្ដឹងឧទ្ធរណ៍ ខ្លួនក៏មិនធ្វើបណ្ដឹងឧទ្ធរណ៍ដែរ ក៏ប៉ុន្តែដើមចោទដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ បណ្ដឹងនោះគង់តែនឹងត្រូវបន្តទៅសាលាឧទ្ធរណ៍ដដែល ដូច្នេះហើយខ្លួនក៏អាចធ្វើបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំនេះឡើង ដើម្បីទាមទារឱ្យលុបចោលនូវភាគនៃសាលក្រមដើម ដែលទទួល

ស្គាល់នូវការទាមទារឱ្យសងប្រាក់កំចីបានដែរ ។ ហើយ ប្រសិនបើមិនមានយន្តការនេះទេ ចុងចម្លើយចាំបាច់ត្រូវតែធ្វើបណ្តឹងឧទ្ធរណ៍តែម្តងហើយ ក្រែងលោដើមចោទដាក់ពាក្យបណ្តឹងទៅឧទ្ធរណ៍ប្តឹងខ្លួន ។ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំក៏អាចធ្វើបានដែរ ទោះជាសិទ្ធិប្តឹងឧទ្ធរណ៍របស់ចុងបណ្តឹងឧទ្ធរណ៍បានរលត់ ដោយហេតុថា អំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍កន្លងផុតហើយក៏ដោយ (មាត្រា ២៧០ កថាខណ្ឌទី ១) ហើយក្នុងករណីបែបនោះ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំកាន់តែមានន័យថែមទៀត (អំឡុងពេលដែលកំណត់ឱ្យធ្វើបណ្តឹងឧទ្ធរណ៍មាន ១ ខែ ដោយគិតពីថ្ងៃដែលទទួលការបញ្ជូនលិខិតនៃសាលក្រមចំពោះភាគីនីមួយៗ ហេតុដូច្នេះ ថ្ងៃចុងក្រោយនៃអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ អាចខុសគ្នា ចំពោះភាគីម្នាក់ ទៅភាគីម្នាក់) ។

តាមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ទំហំនៃឧបាស្រ័យដែលត្រូវបានវិនិច្ឆ័យនៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ត្រូវបានពង្រីក ។ មានន័យថា តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវវិនិច្ឆ័យមិនមែនតែអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឧបាស្រ័យរបស់ដើមបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ គឺ ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឧបាស្រ័យរបស់ចុងបណ្តឹងឧទ្ធរណ៍ផងដែរ ។ ប្រសិនបើមានតែដើមបណ្តឹងឧទ្ធរណ៍ទេដែលធ្វើឧបាស្រ័យ តុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចផ្លាស់ប្តូរសាលក្រមដើម ដោយខូចខាតផលប្រយោជន៍ចំពោះដើមបណ្តឹងឧទ្ធរណ៍ ដោយហួសទំហំនៃសាលក្រមដើមបានឡើយ ("គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយខូចខាតផលប្រយោជន៍" ដែលមានការពន្យល់ខាងក្រោម) ប៉ុន្តែ ប្រសិនបើមានបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំពីចុងបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ អាចធ្វើការផ្លាស់ប្តូរយ៉ាងដូច្នោះបាន ។

ប៉ុន្តែ បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ គឺជាបណ្តឹងឧបាស្រ័យដែលត្រូវបានធ្វើឡើង ដោយឆ្លៀតឱកាសដែលមានបណ្តឹងឧទ្ធរណ៍ពីភាគីម្ខាងទៀត ហេតុដូច្នេះ បើពាក្យបណ្តឹងឧទ្ធរណ៍ត្រូវបានដក ឬ បណ្តឹងឧទ្ធរណ៍ត្រូវបានលើកចោល នោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំត្រូវបាត់បង់អានុភាព (មាត្រា ២៧០ កថាខណ្ឌទី ២) ។ ប៉ុន្តែ ប្រសិនបើបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ត្រូវបានធ្វើឡើង នៅក្នុងអំឡុងពេលដែលចុងបណ្តឹងឧទ្ធរណ៍អាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍បាន បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ត្រូវចាត់ទុកថាជាបណ្តឹងឧទ្ធរណ៍ឯករាជ្យ (មាត្រា ២៧០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ អាចធ្វើបានតែមុនពេលដែលការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ត្រូវបានបញ្ចប់ (មាត្រា ២៧០ កថាខណ្ឌទី ១) ។ ទោះបីជាចុងបណ្តឹងឧទ្ធរណ៍លះបង់សិទ្ធិប្តឹងឧទ្ធរណ៍ ឬ ទោះបីជាអំឡុងពេលសម្រាប់ប្តឹងឧទ្ធរណ៍ កន្លងហួសចំពោះចុងបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏ចុងបណ្តឹងឧទ្ធរណ៍នោះ អាចប្តឹងឧទ្ធរណ៍បន្ទាប់បន្សំបានដែរ (មាត្រា ២៧០ កថាខណ្ឌទី ១) ។

របៀបប្តឹងឧទ្ធរណ៍បន្ទាប់បន្សំ ត្រូវអនុលោមទៅតាមបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍ (មាត្រា ២៧០ កថាខណ្ឌទី ៣) ។ ហេតុដូច្នេះ ដើមបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ (ចុងបណ្តឹងឧទ្ធរណ៍) ត្រូវដាក់លិខិតពាក្យបណ្តឹងឧទ្ធរណ៍

បន្ទាប់បន្សំ រីឯតុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ហើយត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះ ទៅដើមបណ្តឹងឧទ្ធរណ៍ (សូមមើលមាត្រា ២៦៥ ដល់ មាត្រា ២៦៧) ។

## កថាភាគទី ៣ ការវិនិច្ឆ័យ និង ចេញសាលក្រមនៃតុលាការជំនុំជម្រះបណ្តឹងឧទ្ធរណ៍

### ១. ការជំនុំជម្រះនៃតុលាការនៃបណ្តឹងឧទ្ធរណ៍

គោលបំណងចម្បងនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ គឺត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយជាមួយគ្នានោះដែរ ត្រូវពិនិត្យឡើងវិញទៅលើអង្គហេតុ និង អង្គច្បាប់ ចំពោះការទាមទារនៃការជំនុំជម្រះលើកទី ១ ទៅតាមទំហំដែលចាំបាច់ដើម្បីវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការប្តឹងឧបាស្រ័យនោះ ។ ក៏ប៉ុន្តែ តុលាការនៃបណ្តឹងឧទ្ធរណ៍ នឹងមិនចាត់ការរឿងក្តីសាជាថ្មីឡើងវិញទាំងស្រុងតាំងពីដំបូងមក ដោយមិនគិតដល់ការជំនុំជម្រះលើកទី ១ នោះទេ ប៉ុន្តែ នឹងបន្តការជំនុំជម្រះនោះ ដោយផ្អែកលើធនធានដែលបានប្រមូលនៅក្នុងការជំនុំជម្រះលើកទី ១ និង បន្ថែមនូវធនធានថ្មីៗផ្សេងទៀត ហើយបន្ទាប់មក នឹងវិនិច្ឆ័យថាតើគួររក្សាទុកនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ បានដែរឬអត់ (ប្រព័ន្ធនៃការជំនុំជម្រះបន្ត) ។

នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃឧបាស្រ័យចំពោះសាលក្រមដើម ហើយទំហំនៃឧបាស្រ័យនោះ ត្រូវបានកំណត់ដោយដើមបណ្តឹងឧទ្ធរណ៍ និង ចុងបណ្តឹងឧទ្ធរណ៍ ។ ឧបាស្រ័យដែលជាកម្មវត្ថុនៃការវិនិច្ឆ័យ គឺជាឧបាស្រ័យចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ ភាគីអាចធ្វើឧបាស្រ័យចំពោះសេចក្តីសម្រេចអំពីចំណុចដែលជាបុរេល័ក្ខខ័ណ្ឌសម្រាប់សាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី ១ ឬ ចំណុចទាក់ទងនឹងនីតិវិធី (ឧ. សាលក្រមរបៀប (មាត្រា ១៨១) ឬ ដីកាសម្រេចមិនអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬ បន្ថែមកម្មវត្ថុនៃបណ្តឹង (មាត្រា ៨៤ កថាខណ្ឌទី ៤) ជាអាទិ៍) បានផងដែរ (មាត្រា ២៦២) ប៉ុន្តែ ចំណុចទាំងនេះ គ្រាន់តែត្រូវបានវិនិច្ឆ័យ ក្នុងនាមជាមូលហេតុនៃឧបាស្រ័យចំពោះសាលក្រមចុងក្រោយប៉ុណ្ណោះ ។

បញ្ញត្តិស្តីពីនីតិវិធីនៃការជម្រះក្តីលើកទី ១ ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាចំពោះការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ (មាត្រា ២៧៣) ។ នៅពេលដែលបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលើកចោលបណ្តឹងនោះដោយសាលដីកា ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ទេ (មាត្រា ២៦៨) ។ ដើម្បីចេញសាលដីកាដែលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការប្តឹងឧបាស្រ័យដោយបណ្តឹងឧទ្ធរណ៍ តុលាការនៃប្តឹងឧទ្ធរណ៍ ត្រូវធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៤ កថាខណ្ឌទី ១) ។

ដោយសារកម្មវត្ថុចម្បងនៃការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ

នៃបណ្ដឹងឧទ្ធរណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ គឺត្រូវធ្វើត្រឹមតែក្នុងទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្ដូរនូវសាលក្រមដើមនៃការជំនុំជម្រះលើកទី ១ ប៉ុណ្ណោះ (មាត្រា ២៧២ កថាខណ្ឌទី ១) ។ នៅក្នុងករជំនុំជម្រះបណ្ដឹងតវ៉ា តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវបន្តវិនិច្ឆ័យ ដោយបើកឡើងវិញនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានបញ្ចប់ម្ដងនៅក្នុងការជំនុំជម្រះលើកទី ១ ។ ហេតុដូច្នេះ សកម្មភាពបណ្ដឹងដែលត្រូវបានធ្វើនៅក្នុងការជំនុំជម្រះលើកទី ១ (ពាក្យសុំ ការអះអាងអង្គហេតុ ការស្នើសុំឱ្យ ពិនិត្យភស្តុតាង ការសារភាព ជាអាទិ៍) ក៏មានអានុភាពនៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ដែរ (មាត្រា ២៧៤ កថាខណ្ឌទី ១) ។ ប៉ុន្តែ នៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ចៅក្រមត្រូវបានផ្លាស់ប្ដូរ ពីចៅក្រមនៃការជំនុំជម្រះលើកទី ១ ហេតុនេះហើយ ភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១ (មាត្រា ២៧២ កថាខណ្ឌទី ២) ។ ការធ្វើសេចក្ដីថ្លែងការណ៍នេះ ត្រូវបានធ្វើដើម្បីយកលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១ មកបង្ហាញនៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ហេតុដូច្នេះ ការធ្វើសេចក្ដីថ្លែងការណ៍នេះ គឺ គ្រាន់តែជាសកម្មភាពរាយការណ៍ដែលមានលក្ខណៈជាទម្រង់ ដើម្បីបំពេញគោលការណ៍វិនិច្ឆ័យដោយផ្ទាល់ ដូចកថាខណ្ឌទី ២ មាត្រា ១៨៥ ។

នៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ភាគីត្រូវបានផ្ដល់នូវឱកាសដើម្បីដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដែលខ្លួនមិនបានដាក់នៅក្នុងការជំនុំជម្រះលើកទី ១ ប៉ុន្តែ ប្រសិនបើភាគីត្រូវបានអនុញ្ញាតឱ្យដាក់មធ្យោបាយតទល់ ឬ ការពារខ្លួននោះ ដោយគ្មានកម្រិតទេ នោះមានការបារម្ភថា នឹងបណ្ដាលឱ្យមានការយឺតយ៉ាវចំពោះនីតិវិធី ដោយសារភាគីអាចមិនខិតខំប្រឹងប្រែងធ្វើការទាញហេតុផល នៅក្នុងការជំនុំជម្រះលើកទី ១ ដោយមើលស្រាលចំពោះនីតិវិធីនៃការជំនុំជម្រះលើកទី ១ នោះ ហើយបែរទៅជាយកចិត្តទុកដាក់ខាំងជាងចំពោះការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍វិញ ។ ហេតុដូច្នេះ នៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ប្រសិនបើភាគីដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ដោយយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យទៅតាមដំណើរការនៃនីតិវិធី ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងរ មធ្យោបាយនោះអាចត្រូវបានលើកចោល ដោយសារមធ្យោបាយនោះត្រូវបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (មាត្រា ២៧៣, មាត្រា ៩៤) ។ ក្នុងករណីនេះ មិនមែនតែដំណើរការនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ទេ គឺដំណើតការនៃការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះលើកទី ១ ក៏ត្រូវយកមកពិចារណា ដើម្បីវិនិច្ឆ័យអំពីភាពមិនត្រូវនឹងពេលសមរម្យនោះ ។

២. សាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍

(១) សាលដីកាលើកចោលបណ្ដឹងឧទ្ធរណ៍

តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវចេញសាលដីកាចុងក្រោយ ចំពោះបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ ។ ជាបឋម ប្រសិនបើបណ្ដឹងឧទ្ធរណ៍នោះមិនស្របច្បាប់ ដោយសារខ្វះនូវល័ក្ខខ័ណ្ឌនៃបណ្ដឹងឧទ្ធរណ៍

តុលាការនៃបណ្តឹងឧទ្ធរណ៍ ត្រូវចេញសាលដីកាលើកចោលបណ្តឹងឧទ្ធរណ៍នោះ (សូមមើលមាត្រា ២៦៨) ។ ប្រសិនបើបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតចំពោះល័ក្ខខ័ណ្ឌនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកចោលបណ្តឹងឧទ្ធរណ៍ ដោយសាលដីកា ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ២៦៨) ។

(២) សាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍

ក្នុងករណីដែលទទួលស្គាល់ថា សាលក្រមនៃការជំនុំជម្រះលើកទី ១ នោះត្រឹមត្រូវ (មាត្រា ២៧៧ កថាខណ្ឌទី ១) ឬ ក៏ទោះជាការសំអាងហេតុនៃសាលក្រមដើមនោះមិនត្រឹមត្រូវក៏ដោយ តែទទួលស្គាល់ថាសេចក្តីសម្រេចបញ្ចប់នៃសាលក្រមដើមនោះត្រឹមត្រូវ ដោយផ្អែកលើសំអាងហេតុដទៃទៀត (មាត្រា ២៧៧ កថាខណ្ឌទី ២) តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវចេញសាលដីកាច្រានចោលនូវបណ្តឹងឧទ្ធរណ៍នោះ ។ នេះគឺដោយសារតែអាជ្ញាអស់ជំនុំមិនត្រូវកើតឡើងទៅលើសេចក្តីវិនិច្ឆ័យនៅក្នុងសំអាងហេតុនៃសាលក្រម (មាត្រា ១៩៤ កថាខណ្ឌទី ៣) ហេតុដូច្នេះ ភាពមិនត្រឹមត្រូវនៃសំអាងហេតុនោះ គ្មានឥទ្ធិពលអ្វីទៅលើអានុភាពនៃសាលក្រមឡើយ ។ ប៉ុន្តែ ប្រសិនបើតុលាការយល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍ដែលបានឈ្នះក្តីនៅក្នុងសាលក្រមដើម ដោយការអះអាងអំពីការទូទាត់ក្នុងនាមជាអង្គហេតុការពារ (សូមមើលមាត្រា ១៩៤ កថាខណ្ឌទី ៤) ត្រូវឈ្នះក្តី ដោយសារមូលហេតុផ្សេងពីនេះ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវលុបចោលនូវសាលក្រមដើម ហើយត្រូវប្រកាសសាលជាថ្មីថា ច្រានចោលការទាមទារសា ។

ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំវិញ ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ ក៏តុលាការត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំនោះដែរ (មាត្រា ២៧០ កថាខណ្ឌទី ៣) ។

ប្រសិនបើសាលដីកាច្រានចោលបណ្តឹងឧទ្ធរណ៍ចូលជាស្ថាពរ សាលក្រមដើម (សាលក្រមនៃការជំនុំជម្រះលើកទី ១) ក៏ត្រូវចូលជាស្ថាពរដែរ ។ ក្នុងករណីនេះ ប្រសិនបើសាលក្រមដើមជាសាលក្រមបង្គាប់ឱ្យផ្តល់តាវកាលិក សាលក្រមដើមក្លាយទៅជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ក) ។

(៣) សាលដីកាទទួលស្គាល់បណ្តឹងឧទ្ធរណ៍ (សាលដីកាលុបចោលនូវសាលក្រមដើម) ព្រមទាំងការចាត់ចែងក្រោយពីនោះ

ផ្ទុយទៅវិញ ប្រសិនបើការប្តឹងឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ មានមូលហេតុត្រឹមត្រូវ ហើយសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ ឬ ប្រសិនបើនីតិវិធីនៃការជំនុំជម្រះលើកទី ១ ខុសច្បាប់ធ្ងន់ធ្ងរ ហើយតុលាការនៃបណ្តឹងឧទ្ធរណ៍មិនអាចយកនីតិវិធីនៃការជំនុំជម្រះលើកទី ១ នោះមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវទទួលស្គាល់បណ្តឹងឧទ្ធរណ៍ ហើយត្រូវលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ (មាត្រា ២៧៩ កថាខណ្ឌទី ១) ។ ដោយព្រោះការលុបចោល

នូវសាលក្រមនៃការជំនុំជម្រះលើកទី ១ មានន័យថា តុលាការមិនឆ្លើយតបទៅនឹងបណ្តឹងដែលបានប្តឹង តុលាការត្រូវចាត់នូវវិធានសមរម្យដូចតទៅ :

(ក) ការលុបចោល និង ការជំនុំជម្រះដោយខ្លួនឯង

ជាគោលការណ៍ ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមរបស់សាលាដំបូង តុលាការនៃបណ្តឹងឧទ្ធរណ៍នោះត្រូវវិនិច្ឆ័យដោយខ្លួនឯងជំនួសសាលាដំបូងនោះ (មាត្រា ២៧៩ · កថាខណ្ឌទី ២) ។ ដោយសារការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ គឺជាការវិនិច្ឆ័យលើអង្គហេតុ ជាគោលការណ៍ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវវិនិច្ឆ័យដោយខ្លួនឯង នៅពេលលុបចោលសាលក្រមដើម ។ ក្នុងករណីនេះ សេចក្តីសម្រេចបញ្ចប់នៃសាលដីកា មានពីរយ៉ាង គឺ (១) "១. លុបចោលសាលក្រមដើម ។ ២. ច្រានចោលការទាមទាររបស់ដើមចោទ" និង (២) "កែប្រែ (ឬ ផ្លាស់ប្តូរ) សាលក្រមដើមដូចតទៅ : ........" (ដោយបញ្ចូលគ្នានូវការលុបចោល និង ការវិនិច្ឆ័យដោយខ្លួនឯង) ។

(ខ) ការលុបចោល និង បញ្ជូនត្រឡប់ទៅវិញ

ក្នុងករណីដែលតុលាការនៃបណ្តឹងឧទ្ធរណ៍លុបចោលនូវសាលក្រមនៃជំនុំជម្រះលើកទី ១ ដែលលើកចោលបណ្តឹង ដោយយល់ឃើញថា បណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់ តុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវបញ្ជូនរឿងក្តីនោះត្រលប់ទៅសាលាដំបូងវិញ ពីព្រោះ ការវិនិច្ឆ័យអំពីអង្គសេចក្តី មិនបានធ្វើឡើងដោយតុលាការនៃការជំនុំជម្រះលើកទី ១ ទេ (មាត្រា ២៨០ កថាខណ្ឌទី ១) ។ ការធ្វើបែបនេះ គឺដើម្បីធានាសិទ្ធិរបស់ភាគីចំពោះនីតិវិធីដែលភាគីអាចទទួលបាននូវការវិនិច្ឆ័យលើអង្គហេតុពីរដងរហូតដល់ការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។

ក៏ប៉ុន្តែ ទោះបីជាតុលាការនៃការជំនុំជម្រះលើកទី ១ បានចេញសាលក្រមលើកចោលបណ្តឹងក៏ដោយ ប្រសិនបើតុលាការនៃបណ្តឹងឧទ្ធរណ៍យល់ឃើញថា ការទាញហេតុផលបានធ្វើគ្រប់គ្រាន់ហើយនៅក្នុងការជម្រះក្តីលើកទី ១ ហើយមិនមានការចាំបាច់ត្រូវបន្ថែមការទាញហេតុផលទៀតទេ នេះជាករណីលើកលែងដែលតុលាការនៃបណ្តឹងឧទ្ធរណ៍ត្រូវអាចចេញសាលដីកាសម្រេចចំពោះបណ្តឹងនោះបាន (មាត្រា ២៨០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ លើសពីនោះទៅទៀត តុលាការនៃបណ្តឹងឧទ្ធរណ៍អាចបញ្ជូនរឿងក្តីនោះទៅសាលាដំបូងវិញបាន ប្រសិនបើយល់ឃើញថា ចាំបាច់ត្រូវការទាញហេតុផលបន្ថែមទៀត (មាត្រា ២៨០ កថាខណ្ឌទី ២) ។ ជាឧទាហរណ៍ ក្នុងករណីដែលតុលាការនៃការជំនុំជម្រះលើកទី ១ បានចេញសាលក្រមច្រានចោលការទាមទារ ដោយយល់ឃើញថា គ្មានអត្ថិភាពនៃការទាមទារ តែតុលាការនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ បែរទៅជាយល់ឃើញថា ការទាមទារនោះមានអត្ថិភាព ហើយប្រសិនបើតុលាការនៃការជំនុំជម្រះលើកទី ១ មិនបានវិនិច្ឆ័យអំពីចំនួនទឹកប្រាក់នៃការទាមទារ នោះតុលាការនៃបណ្តឹងឧទ្ធរណ៍ អាចបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាដំបូងវិញ ដើម្បីឱ្យសាលាដំបូងនោះវិនិច្ឆ័យអំពីចំណុចនេះ ។

ចំពោះសាលដីកាបញ្ជូនរឿងក្ដីត្រឡប់ទៅវិញ អាចប្ដឹងសាទុក្ខបាន ។ នៅពេលដែលសាលដីកាបញ្ជូនរឿងក្ដីត្រឡប់ទៅវិញ ចូលជាស្ថាពរ រឿងក្ដីនោះត្រូវផ្ទេរទៅតុលាការដើម (សាលាដំបូងនៃកាជំនុំជម្រះលើកទី ១) ។ បន្ទាប់នេះ សាលាដំបូងត្រូវបន្តនីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលបានធ្វើពីមុនមក ។ នីតិវិធីនៃការជំនុំជម្រះលើកទី ១ ដែលបានធ្វើពីមុនមក នៅតែមានអានុភាព លើកលែងតែនីតិវិធីនោះ ត្រូវបានយល់ឃើញថា ផ្ទុយនឹងច្បាប់ នៅក្នុងសំអាងហេតុដើម្បីលុបចោលសាលក្រមដើម (នៅក្នុងសាលដីកា) (មាត្រា ២៨០ កថាខណ្ឌទី ៣) ។

(គ) ការលុបចោល និង ផ្ទេរនូវរឿងក្ដី

ក្នុងករណីដែលបានលុបចោលនូវសាលក្រមរបស់សាលាដំបូង ដោយមូលហេតុខុសសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការនៃការជំនុំជម្រះលើកទី ១ តុលាការនៃបណ្ដឹងឧទ្ធរណ៍ត្រូវផ្ទេររឿងក្ដីនោះ ទៅតុលាការដែលមានសមត្ថកិច្ចដោយផ្ទាល់វិញ ដោយមិនចាំបាច់បញ្ជូនរឿងក្ដីនោះត្រឡប់ទៅតុលាការដើមដែលបានចេញសាលក្រមនៃការជំនុំជម្រះលើកទី ១ វិញទេ (មាត្រា ២៨១) ។ ទោះបីជាខុសសមត្ថកិច្ចមិនផ្ដាច់មុខក៏ដោយ ក៏ការណ៍នេះ មិនមែនក្លាយទៅជាមូលហេតុនៃការលុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ឡើយ ។

(៤) វិសាលភាពនៃការលុបចោល និង ការផ្លាស់ប្ដូរ

តុលាការនៃបណ្ដឹងឧទ្ធរណ៍អាចលុបចោល ឬ ផ្លាស់ប្ដូរនូវសាលក្រមនៃការជំនុំជម្រះលើកទី ១ បានត្រឹមតែកម្រិតនៃឧបាស្រ័យដោយបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ភាគីប៉ុណ្ណោះ (មាត្រា ២៧៨) ។ នេះគឺជាការតំណាងចំពោះគោលការណ៍ (គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី) ដែលមានចែងនៅក្នុងមាត្រា ១៨២ កថាខណ្ឌទី ១ និង ទី ២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) ក្នុងតុលាការនៃបណ្ដឹងឧទ្ធរណ៍ ។ ហេតុនេះហើយ ចំពោះភាគដែលអត់មានបណ្ដឹងឧបាស្រ័យទេ ទោះជាសាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវក៏ដោយ ក៏មិនអាចផ្លាស់ប្ដូរនូវការវិនិច្ឆ័យបានដែរ ហើយក៏មិនអាចចេញសាលដីកាដែលផ្ដល់នូវផលប្រយោជន៍ជាងសាលក្រមនៃការជំនុំជម្រះលើកទី ១ ឱ្យហួសទំហំនៃបណ្ដឹងឧបាស្រ័យបានទេ (គោលការណ៍នៃការហាមការផ្លាស់ប្ដូរដោយផ្ដល់ផលប្រយោជន៍) ។ ជាឧទាហរណ៍ ប្រសិនបើចុងចម្លើយដែលចាញ់ក្ដីចំពោះបណ្ដឹងដើម និង បណ្ដឹងតប បានប្ដឹងឧទ្ធរណ៍ចំពោះតែសាលក្រមនៃបណ្ដឹងតបប៉ុណ្ណោះ ទោះបីជាតុលាការនៃបណ្ដឹងឧទ្ធរណ៍យល់ឃើញថា សាលក្រមនៃបណ្ដឹងដើមមិនត្រឹមត្រូវក៏ដោយ ក៏តុលាការនៃបណ្ដឹងឧទ្ធរណ៍ មិនអាចវិនិច្ឆ័យអំពីសាលក្រមនៃបណ្ដឹងដើមបានឡើយ ។ម្យ៉ាងទៀត ប្រសិនបើមិនមានបណ្ដឹងឧទ្ធរណ៍របស់ភាគីម្ខាងទៀត ឬ មិនមានបណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំរបស់ភាគីម្ខាងទៀតទេ ជាគោលការណ៍ដើមបណ្ដឹងឧទ្ធរណ៍មិនអាចទទួលនូវសាលដីកាដែលខាតប្រយោជន៍ជាងអ្វីដែលបានសម្រេចនៅក្នុងសាលក្រមនៃការជម្រះក្ដីលើកទី ១ ទេ បើយ៉ាងច្រើនបំផុត បណ្ដឹងឧទ្ធរណ៍នោះគ្រាន់តែត្រូវបានច្រានចោលប៉ុណ្ណោះទេ (គោលការណ៍នៃការហាមការផ្លាស់ប្ដូរដោយខូចខាតផលប្រយោជន៍) ។ ទោះបីជាមានបណ្ដឹងឧទ្ធរណ៍បន្ទាប់

បន្ទាំក៏ដោយ ដើមបណ្តឹងឧទ្ធរណ៍អាចរួចផុតពីការផ្លាស់ប្តូរដោយខូចខាតផលប្រយោជន៍បាន ដោយដកពាក្យបណ្តឹងឧទ្ធរណ៍ ( សូមមើលមាត្រា ២៧០ កថាខណ្ឌទី ២) ។

គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយផ្តល់ផលប្រយោជន៍ និង គោលការណ៍នៃការហាមការផ្លាស់ប្តូរដោយខូចខាតផលប្រយោជន៍ ត្រូវអនុវត្ត ចំពោះតែទំហំដែលតុលាការត្រូវបានចងដោយពាក្យសុំរបស់ភាគីប៉ុណ្ណោះ (សូមមើលមាត្រា ១៨២ កថាខណ្ឌទី ១ និង ទី ២) ។ ហេតុដូច្នេះ ការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ជាដើម ដែលអាចធ្វើដោយឆន្ទានុសិទ្ធិរបស់តុលាការ មិនត្រូវទទួលឥទ្ធិពលពីពាក្យសុំរបស់ភាគីឡើយ ។

# ជំពូកទី ៣ បណ្តឹងសាទុក្ខ

## កថាភាគទី ១ អត្ថន័យនៃបណ្តឹងសាទុក្ខ

### ១. ទស្សនៈនៃបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូល ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយ ដែលទាមទារឱ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាចុងក្រោយ ចំពោះតែការអនុវត្តច្បាប់ប៉ុណ្ណោះ ។ ជាគោលការណ៍ បណ្តឹងសាទុក្ខ អាចធ្វើបានចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា ២៨៣ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានការព្រមព្រៀងស្តីពីការប្តឹងសាទុក្ខផ្លោះទៅតុលាការកំពូល (មាត្រា ២៦០ កថាខណ្ឌទី ១ ចំណុច ក និង មាត្រា ២៨៣ កថាខណ្ឌទី ២) និង ក្នុងករណីដែលសាលាឧទ្ធរណ៍ ជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្តឹងសាទុក្ខដោយផ្ទាល់បាន ចំពោះសាលក្រម ឬ សាលដីកានៃតុលាការជំនុំជម្រះលើកទី ១ (មាត្រា ២៨៣ កថាខណ្ឌ ទី ១ វាក្យខណ្ឌទី ២) ។

ការជំនុំជម្រះនៃបណ្តឹងសាទុក្ខ គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលក្រម ឬ សាលដីកាដើមចុងក្រោយ ក្នុងនាមជាតុលាការនៃបណ្តឹងសាទុក្ខ ហេតុដូច្នេះ ខុសគ្នាពីការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៅក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការធ្វើការពិនិត្យមើលជាថ្មីម្តងទៀតទៅលើសាលក្រម ឬ សាលដីកាដើម ដោយផ្អែកទៅលើធនធានដែលត្រូវបានប្រើប្រាស់សម្រាប់វិនិច្ឆ័យនៅក្នុងសាលក្រម ឬ សាលដីកាដើមនោះ ។ តុលាការនៃបណ្តឹងសាទុក្ខ មិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើម ។ ក្នុងន័យនេះ ជាគោលករណ៍ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបានចងដោយអង្គហេតុដែលត្រូវបានទទួលស្គាល់ជាស្ថាពរ ដោយស្របច្បាប់ ក្នុងសាលក្រម ឬ សាលដីកាដើម (មាត្រា ២៩៦ ប៉ុន្តែ ចំពោះចំណុចដែលតុលាការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន មិនមានអានុភាពចងឡើយ, សូមមើលមាត្រា ២៩៧) ។

### ២. គោលបំណងនៃការប្តឹងសាទុក្ខ

គោលដៅនៃការជំនុំជម្រះបណ្តឹងសាទុក្ខ គឺការពារភាគីដែលទទួលរងនូវការខាតប្រយោជន៍ពីការជំនុំជម្រះដែលមិនត្រឹមត្រូវ ហើយព្រមជាមួយគ្នានេះ មានគោលដៅធ្វើឱ្យមានឯកភាពចំពោះការបកស្រាយច្បាប់ ដោយធ្វើការវិនិច្ឆ័យចំពោះសាលដីកាចុងក្រោយដែលចេញដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ ជាអាទិ៍ តាមទស្សនៈវិស័យថាតើមានភាពផ្ទុយនឹងច្បាប់ដែរឬអត់ ហើយកែតម្រូវនូវសាលក្រម ឬ សាលដីកាដែលមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

៣. មូលហេតុនៃការប្ដឹងសាទុក្ខ

ដោយព្រោះតុលាការនៃបណ្ដឹងសាទុក្ខ វិនិច្ឆ័យតែចំពោះបញ្ហាថា តើមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តឬទេ ក្នុងសាលដីកាចុងក្រោយនៃសាលាឧទ្ធរណ៍ ជាអាទិ៍ តែប៉ុណ្ណោះ ភាគីមិនអាចធ្វើបណ្ដឹងសាទុក្ខបានដោយគ្រាន់តែផ្អែកលើមូលហេតុថា ខ្លួនទទួលរងនូវការខាតប្រយោជន៍ពីសាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងសាទុក្ខបានទេ ។ ដើម្បីបណ្ដឹងសាទុក្ខត្រូវតែអះអាងមូលហេតុនៃបណ្ដឹងសាទុក្ខថា មានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្ត ដែលជះឥទ្ធិពលទៅដល់សាលក្រម ឬ សាលដីកា (មាត្រា ២៨៤) ។ មានន័យថា ដើម្បីប្រើប្រព័ន្ធនៃបណ្ដឹងសាទុក្ខ មិនគ្រាន់តែមានផលប្រយោជន៍ក្នុងការប្ដឹងឧបាស្រ័យ (ផលប្រយោជន៍ក្នុងការប្ដឹងសាទុក្ខ) ចំពោះសាលក្រម ឬ សាលដីកាដើមប៉ុណ្ណោះទេ គឺ ត្រូវអះអាងផងដែរនូវភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ជាមូលហេតុនៃបណ្ដឹងសាទុក្ខ (ហេតុដូច្នេះ ភាគីដែលឈ្នះក្ដីទាំងស្រុងនៅការជំនុំជម្រះដើម គ្មានផលប្រយោជន៍ក្នុងការប្ដឹងសាទុក្ខ ហើយបណ្ដឹងសាទុក្ខបែបនេះនឹងត្រូវបានលើកចោលជាដាច់ខាត ដោយសារបណ្ដឹងសាទុក្ខនោះមានលក្ខណៈផ្ទុយនឹងច្បាប់) ។

ប្រសិនបើតុលាការទទួលស្គាល់ថា មានកំហុស ឬ ការបំពានច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត នៅក្នុងការចាត់ចែងនីតិវិធី ឬ ក្នុងការវិនិច្ឆ័យរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ ហើយការណ៍នោះមានឥទ្ធិពលទៅលើការវិនិច្ឆ័យដែលបានបង្ហាញក្នុងសេចក្ដីសម្រេចបញ្ចប់នៃសាលដីកានោះពិតប្រាកដមែន ទើបបណ្ដឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ ។ ប៉ុន្តែ ក្នុងចំណោមភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត មានកំហុសធ្ងន់ធ្ងរខាងនីតិវិធី ដែលភាគីអាចយកធ្វើជាមូលហេតុនៃបណ្ដឹងសាទុក្ខបានដោយគ្មានល័ក្ខខ័ណ្ឌ និង ដោយពុំចាំបាច់អះអាងអំពីឥទ្ធិពលជាក់លាក់ទៅលើសាលក្រម ឬ សាលដីកា ដែលកើតចេញពីការបំពាននោះទេ (មាត្រា ២៨៥) ។ នេះគេហៅថា "មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ" ។ មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ គឺ ①ភាពផ្ទុយច្បាប់ក្នុងការចាត់តាំងតុលាការដែលចេញសាលដីកា ឬ សាលក្រម (មាត្រា ២៨៥ កថាខណ្ឌទី ១ ចំណុច ក) ② ការចូលរួមក្នុងការចេញសាលដីកា ឬ សាលក្រម របស់ចៅក្រមដែលមិនត្រូវបានអនុញ្ញាតឱ្យចូលរួម (ចំណុច ខ) ③ភាពខុសសមត្ថកិច្ចផ្ដាច់មុខ (ចំណុច គ) ④ការខ្វះសិទ្ធិតំណាង ជាអាទិ៍ (ចំណុច ឃ) ⑤ ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ (ចំណុច ង) ⑥ ការខ្វះសំអាងហេតុ ឬ ភាពផ្ទុយគ្នារវាងសំអាងហេតុ និង សេចក្ដីសម្រេចបញ្ចប់នៃសាលដីកា ឬ សាលក្រម (ចំណុច ច) ។ ករណី ①មានដូចជាករណីដែលចៅក្រមខ្វះលក្ខណសម្បត្តិ ឬ មានបញ្ហាអំពីចំនួនចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះ ជាអាទិ៍ ។ ករណី ②មានដូចជាករណីដែលចៅក្រមដែលមានមូលហេតុនៃការដកហូត ឬ ចៅក្រមដែលបានទទួលដីកាសម្រេចជិតចិត្ត ចូលរួម ក្នុងការចេញសាលដីកា ឬ សាលក្រម ឬ ករណីដែលចៅក្រមដែលបានចូលរួមក្នុងការចេញសាលដីកាដើម ឬ សាលក្រមដើមដែលត្រូវបានបដិសេធចោល និង ត្រូវបានបញ្ជូនត្រឡប់មកវិញ បានចូលរួមម្ដងទៀតនៅក្នុងការចេញសាលដីកា ឬ សាលក្រមនៃរឿងក្ដីនោះ (មាត្រា

២៩៩ កថាខណ្ឌទី ៣) ។ "ការចូលរួម" នៅក្នុងចំណុច ខ នេះ មិនន័យថា ការចូលរួមក្នុងការពិភាក្សាដើម្បីចេញសាលដីកា ឬ សាលក្រម ព្រមទាំង ការចូលរួមក្នុង ក្នុងករធ្វើមូលសាលដីកា ឬ មូលសាលក្រម ។ ប៉ុន្តែករណីដែលចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការប្រកាសសាលដីកា ឬ សាលក្រម បានចូលរួមក្នុងការប្រកសនេះ មិនមែនជាមូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខទេ គឺ គ្រាន់តែផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ។ ក្នុងករណី ④ ប្រសិនបើភាគីផ្តល់សច្ចានុមតិ (ទទួលស្គាល់នៅពេលក្រោយ) មុនពេលសាលដីកាដើម ឬ សាលក្រមដើមត្រូវបានបដិសេធចោល នោះលែងជាមូលហេតុដាច់ខាតនៃបណ្ដឹងសាលទុក្ខ (មាត្រា ២៨៥ កថាខណទី ២) ។ ចំពោះករណី ⑤ ការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ មិនបើកនោះ ត្រូវបានបញ្ជាក់ច្បាស់លាស់ដោយកំណុតហេតុស្តីពីលារទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១១៨ កថាខណ្ឌទី ១ ចំណុច ច) ។ ករណី ⑥ គឺជាករណីដែលសំអាងហេតុដែលចាំបាច់ភ្ជាប់ជាមួយសាលដីកា ឬ សាលក្រម ខ្វះទាំងស្រុង ឬ មួយផ្នែក ឬ ករណីដែលតក្កសាស្ត្រដែលនាំឱ្យមានសេចក្តីសន្និដ្ឋាននៃសេចក្តីសម្រេចបញ្ចប់ មិនមានភាពច្បាប់លាស់ ដោយសារសេចក្តីសម្រេចបញ្ចប់នេះផ្ទុយនឹងសំអាងហេតុដែលភ្ជាប់ជាមួយសេចក្តីសម្រេចនេះ ។

៤. បណ្ដឹងសាទុក្ខ និង នីតិវិធីបណ្ដឹងក្នុងការជំនុំជម្រះបណ្ដឹងសាទុក្ខ

បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និង នីតិវិធីនៃបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងសាទុក្ខ និង នីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស (មាត្រា ២៨៦) ។ ការជំនុំជម្រះបណ្ដឹងសាទុក្ខ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់ ប៉ុន្តែ មានលក្ខណៈរួមគ្នាជាច្រើននឹងបណ្ដឹងឧទ្ធរណ៍ដែលជាឧបាស្រ័យចំពោះសាលក្រមនៃការជំនុំជម្រះលើកទី ១ ហេតុដូច្នេះ បញ្ញត្តិស្តីពីនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស ។

## កថាភាគទី ២ ការធ្វើបណ្ដឹងសាទុក្ខ

ដើម្បីប្តឹងសាទុក្ខ ភាគីត្រូវដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការដើម (មាត្រា ២៨៧ វាក្យខណ្ឌទី ១) ។ តុលាការដើម ត្រូវធ្វើឱ្យបានឆាប់រហ័ស នូវពាក្យបណ្ដឹងសាទុក្ខ និង សំណុំរឿង ទៅតុលាការនៃបណ្ដឹងសាទុក្ខ (មាត្រា ២៨៧ វាក្យខណ្ឌទី ២) ។ តុលាការនៃបណ្ដឹងសាទុក្ខ ដែលបានទទួលពាក្យបណ្ដឹងសាទុក្ខ ត្រូវពិនិត្យពាក្យបណ្ដឹងសាទុក្ខ ហើយប្រសិនបើពាក្យបណ្ដឹងនោះមានចំណុចខ្វះខាត តុលាការត្រូវលើកចោលពាក្យបណ្ដឹងសាទុក្ខនោះ ដោយដីកាសម្រេច (មាត្រា ២៨៦ និង មាត្រា ២៦៦) ។ ក្រៅពីករណីនេះ តុលាការនៃបណ្ដឹងសាទុក្ខត្រូវបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខទៅដើមបណ្ដឹងសាទុក្ខ និង បញ្ជូនពាក្យបណ្ដឹងសាទុក្ខ និង លិខិតទទួលបណ្ដឹងសាទុក្ខនោះ ទៅចុងបណ្ដឹងសាទុក្ខ (មាត្រា ២៨៨) ។

ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ ប្រសិនបើខ្លួន មិនបាន សរសេរអំពីមូលហេតុនោះ នៅក្នុងពាក្យបណ្ដឹងសាទុក្ខទេ (មាត្រា ២៨៩ កថាខណ្ឌទី ១) ។ ក្នុងករណី ដែលប្ដឹងសាទុក្ខ ដោយយកមូលហេតុថា ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពល ទៅលើសាលក្រម ឬ សាលដីកាដើម (មាត្រា ២៨៤) ដើមបណ្ដឹងសាទុក្ខ ត្រូវសរសេរនូវបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ ព្រមទាំងហេតុដែលមានភាពផ្ទុយនឹងបញ្ញត្តិនោះ ក្នុងពាក្យបណ្ដឹងសាទុក្ខ ឬ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ហើយបើប្ដឹងសាទុក្ខដោយសារមាន "មូលហេតុដាច់ខាតនៃបណ្ដឹង សាទុក្ខ" ដូចមានចែងក្នុងមាត្រា ២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើមបណ្ដឹងត្រូវសរសេរនូវបញ្ញត្តិច្បាប់ និង អង្គហេតុដែលត្រូវនឹងមូលហេតុដាច់ខាតនោះ (មាត្រា ២៨៩ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។ ប្រសិនបើ មានចំណុចខ្វះខាតនៅក្នុងពាក្យបណ្ដឹងសាទុក្ខ ឬ ក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹង តុលាការនៃបណ្ដឹង សាទុក្ខត្រូវបង្គាប់ឱ្យធ្វើការកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ (មាត្រា ២៩១) ។ ក្នុងករណីដែល ដើមបណ្ដឹងសាទុក្ខមិនបានកែតម្រូវចំណុចខ្វះខាតនៅក្នុងអំឡុងពេលនេះ តុលាការនៃបណ្ដឹងសាទុក្ខ ត្រូវលើក ចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច (មាត្រា ២៩១ កថាខណ្ឌទី ២) ។

ជាគោលការណ៍ អំឡុងពេលដែលអាចធ្វើបណ្ដឹងសាទុក្ខ គឺ ១ ខែ ដោយគិតពីថ្ងៃដែលបានទទួលនូវការ បញ្ជូននៃលិខិតសាល ក្រម ឬ សាលដីកាដើម ដូចអំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ (មាត្រា ២៨៦, មាត្រា ២៦៤) ។

ប្រសិនបើបណ្ដឹងសាទុក្ខត្រូវបានដាក់ អានុភាពបង្អាក់នូវការចូលជាស្ថាពរ និង អានុភាពនៃការផ្ទេរជម្រះក្ដី ត្រូវកើតឡើងចំពោះសាលដីកាដើម ឬ សាលក្រមដើម ។ ក្នុងចំណោមសាលដីកាដើម ឬ សាលក្រមដើម ទោះបីជាមានផ្នែកណាមួយដែលគ្មានឧបាស្រ័យក៏ដោយ ក៏ផ្នែកនោះមិនត្រូវចូលជាស្ថាពរដែរ ។ ហេតុដូច្នេះ តុលាការនៃបណ្ដឹងសាទុក្ខអាចប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ចំពោះផ្នែកនេះ តាមពាក្យសុំ ដោយ ដីកាសម្រេចបាន (មាត្រា ២៩៨) ។ ម្យ៉ាងទៀត ចុងបណ្ដឹងសាទុក្ខ ក៏អាចដាក់ពាក្យបណ្ដឹងសាទុក្ខបន្ទាប់បន្សំ បាន (មាត្រា ២៨៦, មាត្រា ២៧០) ។

## កថាភាគទី ៣ ការជំនុំជម្រះបណ្ដឹងសាទុក្ខ និង ការចេញសាលដីកា

### ១. ការជំនុំជម្រះនៃតុលាការនៃបណ្ដឹងសាទុក្ខ

#### (១) ការលើកចោលនូវបណ្ដឹងសាទុក្ខដោយដីកាសម្រេច

តុលាការនៃបណ្ដឹងសាទុក្ខត្រូវលើកចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច ប្រសិនបើបណ្ដឹងសាទុក្ខនោះ មិនស្របច្បាប់ ហើយមិនអាចកែតម្រូវបានទេនោះ ឬ ប្រសិនបើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ

មិនត្រូវបានដាក់ទៅតុលាការនៃបណ្តឹងសាទុក្ខ ឬ ប្រសិនបើមានភាពផ្ទុយនឹងមាត្រា ២៨៩ កថាខណ្ឌទី ២ និង ៣ (មាត្រា ២៩០) ។ ក្នុងករណីដែលមិនបានចេញដីកាសម្រេចលើកចោលបណ្តឹងសាទុក្ខទេ ជាគោលការណ៍ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនឯកសារចម្លងនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ទៅចុងបណ្តឹងសាទុក្ខ ហើយត្រូវផ្តល់ឱកាសឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀម (មាត្រា ២៩២) ។ តុលាការនៃបណ្តឹងសាទុក្ខត្រូវវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃសាលដីកាដើម ឬ សាលក្រមដើម ត្រឹមតែកម្រិតនៃឧបាស្រ័យប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុនៃបណ្តឹងសាទុក្ខដែលត្រូវបានដាក់ដោយស្របនឹងច្បាប់ (មាត្រា ២៩៥) ។

(២) សាលដីកាច្រានចោលបណ្តឹងសាទុក្ខ

ក្នុងការជំនុំជម្រះទៅលើអង្គសេចក្តី តុលាការត្រូវមើលជាបឋមទៅលើឯកសារជាលាយល័ក្ខណ៍អក្សរដែលមានដូចជា លិខិតពាក្យបណ្តឹង លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខបានដាក់ និង ឯកសារផ្សេងៗទៀត ហើយប្រសិនបើតុលាការយល់ឃើញ ដោយផ្អែកលើឯកសារទាំងអស់នោះថា គ្មានមូលហេតុប្តឹងសាទុក្ខទេ តុលាការនៃបណ្តឹងសាទុក្ខអាចចេញសាលដីកាច្រានចោលនូវបណ្តឹងសាទុក្ខនោះ ដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ២៩៤) ។ ទោះជាក្នុងករណីដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយក៏ដោយ ប្រសិនបើពិនិត្យទៅឃើញថា ពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ (មាត្រា ២៨៦ និង មាត្រា ២៧៧) ។

(៣) សាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ (សាលដីកាបដិសេធចោលនូវសាលដីកាដើម)

ក្នុងករណីដែលទទួលស្គាល់ថា មានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើបណ្តឹងសាទុក្ខ តុលាការត្រូវបដិសេធចោលនូវសាលក្រម ឬ សាលដីកាដើម (មាត្រា ២៩៩ កថាខណ្ឌទី ១) ។ ការបដិសេធចោល មានន័យថា តុលាការនៃការជំនុំជម្រះលើអង្គច្បាប់ លុបចោលនូវសាលដីកាដើម ឬ សាលក្រមដើម ។ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលដែលបដិសេធចោលនូវសាលដីកាដើម ឬ សាលក្រមដើម (ការបកស្រាយបញ្ច្រាស់នៃមាត្រា ២៩៤) ។

(ក) ការបិសេធចោល និង បញ្ជូនត្រឡប់ទៅតុលាការដើម ឬ ការបិសេធចោល និង ផ្ទេររឿងក្តី

ជាគោលការណ៍ ក្រោយការបដិសេធចោលនូវសាលក្រម ឬ សាលដីកាដើម តុលាការពុំពិនិត្យ និងទទួលស្គាល់សាជាថ្មីទៅលើអង្គហេតុនៃរឿងក្តីទេ ដូច្នេះហើយករណីនេះ ខុសពីករណីនៃការលុបចោលនូវសាលក្រម ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីទៅតុលាការដើមវិញ ។ ជាបឋម ក្នុងករណីដែលបើមិនបានធ្វើការទទួលស្គាល់អង្គហេតុសាជាថ្មី មិនអាចធ្វើការជំនុំជម្រះ ជំនួសសាលក្រម ឬ សាលដីកាដើមទេ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវបញ្ជូនរឿងក្តីនោះទៅតុលាការដើមវិញ ឬ

ក្នុងករណីដែលយល់ឃើញថា ការបញ្ជូនត្រឡប់នោះមិនសមស្របទេ ដោយសារមានការកម្រិតនៃកថាខណ្ឌទី ៣ មាត្រា ២៩៩ (ដែលមានការពន្យល់ខាងក្រោម) ត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា (មាត្រា ២៩៩ កថាខណ្ឌទី ១) ។ តុលាការដែលបានទទួលនូវការបញ្ជូនត្រឡប់មកវិញ ឬ ដែលបានទទួលនូវការផ្ទេរនោះ ត្រូវធ្វើការជំនុំជម្រះ ដោយធ្វើការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មី ចំពោះរឿងក្តីនោះ តាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ (មាត្រា ២៩៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ ការទាញហេតុផលដោយផ្ទាល់មាត់នោះ ជសារធាតុ គឺជាការបើកឡើងវិញ និង បន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក ។ ប៉ុន្តែ ដូចដែលនឹងពន្យល់ខាងក្រោម ចៅក្រមដែលដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើម មិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់នេះ (មាត្រា ២៩៩ កថាខណ្ឌទី ២) ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក (មាត្រា ១៨៥ កថាខណ្ឌទី ២, ការអនុវត្តដូចគ្នាដោយមាត្រា ២៧២ កថាខណ្ឌទី ២) ។ ក្នុងករណីនេះ សេចក្តីវិនិច្ឆ័យលើអង្គច្បាប់ និង អង្គហេតុ ដែលតុលាការនៃបណ្តឹងសាទុក្ខយកជាមូលហេតុនៃការបដិសេធចោល មានចំណងទៅលើតុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរ (មាត្រា ២៩៩ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។ នេះគឺដោយសារតែ ប្រសិនបើតុលាការដើម នៅតែធ្វើការវិនិច្ឆ័យដូចមុន ឬ នៅតែធ្វើការចាត់ចែងដូចមុនដដែលនោះ ទោះជាតុលាការនៃបណ្តឹងសាទុក្ខបានបញ្ជូនត្រឡប់ទៅវិញប៉ុន្មានដងក៏ដោយ ក៏រឿងក្តីនោះមិនអាចដោះស្រាយចប់បានឡើយ ។ សេចក្តីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពចងត្រូវបានកម្រិតតែសេចក្តីវិនិច្ឆ័យអំពីអង្គហេតុដែលតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបាន ដូចជាអង្គហេតុដែលទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ (មាត្រា ២៩៧) ប៉ុណ្ណោះ ។ អានុភាពចងនៃសេចក្តីវិនិច្ឆ័យលើអង្គច្បាប់ មានន័យថា តុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរនោះ មិនអាចធ្វើសេចក្តីវិនិច្ឆ័យអំពីចំណុចពាក់ព័ន្ធនឹងអង្គច្បាប់ ដែលសេចក្តីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះដែលមាននៅក្នុងសាលដីកាដើម ឬ សាលក្រមដើម បានក្លាយទៅជាមូលហេតុនៃការបដិសេធចោល ។ ហេតុដូច្នេះ អានុភាពនេះតម្រូវឱ្យតុលាការដែលបានទទួលការបញ្ជូន ឬ ការផ្ទេរ ជៀសវាងធ្វើការសេចក្តីវិនិច្ឆ័យអំពីចំណុចអង្គច្បាប់នោះប៉ុណ្ណោះ តែមិនហាមឃាត់ឱ្យតុលាការនោះចេញសាលដីកា ឬ សាលក្រមដែលមានសេចក្តីសន្និដ្ឋានដូចគ្នានឹងសាលដីកា ឬ សាលក្រមមុន ដោយយកការបកស្រាយផ្សេងនូវអង្គច្បាប់ដែលអាចធ្វើបាន ។

ដើម្បីធានានូវអានុភាពចងការវិនិច្ឆ័យនោះបាន ចៅក្រមណាដែលមានការពាក់ព័ន្ធនឹងសាលដីកាដើម ឬ សាលក្រមដើមដែលត្រូវបានបដិសេធចោល មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចសេចក្តីក្រោយនោះបានទេ (មាត្រា ២៩៩ កថាខណ្ឌទី ៣) ។ ដើម្បីកុំឱ្យមានឧបសគ្គជាក់ស្តែងដោយសារការកម្រិតនេះ ច្បាប់អនុញ្ញាតឱ្យផ្ទេររឿងក្តី ជំនួសការបញ្ជូនត្រឡប់ទៅវិញ ។

(ខ) ការបដិសេធ និង ការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខដែលបានបដិសេធចោលនូវសាលដីកាដើម (ឬ សាលក្រមដើម ក្នុងករណីដែលមានការព្រមព្រៀងផ្លោះទៅបណ្តឹងសាទុក្ខ. ជាតទៅ ពន្យល់តែករណីដែលមានបណ្តឹងសាទុក្ខចំពោះសាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះ) អាចធ្វើការវិនិច្ឆ័យ ដោយខ្លួនឯង ជំនួសសាលដីកាដើមនោះបាន ក្នុងករណីដែលអាចចេញសាលដីកាជំនួសសាលដីកានោះបាន ដោយផ្អែកលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលដីកាដើមតែប៉ុណ្ណោះ (មាត្រា ៣០០) ។ សាលដីកាដែលជំនួសសាលដីកាដើម គឺជាចម្លើយចំពោះពាក្យបណ្តឹងឧទ្ធរណ៍ ហេតុដូច្នេះ មានករណីខ្លះដែលមិនឆ្លើយផ្ទាល់ចំពោះបណ្តឹងនៃការជំនុំជម្រះលើកទី ១ ដែរ ។ ករណីដែលតុលាការនៃបណ្តឹងសាទុក្ខវិនិច្ឆ័យដោយខ្លួនឯង និង ចេញសាលដីកាជំនួសសាលដីកាដើម មានករណីដូចតទៅ :

ជាដំបូង មានករណីដែលតុលាកានៃបណ្តឹងសាទុក្ខ ទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និង លុបចោលសាលក្រមនៃការជំនុំជម្រះលើកទី ១ ហើយបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការនៃការជំនុំជម្រះលើកទី ១ ឬ ផ្ទេររឿងក្តីទៅតុលាការនៃការជំនុំជម្រះលើកទី ១ ។ ក្នុងចំណោមករណីនេះ មាពីរនករណី គឺ (១) ករណីដែលសាលដីកាដើមដែលត្រូវបានបដិសេធចោល រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលច្រានចោលការទាមទារ ឬ រក្សាសាលក្រមនៃការជំនុំជម្រះលើកទី ១ ដែលផ្ទុយនឹងបញ្ញត្តិស្តីពីសមត្ថកិច្ចផ្តាច់មុខ និង (២) ករណីដែលគួរតែឱ្យវិនិច្ឆ័យឡើងវិញពីការជំនុំជម្រះលើកទី ១ ដោយសារការជំនុំជម្រះលើកទី ១ ពីមុននោះ មិនគ្រប់គ្រាន់ ។

ក្រៅពីករណីខាងលើ មានករណីដែលតុលាកានៃបណ្តឹងសាទុក្ខ លើកចោល ឬ ច្រានចោលបណ្តឹងឧទ្ធរណ៍ ឬ ករណីដែលទទួលស្គាល់បណ្តឹងឧទ្ធរណ៍ និង ចេញសាលដីកាផ្ទាល់ចំពោះបណ្តឹង (លើកចោលបណ្តឹង ច្រានចោលការទាមទារ ឬ ទទួលស្គាល់ការទាមទារ) ។ ក្នុងករណីដែលតុលាការនៃបណ្តឹនសាទុក្ខ បានបដិសេធចោលសាលដីកាដើម ដោយហេតុថា សាលដីកាដើមនោះ មានកំហុសក្នុងការអនុវត្ត ឬ បកស្រាយច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ចំពោះអង្គហេតុដែលត្រូវបានកំណត់ជាស្ថាពរ ហើយប្រសិនបើអាចសម្រេចសេចក្តីអំពីអង្គហេតុ ចំពោះរឿងក្តីនោះបាន ដោយតែកែតម្រូវការអនុវត្ត ឬ បកស្រាយច្បាប់ ឬ បទដ្ឋានគតិយុត្តនោះឱ្យបានត្រឹមត្រូវប៉ុណ្ណោះ (១) បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ ត្រឹមត្រូវ តុលាការនៃបណ្តឹនសាទុក្ខ នឹងច្រានចោលបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ ។ (២) បើយល់ឃើញថា សាលក្រមនៃការជំនុំជម្រះលើកទី ១ មិនត្រឹមត្រូវ តុលាការនៃ បណ្តឹនសាទុក្ខ នឹងលុបចោលសាលក្រមនេះ ហើយសម្រេចដោយខ្លួនឯងថា ទទួលស្គាល់ ឬ ច្រានចោលការទាមទារ (មាត្រា ៣០០ កថាខណ្ឌទី ១) ។ ម្យ៉ាងទៀត ក្នុងករណីដែលតុលាការនៃបណ្តឹងសារទុក្ខ បដិសេធចោលសាលដីកាដើម ដោយហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ (មាត្រា ៣០០ កថាខណ្ឌទី ២) ប្រសិនបើសាលក្រមនៃការជំនុំជម្រះលើកទី ១ លើកចោលបណ្តឹង តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងឧទ្ធរណ៍ ហើយប្រសិនបើតុលាការនៃការ

ជំនុំជម្រះលើកទី ១ បានចេញសាលក្រមសម្រេចអង្គសេចក្ដីវិញ តុលាការនៃបណ្ដឹងសាទុក្ខត្រូវលុបចោល សាលក្រមនៃការជំនុំជម្រះលើកទី ១ នោះ និង ត្រូវលើកចោលបណ្ដឹង ដោយខ្លួនឯង ។

## ជំពូកទី ៤ ការប្ដឹងជំទាស់

### កថាភាគទី ១ អត្ថន័យនៃការប្ដឹងជំទាស់

បណ្ដឹងជំទាស់គឺជាប្រព័ន្ធនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និង សង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេចដែលជាសេចក្ដីសម្រេចដែលមិនមែនជាសាលក្រម ឬ សាលដីកា ។ នីតិវិធីនៃបណ្ដឹងជំទាស់ មានលក្ខណៈងាយស្រួល និង ឆាប់រហ័ស បើប្រៀបធៀបជាមួយនឹងការប្ដឹងឧទ្ធរណ៍ ឬ សាទុក្ខ ហើយត្រូវបញ្ចប់ដោយដីកាសម្រេច (នីតិវិធីចេញដីកាសម្រេច) ។ បណ្ដឹងជំទាស់ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស ហេតុដូច្នេះ ត្រង់ចំណុចនោះ ខុសពីការតវ៉ាដែលជាឧបាស្រ័យចំពោះដិកាសម្រេចទៅតុលាការសាមី (ឧ. មាត្រា ៩១. មាត្រា ៣០២ កថាខណ្ឌទី ១) ។

### កថាភាគទី ២ ដីកាសម្រេចដែលអាចប្ដឹងជំទាស់បាន

បណ្ដឹងជំទាស់ អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញត្តិក្នុងច្បាប់ (មាត្រា ២៥៩ កថាខណ្ឌទី ២) ។

ជាទូទៅ ដីកាសម្រេចទាំងឡាយដែលធ្វើឡើងដោយតុលាការ អំពីចំណុចដែលបានក្លាយទៅជាបញ្ហាក្នុងដំណើរការនៃនីតិវិធីរហូតដល់ចេញសាលក្រម ឬ សាលដីកាចុងក្រោយ ត្រូវទទួលការវិនិច្ឆ័យរបស់តុលាការជាន់ខ្ពស់ ជាមួយសាលក្រម ឬ សាលដីកាចុងក្រោយ ដោយបណ្ដឹងឧទ្ធរណ៍ ឬ បណ្ដឹងសាទុក្ខ (មាត្រា ២៦២) ។ ក៏ប៉ុន្តែ ប្រសិនបើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងដំណើរការនៃនីតិវិធី ឬ ដែលកើតឡើងដោយនីតិវិធីនៃការជំនុំជម្រះ សុទ្ធតែដាក់ឱ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះ ការណ៍នេះនឹងរឹតតែមានភាពស្មុគស្មាញទៅវិញ ហើយអាចធ្វើឱ្យមានការយឺតយ៉ាវក្នុងការជំនុំជម្រះរឿងក្ដីនោះ ដោយសារតែបញ្ហាដែលកើតចេញពីនោះ ។ ដូច្នេះ ជាការល្អប្រសិនបើឱ្យបញ្ហាដែលមិនសូវពាក់ព័ន្ធនឹងអង្គសេចក្ដីនៃរឿងក្ដី ហើយដែលត្រូវការសម្រេចឱ្យឆាប់ អាចដោះស្រាយបាន ដោយនីតិវិធីសង្ខេបដែលអាចធ្វើឡើងដាច់ដោយឡែកនោះ ។ម្យ៉ាងទៀត ក្នុងករណីដែលបញ្ចប់នីតិវិធីដោយដីកាសម្រេច (ដូចជាដីកាសម្រេចលើកចោលពាក្យបណ្ដឹង : មាត្រា ៧៨ កថាខណ្ឌទី ២) ឬ ក្នុងករណីដែលតុលាការចេញដីកាសម្រេចចំពោះតតិយជនក្រៅពីភាគី (ដូចជាដីកាសម្រេចបង្គាប់ឱ្យតតិយជនផ្ដល់ឯកសារ : មាត្រា ១៥២ កថាខណ្ឌទី ៣) វាចាំបាច់ដែលត្រូវបើកផ្លូវឱ្យតតិយជន ជាដើម នោះដែលចង់ធ្វើឧបាស្រ័យចំពោះដីកាសម្រេចនោះ អាចធ្វើឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ ដូច្នេះហើយ ក្នុងករណីដែលទទួលស្គាល់ថា មានការចាំបាច់ ក្រមនីតិវិធីរដ្ឋប្បវេណីនេះមានចែងថា អាចប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះបាន ។

បញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ និង នីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបណ្ដឹងជំទាស់ និង នីតិវិធីនៃតុលាការនៃបណ្ដឹងជំទាស់នោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈបណ្ដឹង ឬ នីតិវិធីនោះ (មាត្រា ៣០៤ កថាខណ្ឌទី ១) ។ ហេតុដូច្នេះ ចំពោះបណ្ដឹង

ជំទាស់ចំពោះដីកាសម្រេចដែលត្រូវបានធ្វើដោយសាលាដំបូង បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ នីតិវិធីនៃការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ដោយសារបណ្តឹងជំទាស់នេះ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការនៃការជំនុំជម្រះលើកទី ២ ដូចបណ្តឹងឧទ្ធរណ៍ ។ បញ្ញត្តិដែលត្រូវយកមកអនុវត្តដូចគ្នានេះ មានដូចជា មាត្រា ២៦៣ (ការលះបង់សិទ្ធិប្តឹងឧទ្ធរណ៍), កថាខណ្ឌទី ២ នៃមាត្រា ២៦៥ (របៀបប្តឹងឧទ្ធរណ៍), មាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍របស់តុលាការនៃបណ្តឹងឧទ្ធរណ៍), មាត្រា ២៦៨ (ការលើកចោលបណ្តឹងឧទ្ធរណ៍ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់), មាត្រា ២៧០ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ), មាត្រា ២៧៣ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីនីតិវិធីនៃការជំនុំជម្រះលើកទី ១) ជាអាទិ៍ ។ ប៉ុន្តែប្រសិនបើមានបញ្ញត្តិផ្សេង ឬ មានភាពផ្ទុយនឹងលក្ខណៈបណ្តឹងជំទាស់ នោះអនុញ្ញាតឱ្យមានករណីលើកលែង ។ ករណីលើកលែងនេះ មានដូចជា អំឡុងពេលសម្រាប់ប្តឹងជំទាស់ (មាត្រា ៣០៣), អំឡុងពេលដើម្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងជំទាស់ (មាត្រា ៣០១ កថាខណ្ឌទី ២), ភាពអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដោយឆន្ទានុសិទ្ធិ (មាត្រា ៣០៦ កថាខណ្ឌទី ១), ការអនុញ្ញាតឱ្យធើការសួរ (មាត្រា ៣០៦ កថាខណ្ឌទី ២) ជាអាទិ៍ ។

រីឯ ចំពោះបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលត្រូវបានធ្វើដោយសាលាឧទ្ធរណ៍ក្នុងនាមពុតុល្យាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីនៃបណ្តឹងជំទាស់នោះ បញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្តឹងជំទាស់នោះ ឬ នីតិវិធីបណ្តឹងជំទាស់នោះ ដោយសារបណ្តឹងជំទាស់បែបនេះ មានផលក្ខណៈ ប្រហាក់ប្រហែលគ្នានឹងបណ្តឹងសាទុក្ខចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ។ ហេតុដូច្នេះ បណ្តឹងជំទាស់នេះ ត្រូវបានដាក់ទៅតុលាការកំពុល (មាទ្រា ៣០៤ កថាខណ្ឌទី ២, មាត្រា ២៨៣ កថាខណ្ឌទី ១) ហើយបណ្តឹងជំទាស់នោះ អាចធ្វើបាន ក្នុងករណីដែលមានភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ (មាទ្រា ៣០៤ កថាខណ្ឌទី ២, មាត្រា ២៨៤) ។ ក្រៅពីនេះ បញ្ញត្តិនៃមាត្រា ២៨៦ (ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍), មាត្រា ២៨៨ (ការបញ្ជូនលិខិតទទួលពាក្យបណ្តឹងសាទុក្ខ ជាអាទិ៍), កថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ), មាត្រា ២៩០ (ការលើកចោលបណ្តឹងសាទុក្ខ) ជាអាទិ៍ ។

## កថាភាគទី ៣ បណ្តឹងជំទាស់ និង ការវិនិច្ឆ័យបណ្តឹងជំទាស់

### ១. ការធ្វើបណ្តឹងជំទាស់

ផលប្រយោជន៍ក្នុងការប្តឹងជំទាស់ ត្រូវបានទទួលស្គាល់ ចំពោះ ភាគី ឬ តតិយជន ដែលបាត់បង់នូវផលប្រយោជន៍ដោយសារដីកាសម្រេចដើម ។ បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេលមួយសប្តាហ៍ ដោយគិតចាប់

ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេច (មាត្រា ៣០៣ កថាខណ្ឌទី ១) ។ អំឡុងពេលនេះមិនអាចពន្យារបានទេ (មាត្រា ៣០៣ កថាខណ្ឌទី ២) ។ ដើម្បីធ្វើបណ្ដឹងជំទាស់ ត្រូវដាក់ពាក្យបណ្ដឹងជំទាស់ទៅតុលាការដើម (មាត្រា ៣០១ វាក្យខណ្ឌទី ១) ។ នៅក្នុងពាក្យបណ្ដឹងជំទាស់ គួរតែចុះអំពីមូលហេតុច្បាស់លាស់នៃការសុំលុបចោល ឬ ផ្លាស់ប្ដូរនូវដីកាសម្រេចដើម ក៏ប៉ុន្តែ ប្រសិនបើមិនសរសេរអំពីមូលហេតុទាំងនោះ ក៏បណ្ដឹងជំទាស់នោះមិនបែរជាគ្មានសុពលភាពដែរ ។ ក្នុងករណីដែលពាក្យបណ្ដឹងជំទាស់មិនមានសរសេរអំពីមូលហេតុនោះទេ ដើមបណ្ដឹងជំទាស់គប្បីដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងជំទាស់នោះ ទៅតុលាការនៃបណ្ដឹងជំទាស់ ក្នុងអំឡុងពេល ពីរ សប្ដាហ៍ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងជំទាស់នោះ (មាត្រា ៣០១ កថាខណ្ឌទី ២) ។ នៅពេលទទួលបានពាក្យបណ្ដឹងជំទាស់ តុលាការដើមត្រូវផ្ញើពាក្យបណ្ដឹងជំទាស់ និងសំណុំរឿង ទៅតុលាការនៃបណ្ដឹងជំទាស់ ឱ្យបានឆាប់រហ័ស (មាត្រា ៣០១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ពេលដែលបានទទួលនូវការផ្ញើពាក្យបណ្ដឹងជំទាស់ហើយ តុលាការនៃបណ្ដឹងជំទាស់ ត្រូវពិនិត្យពាក្យបណ្ដឹងជំទាស់នោះ ហើយប្រសិនបើមានចំណុចណាដែលមិនស្របនឹងទម្រង់ ត្រូវបង្គាប់ឱ្យដើមបណ្ដឹងជំទាស់ធ្វើការកែតម្រូវ (មាត្រា ៣០៤ កថាខណ្ឌទី ១, មាត្រា ២៦៦ កថាខណ្ឌទី ១) ។ ប្រសិនបើភាគីនោះមិនធ្វើការកែតម្រូវទៅតាមការបង្គាប់របស់តុលាការទេ តុលាការត្រូវលើកចោលពាក្យបណ្ដឹងជំទាស់នោះ ដោយដីកាសម្រេច (មាត្រា ៣០៤ កថាខណ្ឌទី ១ និង មាត្រា ២៦៦ កថាខណ្ឌទី ២) ។

២. នីតិវិធីនៃការជំនុំជម្រះទៅលើបណ្ដឹងជំទាស់

(១) ភាគីនៃបណ្ដឹងជំទាស់

ចំពោះនីតិវិធីបណ្ដឹងជំទាស់ មិនមែនធ្វើតាមវិធីតទល់គ្នារវាងភាគី នៅគ្រប់ពេលវេលាទេ ។ ប៉ុន្តែក្នុងករណីដែលចំណុចដែលត្រូវបានវិនិច្ឆ័យដោយដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្ដឹងជំទាស់ មានមូលដ្ឋានដែលមានបុគ្គលពាក់ព័ន្ធនឹងផលប្រយោជន៍ ដើមបណ្ដឹងជំទាស់ ត្រូវធ្វើពាក្យសុំប្ដឹងជំទាស់ ប្រឆាំងទៅនឹងបុគ្គលនោះ ហើយតុលាការក៏ត្រូវឱ្យបុគ្គលនោះចូលរួមនៅក្នុងនីតិវិធីទាំងឡាយនៃការប្ដឹងជំទាស់នោះ ។ ឧទាហរណ៍ ក្នុងករណីដែលដើមបណ្ដឹងបានដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យចុងចម្លើយ ផ្ដល់ឯកសារដែលចុងចម្លើយកាន់កាប់ ហើយតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ដោយទទួលស្គាល់ពាក្យសុំនោះ ប្រសិនបើចុងចម្លើយប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះ ចុងចម្លើយត្រូវយកដើមចោទមក ធ្វើជាភាគីម្ខាងទៀត រីឯប្រសិនបើដើមចោទប្ដឹងជំទាស់ចំពោះដីកាសម្រេចច្រានចោលពាក្យសុំ ដើមចោទនោះត្រូវយកចុងចម្លើយមកធ្វើជាភាគីម្ខាងទៀតវិញ ។ ក៏ប៉ុន្តែ មានករណីខ្លះដែលសេចក្ដីសម្រេចធ្វើឡើងតាមរយៈដីកាសម្រេច តែគ្មានបុគ្គលណាពាក់ព័ន្ធនឹងផលប្រយោជន៍ទេ (ឧទាហរណ៍ ដីកាសម្រេចដាក់ពិន័យស៊ីវិល ចំពោះសាក្សី (មាត្រា ១៣២ កថាខណ្ឌទី ៤), ដីកាសម្រេចដក់ពិន្ទ្យយស៊ីវិល ចំពោះតតិយជនដែលមិនគោរពតាមដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ (មាទ្រា ១៥៤ កថាខណ្ឌទី ២) ជាអាទិ៍) ។

(២) បណ្តឹងជំទាស់ និង ការបង្អាក់នូវអានុភាពនៃដីកាសម្រេចដើម

ដីកាសម្រេចមានភាពខុសគ្នាពីសាលក្រម ឬ សាលដីកា គឺជាគោលការណ៍ ដីកាសម្រេចនឹងបង្កើតនូវអានុភាពចាំបាច់ដើម្បីសម្រេចនូវខ្លឹមសារនៃការសម្រេចសេចក្តី ដូចជាអានុភាពអនុវត្ត និង អានុភាពបង្កើតទំនាក់ទំនងគតិយុត្ត ជាដើម ដោយការជូនដំណឹងដែលគេអាចទទួលស្គាល់បានថាសមរម្យមួយតែប៉ុណ្ណោះ (មាត្រា ២១៣ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ពេលដែលមានបណ្តឹងជំទាស់ អានុភាពនៃដីកាសម្រេចដើមដែលបានកើតឡើងម្តងរួចហើយ ត្រូវបានបង្អាក់ (មាត្រា ៣០៥ កថាខណ្ឌទី ១) ។ ឧទាហរណ៍ ប្រសិនបើបណ្តឹងជំទាស់ត្រូវបានដាក់ចំពោះដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ (មាត្រា ១៩២ កថាខណ្ឌទី ៣) ភាគី ឬ តតិយជនដែលត្រូវបានបង្គាប់នោះ មិនចាំបាច់ផ្តល់ឯកសារដែលតុលាការបង្គាប់ឱ្យផ្តល់ឡើយ ។ ជាទូទៅ ដីកាសម្រេចដែលអាចប្តឹងជំទាស់ ប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី និង មានភាពចាំបាច់ក្នុងការចូលជាស្ថាពរឱ្យបានឆាប់រហ័ស ហេតុដូច្នេះ អានុភាពនៃដីកាសម្រេចដើម ត្រូវផ្អាក ដោយមានការដាក់បណ្តឹងជំទាស់តែប៉ណ្ណោះ ។

ប៉ុន្តែ នៅក្នុងករណីដែលការអនុវត្តដោយបង្ខំ ត្រូវបានចាប់ផ្តើម ដោយយកដីកាសម្រេចនោះមកជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច គ) ដើម្បីផ្អាកការអនុវត្តដែលកំពុងធ្វើឡើងដោយស្ថាប័នអនុវត្ត ចាំបាច់ត្រូវដាក់ឯកសារដូចមានរៀបរាប់នៅក្នុងចំណុចទាំងឡាយនៃមាត្រា ៣៧០ កថាខណ្ឌទី ១ និង ទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដូច្នេះ បើបណ្តឹងជំទាស់ត្រូវបានធ្វើឡើង តុលាការនៃបណ្តឹងជំទាស់ ឬ តុលាការដើម អាចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬ បង្គាប់ឱ្យធ្វើការចាត់ចែងចាំបាច់ផ្សេងទៀត រហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ (មាត្រា ៣០៥ កថាខណ្ឌទី ២) ។ ការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្ន ឬ ការចាត់ចែងផ្សេងទៀតនោះ អាចធ្វើបាន តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

(៣) នីតិវិធីជំនុំជម្រះនៃបណ្តឹងជំទាស់

ដោយហេតុថា នីតិវិធីនៃការជំនុំជម្រះបណ្តឹងជំទាស់ត្រូវបញ្ចប់ដោយដីកាសម្រេច តុលាការអាចសម្រេចដោយឆន្ទានុសិទ្ធិបានថាតើត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬអត់ (មាត្រា ៣០៦ កថាខណ្ឌទី ១ និង មាត្រា ១១៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការនៃបណ្តឹងជំទាស់ អាចសួរម្ចាស់បណ្តឹងជំទាស់ ឬ បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងផលប្រយោជន៍នឹងបណ្តឹងជំទាស់នោះបាន (មាត្រា ៣០៦ កថាខណ្ឌទី ២) ។ ក្នុងការជំនុំជម្រះបណ្តឹងជំទាស់ ភាគីអាចដាក់អង្គហេតុថ្មី និង ភស្តុតាងថ្មី ដូចការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ។ សេចក្តីសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្តឹងជំទាស់ គឺជាដីកាសម្រេច (សូមមើលមាត្រា ២៥៩ កថាខណ្ឌទី ៣) ហើយខ្លឹមសារនៃដីកាសម្រេចនោះ ត្រូវអនុលោមទៅតាមសាលដីកាចុងក្រោយនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ (មាត្រា ៣០៤ កថាណ្ឌទី ១) ។ ប៉ុន្តែ ចំពោះបណ្តឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការ

នៃការជំនុំជម្រះលើកទី ១ ការវិនិច្ឆ័យ និង ខ្លឹមសារនៃសេចក្ដីសម្រេចចុងក្រោយ ត្រូវអនុលោមទៅតាមករណី នៃការជំនុំជម្រះបណ្ដឹងសាទុក្ខដែលជាការវិនិច្ឆ័យលើអង្គច្បាប់ ( មាត្រា ៣០៤ កថាខណ្ឌទី ២) ។

## កថាភាគទី ៤ វិសាលភាពនៃការអនុញ្ញាតឱ្យប្ដឹងជំទាស់

### ១. ការប្ដឹងជំទាស់ចំពោះដីកាសម្រេចនៃសាលាឧទ្ធរណ៍

បើទោះជាការប្ដឹងជំទាស់អាចធ្វើឡើងទៅតាមការកំណត់ក្នុងបញ្ញត្តិច្បាប់ ( មាត្រា ២៩៩ កថាខណ្ឌទី ២) ក៏ដោយ ក៏ប៉ុន្តែ ចំពោះដីកាសម្រេចចុងក្រោយនៃការជំនុំជម្រះបណ្ដឹងជំទាស់ ដែលតុលាការនៃបណ្ដឹងជំទាស់ចេញ មិនអាចប្ដឹងជំទាស់ទៀតបានឡើយ ( មាត្រា ២៩៩ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ ក្នុងករណីដែលមានបណ្ដឹងជំទាស់ចំពោះដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ដែលបានចេញដោយសាលាដំបូង ក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ( មាត្រា ១៥២ កថាខណ្ឌទី ១) ភាគីមិនអាចប្ដឹងជំទាស់ ចំពោះដីកាសម្រេចចុងក្រោយអំពីបណ្ដឹងជំទាស់ ដែលត្រូវបានធ្វើដោយសាលាឧទ្ធរណ៍ដែលជាតុលាការនៃបណ្ដឹងជំទាស់នោះ ទៅតុលាការកំពូលថែមទៀតបានឡើយ ។ ការអនុវត្តបែបនេះ គឺដើម្បីសម្រាលនូវបន្ទុករបស់តុលាការកំពូល ។

ផ្ទុយទៅវិញ ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍បានធ្វើឡើងក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ អាចប្ដឹងជំទាស់ទៅតុលាការកំពូលបាន បើមានបញ្ញត្តិច្បាប់អនុញ្ញាតឱ្យប្ដឹងជំទាស់ចំពោះដីកាសម្រេចនោះ ។ បណ្ដឹងជំទាស់នេះ គឺជាបណ្ដឹងជំទាស់ទៅតុលាការកំពូលដែលជាតុលាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយនីតិវិធីនៃការប្ដឹងជំទាស់ទៅតុលាការកំពូលក្នុងករណីនេះ គឺស្រដៀងគ្នាទៅនឹងការអនុវត្តចំពោះបណ្ដឹងសាទុក្ខ ចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ដែលចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ ដោយហេតុនោះ បញ្ញត្តិស្ដីពីបណ្ដឹងសាទុក្ខ និង នីតិវិធីទាក់ទងទៅនឹងការជំនុំជម្រះបណ្ដឹងសាទុក្ខនោះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងជំទាស់លើដីកាសម្រេចដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះលើកទី ១ និង នីតិវិធីដែលទាក់ទងនឹងបណ្ដឹងជំទាស់ទាំងនោះ លើកលែងតែករណីដែលបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្ដឹង ឬ នីតិវិធីនោះ ( មាត្រា ៣០៤ កថាខណ្ឌទី ២) ។ ហេតុដូច្នេះនៅក្នុងករណីនេះ បណ្ដឹងជំទាស់នេះអាចធ្វើទៅបាន ដោយយកមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើដីកាសម្រេចដើមតែប៉ុណ្ណោះ ( សូមមើលមាត្រា ២៨៤) ។

ម្យ៉ាងទៀត មានខ្លះករណីដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ។ ក្នុងករណីនេះ ភាពអាច ឬ មិនអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចដែលសាលាឧទ្ធរណ៍ចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ អាស្រ័យទៅលើការអនុវត្តបញ្ញត្តិនៃមាត្រា ២៩៩ ( ប្រភេទនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់) ហេតុដូច្នេះ លើកលែងតែករណីដែលមានបញ្ញត្តិច្បាប់ដែលអនុញ្ញាត

ឱ្យប្ដឹងជំទាស់ ភាគីមិនអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាឧទ្ធរណ៍បានឡើយ (មាត្រា ២៩៩ កថាខណ្ឌទី ២) ។ ក្នុងករណីដែលសាលាឧទ្ធរណ៍ចេញដីកាសម្រេចជាដំបូងក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ប្រសិនបើបណ្ដឹងជំទាស់ចំពោះដីកាសម្រេចត្រូវបានធ្វើឡើង ផ្អែកលើបញ្ញត្តិនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) ដែលអាចអនុវត្តផ្ទាល់ចំពោះបណ្ដឹងឧទ្ធរណ៍ ភាគីអាចប្ដឹងជំទាស់បាន ។ ឧទាហរណ៍ ចំពោះដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្ដឹងជំទាស់ចៅក្រមនៃសាលាឧទ្ធរណ៍ មិនត្រឹមត្រូវ អាចប្ដឹងជំទាស់បាន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៦ មាត្រា ៣០ នៅក្នុងគន្ថីទី ១ ។ ផ្ទុយទៅវិញ ចំពោះដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ដែលសាលាឧទ្ធរណ៍បានចេញក្នុងនាមជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ មិនអាចប្ដឹងជំទាស់បានឡើយ ដោយសារបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១៥២ មិនត្រូវអនុវត្ត ដោយផ្ទាល់ចំពោះបណ្ដឹងឧទ្ធរណ៍ទេ គឺ ត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងនាមជាបញ្ញត្តិដែលទាក់ទងនឹង "គន្ថីទី ២ នីតិវិធីនៃការជំនុំជម្រះលើកទី ១" ដោយយោងតាមបញ្ញត្តិនៃមាត្រា ២៧២ ។

២. បណ្ដឹងឧបាស្រ័យចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលការបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ

ក្នុងករណីដែលភាគីមិនសុខចិត្តទៅនឹងដីកាសម្រេចដែលធ្វើឡើងដោយចៅក្រមដែលទទួលការបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ជាបឋម វាជាការសមរម្យដែលត្រូវដាក់ដីកាសម្រេចឱ្យតុលាការដែលទទួលបណ្ដឹងនោះពិនិត្យមើលជាមុនសិន ដែលនេះជាចំណុចខុសគ្នានឹងដីកាសម្រេចរបស់តុលាការ ។ ដូច្នេះ បើភាគីដែលមិនយល់ស្របចំពោះដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ អាចប្ដឹងតវ៉ាទៅតុលាការដែលទទួលបណ្ដឹង ដែលក្នុងករណីដែលច្បាប់អនុញ្ញាតឱ្យប្ដឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះ ជាដីកាសម្រេចរបស់តុលាការដែលទទួលបណ្ដឹង ហើយចំពោះដីកាសម្រេចអំពីការតវ៉ានោះតែប៉ុណ្ណោះ អាចប្ដឹងជំទាស់បាន (មាត្រា ៣០២ កថាខណ្ឌទី ១ វាក្យខណ្ឌ ទី ១ និង កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ក្នុងករណីដែលតុលាការដែលទទួលបណ្ដឹង ជាតុលាការកំពូល ឬ សាលាឧទ្ធរណ៍ ភាគីអាចប្ដឹងតវ៉ាបាន លុះត្រាតែច្បាប់អនុញ្ញាតឱ្យប្ដឹងជំទាស់ ប្រសិនបើដីកាសម្រេចនោះ ជាដីកាសម្រេចរបស់សាលាដំបូង (មាត្រា ៣០២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើតុលាការដែលទទួលបណ្ដឹង ជាតុលាការកំពូល ចំពោះដីកាសម្រេចអំពីការតវ៉ានោះ មិនអាចប្ដឹងជំទាស់បាន ដោយសារគ្មានតុលាការជាន់ខ្ពស់ជាងតុលាការកំពូល ។

ចំពោះការតវ៉ាដែលបានកំណត់នៅក្នុងមាត្រា ៣០២ នេះ ប្រសិនបើដីកាសម្រេចដែលជាកម្មវត្ថុនៃការតវ៉ានោះ ត្រូវបានធ្វើឡើងដោយតុលាការដែលទទួលបណ្ដឹងវិញ ត្រូវក្លាយទៅជាកម្មវត្ថុនៃបណ្ដឹងជំទាស់វិញ ។ ហេតុដូច្នេះ ការតវ៉ានោះ ត្រូវធ្វើឡើងក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ៣០៣ ។

## គន្ថីទី ៥ នីតិវិធីនៃការជំនុំជម្រះសាជាថ្មី

### ជំពូកទី ១ អត្ថន័យនៃការជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី គឺជាមធ្យោបាយឧបាស្រ័យពិសេសមួយ ចំពោះសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរហើយ ដើម្បីទាមទារឱ្យតុលាការ លុបចោលសាលក្រម ឬ សាលដីកានោះ និង ធ្វើការពិនិត្យ និងវិនិច្ឆ័យលើរឿងក្តីនោះសាជាថ្មីឡើងវិញ ដោយហេតុថា មានវិការៈធ្ងន់ធ្ងរក្នុងនីតិវិធីបណ្តឹងនោះ ឬ មានវិការៈមិនធម្មតានៅក្នុងមូលដ្ឋាននៃសាលក្រម ឬ សាលដីកានោះ ។ ជាទូទៅ នៅពេលដែលសាលក្រម ឬ សាលដីកាមួយចូលជាស្ថាពរ អានុភាពអាជ្ញាអស់ជំនុំកើតមានឡើង ដែលភាគីមិនអាចធ្វើឧបាស្រ័យចំពោះសាលក្រម ឬ សាលដីកានោះបានទៀតឡើយ ហើយប្រសិនបើការប្តឹងឱ្យបាស្រ័យសុំឱ្យលុប ឬ កែប្រែសាលក្រម ឬ សាលដីកា ត្រូវបានទទួលស្គាល់ដោយងាយៗពេក ដោយគ្រាន់តែសាលក្រម ឬ សាលដីកានោះមិនមានភាពត្រឹមត្រូវ ឬ ដោយមានភស្តុតាងថ្មីប៉ុណ្ណោះ នោះពលរដ្ឋមិនអាចទទួលបាននូវការដោះស្រាយទំនាស់ជាស្ថាពរទេ ហើយប្រព័ន្ធយុត្តិធម៌ក៏មិនអាចការពារនូវសិទ្ធិស្របច្បាប់របស់ពលរដ្ឋបានដែរ ។

ប៉ុន្តែ ម្យ៉ាងវិញទៀត ប្រសិនបើមិនអាចអនុញ្ញាតឱ្យមានការលុបចោលនូវសាលក្រមបានទាល់តែសោះ ទោះបីជារកឃើញថា មានវិការៈធ្ងន់ធ្ងរក៏ដោយនោះ វាដូចជាមានភាពផ្ទុយនឹងទស្សនៈស្តីពីការសម្រេចយុត្តិធម៌តាមរយៈនីតិវិធីបណ្តឹងដែលប្រកបដោយភាពត្រឹមត្រូវមួយ ហើយនាំឱ្យមានការប៉ះពាល់ទៅដល់សិទ្ធិ និងផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធ ។ ហេតុដូច្នេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីកំណត់ករណីមួយចំនួនដែលមានវិការៈធ្ងន់ធ្ងរក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ហើយយល់ឃើញថា យុត្តិធម៌នឹងត្រូវបានបំពានប្រសិនបើមិនអនុញ្ញាតឱ្យលុបចោលសាលក្រម ឬ សាលដីកាទេនោះ ហើយអនុញ្ញាតឱ្យភាគីដាក់ពាក្យសុំលុបចោលសាលក្រម ឬ សាលដីកាស្ថាពរ តែក្នុងករណីដែលច្បាប់បានកម្រិតប៉ុណ្ណោះ ។ នេះគឺជាប្រព័ន្ធនៃការជំនុំជម្រះសាជាថ្មី ។

# ជំពូកទី ២ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

## ១. មូលហេតុនៃការជំនុំជម្រះសាជាថ្មី

### (១) មូលហេតុនីមួយៗនៃការជំនុំជម្រះសាជាថ្មី

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាបណ្ដឹងចំពោះសាលក្រម ឬ សាលដីកាស្ថាពរ ដែលទាមទារឱ្យលុបចោលសាលក្រម ឬ សាលដីកាស្ថាពរនោះ និង ទាមទារឱ្យវិនិច្ឆ័យសាជាថ្មីនូវរឿងក្ដីដែលបានចប់ដោយសាលក្រម ឬ សាលដីកាស្ថាពរនោះរួចហើយ ដោយអះអាងនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលច្បាប់បានកំណត់ (មាត្រា ៣០៧) ។

មូលហេតុនៃការជំនុំជម្រះសាជាថ្មី ត្រូវកម្រិតត្រឹមមូលហេតុដូចមានចែងក្នុងមាត្រា ៣០៧ កថាខណ្ឌទី ១ តែប៉ុណ្ណោះ ។ ការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី គឺជាល័ក្ខខ័ណ្ឌដើម្បីឱ្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះមានភាពត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះ ប្រសិនបើពុំអះអាងអំពីមូលហេតុណាមួយទេ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ នឹងត្រូវលើកចោល ។ ប្រសិនបើតុលាការយល់ឃើញថា មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដូចភាគីអះអាង នោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានមូលហេតុត្រឹមត្រូវ ហើយតុលាការនឹងចាប់ផ្ដើមនីតិវិធីវិនិច្ឆ័យសាជាថ្មីអំពីរឿងក្ដីដែលត្រូវបានបញ្ចប់ ។

ក្នុងចំណោមមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលមានចែងនៅក្នុងមាត្រា ៣០៧ ចំណុច ក ដល់ចំណុច គ នៃកថាខណ្ឌទី ១ គឺជាមូលហេតុដូចគ្នានឹងមូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខដែរ (មាត្រា ២៨៥ កថាខណ្ឌទី ១ ចំណុច ក, ខ និង គ) ។ ប្រសិនបើមានអត្ថិភាពនូវមូលហេតុទាំងនេះ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានទទួលស្គាល់ ទោះបីជាមូលហេតុនោះ មាន ឬ គ្មានឥទ្ធិពលដល់សាលក្រម ឬ សាលដីកាក៏ដោយ ។ រីឯចំពោះមូលហេតុដែលមានចែងពីចំណុច ឃ ដល់ ជ គឺជាករណីដែលធនធានជាមូលដ្ឋានសម្រាប់សាលក្រម ឬ សាលដីកាស្ថាពរនោះ មានវិការៈធ្ងន់ធ្ងរ ហើយមូលហេតុដែលរៀបរាប់ពីចំណុច ឈ ដល់ ញ គឺជាករណីដែលសេចក្ដីសម្រេចរបស់តុលាការខ្លួនឯងក្នុងការចេញសាលក្រម ឬ សាលដីកានោះ មានវិការៈធ្ងន់ធ្ងរ ។ នៅក្នុងករណីដែលពាក់ព័ន្ធជាមួយមូលហេតុដែលមានចែងពីចំណុច ឃ ដល់ ញ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើទៅបាន លុះត្រាតែយល់ឃើញថា មូលហេតុនោះអាចមានឥទ្ធិពលដល់សេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកាប៉ុណ្ណោះ ។ ក្នុងចំណោមមូលហេតុទាំងនេះ មូលហេតុដែលមានចែងពីចំណុច ឃ ដល់ចំណុច ឆ គឺផ្អែកទៅលើការណ៍ដែលមានបទល្មើសព្រហ្មទណ្ឌ ឬ អំពើដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបទល្មើសព្រហ្មទណ្ឌ ក្នុងដំណើរការនៃការធ្វើឯកសារ ឬ ធនធានផ្សេងទៀត ឬ ការប្រមូលភស្តុតាងដែលបានក្លាយទៅជា មូលដ្ឋាននៃសាលក្រម ឬ សាលដីកាស្ថាពរ ។ នៅពេលដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយផ្អែកលើមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំងនេះ ចាំបាច់ត្រូវឱ្យមាន

សាលក្រម ឬ សាលដីកាស្ថាពរ ដែលសម្រេចផ្តន្ទាទោស ឬ សេចក្តីសម្រេចស្ថាពរដែលដាក់ពិន័យស៊ីវិល ចំពោះបទល្មើសព្រហ្មទណ្ឌ ជាដើម នោះ (មាត្រា ៣០៧ កថាខណ្ឌទី ២ ចំណុច ខ) ។ នៅក្នុងករណីខាងលើនេះ ប្រសិនបើមិនអាចទទួលបាននូវសាលក្រម ឬ សាលដីកាសម្រេចផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ពិន័យស៊ីវិល ដោយសារមូលហេតុក្រៅពីមូលហេតុថា ភស្តុតាងមិនគ្រប់គ្រាន់ ដូចជាករណីដែលជនជាប់ចោទបានទទួលមរណភាព ឬ ករណីដែលជនជាប់ចោទ ឬ ទណ្ឌិត បានទទួលការលើកលែងទោស ជាដើម បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើឡើង ដោយគ្មានសាលក្រម ឬ សាលដីកាសម្រេចផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ពិន័យស៊ីវិលនោះ (មាត្រា ៣០៧ កថាខណ្ឌទី ២ ចំណុច ខ) ។

(២) ភាពបង្គ្រប់នៃការជំនុំជម្រះសាជាថ្មី

ទោះបីជាមានអង្គហេតុដែលត្រូវជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក្នុងករណីដែលភាគីបានធ្វើការអះអាងអំពីអង្គហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ មុនពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ តែត្រូវបានតុលាការច្រានចោល ឬ ករណីដែលភាគីមិនបានអះអាង តាមបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយបានដឹងអំពីអង្គហេតុនោះ ភាគីមិនអាចធ្វើការអះអាងអង្គហេតុនោះជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីបានទេ (មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ នេះគេហៅថា ភាពបង្គ្រប់នៃការជំនុំជម្រះសាជាថ្មី ។

២. ល័ក្ខខ័ណ្ឌនៃបណ្តឹងសុំឱ្យជំនុំជម្រះសាជាថ្មី

(១) ត្រូវធ្វើចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលចូលជាស្ថាពរ (មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១)

កម្មវត្ថុនៃការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្តូរតាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺ សាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ ។ ចំពោះសេចក្តីសម្រេចដែលបានចេញនៅកណ្តាលទីនៃនីតិវិធីបណ្តឹង ដូចជា សាលក្រមរបៀប (មាត្រា ១៨១) ជាដើម មិនអាចធ្វើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យបានទេ ។ ប៉ុន្តែ ក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ចំពោះសេចក្តីសម្រេចដែលបានចេញនៅកណ្តាលទីនៃនីតិវិធីបណ្តឹងនោះ ភាគីអាចយកអង្គហេតុនោះមកធ្វើការអះអាងជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីបាន ចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលត្រូវបានធ្វើឡើងដោយផ្អែកលើសេចក្តីសម្រេចដែលបានចេញនៅកណ្តាលទីនៃនីតិវិធីបណ្តឹងនោះ (មាត្រា ៣០៨) ។ ម្យ៉ាងវិញទៀត ក្នុងចំណោមដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យដោយបណ្តឹងជំទាស់ ចំពោះដីកាសម្រេចដែលមានអានុភាពបញ្ចប់នីតិវិធី ដូចជាដីកាសម្រេចលើកពាក្យបណ្តឹងចោល (មាត្រា ៧៨ កថាខណ្ឌទី ២) ដីកាសម្រេចដាក់ពិន័យស៊ីវិលចំពោះសាក្សី (មាត្រា ១៣២ កថាខណ្ឌទី ៣) ជាដើម អាចដាក់ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យបាន ដែលត្រូវអនុលោមដូចគ្នាតាមបញ្ញត្តិស្តីពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែរ (មាត្រា

៣១៧) ។

ក្នុងករណីដែលសាលក្រមអំពីរឿងក្ដីមួយរបស់តុលាការថ្នាក់ក្រោម ព្រមទាំងសាលដីកានៃតុលាការថ្នាក់លើ ដែលលើកចោល ឬ ច្រានចោលនូវបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រមអំពីរឿងក្ដីដដែល របស់តុលាការថ្នាក់ក្រោម បានចូលជាស្ថាពរ ជាគោលការណ៍ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះ សាលក្រម និង បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលដីកានោះ អាចធ្វើឡើងផ្សេងៗគ្នាបាន ។ ប៉ុន្ដែ ក្នុងករណីដែលតុលាការនៃបណ្ដឹងឧទ្ធរណ៍ចេញសាលដីកាសម្រេចអង្គសេចក្ដីដែលច្រានចោលនូវបណ្ដឹងឧទ្ធរណ៍ នោះតុលាការនៃបណ្ដឹងឧទ្ធរណ៍បានជំនុំជម្រះជាថ្មីម្ដងទៀត ទាំងអង្គហេតុ ទាំងអង្គច្បាប់ ចំពោះបណ្ដឹងនោះ ហេតុនេះហើយ មិនអាចធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលដីកានៃការជំនុំជម្រះលើកទី ១ បានឡើយ ( មាត្រា ៣០៧ កថាខណ្ឌទី ៣) ។

(២) អំឡុងពេលដែលអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ដោយហេតុថា បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺដើម្បីកែប្រែនូវអានុភាពនៃសាលក្រម ឬ សាលដីកា ដែលបានចូលជាស្ថាពរហើយនោះ ការអនុញ្ញាតឱ្យដាក់ពាក្យបណ្ដឹងបែបនេះនៅពេលណាក៏បាន គឺជាការរារាំង ដល់ស្ថិរភាពនៃទំនាក់ទំនងគតិយុត្ដរវាងភាគី ។ ដូច្នេះ ជាគោលការណ៍ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីបានដឹងពីអំពីមូលហេតុនៃការជំនុំជម្រះសាជា ថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ( មាត្រា ៣១១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ហើយអំឡុងពេលនេះ មិនអាចពន្យារបានឡើយ ( មាត្រា ៣១១ កថាខណ្ឌទី ២) ។ ម្យ៉ាងទៀត ភាគីពុំអាច ធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ប្រសិនបើអំឡុងពេល ៥ ឆ្នាំ បានកន្លងផុត ដោយគិតពីថ្ងៃ ដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ គិតពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើង ក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ទោះជាភាគី បានដឹង ឬ មិនបានដឹងអំពីមូលហេតុនោះក៏ដោយ ( មាត្រា ៣១១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១) ។

ប៉ុន្ដែ ក្នុងចំណោមមូលហេតុនៃការជំនុំជម្រះសាជាថ្មីទាំងនោះ ចំពោះមូលហេតុនៃការខ្វះសិទ្ធិតំណាង ( មាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុច គ) និង មូលហេតុនៃការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុន ដែលបានចូលជាស្ថាពរហើយ ( មាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុច ញ) ភាគីអាចដាក់ពាក្យបណ្ដឹងទាមទារ ឱ្យជំនុំជម្រះសាជាថ្មីបាន ដោយមិនទទួលនូវការកម្រិតអំពីអំឡុងពេលខាងលើនេះទេ ( មាត្រា ៣១១ កថាខណ្ឌ ទី ១ វាក្យខណ្ឌទី ២, និង កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។ ក្នុងករណីដែលយកការខ្វះសិទ្ធិតំណាង មកធ្វើជា មូលហេតុនៃការការជំនុំជម្រះសាជាថ្មី ដោយហេតុថា បណ្ដឹងដែលមានសាលក្រម ឬ សាលដីកាស្ថាពរ ហើយនោះ ត្រូវបានធ្វើឡើងក្នុងពេលដែលសាមីភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ មិនបានដឹងសោះ (ដូចជាករណីដែលបណ្ដឹងត្រូវបានធ្វើឡើងដោយអ្នកតំណាងដោយគ្មានសិទ្ធិ ជាដើម) ហើយតុលាការបានចេញ

សាលក្រម ឬ សាលដីកា ដោយមិនធានានូវសិទ្ធិមូលដ្ឋាននៃនីតិវិធីចំពោះភាគី ហេតុដូច្នេះ ការកម្រិតនូវអំឡុងពេលសម្រាប់បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅ គឺផ្ទុយនឹងយុត្តិធម៌ ។ម្យ៉ាងទៀត ក្នុងករណីដែលសាលក្រម និង សាលដីកាដែលតុលាការបានចេញមុន និង ក្រោយនោះ មានការប៉ះពាល់គ្នា ការកម្រិតនូវអំឡុងពេលសម្រាប់បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងនាំឱ្យមានការច្របូកច្របល់ ដោយហេតុថាគ្មានច្បាស់លាស់ក្នុងការកំណត់ទំនាក់ទំនងគតិយុត្តរវាងភាគី ដោយសាលក្រម ឬ សាលដីកាណាមួយទេ ដូច្នេះហើយ មិនត្រូវធ្វើការកម្រិតនូវអំឡុងពេលប្តឹងទាមទារសុំឱ្យជំនុំជម្រះសាជាថ្មីទេ ។

(៣) ភាគីដែលអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

អ្នកដែលអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីក្នុងនាមជាដើមចោទ គឺជាអ្នកដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ ហើយដែលមានផលប្រយោជន៍ក្នុងការទាមទារឱ្យលុបចោលនូវសាលក្រម ឬ សាលដីកានោះ (ផលប្រយោជន៍ក្នុងកាធ្វើឧបាស្រ័យ) ហេតុដូច្នេះ ជាគោលការណ៍ គឺជាភាគីនៃបណ្តឹងដែលទទួលសាលក្រម ឬ សាលដីកាចាញ់ក្តីទាំងស្រុង ឬ មួយផ្នែក ។ តតិយជនដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកា ដូចជា បុគ្គលដែលជាម្ចាស់ផលប្រយោជន៍ជាសារធាតុនៅក្នុងបណ្តឹងដែលត្រូវបានទទួលបន្តុកដោយអ្នកដទៃ ឬ បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ក្រោយពេលបណ្តឹងត្រូវបានចាត់ការ ជាដើម (សូមមើលមាត្រា ១៩៨ ពីចំណុច ខ ទៅ) អាចធ្វើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដែរ ឱ្យតែបុគ្គលនោះមានផលប្រយោជន៍ជាក់លាក់ក្នុងការលុបចោលនូវសាលក្រម ឬ សាលដីកា ។ ម្យ៉ាងទៀត ពេលដែលអានុភាពនៃសាលក្រម ឬ សាលដីកាមានចំពោះតតិយជនទូទៅ តតិយជនដែលមានផលប្រយោជន៍ជាក់លាក់ក្នុងការលុបចោលនូវសាលក្រម ឬ សាលដីកានោះ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ។

ក្នុងករណីពិសេសដែលដើមចោទ និង ចុងចម្លើយបានធ្វើបណ្តឹង និង ទទួលសាលក្រម ឬ សាលដីកាស្ថាពរ ដោយផ្សំគំនិតគ្នាក្នុងគោលបំណងធ្វើឱ្យមានការខូចខាតដល់សិទ្ធិ ឬ ផលប្រយោជន៍របស់តតិយជន តតិយជននោះអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ដើម្បីទាមទារឱ្យតុលាការលុបចោលនូវសាលក្រម ឬ សាលដីកានោះ និង វិនិច្ឆ័យសាជាថ្មីអំពីរឿងក្តីនោះ (មាត្រា ៣១៨ កថាខណ្ឌទី ១) ។ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជនបែបនេះ ត្រូវហៅថា បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសកម្មភាពដែលនាំឱ្យខូចខាតផលប្រយោជន៍ ។ ឧទាហរណ៍ ក្នុងករណីដែល A ដែលមានបំណុលច្រើន បានផ្សំគំនិតជាមួយសាច់ញាតិរបស់ខ្លួនឈ្មោះ C ឱ្យ C ដាក់ពាក្យបណ្តឹងចំពោះ A ដែលទាមទារឱ្យបញ្ជាក់កម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ A ដោយឱ្យ C អះអាងថា C ជាកម្មសិទ្ធិករ ក្នុងគោលបំណងរួចផុតពីការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុល B ហើយបានចាញ់បណ្តឹងដោយចេតនា នោះម្ចាស់បំណុល B អាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសកម្មភាពដែលនាំឱ្យខូចខាតផលប្រយោជន៍ ចំពោះសាលក្រមស្ថាពរដែល

បានបញ្ជាក់ថា C ជាម្ចាស់កម្មសិទ្ធិ រវាង A និង C ។

ជាគោលការណ៍ ចុងចម្លើយនៃការជំនុំជម្រះសាជាថ្មី គឺជាភាគីដែលឈ្នះបណ្តឹងក្នុងសាលក្រម ឬ សាលដីកាស្ថាពរ ។ ក្រោយពីពេលដែលភាគីនេះបានទទួលមរណភាពទៅ ជនដែលមានបំណងដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវយកប្រតិសិទ្ធិសកល (សន្តតិជន) ជាចុងចម្លើយ ។ ក្នុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសកម្មភាពដែលនាំឱ្យខូចខាតផលប្រយោជន៍ ជនដែលមានបំណងដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវយកដើមចោទ និង ចុងចម្លើយនៃសាលក្រម ឬ សាលដីកាស្ថាពរមកធ្វើជាសហចុងចម្លើយ ( មាត្រា ៣១៨ កថាខណ្ឌទី ២) ។

(៤) ភាពចាំបាច់ក្នុងការអះអាងអំពីអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលជាមូលហេតុនៃការធ្វើ ឧបាស្រ័យចំពោះសាលក្រម ឬ សាលដីកាស្ថាពរ

៣. តុលាការដែលមានសមត្ថកិច្ចទៅលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ជាគោលការណ៍ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខនៃតុលាការដែលបានចេញសាលក្រម ឬ សាលដីកាស្ថាពរដែលជាកម្មវត្ថុនៃឧបាស្រ័យនោះ ( មាត្រា ៣០៩ កថាខណ្ឌទី ១) ។ ប៉ុន្តែ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬ សាលដីកាស្ថាពរច្រើន ដែលចេញដោយតុលាការច្រើនដែលមានថ្នាក់ខុសៗគ្នា អំពីរឿងក្តីតែមួយ តុលាការជាន់ខ្ពស់ត្រូវមានសមត្ថកិច្ចរួមបញ្ចូលនូវសាលក្រម និង សាលដីកាទាំងនោះ ( មាត្រា ៣០៩ កថាខណ្ឌទី ២) ។

៤. ការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

នៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវសរសេរនូវឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ សញ្ញាណនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃឧបាស្រ័យ និង សេចក្តីទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ ហើយក្រៅពីនេះ ត្រូវសរសេរអំពីអង្គហេតុដែលជាមូលហេតុជាក់ស្តែងនៃការសុំជំនុំជម្រះសាជាថ្មី ដែលជាមូលហេតុឧបាស្រ័យ ( មាត្រា ៣១២ កថាខណ្ឌទី ១) ។ ភាគីដែលបានដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចកែប្រែមូលហេតុនៃការជំនុំជម្រះសាជាថ្មីបាន ក្រោយពីបានដាក់ពាក្យបណ្តឹងនោះ ( មាត្រា ៣១៣) ។

ឯកសារចម្លងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវភ្ជាប់ជាមួយនឹងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ( មាត្រា ៣១២ កថាខណ្ឌទី ២) ។

ការដាក់ពាក្យបណ្តឹងឱ្យជំនុំជម្រះសាជាថ្មី បង្កើតអានុភាពនៃការគោរពអំឡុងពេលដាក់ពាក្យបណ្តឹង ចំពោះមូលហេតុនៃការជំនុំជម្រះសាជាថ្មី ( មាត្រា ៨៧) ។ ការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនត្រូវបង្អាក់នូវអានុភាពអនុវត្តនៃសាលក្រម ឬ សាលដីកាស្ថាពរដើមនោះទេ ។ ប៉ុន្តែ តុលាការអាច

បង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ ឬ លុបចោលការចាត់ចែងអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយបាន តាមពាក្យសុំ ( មាត្រា ៣៦៦ កថាខណ្ឌទី ១ ចំណុច ក និង កថាខណ្ឌទី ២) ។

## ជំពូកទី ៣ ការវិនិច្ឆ័យ និង សម្រេចសេចក្ដីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

១. ពីរដំណាក់កាល នៃការវិនិច្ឆ័យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

បញ្ញត្តិស្ដីពីនីតិវិធីបណ្ដឹងទៅតាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីវិនិច្ឆ័យ និង សម្រេចសេចក្ដីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី លើកលែងតែបញ្ញត្តិនោះមានភាពផ្ទុយនឹងលក្ខណៈនៃបណ្ដឹងនៃការជំនុំជម្រះសាជាថ្មី ( មាត្រា ៣១០) ។ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាបណ្ដឹងដែលមានពាក្យសុំពីរ ដោយរួមមានពាក្យសុំលុបចោលនូវសាលក្រម ឬសាលដីកាស្ថាពរ និង ពាក្យសុំទាមទារឱ្យចេញសាលក្រម ឬ សាលដីកាជំនួសសាលក្រម ឬ សាលដីកាស្ថាពរដើមនោះ អំពីការទាមទារ តាមផ្លូវបណ្ដឹងនៅក្នុងរឿងក្ដីដែលត្រូវបានបញ្ចប់ដោយសាលក្រម ឬ សាលដីកាស្ថាពរដើមនោះ ។ ហេតុដូច្នេះ នីតិវិធីបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើឡើងជាពីរដំណាក់កាល គឺ ដំណាក់កាលនៃការវិនិច្ឆ័យ អំពីការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យជំនុំជម្រះសាជាថ្មី និង ដំណាក់កាលនៃការវិនិច្ឆ័យ និង ចេញសាលក្រម ឬ សាលដីកាអំពីការទាមទារដើម ក្នុងករណីដែលអនុញ្ញាតឱ្យជំនុំជម្រះសាជាថ្មី ។ ដំណាក់កាលទីមួយ ត្រូវធ្វើតាមនីតិវិធីនៃដីកាសម្រេច ( មាត្រា ៣១៤) ។

២. ការវិនិច្ឆ័យ និង ការសម្រេចសេចក្ដីអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការសុំឱ្យជំនុំជម្រះសាជាថ្មី

ពេលដែលពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានដាក់ទៅតុលាការ ជាបឋម តុលាការត្រូវពិនិត្យអំពីភាពស្របច្បាប់នៃបណ្ដឹងនោះ ហើយប្រសិនបើយល់ឃើញថា មិនស្របច្បាប់ទេ តុលាការត្រូវលើកចោលបណ្ដឹងនោះ ដោយដីកាសម្រេច ( មាត្រា ៣១៤ កថាខណ្ឌទី ១) ។ ក្នុងករណីដែលយល់ឃើញថា បណ្ដឹងនោះស្របច្បាប់ បន្ទាប់មក តុលាការត្រូវធ្វើការពិនិត្យអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលភាគីអះអាងនោះ ។ ក្នុងការវិនិច្ឆ័យអំពីអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការអាចធ្វើការពិចារណាអំពីអង្គហេតុដែលមិនបានអះអាងដោយភាគី និង អាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិបាន ។ ការធ្វើបែបនេះ គឺដោយសារ ក្នុងនាមជាស្ថាប័នយុត្តិធម៌ តុលាការចាំបាច់ត្រូវតែរក្សានូវទំនុកចិត្តរបស់ប្រជាពលរដ្ឋ ចំពោះប្រព័ន្ធតុលាការ ។ ក្នុងករណីដែលមានបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលដីកាស្ថាពរនៃតុលាការនៃបណ្ដឹងសាទុក្ខ តុលាការនៃបណ្ដឹងសាទុក្ខអាចធ្វើការវិនិច្ឆ័យលើអង្គហេតុក្នុងកម្រិតនេះបាន ។

ប្រសិនបើយល់ឃើញថា ពុំមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយដីកាសម្រេច ( មាត្រា ៣១៤ កថាខណ្ឌទី ២) ។ ចំពោះដីកាសម្រេចលើកចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយហេតុថា មិនស្របច្បាប់ ឬ ដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយហេតុថា មិនទទួលស្គាល់នូវអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះ

សាជាថ្មី ដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចប្តឹងជំទាស់បាន ( មាត្រា ៣១៤ កថាខណ្ឌទី ១) ។ ក្នុងករណីដែលដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះ បានចូលជាស្ថាពរ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីម្តងទៀត ដោយផ្អែកលើមូលហេតុដូចគ្នានោះបានឡើយ ( មាត្រា ៣១៤ កថាខណ្ឌទី ៣) ។

ប្រសិនបើយល់ឃើញថា មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មី ( មាត្រា ៣១៥ កថាខណ្ឌទី ១) ។ ក្នុងករណីដែលបានចេញដីកាសម្រេចនេះ តុលាការត្រូវសួរភាគីម្ខាងទៀត ដែលជាចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ ជាមុន ( មាត្រា ៣១៥ កថាខណ្ឌទី ២) ។ ចំពោះដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មីនេះ ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចប្តឹងជំទាស់បាន ( មាត្រា ៣១៥ កថាខណ្ឌទី ៣) ។

៣. ការវិនិច្ឆ័យ និង ចេញសាលក្រម ឬ សាលដីកាអំពីអង្គសេចក្តី

(១) ការវិនិច្ឆ័យអំពីអង្គសេចក្តី

ក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ តុលាការត្រូវធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តី (ចេញសាលក្រម ឬ សាលដីកា) អំពីរឿងក្តីដែលត្រូវបានបញ្ចប់ដោយសាលក្រម ឬ សាលដីកាស្ថាពរដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (ដែលត្រូវហៅថា អង្គសេចក្តី ក្នុងការប្រៀបធៀបនឹងចំណុចទាក់ទងនឹងភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការជំនុំជម្រះសាជាថ្មី) តាមទំហំនៃឧបាស្រ័យនោះ ( មាត្រា ៣១៦ កថាខណ្ឌទី ១) ។ ការវិនិច្ឆ័យអំពីអង្គសេចក្តីនៅក្នុងការជំនុំជម្រះសាជាថ្មីត្រូវធ្វើឡើង ដោយបន្តពីបណ្តឹងមុន ហេតុដូច្នេះ នីតិវិធីដែលត្រូវបានធ្វើពីមុនមក ត្រូវមានអានុភាព នៅក្នុងការជំនុំជម្រះសាជាថ្មី លើកលែងតែនីតិវិធីដែលពាក់ព័ន្ធនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។ ប្រសិនបើតុលាការនៃការជំនុំជម្រះសាជាថ្មី ជាតុលាការវិនិច្ឆ័យទៅលើអង្គហេតុ ភាគីអាចដាក់មធ្យោបាយតទល់ និងការពារខ្លួនថ្មីបាន ។ ចុងចម្លើយអាចដាក់ពាក្យសុំលុបចោលនូវផ្នែកណាមួយនៃសាលក្រម ឬ សាលដីកាដើមដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍ខ្លួន តាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំ ដោយអនុលោមតាមបញ្ញត្តិនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បន្ទាប់បន្សំ (បណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ និង បណ្តឹងសាទុក្ខបន្ទាប់បន្សំ ) ។

(២) សាលក្រម ឬ សាលដីកាអំពីអង្គសេចក្តី

តាមលទ្ធផលនៃការវិនិច្ឆ័យ ប្រសិនបើយល់ឃើញថា សាលក្រម ឬ សាលដីកាដើមមិនត្រឹមត្រូវទេ តុលាការត្រូវលុបចោលនូវសាលក្រម ឬ សាលដីកានេះ ក្នុងកម្រិតនៃឧបាស្រ័យ ហើយចេញសាលក្រម ឬ សាលដីកាជំនួសនោះ ( មាត្រា ៣១៦ កថាខណ្ឌទី ៣) ។ ផ្ទុយទៅវិញ ប្រសិនបើយល់ឃើញថា សាលក្រម ឬ សាលដីកាដើមត្រឹមត្រូវ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាច្រានចោលនូវការទាមទារឱ្យជំនុំជម្រះ

សាជាថ្មី ទោះជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី មានអត្ថិភាពក៏ដោយ ( មាត្រា ៣១៦ កថាខណ្ឌទី ២) ។

# គន្ថីទី ៦ នីតិវិធីដាស់តឿន

## ជំពូកទី ១ អត្ថន័យនៃនីតិវិធីដាស់តឿន

នីតិវិធីដាស់តឿន គឺជានីតិវិធីមួយដើម្បីឱ្យម្ចាស់បំណុលទទួលដោយងាយស្រួល និង ឆាប់រហ័ស នូវលិខិតអនុវត្ត ( មាត្រា ៣៥០) ដែលចាំបាច់ដើម្បីអនុវត្តដោយបង្ខំ ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយក៏ជានីតិវិធីមួយជំនួសបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ។ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីជាធម្មតា ដើម្បីសម្រេចសិទ្ធិទាមទារឱ្យផ្តល់តាវកាលិក តាមការអនុវត្តដោយបង្ខំ ម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹង និង ទទួលនូវសាលក្រម ឬ សាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក ប៉ុន្តែ ប្រសិនបើម្ចាស់បំណុលត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ និង ធ្វើនីតិវិធីទាំងអស់ដល់ការទទួលសាលក្រម ឬ សាលដីកា ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលភាគីម្ខាងទៀតពុំធ្វើវិវាទ ម្ចាស់បំណុលនោះនឹងចំណាយពេលវេលា និង ថវិកាយ៉ាងច្រើន ។ ហេតុដូច្នេះ នីតិវិធីដាស់តឿនត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជាវិធីមួយដែលធ្វើឱ្យម្ចាស់បំណុលអាចទទួលបាននូវលិខិតអនុវត្ត ជំនួសសាលក្រម ឬ សាលដីកា តាមវិធីមួយសាមញ្ញ ឆាប់រហ័ស និង អស់សោហ៊ុយតិច ដោយមិនចាំបាច់ឆ្លងកាត់តាមនីតិវិធីបណ្តឹងធម្មតា កាលណាកូនបំណុលមិនធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារទេ តែប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចផ្តល់តាវកាលិកដោយស្ម័គ្រចិត្ត ។ ដោយសារហេតុនេះ កូនបំណុលត្រូវបានធានាឱ្យមានឱកាសទទួលនូវការវិនិច្ឆ័យតាមនីតិវិធីបណ្តឹងធម្មតា ដោយដាក់ពាក្យសុំតវ៉ា ប្រសិនបើកូនបំណុលនោះមានបំណងធ្វើវិវាទចំពោះការទាមទាររបស់ម្ចាស់បំណុល ។ នីតិវិធីដាស់តឿន គឺជាប្រភេទមួយនៃនីតិវិធីពិសេស ដែលមិនមានទម្រង់ សួរដេញដោលភាគីទាំងសងខាងទេ ហើយអ្នកដាក់ពាក្យសុំ ត្រូវហៅថា ម្ចាស់បំណុល រីឯភាគីម្ខាងទៀត ត្រូវហៅថា កូនបំណុល ។

# ជំពូកទី ២ ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

១. តុលាការដែលមានសមត្ថកិច្ច

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចតាមភារកិច្ចរបស់សាលាដំបូងដូចបានកំណត់ខាងក្រោមនេះ :

① ក្នុងករណីដែលកូនបំណុលជារូបវន្តបុគ្គល : សាលាដំបូងដែលមានសមត្ថកិច្ចលើលំនៅឋានរបស់បុគ្គលនោះ ឬ ប្រសិនបើពុំមានលំនៅឋាននោះ ឬ លំនៅដ្ឋានមិនពិតប្រាកដទេ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីសំណាក់របស់បុគ្គលនោះ ( មាត្រា ៣២០ កថាខណ្ឌទី ១ ចំណុច ក)

② ក្នុងករណីដែលកូនបំណុលជានីតិបុគ្គលក្នុងប្រទេស : សាលាដំបូងដែលមានសមត្ថកិច្ចលើទីស្នាក់ការកណ្តាល ឬ ទីកន្លែងអាជីវកម្មចម្បង ឬ ប្រសិនបើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មទេ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើលំនៅឋានរបស់អ្នកតំណាង ឬ អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារចម្បង ( មាត្រា ៣២០ កថាខណ្ឌទី ១ ចំណុច ខ)

③ ក្នុងករណីដែលកូនបំណុលជានីតិបុគ្គលបរទេស : សាលាដំបូងដែលមានសមត្ថកិច្ចលើទីស្នាក់ការកណ្តាល ឬ ទីកន្លែងអាជីវកម្មចម្បងក្នុងប្រទេសកម្ពុជា ឬ ប្រសិនបើពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មក្នុងប្រទេសកម្ពុជាទេ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើលំនៅឋានរបស់អ្នកតំណាង ប្រចាំប្រទេសកម្ពុជា ឬ អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារចម្បងៗនៅក្នុងប្រទេសកម្ពុជា ( មាត្រា ៣២០ កថាខណ្ឌទី ១ ចំណុច គ) ។

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនអំពីការទាមទារចំពោះបុគ្គលដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្ម ហើយការទាមទារនោះទាក់ទងនឹងការងារនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ អាចដាក់ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះបានដែរ ។ម្យ៉ាងទៀត ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនអំពីការទាមទារឱ្យបង់ជាប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ និង ការទាមទារបន្ទាប់បន្សំដែលទាក់ទងនឹងការទាមទារឱ្យបង់ជាប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រនោះ ដូចជាការទាមទារឱ្យសងការប្រាក់ ជាដើម អាចដាក់ទៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវសងរូបិយាណត្តិ ឬ មូលប្បទានប័ត្រនោះបានដែរ ( មាត្រា ៣២០ កថាខណ្ឌទី ២) ។

២. ល័ក្ខខ័ណ្ឌនៃពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

(១) ការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន អាចដាក់បានតែក្នុងករណីដែលសិទ្ធិដែលម្ចាស់បំណុលមាននោះ ជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ប៉ុណ្ណោះ (មាត្រា ៣១៩ វាក្យខណ្ឌទី ១) ។ នេះគឺដោយសារតែសិទ្ធិទាមទារប្រភេទនេះ ទោះជាម្ចាស់បំណុលបានអនុវត្តដោយបង្ខំដោយកំហុសក៏ដោយ ក៏តាម

ធម្មតា អាចធ្វើការបដិទាននូវការខូចខាតដែលកូនបំណុលបានទទួលនោះ ដោយការសងសំណងជាប្រាក់បាន ។ ដើម្បីអាចដាក់ពាក្យសុំ ពេលកំណត់ត្រូវអនុវត្តនៃសិទ្ធិទាមទារ ត្រូវដល់រួចហើយ ។ ទោះបីជាសិទ្ធិទាមទារជាសិទ្ធិដែលត្រូវអនុវត្តដោយផ្ទួននឹងតាវកាលិកតបក៏ដោយ ក៏ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន អាចដាក់បានដែរ ។

(២) ការបញ្ជូនចំពោះកូនបំណុល អាចធ្វើបាន ក្នុងប្រទេសកម្ពុជា តាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន អាចដាក់បាន លុះត្រាតែករណីដែលអាចធ្វើការបញ្ជូនឯកសារនៅក្នុងប្រទេសកម្ពុជា តាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ ( មាត្រា ៣១៩ វាក្យខណ្ឌទី ២) ។ ការចែងបែបនេះ គឺដើម្បីផ្តល់ឱកាសជាសារធាតុឱ្យកូនបំណុលអាចដាក់ពាក្យសុំតវ៉ាបាន ។

(៣) ការអនុវត្តដូចគ្នានូវបញ្ញត្តិស្តីពីបណ្តឹង

ជាទូទៅ បញ្ញត្តិស្តីពីបណ្តឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន លុះត្រាតែគ្មានភាពផ្ទុយនឹងលក្ខណៈរបស់ពាក្យសុំនោះ ( មាត្រា ៣២១) ។ ហេតុនេះហើយ ក្នុងពាក្យសុំម្ចាស់បំណុលត្រូវសរសេរឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន ជាអាទិ៍ របស់ម្ចាស់បំណុល និង កូនបំណុល ហើយក្រៅពីនេះ ត្រូវសរសេរអំពីខ្លឹមសារនៃដីកាសម្រេចដាស់តឿនដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ ព្រមទាំងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ( អនុវត្តដូចគ្នានូវមាត្រា ៧៥ កថាខណ្ឌទី ២) ។

៣. ការវិនិច្ឆ័យ និង សម្រេចសេចក្តីអំពីពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

(១) ក្នុងករណីដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវបានវិនិច្ឆ័យ ដោយមិនសួរកូនបំណុល( មាត្រា ៣២៣ កថាខណ្ឌទី ១) ហើយត្រូវបានសម្រេចសេចក្តីដោយដីកាសម្រេច ។ ប្រសិនបើពាក្យសុំនោះមិនស្របច្បាប់ ដោយសារតែមានកង្វះល័ក្ខខ័ណ្ឌ ( មាត្រា ៣១៩) ឬ ខុសសមត្ថកិច្ច ( មាត្រា ៣២០) ឬ ប្រសិនបើមានភាពច្បាស់លាស់ថា គ្មានមូលហេតុក្នុងការទាមទារ ដោយគិតពីខ្លឹមសារនៃពាក្យសុំ តុលាការត្រូវលើកចោលពាក្យសុំនោះដោយដីកាសម្រេច ( មាត្រា ៣២២ វាក្យខណ្ឌទី ១) ។ ប្រសិនបើមានមូលហេតុនៃការលើកចោលដូចបានរៀបរាប់ខាងលើ ចំពោះតែមួយភាគនៃពាក្យសុំ នោះតុលាការត្រូវលើកចោលនូវភាគដែលមានបញ្ហានោះ ( មាត្រា ៣២២ វាក្យខណ្ឌទី ២) ។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំនេះ មិនអាចប្តឹងឧបាស្រ័យបានទេ ។ នេះគឺព្រោះថា ម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនម្តងទៀត ឬ អាចធ្វើបណ្តឹងធម្មតាបាន ដូច្នេះហើយ ទោះជាបានទទួលនូវដីកាសម្រេចលើកចោលនោះក៏ដោយ ក៏មិនបាត់បង់នូវវិធីអះអាងសិទ្ធិនោះទេ ។

(២) ករណីទទួលស្គាល់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន

ក្នុងករណីដែលទទួលស្គាល់ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន តុលាការត្រូវចេញដីកាសម្រេចដាស់តឿន ។ ក្នុងដីកាសម្រេចដាស់តឿន តុលាការត្រូវសរសេរបញ្ជាក់អំពីឈ្មោះ ឬ នាមករណ៍ អាសយដ្ឋាន ជាអាទិ៍ របស់ភាគី ខ្លឹមសារនៃដីកាសម្រេចដែលម្ចាស់បំណុលទាមទារឱ្យតុលាការចេញ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង សេចក្ដីបង្គាប់ឱ្យសងជាប្រាក់ដែលមានកំណត់ចំនួន ( មាត្រា ៣២៤ កថាខណ្ឌទី ១) ហើយក្រៅពីនេះ ត្រូវសរសេរបន្ថែមថា ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេល ២ សប្ដាហ៍ ចាប់ពីថ្ងៃដែលបានទទួលនូវការបញ្ជូននៃដីកាសម្រេចដាស់តឿននោះ តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ( មាត្រា ៣២៤ កថាខណ្ឌទី ២) ។ តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចដាស់តឿន ទៅម្ចាស់បំណុល ហើយធ្វើការបញ្ជូនទៅកូនបំណុល ( មាត្រា ៣២៥ កថាខណ្ឌទី ១) ។ អានុភាពនៃដីកាសម្រេចដាស់តឿន នឹងកើតឡើងនាពេលដែលបានធ្វើការបញ្ជូនទៅដល់កូនបំណុល ( មាត្រា ៣២៥ កថាខណ្ឌទី ២. ចំពោះករណីដែលមិនអាចធ្វើការបញ្ជូន សូមមើលមាត្រា ៣២៥ កថាខណ្ឌទី ៣ និង ទី ៤) ។

## ជំពូកទី ៣ ការតវ៉ាចំពោះដីកាសម្រេចដាស់តឿន

១. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

(១) អត្ថន័យនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន

ដីកាសម្រេចដាស់តឿន ត្រូវបានចេញដោយមិនពិនិត្យមើលនូវអត្ថិភាពនៃសិទ្ធិទាមទារដែលម្ចាស់បំណុលអះអាង ហើយមិនបានសួរកូនបំណុលទេ (មាត្រា ៣២៣ កថាខណ្ឌទី ១) ។ ហេតុដូច្នេះ ចាំបាច់ត្រូវធានាឱ្យកូនបំណុលមានឱកាសធ្វើឧបាស្រ័យចំពោះដីកាសម្រេចដាស់តឿននេះ ហេតុនេះហើយ ក្រមនីតិវិធីរដ្ឋប្បវេណីចែងថា កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន (មាត្រា ៣២៣ កថាខណ្ឌទី ២) ហើយប្រសិនបើជាមានពាក្យសុំតវ៉ាចំពោះការដាស់តឿន នីតិវិធីដាស់តឿនត្រូវផ្ទេរទៅនីតិវិធីបណ្តឹងធម្មតា ហើយតុលាការត្រូវធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទាររបស់ម្ចាស់បំណុល តាម នីតិវិធីបណ្តឹងធម្មតា (មាត្រា ៣២៧) ។

(២) ក្នុងករណីដែលគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន

ប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេល ២ សប្តាហ៍ គិតពីថ្ងៃដែលបានទទួលការបញ្ជូននូវដីកាសម្រេចការដាស់តឿន តុលាការត្រូវសរសេរបន្ថែមនូវចំនួនទឹកប្រាក់សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន និង ត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិ (មាត្រា ៣២៨ កថាខណ្ឌទី ១) ។ម្យ៉ាងទៀត ទោះបីជាមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេលនោះក៏ដោយ តែប្រសិនបើតុលាការចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ានោះ ដោយហេតុថាមិនស្របច្បាប់ ហើយដីកាសម្រេចលើកចោលនោះបានចូលជាស្ថាពរ ក៏តុលាការត្រូវប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិ ដូចក្នុងករណីដែលគ្មានពាក្យសុំតវ៉ាក្នុងអំឡុងពេលនេះដែរ (មាត្រា ៣២៨ កថាខណ្ឌទី ១) ។ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រូវបញ្ជូនទៅឱ្យភាគីទាំងសងខាង (មាត្រា ៣២៨ កថាខណ្ឌទី ២) ។ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន នឹងក្លាយទៅជាលិខិតអនុវត្ត (មាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច ឃ) ហើយម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំបាន ដោយផ្អែកលើលិខិតនេះ ។

(៣) ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន

ផ្ទុយទៅវិញ ក្នុងករណីដែលមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន នៅមុនការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចដាស់តឿននោះ ត្រូវបាត់បង់អានុភាពក្នុងទំហំនៃការតវ៉ានោះ (មាត្រា ៣២៧ កថាខណ្ឌទី ១) ហើយតុលាការលែងអាចភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នបាន ។ ក្នុង

ករណីដែលមានពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន ត្រូវចាត់ទុកថា មានការដាក់ពាក្យបណ្ដឹងទៅតុលាការដែលចេញដីកាសម្រេចដាស់តឿន នៅពេលដែលពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿនត្រូវបានដាក់ ហើយនីតិវិធីដាស់តឿនត្រូវផ្ទេរទៅនីតិវិធីបណ្ដឹងធម្មតាវិញ (មាត្រា ៣២៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ បន្ទាប់មក តុលាការត្រូវធ្វើការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃការទាមទារដែលត្រូវបានអះអាងដោយម្ចាស់បំណុល និង ចេញសាលក្រម តាមនីតិវិធីបណ្ដឹងធម្មតា ។ ក្នុងករណីនេះ សោហ៊ុយសម្រាប់នីតិវិធីដាស់តឿន ត្រូវបានគិតជាផ្នែកមួយនៃប្រាក់ប្រដាប់ក្ដី (មាត្រា ៣២៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

២. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

(១) អត្ថន័យនៃពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

ក្នុងករណីដែលកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេល ២ សប្ដាហ៍ ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូនដីកាសម្រេចដាស់តឿននោះ ឬ ក្នុងករណីដែលពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនដែលបានធ្វើឡើងក្នុងអំឡុងពេលនោះ ត្រូវបានលើកចោល ដោយហេតុថា មិនស្របច្បាប់ តុលាការត្រូវភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ក្នុងដីកាសម្រេចដាស់តឿននោះ ។ ក្នុងករណីនេះ កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចការដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ ក្នុងអំឡុងពេល ២ សប្ដាហ៍ ដោយគិតពីថ្ងៃដែលបានទទួលនូវការបញ្ជូននូវដីកាសម្រេចការដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ននោះ (មាត្រា ៣២៩ កថាខណ្ឌទី ១) ។ អំឡុងពេល ២ សប្ដាហ៍នេះ មិនអាចធ្វើការពន្យារបានទេ (មាត្រា ៣២៩ កថាខណ្ឌទី ២) ហើយប្រសិនបើកូនបំណុលមិនបានដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនក្នុងអំឡុងពេលនេះទេ នីតិវិធីនៃការដាស់តឿននេះ ត្រូវបញ្ចប់ ហើយដីកាសម្រេចដាស់តឿននេះ ត្រូវមានអានុភាពដូចសាលក្រមស្ថាពរដែរ (មាត្រា ៣៣៣) ។

(២) ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលមិនស្របច្បាប់

ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន នៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ហើយប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំនោះមិនស្របច្បាប់ទេ (ឧទាហរណ៍ អំឡុងពេលដែលអាចដាក់ពាក្យសុំតវ៉ាចំពោះការដាស់តឿននោះ បានកន្លងផុតទៅហើយ ជាដើម) តុលាការត្រូវលើកចោលពាក្យសុំតវ៉ានោះ ដោយដីកាសម្រេច (មាត្រា ៣៣០ កថាខណ្ឌទី ១) ។ កូនបំណុលអាចប្ដឹងជំទាស់ចំពោះដីកាសម្រេចនេះបាន (មាត្រា ៣៣០ កថាខណ្ឌទី ២) ។ ប្រសិនបើដីកាសម្រេចលើកចោលពាក្យសុំតវ៉ា ចូលជាស្ថាពរហើយ នោះមានលទ្ធផលដូចគ្នានឹងករណីដែលគ្មានពាក្យសុំតវ៉ាចំពោះដីកាសម្រេច

ដាស់តឿនក្នុងអំឡុងពេលសម្រាប់ដាក់ពាក្យសុំតវ៉ា ហេតុដូច្នេះ ដីកាសម្រេចដាស់តឿន ត្រូវមានអានុភាពដូច សាលក្រមស្ថាពរដែរ ( មាត្រា ៣៣៣) ។

( ៣) អានុភាពនៃពាក្យសុំតវ៉ាស្របច្បាប់ចំពោះដីកាសម្រេចដាស់តឿន

ក្នុងករណីដែលពាក្យសុំតវ៉ាចំពោះដីកាសម្រេចការដាស់តឿន ត្រូវបានដាក់ដោយស្របច្បាប់ នៅក្រោយការ ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រូវចាត់ទុកថា មានការដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញ ដីកាសម្រេចដាស់តឿន ចំពោះការទាមទារដែលម្ចាស់បំណុលអះអាង នៅពេលដែលមានពាក្យសុំឱ្យចេញ ដីកាសម្រេចដាស់តឿន ( មាត្រា ៣៣១ វាក្យខណ្ឌទី ១) ហើយនីតិវិធីនៃការដាស់តឿននេះ ត្រូវផ្ទេរទៅ នីតិវិធីបណ្តឹងធម្មតា ។ ក្នុងករណីនេះ សោហ៊ុយសម្រាប់នីតិវិធីនៃការដាស់តឿននេះ ក្លាយទៅជាផ្នែកមួយ នៃប្រាក់ប្រដាប់ក្តី ( មាត្រា ៣៣១ វាក្យខណ្ឌទី ២) ។

ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ដែលបានធ្វើនៅក្រោយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន មិនត្រូវមានអានុភាពធ្វើឱ្យបាត់បង់នូវអានុភាពនៃដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យ អនុវត្តជាបណ្តោះអាសន្នទេ ។ ផ្ទុយទៅវិញ ពាក្យសុំតវ៉ានេះ មានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបណ្តឹង ឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលទាមទារឱ្យលុបចោលដីកាសម្រេច ។ ហេតុដូច្នេះ ក្នុងករណីដែលការ សម្រេចសេចក្តីស្តីពីការទាមទាររបស់ម្ចាស់បំណុល តាមនីតិវិធីបណ្តឹងដែលត្រូវបានផ្ទេរពីនីតិវិធីដាស់តឿន ដោយពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន មានភាពស្របគ្នាទៅនឹងដីកាសម្រេចដាស់តឿន ( មានន័យថា តុលាការនឹងទទួលស្គាល់នូវការទាមទារ) តុលាការត្រូវចេញសាលក្រមដែលទទួលស្គាល់នូវដីកាសម្រេចដាស់ តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ( មាត្រា ៣៣២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ។ ប៉ុន្តែ ប្រសិនបើនីតិវិធីដាស់តឿននោះខុសច្បាប់ ត្រូវចេញសាលក្រមលុបចោលដីកាសម្រេចដាស់តឿន ។ សូមមើលមាត្រាដដែល កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ផ្ទុយទៅវិញ ប្រសិនបើយល់ឃើញថា ការ ទាមទារនោះគ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវចេញសាលក្រមដែលលុបចោលនូវដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ( មាត្រា ៣៣២ កថាខណ្ឌទី ២) ។

# គន្ថីទី ៧ អន្តរប្បញ្ញត្តិ និង អវសានប្បញ្ញត្តិ

## ជំពូកទី ១ អត្ថន័យនៃអន្តរប្បញ្ញត្តិ និង ភាពចាំបាច់នៃប្បញ្ញត្តិនេះ

### ១. អត្ថន័យនៃអន្តរប្បញ្ញត្តិ

ពេលដែលមានការអនុម័តច្បាប់ថ្មី ឬ ពេលដែលបានធ្វើវិសោធនកម្ម ឬ លុបចោលនូវច្បាប់ចាស់ណាមួយ ប្រព័ន្ធច្បាប់ នោះនឹងមានការផ្លាស់ប្តូរ ហើយសណ្តាប់ធ្នាប់នៃច្បាប់ក៏មានការផ្លាស់ប្តូរដែរ ។ ក្នុងករណីនេះ ប្រសិនបើអនុវត្តច្បាប់ថ្មីភ្លាមតែម្តងទៅ នឹងអាចធ្វើឱ្យខូចដល់ស្ថិរភាពច្បាប់ដោយមិនសមរម្យបាន ហើយអាចបង្កើតឱ្យមានចលាចលដល់ជីវភាព ក្នុងសង្គម ឬ ដល់នីតិវិធីច្បាប់ក៏មានដែរ ។ ដូច្នេះហើយ ដើម្បីឱ្យមានភាពរលូនក្នុងការប្តូរពីសណ្តាប់ធ្នាប់ច្បាប់ចាស់ ទៅសណ្តាប់ធ្នាប់ច្បាប់ថ្មី ចាំបាច់ត្រូវមានការសម្រួលរវាងសណ្តាប់ធ្នាប់នៃច្បាប់ចាស់ និង សណ្តាប់ធ្នាប់នៃច្បាប់ថ្មី ហើយទទួលស្គាល់នូវការអនុវត្តច្បាប់ចាស់ដែលមានពីមុនមកជាបណ្តោះអាសន្ន ឬ ចាំបាច់មានបញ្ញត្តិអំពីវិធានការពិសេសជាបណ្តោះអាសន្ន ស្តីពីការអនុវត្តបញ្ញត្តិនៃច្បាប់ថ្មី ។ វិធានការស្តីពីការសម្រួលនូវសណ្តាប់ធ្នាប់រវាងច្បាប់ចាស់ និង ច្បាប់ថ្មីដូចនេះ ហៅថា "វិធានការអន្តរកាល" រីឯបញ្ញត្តិដែលកំណត់នូវវិធានការទាំងនេះ ហៅថា "អន្តរប្បញ្ញត្តិ"

### ២. គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី និង គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់

ក្នុងច្បាប់នីតិវិធី ដូចជាក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍ នីតិវិធីដែលជាកម្មវត្ថុនៃច្បាប់នេះ គឺជាទម្រង់នៃសកម្មភាពបណ្តឹងដែលមានជាបន្តបន្ទាប់ ដែលធ្វើឡើងដោយតុលាការ ឬ ដោយភាគី ហើយមានការពាក់ព័ន្ធនឹងការកន្លងផុតទៅនៃពេលវេលាដែលកំណត់មួយ ក្នុងអំឡុងពេលដែលចាប់ផ្តើម រហូតដល់ពេលបញ្ចប់នីតិវិធីបណ្តឹង ហេតុនេះហើយ ចាំបាច់ត្រូវកំណត់នូវការអនុវត្តនូវនីតិវិធីចាស់ ឬ នីតិវិធីថ្មី ចំពោះរឿងក្តីដែលត្រូវបានចាប់ផ្តើមចាត់ការមុនពេលធ្វើវិសោធនកម្មច្បាប់ ។ ចំពោះបញ្ហានេះ មានគំនិតមូលដ្ឋានពីរ គឺ "គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី" និង "គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់" ។

ជាទូទៅ "គោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី" គឺ ជាគំនិតមួយដែលមានខ្លឹមសារថា ត្រូវអនុវត្តតាមនីតិវិធីនៃច្បាប់ក្រោយធ្វើវិសោធនកម្ម ចំពោះរឿងក្តីដែលត្រូវបានដាក់មុនពេលចូលជាធរមាននៃច្បាប់ដែលបានធ្វើវិសោធនកម្មនោះ ឬ មុនពេលអនុវត្តច្បាប់ថ្មីនេះ (ឬ ចំណុចដែលកើតមានឡើងមុនការអនុវត្តច្បាប់ថ្មី) ។

រីឯ "គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់" វិញ គឺជាគំនិតមួយដែលមានខ្លឹមសារថា ត្រូវអនុវត្តតាមច្បាប់ថ្មី ចំពោះតែរឿងក្តីដែលត្រូវបានដាក់ក្រោយការចូលជាធរមាននៃច្បាប់ដែលបានធ្វើវិសោធនកម្ម ហើយត្រូវអនុវត្តតាម នីតិវិធីមុនពេលធ្វើវិសោធនកម្ម ចំពោះរឿងក្តីដែលបានដាក់មុនពេលច្បាប់ថ្មីត្រូវចូលជាធរមាន ឬ ត្រូវបានអនុវត្ត (ឬ ចំណុចដែលកើតមានឡើងមុនការអនុវត្តច្បាប់ថ្មី) ។ម្យ៉ាងទៀត ស្តីពីទោសប្បញ្ញត្តិវិញ

ដោយសារមាន "គោលការណ៍នៃការផ្តន្ទាទោសតាមបញ្ញត្តិនៃច្បាប់ដែលជាធរមាននៅពេលប្រព្រឹត្តបទល្មើស" ហេតុនេះហើយ មិនអាចអនុវត្តដោយប្រតិសកម្មនូវច្បាប់ដែលបានធ្វើវិសោធនកម្មបានឡើយ ។

៣. ផលប្រយោជន៍ និង ផលវិបត្តិនៃគោលការណ៍អនុវត្តតាមច្បាប់ថ្មី និង គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ព្រមទាំងគោលជំហរជាមូលដ្ឋាននៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មី

ច្បាប់វិសោធនកម្ម គឺជាច្បាប់មួយដែលកែលម្អនូវនីតិវិធីដែលអនុវត្តកន្លងមក ដូច្នេះហើយ បើគិតតាមទស្សនៈនៃការសម្រេចនូវគោលគំនិតនៃច្បាប់វិសោធនកម្មឱ្យបានឆាប់រហ័ស ជាទូទៅ គួរតែយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី ។ ប៉ុន្តែ ការជ្រើសរើសគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មីទាំងស្រុងទៅ អាចធ្វើឱ្យមានការច្របូកច្របល់ដល់នីតិវិធី ឬ អាចធ្វើឱ្យខូចផលប្រយោជន៍ដល់សិទ្ធិរបស់ភាគីបាន ហេតុនេះហើយ ក្នុងករណីដែលបានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មី ចាំបាច់បញ្ជាក់ឱ្យច្បាស់លាស់នូវផ្នែកដែលត្រូវបានធ្វើវិសោធនកម្មជាសារធាតុ ដោយច្បាប់វិសោធនកម្ម ហើយត្រូវពិចារណាអំពីវិធានការអន្តរកាលនីមួយៗ ដោយកម្រិតនូវវិសាលភាពនៃការអនុវត្តនោះ ដើម្បីផ្ទេរទៅនីតិវិធីថ្មីនេះឱ្យមានដំណើរការស្រួល ។

ក្នុងករណីដែលបានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ កម្មវត្ថុនៃការអនុវត្តច្បាប់វិសោធនកម្មមានភាពច្បាស់លាស់ ហើយក៏ពុំមានការច្របូកច្របល់ក្នុងនីតិវិធី ជាអាទិ៍ ហើយអន្តរប្បញ្ញត្តិក៏មានភាពងាយស្រួល ប៉ុន្តែ នីតិវិធីចាស់ និង ថ្មី ត្រូវបានអនុវត្តព្រមគ្នាក្នុងអំឡុងពេលដ៏វែង ក្រោយពីច្បាប់វិសោធនកម្មបានចូលជាធរមាន ហើយមានការពិបាកនឹងសម្រេចនូវគោលគំនិតនៃច្បាប់ថ្មីឱ្យបានឆាប់រហ័សជាអាទិ៍ ។

ដូច្នេះហើយ ក្រមនីតិវិធីរដ្ឋប្បវេណីថ្មី បានជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ថ្មី ដែលមានពន្យល់ដូចខាងលើនេះ មកធ្វើជាគោលការណ៍នៃវិធានការអន្តរកាល ហេតុនេះហើយ ចំពោះរឿងក្តីដែលកំពុងចាត់ការ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ដោយមានការកម្រិតនូវវិសាលភាពនៃការអនុវត្តក្រមថ្មី តាមរយៈការទទួលស្គាល់នូវអានុភាពដែលកើតមានឡើងមុនពេលអនុវត្តក្រមថ្មី (មាត្រា ៥៧២) ហើយកំណត់អំពីវិធានការអន្តរកាលជាក់ស្តែងចំពោះករណីនីមួយៗ តាមតម្រូវការ ចាប់ពីមាត្រា ៥៧៣ ទៅ ។

## ជំពូកទី ២ គោលការណ៍នៃវិធានការអន្តរកាល

### ១. ការជ្រើសរើសយកគោលការណ៍ការអនុវត្តតាមច្បាប់ថ្មី

ក្នុងគន្ថីទី ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនេះ មានបញ្ញត្តិស្តីពីគោលការណ៍នៃអន្តរប្បញ្ញត្តិជាដំបូង (មាត្រា ៥៧២) ដែលកំណត់ថា ជាគោលការណ៍ ក្រមនីតិវិធីរដ្ឋប្បវេណីបានជ្រើសរើសយកនូវគោលការណ៍អនុវត្តច្បាប់ថ្មីនេះ ។ ហេតុដូច្នេះ ចំពោះរឿងក្តីដែលកំពុងចាត់ការ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី លើកលែងតែមានបញ្ញត្តិពិសេស នៅក្នុងគន្ថីទី ៨ ។ ម្យ៉ាងទៀត ក្រមនេះក៏កម្រិតនូវវិសាលភាពនៃការអនុវត្តក្រមថ្មីដែរ ដោយទទួលស្គាល់នូវអានុភាពដែលកើតឡើង មុនពេលអនុវត្តក្រមថ្មី ។

ចំពោះរឿងក្តីដែលកំពុងចាត់ការពេលអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើពុំមានបញ្ញត្តិពិសេសនៅក្នុងគន្ថីទី ៨ ទេ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមនេះ ហើយត្រូវបញ្ចប់នីតិវិធីដោយក្រមថ្មី (មាត្រា ៥៧២ វាក្យខណ្ឌទី ១) ។ មានន័យថា ចំពោះរឿងក្តីដែលកំពុងចាត់ការ ប្រសិនបើនីតិវិធីដែលបានធ្វើមុនពេលនោះជានីតិវិធីស្របច្បាប់តាមនីតិវិធីចាស់ ត្រូវគោរពអានុភាពនៃនីតិវិធីទាំងនោះ ហើយនីតិវិធីក្រោយការអនុវត្តក្រមថ្មី ត្រូវអនុវត្តតាមក្រមថ្មី ហើយត្រូវបញ្ចប់តាមក្រមថ្មី ដោយយកនីតិវិធីដែលបានធ្វើហើយពីមុន មកធ្វើជាមូលដ្ឋាន ។

### ២. ការរក្សាទុកនូវអានុភាពដែលកើតមានឡើងក្នុងនីតិវិធីនៃច្បាប់ចាស់

ក្នុងករណីនេះ អានុភាពនៃនីតិវិធីដែលបានកើតឡើងនៅពេលក្រមថ្មីត្រូវបានអនុវត្ត ត្រូវរក្សាទុក (មាត្រា ៥៧២ វាក្យខណ្ឌទី ២) ។ ដូច្នេះហើយ ចំពោះការកោះហៅតាមកាលបរិច្ឆេទ ប្រសិនបើការអនុវត្តនីតិវិធីកោះហៅនេះស្របតាមនីតិវិធីចាស់ទេ ទោះជាមិនបានធ្វើនីតិវិធីនេះតាមក្រមថ្មីក៏ដោយ ក៏អានុភាពនៃការកោះហៅដែលបានធ្វើមុនការអនុវត្តក្រមថ្មី នៅតែមានដដែលដែរ ។ ម្យ៉ាងទៀត ចំពោះការសម្រេចអំពីការជ្រើសរើសសាក្សីក៏ដូចគ្នាដែរ គឺ អានុភាពនៃការជ្រើសរើសនេះនៅមានដដែល ហើយមិនចាំបាច់ចេញដីកាសម្រេចយកសាក្សីជាថ្មីម្តងទៀត តាមក្រមថ្មីនេះទេ ហើយអាចធ្វើការពិនិត្យភស្តុតាងតែម្តងបាន ។

ម្យ៉ាងទៀត កាលបរិច្ឆេទនៃការជំនុំជម្រះដែលកំណត់ហើយនៅពេលអនុវត្តក្រមនេះ ត្រូវចាត់ទុកថា បានកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តាមបញ្ញត្តិនៃក្រមនេះ (មាត្រា ៥៧៨ កថាខណ្ឌទី ១) ហេតុនេះហើយ អាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅកាលបរិច្ឆេទដែលបានកំណត់ជាកាលបរិច្ឆេទនៃការជំនុំជម្រះបាន ។

# ជំពូកទី ៣ វិធានការអន្តរកាលនីមួយៗ

## ១. វិធានការអន្តរកាលស្តីពីសមត្ថកិច្ច

ចំពោះសមត្ថកិច្ចនៃបណ្តឹង និង ការផ្ទេរបណ្តឹង ដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក (មាត្រា ៥៧៣) ។ ដូច្នេះហើយ ចំពោះសមត្ថកិច្ច និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវចាត់ចែងជាបន្ត តាមគំនិតនៃនីតិវិធីចាស់ ដោយពុំមានទទួលឥទ្ធិពលអ្វីទាំងអស់ពីការអនុវត្តក្រមថ្មីនេះទេ (គោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់) ។

ការជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ចំពោះសមត្ថកិច្ច និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលអនុវត្តក្រមថ្មីនេះ មានមូលហេតុដូចតទៅ ។ ប្រសិនបើធ្វើការជ្រើសរើសគោលការណ៍អនុវត្តតាមក្រមថ្មី ចំពោះសមត្ថកិច្ច និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្តទៅ សមត្ថកិច្ចដែលត្រូវបានទទួលស្គាល់ដោយនីតិវិធីចាស់ នឹងអាចលែងត្រូវបានទទួលស្គាល់តាមក្រមថ្មី ឬ ផ្ទុយទៅវិញ កំហុសនៃសមត្ថកិច្ចដោយនីតិវិធីចាស់ នឹងអាចក្លាយទៅជាសមត្ថកិច្ចត្រឹមត្រូវ តាមក្រមថ្មី ឬ បណ្តឹងដែលមិនស្របល័ក្ខខ័ណ្ឌដើម្បីផ្ទេរនៅក្នុងនីតិវិធីចាស់ នឹងអាចក្លាយទៅជាស្របនឹងល័ក្ខខ័ណ្ឌដើម្បីផ្ទេរតាមក្រមថ្មីទៅវិញ ជាអាទិ៍ ដែលធ្វើឱ្យខូចស្ថិរភាពនៃនីតិវិធី ហើយអាចធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ភាគីដោយមិនអាចគិតទុកជាមុនបាន ។ ម្យ៉ាងទៀត សមត្ថកិច្ចសាលាជម្រះក្តី ត្រូវគិតតាមពេលដាក់ពាក្យបណ្តឹង (មាត្រា ១៧) ដូច្នេះហើយ ប្រសិនបើវិធានដើម្បីធ្វើការវិនិច្ឆ័យអំពីសមត្ថកិច្ច ត្រូវបានផ្លាស់ប្តូរដោយក្រមថ្មី មានន័យ ជាសារធាតុថា ការណ៍នេះនឹងខុសទៅនឹងគោលគំនិតនៃមាត្រា ១៧ នេះ ។

ហេតុនេះហើយ មាត្រា ៥៧៣ បានចែងថា ចំពោះសមត្ថកិច្ចនៃបណ្តឹង និង ការផ្ទេរបណ្តឹងដែលកំពុងចាត់ការនៅពេលដែលក្រមនេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

## ២. វិធានការអន្តរកាលស្តីពីការបែងចែករឿងក្តី

(១) តាមនីតិវិធីចាស់ ចៅក្រមដែលទទួលបន្ទុករឿងក្តី ត្រូវបានចាត់តាំងដោយប្រធានតុលាការ ។ ផ្ទុយទៅវិញ តាមក្រមថ្មី ការបែងចែករឿងក្តីនៅតុលាការ ត្រូវកំណត់ទុកជាមុនជារៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ (មាត្រា ២៦ កថាខណ្ឌទី ១) ហើយរឿងក្តីនីមួយៗត្រូវបានបែងចែកដោយស្វ័យប្រវត្តិឱ្យចៅក្រមម្នាក់ៗ តាមការកំណត់អំពីការបែងចែកដែលត្រូវបានសម្រេចដោយប្រធានតុលាការ (មាត្រា ២៦ កថាខណ្ឌទី ២) ។

ការបែងចែករឿងក្តី ត្រូវធ្វើឡើងពេលដាក់ពាក្យបណ្តឹង ក៏ប៉ុន្តែ ក្នុងករណីដែលក្រមថ្មីត្រូវបានអនុវត្តនៅក្រោយពេលដាក់ពាក្យបណ្តឹង នឹងមានចម្ងល់ថា តើត្រូវធ្វើការបែងចែករឿងក្តីតាមបញ្ញត្តិនៃក្រមថ្មីនេះ ឬ

ត្រូវចាត់តាំងចៅក្រមតាមនីតិវិធីចាស់នោះ ឬ ចម្ងល់ផ្សេងទៀតថា ប្រសិនបើត្រូវបែងចែករឿងក្តីតាមបញ្ញត្តិនៃក្រមថ្មីនេះទៅ តើត្រូវបែងចែករឿងក្តីដោយយកពេលណាមួយមកធ្វើមូលដ្ឋាននៃពេលវេលា ។ ដូច្នេះហើយ មាត្រា ៥៧៤ មានចែងអំពីបញ្ញត្តិស្តីពីវិធានការអន្តរកាលដូចតទៅ ក្នុងករណីដែលមានចម្ងល់ក្នុងការអនុវត្តមាត្រា ២៦ ។

(២) ក្រោយការទទួលពាក្យបណ្តឹង ក្នុងករណីដែលក្រមថ្មីត្រូវបានអនុវត្ត នៅមុនពេលដែលចៅក្រមទទួលបន្ទុកនីតិវិធីស៊ើបសួរ ឬ ផ្សះផ្សា ត្រូវបានជ្រើសតាំង នោះត្រូវធ្វើការបែងចែករឿងក្តី ដោយចាត់ទុកថាបានដាក់ពាក្យបណ្តឹង នៅពេលដែលក្រមថ្មីត្រូវបានអនុវត្ត (មាត្រា ៥៧៤ កថាខណ្ឌទី ១) ។

ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្ត ក្រោយពេលជ្រើសតាំងចៅក្រមទទួលបន្ទុកនីតិវិធីស៊ើបអង្កេត ឬ ផ្សះផ្សា តែមុនពេលជ្រើសតាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមជំនុំជម្រះ ត្រូវចាត់ទុកថា ចៅក្រមទទួលបន្ទុក នីតិវិធីស៊ើបសួរ ឬ ផ្សះផ្សានោះ បានទទួលការបែងចែករឿងក្តីនោះតាមក្រមថ្មី (មាត្រា ៥៧៤ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ក្នុងករណីដែលរឿងក្តីនោះជារឿងក្តីស្តីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ ឬ បណ្តឹងជិតចិត្ត (មាត្រា ៣០ កថាខណ្ឌទី ១) ឬ រឿងក្តីផ្សេងទៀតដែលត្រូវចាត់ការដោយក្រុមប្រឹក្សាជំនុំជម្រះ ដូចជារឿងក្តីដែលត្រូវច្បាប់កំណត់ថា ត្រូវវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ (មាត្រា ២៣ កថាខណ្ឌទី ២) មិនអាចចាត់ការដោយចៅក្រមម្នាក់បានទេ ហេតុនេះហើយ ត្រូវធ្វើការបែងចែករឿងក្តីដោយចាត់ទុកថា ពាក្យបណ្តឹងនោះត្រូវបានដាក់ នៅពេលដែលក្រមថ្មីនេះ ត្រូវបានអនុវត្ត (មាត្រា ៥៧៤ កថាខណ្ឌទី ៣) ។

ក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ឬ ការជំនុំជម្រះបណ្តឹងសាទុក្ខ ក្នុងករណីដែលក្រមថ្មីត្រូវបានអនុវត្ត មុនការជ្រើសតាំងចៅក្រមជំនុំជម្រះ ត្រូវធ្វើការបែងចែករឿងក្តីដោយចាត់ទុកថា ពាក្យបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ ត្រូវបានដាក់នៅពេលក្រមថ្មីនេះត្រូវបានអនុវត្ត (មាត្រា ៥៧៤ កថាខណ្ឌទី ៤ និង កថាខណ្ឌទី ៥) ។

ប្រសិនបើចៅក្រមជំនុំជម្រះត្រូវបានជ្រើសតាំងនៅពេលអនុវត្តក្រមថ្មី នៅក្នុងមាត្រា ៥៧៤ ពុំមានចែងទេ តែយោងតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ ចៅក្រមជំនុំជម្រះត្រូវក្លាយជាចៅក្រមទទួលបន្ទុកនូវរឿងក្តីនោះដដែល ហើយធ្វើការជំនុំជម្រះបន្ត ហេតុនេះហើយ មិនចាំបាច់ធ្វើការបែងចែករឿងក្តីជាថ្មីទេ ។

៣. វិធានការអន្តរកាលស្តីពីការសម្រេចសេចក្តីអំពីពាក្យសុំដកហូត និង បណ្តឹងជិតចិត្ត

មាត្រា ៣០ (ការសម្រេចសេចក្តីអំពីពាក្យសុំដកហូត ឬ បណ្តឹងជិតចិត្ត) កថាខណ្ឌទី ១ ចែងថា ចំពោះការដកហូតចៅក្រម ឬ បណ្តឹងជិតចិត្តចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម ត្រូវសម្រេចសេចក្តី ដោយដីកាសម្រេច ហេតុនេះហើយ រឿងក្តីសុំដកហូតចៅក្រម ឬ បណ្តឹងជិតចិត្ត គឺជារឿងក្តីដែលច្បាប់កំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សានៃចៅក្រម

(មាត្រា ២៣ កថាខណ្ឌទី ២ ចំណុច ខ) ។ ក៏ប៉ុន្តែ ចំពោះសាលាដំបូងដែលពុំមានចៅក្រមគ្រប់ចំនួនដើម្បីអាចបង្កើតក្រុមប្រឹក្សាជំនុំជម្រះ ដោយមិនគិតអំពីចៅក្រមដែលត្រូវបានសុំដកហូត ឬ ប្ដឹងជំទាស់ ក្រមថ្មីអនុញ្ញាតឱ្យសម្រេចសេចក្ដីអំពីពាក្យសុំដកហូត ឬ បណ្ដឹងជំទាស់ ដោយចៅក្រមតែម្នាក់ ក្នុងមួយរយៈពេល ដូចដែលបានធ្វើពីមុនមក (មាត្រា ៥៧៥) ។ នេះគឺដោយសារ នៅតុលាការបែបនេះមិនអាចបង្កើតក្រុមប្រឹក្សាជំនុំជម្រះក្នុងស្ថានភាពខាងលើនេះបានទេ ម្យ៉ាងទៀត មានការពិបាកក្នុងការជ្រើសតាំងចៅក្រមជាបណ្ដោះអាសន្ន ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះឱ្យបានគ្រប់ចំនួនដើម្បីធ្វើការសម្រេចសេចក្ដីអំពីពាក្យសុំដកហូត ឬ បណ្ដឹងជំទាស់ ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមវិធានការពិសេសតាមផ្លូវច្បាប់ចាត់តាំងតុលាការ ។ ដូច្នេះហើយ មាត្រា ៥៧៥ នេះ ចែងអំពីវិធានការពិសេស ដើម្បីឱ្យអាចធ្វើការសម្រេចសេចក្ដីអំពីពាក្យសុំដកហូត ឬ បណ្ដឹងជំទាស់ ដោយចៅក្រមតែម្នាក់ ក្នុងមួយរយៈពេលដូចដែលបានធ្វើពីមុនមក ។ ហេតុនេះហើយ នៅតុលាការដែលមាត្រានេះត្រូវអនុវត្ត ករណីនៃការសុំដកហូត ឬនៃបណ្ដឹងជំទាស់នេះ មិនមែនជារឿងក្ដីដែលច្បាប់កំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និង ជម្រះក្ដីដោយក្រុមប្រឹក្សានៃចៅក្រម (មាត្រា ២៣ កថាខណ្ឌទី ២ ចំណុច ខ) ទេ ។

ម្យ៉ាងទៀត "មួយរយៈពេល" ដែលមានក្នុងនេះ គឺជាពាក្យដែលប្រើសម្រាប់ករណីដែលអំឡុងពេលមិនអាចកំណត់ ឱ្យបានច្បាស់លាស់ ហើយនេះបង្ហាញថាជាវិធានការបណ្ដោះអាសន្នតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែមាត្រានេះ មិនមែនជាបញ្ញត្តិដែលកម្រិតអំឡុងពេលអនុវត្តជាក់លាក់ (មានន័យថា ច្បាប់ ឬ បញ្ញត្តិដែលកម្រិតអំឡុងពេលមួយដែលមានសុពលភាព) ទេ ហេតុនេះហើយ ដើម្បីធ្វើឱ្យបញ្ញត្តិនេះបាត់បង់អានុភាពចាំបាច់ត្រូវធ្វើនិរាករណ៍ដោយច្បាប់ ។

## ៤. វិធានការអន្តរកាលស្ដីពីនីតិវិធីអង្កេតស៊ើបសួរ និង នីតិវិធីក្រោយពីនេះ

(១) នីតិវិធីអង្កេតស៊ើបសួរ នៅក្នុងនីតិវិធីចាស់ ពេលខ្លះមានលក្ខណៈជាការរៀបចំនូវចំណុចវិវាទដែលជាការត្រៀមនៃការជំនុំជម្រះផង ពេលខ្លះមានលក្ខណៈជាការពិនិត្យភស្តុតាងផង ហើយនោះគឺជានីតិវិធីមួយដែលមានលក្ខណៈខុសគ្នាឆ្ងាយពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងក្រមនេះ ។

ម្យ៉ាងទៀត ក្រមថ្មីនេះ បានបែងចែកដាច់ដោយឡែកនូវការរៀបចំចំណុចវិវាទ និង ការពិនិត្យភស្តុតាងនៅក្នុងនីតិវិធី ដោយធ្វើនីតិវិធីផ្សេងពីគ្នា ហើយពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ មុននឹងធ្វើការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីពិនិត្យភស្តុតាង និង ធ្វើសកម្មភាពជំនុំជម្រះផ្សេងទៀត ត្រូវធ្វើការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន ដើម្បីរៀបចំការអះអាងរបស់ភាគី ភស្តុតាង និង ចំណុចវិវាទផ្សេងទៀត (មាត្រា ៨០) ។ ម្យ៉ាងទៀត នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវធ្វើឡើងសម្រាប់ការត្រៀមនៃកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយសកម្មភាពទាំងនោះដែលធ្វើឡើងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ពុំមែនយក

មកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យដោយស្វ័យប្រវត្តិទេ ហើយតាមរយៈការធ្វើសេចក្ដីថ្លែងការណ៍ស្ដីពីលទ្ធផលនៃការត្រៀមសម្រាប់ការទាញហេតុផល នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពេលក្រោយនោះ ទើបអាចក្លាយជាមូលដ្ឋាននៃការវិនិច្ឆ័យបាន (មាត្រា ១១៦) ។

ដោយសារតែទម្រង់នៃនីតិវិធីនេះ និង ដោយសារនីតិវិធីអង្កេតស៊ើបសួរ ជាគោលការណ៍ មានលក្ខណៈ និង ខ្លឹមសារខុសគ្នាទាំងស្រុង ពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហេតុដូច្នេះ លើកលែងតែករណីដែលកាលបរិច្ឆេទនៃការជំនុំជម្រះត្រូវបានចាប់ផ្ដើមរួចហើយ ហើយលទ្ធផលនៃនីតិវិធីអង្កេតស៊ើបសួរត្រូវបានក្លាយជាមូលដ្ឋាននៃការវិនិច្ឆ័យរួចហើយ នៅពេលដែលក្រមថ្មីត្រូវបានអនុវត្ត ក្នុងករណីដែលក្រមថ្មីនេះត្រូវបានអនុវត្ត មុនកាលបរិច្ឆេទនៃការជំនុំជម្រះ មិនគួរបន្តនីតិវិធីសម្រាប់ការទាញហេតុផលពីនីតិវិធីអង្កេតស៊ើបសួរដោយអនុវត្តតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ ចំពោះនីតិវិធីអង្កេតស៊ើបសួរទេ ។

ដូច្នេះ មាត្រា ៥៧៦ ចែងស្ដីពីវិធានការអន្តរកាលពិសេសសម្រាប់នីតិវិធីអង្កេតស៊ើបសួរដូចខាងក្រោម ។

(២) ក្នុងករណីដែលបានអនុវត្តក្រមថ្មី នៅពេលកំពុងធ្វើនីតិវិធីអង្កេតស៊ើបសួរ ការបន្តនូវនីតិវិធីអង្កេតស៊ើបសួរនេះ ហើយបន្តនីតិវិធីអង្កេតស៊ើបសួរនេះទៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាការធ្វើផ្ទុយនឹងគោលគំនិតនៃក្រមថ្មី ដូច្នេះតុលាការត្រូវបញ្ឈប់នីតិវិធីអង្កេតស៊ើបសួរនេះជាបន្ទាន់ ហើយធ្វើការកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយកោះហៅភាគីទាំងសងខាងឱ្យចូលរួម ឱ្យបានទាន់ពេលវេលា (មាត្រា ៥៧៦ កថាខណ្ឌទី ១) ។

រីឯនីតិវិធីបន្ទាប់ពីនោះ គឺដូចគ្នានឹងករណីដែលបានអនុវត្តតាមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតាំងពីដំបូងមក ក៏ប៉ុន្តែ ក្នុងនីតិវិធីនៃការត្រៀមសម្រាប់ការទាញហេតុផល អាចធ្វើសេចក្ដីសម្រេចអំពីការស្នើសុំឱ្យពិនិត្យភស្តុតាង និង សេចក្ដីសម្រេចដទៃទៀតបាន នៅក្រៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយលើសពីនេះ អាចធ្វើការពិនិត្យភស្តុតាងជាឯកសារបាន ក្នុងកម្រិតដែលចាំបាច់ដើម្បីរៀបចំចំណុចវិវាទ និង រៀបចំភស្តុតាង ។ ហេតុនេះហើយ អាចចាត់ទុកថា លទ្ធផលនៃការពិនិត្យភស្តុតាង ជាអាទិ៍ ដែលបានមកពីនីតិវិធីនៃការអង្កេតស៊ើបសួរ ក៏មានសុពលភាពក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក្នុងទំហំនៃសិទ្ធិអំណាចរបស់តុលាការ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែលបានបញ្ជាក់ខាងលើនេះដែរ ។ ដូច្នេះ បញ្ញត្តិនៃមាត្រា ៥៧៦ កថាខណ្ឌទី ៣ មានចែងទទួលស្គាល់នូវអានុភាពនៃសកម្មភាពបណ្ដឹងដែលបានធ្វើក្នុងនីតិវិធីអង្កេតស៊ើបសួរ ក្នុងទំហំនៃសិទ្ធិអំណាចរបស់តុលាការ ដូចបានបញ្ញត្តនៅក្នុងមាត្រា ១០៦ (សកម្មភាពនៃបណ្ដឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល) ។

(៣) ក្រោយការបញ្ចប់នីតិវិធីអង្កេតស៊ើបសួរ ក្នុងករណីដែលបានអនុវត្តក្រមថ្មី មុនពេលបើកកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ពេលនោះ បានលទ្ធផលពីនីតិវិធីអង្កេតស៊ើបសួររួចហើយ ក៏ប៉ុន្តែ មិនគួរទទួលស្គាល់នូវលទ្ធផលដែលបានមកពីនីតិវិធីអង្កេតស៊ើបសួរនោះ ហើយចាប់ផ្ដើមការជំនុំជម្រះរឿងក្ដីនោះ

ដោយការទាញហេតុផលដោយផ្ទាល់មាត់ ដោយមិនបានឆ្លងកាត់តាមការរៀបចំនូវចំណុចវិវាទ និង រៀបចំភស្តុតាងឱ្យបានពេញលេញ ដោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ ។ ដូច្នេះហើយបានជា មាត្រា ៥៧៦ កថាខណ្ឌទី ២ មានចែងថា ក្នុងករណីដែលបានបញ្ចប់នីតិវិធីអង្កេតស៊ើបសួររួចហើយ ហើយបានអនុវត្តក្រមថ្មីនេះមុនកាលបរិច្ឆេទនៃសវនាការ តុលាការត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយបន្ទាប់មក ធ្វើការកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ដូច្នេះ ក្នុងករណីនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កុំឱ្យមានការយឺតយ៉ាវ ហើយធ្វើការកោះហៅភាគីឱ្យចូលរួម ។ ក៏ប៉ុន្តែ ក្នុងករណីដែលបានធ្វើការកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះរឿងក្តីលើកទីមួយរួចហើយ បន្ទាប់ពីបានបញ្ចប់នីតិវិធីអង្កេតស៊ើបសួរ អាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បាន មុននឹងចាប់ផ្តើមកាលបរិច្ឆេទនេះ (យោងតាមមាត្រា ៥៧៨ កថាខណ្ឌទី ១ កាលបរិច្ឆេទនៃការជំនុំជម្រះរឿងក្តីនេះ អាចចាត់ទុកថាជាកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន) ។ ដូច្នេះ ក្នុងករណីនេះ មិនចាំបាច់ធ្វើការកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ (មាត្រា ៥៧៦ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

នីតិវិធីបន្ទាប់ពីនោះ ត្រូវធ្វើដូចគ្នានឹងករណីដែលបានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ពីដើមទីដែរ ក៏ប៉ុន្តែ ស្តីពីអានុភាពនៃសកម្មភាពបណ្តឹងដែលបានធ្វើនៅក្នុងនីតិវិធីអង្កេតស៊ើបសួរវិញ ត្រូវចាត់ទុកដូចគ្នានឹងករណីដែលបានអនុវត្តក្រមថ្មីនៅពេលកំពុងធ្វើនីតិវិធីអង្កេតស៊ើបសួរដែរ (មាត្រា ៥៧៦ កថាខណ្ឌទី ៣) ។

(៤) ក្នុងករណីដែលក្រមថ្មីត្រូវបានអនុវត្តនៅក្រោយពេលបើកកាលបរិច្ឆេទនៃការជំនុំជម្រះ ចម្លើយជាកសិណសាក្សីរបស់សាក្សី ឬ លទ្ធផលនៃការសាកសួរសាមីភាគី នៅក្នុងការពិនិត្យភស្តុតាងនៃដំណាក់កាលនៃនីតិវិធីអង្កេតស៊ើបសួរ នឹងក្លាយទៅជាភស្តុតាងតែម្តង ហើយនឹងអាចប្រើសម្រាប់ទទួលស្គាល់អង្គហេតុ ជាមួយគ្នានឹងភស្តុតាងផ្សេងទៀតដែលត្រូវបានពិនិត្យ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ក្រោយពេលនោះ ។ ក្នុងករណីនេះ ប្រសិនបើអាចបញ្ចប់ការវិនិច្ឆ័យ និង ជំនុំជម្រះ ដោយមិនធ្វើការសាកសួរសាក្សី ឬ សាមីភាគីនៅក្នុងការជំនុំជម្រះបានទៅ ចំពោះសាមីភាគី គឺមិនផ្តល់ឱកាសឱ្យធ្វើការសាកសួរសាក្សី ឬ ភាគីទាំងនោះនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ ហើយនឹងទទួលនូវសាលក្រម ដូច្នេះហើយ នេះគឺជាការណ៍មួយដែលអាចធ្វើឱ្យមានកង្វះខាតក្នុងការធានានូវនីតិវិធីចំពោះភាគី ។

ដូច្នេះហើយ ដើម្បីធានានូវសិទ្ធិសាកសួររបស់ភាគី មាត្រា ៥៧៦ កថាខណ្ឌទី ៤ មានចែងថា ត្រូវធ្វើការសាកសួរសាក្សី ឬ ភាគី ប្រសិនបើនៅក្នុងការជំនុំជម្រះ មិនបានធ្វើការសាកសួរសាក្សី ឬ សាកសួរសាមីភាគីដែលបានសាកសួរ ហើយនៅក្នុងនីតិវិធីអង្កេតស៊ើបសួរ ហើយបើភាគីស្នើសុំឱ្យធ្វើការសាកសួរ នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ។

## ៥. វិធានការអន្តរកាលស្តីពីប្រាក់ប្រដាប់ក្តី

(១) ចំពោះប្រាក់ប្រដាប់ក្តីនៃបណ្តឹងរដ្ឋប្បវេណី ដែលភាគី ឬ បុគ្គលពាក់ព័ន្ធផ្សេងទៀត ត្រូវទទួលបន្ទុក ទាក់ទងទៅនឹងបណ្តឹងដែលបានដាក់នៅមុនពេលដែលក្រមថ្មីត្រូវបានអនុវត្ត មិនត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីទេ គឺ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក (មាត្រា ៥៧៧) ។ នេះគឺជាការជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ចំពោះប្រាក់ប្រដាប់ក្តី ដោយមានមូលហេតុដូចតទៅ ។

បណ្តឹងរដ្ឋប្បវេណី មានទម្រង់ជានីតិវិធីដែលមានជាបន្តបន្ទាប់ ដែលមានសកម្មភាពបណ្តឹងជាច្រើន រួមទាំងសកម្មភាពដែលចាំបាច់ត្រូវបង់ពន្ធ ឬ សោហ៊ុយ ហើយការសម្រេចសេចក្តីអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី ត្រូវធ្វើឡើង ចំពោះប្រាក់ប្រដាប់ក្តីសរុបនៃការជម្រះក្តីនៃថ្នាក់នីមួយៗ ឬ ចំពោះសោហ៊ុយសរុបតាមថ្នាក់ទាំងអស់នៃការជម្រះក្តី (មាត្រា ៦៥) ហើយត្រូវកំណត់ជាស្ថាពរនូវចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនេះ ភ្ជាប់ជាមួយគ្នានឹងរឿងក្តីនីមួយៗ ហើយត្រូវធ្វើការចាត់ចែងទូទាត់រវាងប្រាក់ប្រដាប់ក្តីរបស់ភាគីទាំងសងខាង (មាត្រា ៦៦) ។ យោងតាមស្ថានភាពទាំងនេះ ចំពោះពន្ធ និង ប្រាក់ប្រដាប់ក្តីផ្សេងទៀត ដែលភាគី ឬ បុគ្គលដែលមានទំនាក់ទំនងនឹងរឿងក្តីដែលបានដាក់មុនពេលអនុវត្តក្រមនេះ ត្រូវទទួលបន្ទុក ការផ្លាស់ប្តូរទំហំ និង ចំនួនទឹកប្រាក់ ទៅតាមពេលដែលកើតមានឡើងមុន ឬ ក្រោយការអនុវត្តក្រមថ្មីទៅ នឹងអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពច្បាប់ និង សមភាពរវាងភាគីបាន ។ ឧទាហរណ៍ ពន្ធដើម្បីដាក់ពាក្យបណ្តឹង ត្រូវបង់នៅពេលដាក់ពាក្យបណ្តឹង ។ ប្រសិនបើធ្វើការផ្លាស់ប្តូរពន្ធនេះ តាមវិសោធនកម្មច្បាប់ ក្រោយពេលដាក់ពាក្យបណ្តឹងហើយទៅ នឹងធ្វើឱ្យបាត់បង់ស្ថិរភាពច្បាប់ ។ ដូច្នេះហើយ ចំពោះប្រាក់ប្រដាប់ក្តីនៃបណ្តឹងរដ្ឋប្បវេណី មាត្រា ៥៧៧ បានជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ចាស់ ហើយចំពោះពន្ធ និង ប្រាក់ប្រដាប់ក្តីផ្សេងទៀតដែលត្រូវទទួលបន្ទុកដោយភាគីដែលមានទំនាក់ទំនងនឹងរឿងក្តី ឬ បុគ្គលដែលមានទំនាក់ទំនងនឹងរឿងក្តីដែលបានដាក់ឡើងមុនការអនុវត្តក្រមថ្មីនេះ ដោយអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ហើយមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីនេះ ។

ចំពោះពន្ធ និង ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ សម្រាប់ពាក្យសុំក្នុងដំណើរការពាក់កណ្តាលទី ឬ ពាក្យសុំបន្ទាប់បន្សំនៃរឿងក្តីដែលបានដាក់ឡើងមុនការអនុវត្តក្រមថ្មីនេះ ក៏ត្រូវបកស្រាយដូចនេះដែរ ។

(២) នៅក្នុងនីតិវិធីចាស់ គ្មានរបបនៃប្រាតិភោគលើប្រាក់ប្រដាប់ក្តីទេ ក៏ប៉ុន្តែ ក្រមថ្មីចែងថា ប្រសិនបើដើមចោទពុំមានលំនៅឋាន ទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនៅកម្ពុជាទេ តុលាការត្រូវបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្តី តាមពាក្យសុំរបស់ចុងចម្លើយ ដោយដីកាសម្រេច ហើយក្នុងករណីដែលមានកង្វះនូវប្រាតិភោគនោះ ក៏ដូចគ្នាដែរ (មាត្រា ៦៧ កថាខណ្ឌទី ១) ។

បញ្ញត្តិនៃក្រមថ្មីស្តីពីប្រាតិភោគលើប្រាក់ប្រដាប់ក្តី មិនត្រូវយកមកអនុវត្តឡើយ ចំពោះបណ្តឹងដែលបានដាក់នៅមុនពេលដែលក្រមថ្មីត្រូវបានអនុវត្ត (មាត្រា ៥៧៧ កថាខណ្ឌទី ២) ។ ចំពោះប្រាតិភោគលើ

ប្រាក់ប្រដាប់ក្តី ពេលដែលដាក់ពាក្យបណ្តឹង ពុំមានកាតព្វកិច្ចដាក់ទេ តែក្រោយមក កាតព្វកិច្ចដាក់ប្រាតិភោគនោះកើតមានឡើងដោយសារវិសោធនកម្មច្បាប់ ក្នុងករណីនេះ ប្រសិនបើលើកចោលនូវបណ្តឹងនោះ ដោយសារការមិនផ្តល់ប្រាតិភោគទៅ អាចធ្វើឱ្យខូចដល់ផលប្រយោជន៍របស់ដើមចោទ ដែលមិនអាចគិតទុកជាមុនបាន ។

**៦. វិធានការអន្តរកាលស្តីពីកាលបរិច្ឆេទនៃការជំនុំជម្រះរឿងក្តី**

(១) ក្នុងក្រមថ្មី ការវិនិច្ឆ័យ និង ជំនុំជម្រះបណ្តឹងយ៉ាងសកម្មត្រូវប្រតិបត្តិក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយពុំមានយកទស្សនៈនៃកាលបរិច្ឆេទនៃការជំនុំជម្រះក្នុងនីតិវិធីចាស់មកប្រើទេ ហេតុនេះហើយ ក្រោយការអនុវត្តក្រមថ្មីនេះ មិនអាចបើកកាលបរិច្ឆេទនៃការជំនុំជម្រះនោះបានទេ ។ ក៏ប៉ុន្តែ កាលបរិច្ឆេទនៃការទាញហេតុផល ដោយផ្ទាល់មាត់ និង កាលបរិច្ឆេទនៃការជំនុំជម្រះ មានចំណុចរួមមួយត្រង់ចំណុចស្តីពីកាលបរិច្ឆេទនៃការវិនិច្ឆ័យ និង ជំនុំជម្រះយ៉ាងសកម្ម ហេតុនេះហើយ ទោះបីជាធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទដែលត្រូវបានកំណត់សម្រាប់ការជំនុំជម្រះក៏ដោយ ក៏ពុំមានបញ្ហាអ្វីឡើយ ។

ហេតុដូច្នេះ មាត្រា ៥៧៨ កថាខណ្ឌទី ១ ចែងថា កាលបរិច្ឆេទនៃការជំនុំជម្រះក្តីដែលបានកំណត់ហើយ នៅពេលដែលក្រមថ្មីត្រូវបានអនុវត្ត ត្រូវចាត់ទុកថា បានកំណត់ជាកាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តាមបញ្ញត្តិនៃក្រមថ្មី ។ ហេតុនេះហើយ ក្នុងករណីដែលបានកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះរួចហើយ មិនចាំបាច់ធ្វើការកំណត់ជាថ្មីឡើងវិញ នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ គឺអាចធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទដែលត្រូវបានកំណត់សម្រាប់ការជំនុំជម្រះនោះបាន ។

ម្យ៉ាងទៀត ក្នុងករណីដែលក្រមនេះត្រូវបានអនុវត្តក្រោយការបញ្ចប់នីតិវិធីស៊ើបសួរ តែមុនពេលបើកកាលបរិច្ឆេទនៃការជំនុំជម្រះ តុលាការត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីសិន ទើបអាចបើកកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន (មាត្រា ៥៧៦ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១) ។ ក៏ប៉ុន្តែ ប្រសិនបើបានកំណត់កាលបរិច្ឆេទនៃការជំនុំជម្រះលើកទី ១ ក្រោយការបញ្ចប់នីតិវិធីស៊ើបសួររួចហើយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន មុននឹងចាប់ផ្តើមកាលបរិច្ឆេទនៃការជំនុំជម្រះនោះ ។ ដូច្នេះ ក្នុងករណីនេះ ពុំចាំបាច់កំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ (មាត្រា ៥៧៦ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

**៧. វិធានការអន្តរកាលស្តីពីទណ្ឌកម្មនៅក្នុងការពិនិត្យភស្តុតាង**

ការដាក់ទណ្ឌកម្មទៅលើសាក្សី ជាអាទិ៍ ដែលមានចែងក្នុងក្រមថ្មីនេះ គន្ថីទី ២ ជំពូកទី ៣ (ភស្តុតាង) ត្រូវបានបង្កើត ឡើងដោយយកការអនុវត្តនីតិវិធីនៃការកោះហៅ ដែលត្រូវបានធ្វើឡើងស្របទៅនឹងក្រមថ្មីមកធ្វើជាមូលដ្ឋាន ហេតុនេះហើយ ទំហំនៃការអនុវត្តបញ្ញត្តិទណ្ឌកម្មនោះ ត្រូវបានកម្រិតចំពោះតែសាក្សី

ជាដើម ដែលត្រូវបានសម្រេចដើម្បីធ្វើការពិនិត្យភស្តុតាង ក្រោយការអនុវត្តក្រមនេះប៉ុណ្ណោះ (មាត្រា ៥៧៩ កថាខណ្ឌទី ១) ។

ម្យ៉ាងទៀត ការអនុវត្តប្រតិសកម្មនូវបញ្ញត្តិនៃមាត្រា ១៩៧ (ប្រាក់ពិន័យចំពោះអ្នកប្រកែកនឹងភាពត្រឹមត្រូវក្នុងការធ្វើឯកសារ) ចំពោះករណីដែលមានវិវាទអំពីភាពត្រឹមត្រូវនៃការធ្វើឯកសារ មុនពេលអនុវត្តក្រមថ្មីនេះ គឺជាការមួយមិនសមរម្យទេ ហេតុនេះហើយ ទណ្ឌកម្មដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះករណីដែលភាគី ឬ អ្នកតំណាងដោយអាណត្តិ មានវិវាទស្តីពីភាពត្រឹមត្រូវនៃការធ្វើឯកសារក្រោយការអនុវត្តក្រមនេះតែប៉ុណ្ណោះ (មាត្រា ៥៧៩ កថាខណ្ឌទី ២) ។

៨. វិធានការអន្តរកាលស្តីពីសាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលត្រូវបានប្រកាសឡើង ដោយផ្អែកទៅលើតែការអះអាងរបស់ភាគីម្ខាងដែលមានវត្តមាន ក្នុងករណីដែលភាគីម្ខាងទៀតអវត្តមានក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (សូមមើលគន្លឹទី ២ ជំពូកទី ៥ ផ្នែកទី ៥ (សាលក្រមកំបាំងមុខ)) ។ ចំពោះសាលក្រមកំបាំងមុខអាចដាក់បណ្តឹងទាស់បាន ដើម្បីធ្វើឱ្យនីតិវិធីនៃបណ្តឹងនោះត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតមានឡើង (មាត្រា ២០៨) ក៏ប៉ុន្តែ ក្នុងបណ្តឹងទាស់នេះ ចាំបាច់ត្រូវស្របនឹងល័ក្ខខ័ណ្ឌដូចដែលមានចែងក្នុងមាត្រា ២០៤ ដូចជា ការអវត្តមាននោះកើតមានឡើងដោយសារមូលហេតុដែលមិនអាចព្យាករបាន ជាអាទិ៍ ដែលបានធ្វើឱ្យមិនអាចបង្ហាញខ្លួននៅកាលបរិច្ឆេទ ។

ក្នុងករណីដែលអនុវត្តបញ្ញត្តិស្តីពីសាលក្រមកំបាំងមុខ ទៅតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទោះជាករណីដែលបានអវត្តមាននៅកាលបរិច្ឆេទមុនពេលអនុវត្តក្រមថ្មីនេះក៏ដោយ ប្រសិនបើការប្រកាសសាលក្រមមិនទាន់បានធ្វើនៅឡើយទេ គឺអាចអនុវត្តតាមបញ្ញត្តិស្តីពីសាលក្រមកំបាំងមុខនៃក្រមនេះបាន ។ ក៏ប៉ុន្តែ ប្រសិនបើអនុវត្តជាប្រតិសកម្មនូវបញ្ញត្តិស្តីពីសាលក្រមកំបាំងមុខនេះចំពោះករណីដែលបានអវត្តមាន នៅកាលបរិច្ឆេទមុនពេលអនុវត្តក្រមថ្មីនេះទៅ ភាគីដែលអវត្តមានត្រូវទទួលសាលក្រមកំបាំងមុខ ដោយមិនអាចគិតទុកជាមុនបាន ហើយអាចបាត់បង់ផលប្រយោជន៍ដោយមិនអាចព្យាករបាន ដោយសារការកម្រិតនូវការដាក់បណ្តឹងឧបាស្រ័យដូចខាងលើនេះ ។

ដូច្នេះ មាត្រា ៥៨០ ចែងកម្រិតថា ត្រូវអនុវត្តមាត្រានេះចំពោះករណីដែលដើមចោទ ឬ ចុងចម្លើយបានអវត្តមាន នៅកាលបរិច្ឆេទដែលនីតិវិធីកោះហៅត្រូវបានធ្វើឡើង ក្រោយពេលអនុវត្តក្រមនេះតែប៉ុណ្ណោះ ហើយចំពោះករណីដែលបានអវត្តមាននៅកាលបរិច្ឆេទដែលនីតិវិធីនៃការកោះហៅត្រូវបានធ្វើឡើង មុនពេលអនុវត្តក្រមថ្មី មិនត្រូវអនុវត្តតាមក្រមថ្មីនេះទេ គឺត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

៩. វិធានការអន្តរកាលស្តីពីការអាច ឬ មិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះ

(១) ស្ដីពីការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលធ្វើបណ្ដឹងឧបាស្រ័យ ក្រមថ្មីមានចែងថា អំឡុងពេលនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសាលក្រម ឬ សាលដីកា គឺមាន ១ (មួយ) ខែ ដោយគិតពីថ្ងៃដែលបានទទួលការបញ្ជូននូវលិខិតសាលក្រម ឬ សាលដីកា (មាត្រា ២៦៤ កថាខណ្ឌទី ១, មាត្រា ២៨៦) ហើយស្ដីពីបណ្ដឹងសាទុក្ខ ចាំបាច់ត្រូវមានមូលហេតុដែលកំណត់ដោយច្បាប់ ដើម្បីធ្វើបណ្ដឹងសាទុក្ខ (មាត្រា ២៨៤, មាត្រា ២៨៥) ជាអាទិ៍ ដែលជាការផ្លាស់ប្ដូរច្រើនពីនីតិវិធីចាស់ ។ ហេតុនេះហើយ ចំពោះរឿងក្ដីដែលកំពុងចាត់ការ ប្រសិនបើទទួលស្គាល់នូវការអនុវត្តតាមក្រមថ្មីនេះទាំងអស់ទៅ នឹងអាចបង្កើតជាបញ្ហា ដូចជាធ្វើឱ្យបាត់បង់នូវស្ថិរភាពនៃច្បាប់ ឬ ធ្វើឱ្យមានការបាត់បង់នូវផលប្រយោជន៍របស់ភាគីបាន ។ ដូច្នេះ មាត្រា ៥៨១ ចែងនូវករណីពិសេសនៃគោលការណ៍នៃការអនុវត្តតាមច្បាប់ថ្មីស្ដីពីវិធានការអន្តរកាល (មាត្រា ៥៧២) ដោយមានខ្លឹមសារថា មិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ហើយអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ចំពោះករណីដូចតទៅនេះ ។

(២) ចំពោះសាលក្រម ឬ សាលដីកានៃរឿងក្ដីដែលការជំនុំជម្រះត្រូវបានបញ្ចប់មុនពេលក្រមថ្មីត្រូវបានអនុវត្ត ប្រសិនបើទទួលស្គាល់នូវការអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីស្ដីពីការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទៅ ការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ នឹងត្រូវផ្លាស់ប្ដូរក្រោយការបញ្ចប់នូវការជំនុំជម្រះ ហើយអាចធ្វើឱ្យបាត់បង់ស្ថិរភាពច្បាប់ ព្រមជាមួយគ្នានេះ អាចធ្វើឱ្យមានការជ្រួលច្របល់ដល់នីតិវិធី និង ធ្វើឱ្យខូចផលប្រយោជន៍ដល់ភាគី ដោយមិនអាចគ្រោងទុកជាមុនបាន ។ ដូច្នេះ មាត្រា ៥៨១ កថាខណ្ឌទី ១ មានចែងថា ការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រម ឬ សាលដីកាដែលត្រូវបានប្រកាសឡើង ដោយផ្អែកលើការជំនុំជម្រះដែលបានបញ្ចប់មុនពេលក្រមថ្មីត្រូវបានអនុវត្ត មិនត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីនេះទេ គឺត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

មានន័យលំអិតថា យោងតាមមាត្រា ៥៨១ កថាខណ្ឌទី ១ ចំពោះសាលក្រម ឬ សាលដីកាដែលត្រូវបានប្រកាសឡើងដោយផ្អែកលើការជំនុំជម្រះដែលបានបញ្ចប់មុនពេលក្រមថ្មីត្រូវបានអនុវត្ត មិនត្រូវអនុវត្តបញ្ញត្តិនៃក្រមថ្មី ស្ដីពីការអាច ឬ មិនអាចធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ គឺត្រូវអនុវត្តតាមនីតិវិធីចាស់ ហេតុនេះហើយ ចំពោះសាលក្រម ឬ សាលដីកាដែលមិនអនុញ្ញាតឱ្យប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ក្នុងនីតិវិធីចាស់ ហើយទោះជាក្នុងក្រមថ្មីអាចអនុញ្ញាតឱ្យប្ដឹងឧបាស្រ័យក៏ដោយ ក៏មិនទទួលស្គាល់នូវការប្ដឹងឧបាស្រ័យនេះឡើយ ។ ផ្ទុយទៅវិញ ទោះជាក្នុងក្រមថ្មី គេមិនទទួលស្គាល់នូវការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ក៏ដោយ តែប្រសិនបើនៅក្នុងនីតិវិធីចាស់ គេទទួលស្គាល់ឱ្យធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ គឺអាចធ្វើបណ្ដឹងឧបាស្រ័យទៅ

តុលាការជាន់ខ្ពស់បាន ។ ចំពោះអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ ត្រូវអនុវត្តតាមនីតិវិធីចាស់ ហើយអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងក្រមថ្មីនេះ ពុំមានឥទ្ធិពលទៅលើករណីនេះទេ ដូច្នេះហើយ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលបានធ្វើឡើងក្រោយការកន្លងផុតទៅនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងនីតិវិធីចាស់នោះ គឺត្រូវចាត់ទុកថា ខុសច្បាប់ ដោយសារការកន្លងផុតទៅនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

ផ្ទុយទៅវិញ ក្នុងករណីដែលការជំនុំជម្រះបានបញ្ចប់ក្រោយពេលក្រមថ្មីត្រូវបានអនុវត្តវិញ ជាគោលការណ៍ការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នេះ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីនេះ (មាត្រា ៥៨១ កថាខណ្ឌទី ១, មាត្រា ៥៧២) ក៏ប៉ុន្តែ ដូចដែលបានរៀបរាប់ខាងក្រោមនេះ ចំពោះសាលដីកាមួយចំនួន ដូចជាសាលដីកានៃសាលាឧទ្ធរណ៍ដែលត្រូវតុលាការកំពូលបញ្ជូនត្រឡប់មកវិញ មុនពេលក្រមថ្មីត្រូវបានអនុវត្ត អាចមានករណីដែលត្រូវអនុវត្តតាមនីតិវិធីចាស់ដែរ (មាត្រា ៥៨១ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។

(៣) ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានប្រកាសជាថ្មីចំពោះរឿងក្តីដែលទទួលការបញ្ជូនត្រឡប់មកវិញពីតុលាការកំពូល មុនពេលក្រមថ្មីត្រូវបានអនុវត្ត (មាត្រា ៥៨១ កថាខណ្ឌទី ២) តាមទំនាក់ទំនងទៅនឹងរបបប្តឹងសាទុក្ខនៅក្នុងនីតិវិធីចាស់ ការទទួលស្គាល់នូវចំណងនៃសាលដីកានៃរឿងក្តីនេះ ដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈ មិនត្រឹមត្រូវទេ (មាត្រា ៥៨៣, មាត្រា ៥៨២ កថាខណ្ឌទី ២) ដូច្នេះហើយ ទោះបីជាការជំនុំជម្រះដើម្បីចេញសាលដីកាសាជាថ្មីនៃសាលាឧទ្ធរណ៍ ត្រូវបានបញ្ចប់មុន ឬ ក្រោយពេលក្រមថ្មីត្រូវបានអនុវត្តក៏ដោយ ក៏ត្រូវជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ដោយចាំបាច់ត្រូវរក្សាដដែលនូវការដាក់ពាក្យបណ្តឹងឧបាស្រ័យតាមនីតិវិធីចាស់ដែរ ។

ដូច្នេះ ស្តីពីការអាច ឬ មិនអាចប្តឹងសាទុក្ខចំពោះសាលដីកានេះ និង អំឡុងពេលនៃការប្តឹងសាទុក្ខនេះ យោងតាមមាត្រា ៥៨១ កថាខណ្ឌទី ២ គឺមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីទេ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ ម្យ៉ាងទៀត ចំពោះបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ក៏មានបញ្ញត្តិពិសេសដែលមានគោលគំនិត ដូចគ្នានេះដែរ ។

(៤) ក្នុងរឿងក្តីដែលតុលាការកំពូលសម្រេចទុកជាមោឃៈនូវសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនពេលក្រមថ្មីត្រូវបានអនុវត្ត ហើយបានចេញសាលដីកាបញ្ជូនរឿងក្តីនោះទៅសាលាឧទ្ធរណ៍វិញ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចសាជាថ្មី តាមទំនាក់ទំនងទៅនឹងរបបប្តឹងសាទុក្ខក្នុងនីតិវិធីចាស់ ការទទួលស្គាល់នូវចំណងនៃសាលដីកាទុកជាមោឃៈដែលសម្រេចដោយតុលាការកំពូលក្នុងរឿងក្តីនោះ គឺមិនត្រឹមត្រូវទេ ដូចសាលដីកាដែលបានលើកឡើងនៅចំណុច (៣) ខាងលើនេះ (សាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មីឡើងវិញ អំពីរឿងក្តីដែលតុលាការកំពូលបាន

សម្រេចបញ្ជូនត្រឡប់វិញនៅមុនពេលដែលក្រមថ្មីត្រូវបានអនុវត្ត) ដែរ (មាត្រា ៥៨៣, មាត្រា ៥៨២ កថាខណ្ឌទី ៣) ដូច្នេះហើយ ចំពោះបណ្តឹងឧបាស្រ័យ ទោះជាការជំនុំជម្រះដើម្បីសម្រេចសាលដីកាសាជាថ្មីនៃសាលាឧទ្ធរណ៍ ត្រូវបានបញ្ចប់មុន ឬ ក្រោយពេលក្រមថ្មីត្រូវបានអនុវត្តក៏ដោយ ក៏ត្រូវជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ដោយចាំបាច់ត្រូវរក្សាដដែលនូវការដាក់ពាក្យបណ្តឹងឧបាស្រ័យតាមនីតិវិធីចាស់ ។

ដូច្នេះ ស្តីពីការអាច ឬ មិនអាចប្តឹងសាទុក្ខចំពោះសាលដីកានេះ និង អំឡុងពេលនៃការប្តឹងសាទុក្ខនេះ យោងតាមមាត្រា ៥៨១ កថាខណ្ឌទី ៣ គឺមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មីទេ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ ចំពោះបណ្តឹងសាទុក្ខចំពោះសាលដីកានេះ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនោះ ក៏មានបញ្ញត្តិពិសេសដែលមានគោលគំនិតដូចគ្នានេះដែរ (មាត្រា ៥៨២ កថាខណ្ឌទី ៣) ។

(៥) ចំពោះសេចក្តីសម្រេច ក្រៅពីសាលក្រម និង សាលដីកា ពុំមានទស្សនៈនៃការបញ្ចប់នៃការជំនុំជម្រះដូចករណីនៃសាលក្រម និង សាលដីកាទេ ហេតុនេះហើយ មាត្រា ៥៨១ កថាខណ្ឌទី ៤ បានយកពេលវេលានៃការជូនដំណឹងដែលជាពេលវេលាដែលសេចក្តីសម្រេចក្រៅពីសាលក្រម និង សាលដីកាបង្កើតអានុភាពចំពោះខាងក្រៅ មកធ្វើជាមូលដ្ឋាន ហើយស្តីពីការអាច ឬ មិនអាចប្តឹងឧបាស្រ័យវិញ ព្រមទាំងអំឡុងពេលដែលអាចធ្វើបណ្តឹងឧបាស្រ័យ ចំពោះសេចក្តីសម្រេចក្រៅពីសាលក្រម និង សាលដីកាដែលត្រូវបានជូនដំណឹងមុនពេលក្រមថ្មីត្រូវបានអនុវត្ត គឺមិនត្រូវអនុវត្ត តាមបញ្ញត្តិនៃក្រមថ្មីទេ ហើយត្រូវអនុវត្តតាមនីតិវិធីចាស់ ។

មានន័យលំអិតថា ចំពោះសេចក្តីសម្រេច ក្រៅពីសាលក្រម និង សាលដីកា ដែលត្រូវបានជូនដំណឹងមុនពេលក្រមថ្មីត្រូវបានអនុវត្ត មិនត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ស្តីពីការអាច ឬ មិនអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង អំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ គឺត្រូវអនុវត្តតាមនីតិវិធីចាស់ ហេតុនេះហើយ ចំពោះសេចក្តីសម្រេចដែលមិនអនុញ្ញាតឱ្យប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តាមនីតិវិធីចាស់ ទោះបីជាសេចក្តីសម្រេចនោះ អាចអនុញ្ញាតឱ្យប្តឹងឧបាស្រ័យតាមបញ្ញត្តិនៃក្រមថ្មីក៏ដោយ ក៏មិនទទួលស្គាល់នូវការប្តឹងឧបាស្រ័យនេះឡើយ ។ ផ្ទុយទៅវិញ ទោះបីជាសេចក្តីសម្រេចដែលគេមិនត្រូវបានទទួលស្គាល់នូវការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់តាមបញ្ញត្តិនៃក្រមថ្មីក៏ដោយ តែប្រសិនបើនីតិវិធីចាស់ទទួលស្គាល់ឱ្យធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់វិញ គឺអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ។ ស្តីពីអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ក៏ត្រូវអនុវត្តតាមនីតិវិធីចាស់ដែរ ហើយអំឡុងពេលនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងក្រមថ្មីនេះ ពុំមានឥទ្ធិពលទៅលើករណីនេះទេ ដូច្នេះហើយ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលបានធ្វើឡើងក្រោយការកន្លងផុតនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានចែងក្នុងនីតិវិធីចាស់នោះ គឺត្រូវចាត់ទុកថា ខុសច្បាប់ ដោយសារការកន្លងផុតនៃអំឡុងពេលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។

## ១០.វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ

(១) បណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលត្រូវបានសម្រេច ដោយផ្អែកលើការដេញដោល ដែលបានចប់នៅមុនពេលដែលក្រមថ្មីត្រូវបានអនុវត្ត ត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក (មាត្រា ៥៨២ កថាខណ្ឌទី ១) ។ ហេតុនេះហើយ ស្តីពីការប្តឹងសាទុកចំពោះសាលដីកានេះ មិនត្រូវអនុវត្តបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនៃក្រមថ្មីទេ ដូច្នេះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។ មូលហេតុដែលត្រូវមានវិធានការអន្តរកាលដូចនេះគឺមានដូចតទៅ :

ស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ក្រមថ្មីមានចែងថា អង្គហេតុដែលបានចូលជាស្ថាពរ ដោយត្រឹមត្រូវតាមច្បាប់ ដោយតុលាការដើម នឹងចងតុលាការនៃបណ្តឹងសាទុក្ខ (មាត្រា ២៩៦ កថាខណ្ឌទី ១) ហើយការវិនិច្ឆ័យបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់តែម្តង ហើយមានការកែប្រែពីនីតិវិធីចាស់ជាច្រើនចំណុច ដែលមានដូចជា ការកំណត់ដោយច្បាប់អំពីវិធីដាក់ពាក្យបណ្តឹងឧបាស្រ័យ ឬចំណុចដែលសរសេរនៅក្នុងឯកសារបញ្ជាក់ អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ជាដើម ។

ហេតុនេះហើយ ប្រសិនបើអនុវត្តគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ នេះ ហើយអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ក្រោយពេលបណ្តឹងសាទុក្ខត្រូវបានចាត់ការ នឹងធ្វើឱ្យមានការផ្លាស់ប្តូរនូវមូលដ្ឋាននៃទម្រង់នៃនីតិវិធីជំនុំជម្រះបណ្តឹងសាទុក្ខ នៅពេលដែលនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនោះកំពុងតែមានដំណើរការ ហើយដែលជាកត្តាមួយធ្វើឱ្យមានការបាត់បង់នូវស្ថិរភាពនៃនីតិវិធី ហើយអាចនាំឱ្យមានការច្របូកច្របល់ដល់នីតិវិធីនោះ ។ មូលដ្ឋាននៃពេលវេលានៃការអនុវត្តក្រមថ្មីមានដូចជា ពេលបញ្ចប់ការជំនុំជម្រះ និង ពេលប្រកាសសាលដីកា ក៏ប៉ុន្តែ ក្នុងករណីដែលយកកាលបរិច្ឆេទនៃការប្រកាសសាលដីកា មកធ្វើជាមូលដ្ឋាននៃពេលវេលា ទោះជារឿងក្តីដែលត្រូវបានបញ្ចប់ជំនុំជម្រះពេលដូចគ្នាក៏ដោយ តែការប្រកាសសាលដីកានោះត្រូវធ្វើឡើងមុន ឬ ក្រោយការអនុវត្តក្រមថ្មី នឹងធ្វើឱ្យបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខមានភាពខុសគ្នា ជាអាទិ៍ ដែលជាបញ្ហា ។ ដូច្នេះ មាត្រា ៥៨២ កថាខណ្ឌទី ១ បានជ្រើសរើសយកពេលបញ្ចប់ការជំនុំជម្រះនៅតុលាការនៃបណ្តឹងសាលាឧទ្ធរណ៍ មកធ្វើជាមូលដ្ឋាននៃពេលវេលា ហេតុនេះហើយ ក្នុងករណីដែលមានបណ្តឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចដោយផ្អែកទៅលើការវិនិច្ឆ័យដែលត្រូវបានបញ្ចប់មុនពេលអនុវត្តក្រមថ្មី បណ្តឹងសាទុក្ខនោះ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនោះត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ។

(២) ផ្ទុយទៅវិញ ចំពោះបណ្តឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចដោយផ្អែកទៅលើការវិនិច្ឆ័យ ដែលត្រូវបានបញ្ចប់ក្រោយពេលអនុវត្តក្រមថ្មី ពុំមានបញ្ញត្តិពិសេសទេ ហេតុនេះហើយ ដោយយោងតាមគោលការណ៍នៃវិធានការអន្តរកាលនៃមាត្រា ៥៧២ ត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ។

ក៏ប៉ុន្តែ ចំពោះបណ្តឹងសាទុក្ខលើកទី ២ អាចមានករណីដែលត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ដូចដែលមានរៀបរាប់តទៅនេះ ( មាត្រា ៥៨២ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣) ។

(៣) ក្នុងករណីដែលមានបណ្តឹងសាទុក្ខ ចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចសាជាថ្មី អំពីរឿងក្តីដែលទទួលនូវការបញ្ជូនត្រឡប់មកវិញ នៅមុនពេលក្រមថ្មីត្រូវបានអនុវត្ត ដោយតុលាការកំពូល មិនត្រូវអនុវត្តបញ្ញត្តិស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនៃក្រមថ្មីនេះ ចំពោះករណីនេះទេ ( មាត្រា ៥៨២ កថាខណ្ឌទី ២) ។ មូលហេតុដែលមានបញ្ញត្តិស្តីពីវិធានការអន្តរកាលនេះ មានដូចតទៅ :

ជាបឋម កិច្ចការស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខសព្វថ្ងៃនេះ គឺមានដូចតទៅ ។ មានន័យថា ចំពោះបណ្តឹងសាទុក្ខលើកទី ១ ជាគោលការណ៍ (លើកលែងតែករណីពិសេស គឺ ករណីនៃការសម្រេចសេចក្តីស្តីពីកំហុសនៃសមត្ថកិច្ច និង ស្តីពីវិវាទអំពីប្រាក់ប្រដាប់ក្តី) តុលាការកំពូលមិនអាចសម្រេចទុកជាមោឃៈ ហើយវិនិច្ឆ័យដោយខ្លួនឯងបានឡើយ ដូច្នេះក្នុងករណីដែលយល់ឃើញថា មានកំហុសក្នុងការវិនិច្ឆ័យនៃសាលដីកាដើម តុលាការកំពូលត្រូវសម្រេចទុកជាមោឃៈនូវសាលដីកាដើមនោះ ហើយបញ្ជូនរឿងក្តីនោះ ទៅសាលាឧទ្ធរណ៍វិញ ។ ក៏ប៉ុន្តែ នៅក្នុងនីតិវិធីចាស់ ពុំមានបញ្ញត្តិណាមួយដែលចងនូវការវិនិច្ឆ័យរបស់តុលាការកំពូល ចំពោះសាលាឧទ្ធរណ៍ ដូចដែលមានចែងក្នុងក្រមថ្មី មាត្រា ២៩៩ កថាខណ្ឌទី ២ ទេ ។ ដូច្នេះ ការវិនិច្ឆ័យនៃតុលាការកំពូល ពុំមានអ្វីចងសាលាឧទ្ធរណ៍ដែលជាតុលាការវិនិច្ឆ័យរឿងក្តីដែលត្រូវបានបញ្ជូនត្រឡប់មកវិញ តាមផ្លូវច្បាប់ទេ ហេតុនេះហើយ សាលាឧទ្ធរណ៍អាចធ្វើការសម្រេចសេចក្តីដូចមុនម្តងទៀត ដោយមិនធ្វើតាមការវិនិច្ឆ័យរបស់តុលាការកំពូលបាន ។ ចំពោះបញ្ហានេះ មានករណីច្រើនដែលភាគីនឹងធ្វើបណ្តឹងសាទុក្ខជាលើកទី ២ ទៀត ហើយចំពោះការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខជាលើកទី ២ តុលាការកំពូលមានសិទ្ធិធ្វើការវិនិច្ឆ័យទៅលើអង្គហេតុផង ទៅលើអង្គច្បាប់ផង ហើយនឹងធ្វើនីតិវិធីសាជាថ្មីឡើងវិញទាំងអស់ តាំងពីការពិនិត្យភស្តុតាងឡើងវិញ ដោយខ្លួនឯង ។ ម្យ៉ាងទៀត ប្រសិនបើយោងតាមរបបនេះ ក្នុងករណីដែលមានការមិនពេញចិត្តនឹងលទ្ធផលនៃសាលដីការបស់សាលាឧទ្ធរណ៍ ដែលទទួលការបញ្ជូនរឿងក្តីមកវិញ ពីតុលាការកំពូល ភាគីនឹងធ្វើបណ្តឹងសាទុក្ខជាលើកទី ២ ទៀត ដោយរំពឹងថា តុលាការកំពូលនឹងធ្វើនីតិវិធីសាជាថ្មីវិញ ដូច្នេះ ជាលទ្ធផល មានករណីជាច្រើន ដែលភាគីណាម្ខាងបានប្តឹងសាទុក្ខពីរដងដូចស្ថានភាពសព្វថ្ងៃនេះ ហេតុនេះហើយ មានករណីជាច្រើនដែលគេប្តឹងសាទុក្ខទៅតុលាការកំពូល ដើម្បីរង់ចាំឱ្យតុលាការកំពូលធ្វើការវិនិច្ឆ័យទៅលើអង្គហេតុម្តងទៀត ។

តាមកិច្ចការទាំងអស់ដែលបានពន្យល់ខាងលើនេះ យើងយល់ឃើញថា តាមការជាក់ស្តែង ការវិនិច្ឆ័យបណ្តឹងសាទុក្ខលើកទី ១ គឺជាការវិនិច្ឆ័យទៅលើអង្គច្បាប់ ហើយការវិនិច្ឆ័យបណ្តឹងសាទុក្ខលើកទី ២ គឺជាការវិនិច្ឆ័យទៅលើអង្គហេតុ ហើយចំពោះសាលដីកាសម្រេចទុកជាមោឃៈនូវសាលដីកាសាលាឧទ្ធរណ៍ ក្នុងការវិនិច្ឆ័យបណ្តឹងសាទុក្ខលើកទី ១ គេមិនទទួលស្គាល់នូវចំណងនៃសាលដីកាសម្រេចទុកជាមោឃៈនេះទេ ហេតុនេះហើយ

តួនាទីនៃការវិនិច្ឆ័យទៅលើអង្គច្បាប់នៃបណ្តឹងសាទុក្ខទី ១ ដែលត្រូវធ្វើឱ្យទៅជាស្ថាពរនូវការវិនិច្ឆ័យតាមផ្លូវច្បាប់ទៅលើរឿងក្តីនេះ តាមរយៈសាលដីកានៃការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខលើកទី ១ ហើយធ្វើការបញ្ជូនត្រឡប់វិញនូវបណ្តឹងនោះទៅឱ្យសាលាឧទ្ធរណ៍ ដើម្បីឱ្យធ្វើការវិនិច្ឆ័យ ក្នុងកម្រិតនៃការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខលើកទី ១ ពុំមានដំណើរការល្អទេ តាមភាពជាក់ស្តែង ។

ផ្ទុយទៅវិញ ក្រមនីតិវិធីរដ្ឋប្បវេណីលើកនេះ បានឱ្យតួនាទីទៅលើការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខ ជាការវិនិច្ឆ័យទៅលើអង្គច្បាប់ទាំងស្រុងតែម្តង ហើយការទទួលស្គាល់អង្គហេតុ គឺជាសិទ្ធិរបស់តុលាការវិនិច្ឆ័យអង្គហេតុ ដូច្នេះ អង្គហេតុដែលបានចូលជាស្ថាពរដោយត្រឹមត្រូវតាមច្បាប់នោះ ត្រូវចងតុលាការនៃបណ្តឹងសាទុក្ខ ( មាត្រា ២៩៦) ហើយដើម្បីធ្វើបណ្តឹងសាទុក្ខ ចាំបាច់ត្រូវមានមូលហេតុនៃបណ្តឹងសាទុក្ខ ព្រមជាមួយគ្នានេះ បានកម្រិតមូលហេតុនៃបណ្តឹងសាទុក្ខនេះ ត្រឹមតែភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ ខុសធ្ងន់នឹងនីតិវិធីប៉ុណ្ណោះ ( មាត្រា ២៨៤, មាត្រា ២៨៥) ហើយការវិនិច្ឆ័យទៅលើអង្គហេតុ និងអង្គច្បាប់ដែលជាមូលហេតុនៃការបដិសេធរបស់តុលាការនៃបណ្តឹងសាទុក្ខ ត្រូវចងតុលាការដែលទទួលការបញ្ជូនបណ្តឹងនោះមកវិញ ( មាត្រា ២៩៩ កថាខណ្ឌទី ២) ។

ហេតុនេះហើយ វិសោធនកម្មលើកនេះ គឺជាវិសោធនកម្មមួយដ៏ធំពាក់ព័ន្ធទៅនឹងទម្រង់ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខ ហើយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើរបៀបធ្វើការវិនិច្ឆ័យនៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ព្រមទាំងទៅលើសកម្មភាពបណ្តឹងរបស់ភាគី ។ ម្យ៉ាងទៀត សម្រាប់ភាគី ប្រសិនបើមុនពេលបញ្ចប់ការដេញដោលក្នុងបណ្តឹងឧទ្ធរណ៍ គេអាចធ្វើសកម្មភាពបណ្តឹងរបស់ខ្លួន ដោយគិតដល់ចំណុចវិសោធនកម្មនេះ ។ ប៉ុន្តែប្រសិនបើការកែទម្រង់បណ្តឹងសាទុក្ខនេះត្រូវបានធ្វើឡើងក្រោយការបញ្ចប់នៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៅពេលនោះ ភាគីមិនអាចចាត់ចែងដោយគិតពិចារណានូវមូលដ្ឋាននៃក្រមថ្មីនេះបានទេ ហើយភាគីអាចយកត្រឹមតែមូលហេតុនៃការខុសនឹងច្បាប់ ឬ បទដ្ឋានគតិយុត្តប៉ុណ្ណោះ មកធ្វើជាមូលហេតុនៃការប្តឹងឧបាស្រ័យ ហើយមិនអាចប្តឹងឧបាស្រ័យ ដោយយកការទទួលស្គាល់អង្គហេតុមកធ្វើជាមូលហេតុបានឡើយ ជាដើម ។ ដូច្នេះ តាមរយៈការអនុវត្តក្រមថ្មីក្រោយពេលនោះ ភាគីអាចទទួលនូវការខូចផលប្រយោជន៍ដោយមិនអាចគ្រោងទុកជាមុនបាន ។

ដូច្នេះ ចំពោះបណ្តឹងសាទុក្ខចំពោះសាលដីការបស់តុលាការបណ្តឹងឧទ្ធរណ៍ ដែលបានសម្រេចឡើងដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនពេលអនុវត្តក្រមថ្មី មាត្រា ៥៨២ កថាខណ្ឌទី ២ បានជ្រើសរើសយកគោលការណ៍នៃការអនុវត្តតាមច្បាប់ចាស់ ចំពោះនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ហើយអនុលោមតាមនីតិវិធីចាស់ ចំពោះបញ្ហានេះ ។

( ៤) ចំពោះរឿងក្តីដែលតុលាការកំពូលបានសម្រេចទុកជាមោឃៈនូវសាលដីកា ដែលសាលាឧទ្ធរណ៍បានសម្រេចដោយផ្អែកលើការដេញដោលដែលត្រូវបានបញ្ចប់មុនការអនុវត្តក្រមថ្មី ហើយដែលតុលាការកំពូលបាន

ចេញសាលដីកាបញ្ជូនរឿងក្តីនោះត្រឡប់ទៅសាលាឧទ្ធរណ៍វិញ (ក្រោយពេលបណ្តឹងសាទុក្ខ ត្រូវបានដាក់តាមនីតិវិធីចាស់ និង តុលាការកំពូលបានវិនិច្ឆ័យតាមនីតិវិធីបណ្តឹងសាទុក្ខចាស់) ក្នុងករណីដែលមានបណ្តឹងសាទុក្ខចំពោះសាលដីកាដែលសាលាឧទ្ធរណ៍បានសម្រេចជាថ្មី ស្តីពីបណ្តឹងសាទុក្ខនោះ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខនោះ ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក (មាត្រា ៥៨២ កថាខណ្ឌទី ៣) ។ ដូច្នេះហើយ ចំពោះករណីនេះ ត្រូវអនុវត្តតាមនីតិវិធីចាស់ ដោយពុំអនុវត្តតាមនីតិវិធីថ្មីទេ ។

មូលហេតុដែលមានវិធានការអន្តរកាលបែបនេះ គឺ មានដូចដែលបានពន្យល់នៅក្នុង (3) ខាងលើនេះដែរ ។ មានន័យថា នៅក្នុងនីតិវិធីចាស់ ពេលដែលធ្វើការវិនិច្ឆ័យទៅលើបណ្តឹងសាទុក្ខជាលើកទី ២ តុលាការកំពូលមានសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យជាថ្មីឡើងវិញ ទាំងលើអង្គហេតុ ទាំងលើអង្គច្បាប់ ហើយតាមកិច្ចការជាក់ស្តែង នឹងធ្វើនីតិវិធីទាំងអស់ឡើងវិញ ព្រមទាំងពិនិត្យភស្តុតាងដោយខ្លួនឯងឡើងវិញ ។ ប្រសិនបើអនុវត្តក្រមថ្មី ទៅលើការវិនិច្ឆ័យនៃបណ្តឹងសាទុក្ខនោះទៅ តុលាការកំពូលអាចធ្វើការវិនិច្ឆ័យតែចំពោះអង្គច្បាប់ប៉ុណ្ណោះ ដូច្នេះហើយ ទម្រង់មូលដ្ឋាននៃនីតិវិធីចុងក្រោយ ក្នុងចំណោមនីតិវិធីនានានៃករណីនេះ នឹងមានការផ្លាស់ប្តូរ ហើយការនេះអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពច្បាប់ ហើយនឹងធ្វើឱ្យខូចដល់សេចក្តីសង្ឃឹមរបស់ភាគី ។

**១១.វិធានការអន្តរកាលស្តីពីចំណងនៃសាលដីការបស់តុលាការកំពូលដែលទុកជាមោឃៈនូវសាលដីកាដើម**

មាត្រា ៥៨២ ចែងអំពីករណីដែលត្រូវធ្វើតាមនីតិវិធីចាស់ ដោយមិនអនុវត្តតាមបញ្ញត្តិនៃក្រមថ្មី ចំពោះនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ។ ក្នុងករណីដែលនីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ ត្រូវធ្វើតាមនីតិវិធីចាស់ ក្រោមនីតិវិធីនេះ ចាំបាច់ត្រូវចែងថា មិនត្រូវអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) ស្តីពីអានុភាពនៃចំណងនៃសាលដីកា បដិសេធចោល ដោយសារ នៅក្នុងនីតិវិធីចាស់ គេមិនទទួលស្គាល់អានុភាពនៃចំណងនៃសាលដីកាដែលតុលាការកំពូលបានទុកជាមោឃៈនូវសាលដីកានៃសាលាឧទ្ធរណ៍ ។

ហេតុដូច្នេះ មាត្រា ៥៨៣ ចែងថា ក្នុងករណីដែលបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខត្រូវអនុលោមទៅតាមកិច្ចការដែលបានធ្វើពីមុនមក ដោយយោងតាមបញ្ញត្តិនៃមាត្រា ៥៨២ (វិធានការអន្តរកាលស្តីពីបណ្តឹងសាទុក្ខ និង នីតិវិធីនៃការវិនិច្ឆ័យបណ្តឹងសាទុក្ខ) ប្រសិនបើតុលាការកំពូលសម្រេចទុកជាមោឃៈនូវសាលដីកាដើម ហើយបញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍វិញ ឬ ផ្ទេរទៅតុលាការផ្សេង បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ២៩៩ (ការបដិសេធចោល ហើយបញ្ជូនត្រឡប់ទៅតុលាការដើមវិញ ជាអាទិ៍) មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលដីកានោះ ។

**១២.វិធានការអន្តរកាលស្តីពីការជំនុំជម្រះសាជាថ្មី**

ការជំនុំជម្រះសាជាថ្មី ធ្វើឱ្យបាត់បង់អានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ ហេតុនេះហើយ ប្រសិនបើជ្រើសរើសយកគោលការណ៍អនុវត្តតាមច្បាប់ថ្មី ចំពោះការអនុវត្តបញ្ញត្តិស្តីពីការជំនុំជម្រះសាជាថ្មី ហើយទទួល

ស្គាល់នូវការជំនុំជម្រះសាជាថ្មីដែលគេមិនទទួលស្គាល់នៅក្នុងនីតិវិធីចាស់ មានន័យថា បានផ្លាស់ប្តូរនៅពេលក្រោយ នូវអានុភាពនៃសាលក្រម ឬ សាលដីកាដែលចូលស្ថាពរ តាមនីតិវិធីចាស់ ហើយដែលអាចធ្វើឱ្យបាត់បង់នូវស្ថិរភាពច្បាប់ ។

ហេតុដូច្នេះ ការជំនុំជម្រះសាជាថ្មី អាចត្រូវបានទទួលស្គាល់ ចំពោះតែការជំនុំជម្រះដែលបានចូលជាស្ថាពរក្រោយការអនុវត្តក្រមថ្មីប៉ុណ្ណោះ ( មាត្រា ៥៨៤) ។

# ជំពូកទី ៤ អវសានប្បញ្ញត្តិ

១. កាលបរិច្ឆេទនៃការអនុវត្ត

ក្រមថ្មីនេះ ត្រូវផ្សព្វផ្សាយរយៈពេល ១ ឆ្នាំ ក្រោយពីថ្ងៃចូលជាធរមាន ទើបអនុវត្ត (មាត្រា ៥៨៧) ។ ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តប្រកាសឱ្យប្រើ នឹងត្រូវចូលជាធរមាន ១០ ថ្ងៃគត់ នៅភ្នំពេញ ក្រោយថ្ងៃឡាយព្រះហស្តលេខា ហើយ ២០ ថ្ងៃគត់ នៅទូទាំងប្រទេស ក្រោយថ្ងៃឡាយព្រះហស្តលេខា (ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ៩៣ កថាខណ្ឌទី ១) ហេតុនេះហើយ ក្រមថ្មីនេះនឹងត្រូវអនុវត្ត ១ ឆ្នាំ និង ១០ ថ្ងៃក្រោយ នៅភ្នំពេញ ហើយ ១ ឆ្នាំ និង ២០ ថ្ងៃក្រោយ នៅទូទាំងប្រទេស ដោយគណនាពីថ្ងៃដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខា ។

ការទុករយៈពេល ១ ឆ្នាំ សម្រាប់ធ្វើការផ្សព្វផ្សាយក្រមថ្មី ក្រោយពេលចូលជាធរមាននេះ មានមូលហេតុដូចតទៅ :

ជាទូទៅ ពេលច្បាប់ណាមួយចូលជាធរមានទៅ អានុភាពនៃច្បាប់នោះនឹងកើតមានឡើងជាក់ស្តែង ហើយអាចអនុវត្តភ្លាមៗ ។ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេស ក្នុងរយៈពេល ២០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញ មាត្រា ៩៣ វាក្យខណ្ឌទី ១) ។ ប៉ុន្តែ បើច្បាប់បានចែងថា ជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាម នៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ (រដ្ឋធម្មនុញ្ញ មាត្រា ៩៣ វាក្យខណ្ឌទី ២) ។

ដូច្នេះហើយ ក្រមថ្មីនេះក៏ដូចគ្នាដែរ គឺក្រោយការអនុម័តរបស់សភាហើយ ព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខា ហើយយ៉ាងយឺតបំផុតក៏ក្រមនេះនឹងមានអានុភាពជាក់ស្តែង ២០ ថ្ងៃក្រោយពីថ្ងៃដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាដែរ ។ ក៏ប៉ុន្តែ ក្រមថ្មីនេះ មានការផ្លាស់ប្តូរនូវនីតិវិធីយ៉ាងច្រើនពីនីតិវិធីនៃបណ្តឹងរដ្ឋប្បវេណីចាស់ និង នីតិវិធីនៃការអនុវត្តដោយបង្ខំចាស់ ជាអាទិ៍ ហេតុនេះហើយ មុននឹងចាប់ផ្តើមអនុវត្ត ចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយ ឱ្យជ្រួតជ្រាបដល់ប្រជាជនគ្រប់ៗរូប ម្យ៉ាងទៀតចាំបាច់ត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំត្រៀមនូវរបបពាក់ព័ន្ធ នឹងតុលាការ អាជ្ញាសាលា ជាដើម ដែលជាអ្នកចាំបាច់ត្រូវដឹកនាំនីតិវិធីនៃក្រមនេះឱ្យមានភាពរមូតនោះផងដែរ ដូច្នេះ ការផ្តល់អានុភាពជាក់ស្តែងនៅក្នុងពេលវេលាដ៏ខ្លី មិនសមរម្យទេ គឺត្រូវទុកពេលវេលាវែងមួយ ដើម្បីធ្វើការផ្សព្វផ្សាយ និង រៀបចំ ទើបអនុវត្តទៅមានប្រសិទ្ធភាពល្អ ។

ហេតុដូច្នេះ ដោយពិនិត្យមើលតាមស្ថានភាពទាំងនេះហើយ បានជាមាត្រា ៥៨៧ បានកំណត់ថា ក្រោយពីថ្ងៃចូលជាធរមាន ត្រូវធ្វើការផ្សព្វផ្សាយរយៈពេល ១ ឆ្នាំ ទើបអនុវត្តក្រមនេះ ។

## ២. ការធ្វើនិរាករណ៍នូវច្បាប់ដទៃទៀត ជាអាទិ៍

(១) ក្រមថ្មីនេះ ត្រូវបានតាក់តែងឡើងជាច្បាប់មូលដ្ឋាន ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណី រួមទាំងការអនុវត្តដោយបង្ខំ និង ការរក្សាការពារផ្នែករដ្ឋប្បវេណីផងដែរ (សូមមើលមាត្រា ១) ។ ហេតុនេះហើយ ច្បាប់ស្ដីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី និង ច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលជាច្បាប់ទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីកន្លងមក ត្រូវបាត់បង់អានុភាព ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត (មាត្រា ៥៨៨ កថាខណ្ឌទី ១) ។

(២) ក្នុងករណីដែលក្នុងច្បាប់ផ្សេងណាមួយ មានបញ្ញត្តិដែលផ្ទុយនឹង ឬ ប៉ះពាល់ដល់បញ្ញត្តិនៃក្រមថ្មីនេះ បញ្ញត្តិនៃក្រមថ្មីត្រូវមានអាទិភាពក្នុងការអនុវត្ត ហេតុដូច្នេះ បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលផ្ទុយនឹងបញ្ញត្តិនៃក្រមថ្មី ត្រូវចាត់ទុកថា គ្មានអានុភាព ត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ (មាត្រា ៥៨៨ កថាខណ្ឌទី ២) ។